# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## សង្ឃាទិសេស១៣ អនិយត២

## និស្សគ្គិយ៣០

## ភាគ ២_៣

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## សង្ឃាទិសេស១៣ អនិយត២

## និស្សគ្គិយ៣០

## ភាគ ២_៣

ឈ្មោះសៀវភៅ **សមន្តប្បាសាទិកា អដ្ឋកថាវិនយបិដក**

**ភាគ ២_៣**

ប្រែដោយ **ភិក្ខុ អគ្គធីរោ គង់ សុមិត្ត**

ប្រែផ្ទៀងផ្ទាត់ដោយ **ភិក្ខុ-សាមណេរ វត្តនិគ្រោធវ័ន“គល់ទទឹង”**

| | |
|---|---|
| ភិក្ខុ ភួង សុវណ្ណ | ភិក្ខុ តុន ប៊ុនសាយ |
| ភិក្ខុ ឈឹម ហ៊ាន | សាមណេរ នៅ ហៃឡុន |
| ភិក្ខុ សឹម ស៊ីសាមុត | សាមណេរ គល់ សុភាព |
| ភិក្ខុ ភុល ណារិន | សាមណេរ សឿន សាន |

កាលបរិច្ឆេទ ព.ស. ២៥៥៣

ស្ថានទីធ្វើ ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន

“គល់ទទឹង” ភូមិកោះក្របី ឃុំព្រែកថ្មី ស្រុក

កៀនស្វាយ ខេត្តកណ្ដាល

ISBN 9789996306051



ភិក្ខុ អគ្គធីរោ គង់~សុមិត្ត

# ជីវប្រវត្តិសង្ខេប

ភិក្ខុ គង់-សុមិត្ត អាយុ៣៩ឆ្នាំ គង់នៅវត្តនិគ្រោធវ័នគល់ទទឹង ។

ញោមប្រុសឈ្មោះ គង់-តិក( ស្លាប់ ) ញោមស្រីឈ្មោះ ហុក-តាង

កើតថ្ងៃព្រហស្បតិ៍៩កើត ខែមិគសិរ ឆ្នាំថោះ ព.ស.២៥១៩ ។ មានបងប្អូន ៧ នាក់ គឺប្រុស ៥ នាក់ ស្រី ២ នាក់. ជាកូនពៅ ។ ក្នុងកុមារបានចូលរៀនសាលារដ្ឋ ដល់ថ្នាក់ទី ៨ ។

ក្នុងព.ស.២៥៣៧ មានអាយុ១៩ឆ្នាំ បួសជាសាមណេរក្នុងសំណាក់ឧបជ្ឈាយ៍ ព្រះនាម ឡុយលឿង វត្តស្លាកែត មកគង់នៅវត្តក្តាំងផា ខេត្តបាត់ដំបង ។ ព.ស. ២៥៣៨ មានអាយុគ្រប់ ២០ បានឧបសម្បទា ជាភិក្ខុភាវៈ ។

ព.ស. ២៥៤០ មកគង់នៅវត្តនិគ្រោធវ័ន រៀនធម៌វិន័យ ។ ព.ស. ២៥៤១ ចេញទៅគង់នៅវត្តខេមវ័ន( ខេត្តកំពង់ចាម ) បង្រៀនធម៌វិន័យ ។ ព.ស. ២៥៤៥ បានត្រឡប់មកវត្តនិគ្រោធវ័នវិញហើយលាសិក្ខា បានខិតខំ រៀបចំ និងជួយសរសេរសៀវភៅធម៌វិន័យ ។

ព.ស. ២៥៤៦ បួសជាសាមណេរវិញ ឧបជ្ឈាយ៍ព្រះនាម យឹ ទិត វត្តកោះក្របី ឃុំព្រែកថ្មី ស្រុក គៀនស្វាយ ខេត្តកណ្តាល បានជួយបង្រៀនព្រះវិន័យដល់ព្រះសង្ឃ ក្នុងវត្តនិគ្រោធវ័ន ។

ព.ស. ២៥៤៧ បំពេញជាភិក្ខុភាវៈ បានជួយបង្រៀននិងខិតខំរៀបចំអដ្ឋកថា និងសៀវភៅធម៌វិន័យជាច្រើនទៀត រហូតមក ។

# ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ

ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់គង់នៅក្បែរដើមស្ដៅ ជាលំនៅរបស់នឡេរុយក្ស ជិតក្រុងវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃមានប្រមាណច្រើនចំនួន ៥០០ រូប ។ វេរញ្ជព្រាហ្មណ៍បានចូលទៅលើកពាក្យចោទប្រកាន់ ចំពោះព្រះដ៏មានព្រះភាគ មានពាក្យជាដើមថា "ព្រះគោតមមិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយ ដែលចាស់គ្រាំគ្រាជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមក ក្នុងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះ ឱ្យអង្គុយលើអាសនៈ(ក៏ព្រះអង្គមិនធ្វើ)" ព្រះដ៏មានព្រះភាគទ្រង់ញ៉ាំងព្រាហ្មណ៍នោះ ឱ្យជ្រះថ្លាហើយ និងប្រកាសខ្លួនជាឧបាសក ដល់ព្រះត្រ័យសរណគមន៍ស្មើដោយជីវិត រួចក៏អារាធនាឱ្យទ្រង់ចាំវស្សាជិតស្រុកវេរញ្ជានោះមួយអន្លើដោយភិក្ខុសង្ឃ ។

ក្នុងវស្សានោះ ស្រុកវេរញ្ជាកើតអំណត់អត់បាយ ព្រះដ៏មានព្រះភាគ និងព្រះភិក្ខុសង្ឃឆាន់បាយក្រៀមរបស់ពួកឈ្មួញសេះ ។ ព្រះមហាមោគ្គល្លានទូលសូមសម្ដែងឫទ្ធិប្រែត្រឡប់ផែនដី ដើម្បី បានឱជារសដែលកើតឡើងអំពីស្រទាប់នៃផែនដី និងទូលសូមនាំភិក្ខុទៅបិណ្ឌបាត

ឯឧត្តរកុរុទ្វីប, តែព្រះដ៏មានព្រះភាគទ្រង់មិនអនុញ្ញាត ។ ចំណែកព្រះសារីបុត្រ ក៏ក្រាបទូលសួរអំពីសាសនារបស់ព្រះពុទ្ធទាំងឡាយ ដែលឋិតនៅមិនបានយូរ និងដែលឋិតនៅបានយូរ, ព្រះដ៏មានព្រះភាគក៏ទ្រង់សម្ដែងសាសនារបស់ព្រះពុទ្ធទាំង ៦ ព្រះអង្គមានព្រះពុទ្ធព្រះនាមវិបស្សីជាដើម ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ក្រោកចាកអាសនៈហើយ ធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា "សូមទ្រង់ព្រះមេត្តាប្រោស កាលនេះជាកាលគួរហើយ បពិត្រព្រះសុគត កាលនេះជាកាលគួរដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ៗ គួរបញ្ញត្តិសិក្ខាបទ គួរសម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ព្រោះកិច្ចដូច្នេះហើយ ជាហេតុនឹងឱ្យព្រហ្មចរិយធម៌ឋិតនៅអស់កាលអង្វែងទៅ" ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា "ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន តថាគតឯងសឹងដឹងកាលគួរក្នុងកិច្ចដែលនឹងបញ្ញត្តសិក្ខាបទជាដើមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ មិនទាន់ប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមណា ព្រះសាស្ដាក៏មិនទាន់បញ្ញត្តសិក្ខាបទ មិនទាន់សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយត្រឹមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទី

តាំងនៃអាសវៈ មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលណា ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយក្នុងកាលនោះ ដើម្បីនឹងការពារពាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងនោះប៉ុណ្ណោះ ម្នាលសារីបុត្ត សង្ឃនៅមិនទាន់មានភិក្ខុបួសចាស់វស្សាច្រើនគ្នាត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្តីចម្រើនមានភិក្ខុបួសចាស់វស្សាច្រើនគ្នា ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នឹងមានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារពាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់បាននូវសេចក្តីចម្រើនមានគ្នាច្រើនត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះ ត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្តីចម្រើនមានគ្នាច្រើន ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារពាំងនូវធម៌ទាំងឡាយ

ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់ដល់នូវសេចក្ដីចម្រើនដោយលាភសក្ការៈដ៏ប្រសើរត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នៅមិនទាន់មានប្រាកដចំពោះសង្ឃត្រឹមនោះ ម្នាលសារីបុត្ត លុះសង្ឃបានដល់នូវសេចក្ដីចម្រើនដោយលាភសក្ការៈដ៏ប្រសើរក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងកាលនោះដែរ ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារកាំងនូវធម៌ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះ ក្នុងកាលនោះឯង ម្នាលសារីបុត្ត ពីព្រោះ( ឥឡូវ )ភិក្ខុសង្ឃនៅមិនទាន់មានពុត( ហ៊ានលបលួចធ្វើអាក្រក់ )នៅឡើយ មិនទាន់មានទោសមោះមៃនៅឡើយ កំពុងនៅមានធម៌បរិសុទ្ធ ឥតទាន់មានពណ៌ខ្មៅសៅហ្មង សុទ្ធសឹងតែផូរផង់ផូង់ចិត្តឋិតនៅក្នុងធម៌មានខ្លឹមនៅឡើយ ម្នាលសារីបុត្ត ក៏បណ្ដាភិក្ខុទាំង ៥០០ រូបនេះ ភិក្ខុដែលមានមគ្គផលយ៉ាងទាបចុងគេបំផុតនោះ ក៏គង់បានសម្រេចត្រឹមថ្នាក់សោតៈ ជាបុគ្គលទៀងទាត់ លែងធ្លាក់ទៅក្នុងអបាយភូមិហើយ នឹងបានត្រាស់ដឹងមគ្គផលត ៗទៅទៀតជាប្រាកដ” ។

ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ ចប់

# ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ

## ឃោសកុមារកើតឡើង និងការសិក្សាត្រៃវេទ

*រាប់អំពីកាលនៃការបរិនិព្វានរបស់ព្រះមានព្រះភាគ កន្លងទៅហើយបាន ៩៥៦ ព្រះវស្សា ។ ព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមថា មហានាម បានគ្រងរាជ្យសម្បត្តិ ប្រកបដោយទសពិធរាជធម៌ក្នុងលង្កាទ្វីប ។ បានឮថា ក្នុងសម័យនោះឯង មានព្រាហ្មណ៍ មាណពម្នាក់ កើតនៅក្នុងត្រកូល ព្រាហ្មណ៍មួយ បិតាឈ្មោះ* ***កេសី*** *ជារាជបុរោហិត មាតាឈ្មោះ* ***កេសិនី*** *មានលំនៅស្ថិតនៅក្នុងទីជិតនៃពោធិមណ្ឌល (កន្លែងត្រាស់ដឹងរបស់ព្រះសម្ពុទ្ធ) ក្នុងមជ្ឈិមប្រទេសជម្ពូទ្វីប ។*

*ក៏ព្រោះក្នុងវេលាដែលមាណពនោះប្រសូតមក ពួកបរិវាររបស់ព្រាហ្មណ៍ មានទាសនិងកម្មករជាដើម បញ្ចេញសំឡេង សម្ដែងភាពត្រេកអររីករាយយ៉ាងគឹកកង ដូច្នោះ ទើបគេដាក់ឈ្មោះឱ្យកុមារនោះថា* ***ឃោសៈ*** *។ ទីខ្លះក៏ពោលថា មាណពនោះ កើតនៅក្នុងឃោសគ្រាម ទើបដាក់ឈ្មោះឱ្យថា ឃោសៈ ។ ឃោសៈមាណពនោះ ជាអ្នកដឹងវិជ្ជានិងក្បួនសិល្បៈទាំងពួងយ៉ាងជំនាញ ចេះចប់ត្រៃវេទយ៉ាងប្រាកដក្នុងលទ្ធិ បានត្រាច់ទៅដើម្បីសាកសួរ និងដោះស្រាយបញ្ហាវិជ្ជាសិល្បៈ ក្នុងស្រុកនិគមជនបទ រាជធានីទាំងឡាយ ក្នុងជម្ពូទ្វីប ។*

ដឹងថា មានសមណព្រាហ្មណ៍ ដែលជាបណ្ឌិតនៅក្នុងទីណា ៗ ក៏ចូលទៅធ្វើការសាកច្ឆាក្នុងទីនោះ ៗ បណ្ឌិតដទៃ (នោះ) ៗ មិនអាចឆ្លើយនូវបញ្ហាដែលមាណពនោះ សួរបានឡើយ តែមាណពនោះ អាចឆ្លើយនូវបញ្ហារបស់បណ្ឌិតទាំងនោះ ៗ ដែលសួរហើយបាន ។

## ឃោសមាណពជួបនឹងព្រះរេវតត្ថេរ

មាណពនោះ ត្រាច់ទៅទូទាំងជម្ពូទ្វីបដោយអាការយ៉ាងនេះ រហូតមកដល់វត្តមួយ (ក៏បានស្នាក់នៅក្នុងបរិវេណវត្តនោះ) ។ ក៏ក្នុងវត្តនោះ មានភិក្ខុនៅច្រើនរូប ព្រះរេវតៈ(ឬធម្មឃោសៈ) ជាសង្ឃត្ថេររបស់ភិក្ខុទាំងនោះ ជាព្រះមហាខីណាស្រពបានសម្រេចបដិសម្ភិទា អាចញ៉ាំញីបរប្បវាទបាន ។ គ្រានោះ កាលវេលាអាធ្រាត្រ ព្រាហ្មណ៍មាណព បានបរិវត្តបាតញ្ជលី (សាធ្យាយ) នូវមន្តឱ្យមានបទបរិបូណ៌ និងឱ្យជាបរិមណ្ឌល ព្រះថេរៈស្តាប់នូវសំឡេងព្រាហ្មណ៍សាធ្យាយមន្ត ក៏ជ្រាបថា "ព្រាហ្មណ៍នេះជាអ្នកមានបញ្ញាច្រើន" (រូបទើប) គិតថា "បើយើងទូន្មានឱ្យមករាប់អានព្រះពុទ្ធសាសនាបាននឹងជាការល្អ" ទើបហៅព្រាហ្មណ៍នោះមក រួចសួរថា "ម្នាលព្រាហ្មណ៍ អ្នកណាហ្នឹងស្រែកជាសំឡេងដូចលា" ។ ឃោសៈព្រាហ្មណ៍នោះសួរថា "នែបព្វជិតដ៏ចម្រើន លោកដឹងនូវសំឡេងរបស់ពួកលាឬ ?" ព្រះថេរៈតបថា "យើង

ដឹង” ។ ព្រាហ្មណ៍នោះ ទើបសួរព្រះថេរៈក្នុងគណ្ឋិដ្ឋាន (គឺមន្តដែលយល់បាន លំបាក) ទាំងឡាយក្នុងគម្ពីរត្រៃវេទ ទាំងគម្ពីរឥតិហាសជាគម្ពីរ ទី៥ ដែលខ្លួន ឯងសម្លឹងមិនឃើញន័យឡើយ ទាំងអាចារ្យរបស់ខ្លួន ក៏មិនឃើញមកហើយផង ដែលព្រះថេរៈនោះ ដោយប្រក្រតីក៏ជាអ្នកចេះចប់ត្រៃវេទហើយ មកដល់ឥឡូវ នេះ ជាអ្នកបានសម្រេចនូវបដិសម្ភិទាទៀត ព្រោះហេតុនោះ សេចក្តីលំបាកក្នុង ការឆ្លើយនូវបញ្ហាទាំងនោះ ទើបមិនមានដល់លោក ព្រោះដូច្នោះ ទើបព្រះថេរៈ ឆ្លើយនូវបញ្ហាទាំងនោះបានភ្លាម ។ ហើយពោលនឹងព្រាហ្មណ៍នោះថា “នែ ព្រាហ្មណ៍ដ៏ចំរើន អ្នកសាកសួរយើងមកច្រើនហើយ ឥឡូវនេះ យើងនឹង សាកសួរនូវបញ្ហាកម្មនឹងអ្នកមួយ អ្នកនឹងឆ្លើយបញ្ហារបស់យើងបានឬទេ ?” ព្រាហ្មណ៍តបថា “ខ្ញុំនឹងឆ្លើយមន្តនោះប្រគេនបាន លោកម្ចាស់ចូរសួរមកចុះ” ទើបព្រះថេរៈសួរនូវបញ្ហាក្នុងគម្ពីរអភិធម្ម ចិត្តយមកៈ[១]នេះថា “យស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ តស្ស ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ យស្ស វា បន ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ តស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ, : ចិត្តរបស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងរលត់ នឹងមិនកើត

១. អភិ. យម. យមកវគ្គ. ៩១. ១/១ ។

ឡើង ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង រមែងមិនរលត់”[១] ។

ព្រាហ្មណមាណពនោះ មិនអាចនឹងឆ្លើយបាន មិនថា លើ ឬក្រោម ទើបសួរថា “បពិត្រលោកម្ចាស់ដ៏ចំរើន មន្តនេះឈ្មោះមន្តអ្វី ?” ព្រះថេរៈតប ថា “ម្នាលព្រាហ្មណ៍ មន្តនេះ ឈ្មោះថា ពុទ្ធមន្ត” ។ ព្រាហ្មណ៍សួរថា “លោកម្ចាស់ដ៏ចម្រើន ឱ្យមន្តនេះដល់ខ្ញុំព្រះករុណាបានដែរឬទេ ?” ព្រះថេរៈ តបថា “ម្នាលព្រាហ្មណ៍ យើងឱ្យ (មន្តនេះ) ដល់អ្នកបាន លុះត្រាតែ អ្នកបួសជាបព្វជិតដូចយើង” ។

## មាណពបួស ប្រាកដឈ្មោះ ព្រះពុទ្ធឃោសៈ

ឃោសៈព្រាហ្មណ៍ដែលបុព្វហេតុ (គឺកុសលក្នុងកាលមុន) ទាំងឡាយ ជាស់តឿនហើយ ទើបសូមបព្វជ្ជា ដើម្បីត្រូវការមន្ត ព្រះថេរៈទើឱ្យព្រាហ្មណ៍ បព្វជ្ជាឧបសម្បទាហើយ ឱ្យរៀនព្រះត្រៃបិដកពុទ្ធវចនៈ ភិក្ខុនោះ ក៏យល់ដឹង អត្ថធម៌របស់ព្រះត្រៃបិដកថា “នេះជាឯកាយមគ្គ (ដំណើរផ្លូវដ៏ឯក ប្រសើរ ជាផលុទ្ធិចាស់របស់ខ្លួន)” (តមក) ក៏បានជាអ្នកប្រាកដច្បាស់ក្នុងលោក ដូច

---

១. ពាក្យថា **រមែងកើតឡើង** គឺនៅក្នុងឧប្បាទខណៈ, ពាក្យថា **រមែងមិនរលត់** គឺមិនទាន់ដល់ និរោធឬភង្គខណៈ ។ ចិត្តក្នុងទីនេះ សំដៅដល់បច្ឆិមចិត្ត គឺចុតិចិត្ត របស់ព្រះអរហន្ត ខណៈចិត្ត របស់ព្រះអរហន្តកំពុងប្រព្រឹត្តទៅ ឈ្មោះថា រមែងកើតឡើង រមែងមិនរលត់ កាលដល់ភង្គ ខណៈហើយ ចុតិចិត្តនោះ ក៏នឹងរលត់ និងមិនមានចិត្តដទៃកើតឡើងតទៅទៀត ។

ពន្លឺភ្លើង ដូចពន្លឺព្រះចន្ទ ដូចពន្លឺព្រះអាទិត្យ ដោយការដែលលោកបានព្យាករណ៍ពោលឆ្លើយបញ្ហាព្រះធម៌ដ៏ជ្រាលជ្រៅដល់ជនទាំងឡាយ ដូចជាពុទ្ធព្យាករណ៍, ភិក្ខុឃោសៈ ទើបបានប្រាកដនាមថា "ព្រះពុទ្ធឃោសៈ" ព្រោះល្បីផ្សាយទៅក្នុងផ្ទៃផែនដីដូចព្រះពុទ្ធអង្គ ។

## ព្រះថេរៈបញ្ជូនឱ្យទៅប្រែគម្ពីរអដ្ឋកថា

ព្រះពុទ្ធឃោសៈនោះ ជាអ្នកនៅក្នុងវិហារនោះ បានតែងបករណ៍ឈ្មោះញាណោទ័យទុកក្នុងវិហារហើយ ផ្ដើមតែងអដ្ឋកថា ព្រះអភិធម្មសង្គណី និងអដ្ឋកថាច្បាប់ឈ្មោះអដ្ឋសាលិនី ព្រះថេរៈឃើញដូច្នោះទើបប្រាប់ថា "ម្នាលអាវុសោពុទ្ធឃោសៈ ក្នុងជម្ពូទ្វីបនេះ មានតែគម្ពីរព្រះត្រៃបិដកបាលីប៉ុណ្ណោះ អដ្ឋកថារបស់ព្រះត្រៃបិដកនោះ និងថេរវាទ (គឺពាក្យដែលព្រះថេរៈក្នុងសម័យសង្គីតិ ពោលទុកជាច្បាប់) មិនមាន តែអដ្ឋកថាព្រះត្រៃបិដកដែលឡើងកាន់សង្គីតិទាំង៣លើក ជាពាក្យដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងទុក និងព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើមចងក្រងទុកហើយ ឯព្រះមហិន្ទត្ថេរត្រួតមើលកថាមគ្គ (សម្ដែងផ្លូវនៃពាក្យដែលពោលទុក)ហើយ (រួបរួមមក) តែងទុកដោយភាសាសីហឡៈ កំពុងប្រព្រឹត្តទៅនៅក្នុងសីហឡទ្វីប ចូរលោកទៅកាន់សីហឡទ្វីបនោះ ត្រួតរមើលឱ្យសព្វអន្លើហើយ បកប្រែមកជាភាសាមគធ

បាន អដ្ឋកថានោះ នឹងនាំមកនូវប្រយោជន៍សុខដល់មនុស្សលោកទាំងពួង” ។

កាលព្រះថេរណែនាំយ៉ាងនោះ ព្រះពុទ្ធឃោសៈ ជាអ្នកមានបញ្ញាច្រើន ក៏កើតបីតិសោមនស្ស ក្រាបទូលលាព្រះឧបជ្ឈាយ៍ និងភិក្ខុសង្ឃ បានធ្វើដំណើរទៅកាន់កំពង់ទឹកដោយលំដាប់ឡើង ទូកទៅជួបព្រះពុទ្ធទត្តត្ថេរតាមផ្លូវដែលមកដល់កណ្តាលសមុទ្រ ក៏បាននិយាយប្រាស្រ័យគ្នា ហើយធ្វើដំណើរបន្តទៅដរាបដល់កំពុង ក្រុងលង្កា ក្នុងកាលនោះ ព្រះបាទមហានាម គ្រប់គ្រងរាជ្យក្នុងលង្កាទ្វីប ។

# តែងបករណ៍ ឈ្មោះវិសុទ្ធិមគ្គ

ព្រះពុទ្ធឃោសៈ និមន្តទៅជួបព្រះសង្ឃក្នុងវិហារ ក្រុងអនុរាធបុរី ហើយទើបទៅកាន់សំណាក់ព្រះសង្ឃបាលត្ថេរ ដែលគង់នៅក្នុងមហាបធានឃរៈ បានស្តាប់(ជ្រាបសេចក្តី) អដ្ឋកថាភាសាសីហឡៈ និងថេរវាទទាំងពួងហើយ ជឿទុកចិត្តថា “នេះឯងជាព្រះពុទ្ធាធិប្បាយរបស់ព្រះធម្មសាមិត្រពិត” ទើបទៅកាន់ទីប្រជុំសង្ឃ ក្នុងវិហារនោះ ដើម្បីសូមគម្ពីរធ្វើអដ្ឋកថាព្រះត្រៃបិដក ក៏បានពោលសូមថា “សូមលោកម្ចាស់ទាំងឡាយ មេត្តាឱ្យសៀវភៅគម្ពីរទាំងឡាយដល់ខ្ញុំព្រះករុណាដើម្បីធ្វើអដ្ឋកថា” ។ ដើម្បីសាកល្បង សមត្ថភាពរបស់

លោក ទើបភិក្ខុសង្ឃឱ្យគាថា ២ បទ ហើយពោលថា "លោកចូរសម្តែងសមត្ថភាពក្នុងគាថា ២ បទនេះ យើងទាំងឡាយ បានឃើញសមត្ថភាពរបស់លោកហើយ នឹងប្រគល់ ច្បាប់គម្ពីរឱ្យទាំងអស់" ព្រះពុទ្ធឃោសមើលបាលីព្រះត្រៃបិដក និងអដ្ឋកថារបស់ព្រះត្រៃបិដកនោះហើយ ទើបព្រះថេរៈរួបរួមព្រះត្រៃបិដកព្រមទាំងអដ្ឋកថាដោយសង្ខេប តែងបករណ៍ ឈ្មោះ វិសុទ្ធិមគ្គឡើង ក្នុងមហាវិហារនេះឯង ។

គ្រានោះ ទេវតា[១]មានបំណង ដើម្បីនឹងប្រកាសថ្វីដៃរបស់លោកឱ្យប្រាកដ ក្នុងមហាជន ទើបបណ្តាលឱ្យសៀវភៅគម្ពីរច្បាប់ (ដែលលោកសរសេររួចហើយ) ឱ្យអន្តរធានបាត់ទៅ ទើបលោកសរសេរឡើងថ្មីមួយច្បាប់ទៀត ទេវតាក៏បណ្តាលឱ្យអន្តរធានបាត់ទៅទៀត ទើបលោកសរសេរឡើងថ្មីលើកទី ៣ ទៀត ក៏បាន ចប់សព្វគ្រប់ទៀត ក្នុងគ្រានោះ ព្រះពុទ្ធឃោសៈនិមន្តព្រះសង្ឃ ដែលជាអ្នកឆ្លាសក្នុងធម៌របស់ព្រះសម្ពុទ្ធឱ្យមកប្រជុំគ្នា ក្នុងទីជិតមហាពោធិព្រឹក្ស(ប្រទេសលង្កា) ប្រារព្ធនឹងអានបករណ៍វិសុទ្ធិមគ្គនោះ (ឱ្យសង្ឃស្តាប់) ស្រាប់តែទេវតាដែលបំបាំងសៀវភៅនោះ នាំសៀវភៅទាំងពីរចប់នោះ មកប្រគេនសងវិញព្រមក្នុងខណៈនោះ ទើបបានជាសៀវភៅវិសុទ្ធិមគ្គ

---

១. ខ្លះថា ព្រះសង្ឃ ។

បីចប់ឡើង ក៏បានប្រគល់សៀវភៅទាំងបីចប់ ទៅព្រះភិក្ខុសង្ឃ, ភិក្ខុសង្ឃឱ្យអានសៀវភៅទាំងបីចប់ ព្រមគ្នា ការខុសភ្លាំងភ្លាត់បីចប់នោះ ដោយគណ្ឋៈក្តី ដោយអក្ខរៈក្តី ដោយបទក្តី ដោយព្យញ្ជនៈក្តី ដោយអត្ថក្តី ដោយការសរសេរមុន ក្រោយក្តី ដោយវាទៈទាំងឡាយមានថេរវាទជាដើមក្តី ដោយព្រះបាលីទាំងឡាយក្តី មិនមានឡើយ បានឮថា កាលគម្ពីរវិសុទ្ធិមគ្គ ទាំង ៣ ដែលព្រះពុទ្ធឃោសៈធ្វើរួចស្រេចហើយយ៉ាងនោះ ទេវតាទាំងឡាយ បាននាំគ្នាធ្វើសាធុការ សម័យនោះភិក្ខុច្រើនពាន់ប្រជុំ គ្នានៅក្នុងវិហារ ឃើញការអស្ចារ្យនោះហើយ ក៏នាំគ្នាសរសើរឱ្យសាធុការ ប្រកាសប្រាប់គ្នាសុសសាយទៅថា "នេះព្រះពោធិសត្វ មេត្រីមកកើត ដោយឥតសង្ស័យ"[១] ។

## បកប្រែអដ្ឋកថាព្រះត្រៃបិដក មកជាភាសាមគធៈ

ចំណែកស្តេចផែនដី ទ្រង់បានស្តាប់ដំណឹងនោះ ក៏ស្តេចចេញពីព្រះនគរព្រមទាំងរាជបរិវារទៅកាន់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយ ទ្រង់នមស្ការព្រះពុទ្ធឃោសៈ និមន្តឱ្យទទួលនូវចង្ហាន់នៅក្នុងរាជវាំងជាប្រចាំរហូតដល់ការតែងគម្ពីរចប់ ព្រះថេរៈ ទទួលនិមន្តដោយតុណ្ហីភាព ។

ព្រះភិក្ខុសង្ឃឃើញសមត្ថភាពរបស់ព្រះថេរៈហើយ ទើបប្រគល់សៀវភៅ

១. នេះជាការឃើញអស្ចារ្យរបស់ភិក្ខុទាំងឡាយទេ មិនប្រាកដជាព្រះមេត្រីឡើយ ។

ព្រះត្រៃបិដកបាលី ព្រមទាំងសៀវភៅអដ្ឋកថាសីហឡៈឱ្យដល់ព្រះថេរៈ, ព្រះថេរៈទទួលសៀវភៅគម្ពីរទាំងអស់ទៅទុកក្នុងប្រាសាទ ឈ្មោះថា បធានឃរៈ ដែលតាំងនៅខាងត្បូងនៃមហាវិហារ ប្រែអដ្ឋកថាទាំងអស់ធ្វើជាអដ្ឋកថាព្រះត្រៃបិដកក្នុងភាសាមគធ ដែលជាមូលភាសា ( គឺភាសាដើម ) ។

ក៏អដ្ឋកថាសីហឡៈនោះ មាន ៣ ភាគ គឺ មហាអដ្ឋកថា ១ បច្ចរិយអដ្ឋកថា ១ កុរុន្ទីអដ្ឋកថា ១ ។

អដ្ឋកថាដែលឡើងកាន់មហាសង្គីតិ ព្រះមហិន្ទត្ថេរនាំមកតែងទុកក្នុងភាសាសីហឡ: ឈ្មោះថា **មហាអដ្ឋកថា** ។

មានផ្ទះផែមួយខ្នង មានឈ្មោះហៅក្នុងភាសាសីហឡៈថា បច្ចរិយៈ ។ អដ្ឋកថាដែលភិក្ខុទាំងនោះប្រជុំគ្នាធ្វើក្នុងផ្ទះផែនោះ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

មានវិហារមួយកន្លែង ឈ្មោះកុរុន្ទីវិហារ ។ អដ្ឋកថាដែលភិក្ខុទាំងនោះប្រជុំគ្នាធ្វើក្នុងវិហារនោះ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទដែលព្រះថេរៈជំនាន់មុនមានព្រះថេរិកាចារ្យ ( អាចារ្យធំ ) ជាដើមកាន់យកន័យព្រះបាលីតែងទុក ឈ្មោះថា **ថេរវាទ** ។

ព្រះពុទ្ធឃោសៈ ប្រែកុរុន្ទីអដ្ឋកថាភាសាសីហឡ: ធ្វើអដ្ឋកថាព្រះវិន័យបិដក ឈ្មោះសមន្តប្បាសាទិកា ក្នុងភាសាមគធៈហើយ តពីនោះក្នុងសុត្តន្តបិដក បកប្រែមហាអដ្ឋកថាអំពីភាសាសីហឡ: តាំងជាអដ្ឋកថាទីឃនិកាយ

ឈ្មោះសុមង្គលវិលាសិនី, ជាអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី, ជាអដ្ឋកថាសំយុត្តនិកាយ ឈ្មោះ សារត្ថបកាសិនី, និងជាអដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះមនោរថបូរណី, តពីនោះ ក្នុងអភិធម្មបិដក បកប្រែបច្ចរិយអដ្ឋកថាអំពីភាសាសីហឡ: តាំងជាអដ្ឋកថាបករណ៍ធម្មសង្គណី ឈ្មោះអដ្ឋសាលិនីក្នុងភាសាមគធ: ជាអដ្ឋកថាបករណ៍វិភង្គ ឈ្មោះសម្មោហវិនោទនី និងជាអដ្ឋកថា ៥ បករណ៍ ឈ្មោះបរមត្ថទីបនី ។

ព្រះពុទ្ធឃោស: ធ្វើអដ្ឋកថាសីហឡ:ទាំងអស់ឱ្យជាអដ្ឋកថា ព្រះត្រៃបិដក ក្នុងភាសាមគធ: ដែលជាមូលភាសាដូចពោលមកហើយដូច្នោះ អដ្ឋកថានោះឯង បាននាំមកនូវប្រយោជន៍សុខដល់ពពួកជន ក្នុងប្រទេសដទៃ ៗទាំងពួងយ៉ាងច្រើនសន្ធឹកសន្ធាប់ហើយ រស់នៅរហូតដល់អស់អាយុ ទើបទៅកាន់ទេវលោកនោះឯង ។

កាលដែលបានបកប្រែអដ្ឋកថាព្រះត្រៃបិដក ចប់សព្វគ្រប់ហើយ ផែនដីក៏កក្រើកញ័រ (ជាអស្ចារ្យ) អដ្ឋកថាព្រះត្រៃបិដក ដែលព្រះថេរ: ធ្វើដូចពោលមកនេះ គឺបកប្រែចប់សព្វ គ្រប់ តែក្នុងរយ:កាល ១ ឆ្នាំប៉ុណ្ណោះ ។

លុះបកប្រែរួចហើយ ព្រះពុទ្ធឃោស: ប្រាថ្នាដើម្បីនឹងបាន មកថ្វាយបង្គំព្រះមហាពោធិព្រឹក្ស ទើបក្រាបថ្វាយបង្គំព្រះភិក្ខុសង្ឃ ត្រឡប់មកជម្ពូទ្វីបវិញ ។

ព្រះរាជាមហានាម ទ្រង់គ្រងផែនដីអស់ ១២ ឆ្នាំ ទ្រង់ធ្វើបុណ្យច្រើនយ៉ាង ដោយប្រការផ្សេង ៗហើយ ស្តេចក៏ទៅកាន់បរលោកតាមយថាកម្ម ។ ចំណែកព្រះពុទ្ធឃោសត្ថេរនោះ បានរចនាអដ្ឋកថានៃព្រះត្រៃបិដកទុក បានសាងប្រយោជន៍ដ៏សមគួរដល់សត្វលោកជាច្រើន តាំងនៅរហូតគ្រប់អាយុខ័យ ក៏បានទៅកាន់ឋានតាវត្តិង្សហើយ ដូច្នេះឯង ។

## សេចក្តីប្រាថ្នារបស់ព្រះពុទ្ធឃោសត្ថេរ

យំ សិទ្ធំ ឥមិនា បុញ្ញ  យំ ចញ្ញំ បសុតំ មយា
ឯតេន បុញ្ញកម្មេន  ទុតិយេ អត្តសម្ភវេ
តាវតឹសេ បមោទេន្តោ  សីលាចារគុណេ រតោ
អលគ្គោ បញ្ចកាមេសុ  បត្វា បឋមំ ផលំ
អន្តិមេ អត្តភាវម្ហិ  មេត្តេយ្យំ មុនិបុង្គវំ
លោកគ្គបុគ្គលំ នាថំ  សព្វសត្តហិតេ រតំ
ទិស្វាន តស្ស ធីរស្ស  សុត្វា សទ្ធម្មទេសនំ
អធិគន្ត្វា ផលំ អគ្គំ  សោភេយ្យំ ជិនសាសនន្តិ ។

បុណ្យណា ដែលសម្រេចហើយដោយការធ្វើនេះ និងបុណ្យដទៃណា ដែលខ្ញុំបានខ្វល់ខ្វាយទុក ដោយអំណាចនៃបុណ្យនោះ ក្នុងអត្តភាពទី២ សូមឱ្យខ្ញុំរីករាយក្នុងឋានតាវត្តិង្ស ត្រេកអរក្នុងគុណគឺសីលនិងអាចារៈ មិនជាប់ជំពាក់ក្នុងកាមគុណទាំង ៥ បានសម្រេចអរិយផលទី ១ (សោតាបត្តិផល) ក្នុងអត្តភាពចុងបំផុត សូមឱ្យខ្ញុំបានជួបព្រះអារ្យមេត្រី ព្រះមុនីដ៏ប្រសើរ ជាបុគ្គលចម្បងក្នុងលោក ជាព្រះលោកនាថ ទ្រង់ពេញព្រះទ័យក្នុងការជួយសត្វលោកទាំងពួង សូមឱ្យខ្ញុំបានស្តាប់ព្រះសទ្ធម្មរបស់ព្រះមុនីអង្គនោះ ដែលទ្រង់ជាអ្នកប្រាជ្ញា ហើយបានសម្រេចអរិយផលជាន់ខ្ពស់ (អរហត្តផល) ញ៉ាំងព្រះសាសនារបស់ព្រះជិនស្រីឱ្យល្អស្អាត ដោយប្រការដូច្នេះហោង ។

ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ ចប់

# ឧប្បត្តិកថា

សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យ ជាស្នាដៃរបស់ព្រះពុទ្ធឃោសាចារ្យ

ប្រទេសខ្មែរយើងនេះ មានគម្ពីរព្រះត្រៃបិដកចប់សព្វគ្រប់ ដែលក្រុមជំនុំ បានរៀបចំឡើងជាភាសាបាលីផង ភាសាខ្មែរផង ខ្ញុំមានចិត្តសោមនស្សរីករាយ ហើយក៏រៀបចំប្រែអដ្ឋកថាព្រះវិន័យនេះ ឱ្យមកជាភាសាខ្មែរផង ដើម្បីបានការយល់ដឹងក្នុងផ្នែកព្រះវិន័យរបស់ព្រះសង្ឃ និងពុទ្ធបរិស័ទខ្មែរយើង ដែលកំពុង តែប្រឹងប្រែងសិក្សាព្រះវិន័យ ។

ខ្ញុំបានសសេរពាក្យបញ្ចូលថែម, គឺ ពាក្យខ្លះយកអំពីបិដក តាមដែល អដ្ឋកថាចង្អុលប្រាប់ផង មិនប្រាប់ផង ដោយមានលេខយោងបញ្ជាក់, ពាក្យខ្លះ មិនមានក្នុងបាលីអដ្ឋកថាទេ ថែមដោយបំណងដើម្បីបញ្ជាក់សេចក្ដីប៉ុណ្ណោះ, ម្យ៉ាងទៀត បានដាក់លេខឃ្នាបតាមបិដក ដើម្បីងាយដឹងថា នេះជាសេចក្ដីពន្យល់ ក្នុងបិដកត្រង់លេខឃ្នាបនេះ ។ តែដោយសមត្ថភាពរបស់ខ្ញុំព្រមទាំងក្រុមប្រឹក្សា តិចតួច សៀវភៅនេះក៏នៅមានសេចក្ដី និងអក្ខរៈ ខុសភ្លាំងភ្លាត់នៅឡើយ ដោយអចេតនា សូមមេត្តាជួយសម្រួលដោយអនុគ្រោះផងចុះ ។

បុណ្យដែលកើតអំពីការព្យាយាមសាងសៀវភៅនេះ សូមចែកដល់អ្នកសិក្សាទាំងឡាយផង ។ សូមអ្នកសិក្សាទាំងឡាយ ទទួលអនុមោទនាត្រេកអរនូវបុណ្យនេះ ដោយមហាកុសលសោមនស្សរីករាយ ដែលប្រកបដោយបញ្ញា ឱ្យបានគ្រប់ ៗគ្នា សូមអនុមោទនា !!! ។

សូមឱ្យកុលបុត្រខ្មែរ ខិតខំសិក្សាព្រះធម៌វិន័យ ឱ្យកើតបញ្ញាយល់ដឹង ហើយទ្រទ្រង់សិក្ខាឱ្យបានមាំមួន ឱ្យបានតាំងនៅក្នុងភាពជាអ្នកខ្មាសបាប សង្រួម ប្រយ័ត្នដើម្បីកម្ចាត់បង់នូវបាបចេញ លាងជម្រះមន្ទិលសៅហ្មងក្នុងចិត្ត បំពាក់ អលង្ការ គឺព្រះសទ្ធម្ម ធ្វើខ្លួនឱ្យមានគុណតម្លៃ ឱ្យប្រសើរ ឱ្យផុតពីទុក្ខកង្វល់ នាំខ្លួនឱ្យដល់ឋានសុខសាន្ត ។

ខ្ញុំសូមប្រាថ្នាឱ្យមានបញ្ញាទ្រទ្រង់ព្រះធម៌ព្រះវិន័យ សូមឱ្យបានផុតពីក្តី អន្តរាយទាំងពួង និងបានសម្រេចតាមគោលបំណងដ៏ល្អ ជាពិសេសឱ្យបានដល់ ទីបំផុតទុក្ខ គឺ ព្រះនិព្វាន ដោយឆាប់រហ័សហោង ។

# អក្សរសង្ខេប និងអក្សរពេញ

## បិដក

| អក្សរសង្ខេប | អក្សរពេញនៃបិដក | | | ភាគ |
|---|---|---|---|---|
| *វិន. បារា.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *បារាជិក* | *ភាគ ១* |
| *វិន. សង្ឃា.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *សង្ឃាទិសេស* | *ភាគ ២* |
| *វិន. និស្ស.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *និស្សគ្គិយ* | *ភាគ ៣* |
| *វិន. បាចិ.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *បាចិត្តិយ* | *ភាគ ៤* |
| *វិន. ភិក្ខុនី.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *ភិក្ខុនីវិភង្គ* | *ភាគ ៥* |
| *វិន. មហា.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *មហាវគ្គ* | *ភាគ ៦-៨* |
| *វិន. ចុល្ល.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *ចុល្លវគ្គ* | *ភាគ ៩-១១* |
| *វិន. បរិ.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *បរិវារៈ* | *ភាគ ១២-១៣* |
| *ទីឃ. សីល.* | *សុត្តន្តបិដក* | *ទីឃនិកាយ* | *សីលក្ខន្ធវគ្គ* | *ភាគ ១៤-១៥* |
| *ទីឃ. មហា.* | *សុត្តន្តបិដក* | *ទីឃនិកាយ* | *មហាវគ្គ* | *ភាគ ១៦-១៧* |
| *ទីឃ. បាដិ.* | *សុត្តន្តបិដក* | *ទីឃនិកាយ* | *បាដិកវគ្គ* | *ភាគ ១៨-១៩* |
| *មជ្ឈិ. មូល.* | *សុត្តន្តបិដក* | *មជ្ឈិមនិកាយ* | *មូលបណ្ណាសក* | *ភាគ ២០-២២* |
| *មជ្ឈិ. មជ្ឈិ.* | *សុត្តន្តបិដក* | *មជ្ឈិមនិកាយ* | *មជ្ឈិមបណ្ណាសក* | *ភាគ ២៣-២៥* |
| *មជ្ឈិ. ឧប.* | *សុត្តន្តបិដក* | *មជ្ឈិមនិកាយ* | *ឧបរិបណ្ណាសក* | *ភាគ ២៦-២៨* |
| *សំយុ. សគា.* | *សុត្តន្តបិដក* | *សំយុត្តនិកាយ* | *សគាថវគ្គ* | *ភាគ ២៩-៣០* |
| *សំយុ. និទា.* | *សុត្តន្តបិដក* | *សំយុត្តនិកាយ* | *និទានវគ្គ* | *ភាគ ៣១-៣២* |

| **អក្សរសង្ខេប** | **អក្សរពេញនៃអដ្ឋកថា** | | | **ភាគ** |
|---|---|---|---|---|
| សំយុ. ខន្ធ. | សុត្តន្តបិដក | សំយុត្តនិកាយ | ខន្ធវារវគ្គ | ភាគ ៣៣-៣៤ |
| សំយុ. សឡា. | សុត្តន្តបិដក | សំយុត្តនិកាយ | សឡាយតនវគ្គ | ភាគ ៣៥-៣៦ |
| សំយុ. មហា. | សុត្តន្តបិដក | សំយុត្តនិកាយ | មហាវារវគ្គ | ភាគ ៣៧-៣៩ |
| អង្គុ. ឯក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឯកនិបាត | ភាគ ៤០ |
| អង្គុ. ទុក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ទុកនិបាត | ភាគ ៤០ |
| អង្គុ. តិក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | តិកនិបាត | ភាគ ៤១ |
| អង្គុ. ចតុ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ចតុក្កនិបាត | ភាគ ៤២-៤៣ |
| អង្គុ. បញ្ច. | សុត្តន្តបិដក | អង្គុត្តរនិកាយ | បញ្ចកនិបាត | ភាគ ៤៤-៤៥ |
| អង្គុ. ឆក្ក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឆក្កនិបាត | ភាគ ៤៦ |
| អង្គុ. សត្ត. | សុត្តន្តបិដក | អង្គុត្តរនិកាយ | សត្តកនិបាត | ភាគ ៤៧ |
| អង្គុ. អដ្ឋ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | អដ្ឋកនិបាត | ភាគ ៤៨ |
| អង្គុ. នវ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | នវកនិបាត | ភាគ ៤៩ |
| អង្គុ. ទស. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ទសកនិបាត | ភាគ ៥០-៥១ |
| អង្គុ. ឯកា. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឯកាទសកនិបាត | ភាគ ៥១ |
| ខុទ្ទ. បាឋ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ខុទ្ទកបាឋ | ភាគ ៥២ |
| ខុទ្ទ. ធម្ម. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ធម្មបទ | ភាគ ៥២ |
| ខុទ្ទ. ឧទា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ឧទាន | ភាគ ៥២ |
| ខុទ្ទ. ឥតិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ឥតិវុត្តក | ភាគ ៥៣ |
| ខុទ្ទ. សុត្ត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | សុត្តនិបាត | ភាគ ៥៤ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | | ភាគ |
|---|---|---|---|---|
| ខុទ្ទ. វិមា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | វិមានវត្ថុ | ភាគ ៥៥ |
| ខុទ្ទ. បេត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | បេតវត្ថុ | ភាគ ៥៦ |
| ខុទ្ទ. ថេរ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ថេរគាថា | ភាគ ៥៦. ៥៧. |
| ខុទ្ទ. ថេរី. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ថេរីគាថា | ភាគ ៥៧ |
| ខុទ្ទ. ជាត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ជាតក | ភាគ ៥៨-៦៣ |
| ខុទ្ទ. មហា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | មហានិទ្ទេស | ភាគ ៦៤-៦៦. |
| ខុទ្ទ. ចូឡ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ចូឡនិទ្ទេស | ភាគ ៦៧. ៦៨. |
| ខុទ្ទ. បដិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ | ភាគ ៦៩-៧១. |
| ខុទ្ទ. អប្ប. | សុត្តន្តបិដក | ខុទ្ទកនិកាយ | អប្បទាន | ភាគ ៧២-៧៦ |
| ខុទ្ទ. ពុទ្ធ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ពុទ្ធវង្ស | ភាគ ៧៦ |
| ខុទ្ទ. ចរិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ចរិយាបិដក | ភាគ ៧៦ |
| អភិ. សង្គ. | អភិធម្មបិដក | ខុទ្ទកនិកាយ | ធម្មសង្គណី | ភាគ ៧៨. ៧៩. |
| អភិ. វិភ. | អភិធម្មបិដក | ខុទ្ទកនិកាយ | វិភង្គ | ភាគ ៨០-៨២. |
| អភិ. ធាតុ. | អភិធម្មបិដក | ខុទ្ទកនិកាយ | ធាតុកថា | ភាគ ៨៣. |
| អភិ. បុគ្គ. | អភិធម្មបិដក | ខុទ្ទកនិកាយ | បុគ្គលបញ្ញត្តិ | ភាគ ៨៣. |
| អភិ. កថា. | អភិធម្មបិដក | ខុទ្ទកនិកាយ | កថាវត្ថុ | ភាគ ៨៤-៩០ |
| អភិ. យម. | អភិធម្មបិដក | ខុទ្ទកនិកាយ | យមក | ភាគ ៩១-៩៣. |
| អភិ. បដ្ឋា. | អភិធម្មបិដក | ខុទ្ទកនិកាយ | មហាបដ្ឋាន | ភាគ ៩៤-១១០ |

# អដ្ឋកថា

| អក្សរសង្ខេប | | អក្សរពេញនៃអដ្ឋកថា | | |
|---|---|---|---|---|
| សមន្ត. | ពាហិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | ពាហិរនិទាន |
| សមន្ត. | វេរ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | វេរញ្ជកណ្ឌ |
| សមន្ត. | បារា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | បារាជិកកណ្ឌ |
| សមន្ត. | សង្ឃា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | សង្ឃាទិសេស |
| សមន្ត. | និស្ស. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | និស្សគ្គិយ |
| សមន្ត. | បាចិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | បាចិត្តិយ |
| សមន្ត. | មហា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | មហាវគ្គ |
| សមន្ត. | ចុល្ល. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | ចុល្លវគ្គ |
| សមន្ត. | បរិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិន័យ | បរិវារៈ |
| សុមង្គ. | សីល. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | សីលក្ខន្ធវគ្គ |
| សុមង្គ. | មហា. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | មហាវគ្គ |
| សុមង្គ. | បាដិ. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | បាដិកវគ្គ |
| បបញ្ច. | មូល. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | មូលបណ្ណាសក |
| បបញ្ច. | មជ្ឈិ. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | មជ្ឈិមបណ្ណាសក |
| បបញ្ច. | ឧប. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | ឧបរិបណ្ណាសក |
| សារត្ថ. | សគា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | សគាថវគ្គ |
| សារត្ថ. | និទា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | និទានវគ្គ |
| សារត្ថ. | ខន្ធ. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | ខន្ធវារវគ្គ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | |
|---|---|---|---|
| សារត្ថ. សឡា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | សឡាយតនវគ្គ |
| សារត្ថ. មហា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | មហាវារវគ្គ |
| មនោរ. ឯក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឯកនិបាត |
| មនោរ. ទុក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ទុកនិបាត |
| មនោរ. តិក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | តិកនិបាត |
| មនោរ. ចតុ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ចតុក្កនិបាត |
| មនោរ. បញ្ច. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | បញ្ចកនិបាត |
| មនោរ. ឆក្ក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឆក្កនិបាត |
| មនោរ. សត្ត. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | សត្តកនិបាត |
| មនោរ. អដ្ឋ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | អដ្ឋកនិបាត |
| មនោរ. នវ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | នវកនិបាត |
| មនោរ. ទស. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ទសកនិបាត |
| មនោរ. ឯកា. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឯកាទសកនិបាត |
| បរត្ថ. បាឋ. | បរមត្ថជោតិកាយ | អដ្ឋកថានៃខុទ្ទកនិកាយ | ខុទ្ទកបាឋ |
| អដ្ឋ. ធម្ម. | ធម្មបទដ្ឋកថា | អដ្ឋកថានៃខុទ្ទកនិកាយ | ធម្មបទគាថា |
| បរត្ថ. ឧទា. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ឧទាន |
| បរត្ថ. ឥតិ. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ឥតិវុត្តក |
| បរត្ថ. សុត្ត. | បរមត្ថជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | សុត្តនិបាត |
| បរត្ថ. វិមា. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | វិមានវត្ថុ |
| បរត្ថ. បេត. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | បេតវត្ថុ |

## អក្សរសង្ខេប អក្សរពេញនៃអដ្ឋកថា

| | | | |
|---|---|---|---|
| បរត្ថ. ថេរ. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ថេរគាថា |
| បរត្ថ. ថេរី. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ថេរីគាថា |
| អដ្ឋ. ជាត. | ជាតកដ្ឋកថា | អដ្ឋកថានៃខុទ្ទកនិកាយ | ជាតក |
| សទ្ធម្ម. មហា. | សទ្ធម្មប្បជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | មហានិទ្ទេស |
| សទ្ធម្ម. ចូឡ. | សទ្ធម្មប្បជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | ចូឡនិទ្ទេស |
| សទ្ធម្ម. បដិ. | សទ្ធម្មប្បកាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ |
| វិសុទ្ធ. អប្ប. | វិសុទ្ធជនវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | អប្បទាន |
| មធុរ. ពុទ្ធ. | មធុរត្ថវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | ពុទ្ធវង្ស |
| បរម. ចរិ. | វិមលវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | ចរិយា |
| អដ្ឋសា. សង្គ. | អដ្ឋសាលិនី | អដ្ឋកថានៃព្រះអភិធម្ម | ធម្មសង្គណី |
| សម្មោហ. វិភ. | សម្មោហវិនោទនី | អដ្ឋកថានៃព្រះអភិធម្ម | វិភង្គ |
| បរម. បញ្ច. | បរមត្ថទីបនី | អដ្ឋកថានៃព្រះអភិធម្ម | បញ្ចបករណ៍ |
| វិសុ. សីល. | វិសុទ្ធិមគ្គ | សីលនិទ្ទេស ភាគ ១ | |
| វិសុ. សមាធិ. | វិសុទ្ធិមគ្គ | សមាធិនិទ្ទេស ភាគ ២ | |
| វិសុ. បញ្ញា. | វិសុទ្ធិមគ្គ | បញ្ញានិទ្ទេស ភាគ ៣ | |
| ថៃ. | អដ្ឋកថាថៃ | | |
| ភូមា. | ឆដ្ឋសង្គាយនាភូមា | | |

គប្បីជ្រាបលេខ ដែលនៅបន្ទាប់ពីអក្សរសង្ខេប ដូច្នេះ គឺ លេខខាងដើមជាលេខភាគនៃគម្ពីរ លេខកណ្តាលជាលេខឃ្នាប លេខខាងចុងជាលេខទំព័រ ។

ឧទាហរណ៍ ៤. ៤៧៦/៤៧៨ គឺ ភាគទី ៤ ឃ្នាបទី ៤៧៦ ទំព័រទី ៤៧៨ ។

# បញ្ជីមាតិកា


| មាតិកា | ទំព័រ |
|---|---|
| ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ … … … … … … | ក |
| ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ … … … … … … … | ង |
| ឧប្បត្តិកថា … … … … … … … … … … … … | ឋ |
| អក្សរសង្ខេប និងអក្សរពេញ … … … … … … … | ជ |
| បញ្ជីមាតិកា … … … … … … … … … … … … | ម |


## មាតិកាសង្ឃាទិសេសកណ្ឌ


| | |
|---|---|
| ១. សុក្កវិស្សដ្ឋិសិក្ខាបទវណ្ណនា … … … … … … | ១ |
| ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងសេយ្យសកភិក្ខុ | ១ |
| ពន្យល់អត្ថក្នុងអនុប្បញ្ញត្តិរឿងភិក្ខុច្រើនរូប … | ៤ |
| អធិប្បាយសិក្ខាបទវិភង្គ … … … … … … | ៦ |
| សញ្ចេតនិកាសព្ទ … … … … … … … … | ៦ |
| អធិប្បាយហេតុឱ្យកើតការយល់សប្តិ ៤ យ៉ាង | ១០ |
| អធិប្បាយពាក្យថាសង្ឃាទិសេស … … … … | ១៤ |
| អធិប្បាយបទភាជនី អំពីហេតុឱ្យបញ្ចេញទឹកសុក្ក | ១៦ |
| អធិប្បាយសុទ្ធិកសង្ឃាទិសេស … … … … … | ២១ |

**មាតិកា** **ទំព័រ**


អធិប្បាយខណ្ឌចក្ក និង ពន្ធចក្កជាដើម ... ... ២៣
អធិប្បាយភាគៈ និងប្រយោគ ១១ យ៉ាង ... ... ២៨
វិនីតវត្ថុក្នុងសង្ឃាទិសេសសិក្ខាបទទី ១ ... ... ៣៧
២. កាយសំសគ្គសិក្ខាបទវណ្ណនា ... ... ... ... ... ... ៤២
ពន្យល់អត្ថក្នុងបឋមបញ្ញត្តិនៃរឿងឧទាយីភិក្ខុ ... ៤២
អធិប្បាយសិក្ខាបទវិភង្គ ... ... ... ... ... ... ៤៥
ភិក្ខុត្រូវរាគៈគ្របសង្កត់ ... ... ... ... ... ... ៤៥
អត្ថាធិប្បាយបទភាជនីយ៍ ... ... ... ... ... ... ៥០
ការចាប់ដៃជាដើម ... ... ... ... ... ... ... ... ៥០
សេចក្ដីផ្សេងគ្នានៃមតិរបស់ព្រះថេរៈ ២ រូប ... ៥៩
អធិប្បាយអាបត្តិនិងអនាបត្តិដោយលក្ខណៈ ... ៦៥
វិនីតវត្ថុក្នុងសង្ឃាទិសេសសិក្ខាបទទី ២ ... ... ៦៩
អធិប្បាយវត្ថុដែលជាអនាមាស ... ... ... ... ៧០
រតនៈ ១០ ប្រការ ... ... ... ... ... ... ... ... ៧៣
៣. ទុដ្ឋុល្លវាចាសិក្ខាបទវណ្ណនា ... ... ... ... ... ... ៨២
អធិប្បាយសិក្ខាបទវិភង្គសង្ឃាទិសេសទី ៣ ... ៨៥
អធិប្បាយបទភាជនីសង្ឃាទិសេសទី ៣ ... ... ៨៥

មាតិកា ទំព័រ

អនាបត្តិវារ ... ... ... ... ... ... ... ... ... ... ៩១
វិនីតវត្ថុក្នុងតតិយសង្ឃាទិសេស ... ... ... ... ៩២
៤. អត្តកាមបារិចរិយសិក្ខាបទវណ្ណនា ... ... ... ... ៩៤
ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងឧទាយីភិក្ខុ ... ... ៩៤
អធិប្បាយសិក្ខាបទវិភង្គចតុត្ថសង្ឃាទិសេស ... ៩៥
៥. សញ្ចរិត្តសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៩៩
ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងឧទាយីភិក្ខុ ... ... ៩៩
អធិប្បាយការប្រព្រឹត្តនិយាយដឹកនាំ ... ... ... ១០៤
អធិប្បាយស្រី ១០ ពួក ... ... ... ... ... ... ១០៧
អធិប្បាយនិក្ខេបបទរឿងប្រុសបញ្ជូនភិក្ខុ ... ... ១១១
អធិប្បាយរឿងភិក្ខុទទួលពាក្យជាដើម ... ... ... ១១៥
វិនីតវត្ថុក្នុងបញ្ចមសង្ឃាទិសេស ... ... ... ... ១២៣
៦. កុដិការសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ១២៧
ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងភិក្ខុក្នុងដែនអាឡវី ១២៧
ការចេញមាត់សូម ... ... ... ... ... ... ... ... ១២៩
ពន្យល់អត្ថក្នុងសំព័ន្ធនៃរឿងមណិកណ្ឋនាគរាជ ... ១៣៧

មាតិកា ទំព័រ


ពន្យល់អត្ថក្នុងស័ព្ទនៃរឿងសត្វមួយហ្វូងធំ ... ... ១៤០
ពន្យល់អត្ថក្នុងស័ព្ទនៃរឿងបិតារបស់រដ្ឋបាល ... ១៤២
ពន្យល់អត្ថក្នុងសិក្ខាបទវិភង្គការបូកលាបកុដិ ... ១៤៤
ផ្ទៃដីគួរសាងកុដិនិងមិនគួរសាង ... ... ... ... ១៤៩
លក្ខណៈការសាងកុដិ ... ... ... ... ... ... ... ១៥៣
ពន្យល់អត្ថក្នុងបទភាជនីយតុក្កៈធ្វើឱ្យត្រូវអាបត្តិផ្សេង ៗ ១៥៨
អនាបត្តិវារវណ្ណនា ... ... ... ... ... ... ... ... ១៦១
៧. វិហារការសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ១៦៥
ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងព្រះឆន្នៈ ... ... ១៦៥
៨. ទុដ្ឋទោសសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ២៦៨
ប្រវត្តិវេឡុវនវិហារ ... ... ... ... ... ... ... ... ២៦៨
ពន្យល់អត្ថក្នុងរឿងព្រះទព្វមល្លបុត្រ . ... ... ... ២៦៩
ពន្យល់អត្ថក្នុងរឿងព្រះមេត្តិយៈនិងព្រះភុម្មជកៈ ២៨០
ព្រះទព្វមល្លបុត្រត្រូវដេញដោលសួរ ... ... ... ២៨៤
រឿងយល់អត្ថន័យបាលីព្រះវិន័យខុស ... ... ... ២៩០
ព្រមព្រៀងគ្នាមិនបាន ... ... ... ... ... ... ... ២៩០
ពន្យល់អត្ថក្នុងសិក្ខាបទវិភង្គសង្ឃាទិសេសទី៨ ... ២៩៤

# មាតិកា ទំព័រ


អធិប្បាយរឿងអធិករណ៍មានមូលនិងមិនមានមូល ២៩៧
អធិប្បាយលក្ខណៈនៃការចោទផ្សេង ៗ ... ... ... ៣០៣
អត្ថាធិប្បាយការចោទ២និង៤យ៉ាងជាដើម ... ... ៣០៦
អធិប្បាយអ្នកចោទនិងអ្នកជាប់ចោទតាមន័យអដ្ឋកថា ៣០៩
រឿងធ្វើតាមបដិញ្ញារបស់អ្នកជាប់ចោទលជ្ជីនិងអលជ្ជី ៣១៣
អង្គរបស់អ្នកចោទនិងអ្នកជាប់ចោទ ... ... ... ៣១៥
អធិប្បាយពាក្យថាអធិករណ៍ជាដើម ... ... ... ៣១៩
ពន្យល់អត្ថក្នុងបទភាជនី ... ... ... ... ... ... ៣២៥
៩. អញ្ញភាគិយសិក្ខាបទវណ្ណនា ... ... ... ... ... ... ៣៣៣
ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងភិក្ខុមេត្តិយៈនិងភុម្មជកៈ ៣៣៣
អធិប្បាយអធិករណ៍ជារឿងដទៃនិងជារឿងនោះ ៣៣៨
ពន្យល់អត្ថក្នុងសិក្ខាបទវិភង្គផ្នែកលេស ... ... ៣៤៣
១០. សង្ឃភេទសិក្ខាបទវណ្ណនា ... ... ... ... ... ... ៣៤៧
ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងភិក្ខុទេវទត្ត ... ... ៣៤៧
បំណងរបស់ព្រះមានព្រះភាគក្នុងសេចក្ដីនេះ ... ៣៤៩

មាតិកា ទំព័រ


កប្បិយមំសៈ ... ... ... ... ... ... ... ... ... ៣៥២
ពន្យល់អត្ថក្នុងផ្នែកភិក្ខុទេវទត្តទូលសូមវត្ថុ៥ ... ៣៥៨
ពន្យល់អត្ថក្នុងផ្នែកត្រាស់ប្រជុំសង្ឃហើយទ្រង់បញ្ញត្តិសិក្ខាបទ ... ... ... ... ... ... ... ... ... ... ៣៦០
ពន្យល់អត្ថក្នុងបទភាជនីដោយកម្មប្រកបដោយធម៌ជាដើម ... ... ... ... ... ... ... ... ... ... ... ៣៦៨
១១. ភេទានុវត្តកសិក្ខាបទវណ្ណនា ... ... ... ... ... ... ៣៧២
ពន្យល់អត្ថក្នុងរឿងភិក្ខុប្រព្រឹត្តតាមភិក្ខុដែលបំបែកសង្ឃ ... ... ... ... ... ... ... ... ... ... ... ៣៧២
១២. ទុព្វចសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៣៧៤
ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងភិក្ខុឆន្នៈ ... ... ៣៧៤
១៣. កុលទូសកសិក្ខាបទវណ្ណនា ... ... ... ... ... ... ៣៨១
ពន្យល់អត្ថក្នុងរឿងភិក្ខុអស្សជិនិងភិក្ខុបុនព្វសុកៈ ៣៨១
ប្រវត្តិពួកភិក្ខុឆព្វគ្គិយៈ ... ... ... ... ... ... ... ៣៨២
អធិប្បាយលក្ខណៈ៥ មានអកប្បិយវោហារជាដើម ៣៨៥
ការវិនិច្ឆ័យអាបត្តិក្នុងការដាំដោយខ្លួនឯងជាដើម ៣៩២

**មាតិកា** **ទំព័រ**

អត្ថាធិប្បាយបុប្ផវិកត្តិ ៦ ប្រភេទ … … … … ៣៩៤
ការប្រព្រឹត្តអនាចារផ្សេង ៗ … … … … … ៤០០
ពន្យល់អត្ថក្នុងផ្នែកអ្នកកិដាគីរីជួបភិក្ខុអាគន្តុកៈ ៤០៥
ឧបាសកនិមន្តភិក្ខុអាគន្តុកៈទៅកាន់ផ្ទះ … … … ៤២០
ទ្រង់ត្រាស់ឱ្យដាក់បព្វាជនីយកម្មពួកភិក្ខុឆព្វគ្គិយ ៤១៣
អត្ថាធិប្បាយកុលទូសកកម្មមានការឱ្យផ្កាឈើជាដើម ៤១៨
ពន្យល់អត្ថបទសរុបសង្ខេបវិសេស … … … ៤២៥

## មាតិកាអនិយតកណ្ឌ

១. បឋមអនិយតសិក្ខាបទវណ្ណនា … … … … … … ៤២៩
ពន្យល់អត្ថក្នុងមូលហេតុនៃបឋមបញ្ញត្តិជាដើម ៤២៩
រឿងព្រះថេរៈជាឧទាយីស្រពអង្គុយជាមួយមាតុគ្រាម ៤៣៥
គប្បីវិនិច្ឆ័យអាបត្តិតាមបដិញ្ញារបស់ភិក្ខុ … … … ៤៣៦
២. ទុតិយអនិយតសិក្ខាបទវណ្ណនា … … … … … … ៤៤០
អធិប្បាយស្ថានទីកំបាំងធ្វើឱ្យត្រូវអាបត្តិ … … ៤៤១

មាតិកា ទំព័រ

# មាតិកានិស្សគ្គិយបាចិត្តិយកណ្ឌ

## ចីវរវគ្គទី ១

១. កឋិនសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ... ៤៤៣
ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងព្រះអានន្ទ ... ... ៤៤៣
ហេតុដែលព្រះអានន្ទជ្រាបការមករបស់ព្រះសារីបុត្តបាន ៤៤៦
ពន្យល់អត្ថក្នុងសិក្ខាបទវិភង្គការដោះកឋិន ... ... ៤៤៧
អធិប្បាយកំណើតចីវរ ៦ ប្រភេទ ... ... ... ... ៤៥២
អធិប្បាយវិធីលះបង់ចេញ និងវិធីសម្ដែងអាបត្តិ ៤៥៥
ពន្យល់អត្ថក្នុងបទភាជនីអតិរេកចីវរកន្លង ១០ ថ្ងៃ
ជាដើម ... ... ... ... ... ... ... ... ... ... ... ៤៦២
ខ្នាតចីវរដែលគួរអធិដ្ឋាននិងវិកប្ប ... ... ... ... ៤៦៤
ការអធិដ្ឋានត្រៃចីវរជាដើម ... ... ... ... ... ... ៤៦៦
ហេតុឱ្យដាច់អធិដ្ឋាន ... ... ... ... ... ... ... ៤៧១
អធិប្បាយការវិកប្បចីវរ ... ... ... ... ... ... ៤៧៧

មាតិកា ទំព័រ

២. ឧទោសិតសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៤៨៥
ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងភិក្ខុច្រើនរូប ... ៤៨៥
អនុប្បញ្ញត្តិពន្យល់អត្ថក្នុងរឿងភិក្ខុអាពាធ ... ... ៤៨៦
អធិប្បាយស្ថានទីរក្សាចីវរនិងវិធីបដិបត្តិ ... ... ៤៨៩
មតិផ្សេង ៗក្នុងស្ថានទីរក្សានិងការរក្សាចីវរ ... ៤៩២
៣. អកាលចីវរសិក្ខាបទវណ្ណនា ... ... ... ... ... ... ៥០៣
ពន្យល់អត្ថក្នុងរឿងភិក្ខុមួយរូប ... ... ... ... ៥០៣
ពន្យល់អត្ថក្នុងសិក្ខាបទវិភង្គសេចក្តីប្រាថ្នានឹងបានចីវរ ៥០៤
៤. បុរាណចីវរសិក្ខាបទវណ្ណនា ... ... ... ... ... ... ៥០៨
អធិប្បាយបុគ្គលដែលចាត់ជាញាតិនិងមិនមែនញាតិ ៥០៨
ចីវរចាស់និងការប្រើឱ្យបោក ... ... ... ... ... ៥១០
អាបត្តិនិងអនាបត្តិក្នុងការប្រើឱ្យបោក ... ... ៥១៣
៥. ចីវរបដិគ្គហណសិក្ខាបទវណ្ណនា ... ... ... ... ... ៥១៦
ពន្យល់អត្ថក្នុងសព្ទរឿងបឋមបញ្ញត្តិ ... ... ... ៥១៦
ឧទាយីភិក្ខុសូមអន្តរវាសកៈរបស់ព្រះថេរី ... ... ៥១៧

មាតិកា ទំព័រ


៦. អញ្ញាតកវិញ្ញត្តិសិក្ខាបទវណ្ណនា ... ... ... ... ... ៥២៣

ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងព្រះឧបនន្ទសក្យបុត្រ ៥២៣

កាលត្រូវចោរដណ្តើមយកចីវរទៅ ហាមធ្វើដំណើរ

ទាំងអាក្រាតកាយ ... ... ... ... ... ... ... ... ៥២៤

៧. តតុត្តរិសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៥៣២

ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងបវារណាដើម្បីនាំទៅ ៥៣២

៨. បឋមឧបក្ខដសិក្ខាបទវណ្ណនា ... ... ... ... ... ... ៥៣៧

ពន្យល់អត្ថក្នុងមូលហេតុបឋមបញ្ញត្តិ ... ... ... ៥៣៧

ពន្យល់អត្ថក្នុងសិក្ខាបទវិភង្គតម្លៃសម្រាប់ទិញចីវរ ៥៣៨

៩. ទុតិយឧបក្ខដសិក្ខាបទវណ្ណនា ... ... ... ... ... ... ៥៤៥

១០. រាជសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ... ៥៤៦

ពន្យល់អត្ថក្នុងមូលហេតុបឋមបញ្ញត្តិ ... ... ... ៥៤៦

អធិប្បាយការទាមទារនិងការឈរ ... ... ... ... ៥៥០

កប្បិយការកនិងវេយ្យាវច្ចករ ... ... ... ... ... ៥៥៤

វិធីបដិបត្តិក្នុងរឿងប្រាក់និងមាសដែលមានអ្នកប្រគេន ៥៦០

វិធីបដិបត្តិក្នុងបឹងនិងស្រះទឹកជាដើមដែលមានអ្នកប្រគេន.៥៦៣

## មាតិកាសិក្ខាបទមហាវិភង្គ ទំព័រ


វិធីបដិបត្តិក្នុងពូជផលដែលបានព្រោះអាស្រ័យ
ស្រះទឹករបស់វត្តជាដើម ... ... ... ... ... ... ៥៦៧
វិធីបដិបត្តិក្នុងទាសៈ អារាមិកជន និងបសុសត្វ
ដែលមានអ្នកប្រគេន ... ... ... ... ... ... ... ៥៧៣


## កោសិយវគ្គ


១. កោសិយសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៥៧៦
២. សុទ្ធកាឡកសិក្ខាបទវណ្ណនា ... ... ... ... ... ... ៥៤៧
៣. ទ្វេភាគសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៥៧៨
៤. ឆព្វស្សសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៥៧៩
៥. និសីទនសន្ថតសិក្ខាបទវណ្ណនា ... ... ... ... ... ៥៨១
៦. ឯឡកលោមសិក្ខាបទវណ្ណនា ... ... ... ... ... ... ៥៩២
៨. រូបិយសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៥៩៣
អធិប្បាយវត្ថុនៃនិស្សគ្គិយនិងទុក្កដ ... ... ... ... ៥៩៤
ការទទួល ការប្រើឱ្យទទួល និងវិធីបដិបត្តិក្នុងរូបិយៈ ៥៨៦
បច្ច័យដែលបានពីរូបិយៈដែលភិក្ខុទទួល មិនគួរដល់
លោកអ្នកទទួល ... ... ... ... ... ... ... ... ៥៩៩

| មាតិកា | ទំព័រ |
| --- | --- |


អត្ថនៃភិក្ខុដែលចោលរូបិយៈ ... ... ... ... ... ៦០១
អធិប្បាយការបរិភោគបច្ច័យមាន ៤ យ៉ាង ... ... ៦០៣
អធិប្បាយ ការបរិភោគ ៤ យ៉ាងទៀត ... ... ៦០៦
អធិប្បាយការលើកតម្កើងនិងការបរិភោគម្យ៉ាង ៗ២ទៀត ៦០៨
រឿងរៀនគណ្ឋៈពីមនុស្សអាក្រក់ដើម្បីអនុគ្រោះធម៌ ៦០៩
៩. រូបិយសំវោហារសិក្ខាបទវណ្ណនា ... ... ... ... ... ៦១២
ការទិញដូររូបិយៈដោយរូបិយៈជាដើម ... ... ... ៦១៣
អធិប្បាយបត្តចតុក្កៈជាឧទាហរណ៍ ... ... ... ... ៦១៦
១០. កយវិក្កយសិក្ខាបទវណ្ណនា ... ... ... ... ... ... ៦២០
អធិប្បាយការទិញនិងលក់ដែលធ្វើឱ្យត្រូវអាបត្តិ ៦២១
អធិប្បាយវិធីការផ្លាស់ប្តូរកប្បិយភណ្ឌៈ ... ... ៦២៣
អធិប្បាយអនាបត្តិវារ ... ... ... ... ... ... ... ៦២៤


## បត្តវគ្គ


១. បត្តសិក្ខាប៤៣២ទវណ្ណនា ... ... ... ... ... ... ... ៦២៩
អធិប្បាយខ្នាតបាត្រ ៣-៩ ខ្នាត ... ... ... ... ៦២៩
អធិប្បាយបាត្រដែលគួរអធិដ្ឋាននិងវិកប្ប ... ... ៦៣៤

## មាតិកាសិក្ខាបទមហាវិភង្គ ទំព័រ


អធិប្បាយការអធិដ្ឋានបាត្រ ... ... ... ... ... ... ៦៣៦

ការដាច់អធិដ្ឋានរបស់បាត្រ ... ... ... ... ... ... ៦៣៨

ការវិកប្បបាត្រ ... ... ... ... ... ... ... ... ... ៦៣៩

២. ឩនបញ្ចពន្ធនសិក្ខាបទវណ្ណនា ... ... ... ... ... ... ៦៤៣

អធិប្បាយបាត្រមានទីចង ៥ នៃជាដើម ... ... ៦៤៣

៣. ភេសជ្ជសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៦៤៩

ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងព្រះបិលិន្ទវច្ឆៈ ... ៦៤៩

អធិប្បាយវិធីបដិបត្តិក្នុងការទទួលប្រគេនភេសជ្ជៈផ្សេង ៗ ៦៥២

អធិប្បាយវិធីបដិបត្តិក្នុងទឹកដោះថ្លានិងទឹកដោះខាប់ ... ៦៥២

អធិប្បាយវិធីបដិបត្តិក្នុងភេសជ្ជៈ គឺប្រេង ... ... ៦៥៤

អធិប្បាយប្រេងធ្វើអំពីខ្លាញ់សត្វផ្សេង ៗ ... ... ៦៥៨

អធិប្បាយភេសជ្ជៈទឹកឃ្មុំ ... ... ... ... ... ... ៦៦១

អធិប្បាយភេសជ្ជៈទឹកអំពៅ ... ... ... ... ... ៦៦៥

អធិប្បាយខដែលទ្រង់អនុញ្ញាតទុកចំពោះ ៧យ៉ាង ... ៦៦៩

អធិប្បាយបទភាជនីនិងអនាបត្តិវារ ... ... ... ... ៦៧៣

៤. វស្សិកសាដិកសិក្ខាបទវណ្ណនា ... ... ... ... ... ... ៦៧៧

## មាតិកាសិក្ខាបទមហាវិភង្គ ទំព័រ


៥. ចីវរអច្ឆិន្នសិក្ខាបទវណ្ណនា ... ... ... ... ... ... ៦៨៦

ការដណ្តើមយកមកវិញរបស់ភិក្ខុដែលឱ្យចីវរ ... ៦៨៦

អធិប្បាយការសងឱ្យដល់ម្ចាស់របស់ដើមនៃភិក្ខុដែល ទទួលទៅ ... ... ... ... ... ... ... ... ... ... ៦៨៨

៦. សុត្តវិញ្ញត្តិសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៦៩១

កំណើតអំបោះ៦ប្រភេទ ... ... ... ... ... ... ៦៩១

អធិប្បាយការប្រើឱ្យជាងតម្បាញត្បាញ ដោយអំបោះ កប្បិយជាដើម ... ... ... ... ... ... ... ... ... ៦៩៣

ជាងតម្បាញ ២ នាក់ផ្លាស់ប្តូរគ្នាត្បាញ ... ... ៦៩៥

៧. មហាបេសការសិក្ខាបទវណ្ណនា ... ... ... ... ... ៦៩៩

៨. អច្ចេកចីវរសិក្ខាបទវណ្ណនា ... ... ... ... ... ... ៧០១

អធិប្បាយការកើតនៃអច្ចេកចីវរ ... ... ... ... ៧០២

៩. សាសង្កសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៧០៦

១០. បរិណតសិក្ខាបទវណ្ណនា ... ... ... ... ... ... ... ៧១២

អធិប្បាយលាភសង្ឃនិងការបង្អោនលាភសង្ឃ ... ៧១៣


ចប់ បញ្ជីមាតិកា មហាវិភង្គ

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## សង្ឃាទិសេស១៣ អនិយត២

## ទុតិយភាគ ២

# សង្ឃាទិសេស ១៣

តេរសកៈ (សង្ឃាទិសេស១៣) ដែលព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានចងក្រងទុកក្នុងលំដាប់នៃបារាជិកកណ្ឌ មានការពណ៌នាបទដែលមិនទាន់មានក្នុងកាលមុន ដូចតទៅនេះ ។

## ១. សុក្កវិស្សដ្ឋិសិក្ខាបទវណ្ណនា

### ពន្យល់អត្ថក្នុងបឋមបញ្ញត្តិ រឿងសេយ្យសកភិក្ខុ

[១] បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា សម័យនោះ ព្រះពុទ្ធដ៏មានជោគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង សេយ្យសកភិក្ខុដ៏មានអាយុ មិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយធម៌ នេះ ដូចតទៅនេះ ៖

ពាក្យថា អាយស្មា : ដ៏មានអាយុ ជាពាក្យពីរោះ ។

បទថា សេយ្យសកោ : សេយ្យសកភិក្ខុ ជាឈ្មោះរបស់ភិក្ខុរូបនោះ ។

ពាក្យថា អនភិរតោ : មិនត្រេកអរ សេចក្ដីថា ជាអ្នកមានចិត្តរវើរវាយ គឺ ត្រូវសេចក្ដីក្រហល់ក្រហាយ ព្រោះកាមរាគៈដុតរោល តែមិនប្រាថ្នាភាពជាគ្រហស្ថ ។

ពាក្យថា សោ តេន កិសោ ហោតិ : ដោយហេតុនោះ សេយ្យសកភិក្ខុ ក៏ស្គាំងស្គម សេចក្ដីថា សេយ្យសកភិក្ខុនោះ រមែងជាអ្នកស្គមស្គាំង ព្រោះភាពជាអ្នកមិនត្រេកអរនោះ ។

ក្នុងពាក្យថា អទ្ទសា ខោ អាយស្មា ឧទាយិ : ចំណែកឧទាយិត្ថេរដ៏មានអាយុ នេះ មានវិនិច្ឆ័យដូច្នេះ ៖

បទថា ឧទាយិ ជាឈ្មោះរបស់ព្រះថេរៈនោះ ។ ពិតមែន ព្រះថេរៈឈ្មោះលោឡុទាយីនេះ ជាឧបជ្ឈាយ៍របស់សេយ្យសកភិក្ខុ ជាអ្នកមានចំណែកប្រៀបដោយម្រឹគភ្នាក់ផ្អើល គឺ ជាភិក្ខុឡេះឡោះមួយរូប បណ្ដាភិក្ខុដែលតាមប្រកបហេតុនៃសេចក្ដីខ្ជិលច្រអូស មានភាពជាអ្នកត្រេកអរក្នុងការដេកលក់ជាដើម ។

បទថា កច្ចិ នោ ត្វំ : លោកមិនត្រេកអរ (នឹងប្រព្រឹត្តព្រហ្មចរិយធម៌ ) ឬអ្វី ? បានសេចក្ដីថា កច្ចិ នុ ត្វំ : លោកលះបង់ (ការប្រព្រឹត្តព្រហ្មចរិយធម៌ ) ឬហ្ន៎ ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យមានជាដើមថា យាវទត្ថំ ភុញ្ជ ដូចតទៅនេះ ៖

សេចក្ដីត្រូវការមានប្រមាណត្រឹមណា ឈ្មោះថា យាវទត្ថៈ (ពេញចំណង់ ) ។ មានពាក្យអធិប្បាយថា លោកមានសេចក្ដីប្រាថ្នាដោយភោជនប្រមាណប៉ុន្មាន, គឺ លោកត្រូវការប៉ុន្មាន, ចូរបរិភោគប៉ុណ្ណោះ, ឬថា លោកប្រាថ្នាដើម្បីសិងក្នុងពេលយប់ ឬពេលថ្ងៃ អស់

រយៈកាលប៉ុនណា, ចូរសិងអស់រយៈកាលប៉ុណ្ណោះ, លោកប្រាថ្នានូវការជម្រះកាយ ដោយដីស្អិតជាដើម ផាត់ស្បែកដោយម្សៅជាដើម ហើយងូតទឹក ប្រមាណប៉ុនណា, ចូរងូតទឹកប្រមាណប៉ុណ្ណោះ, មិនមានប្រយោជន៍ដោយបាលី អដ្ឋកថា វត្តបដិបត្តិ ឬដោយកម្មដ្ឋាន ។

ពាក្យថា យទា តេ អនភិរតិ ឧប្បជ្ជតិ : **កាលណាបើសេចក្តីអផ្សុកកើតឡើងដល់លោក** សេចក្តីថា ក្នុងកាលណា សេចក្តីអផ្សុក គឺ ភាពជាអ្នកមានចិត្តរវើរវាយ ដោយអំណាចនៃការត្រេកអរក្នុងកាមកើតដល់លោក ។

ពាក្យថា រាគោ ចិត្តំ អនុទ្ធំសេតិ : **រាគគ្របសង្កត់ចិត្តលោក** សេចក្តីថា កាមរាគៈ រមែងកម្ចាត់ទម្លាយ គឺ ធ្វើឱ្យចិត្តរាយមាយ និងធ្វើឱ្យចិត្តស្វិតស្រពោន ។

ពាក្យថា តទា ហត្ថេន ឧបក្កមិត្វា អសុចឹ មោចេហិ : **លោកចូរព្យាយាមដោយដៃ ញ៉ាំងទឹកអសុចិឱ្យឃ្លាតចេញក្នុងកាលនោះចុះ** មានសេចក្តីថា ក្នុងកាលនោះ លោកចូរយកដៃព្យាយាមធ្វើការបញ្ចេញអសុចិ, ពិតមែន ដោយការធ្វើយ៉ាងនេះ ឯកគ្គតាចិត្ត នឹងមានដល់លោក, ឧបជ្ឈាយ៍ទូន្មានលោកយ៉ាងនេះ ដូចមនុស្សល្ងង់ទូន្មានមនុស្សល្ងង់ មនុស្សឆ្កួតទូន្មានមនុស្សឆ្កួត ដូច្នោះ ។

# ពន្យល់អត្ថក្នុងអនុប្បញ្ញត្តិរឿងភិក្ខុច្រើនរូប

[២] ពាក្យថា តេសំ មុដ្ឋស្សតីនំ អសម្បជានានំ[1] និទ្ទំ ឱក្កមន្តានំ : កាលបើភិក្ខុទាំងនោះ កំពុងតែភ្លេចស្មារតីមិនដឹងខ្លួនសិងលក់ទៅ មានសេចក្តីថា កាលភិក្ខុទាំងនោះ លះសតិសម្បជញ្ញៈសិង ។ ក្នុងពាក្យនោះ មានវិនិច្ឆ័យដូច្នេះ ៖

កាលភិក្ខុទាំងឡាយកំពុងសិង ភវង្គវារៈដែលជាអព្យាក្រិតប្រព្រឹត្តទៅ, សតិសម្បជញ្ញវារៈនឹងឃ្លាតទៅ ក៏ពិតមែនហើយ តែថា ក្នុងការសិង ភិក្ខុគួរធ្វើមនសិការៈ ។ ភិក្ខុកាលនឹងសិងក្នុងពេលថ្ងៃ គប្បីសិងព្រមដោយសេចក្តីឧស្សាហ៍ថា យើងនឹងសិងរយៈវេលាដែលសក់របស់ភិក្ខុស្រង់ទឹកមិនទាន់ស្ងួត ហើយនឹងក្រោកឡើង ដូច្នេះ កាលសិងក្នុងវេលាពេលយប់ គប្បីជាអ្នកមានសេចក្តីឧស្សាហ៍សិងថា យើងនឹងលង់លក់អស់ចំណែកនៃរាត្រី ឈ្មោះមានប្រមាណប៉ុណ្ណេះ ហើយក្រោកឡើងក្នុងវេលាដែលព្រះចន្ទ ឬផ្កាយគោចរមកដល់ស្ថានទីឈ្មោះនេះ ។

ម្យ៉ាងទៀត គប្បីកំណត់កម្មដ្ឋានណាមួយ ក្នុងបណ្តាកម្មដ្ឋានទាំង ១០ មានពុទ្ធានុស្សតិជាដើម ឬកម្មដ្ឋានដទៃដែលពេញចិត្ត ហើយសឹមសិង ។ ក៏កាលភិក្ខុធ្វើយ៉ាងនោះ លោកហៅថា មានសតិសម្បជញ្ញៈ គឺ

---

១. បិដកថា មុដ្ឋស្សតី អសម្បជានា ។

មិនលះសតិនិងសម្បជញ្ញៈ សិង, ក៏ភិក្ខុទាំងនោះជាមនុស្សល្ងង់ ឡេះឡោះ មានចំណែកប្រៀបដោយម្រឹគភ្ញាក់ផ្អើល មិនបានធ្វើយ៉ាងនោះ ។ ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ទើបពោលថា តេសំ មុដ្ឋស្សតី អសម្បជានា និទ្ទំ ឱក្កមន្តានំ ដូច្នេះ ។

ពាក្យថា អត្ថិ ចេតា ចេតនា ឧបលព្ភតិ : ឯចេតនាក៏មានក្នុងកាលយល់សប្តិនោះដែរ មានសេចក្តីថា ក៏ចេតនាជាហេតុត្រេកអរក្នុងការយល់សប្តិនេះ មាន គឺមានមែន ។

ពាក្យថា អត្ថេសា ភិក្ខវេ ចេតនា សា ច ខោ អព្វោហារិកា : ម្នាលភិក្ខុទាំងឡាយ ចេតនានោះ មានមែន, ប៉ុន្តែចេតនានោះ ជាអព្វោហារិកា មានសេចក្តីថា ម្នាលភិក្ខុទាំងឡាយ ចេតនាជាហេតុត្រេកអរនេះ មាន, តែចេតនានោះឯង ឈ្មោះថា ជាអព្វោហារិក គឺមិនជាអង្គនៃអាបត្តិ ព្រោះកើតក្នុងឋានដែលមិនមែនវិស័យ ។

លុះព្រះមានព្រះភាគទ្រង់សម្តែងចេតនាក្នុងការយល់សប្តិ ជាអព្វោហារិក ដោយប្រការយ៉ាងនេះហើយ ទើបទ្រង់បញ្ញត្តិសិក្ខាបទ ព្រមទាំងអនុប្បញ្ញត្តិថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្តែងនូវសិក្ខាបទនេះយ៉ាងនេះថា សញ្ចេតនិកា សុក្កវិស្សដ្ឋិ អញ្ញត្រ សុបិនន្តា សង្ឃាទិសេសោ : ភិក្ខុក្លែងញុំាងទឹកសុក្កឱ្យឃ្លាតចេញ ត្រូវសង្ឃាទិសេស លើកលែងតែយល់សប្តិ" ដូច្នេះ ។

# អធិប្បាយសិក្ខាបទទី៦

## សញ្ចេតនិកាសំពួ

[៣] ក្នុងសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ចេតនានៃការបញ្ចេញទឹកសុក្កនោះ មាន; ហេតុនោះ ការបញ្ចេញទឹកសុក្កនោះ ទើបឈ្មោះថា សញ្ចេតនា (មានចេតនា), សញ្ចេតនានុ៎ះឯង ឈ្មោះថា **សញ្ចេតនិកា** ។ ម្យ៉ាងទៀត ចិត្តក្លែងក្នុងការបញ្ចេញទឹកសុក្កនោះ មាន; ហេតុនោះ ការបញ្ចេញទឹកសុក្កនោះ ទើបឈ្មោះថា **សញ្ចេតនិកា** (មានចិត្តក្លែង) ។ ការបញ្ចេញទឹកសុក្កៈដោយមានចិត្តក្លែង ជារបស់ភិក្ខុណា, ភិក្ខុនោះជាអ្នកដឹង គឺ រលឹកដឹងខ្លួន, និងការបញ្ចេញទឹកសុក្កនោះ របស់ភិក្ខុនោះ ជាការក្លែង គឺ ប្រព្រឹត្តល្មើសដោយបំពាន; ព្រោះហេតុនោះ ដើម្បីសម្តែងសេចក្តីតែប៉ុណ្ណោះ មិនធ្វើការអើពើក្នុងព្យញ្ជនៈ ទើបព្រះមានព្រះភាគត្រាស់បទភាជនៈនៃបទថា សញ្ចេតនិកា នោះ យ៉ាងនេះថា "ភិក្ខុក្លែង សេចក្តីថា ភិក្ខុកំពុងដឹង កំពុងចាំច្បាស់ ហើយក្លែងបំពានធ្វើឱ្យកន្លង" (ឈ្មោះថា មានចិត្តក្លែង) ។

បណ្តាបទទាំងនោះ បទថា ជានន្តោ : ភិក្ខុកំពុងដឹង បានដល់ ដឹងប្រាកដថា យើងកំពុងព្យាយាម ។

បទថា សញ្ជានន្តោ : កំពុងចាំច្បាស់ បានដល់ កំពុងដឹងខ្លួនថា

យើងកំពុងបញ្ចេញទឹកសុក្ក ។ អធិប្បាយថា ដឹងព្រមជាមួយអាការដែលព្យាយាមនិងសេចក្ដីដឹងនោះឯង ។

បទថា **ចេច្ច : ក្លែង** បានដល់ ចិត្តក្លែង គឺ មានចិត្តក្លែងដោយអំណាចចេតនា គឺសេចក្ដីត្រេកអរក្នុងការបញ្ចេញ ។

បទថា **អភិវិតរិត្វា : បំពាន** បានដល់ កាលបំពានដោយអំណាចសេចក្ដីព្យាយាមបញ្ជូនចិត្តដែលប្រាសចាកសេចក្ដីរង្កៀសទៅ ។

បទថា **វិតិក្កមោ : ធ្វើឱ្យកន្លង** មានពាក្យអធិប្បាយថា សេចក្ដីកន្លង ល្មើសណារបស់ភិក្ខុដែលប្រព្រឹត្តយ៉ាងនោះ, សេចក្ដីកន្លងល្មើសនោះ ជាសេចក្ដីចុងបំផុតនៃសញ្ចេតនិកាស័ព្ទ ។

ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ពាក្យថា សុក្កន្តិ ទស សុក្កានិ : ត្រង់ពាក្យថា ទឹកសុក្ក សេចក្ដីថា ទឹកសុក្ក មាន ១០ យ៉ាងជាដើម ក៏ដើម្បីសម្ដែងទឹកសុក្កនិងការបញ្ចេញ ក្នុងបទថា សុក្កវិស្សដ្ឋិ នេះ ដោយចំនួន និងដោយការផ្សេងគ្នានៃពណ៌ ។ ក្នុងចំនួននិងការផ្សេងគ្នានៃពណ៌, គប្បីជ្រាបការផ្សេងគ្នានៃពណ៌, មានពណ៌ខៀវជាដើម ដោយការផ្សេងគ្នានៃទីអាស្រ័យរបស់ទឹកសុក្កទាំងឡាយ និងដោយការផ្សេងគ្នានៃធាតុ ។ ការធ្វើឱ្យចេញ ឈ្មោះថា ការបញ្ចេញ ។ ក៏ពាក្យថា បញ្ចេញនេះ ដោយសេចក្ដីថា ការធ្វើឱ្យឃ្លាតចាកឋាន ។ ព្រោះហេតុ

នោះ ទើបព្រះមានព្រះភាគត្រាស់ថា “ឱ្យកម្រើកឃ្លាតចេញចាកទឹកនៃ្លង ដើម តថាគតហៅថា ឱ្យឃ្លាតចេញ” ។ ក្នុងពាក្យនោះ អាចារ្យទាំងឡាយ កំណត់ឋាននៃទឹកសុក្កទុក ៣ ចំណែក គឺ ផ្លោកនោម ១ ចង្កេះ ១ កាយ ១ បានឮថា អាចារ្យមួយរូបពោលថា ផ្លោកនោមជាឋានរបស់ទឹកសុក្ក ។ អាចារ្យមួយរូបពោលថា ចង្កេះជាឋានរបស់ទឹកសុក្ក ។ អាចារ្យមួយរូបពោលថា កាយទាំងអស់ ។

បណ្តាអាចារ្យទាំង ៣ នាក់នោះ ភាសិតរបស់អាចារ្យរូបទី ៣ ពោលត្រឹមត្រូវ ។ ព្រោះថា វៀរសក់ រោម ក្រចក និង ធ្មេញ ដែលផុតពីសាច់ និងឧច្ចារៈ បស្សាវៈ ទឹកមាត់ ទឹកសម្បោរ ព្រមទាំងស្បែកស្ងួត ឬក្រិនចេញហើយ កាយស្ទើរទាំងអស់, ក្រៅពីនោះ ស្បែក និងសាច់ ដែលលោហិតសញ្ជរបានទាំងអស់ ជាឋានរបស់កាយប្រសាទភាវៈ ជីវិតិន្ទ្រិយ និងប្រម៉ាត់ឥតស្រោម និងជាឋានរបស់ទឹកសម្ភពដូចគ្នា ។ ពិតណាស់ ទឹកសម្ភព រមែងហូរចេញតាមគុម្ពត្រចៀកទាំងពីររបស់ដំរីទាំងឡាយ ដែលត្រូវសេចក្តីតម្រេកគ្របសង្កត់ហើយ ។ និងព្រះបាទមហាសេនៈ ដែលទ្រង់របរិតដោយរាគៈ ទ្រង់មិនអាចទ្រាំងអត់ធន់កម្លាំងទឹកសម្ភពបាន ទើបទ្រង់បង្គាប់ឱ្យវះដើមដៃដោយសស្ត្រា ទ្រង់សម្តែងទឹកសម្ភព ដែលហូរចេញតាមមុខដំបៅ ដូច្នេះឯង ។

ក៏បណ្ដាវាទៈទាំងនេះ ក្នុងវាទៈរបស់អាចារ្យទីមួយ កាលភិក្ខុព្យាយាមត្រង់និមិត្ត ដោយសេចក្ដីត្រេកអរនឹងឱ្យឃ្លាត សត្វរុយតូចមួយគប្បីផឹកទឹកអសុចិមានប្រមាណប៉ុនណាបាន កាលអសុចិមានប្រមាណប៉ុណ្ណោះ គ្រាន់តែឃ្លាតអំពីផ្ទៅកនោមហូរចុះកាន់គន្លងបស្សាវៈ ទោះចេញមកខាងក្រៅក៏ដោយ មិនចេញក៏ដោយ ត្រូវអាបត្តិសង្ឃាទិសេស ។ ក្នុងវាទៈរបស់អាចារ្យទីពីរ ក៏ដូចគ្នា កាលអសុចិគ្រាន់តែឃ្លាតចាកចង្កេះហូរកាន់គន្លងបស្សាវៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ក្នុងវាទៈរបស់អាចារ្យទីបី ក៏ដូចគ្នា ព្រោះញុំាងកាយទាំងអស់ឱ្យកម្រើក កាលអសុចិគ្រាន់តែឃ្លាតចេញចាកកាយនោះ ហូរចុះកាន់គន្លងបស្សាវៈ ទោះចេញខាងក្រៅក៏ដោយ មិនចេញក៏ដោយ ត្រូវអាបត្តិសង្ឃាទិសេស ។ ក៏ឯការហូរចុះកាន់គន្លងបស្សាវៈ លោកពោលទុកក្នុងការបញ្ចេញទឹកសុក្កនេះ ក៏ព្រោះជារបស់ដែលអ្នកណា ៗ មិនអាចនឹងទប់ស្កាត់ ឃាំងទុកក្នុងចន្លោះបាន ។ ពិតមែន អសុចិឃ្លាតចាកឋានហើយ រមែងចុះកាន់គន្លងបស្សាវៈពិតប្រាកដ; ព្រោះដូច្នោះ ក្នុងការបញ្ចេញទឹកសុក្កនេះ គប្បីជ្រាបអាបត្តិ ដោយហេតុគ្រាន់តែឱ្យឃ្លាតចាកឋានប៉ុណ្ណោះ ។ និងអាបត្តិនុ៎ះឯង រមែងមានដល់ភិក្ខុដែលព្យាយាមត្រង់និមិត្តប៉ុណ្ណោះ ។ ចំណែកក្នុងការធ្វើហត្ថបរិកម្ម បាទបរិកម្ម និងគត្តបរិកម្ម ( ប្របាច់ដៃជើង ) ទោះបីជាអសុចិឃ្លាត ក៏មិនត្រូវអាបត្តិ ។ នេះជាសេចក្ដីវិនិច្ឆ័យទូទៅនៃអាចារ្យទាំងពួង ។

## អធិប្បាយហេតុឱ្យកើតការយល់សប្តិ ៤ យ៉ាង

ក្នុងពាក្យថា អញ្ញត្រ សុបិនន្តា : លើកលែងតែយល់សប្តិ នេះមានវិនិច្ឆ័យដូច្នេះ ៖

សុបិនន្ទុំះឯង ឈ្មោះថា សុបិនន្តៈ មានអធិប្បាយថា វៀរលែង គឺលើកលែងតែការយល់សប្តិនោះចេញទៅ ។ ក៏ឯបុគ្គលកាលនឹងយល់សប្តិនោះ រមែងយល់សប្តិព្រោះហេតុ ៤ ប្រការ គឺ ព្រោះធាតុកម្រើក១ ព្រោះធ្លាប់ជ្រាបមកអំពីមុន១ ព្រោះទេវតាបណ្តាល១ ព្រោះបុព្វនិមិត្ត១ ។

បណ្តាហេតុ ៤ យ៉ាងនោះ អ្នកមានធាតុកម្រើក ព្រោះប្រកបដោយបច្ច័យ ដែលធ្វើឱ្យប្រម៉ាត់ជាដើមកម្រើក ឈ្មោះថា រមែងយល់សប្តិ ព្រោះធាតុកម្រើក ។ និងកាលយល់សប្តិ រមែងយល់សប្តិផ្សេង ៗ ដូចជាធ្លាក់ពីលើភ្នំ ដូចហោះទៅតាមអាកាស និងដូចត្រូវម្រឹគកាច ដំរីកាច និងចោរជាដើមដេញតាម ។ កាលយល់សប្តិ ព្រោះធ្លាប់ជ្រាបមកអំពីមុន ឈ្មោះថា រមែងយល់សប្តិដល់អារម្មណ៍ដែលខ្លួនធ្លាប់សោយមកហើយក្នុងកាលមុន ។ ពួកទេវតា រមែងនាំអារម្មណ៍មានប្រការផ្សេង ៗ ចូលទៅដើម្បីសេចក្តីចម្រើនខ្លះ ដើម្បីសេចក្តីសាបសូន្យខ្លះ ព្រោះជាអ្នកប្រាថ្នា សេចក្តីចម្រើនខ្លះ ព្រោះជាអ្នកប្រាថ្នាសេចក្តីសាបសូន្យខ្លះ ដល់បុគ្គលដែលយល់សប្តិ ព្រោះទេវតាបណ្តាល អ្នកនោះរមែងយល់សប្តិឃើញអារម្មណ៍ទាំងនោះ ដោយអានុភាពរបស់ពួកទេវតា

នោះ ។ កាលបុគ្គលយល់សប្តិ ព្រោះបុព្វនិមិត្ត ឈ្មោះថា រមែងយល់សប្តិដែលជាបុព្វនិមិត្តនៃសេចក្តីចម្រើនខ្លះ នៃសេចក្តីសាបសូន្យខ្លះ ដែលត្រូវការកើតឡើង ដោយអំណាចនៃបុណ្យនិងបាប ដូចមាតារបស់ព្រះពោធិសត្វទ្រង់ព្រះសុបិននិមិត្តក្នុងការដែលនឹងត្រូវបានព្រះឱរស ដូច្នោះ, ដូចព្រះពោធិសត្វ ទ្រង់មហាសុបិន ៥ ប្រការ និងដូចព្រះបាទបសេនទិកោសលទ្រង់ព្រះសុបិន ១៦ ប្រការ ដូច្នោះឯង ។

បណ្តាការយល់សប្តិ ៤ យ៉ាងនោះ ការយល់សប្តិ ព្រោះធាតុកម្រើក និងព្រោះធ្លាប់ជ្រាបមកពីកាលមុន មិនពិតទេ ។ ការយល់សប្តិព្រោះទេវតាបណ្តាល ពិតក៏មាន មិនពិតក៏មាន, ព្រោះថា ពួកទេវតាក្រោធហើយ ប្រាថ្នានឹងឱ្យវិនាសដោយឧបាយ ទើបសម្តែងឱ្យឃើញវិបរិតទៅខ្លះ ។ ចំណែកការយល់សប្តិ ព្រោះបុព្វនិមិត្ត ជាសេចក្តីពិតដោយចំណែកតែមួយនេះឯង ។ សេចក្តីផ្សេងគ្នានៃការយល់សប្តិ សូម្បីសេចក្តីផ្សេងគ្នានៃមូលហេតុទាំង ៤ យ៉ាងនេះ លាយឡំគ្នាក៏មាន ដូចគ្នា ។ ក៏ឯការយល់សប្តិទាំង ៤ យ៉ាងនេះ ព្រះសេក្ខៈ និងបុថុជ្ជនប៉ុណ្ណោះ រមែងយល់សប្តិ ព្រោះលះវិបល្លាសមិនបាន ។ ព្រះអសេក្ខៈទាំងឡាយ រមែងមិនយល់សប្តិ ព្រោះលោកលះវិបល្លាសបានហើយ ។

សួរថា ក៏បុគ្គលកាលយល់សប្តិនោះ ដេកលក់យល់សប្តិ ឬភ្ញាក់យល់សប្តិ ឬថា មិនដេកលក់មិនភ្ញាក់យល់សប្តិ ។

ឆ្លើយថា ក្នុងរឿងការយល់សប្តិនេះ លោកគួរពោលបន្ថែមត្រឹមតែបន្តិចបន្តួចទៀត ។ គ្រាដំបូង បើអ្នកដេកលក់យល់សប្តិ ក៏ត្រូវជំទាស់នឹងព្រះអភិធម្ម ។ ព្រោះថា អ្នកដេកលក់ដោយភវង្គចិត្ត ។ ភវង្គចិត្តនោះ មិនមានរូបនិមិត្តជាដើមជាអារម្មណ៍ ឬសម្បយុត្តដោយរាគៈជាដើមទេ ។ ក៏កាលបុគ្គលយល់សប្តិ ចិត្តទាំងឡាយដូច្នេះ រមែងកើតឡើងបាន ។ បើបុគ្គលភ្ញាក់យល់សប្តិ ក៏ត្រូវជំទាស់នឹងព្រះវិន័យ ។ ព្រោះថា អ្នកភ្ញាក់ យល់សប្តិឃើញវត្ថុណា, គេឃើញវត្ថុនោះ ដោយសព្វោហារិកចិត្ត* (ដោយចិត្តតាមប្រក្រតី) ។ ក៏ឈ្មោះថា អនាបត្តិរមែងមិនមាន ព្រោះការកន្លងល្មើសដែលភិក្ខុធ្វើដោយសព្វោហារិកចិត្ត តែកាលអ្នកកំពុងយល់សប្តិធ្វើការកន្លងល្មើស ជាអនាបត្តិដោយចំណែកតែមួយពិត ។ បើបុគ្គលយល់សប្តិ ក្នុងពេលមិនដេកលក់ មិនភ្ញាក់ ឈ្មោះថា អ្នកណា ៗ មិនអាចយល់សប្តិបាន និងកាលបើយ៉ាងនោះ ការយល់សប្តិក៏នឹងត្រូវមិនមានពិត, នឹងមិនមានក៏ទេ ។ តើព្រោះហេតុអ្វី ? ព្រោះអ្នកដេកលក់ដូចស្វាដេកលក់ ទើបយល់សប្តិ ។ សមពិតដូចពាក្យដែលព្រះនាគសេនត្ថេរៈ ពោលទុកថា "មហាបពិត្រ អ្នកត្រូវសេចក្តីលង់លក់ដូចស្វាគ្របសង្កត់ ទើបយល់សប្តិនុ៎ះឯង" ។

* វិមតិវិនោទនីដីកា, សព្វោហារិកចិត្តេនាតិ បដិពុទ្ធស្ស បកតីវិថីចិត្តេន ប្រែថា បទថា ដោយសព្វោហារិកចិត្ត នោះ គឺ ដោយវិថីចិត្តតាមប្រក្រតីរបស់អ្នកភ្ញាក់ ។

ពាក្យថា អ្នកត្រូវសេចក្ដីលង់លក់ដូចស្វា គឺ ប្រកបដោយការដេកលក់ដូចស្វា ។ ឧបមាដូច ការដេកលក់របស់ស្វា ផ្លាស់ប្ដូរហ័សយ៉ាងណា, ការលក់ណា ផ្លាស់ប្ដូរហ័ស ព្រោះដេរដាស់ដោយចិត្តជាកុសលជាដើមរឿយ ៗ ក៏យ៉ាងនោះ គឺ មានការភ្ញាក់ឡើងអំពីភវង្គរឿយ ៗ ក្នុងពេលដេកលក់ណាប្រព្រឹត្តទៅ បុគ្គលនោះប្រកបដោយការលង់លក់នោះ រមែងយល់សប្តិ បានព្រោះហេតុនោះ ការយល់សប្តិនេះទើបជាកុសលខ្លះ ជាអកុសលខ្លះ ជាអព្យាក្រិតខ្លះ ។ បណ្ដាការយល់សប្តិ ៣ យ៉ាងនោះ ការយល់សប្តិរបស់អ្នកដែលយល់សប្តិថា កំពុងធ្វើការថ្វាយបង្គំព្រះចេតិយ ស្ដាប់ធម៌និងសម្ដែងធម៌ជាដើម គប្បីជ្រាបថាជាកុសល, របស់អ្នកដែលយល់សប្តិថា កំពុងធ្វើបាប មានការសម្លាប់សត្វជាដើម គប្បីជ្រាបថា ជាអកុសល, ការយល់សប្តិដែលផុតពីអន្តពីរនេះ គប្បីជ្រាបថា ជាអព្យាក្រិត ក្នុងខណៈនៃអាវជ្ជនចិត្ត និងតទាលម្ពណចិត្ត ។ ការយល់សប្តិនោះ មិនអាចនាំបដិសន្ធិមកបាន ព្រោះចេតនានៃវត្ថុមានកម្លាំងខ្សោយ តែក្នុងបវត្តិកាល ដែលកុសលនិងអកុសលពួកដទៃទំនុកបម្រុងហើយ រមែងឱ្យវិបាកបាន នឹងឱ្យវិបាកបានក៏ពិតមែនហើយ តែថា ចេតនាក្នុងការយល់សប្តិ ក៏ចាត់ជាអព្វោហារិកពិត ព្រោះកើតក្នុងឋានដែលមិនមែនវិស័យ ។ ព្រោះហេតុនោះ ទើបព្រះឧបាលីពោលថា វៀរលែងតែយល់សប្តិ ។

# អធិប្បាយពាក្យថា សង្ឃាទិសេស

ពាក្យថា សង្ឃាទិសេស ជាឈ្មោះរបស់កងអាបត្តិនេះ ។ ព្រោះហេតុនោះ អ្នកសិក្សាគប្បីជ្រាបសម្ព័ន្ធក្នុងសិក្ខាបទនេះយ៉ាងនេះថា ការបញ្ចេញទឹកសុក្ក មានសេចក្ដីតម្រេក វៀរការយល់សប្តិយ៉ាងណា, យ៉ាងនេះជាកងនៃអាបត្តិឈ្មោះសង្ឃាទិសេស ។ ក៏ឯសេចក្ដីចំពោះពាក្យក្នុងបទថា សង្ឃាទិសេស នេះថា សង្ឃដែលភិក្ខុគប្បីប្រាថ្នាក្នុងកម្មខាងដើម និងក្នុងកម្មដែលសល់នៃកងអាបត្តិនោះ ; ព្រោះដូច្នោះ កងអាបត្តិនោះទើបឈ្មោះថា សង្ឃាទិសេស ។ មានពាក្យអធិប្បាយយ៉ាងណា ? មានពាក្យអធិប្បាយថា ភិក្ខុត្រូវអាបត្តិនេះហើយ គប្បីប្រាថ្នាសង្ឃ ដើម្បីប្រយោជន៍ដល់បរិវាស ក្នុងកម្មខាងដើមនៃការចេញចាកអាបត្តិរបស់អ្នកប្រាថ្នានឹងចេញ និងដើម្បីប្រយោជន៍ដល់ការឱ្យមានត្ត ឬ ដើម្បីប្រយោជន៍ដល់ការឱ្យមានត្ត រួមជាមួយនឹងមូលាយបដិកស្សនា ក្នុងកម្មជាកណ្ដាល ដើម្បីប្រយោជន៍ដល់អព្ភានក្នុងកម្មជាទីបំផុត ដែលសល់អំពីកម្មជាខាងដើម ព្រោះថា បណ្ដាកម្មទាំងនេះ កម្មសូម្បីតែមួយ វៀរសង្ឃចេញហើយ អ្នកណា ៗ មិនអាចនឹងធ្វើបាន ។ សង្ឃដែលភិក្ខុគប្បីប្រាថ្នាក្នុងកម្មខាងដើម និងកម្មដ៏សេសនៃកងអាបត្តិនោះ; ព្រោះដូច្នោះ កងអាបត្តិនោះ ទើបឈ្មោះថា សង្ឃាទិសេស ។

ក៏ដើម្បីមិនអើពើក្នុងព្យញ្ជនៈ សម្ដែងតែសេចក្ដីប៉ុណ្ណោះ ទើប

ព្រះមានព្រះភាគត្រាស់បទភាជនៈនៃបទថា សង្ឃាទិសេសនោះ ដូច្នេះថា "សង្ឃតែម្យ៉ាង ដែលឱ្យនូវបរិវាស ព្រោះអាបត្តិនោះ ត្រឡប់សើរើចាកមូលាបត្តិ ឱ្យនូវមានត្ត ឱ្យនូវអព្ភាន, មិនមែនភិក្ខុច្រើនរូប មិនមែនបុគ្គលតែ ១ រូប ; ព្រោះហេតុនោះ បានជាតថាគតហៅថា សង្ឃាទិសេស" ។ និងត្រាស់ហេតុនៃពាក្យទុកក្នុងគម្ពីរបរិវារៈថា ៖

> "សិក្ខាបទណា ដែលតថាគតហៅថា សង្ឃាទិសេស, អ្នកចូរប្រុងស្ដាប់សិក្ខាបទនោះ ដូចសម្ដែងតទៅនេះ ។ សង្ឃឱ្យបរិវាស ទាញមកដាក់ក្នុងមូលាបត្តិ ឱ្យមានត្ត ឱ្យអព្ភាន ព្រោះហេតុនោះ សិក្ខាបទនុ៎ះ តថាគតហៅថា សង្ឃាទិសេស"[១] ។

ក៏វុដ្ឋានវិធី មានការឱ្យបរិវាសជាដើម ក្នុងកងអាបត្តិនោះ មកហើយ ដោយពិស្ដារក្នុងសមុច្ចយក្ខន្ធកៈ ខ្ញុំព្រះករុណានឹងពណ៌នាវុដ្ឋានវិធីទាំងនោះ ក្នុងសមុច្ចយក្ខន្ធកៈនោះឯង ។

ពីរបទថា តស្សេវ វា **អាបត្តិ និកាយស្ស : ជាឈ្មោះរបស់កងអាបត្តិនោះឯង** មានសេចក្ដីថា (ម្យ៉ាងទៀត កម្មជាឈ្មោះសម្រាប់ហៅ) ប្រជុំនៃអាបត្តិនោះឯង ។ ក្នុងព្រះបាលីនោះ អាបត្តិនេះ មានត្រឹមតែមួយប៉ុណ្ណោះ ក៏ពិតមែនហើយ, តែថា និកាយសព្ទលោកពោលដោយ រុឡ្ហិ សព្ទ ឬដោយវោហារដែលហៅចំណែកទាំងឡាយរួមគ្នា ដូចខន្ធសព្ទក្នុងពាក្យថា វេទនាខន្ធមួយ វិញ្ញាណក្ខន្ធមួយ ដូច្នេះជាដើម ។

---

១. វិន. បរិ. គាថាសង្គណិក. ១៣. ១១៩/១៣៥ ។

# អធិប្បាយបទភាជនី អំពីហេតុឱ្យបញ្ចេញទឹកសុក្ក

[៤] លុះព្រះមានព្រះភាគទ្រង់ចែកសិក្ខាបទ ដែលព្រះអង្គឧទ្ទេសទុកតាមលំដាប់យ៉ាងនោះហើយ ឥឡូវនេះ ទើបត្រាស់ពាក្យថា អជ្ឈត្តរូបេ មោចេតិ : ភិក្ខុញ៉ាំងទឹកសុក្កឱ្យឃ្លាតចេញក្នុងរូបខាងក្នុង (អវយវៈខ្លួនឯង)ជាដើម ដើម្បីសម្តែងឧបាយ កាលសេចក្តីប្រាថ្នា និងវត្ថុនៃសេចក្តីប្រាថ្នារបស់ភិក្ខុ ដែលដល់ការបញ្ចេញទឹកសុក្កៈនេះ ។

ពិតមែន ក្នុងចំណែកទាំង ៤ មានឧបាយជាដើមនេះ ឧបាយទ្រង់សម្តែងហើយដោយ ៤ បទ មានអជ្ឈត្តរូបជាដើម ព្រោះថា ភិក្ខុគប្បីបញ្ចេញក្នុងរូបខាងក្នុងខ្លះ ក្នុងរូបខាងក្រៅខ្លះ ក្នុងរូបទាំងពីរខ្លះ គប្បីពើងចង្កេះក្នុងអាកាសបញ្ចេញខ្លះ ។ ឧបាយដទៃក្រៅអំពីនេះ មិនមាន ។ ក្នុងឧបាយនោះ ភិក្ខុព្យាយាមបញ្ចេញក្នុងរូបក្តី ព្យាយាមបញ្ចេញដោយរូបក្តី គប្បីជ្រាបថា "បញ្ចេញក្នុងរូបទាំងអស់នោះ ព្រោះថា កាលមានរូប ទើបលោកបញ្ចេញបាន, មិនមានរូប បញ្ចេញមិនបាន ដូច្នេះឯង ។

ចំណែកកាលទ្រង់សម្តែងដោយ ៥ បទ មានរាគៈឧបត្ថម្ភជាដើម ។ ពិតមែន កាលអង្គជាតិណា គួរដល់ការងារមាន ភិក្ខុទើបបញ្ចេញបាន, អង្គជាតិនោះ រមែងជាអវយវៈគួរដល់ការងារ ក្នុងកាលដែលរាគៈឧបត្ថម្ភជាដើម (ក្នុងវេលាមានសេចក្តីតម្រេកជំនួយកម្លាំងជាដើម) កាលដទៃក្រៅអំពីនេះ រមែងមិនមានព្រោះថា វៀរចាកកាលដែល

ភាគៈឧបត្ថម្ភជាដើមនោះចេញហើយ កាលផ្សេង ៗមានពេលព្រឹកជាដើម នឹងជាទីកំណត់ ក្នុងការឱ្យឃ្លាតមិនបានទេ ។ សេចក្តីប្រាថ្នាទ្រង់សម្តែងដោយ ១០ បទ មានបទថា អារោគ្យត្ថាយ ជាដើម ។ ពិតមែន ភិក្ខុរមែងឱ្យឃ្លាតតាមប្រភេទនៃសេចក្តីប្រាថ្នាបែបនេះ, មិនមែនដោយប្រការយ៉ាងដទៃទេ, ចំណែកវត្ថុនៃសេចក្តីប្រាថ្នាទី ៩ ទ្រង់សម្តែងដោយ ១០ បទ មាននីលបទជាដើម ។ ពិតមែន ភិក្ខុកាលនឹងសាកល្បង រមែងសាកល្បងដោយអំណាចនៃពណ៌ខៀវជាដើម យ៉ាងណាមួយ, ពណ៌ដទៃផុតពីពណ៌ទាំងនោះទៅ រមែងមិនមាន ដូច្នេះឯង ។

[៥] តពីនេះទៅ ព្រះមានព្រះភាគត្រាស់ពាក្យថា អជ្ឈត្តរូបេតិ អជ្ឈត្តឧបាទិន្នរូបេ : ត្រង់ពាក្យថា ក្នុងរូបខាងក្នុងសេចក្តីថា ក្នុងរូបដែលមានវិញ្ញាណចូលទៅអាស្រ័យនៅជាខាងក្នុងជាដើម ដើម្បីប្រកាសបទទាំងឡាយ មានអជ្ឈត្តរូបបទជាដើមទាំងនេះឯង ។ បណ្តាបទទាំងនោះ បទថា អជ្ឈត្តំ ឧបាទិន្នរូបេ គឺក្នុងរូបផ្សេង ៗ មានដៃជាដើមរបស់ខ្លួន ។

បទថា ពហិទ្ធា ឧបាទិន្នេ : ក្នុងរូបដែលមានវិញ្ញាណក្តី ជាខាងក្រៅ គឺ ក្នុងរូបបែប( អជ្ឈត្ត )ដូចគ្នានោះ ដែលជារបស់អ្នកដទៃ ។

បទថា អនុបាទិន្នេ : ក្នុងរូបដែលឥតវិញ្ញាណក្តី គឺ ក្នុងរូប

ផ្សេង ៗ មានប្រយោជន៍នៃសោទ្វារជាដើម ។

បទថា ឥធុភយេ : **ក្នុងរូបខាងក្នុងនិងរូបខាងក្រៅ** គឺ ក្នុងរូបរបស់ខ្លួន និងរបស់អ្នកដទៃ ។ ការឱ្យទឹកសុក្កឃ្លាត ដែលព្រះមានព្រះភាគត្រាស់ដោយអំណាចសេចក្ដីព្យាយាមក្នុងរូបទាំងពីរ ។ ការឱ្យទឹកសុក្កឃ្លាត រមែងមានបាន សូម្បីក្នុងសេចក្ដីព្យាយាមរួមគ្នាដោយរូបរបស់ខ្លួន និងដោយអនុបាទិន្នរូប ។

ពីរបទថា អាកាសេ វាយមន្តស្ស : **ដែលកំពុងព្យាយាមទៅក្នុងអាកាស** សេចក្ដីថា មិនព្យាយាមដោយរូបអ្វីឡើយ គ្រាន់អង្គជាតិទៅមកដោយប្រយោគ គឺ ការពើងចង្កេះក្នុងអាកាសតែម្យ៉ាង ។

បទថា រាគូបត្ថម្ភេ : **ព្រោះសេចក្ដីឧបត្ថម្ភដោយរាគៈ** សេចក្ដីថា ក្នុងវេលាអង្គជាតិកើតសេចក្ដីតម្រេក ព្រោះរាគៈមានកម្លាំង ឬព្រោះសេចក្ដីតម្រេក ។ មានអធិប្បាយថា កាលអង្គជាតិកើតសេចក្ដីរឹងឡើងហើយ ។

ពីរបទថា កម្មនិយំ ហោតិ សេចក្ដីថា អង្គជាតិជាអវយវៈ គួរដល់ការងារក្នុងការឱ្យឃ្លាត គឺ សមគួរដល់ការព្យាយាម ក្នុងអជ្ឈត្តរូបជាដើម ។

បទថា ឧច្ចាលិង្គបាណកទដ្ឋុបត្ថម្ភេ : ព្រោះសេចក្តីឧបត្ថម្ភដោយជន្លូវរមាស់ពេល សេចក្តីថា កាលអង្គជាតិត្រូវឧបត្ថម្ភឱ្យកើតតម្រេក ព្រោះជន្លូវរមាស់ពេល ។ ដែលឈ្មោះថា ជន្លូវរមាស់ ជាសត្វតូច ៗ មានពោម, អង្គជាតិ ដែលពោមរបស់សត្វតូច ៗ ទាំងនោះពាល់ត្រូវ ក៏រមាស់ហើយ (អង្គជាតិ)ឡើងរឹង ។ ក្នុងបាលីនោះ ព្រះមានព្រះភាគត្រាស់ថា "ព្រោះជន្លូវរមាស់ពេល" (ក៏) ព្រោះពោមទាំងនោះរមែងសម្រេចដូចទិចអង្គជាតិ ។ តែដោយសេចក្តីមានអធិប្បាយថា ព្រោះត្រូវពោមរបស់ជន្លូវរមាស់ចុចឬចាក់ ។

ពាក្យថា អរោគោ ភវិស្សាមិ : ដើម្បីប្រយោជន៍មិនឱ្យមានរោគ សេចក្តីថា យើងឱ្យទឹកសុក្កឃ្លាតហើយនឹងជាអ្នកមិនមានរោគ ។

ពាក្យថា សុខវេទនំ ឧប្បាទេស្សាមិ : អញនឹងញ៉ាំងសុខវេទនាឱ្យកើតឡើង សេចក្តីថា សុខវេទនាយ៉ាងណា រមែងមានព្រោះការឱ្យឃ្លាត គឺ ព្រោះកើតការបញ្ចេញ និងព្រោះទឹកសុក្កឃ្លាតហើយជាបច្ច័យ, យើងនឹងញ៉ាំងសុខវេទនានោះ ឱ្យកើតឡើង ។

ពាក្យថា ភេសជ្ជំ ភវិស្សតិ : ទឹកសុក្កនេះនឹងបានជាថ្នាំ សេចក្តីថា ទឹកសុក្កដែលយើងឱ្យឃ្លាតហើយនេះ នឹងជាថ្នាំប្រភេទណាមួយនោះឯង ។

ពាក្យថា ធានំ ធស្សាមិ : អញនឹងឱ្យទឹកសុក្កជាទាន សេចក្ដីថា យើងធ្វើឱ្យឃ្លាតហើយ នឹងឱ្យទានដល់សត្វតូច ៗ មានរុយនិងស្រមោចជាដើម ។

ពាក្យថា បុញ្ញំ ភវិស្សតិ : ទឹកសុក្កនេះនឹងជាបុណ្យ សេចក្ដីថា កាលយើងបញ្ចេញឱ្យជាទានដល់រុយជាដើម នឹងជាបុណ្យ ។

ពាក្យថា យញ្ញំ យជិស្សាមិ : អញនឹងបូជាទឹកសុក្កជាគ្រឿងយញ្ញ សេចក្ដីថា យើងធ្វើឱ្យឃ្លាតហើយ នឹងបូជាយញ្ញដល់ពួករុយជាដើម មានអធិប្បាយថា យើងនឹងពោលបទមន្តយ៉ាងណាមួយ ហើយឱ្យ ។

ពាក្យថា សគ្គំ គមិស្សាមិ : អញនឹងទៅកាន់ស្ថានសួគ៌ សេចក្ដីថា យើងនឹងទៅឋានសួគ៌ ដោយការបញ្ចេញឱ្យទានដល់ពួករុយជាដើម ដោយបុណ្យ ឬដោយយញ្ញវិធី ។

ពាក្យថា វីជំ ភវិស្សតិ : ទឹកសុក្កនឹងជាពូជ សេចក្ដីថា នឹងជាពូជដើម្បីទារក ជាអ្នកបន្តវង្សត្រកូល ។ អធិប្បាយថា រមែងបញ្ចេញដោយប្រាថ្នាយ៉ាងនេះថា បុត្រនឹងកើតដោយពូជរបស់យើងនេះ ។

បទថា វីមំសត្ថាយ : អញនឹងល្បងមើល គឺ ដើម្បីត្រូវការដឹង ។

ក្នុងពាក្យថា នីលំ ភវិស្សតិ : ទឹកសុក្កនឹងជាពណ៌ខៀវជាដើម

បណ្ឌិត គប្បីជ្រាបសេចក្ដីយ៉ាងនេះថា យើងនឹងដឹងមុនថា ទឹកសុក្កដែលយើងបញ្ចេញហើយ នឹងជាពណ៌ខៀវ ឬពណ៌យ៉ាងណាមួយ មានពណ៌លឿងជាដើម ។

បទថា **ចិត្តាធិប្បាយោ : ភិក្ខុមានបំណងក្នុងការលេង** គឺ ខ្វល់ខ្វាយក្នុងការលេង ។ មានពាក្យអធិប្បាយថា ភិក្ខុរមែងបញ្ចេញលេងដោយសេចក្ដីប្រាថ្នានោះ ៗ ។

## អធិប្បាយសុទ្ធិកសង្ឃាទិសេស

[៦] ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងអាការដែលភិក្ខុឱ្យទឹកសុក្កឃ្លាត ត្រូវអាបត្តិ និងចំនួនប្រភេទអាបត្តិដោយអំណាចនៃបទទាំងអស់នោះ ក្នុងព្រះតម្រាស់ដែលត្រាស់ទុកថា អជ្ឈត្តរូបេ មោចេតិ ជាដើម ទើបត្រាស់ដោយព្រះតម្រាស់ មានជាដើមថា "ភិក្ខុគិតចំពោះរូបខាងក្នុងក៏ព្យាយាមទាល់តែទឹកសុក្កឃ្លាតចេញត្រូវអាបត្តិសង្ឃាទិសេស" ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា ចេតេតិ សេចក្ដីថា រមែងមានចំណង់ក្នុងចិត្តថា ទឹកសុក្កចូរឃ្លាត ដោយចេតនាដែលត្រេកអរក្នុងការឱ្យឃ្លាត ។

បទថា ឧបក្កមតិ សេចក្ដីថា រមែងធ្វើសេចក្ដីព្យាយាម ដ៏សមគួរដល់ការតាំងចិត្តនោះ ។

បទថា **មុច្ចតិ** សេចក្តីថា កាលភិក្ខុមានតម្រេកយ៉ាងនោះ ព្យាយាម ដោយការព្យាយាមដែលសមគួរដល់ការមានតម្រេកនោះ ទឹកសុក្ករមែងឃ្លាតចាកឋាន ។

ពាក្យថា **អាបត្តិ សង្ឃាទិសេសស្ស** សេចក្តីថា រមែងត្រូវអាបត្តិឈ្មោះសង្ឃាទិសេស ដល់ភិក្ខុនោះ ដោយអង្គទាំង ៣ នេះ ។ សូម្បីក្នុង២៨ បទដ៏សេសមានបទថា **ពហិទ្ធារូបេ** ជាដើម ក៏ន័យនេះ ។

ក៏ក្នុងបញ្ចកៈទាំង ៤ នេះ បណ្ឌិតគប្បីនាំអាបត្តិពីរពាន់ចេញមកសម្តែង ។ សម្តែងយ៉ាងណា ? គឺ កាលភិក្ខុបញ្ចេញទឹកសុក្កពណ៌ខៀវដើម្បីប្រយោជន៍មិនឱ្យមានរោគ ក្នុងវេលាកើតសេចក្តីតម្រេក ក្នុងរូបខាងក្នុងជាដំបូង រមែងត្រូវអាបត្តិតែមួយ, ជាអាបត្តិ ៩ ទៀត ដោយអំណាចបញ្ចេញទឹកសុក្កពណ៌លឿងជាដើម ក្នុងរូបខាងក្នុងនុ៎ះឯង ដើម្បីប្រយោជន៍មិនឱ្យមានរោគ ក្នុងវេលាមានសេចក្តីតម្រេក ; ដូច្នោះ ទើបរួមជាអាបត្តិ ១០ ។ ដូចឧបមាថា ដើម្បីប្រយោជន៍មិនឱ្យមានរោគ មានអាបត្តិ ១០ យ៉ាងណា, ដើម្បីប្រាថ្នា ៩ បទ មានសុខបទជាដើម ក៏មានអាបត្តិ ៩០ ព្រោះចែកចេញទៅក្នុងមួយបទ ៗ ជាអាបត្តិ ១០ ៗ ដូច្នោះ ។ អាបត្តិ ៩០ ទាំងនេះ បូកនិងអាបត្តិពីមុន ១០ ដោយប្រការយ៉ាងនេះ; ដូច្នោះ ទើបត្រូវអាបត្តិ ១០០ ក្នុងវេលាកើតតម្រេកដំបូង ។

ដូចក្នុងវេលាកើតតម្រេក មានអាបត្តិ ១០០ យ៉ាងណា, សូម្បីក្នុងឧបត្ថម្ភ ៤ យ៉ាង មានឈើឧច្ចារៈជាដើម ក៏មានអាបត្តិ ៤០០ ព្រោះចែកឧបត្ថម្ភតែម្យ៉ាង ៗ ចេញទៅជាអាបត្តិ ១០០ ៗ ក៏យ៉ាងនោះដែរ ។ អាបត្តិទាំង ៤០០ នេះ និងអាបត្តិពីមុន ១០០ ដូចពោលមកនេះ ទើបជាអាបត្តិ ៥០០ ដោយអំណាចនៃការឧបត្ថម្ភ ៥ យ៉ាង, ក្នុងរូបខាងក្នុងជាដំបូង ។ ក្នុងរូបខាងក្នុងមានអាបត្តិ ៥០០ យ៉ាងណា, ក្នុងរូបខាងក្រៅ ក៏មានអាបត្តិ ៥០០ ក្នុងរូបខាងក្នុងនិងរូបខាងក្រៅ ក៏មានអាបត្តិ ៥០០, កាលភិក្ខុពើងចង្កេះក្នុងអាកាស ក៏មានអាបត្តិ ៥០០ យ៉ាងនោះដែរ; បណ្ឌិតគប្បីជ្រាបអាបត្តិទាំងអស់ ២,០០០ ដោយអំណាចបញ្ចកៈទាំង ៤ ដោយប្រការដូច្នេះ ។

## អធិប្បាយខណ្ឌចក្កនិងពទ្ធចក្កជាដើម

[៧-២០] ឥឡូវនេះ ព្រះមានព្រះភាគ ត្រាស់ព្រះបាលីមានសេចក្តីវិចិត្រទៅដោយប្រភេទនៃខណ្ឌចក្ក និងពទ្ធចក្កជាដើមថា "ដើម្បីប្រយោជន៍មិនឱ្យមានរោគ និងដើម្បីសេចក្តីសុខ" ដូច្នេះ ក៏ដើម្បីសម្តែងថា "កាលមានការបញ្ចេញទឹកសុក្កឱ្យឃ្លាត ដោយសេចក្តីព្យាយាមដោយចំណង់ក្នុងចិត្តរបស់ភិក្ខុដែលចាប់ (អង្គជាត) តាមលំដាប់ ឬខុសលំដាប់ ឬខាងក្រោមក្នុង១០ បទ មានបទថា អារោគ្យត្ថាយ ជា

ដើមមុន ហើយចាប់ខាងលើក្តី ចាប់ខាងលើហើយចាប់ខាងក្រោមក្តី ចាប់ទាំងពីរខាងហើយឈប់នៅត្រង់កណ្តាលក្តី ចាប់ត្រង់កណ្តាលហើយកន្ទ្រាក់ទៅទាំងពីរខាងក្តី ចាប់ឱ្យមានមូលរួមគ្នាទាំងអស់ក្តី ឈ្មោះថាសេចក្តីខុសសង្កេត រមែងមិនមាន” ។

[២១] ក្នុងព្រះបាលីនោះ ព្រះមានព្រះភាគត្រាស់ខណ្ឌចក្កទីមួយប្រកបអាពេក្យបទ ដោយគ្រប់ ៗ បទ យ៉ាងនេះថា “ដើម្បីមិនឱ្យមានពោគ និងដើម្បីសេចក្តីសុខ ដើម្បីមិនឱ្យមានរោគ និងដើម្បីភេសជ្ជៈ” ដូច្នេះជាដើម, ទ្រង់ប្រកបសុខបទជាដើមគ្រប់ ៗ បទ នាំមកដរាបដល់បទជាលំដាប់ដែលបន្ទាប់ពីខ្លួនទៅ ហើយត្រាស់ ៩ ពទ្ធចក្ក, ដោយប្រការដូចពោលមកនេះ ទើបជាចក្ក មានមូលមួយជាមួយគ្នា ១០ ចក្ក ។ ចក្កទាំងនោះ និងដោយចក្កមានមូលពីរជាដើម ដែលអ្នកសិក្សាគប្បីជ្រាបសេចក្តីឱ្យបានពិស្តារ ដោយការមិនភាន់ច្រឡំ ។ ចំណែកសេចក្តីក្នុងឯកមូលចក្កនេះ ប្រាកដច្បាស់ហើយ ។ ម្យ៉ាងទៀត ត្រាស់ចក្កទាំងឡាយ សូម្បីក្នុងទឹកសុក្កពណ៌ខៀវជាដើម ដោយន័យមានជាដើមថា “ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ និងពណ៌លឿង ក៏ព្យាយាម” ដូច្នេះ ដូចក្នុង១០ បទ មានបទថា ដើម្បីមិនឱ្យមានរោគជាដើមដូច្នោះ ។ សូម្បីចក្កទាំងនោះ ក៏គួរជ្រាបឱ្យបានពិស្តារដោយការមិនភាន់ច្រឡំ ។ ចំណែកសេចក្តីសូម្បីក្នុងចក្កទាំងឡាយនេះ ក៏ប្រាកដច្បាស់

ហើយដូចគ្នា ។ ត្រាស់មិស្សកចក្កមួយទៀតប្រកបបទក្រោយ នឹងបទដើមយ៉ាងនេះ គឺ បទមួយរួមនឹងបទមួយ ពីរបទរួមនឹងពីរបទ ។ល ។ ដប់បទរួមនឹងដប់បទ ថា **អារោគ្យត្ថញ្ច នីលញ្ច អារោគ្យត្ថញ្ច សុខត្ថញ្ច នីលញ្ច បីតកញ្ច** ដូច្នេះជាដើម ។

[២៨-៤០] ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ចក្កដោយន័យមានជាដើមថា "ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌លឿង ឃ្លាតចេញវិញ" ដូច្នេះ ដើម្បីសម្តែងន័យនេះ ព្រោះកាលភិក្ខុមានតម្រេកព្យាយាមថា "នឹងបញ្ចេញទឹកសុក្កពណ៌ខៀវ គ្រាទឹកសុក្កពណ៌ខៀវជាដើមឃ្លាតក្តី មានតម្រេកព្យាយាមដោយអំណាចនៃទឹកសុក្កពណ៌លឿងជាដើម កាលទឹកសុក្កពណ៌លឿងជាដើមក្រៅនេះ ឃ្លាតចេញក្តី មិនមានការខុសសង្កេតឡើយ តពីនោះ ទ្រង់ប្រកបបទក្រោយទាំងអស់ដោយ ៩ បទ មាននីលបទជាដើម ហើយត្រាស់ឱ្យឈ្មោះថា **កុច្ឆិចក្ក** ។ តពីនោះ ទ្រង់ប្រកប ៩ បទ មាន**បីតកបទ**ជាដើម ចូលជាមួយនឹងនីលបទត្រឹមតែមួយបទ ហើយត្រាស់ឱ្យឈ្មោះថា **បិដ្ឋិចក្ក** ។ តពីនោះ ទ្រង់ប្រកប ៩ បទ មាន**លោហិតកបទ**ជាដើម ចូលជាមួយនឹង**បីតកបទ**តែមួយប៉ុណ្ណោះ ហើយត្រាស់ទុតិយបិដ្ឋិចក្ក ។ ទ្រង់ប្រកប ៩ បទ ៗ ក្រៅនេះ ជាមួយនឹង**លោហិតកបទ**ជា

ដើមយ៉ាងនោះ ហើយត្រាស់ ៨ ចក្កពួកដទៃ ; ព្រោះដូច្នោះ គប្បីជ្រាប បិដ្ឋិចក្កមានគតិ ១០ យ៉ាង ដោយប្រការដូច្នេះ ។

[៤១] ព្រះមានព្រះភាគទ្រង់សម្តែងគរុកាបត្តិតែម្យ៉ាង ដោយពិស្តារដោយអំណាចនៃចក្កមិនមែនតិច មានខណ្ឌចក្កជាដើមយ៉ាងនេះ ហើយ ដើម្បីទ្រង់សម្តែងគរុកាបត្តិ លហុកាបត្តិ និងអនាបត្តិ ដោយអំណាចនៃអង្គប៉ុណ្ណោះ ទើបត្រាស់ពាក្យជាដើមថា "ភិក្ខុគិត ក៏ព្យាយាម, ទាល់តែទឹកសុក្កឃ្លាតចេញ" ដូច្នេះ ។

បណ្តាន័យទាំងនោះ ព្រះមានព្រះភាគ ត្រាស់គរុកាបត្តិដល់ព្រមដោយអង្គ ៣ ព្រោះការព្យាយាមបញ្ចេញអសុចិនៃភិក្ខុ ដែលមានតម្រេកដើម្បីត្រូវការមិនមានរោគជាដើម ក្នុងវេលាកើតមានសេចក្តីតម្រេកជាដើម ក្នុងអជ្ឈត្តរូបជាដើម សូម្បីដោយន័យមុនទុំះឯង ។ ត្រាស់លហុកាបត្តិ គឺ អាបត្តិថុល្លច្ច័យ សម្រេចដោយអង្គ ២ ក្នុងកាលមិនមានការបញ្ចេញនៃភិក្ខុដែលមានតម្រេក និងព្យាយាមដោយន័យទីពីរ ។ ត្រាស់អនាបត្តិដោយ ៦ ន័យ មានន័យថា "ភិក្ខុគិត (តែ)មិនព្យាយាម (ក៏ស្រាប់តែ)ទឹកសុក្កឃ្លាតចេញឯង" ដូច្នេះជាដើម ។ ក៏សេចក្តីផ្សេងគ្នានៃអាបត្តិ និងអនាបត្តិនេះ ល្អិតសុខុម ; ព្រោះដូច្នោះ ព្រះវិន័យធរគួរកំណត់ចំណាំឱ្យល្អ គ្រាកំណត់ឱ្យល្អហើយ ត្រូវសាកសួរដល់

សេចក្តីវង្វេស គប្បីប្រាប់អាបត្តិ ឬអនាបត្តិ ឬគប្បីធ្វើវិន័យកម្ម ។ ពិតមែន ព្រះវិន័យធរកាលកំណត់មិនបាន ធ្វើកិច្ចការទៅ រមែងដល់សេចក្តីលំបាក និងមិនអាចកែនូវបុគ្គលដូច្នោះបាន ដូចពេទ្យដែលមិនដឹងដើមហេតុនៃរោគហើយផ្សំថ្នាំដូច្នោះ ។

វិធីកំណត់ក្នុងអធិការពោលដោយសេចក្តីផ្សេងគ្នានៃអាបត្តិ និងអនាបត្តិនោះ ដូចតទៅនេះ ៖

ភិក្ខុដែលមកព្រោះសេចក្តីវង្វេស ដែលព្រះវិន័យធរគប្បីសួរ ៣ ដងថា "លោកត្រូវដោយប្រយោគណា ដោយសេចក្តីតម្រេកណា" ។ បើគ្រាដំបូងលោកពោលម្យ៉ាង ហើយខាងក្រោយពោលយ៉ាងដទៃផ្សេងទៀត មិនពោលដោយមកតែមួយ, គប្បីពោលដាស់តឿនលោកថា លោកមិននិយាយមកមួយ និយាយដោះខ្លួនទៅ, យើងមិនអាចធ្វើវិន័យកម្មដល់លោកបាន, លោកចូរទៅស្វែងរកសេចក្តីសួស្តីចុះ ។ ក៏បើលោកពោលអះអាងដោយមកតែមួយប៉ុណ្ណោះដល់ ៣ ដង, ធ្វើខ្លួនឱ្យច្បាស់តាមសេចក្តីពិត, លំដាប់នោះ ព្រះវិន័យធរគប្បីពិចារណាប្រយោគ ១១ ដោយអំណាចនៃភាគៈ ១១ យ៉ាង ដើម្បីវិនិច្ឆ័យអាបត្តិ អនាបត្តិ គរុកាបត្តិ និងលហុកាបត្តិរបស់លោក ។

# អធិប្បាយភាគៈនិងប្រយោគ ១១ យ៉ាង

បណ្ដាភាគៈនិងប្រយោគ ១១ នោះ ភាគៈ ១១ ទាំងនេះ គឺ សេចក្ដីត្រេកអរដើម្បីឱ្យឃ្លាត ១ សេចក្ដីត្រេកអរក្នុងខណៈឃ្លាត ១ សេចក្ដីត្រេកអរក្នុងកាលអសុចិឃ្លាតហើយ ១ សេចក្ដីត្រេកអរក្នុងមេថុន ១ សេចក្ដីត្រេកអរក្នុងផស្សៈ ១ សេចក្ដីត្រេកអរក្នុងរមាស់ ១ សេចក្ដីត្រេកអរក្នុងការមើល ១ សេចក្ដីត្រេកអរក្នុងកិរិយាអង្គុយ ១ សេចក្ដីត្រេកអរក្នុងពាក្យនិយាយ ១ សេចក្ដីស្រឡាញ់អាស្រ័យផ្ទះ ១ សេចក្ដីត្រេកអរដោយមែកឈើដែលគប្បីកាច់បាន ១ ។

ក្នុងភាគៈ ១១ យ៉ាងនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

១. **មោចនស្សាទៈ** សេចក្ដីត្រេកអរដើម្បីឱ្យទឹកសុក្កឃ្លាតចេញ

២. **មុច្ចនស្សាទៈ** សេចក្ដីត្រេកអរក្នុងខណៈអសុចិឃ្លាតចេញ

៣. **មុត្តស្សាទៈ** សេចក្ដីត្រេកអរក្នុងកាលអសុចិឃ្លាតហើយ

៤. **មេថុនស្សាទៈ** សេចក្ដីត្រេកអរក្នុងមេថុន

៥. **ផស្សស្សាទៈ** សេចក្ដីត្រេកអរក្នុងផស្សៈ

៦. **កណ្ឌូវនស្សាទៈ** សេចក្ដីត្រេកអរក្នុងរមាស់

៧. **ទស្សនស្សាទៈ** សេចក្ដីត្រេកអរក្នុងការមើល

៨. **និសជ្ជស្សាទៈ** សេចក្ដីត្រេកអរក្នុងកិរិយាអង្គុយ

៩. **វាចស្សាទៈ** សេចក្ដីត្រេកអរក្នុងពាក្យនិយាយ

១០. **គេហស្សិតបេមៈ** សេចក្ដីស្រឡាញ់អាស្រ័យផ្ទះ

១១. **វនភង្គិយៈ** (របស់កំណាន់ចិត្ត) វត្ថុអវយវៈយ៉ាងណាមួយ មានផ្កាឈើនិងផ្លែឈើជាដើម ដែលគេកាច់យកមកពីព្រៃ ។

ក៏បណ្ដាបទទាំង ១១ នេះ ព្រះមានព្រះភាគត្រាស់រាគៈ ដោយលើកសេចក្ដីត្រេកអរ ដែលសម្បយុត្តជាប្រធានដោយ ៩ បទ ត្រាស់សរុបដោយបទតែមួយ, ត្រាស់ដោយវត្ថុ ដោយបទតែមួយ ។ ពិតមែនវនភង្គៈ ជាទីតាំងនៃរាគៈ, មិនមែនជារាគៈ ។ តែប្រយោគ (ក្នុងការបញ្ចេញ) ព្រះវិន័យធរគប្បីជ្រាប ដោយអំណាចនៃរាគៈទាំងនេះ ដោយន័យដូចពោលតទៅនេះ ៖

ក្នុងសេចក្ដីត្រេកអរដើម្បីឱ្យទឹកសុក្កឃ្លាតចេញ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

កាលភិក្ខុមានតម្រេក និងត្រេកអរដោយមោចនស្សាទចេតនាព្យាយាម, អសុចិឃ្លាត ត្រូវអាបត្តិសង្ឃាទិសេស, កាលភិក្ខុមានតម្រេកនិងត្រេកអរដោយចេតនាយ៉ាងនោះដូចគ្នា ព្យាយាម, តែអសុចិមិនឃ្លាត ត្រូវអាបត្តិថុល្លច្ច័យ, បើថា ក្នុងវេលាដេក ភិក្ខុត្រូវរាគៈគ្របសង្កត់ យកភ្លៅតៀ្រត ឬ ដៃក្ដាប់អង្គជាតិយ៉ាងណែន ហើយសិងលក់ទៅទាំងដែលនៅមានសេចក្ដីឧស្សាហ៍ដើម្បីត្រូវការនឹងបញ្ចេញ ក៏កាលភិក្ខុនោះសិង

លក់ អសុចិឃ្លាតចេញ, ត្រូវអាបត្តិសង្ឃាទិសេស, ប្រសិនបើថា លោកញ៉ាំងពាគៈដែលគ្របសង្កត់នោះ ឱ្យស្ងប់ដោយមនសិការអសុភៈ មានចិត្តបរិសុទ្ធសិងលក់ទៅ, សូម្បីអសុចិឃ្លាតក្នុងខណៈ លោកសិងលក់ជាអនាបត្តិ ។

ក្នុងសេចក្ដីត្រេកអរខណៈឃ្លាត គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុត្រេកអរនឹងអសុចិ ដែលកំពុងឃ្លាតដោយធម្មតារបស់វា មិនព្យាយាម, អសុចិឃ្លាត ជាអនាបត្តិ ។ ក៏ប្រសិនបើថា លោកត្រេកអរនឹងអសុចិដែលកំពុងឃ្លាត រមែងព្យាយាម, កាលអសុចិឃ្លាតហើយដោយសេចក្ដីព្យាយាមនោះ ត្រូវអាបត្តិសង្ឃាទិសេស ។ ក្នុងមហាបច្ចរីពោលថា កាលអសុចិឃ្លាតដោយធម្មតារបស់វា លោកចាប់អង្គជាតិទុកដោយគិតថា "កុំប្រលាក់សំពត់កាសាវៈ ឬ សេនាសនៈ" ទៅកាន់ទីមានទឹក ដើម្បីជម្រះសម្អាត រមែងគួរ ។

ក្នុងសេចក្ដីត្រេកអរកាលអសុចិឃ្លាតហើយ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

កាលអសុចិឃ្លាត គឺ ឃ្លាតចាកឋានដោយធម្មតារបស់វាហើយ កាលភិក្ខុត្រេកអរជាខាងក្រោយ អសុចិឃ្លាត វៀរចាកការព្យាយាម ជាអនាបត្តិ ។ បើលោកត្រេកអរ ព្យាយាមត្រង់និមិត្ត ដើម្បីត្រូវការឱ្យឃ្លាតទៀត ហើយឱ្យឃ្លាត ជាសង្ឃាទិសេស ។

ក្នុងសេចក្ដីត្រេកអរក្នុងមេថុន គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុចាប់មាតុគ្រាមដោយសេចក្ដីតម្រេកក្នុងមេថុន អសុចិឃ្លាត ព្រោះប្រយោគនោះ ជាអនាបត្តិតែការចាប់ពាល់ (មាតុគ្រាម) ដូច្នោះ ត្រូវអាបត្តិទុក្កដ ព្រោះជាប្រយោគនៃមេថុនធម្ម ។ កាលដល់ទីបំផុត ត្រូវអាបត្តិបារាជិក ។ ប្រសិនបើភិក្ខុមានសេចក្ដីត្រេកអរក្នុងមេថុន ត្រឡប់ត្រេកអរព្យាយាមត្រង់និមិត្ត ដើម្បីត្រូវការនឹងបញ្ចេញ ហើយបញ្ចេញ, ត្រូវអាបត្តិសង្ឃាទិសេស ។

គប្បីជ្រាបវិនិច្ឆ័យសេចក្ដីត្រេកអរក្នុងផស្សៈ ដូចតទៅនេះ ៖

ផស្សៈមាន ២ យ៉ាង ផស្សៈខាងក្នុង១ ផស្សៈខាងក្រៅ ១ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងផស្សៈដែលជាខាងក្នុងជាមុនសិន ៖

កាលភិក្ខុលេងនិមិត្តរបស់ខ្លួនដោយគិតថា "យើងដឹងថា រឹង ឬ ទន់" ក្ដី ដោយការរពឹសក្ដី អសុចិឃ្លាត ជាអនាបត្តិ ។ បើលោកលេងដោយត្រេកអរ ព្យាយាមត្រង់និមិត្ត ដើម្បីប្រាថ្នានឹងបញ្ចេញ ហើយបញ្ចេញ, ត្រូវអាបត្តិសង្ឃាទិសេស ។

ចំណែកក្នុងផស្សៈខាងក្រៅ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

កាលភិក្ខុស្ទាបអង្អែលអវយវៈតូចធំរបស់មាតុគ្រាម និងឱបរឹត ដោយសេចក្ដីតម្រេកក្នុងការត្រដុសអង្អែលកាយ អសុចិឃ្លាត ជា

អនាបត្តិ ។ តែលោកត្រូវកាយសំសគ្គសង្ឃាទិសេស ។ បើថា ភិក្ខុមានតម្រេកក្នុងការស្ទាបអង្អែលកាយ ត្រឡប់ត្រេកអរព្យាយាមត្រង់និមិត្ត ដើម្បីត្រូវការបញ្ចេញ ហើយបញ្ចេញ, ត្រូវអាបត្តិសង្ឃាទិសេស សួម្បីព្រោះការបញ្ចេញទឹកសុក្កជាបច្ច័យ ។

គប្បីជ្រាបវិនិច្ឆ័យសេចក្តីត្រេកអរក្នុងរមាស់ ដូច្នេះ ៖

កាលភិក្ខុអេះនិមិត្តដែលកំពុងរមាស់ ដោយអំណាចនៃរោគរមាស មានរោគដំនួចពិស រោគកមគ្រិន រោគរលកកែវ និងសត្វល្អិតជាដើម យ៉ាងណាមួយ ដោយសេចក្តីត្រេកអរក្នុងសេចក្តីរមាស់ប៉ុណ្ណោះ អសុចិឃ្លាត ជាអនាបត្តិ ។ ភិក្ខុមានសេចក្តីត្រេកអរក្នុងរមាស់ ត្រឡប់ត្រេកអរព្យាយាមត្រង់និមិត្ត ដើម្បីត្រូវការទឹងបញ្ចេញ ហើយបញ្ចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

គប្បីជ្រាបវិនិច្ឆ័យសេចក្តីត្រេកអរក្នុងការមើល ដូច្នេះ ៖

ភិក្ខុសម្លឹងមើលឱកាសដែលមិនសមគួរ ( អង្គកំណើត ) របស់មាតុគ្រាមរឿយ ៗ ដោយអំណាចសេចក្តីត្រេកអរ ក្នុងការមើលអសុចិឃ្លាត ជាអនាបត្តិ ។ តែត្រូវអាបត្តិទុក្កដ ព្រោះសម្លឹងមើលទីមិនមែនឱកាសដ៏សមគួរនៃមាតុគ្រាម ។ បើភិក្ខុត្រេកអរក្នុងការមើល ត្រឡប់ត្រេកអរព្យាយាមត្រង់និមិត្ត ដើម្បីត្រូវការទឹងបញ្ចេញ ហើយបញ្ចេញ

ត្រូវអាបត្តិសង្ឃាទិសេស ។

គប្បីជ្រាបវិនិច្ឆ័យសេចក្ដីត្រេកអរក្នុងការអង្អែល ដូច្នេះ ៖

កាលភិក្ខុអង្អែល ដោយការត្រេកអរនឹងការអង្អែលក្នុងទឹកបាំងជាមួយនឹងមាតុគ្រាម អសុចិឃ្លាត ជាអនាបត្តិ ។ តែព្រះវិន័យធរគប្បីពិន័យលោកដោយអាបត្តិ ដែលត្រូវព្រោះការអង្អែលក្នុងទឹកបាំងជាបច្ច័យ ។ បើភិក្ខុមានសេចក្ដីត្រេកអរក្នុងការអង្អែល ហើយត្រឡប់ត្រេកអរ ព្យាយាមត្រង់និមិត្ត ដើម្បីត្រូវការនឹងបញ្ចេញ ហើយបញ្ចេញ, ត្រូវអាបត្តិសង្ឃាទិសេស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្ដីត្រេកអរនឹងពាក្យនិយាយ ដូច្នេះ ៖

ភិក្ខុនិយាយបែចង់ជាមួយមាតុគ្រាម ដោយពាក្យនិយាយអាស្រ័យមេថុន ដោយសេចក្ដីត្រេកអរក្នុងពាក្យចរចា អសុចិឃ្លាត ជាអនាបត្តិ ។ តែលោកត្រូវអាបត្តិសង្ឃាទិសេស ព្រោះវាចាអាក្រក់ ។ បើភិក្ខុមានសេចក្ដីត្រេកអរ ក្នុងពាក្យចរចាហើយ ត្រឡប់ត្រេកអរ ព្យាយាមត្រង់និមិត្ត ដើម្បីត្រូវការនឹងបញ្ចេញ ហើយបញ្ចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្ដីស្រឡាញ់អាស្រ័យផ្ទះ ដូច្នេះ ៖

កាលភិក្ខុស្ទាបអង្អែល និងអោបរឹតរឿយ ៗ នូវមាតាដោយ

សេចក្តីស្រឡាញ់ក្នុងឋានជាមាតាក្តី នូវបងស្រីប្អូនស្រីដោយសេចក្តីស្រឡាញ់ជាបងស្រីប្អូនស្រីក្តី អសុចិឃ្លាត ជាអនាបត្តិ ។ តែត្រូវអាបត្តិទុក្កដ ព្រោះពាល់ត្រូវដោយសេចក្តីស្រឡាញ់អាស្រ័យផ្ទះ ជាបច្ច័យ ។ ប្រសិនបើថា ភិក្ខុមានសេចក្តីត្រេកអរដោយសេចក្តីស្រឡាញ់អាស្រ័យផ្ទះ ហើយត្រឡប់ត្រេកអរ ព្យាយាមត្រង់និមិត្តដើម្បីត្រូវការទឹងបញ្ចេញ ហើយបញ្ចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវនភង្គៈ (របស់កំណាន់ចិត្ត) ដូច្នេះ ៖

ស្រីនឹងប្រុស រមែងបញ្ជូនបណ្ណាការ (វត្ថុកំណាន់ចិត្ត) មានប្រភេទ គឺ ស្លា ម្លូ របស់ក្រអូប ផ្កាឈើ និងគ្រឿងអប់ក្លិនជាដើមណាមួយ ទៅឱ្យគ្នានិងគ្នា ដើម្បីត្រូវការឱ្យមានសន្ថវមេត្រីដ៏រឹងមាំនេះឈ្មោះថា វនភង្គៈ ។ បើមាតុគ្រាមបញ្ជូនរបស់កំណាន់ចិត្ត បែបនោះទៅឱ្យដល់ភិក្ខុដែលចូលកាន់ត្រកូលនៅជិតខាងរូបខ្លះ, និងកាលលោកតម្រេកខ្លាំងថា របស់នេះស្រីឈ្មោះឯណោះបញ្ជូនមកឱ្យ ដូច្នេះហើយ យកដៃស្ទាបអង្អែលរបស់កំណាន់នោះលេងរឿយ ៗ អសុចិឃ្លាត ជាអនាបត្តិ ។ បើជាភិក្ខុតម្រេកខ្លាំងក្នុងវនភង្គៈ ហើយត្រឡប់ត្រេកអរ ព្យាយាម ត្រង់និមិត្តដើម្បីប្រាថ្នា ទឹងបញ្ចេញ ហើយបញ្ចេញ, ត្រូវអាបត្តិសង្ឃាទិសេស ។ បើសូម្បីកាលភិក្ខុព្យាយាម តែអសុចិមិនឃ្លាត ត្រូវអាបត្តិថុល្លច្ច័យ ។

ព្រះវិន័យធរគប្បីពិចារណាប្រយោគទាំង ១១ នេះ ដោយអំណាចនៃភាគៈទាំង ១១ នេះ ហើយកំណត់អាបត្តិ ឬអនាបត្តិ ដោយប្រការយ៉ាងនេះ កាលកំណត់ល្អហើយ បើជាគរុកាបត្តិ គប្បីប្រាប់ថា "ជាគរុកាបត្តិ" បើជាលហុកាបត្តិ គប្បីប្រាប់ថា "ជាលហុកាបត្តិ" និងគប្បីធ្វើវិន័យកម្មឱ្យសមគួរដល់អាបត្តិទាំងនោះ ៗ ។ ពិតមែនវិន័យកម្មដែលធ្វើហើយយ៉ាងនេះ ឈ្មោះថា ជាកម្មដែលធ្វើល្អហើយ ដូចពេទ្យដឹងសមុដ្ឋាននៃរោគហើយ ផ្សំថ្នាំ ដូច្នោះ និងរមែងប្រព្រឹត្តទៅដើម្បីសេចក្ដីសួស្ដីដល់បុគ្គលនោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ចេតេតិ ន ឧបក្កមតិ : ភិក្ខុគិត( តែ ) មិនព្យាយាម** ជាដើម ដូច្នេះ ៖

ភិក្ខុគិតដោយចេតនាត្រេកអរនឹងការបញ្ចេញ តែមិនព្យាយាម អសុចិឃ្លាត មិនត្រូវអាបត្តិ ។ ភិក្ខុត្រូវសេចក្ដីត្រេកអរក្នុងការបញ្ចេញបៀតបៀនហើយ គិតថា "ដូចម្ដេចហ្ន៎ អសុចិនឹងឃ្លាតចេញ" តែមិនព្យាយាម, អសុចិមិនឃ្លាត មិនត្រូវអាបត្តិ ។ ភិក្ខុមិនគិតដោយសេចក្ដីត្រេកអរក្នុងការបញ្ចេញ ព្យាយាមដោយសេចក្ដីត្រេកអរក្នុងផស្សៈក្ដី ដោយសេចក្ដីត្រេកអរក្នុងការរមោសក្ដី អសុចិឃ្លាតចេញ មិនត្រូវអាបត្តិ ។ ភិក្ខុមិនគិតយ៉ាងនោះដូចគ្នា តែព្យាយាម អសុចិមិនឃ្លាត មិន

ត្រូវអាបត្តិ ។ ភិក្ខុកាលត្រិះរិះដល់កាមវិតក្កៈ មិនគិត មិនព្យាយាមដើម្បីត្រូវការបញ្ចេញ តែអសុចិឃ្លាត, មិនត្រូវអាបត្តិ ។ បើសូម្បីកាលភិក្ខុនោះកំពុងត្រិះរិះដល់កាមវិតក្កៈ អសុចិមិនឃ្លាត ។ ពាក្យនេះ ជាពាក្យដែលនាំមកអាងក្នុងអដ្ឋកថាបូរាណថា ភិក្ខុមិនគិត មិនព្យាយាម អសុចិមិនឃ្លាត មិនត្រូវអាបត្តិ ដូច្នេះ ។

[៤២] ពាក្យថា **អនាបត្តិ សុបិនន្តេន :** **ភិក្ខុយល់សប្តិ មិនត្រូវអាបត្តិឡើយ** សេចក្តីថា កាលភិក្ខុសិងលក់ហើយ យល់សប្តិថាសេពមេថុនធម្មក្តី បានស្ទាបអង្អែលកាយ (មាតុគ្រាម)ជាដើមក្តី មិនត្រូវអាបត្តិដល់ភិក្ខុដែលមានអសុចិឃ្លាត ព្រោះហេតុក្នុងការយល់សប្តិនោះឡើយ ។ តែកាលចេតនាត្រេកអរកើតក្នុងការយល់សប្តិ ប្រសិនបើជាវិស័យរបស់លោក[១], កុំឱ្យកម្រើក មិនគប្បីយកដៃចាប់និមិត្តលេងតែដើម្បីរក្សាសំពត់កាសាវៈ និងសំពត់ក្រាលដេក នឹងយកដៃចាប់ទៅកាន់ទីមានទឹក ដើម្បីលាងជម្រះ គួរ ។

បទថា **នមោចនាធិប្បាយស្ស :** **ភិក្ខុមិនមានបំណងឱ្យទឹកសុក្កឃ្លាតចេញ** មានសេចក្តីថា កាលភិក្ខុណា លាបនិមិត្តដោយថ្នាំក្តី ធ្វើការ

---

(១) យោជនាបាលី. សចស្សាសយោតិ សចេ អស្ស ភិក្ខុស្ស អវិសយោ ។

បន្ទោបង់ឧច្ចារៈជាដើមក្តី មិនមានសេចក្តីប្រាថ្នាក្នុងការឱ្យឃ្លាត អសុចិឃ្លាត, មិនជាអាបត្តិសូម្បីដល់ភិក្ខុនោះ ។ មិនត្រូវអាបត្តិ សូម្បីដល់ភិក្ខុឆ្កួតទាំងពីរពួក ។ ក្នុងសិក្ខាបទនេះ សេយ្យសកភិក្ខុជាដើមបញ្ញត្តិ ។ មិនត្រូវអាបត្តិដល់សេយ្យសកភិក្ខុ ដែលជាដើមបញ្ញត្តិនោះដូច្នេះឯង ។

បទភាជនីយវណ្ណនា ចប់

គប្បីជ្រាបវិនិច្ឆ័យក្នុងសមុដ្ឋានជាដើម ដូច្នេះ ៖

សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិកសិក្ខាបទ រមែងតាំងឡើងមកកាយចិត្ត ជាកិរិយា ជាសញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត មានវេទនា ២ ជាសុខវេទនា និងឧបេក្ខាវេទនានោះឯង ។

## វិនីតវត្ថុក្នុងសង្ឃាទិសេសសិក្ខាបទទី ១

[៤៤-៤៦] បណ្តាវិនីតវត្ថុទាំងឡាយ រឿងការយល់សប្តិ មានន័យដូចដែលព្រះមានព្រះភាគត្រាស់ហើយ ក្នុងអនុប្បញ្ញត្តិនុ៎ះឯង ។ រឿងបន្ទោបង់ឧច្ចារៈ បស្សាវៈ ច្រើនរឿង មានសេចក្តីជាក់ច្បាស់ទាំងអស់នោះហើយ ។

[៤៧] ក្នុងរឿងវិតក្កៈ បទថា កាមវិតក្កំ ៖ ត្រិះរិះក្នុងកាម

បានដល់ សេចក្ដីត្រិះរិះដល់កាមដែលអាស្រ័យផ្ទះ ។ ក្នុងរឿងកាមវិតក្កៈនោះ ត្រាស់អនាបត្តិទុក ក៏ពិតមែន, តែថា ភិក្ខុមិនគួរធ្លាក់នៅក្នុងអំណាចនៃវិតក្កៈ ។

[៤៨] រឿងទឹកក្ដៅ រឿងជំបូនឆាយយល់ ។ រឿងទី២ ភិក្ខុនោះប្រាថ្នានឹងបញ្ចេញ យកទឹកស្រោចហើយស្រោចទៀតនូវនិមិត្ត ហើយងូតទឹក ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគពិន័យអាបត្តិដល់លោក ។ ក្នុងរឿងទី ៣ ត្រូវអាបត្តិថុល្លច្ច័យ ព្រោះមានសេចក្ដីព្យាយាម ។

[៤៩-៥០] រឿងលាបថ្នាំដំបៅនិងរឿងអេះអណ្ឌ(ពងស្វាស) មានសេចក្ដីភ្លឺច្បាស់ ទាំងអស់នោះឯង ។

[៥១] គប្បីជ្រាបវិនិច្ឆ័យក្នុងមគ្គវត្ថុច្រើនរឿង ដូច្នេះ ៖

កាលភិក្ខុរូបជំបូងមានភ្លៅធំកំពុងធ្វើដំណើរ អសុចិបានឃ្លាត ព្រោះការត្រដុសកកិតក្នុងទីចន្លោះ មិនត្រូវអាបត្តិដល់លោក ព្រោះមិនមានសេចក្ដីប្រាថ្នាក្នុងការឱ្យឃ្លាត ។ សម្រាប់ភិក្ខុរូបទីពីរ អសុចិបានឃ្លាតយ៉ាងនោះដូចគ្នា តែត្រូវអាបត្តិសង្ឃាទិសេស ព្រោះមានបំណងឱ្យឃ្លាត ។ ភិក្ខុរូបទីបី អសុចិមិនឃ្លាត តែជាអាបត្តិថុល្លច្ច័យ ព្រោះមានសេចក្ដីព្យាយាម ។ ព្រោះហេតុនោះ ភិក្ខុកំពុងធ្វើដំណើរ កាលការកកិតកើតឡើង មិនគួរធ្វើដំណើរ គប្បីឈប់ញ៉ាំងចិត្តឱ្យស្ងប់ដោយមនសិការ

ក្នុងអសុភជាដើម កំណត់កម្មដ្ឋានដោយចិត្តបរិសុទ្ធិ ហើយសឹមដើរតទៅ, បើឈប់ហើយ មិនអាចបន្ទោបង់បាន គប្បីចេញឱ្យផុតពីមក អង្គុយបន្ទោបង់ហើយដើរកំណត់កម្មដ្ឋានដោយចិត្តបរិសុទ្ធិនុ៎ះឯង ។

[៥២] ក្នុងរឿងកាន់ស្បែកខាងចុងអង្គជាតិច្រើនរឿង ពួកភិក្ខុទាំងនោះ ចាប់ស្បែកចុង[1] ឱ្យណែនបញ្ចេញ (ទឹកនោម) ឱ្យពេញហើយ ទើបបន្ទោបង់បស្សាវៈ ដូចពួកក្មេងអ្នកស្រុក ។

[៥៣] ក្នុងរឿងរោងភ្លើងមានវិនិច្ឆ័យថា ៖

កាលភិក្ខុរោលកម្តៅពោះ មានសេចក្តីប្រាថ្នានឹងឱ្យឃ្លាតក្តី មិនប្រាថ្នានឹងឱ្យឃ្លាតក្តី កាលអសុចិឃ្លាតហើយ ជាអនាបត្តិដូចគ្នា ។

[៥៤] កាលកំពុងធ្វើបរិកម្ម អសុចិឃ្លាតដោយអំណាចនៃការញុំាងនិមិត្តឱ្យកម្រើក ព្រោះហេតុនោះ ទើបព្រះមានព្រះភាគពិន័យអាបត្តិក្នុងឋានៈនៃអាបត្តិ ។

[៥៥] ក្នុងរឿងត្រដុសទឹងភ្លៅច្រើនរឿង លោកពោលទុកក្នុងកុរុន្ទីអដ្ឋកថា យ៉ាងនេះថា ព្រះមានព្រះភាគពិន័យអាបត្តិដល់ភិក្ខុពួកណា,

---

(១) សារត្ថទីបនី. វត្ថឹ ទឡ្ហំ គហេត្វាតិ អង្គជាតស្ស អគ្គេ បស្សាវនិគ្គមនឋានេ ចម្មំ ទឡ្ហំ គហេត្វា ប្រែថា ពាក្យថា ចាប់ស្បែកចុងឱ្យណែននោះ បានដល់ ចាប់ត្រង់ចុងអង្គជាតិ គឺ ស្បែកក្នុងទីដែលបស្សាវៈហូរចេញ ឱ្យណែន ។

ភិក្ខុទាំងនោះ បណ្ឌិតគប្បីជ្រាបថា ត្រដុសនៅក្នុងទីជុំវិញអង្គជាតិ ឱ្យពាល់ត្រូវអង្គជាតិនោះហើយ ។

[៥៦-៦០] រឿងសាមណេរជាដើម មានសេចក្តីភ្លឺច្បាស់ទាំងអស់នោះ ។

[៦១] ក្នុងរឿងប្រឹងមឹតពត់កាយ ពាក្យថា **កាយំ ឧម្មទ្ទន្តស្ស : ប្រឹងមឹតពត់កាយ** មានសេចក្តីថា កាលភិក្ខុអង្គុយយូរក្តី ដេកយូរក្តី ធ្វើនវកម្មក្តី ហើយប្រឹងមឹតពត់កាយដើម្បីបន្ធូរការឈឺចុកចាប់ ។

[៦២] គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងសម្លឹងមើល ដូច្នេះ ៖

សូម្បីបើថា ស្រីនោះស្លៀកសំពត់ទាំងរយដាន់ ភិក្ខុឈរខាងមុខក៏ដោយ ខាងក្រោយក៏ដោយ សម្លឹងមើលថា "និមិត្តនៅក្នុងឱកាសឈ្មោះនេះ" ត្រូវអាបត្តិទុក្កដពិត ។ ចាំបាច់ពោលទៅថ្វីដល់ការសម្លឹងមើលនិមិត្តនៃពួកក្មេងស្រីអ្នកស្រុកដែលមិនស្លៀកសំពត់ សូម្បីក្នុងនិមិត្តនៃសត្វតិរច្ឆានក៏មានន័យដូចគ្នានេះ ។ តែ កាលភិក្ខុ មិនក្រឡេកទៅខាងឯណោះខាងនេះ សម្លឹងមើលដោយប្រយោគតែមួយ សូម្បីរហូតអស់មួយថ្ងៃ ក៏ត្រូវអាបត្តិទុក្កដតែមួយប៉ុណ្ណោះ ។ កាលក្រឡេកមើលទីឯណោះឯណោះ សម្លឹងមើលហើយមើលទៀត ត្រូវអាបត្តិទុក្កដគ្រប់ ៗ ប្រយោគ ។ ព្រះវិន័យធរ មិនគប្បីពិន័យ ដោយអំណាចនៃការបើក

ភ្នែក និងធ្មេចភ្នែកទេ ។ កាលសម្លឹងមើលដោយចៃដន្យត្រឡប់ពិចារណាហើយតាំងនៅក្នុងសំរេះទៀត ជាអនាបត្តិ ។ កាលលះសំរេះនោះហើយ សម្លឹងមើលទៀត ត្រូវអាបត្តិទុក្កដតែម្តង ។

[៦៣-៦៤] រឿងបញ្ចូលអង្គជាតទៅទីងប្រហោងដាន និងរឿងត្រដុសអង្គជាតទីងកំណាត់ឈើ មានសេចក្តីជាក់ច្បាស់ទាំងអស់ ។

[៦៥-៦៧] ក្នុងរឿងផ្លូតទឹកច្រើនរឿង ព្រះមានព្រះភាគ ពិន័យអាបត្តិដល់ពួកភិក្ខុដែលយកនិមិត្តដាក់ចំក្រសែទឹក ។ សូម្បីរឿងលេងទឹកដែលមានល្បាប់ច្រើនរឿង ក៏មានន័យដូចគ្នានេះ ។ ក៏ក្នុងរឿងទឹកមានល្បាប់នេះ ទឹកដែលប្រកបដោយភក់ លោកហៅថា **ឧទញ្ជលៈ** ទឹកល្បាប់ ។ រឿងដទៃ ៗ ក្រៅនេះ ទាំងអស់មានរឿងរត់ស្ទុះទៅក្នុងទឹកជាដើម បណ្ឌិតគប្បីជ្រាបដោយឧបាយនេះដូចគ្នា ។

[៦៨] ចំណែកសេចក្តីប្លែកគ្នា ក្នុងរឿងបុប្ផាវឡិយ (កងផ្កា) ដូចតទៅនេះ ៖

ទោះជាថា មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងឱ្យឃ្លាត ។ តែក៏ត្រូវអាបត្តិទុក្កដ ព្រោះការលេងជាបច្ច័យ ដូច្នេះឯង ។

សុក្កវិស្សដ្ឋិសិក្ខាបទវណ្ណនា ចប់

## ២. កាយសំសគ្គសិក្ខាបទវណ្ណនា

[៧៥] កាយសំសគ្គសិក្ខាបទថា តេន សមយេន ពុទ្ធោ ភគវា : សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថីជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងកាយសំសគ្គសិក្ខាបទនោះ មានការពណ៌នាបទដែលនៅមិនជាក់ច្បាស់ ដូចតទៅនេះ ៖

### ពន្យល់អត្ថក្នុងបឋមបញ្ញត្តិនៃរឿងឧទាយីភិក្ខុ

ពីរបទថា អរញ្ញេ វិហរតិ : សម្រេចឥរិយាបថនៅក្នុងព្រៃ សេចក្តីថា មិនមែននៅក្នុងព្រៃឯណាដទៃ គឺ នៅទីបំផុតដែនម្ខាងនៃព្រះវិហារជេតពនទុំះឯង ។

ពីរបទថា មជ្ឈេ គព្ភោ : មានបន្ទប់ខាងក្នុងសេចក្តីថា ក៏ត្រង់ទីកណ្តាលកុដិរបស់ឧទាយីភិក្ខុនោះ មានបន្ទប់ ។

បទថា សមន្តា បរិយាគារោ : មានរបៀងជុំវិញ សេចក្តីថា ក៏ដោយជុំវិញបន្ទប់នោះ មានរបៀងរោងមូលហោមព័ទ្ធ ។ បានឮថា បន្ទប់នោះ ឧទាយីភិក្ខុសាងឱ្យជាបន្ទប់ ៤ ជ្រុងចតុរស្សនៅត្រង់កណ្តាល ដោយមានរោងមូល ជារបៀងហោមព័ទ្ធខាងក្រៅ ដែលជនទាំងឡាយ

អាចដើរវិលជុំវិញខាងក្នុងបានតែម្ដង ។

បទថា សុប្បញ្ញត្តំ : ក៏រៀបចំល្អ ប្រែថា ចាត់ចែងទុកដាក់រៀបរយ ។ អធិប្បាយថា គ្រែ និងតាំងនោះ ចាត់ចែងទុកដាក់ដោយប្រការណា ៗ និង ក្នុងឱកាសណា ៗ ទើបបង្ក ឱ្យកើតសេចក្ដីជ្រះថ្លា ឱ្យជនទាំងឡាយត្រេកអរ, ឧទាយីភិក្ខុបានចាត់ចែងទុកដាក់ដោយប្រការនោះ ៗ ក្នុងឱកាសនោះ ៗ ។ ពិតមែន
ឧទាយីភិក្ខុនោះ ធ្វើកិច្ចយ៉ាងណាមួយ ដោយកិច្ចវត្តជាប្រធាន ក៏ទេ ។

ពាក្យថា ឯកច្ចេ វាតបានេ : បង្អួចខ្លែងខ្លះ សេចក្ដីថា បើកបង្អួចទាំងឡាយ ដែលបិទហើយមានភាពងងឹត បិទបង្អួចទាំងឡាយដែលបើកហើយមានពន្លឺ ។

ពាក្យថា ឯវំ វុត្តេ សា ព្រាហ្មណី តំ ព្រាហ្មណំ ឯតទវោច : កាលបើព្រាហ្មណ៍ពោលពាក្យសរសើរយ៉ាងនេះហើយ នាងព្រាហ្មណីនោះ បានពោលពាក្យនេះនឹងព្រាហ្មណ៍នោះ សេចក្ដីថា កាលព្រាហ្មណ៍នោះពោលសរសើរយ៉ាងនេះ នាងព្រាហ្មណីនោះយល់ថា "ព្រាហ្មណ៍នេះជ្រះថ្លាហើយ ប្រហែលជាចង់បួស" កាលនឹងបើកបង្ហាញការដែលគួរអាម៉ាស់នោះរបស់ខ្លួន សូម្បីគួរបិទបាំងទុក មាន សេចក្ដី

ប្រាថ្នានឹងកាត់បន្ថយសទ្ធារបស់ព្រាហ្មណ៍នោះតែម្យ៉ាង ទើបបានពោលពាក្យមានជាដើមថា កុតោ តស្ស ឧឡារត្តតា[1] : សេចក្តីថ្កុំថ្កើងរបស់លោកឧទាយីនោះ មានមកពីណា នេះ ។

ក្នុងបទថា ឧឡារតា[2] : ថ្កុំថ្កើង នោះ មានវិគ្រោះថា ខ្លួន (អធ្យាស្រ័យ) របស់អ្នកនោះថ្កុំថ្កើង; ព្រោះហេតុនោះ ទើបឈ្មោះថា មានខ្លួនថ្កុំថ្កើងណាស់ ។ ភាវៈនៃបុគ្គលអ្នកមានខ្លួនដ៏ឱឡារនោះ ឈ្មោះថា ឧឡារតា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា កុលិត្ថីហិ : ពួកស្ត្រីក្នុងត្រកូលជាដើមតទៅ ៖

ស្រីមេផ្ទះទាំងឡាយ ឈ្មោះថា ស្ត្រីក្នុងត្រកូល ។ ពួកកូនក្រមុំរបស់ ត្រកូលអ្នកទៅជាមួយបុរសដទៃបាន ឈ្មោះថា ធីតារបស់ត្រកូល ។ ពួកស្រីវ័យជំទង់មានចិត្តមិនទាន់តាំងស៊ប់ ហៅថា កុមារីរបស់ត្រកូល ។ ស្រីក្រមុំដែលគេនាំមកពីត្រកូលដទៃ ដើម្បីក្មេងកម្លោះក្នុងត្រកូល ហៅថា កុលសុណ្ហា ។

---

(១) បាលីជា ឧឡារតា ។ ២. ឆដ្ឋ. និងថៃ. ឧឡារត្តា ។

# អធិប្បាយសិក្ខាបទវិភង្គ

## ភិក្ខុត្រូវរាគៈគ្របសង្កត់

[៧៦] បទថា ឱតិណ្ណោ : កាមរាគៈគ្របសង្កត់ហើយ នោះ បានដល់ អ្នកដែលរាគៈកើតខាងក្នុងគ្របសង្កត់ហើយ ដូចជាសត្វទាំងឡាយ ដែលត្រូវយក្ខជាដើមបៀតបៀន ដូច្នោះ ។ ម្យ៉ាងទៀត កាលមិនពិចារណាតម្រេកនៅក្នុងឋានៈដែលគួរតម្រេក ឈ្មោះថា ធ្លាក់ចុះកាន់សេចក្តីតម្រេកនោះឯង ដូចសត្វដែលមិនពិចារណាធ្លាក់រណ្តៅជាដើម ដូច្នោះ ។ ក៏ពាក្យថា ឱតិណ្ណោ នេះ ជាឈ្មោះរបស់ភិក្ខុដែលពោរពេញដោយរាគៈប៉ុណ្ណោះ ដោយប្រការទាំងពីរ; ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់បទភាជនៈនៃបទថា ឱតិណ្ណោ នោះ យ៉ាងនេះថា "ភិក្ខុដែលត្រេកអរ សម្លឹងគយគន់[១] មានចិត្តប្រតិព័ទ្ធ ហៅថា (ភិក្ខុ)ត្រូវកាមរាគៈគ្របសង្កត់ហើយ" ។ បណ្តាបទទាំងនោះ បទថា សារត្តោ : ដែលត្រេកអរ បានដល់ អ្នកមានតម្រេកខ្លាំង ដោយកាយសំសគ្គរាគៈ ។

បទថា អបេក្ខវា : សម្លឹងគយគន់[២] បានដល់ អ្នកមានសេចក្តីសម្លឹងមើល ដោយសេចក្តីប្រាថ្នាក្នុងកាយសំសគ្គៈ ។

---

១.២. បិដកប្រែថា មានសេចក្តីអាឡោះអាល័យ ។ មិនត្រូវតាមន័យពន្យល់របស់អដ្ឋកថា ។

បទថា **បដិពទ្ធចិត្តោ : មានចិត្តប្រតិព័ទ្ធ** បានដល់ អ្នកមានចិត្តជាប់ជំពាក់ ក្នុងវត្ថុនោះ ដោយកាយសំសគ្គរាគៈនុ៎ះឯង ។

បទថា **វិបរិណតេន : មានចិត្តប្រែប្រួលហើយ** មានសេចក្តីថា ចិត្តដែលលះប្រក្រតីពោលគឺ ភវង្គសន្តតិដ៏បរិសុទ្ធិចេញ ប្រព្រឹត្តទៅដោយប្រការដទៃ ចាត់ថា ប្រែប្រួលទៅខុសរូប ឬផ្លាស់ប្តូរទៅខុសរូប ។ អធិប្បាយថា ចិត្តផ្លាស់ប្តូរយ៉ាងណា ឈ្មោះថា ខុសរូប, មានចិត្តផ្លាស់ប្តូរទៅយ៉ាងនោះ ។ ក៏ព្រោះហេតុដែលចិត្តនោះ មិនកន្លងហួសសេចក្តីប្រកបព្រមដោយកិលេស មានរាគៈជាដើមទៅបាន; ដូច្នោះ ព្រះមានព្រះភាគកាលត្រាស់បទភាជនៈនៃបទថា វិបរិណតំ នោះ ដោយន័យជាដើមថា **វិបរិណតន្តិ រត្តម្បិ ចិត្តំ : ត្រង់ពាក្យថា ប្រែប្រួលហើយ សេចក្តីថា ចិត្តដែលត្រេកអរ** ហើយទ្រង់សម្តែងអត្ថ ដែលបំណងក្នុងសិក្ខាបទនេះ ក្នុងទីបំផុត ទើបត្រាស់ថា "ប៉ុន្តែក្នុងអត្ថនេះ តថាគតសំដៅយកចិត្តដែលត្រេកអរ ឱ្យឈ្មោះថា ចិត្តប្រែប្រួលហើយ" ។

បទថា **តទហុជាតា : សូម្បីកើតក្នុងថ្ងៃនោះ** បានដល់ ក្មេងស្រីដែលកើតក្នុងថ្ងៃនោះ គឺ ត្រឹមតែកើតនៅមានពណ៌ជាដុំសាច់ស្រស់ ។ ពិតមែន ព្រោះការស្ទាបអង្អែលកាយក្មេងស្រីបែបនេះ ក៏រមែងត្រូវអាបត្តិសង្ឃាទិសេស, ព្រោះការប្រព្រឹត្តកន្លងដោយមេថុន ត្រូវ

អាបត្តិបារាជិក, និងព្រោះការត្រេកអរដោយរបោះនិសជ្ជៈ(ការអង្គុយក្នុងទីកំបាំង) រមែងត្រូវអាបត្តិបាចិត្តិយ ។

បទថា បរេតៅ : មិនបាច់ពោល បានដល់ ស្រ្តីដែលពោលដំបូងនុ៎ះឯង ។

ពីរបទថា កាយសំសគ្គំ សមាបជ្ជេយ្យ : គប្បីដល់ព្រមដោយកាយសំសគ្គៈ មានសេចក្ដីថា គប្បីដល់ការប្រកៀកកាយមានចាប់ដៃជាដើម គឺ ជាអ្នកស្ទាបអង្អែលដោយកាយ ។ ក៏កាយសំសគ្គៈរបស់ភិក្ខុដែលចូលដល់ការស្ទាបអង្អែលដោយកាយនុ៎ះឯង ដោយសេចក្ដី រមែងជាអជ្ឈាចារ គឺ ការប្រព្រឹត្តកន្លងដែននៃសំវរៈដោយអំណាចរាគៈ ; ព្រោះហេតុនោះ ព្រះមានព្រះភាគកាលនឹងទ្រង់សម្ដែងសេចក្ដីដោយសង្ខេបនៃពីរបទនោះ ទើបត្រាស់បទភាជនៈថា "សេចក្ដីប្រព្រឹត្តល្មើស" ។

បទថា ហត្ថគ្គាហំ វា : ទោះចាប់ដៃក្ដីជាដើម ជាបទចែករបស់ពីរបទនោះ លោកសម្ដែងដោយពិស្ដារ ក្នុងសិក្ខាបទនេះ ។ ព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា ហត្ថោ នាម កប្បរំ[1] ឧបាទាយ : សរីរប្រទេសរាប់តាំងពីត្រឹមជុំដៃ ហៅថា ដៃ ដើម្បីសម្ដែងវិភាគនៃអវយវៈមានដៃជាដើម ក្នុងបទភាជនៈនោះ ។

---

១. បិដកខ្មែរ. កប្បុរំ ; ថៃ. កុប្បរំ ។

បណ្តាបទទាំងនោះ ពីរបទថា កាបរំ ឧទ្ទាងាយ : សរីរប្រទេសរាប់តាំងពីត្រឹមជុំដៃ មានសេចក្តីថា សំដៅដល់ទីតជំទីពីរ (តាំងពីកែងដៃចុះទៅ) ។ តែក្នុងទីដទៃតាំងពីដើមដៃដល់ចុងក្រចក ចាត់ជាដៃ ។ ក្នុងទីនេះ ប្រាថ្នា តាំងពីកែងដៃព្រមទាំងចុងក្រចក ។

បទថា សុទ្ធកេសា[១] វា : សក់សុទ្ធក្តី បានដល់ សក់ដែលមិនលាយឡំដោយអំបោះជាដើម គឺសក់សុទ្ធ ៗ ទុំះឯង ។ ពាក្យថា ផ្នូននេះ ជាឈ្មោះរបស់កម្រងសក់ដែលក្រងដោយសក់ ៣ ធ្នូង ៗ ។

បទថា សុត្តមិស្សា : សក់លាយដោយអំបោះក្តី បានដល់ ផ្នូនសក់ដែលគេយកអំបោះ ៥ ពណ៌ដោតចូលទៅក្នុងសក់ ។

បទថា មាលាមិស្សា : លាយដោយផ្កាកម្រងក្តី បានដល់ ផ្នូនសក់ដែលគេដោតចូលទៅ ដោយផ្កាម្លិះជាដើម ឬក្រងដោយសក់ ៣ ធ្នូង ៗ ។ ម្យ៉ាងទៀត បាច់សក់ដែលចាក់ចូលទៅដោយផ្កាឈើតែម្យ៉ាងសូម្បីមិនបាន ក្រង ក៏គប្បីជ្រាបថា ផ្នូនសក់ ក្នុងទីនេះ ។

បទថា ហិរញ្ញមិស្សា : លាយដោយប្រាក់ក្តី បានដល់ ផ្នូនសក់ដែលដោតចូលដោយរបៀបកហាបណៈ ។

១. ថៃ. សុទ្ធកេសានំ ។

បទថា **សុវណ្ណាមិស្សា : លាយដោយមាសក្តី** បានដល់ ផ្នួងសក់ដែលប្រដាប់ដោយខ្សែមាស ឬដោយសន្ធារជាដើម ។

បទថា **មុត្តាមិស្សា : លាយដោយកែវមុក្តាក្តី** បានដល់ ផ្នួងសក់ដែលប្រដាប់ដោយកែវមុក្តា ។

បទថា **មណិមិស្សា : លាយដោយកែវមណីក្តី** បានដល់ ផ្នួងសក់ដែលប្រដាប់ដោយកែវមណីក្រងអំបោះ ។ ពិតមែន កាលភិក្ខុចាប់ផ្នួងសក់ប្រភេទណា មួយក្នុងផ្នួងទាំងនេះ ត្រូវអាបត្តិសង្ឃាទិសេសទាំងអស់ ។ ការរួចផុត មិនមានដល់ភិក្ខុដែលគេចកែខ្លួនថា "ខ្ញុំព្រះករុណាបាន ចាប់ផ្នួងសក់ដែលលាយ" ។

ចំណែកសក់ ជាការដែលព្រះមានព្រះភាគកាន់យកដោយ **វេណិ** ស័ព្ទ ក្នុងបទថា **វេណិគ្គាហំ : ចាប់ផ្នួងសក់** នេះ, ព្រោះហេតុនោះ សូម្បីភិក្ខុណាចាប់សក់តែមួយសរសៃ, ភិក្ខុនោះ ក៏ត្រូវអាបត្តិដូចគ្នា ។

រាងកាយដ៏សេស វៀរដៃនិងផ្នួងសក់មានប្រការគ្រប់យ៉ាង មានលក្ខណៈដូចដែលពោលហើយ ក្នុងពាក្យថា ហត្ថញ្ច វេណិញ្ច ឋបេត្វា : **លើកលែងតែដៃនិងផ្នួងសក់ចេញ** នេះ គប្បីជ្រាបថា អវយវៈ ។ បណ្តាអវយវៈមានដៃជាដើម ដែលកំណត់ហើយយ៉ាងនេះ ការចាប់ដៃ ឈ្មោះថា ហត្ថគ្គាហៈ ។ ការចាប់ផ្នួងសក់ ឈ្មោះថា

វេណិគ្គាហៈ ។ ការស្ទាបអវៃ្ទលសរីរៈដ៏សេស ឈ្មោះថា ការស្ទាបអង្អែលអវយវៈយ៉ាងណាមួយក៏ដោយ ។ អត្ថនេះថា ភិក្ខុណាគប្បីដល់ការចាប់ដៃក៏ដោយ ការចាប់ផ្នួងសក់ក៏ដោយ ការស្ទាបអង្អែលអវយវៈយ៉ាងណាមួយក៏ដោយ, ជាកងអាបត្តិសង្ឃាទិសេសដល់ភិក្ខុនោះ ដូច្នេះ ជាសេចក្ដីនៃសិក្ខាបទ ។

## អត្ថាធិប្បាយបទភាជនីយ៍

### ការចាប់ដៃជាដើម

[៧៧] មួយទៀត ការចាប់ដៃក្តី ការចាប់ផ្នួងសក់ក្តី ការស្ទាបអង្អែលអវយវៈដ៏សេសក្តី ទាំងអស់ដោយសេចក្ដីផ្សេងគ្នាមាន ១២ យ៉ាង ; ព្រោះដូច្នោះ ដើម្បីសម្តែងសេចក្ដីផ្សេងគ្នានោះ ទើបព្រះមានព្រះភាគត្រាស់បទភាជនៈនៃបទថា ហត្ថគ្គាហៈជាដើមនោះ ដោយន័យមានជាដើមថា អាមសនា បរាមសនា : កិរិយាស្ទាប អង្អែល ដូច្នេះ ។

[៧៨] បណ្ដាបទថា អាមសនា : កិរិយាស្ទាបជាដើមនោះ ពីរបទដែលព្រះមានព្រះភាគត្រាស់ថា អាមសនា ឆាម អាមដ្ឋមត្តា : កិរិយាដែលគ្រាន់តែលូកពាល់ ហៅថា ស្ទាប និងថា ឆុបនំ ឆាម ឆុដ្ឋមត្តា : កិរិយាប៉ះត្រូវ ហៅថា ពាល់ នេះមានសេចក្ដីប្លែកគ្នាដូច

តទៅនេះ ៖

ការពាល់ត្រូវ គឺ ការត្រេដុសក្នុងឱកាសដែលពាល់ត្រូវប៉ុណ្ណោះ មិនដល់នឹងហួសឱកាសដែលពាល់ត្រូវ ឈ្មោះថា អាមសនា ។ ពិតមែនការត្រេដុសនេះ ព្រះមានព្រះភាគត្រាស់ ហៅថា អាមដ្ឋមត្តា ។ កិរិយាត្រឹមតែពាល់ត្រូវមិនត្រេដុស ឈ្មោះថា ឆុបនំ ។ សូម្បីក្នុងបទជាមួយគ្នានុ៎ះឯង ដែលព្រះមានព្រះភាគត្រាស់ទុក ក្នុងនិទ្ទេសនៃឧម្មសនា និង ឧល្លង្ឃនា ថា ឧទ្ធំ ឧច្ចារណា : កិរិយាចាប់ផ្ងារទៅខាងលើ ដូច្នេះ ក៏មានសេចក្តីប្លែកគ្នាដូចតទៅនេះ ៖

បទទី ១ ត្រាស់ដោយអំណាចនៃកាយរបស់ខ្លួនពាល់ត្រូវ ខាងលើកាយរបស់ស្រី ។ បទទី ២ ត្រាស់ដោយអំណាចនៃការលើកកាយរបស់ស្ត្រីឡើង ។ បទដ៏សេស ប្រាកដច្បាស់ហើយនោះឯង ។

[៨០] ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងប្រភេទនៃអាបត្តិយ៉ាងពិស្តារ ដោយអំណាចនៃបទទាំងនេះ របស់ភិក្ខុដែលត្រូវរាគៈគ្របសង្កត់ហើយមានចិត្តប្រែប្រួលដល់ការស្ទាបអង្អែលកាយ ទើបត្រាស់ពាក្យជាដើមថា "មនុស្សស្រីពិត ភិក្ខុសម្គាល់ថា ជាស្រី មានសេចក្តីត្រេកអរ ក៏យកកាយ (ខ្លួន) ស្ទាប ។ល។ ពាល់ កាយស្រីនោះ" ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះ ដូច្នេះ ៖

ពាក្យថា **ភិក្ខុ ច នំ ឥត្ថិយា កាយេន កាយំ :** ភិក្ខុក៏យកកាយ... កាយស្រីនោះ សេចក្តីថា ភិក្ខុនោះមានសេចក្តីតម្រេក ១ មានការសម្គាល់ថា ជាស្រី ១ (ស្ទាបអង្អែលកាយរបស់ស្រី) ដោយកាយរបស់ខ្លួន ។ បទថា នំ ត្រឹមតែជានិបាត ។ ម្យ៉ាងទៀត សេចក្តីថា (ស្ទាបអង្អែល) កាយនោះ គឺ កាយមានដៃជាដើមរបស់ស្រីនោះ ។

ពាក្យថា **អាមសតិ បរាមសតិ : ស្ទាប អង្អែល** សេចក្តីថា ក៏ភិក្ខុប្រព្រឹត្តកន្លងល្មើសដោយអាការសូម្បីតែម្យ៉ាង បណ្តាការចាប់ពាល់ជាដើម ទាំងនេះ ត្រូវអាបត្តិសង្ឃាទិសេស, ក្នុងការចាប់ពាល់ជាដើមនោះ កាលភិក្ខុចាប់ពាល់ម្តងត្រូវអាបត្តិមួយ, កាលចាប់ពាល់រឿយ ៗ ជាអាបត្តិសង្ឃាទិសេសគ្រប់ ៗ ប្រយោគ ។ សូម្បីកាលស្ទាបអង្អែល បើមិនលែងឱ្យផុតពីកាយ វី បង្វិល រុញ ដៃក្តី កាយក្តី របស់ខ្លួនទៅខាងឯនេះ ខាងឯណោះ, កាលស្ទាបអង្អែល សូម្បីអស់មួយថ្ងៃ ក៏ត្រូវអាបត្តិតែមួយប៉ុណ្ណោះ, បើលែងឱ្យផុតពីកាយ ហើយស្ទាបអង្អែលញយ ៗ ក៏ត្រូវអាបត្តិគ្រប់ ៗ ប្រយោគ ។ កាលស្ទាបចុះ បើមិនឱ្យផុតពីកាយ ស្ទាបតាំងពីក្បាលរបស់ស្រី ចុះទៅដរាបដល់ខ្នងជើង ក៏ត្រូវអាបត្តិត្រឹមតែមួយ ។ ក៏បើថា ដល់ទីនោះ ៗ បណ្តាទីមានពោះជាដើម

លែង(ដៃ) ហើយស្ទាបចុះទៅ, ត្រូវអាបត្តិគ្រប់ ៗ ប្រយោគ ។

គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុងការស្ទាបឡើង ដូច្នេះ ៖

កាលភិក្ខុស្ទាបឡើងតាំងពីជើងទៅដរាបដល់ក្បាល ក៏មាន ន័យយ៉ាងនេះដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការផ្ទុបចុះ ដូច្នេះ ៖

កាលភិក្ខុចាប់មាតុគ្រាមត្រង់សក់ហើយសង្កត់ ធ្វើអជ្ឈាចារតាមប្រាថ្នា មានការថើបជាដើម ហើយលែងត្រូវអាបត្តិតែមួយ ។ កាលភិក្ខុសង្កត់ស្រីដែលងើយឡើងហើយ ឱ្យឱនចុះរឿយ ៗ ជាអាបត្តិគ្រប់ ៗ ប្រយោគ ។

គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុងការផ្ងើយឡើង ដូច្នេះ ៖

កាលភិក្ខុចាប់មាតុគ្រាមត្រង់សក់ក្តី ត្រង់ដៃទាំងពីរក្តី ឱ្យក្រោកឡើង មានន័យយ៉ាងនេះដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការទាញមក ដូច្នេះ ៖

ភិក្ខុទាញមាតុគ្រាមឱ្យបែរមុខមករកខ្លួន មិនទាន់លែង(ដៃ) ត្រឹមណា ត្រូវអាបត្តិតែមួយប៉ុណ្ណោះឯង ។ កាលដក(ដៃ) ហើយ ត្រឡប់ទាញមកទៀត ត្រូវអាបត្តិគ្រប់ប្រយោគ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការទាញត្រឡប់ ដូច្នេះ ៖

ក៏កាលភិក្ខុចាប់ត្រង់ខ្នងមាតុគ្រាម ហើយប្រានទៅ មានន័យដូច្នេះដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការចាប់សង្កត់ ដូច្នេះ ៖

កាលភិក្ខុចាប់ត្រង់ដៃ ឬត្រង់ដើមដៃមាតុគ្រាមឱ្យណែនហើយ ដើរទៅសូម្បីអស់ចម្ងាយមួយយោជន៍ ត្រូវអាបត្តិត្រឹមតែមួយ ។ កាលលែងហើយចាប់ ៗ ត្រូវអាបត្តិគ្រប់ប្រយោគនៃការចាប់, ព្រះមហាសុមត្ថេរៈពោលថា កាលមិនលែង ពាល់ត្រូវ ឬឱបរឹតរឿយ ៗ ត្រូវអាបត្តិគ្រប់ប្រយោគ ។

ចំណែកព្រះមហាបទុមត្ថេរៈពោលថា ការចាប់តាំងពីដើមនុំះឯងជាប្រមាណ, ព្រោះហេតុនោះ ភិក្ខុមិនទាន់ដក ( ដៃ ) ដរាបណា ត្រូវអាបត្តិត្រឹមតែមួយ ដរាបនោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការចាប់ឈ្ងួច ដូច្នេះ ៖

កាលភិក្ខុប្របាច់ព្រមដោយសំពត់ក្ដី ដោយគ្រឿងប្រដាប់ក្ដី មិនពាល់ត្រូវខ្លួន ត្រូវអាបត្តិថុល្លច្ច័យ, កាលពាល់ត្រូវខ្លួន ត្រូវអាបត្តិសង្ឃាទិសេស ។ ត្រូវអាបត្តិតែមួយដោយប្រយោគតែមួយ, ត្រូវអាបត្តិផ្សេង ៗ ដោយប្រយោគផ្សេង ៗគ្នា ។ ក្នុងការចាប់និងពាល់ត្រូវ សូម្បីកាលមិនធ្វើវិការណា ៗដទៃ រមែងត្រូវអាបត្តិសូម្បីដោយអាការត្រឹមតែចាប់ ត្រឹមតែពាល់ត្រូវ ។

បណ្ដាអាការ មានការចាប់ពាល់ជាដើមនេះ ដូចពោលមកនេះ កាលភិក្ខុមានការសម្គាល់ក្នុងស្រីថា ជាមនុស្សស្រីប្រព្រឹត្តកន្លងល្មើស ដោយអាការសូម្បីមួយយ៉ាង ជាអាបត្តិសង្ឃាទិសេស ។ ជាអាបត្តិថុល្លច្ច័យដល់ភិក្ខុដែលមានសេចក្ដីសង្ស័យ, សូម្បីភិក្ខុសម្គាល់ក្នុងស្រីថា ជាបណ្ឌកៈ ជាបុរស និងជាតិរច្ឆាន ក៏ជាអាបត្តិថុល្លច្ច័យ ដូចគ្នា ។ ជាអាបត្តិថុល្លច្ច័យដល់ភិក្ខុដែលមានការសម្គាល់ក្នុងបណ្ឌកៈថា ជាបណ្ឌកៈ ជាអាបត្តិទុក្កដដល់ភិក្ខុ ដែលមានសេចក្ដីសង្ស័យ ។ សម្រាប់ភិក្ខុដែលសម្គាល់ (ក្នុងបណ្ឌកៈ)ថា ជាបុរស ជាតិរច្ឆាន និងជាស្រី ជាតូវអាបត្តិទុក្កដដូចគ្នា ។ ភិក្ខុមានការសម្គាល់ក្នុងបុរសថា ជាបុរសក្ដី មានសេចក្ដីសង្ស័យ ក្ដី មានការសម្គាល់ថា ជាស្រី ជាបណ្ឌកៈ ជាសត្វតិរច្ឆានក្ដី ជាអាបត្តិទុក្កដទាំងអស់នោះ ។ សូម្បីក្នុងសត្វតិរច្ឆាន ក៏ជាតូវអាបត្តិទុក្កដ ដោយអាការគ្រប់យ៉ាងដូចគ្នានោះឯង ។

[៨១] បណ្ឌិតគប្បីកំណត់អាបត្តិទាំងនេះ ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងឯកមូលកន័យ ហើយជ្រាបអាបត្តិទ្វេគុណ សូម្បីក្នុងទ្វិមូលកន័យដែលត្រាស់ដោយឧបាយនេះ និងដោយអំណាចនៃពាក្យថា ទ្វេ ឥត្ថិយោ ទ្វិន្នំ ឥត្ថីនំ : ស្រីពីរនាក់ ... ជាស្រីទាំងពីរនាក់ ជាដើម ។

ដូចឧបមាថា ក្នុងស្រី ២ នាក់ គប្បីជ្រាបសង្ឃាទិសេស ២

យ៉ាងណា ក្នុងស្រីច្រើននាក់ គប្បីជ្រាបសង្ឃាទិសេសច្រើនយ៉ាងនោះ ។ ពិតមែន ភិក្ខុណាយកដៃទាំងពីរចាប់ឱបស្រីច្រើននាក់ដែលនៅរួមគ្នា ភិក្ខុនោះត្រូវសង្ឃាទិសេសច្រើន តាមរាប់ចំនួនស្រីដែលខ្លួនពាល់ត្រូវ, ជាថុល្លច្ច័យ ដោយការរាប់តាមចំនួនស្រីដែលនៅកណ្តាល (មិនបានប៉ះ) ។ ពិតមែន ភិក្ខុនោះរមែងជាការចាប់ពាល់ស្រីទាំងនោះ ដោយរបស់ជាប់នឹងកាយ ។

មួយទៀត ភិក្ខុណា ចាប់ម្រាមដៃ ឬសក់របស់ស្រីចំនួនច្រើនរួមគ្នា, ភិក្ខុនោះ ព្រះវិន័យធរ កុំរាប់ម្រាមដៃ ឬសរសៃសក់ពិន័យអាបត្តិ គប្បីរាប់ស្រីពិន័យដោយអាបត្តិសង្ឃាទិសេស និងលោករមែងត្រូវអាបត្តិថុល្លច្ច័យដោយរាប់តាមចំនួនស្រីទាំងឡាយ ដែលមានម្រាមដៃនិងសក់នៅចន្លោះកណ្តាល ។ ពិតមែន ភិក្ខុនោះរមែងជាការចាប់ពាល់ស្រីទាំងនោះ ដោយរបស់ជាប់នឹងកាយ ។ តែកាលភិក្ខុចាប់ឱបស្រីច្រើន ដោយរបស់ដែលជាប់នឹងកាយ មានខ្សែនិងសំពត់ជាដើម រមែងជាអាបត្តិថុល្លច្ច័យ ដោយរាប់តាមចំនួនស្រីទាំងអស់ដែលនៅខាងក្នុងរង្វង់ព័ទ្ធជុំវិញនោះឯង ។ ក្នុងមហាបច្ចរីលោកពិន័យទុក្កដ ក្នុងពួកស្រីដែល (ខ្សែជាដើម) មិនបានពាល់ត្រូវផង ។ បណ្តានន័យមុន និងន័យដែលលោកពោលទុកក្នុងមហាបច្ចរីនោះ ដែលឈ្មោះថា ការចាប់ពាល់របស់ជាប់នឹង

កាយ ជាមួយនឹងរបស់ជាប់នឹងកាយ មិនមានក្នុងបាលី ; ព្រោះដូច្នោះឯង ន័យមុនដែលលោក រួបរួមរបស់ជាប់នឹងកាយទាំងអស់ចូលជាមួយនឹងគ្នា ពោលទុកក្នុងមហាអដ្ឋកថា និងកុរុន្ទី ប្រាកដជា ត្រឹមត្រូវជាងក្នុងអធិការនេះ ។

ក៏ភិក្ខុណាមានសេចក្តីតម្រេកខ្លាំងប៉ុនគ្នា ក្នុងស្រីទាំងឡាយ ដែលឈរយកដៃចាប់ដៃគ្នានៅតាមលំដាប់ ចាប់ស្រីម្នាក់ត្រង់ដៃ, ភិក្ខុនោះរមែងត្រូវអាបត្តិសង្ឃាទិសេសតែមួយ ដោយអំណាចនៃស្រីដែលខ្លួនចាប់, ត្រូវអាបត្តិថុល្លច្ច័យច្រើន តាមចំនួននៃស្រីក្រៅនេះ ដោយន័យមុននុ៎ះឯង ។ បើថា ភិក្ខុនោះចាប់ស្រីនោះ ត្រង់សំពត់ ឬត្រង់ផ្កាឈើដែលជារបស់ជាប់នឹងកាយ, រមែងត្រូវអាបត្តិថុល្លច្ច័យច្រើន តាមចំនួននៃស្រីទាំងអស់ ។ ដូចជាភិក្ខុចាប់ឱបស្រីទាំងឡាយ ដោយខ្សែនិងសំពត់ជាដើម រមែងជាការចាប់ពាល់ស្រីសូម្បីទាំងអស់ ដោយរបស់ជាប់នឹងកាយយ៉ាងណា, សូម្បីក្នុងអធិការនេះ ភិក្ខុក៏ជាការចាប់ពាល់ស្រីទាំងអស់ហើយ ដោយរបស់ជាប់នឹងកាយ យ៉ាងនោះដែរ ដូច្នេះឯង ។

ក៏បើថា ស្រីទាំងនោះឈរចាប់គ្នានិងគ្នាត្រង់ជាយសំពត់, ភិក្ខុនេះចាប់ស្រីដំបូង (ឬស្រីណាមួយ)ក្នុងបណ្តាស្រីទាំងនោះ ត្រង់ដៃ, ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស ដោយអំណាចនៃស្រីអ្នកដែលខ្លួនចាប់, ត្រូវទុក្កដច្រើនតាមចំនួននៃស្រីក្រៅនេះ ដោយន័យមុននុ៎ះឯង ។ ព្រោះ

ថា របស់ដែលជាប់ដោយកាយ ជាមួយនឹងរបស់ដែលជាប់ដោយកាយ របស់ស្រីទាំងអស់នោះ ជាការដែលភិក្ខុនោះចាប់ពាល់ហើយ ដោយន័យមុនដូចគ្នា ។ ក៏បើថា ភិក្ខុចាប់ស្រីនោះត្រង់របស់ដែលជាប់នឹងកាយប៉ុណ្ណោះ រមែងត្រូវអាបត្តិថុល្ល័យ, ត្រូវទុក្កដច្រើនតាមចំនួននៃស្រីក្រៅនេះ ដោយន័យបន្ទាប់នុ៎ះឯង ។

ក៏ភិក្ខុណា ដែលមនុស្សស្រីស្លៀកសំពត់ក្រាស់ ប៉ះសំពត់ដោយកាយសំសគ្គរាគៈ, ភិក្ខុនោះត្រូវថុល្លច្ច័យ ។ ប៉ះត្រូវសំពត់ស្ដើងដែលមនុស្សស្រីស្លៀក, បើថា ក្នុងទីដែលប៉ះនោះ រោមរបស់មនុស្សស្រីដែលចាក់ចេញតាមរន្ធសំពត់ប៉ះកាយភិក្ខុ ឬរោមរបស់ភិក្ខុចាក់ចូលទៅប៉ះកាយស្រី ឬរោមទាំងពីរផ្ទែកប៉ះគ្នាប៉ុណ្ណោះ, ត្រូវអាបត្តិសង្ឃាទិសេស ។ ព្រោះថា សូម្បីប៉ះត្រូវរូបដែលមានវិញ្ញាណគ្រប់គ្រង ឬមិនមានវិញ្ញាណគ្រប់គ្រង (របស់ស្រី) ដោយកម្មជរូបដែលមានវិញ្ញាណ (របស់ខ្លួន) ក្ដី ប៉ះត្រូវរូប ដែលមានវិញ្ញាណគ្រប់គ្រង ឬមិនមានវិញ្ញាណគ្រប់គ្រង (របស់ស្រី) ដោយសក់ជាដើម សូម្បីមិនមានវិញ្ញាណគ្រប់គ្រងក្ដី រមែងត្រូវអាបត្តិសង្ឃាទិសេស ដូចគ្នា ។ ក្នុងការដែលរោមនិងរោមប៉ះគ្នានោះ ក្នុងកុរុន្ទីពោលថា គប្បីរាប់រោមពិន័យសង្ឃាទិសេស ។ តែក្នុងមហាអដ្ឋកថា ពោលថា មិនគួររាប់រោមពិន័យអាបត្តិ, ភិក្ខុនោះ ត្រូវអាបត្តិសង្ឃាទិសេស តែមួយប៉ុណ្ណោះ ចំណែកភិក្ខុមិនក្រាល ដេកលើ

គ្រែរបស់សង្ឃ ទើបគួររាប់រោមពិន័យអាបត្តិ ។ ពាក្យរបស់ព្រះអដ្ឋកថានុ៎ះឯង ត្រឹមត្រូវ ។ ព្រោះថា អាបត្តិនេះ ពិន័យ ដោយអំណាចនៃស្រី មិនមែន ពិន័យដោយអំណាចនៃចំណែកដូច្នេះឯង ។

## សេចក្តីផ្សេងគ្នានៃមតិរបស់ព្រះថេរៈ ២ រូប

ក្នុងអធិការនេះ លោកតាំងពាក្យសួរថា ក៏ភិក្ខុណា គិតថា នឹងចាប់របស់ជាប់នឹងកាយ ហើយចាប់កាយក្តី គិតថា នឹងចាប់កាយ ហើយចាប់របស់ជាប់នឹងកាយក្តី ភិក្ខុនោះត្រូវអាបត្តិអ្វី ?

ព្រះសូមត្ថេរៈតបមុនថា ត្រូវអាបត្តិតាមវត្ថុប៉ុណ្ណោះ ។ បានឮថា លទ្ធិរបស់លោកមានដូច្នេះ ៖

វត្ថុ ១ សញ្ញា ១ រាគៈ ១ សេចក្តីទទួលដឹងផស្សៈ
១ ព្រោះ ដូច្នោះ គួរពិន័យគរុកាបត្តិ ដែលពោល
ហើយ ក្នុងនិទ្ទេសតាម ដែលទ្រង់អធិប្បាយទុក ។

ក្នុងគាថានេះ វត្ថុ នោះ បានដល់ មនុស្សស្រី ។ សញ្ញា នោះ បានដល់ ការសម្គាល់ថា ជាមនុស្សស្រី ។ រាគៈ នោះ បានដល់ សេចក្តីតម្រេកក្នុងការស្ទាបអង្អែលដោយកាយ ។ ការទទួលដឹងផស្សៈ នោះ បានដល់ សេចក្តីរលឹកដឹងផស្សៈក្នុងការស្ទាបអង្អែលដោយកាយ ។ ព្រោះដូច្នោះ ភិក្ខុណា មានការសម្គាល់ថា ជាមនុស្សស្រី

ដោយសេចក្ដីតម្រេកក្នុងការស្ទាបអង្អែលដោយកាយ គិតថា ទីងចាប់របស់ជាប់នឹងកាយ សូម្បីភ្ជាត់ទៅត្រូវកាយ, ភិក្ខុនោះ ត្រូវសង្ឃាទិសេសជាទោសធ្ងន់ពិត, ចំណែកភិក្ខុក្រៅនេះ ត្រូវថុល្លច្ច័យដូច្នេះឯង ។

ចំណែកព្រះមហាបទុមត្ថេរៈ ពោលថា

កាលការសម្គាល់ខុសទៅ និងការចាប់ភ្លាត់ទៅ អាបត្តិធ្ងន់ក្នុងនិទ្ទេសតាមដែលទ្រង់អធិប្បាយទុក រមែងមិនប្រាកដក្នុងការចាប់នោះ ។

លទ្ធិរបស់លោក មានដូច្នេះ ៖

ពិតមែន លោកពិន័យសង្ឃាទិសេសដល់ភិក្ខុដែលមានការសម្គាល់ក្នុងមនុស្សស្រីថា ជាមនុស្សស្រី, តែការសម្គាល់ថា ជាមនុស្សស្រីដែលភិក្ខុនេះឱ្យឃ្លាតចេញ, ការសម្គាល់ក្នុងរបស់ជាប់នឹងកាយថា ជារបស់ជាប់នឹងកាយ ដែលលោកឱ្យកើតឡើងហើយ, ក៏កាលលោកចាប់របស់ជាប់នឹងកាយនោះ លោកពិន័យថុល្លច្ច័យ ។

មួយទៀត ការចាប់របស់ភិក្ខុនេះ ក៏ឱ្យឃ្លាតចេញ, លោកមិនបានចាប់របស់ជាប់នឹងកាយនោះ តែបានចាប់មនុស្សស្រី ; ព្រោះដូច្នោះ សង្ឃាទិសេស ឈ្មោះថា មិនទាន់ប្រាកដ ព្រោះការចាប់នេះ មិនមានការសម្គាល់ថា ជាមនុស្សស្រី, ថុល្លច្ច័យ ឈ្មោះថា មិនប្រាកដ ព្រោះរបស់ជាប់នឹងកាយ លោកក៏មិនបានចាប់, តែពិន័យអាបត្តិទុក្កដ ព្រោះ

លោកពាល់ត្រូវដោយកាយ សំសគ្គរាគៈ, ពិតមែន កាលពាល់ត្រូវវត្ថុដូច្នេះ ដោយកាយសំសគ្គរាគៈ ពាក្យថា មិនត្រូវអាបត្តិ មិនមាន ; ព្រោះដូច្នោះ ទើបត្រូវអាបត្តិទុក្កដពិត ។

លុះ(ព្រះមហាបទុមត្ថេរៈ)ពោលពាក្យនេះហើយ ទើបពោលចតុក្កៈនេះថា ភិក្ខុគិតថា នឹងចាប់រូបដែលមានសេចក្តីតម្រេក ហើយចាប់រូបដែលមានសេចក្តីតម្រេក ត្រូវអាបត្តិសង្ឃាទិសេស, គិតថា នឹងចាប់រូបដែលប្រាសចាកសេចក្តីតម្រេក ហើយចាប់រូបដែលប្រាសចាកសេចក្តីតម្រេក ត្រូវអាបត្តិទុក្កដ ។ គិតថា នឹងចាប់រូបដែលមានសេចក្តីតម្រេកភ្លាត់ទៅចាប់រូបដែលប្រាសចាកសេចក្តីតម្រេក ត្រូវអាបត្តិទុក្កដ គិតថា នឹងចាប់រូបដែលប្រាសចាកសេចក្តីតម្រេក ភ្លាត់ទៅចាប់រូបដែលមានសេចក្តីតម្រេក ត្រូវអាបត្តិទុក្កដដូចគ្នា ។

ព្រះមហាបទុមត្ថេរៈពោលហើយយ៉ាងនេះ ក៏ពិតមែនហើយ តែថា បណ្តាវាទៈរបស់ព្រះថេរៈទាំងពីរនេះ វាទៈរបស់ព្រះមហាសុមត្ថេរៈប៉ុណ្ណោះ រមែងសមដោយព្រះបាលីនេះថា "ស្រីជាប្រាកដ ភិក្ខុសម្គាល់ថា ជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល ។ល ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយស្រីនោះ ដោយកាយ(របស់ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យ" និងដោយវិនិច្ឆ័យក្នុងអដ្ឋកថាមានជាដើមថា ក៏ភិក្ខុ

ណា យកដៃទាំងពីរចាប់ឱបស្រី ច្រើនអ្នកដែលឈររួមគ្នា, ភិក្ខុនោះ ត្រូវសង្ឃាទិសេសតាមចំនួនស្រីដែលខ្លួនពាល់ត្រូវ ដូច្នេះ ។

ក៏បើថា ការចាប់ ឈ្មោះថា ភ្លាត់ទៅ ដោយសេចក្តីភ្លាត់នៃសញ្ញា ជាដើមគប្បីមានសោត, ព្រះមានព្រះភាគ គប្បីត្រាស់សេចក្តីប្លែកនៃបាលី ដោយន័យជាដើមថា កាយបដិពទ្ធញ្ច ហោតិ កាយសញ្ញី ច : របស់ជាប់ដោយកាយពិត តែភិក្ខុសំគាល់ថា កាយ១ ដូច្នេះខ្លះ ដូចត្រាស់ទុកក្នុងបាលីជាដើមថា បណ្ឌកោ ច ហោតិ ឥត្ថីសញ្ញី : មនុស្សខ្ទើយពិត តែភិក្ខុសំគាល់ថា ស្រី ដូច្នេះ ។ ក៏ព្រោះសេចក្តីប្លែកគ្នានោះ ព្រះមានព្រះភាគមិនត្រាស់ទុកហើយ; ដូច្នោះ សមគួរតាមវត្ថុថា កាលមានការសម្គាល់ក្នុងមនុស្សស្រីថា ជាមនុស្សស្រី ត្រូវអាបត្តិសង្ឃាទិសេស ដល់ភិក្ខុដែលពាល់ត្រូវកាយមនុស្សស្រី, ត្រូវអាបត្តិថុល្លច្ច័យ ដល់ភិក្ខុដែលប៉ះរបស់ជាប់ នឹងកាយ ដូច្នេះប៉ុណ្ណោះ រមែងត្រឹមត្រូវ ។

ពិតមែន សូម្បីក្នុងមហាបច្ចរី លោកពោលថា កាលស្រីខ្ទៅដណ្តប់សំពត់ពណ៌ខៀវដេក ភិក្ខុគិតថា នឹងប៉ះពាល់កាយ ហើយប៉ះពាល់កាយ ត្រូវអាបត្តិសង្ឃាទិសេស, គិតថា នឹងប៉ះពាល់កាយ ហើយប៉ះពាល់សំពត់ពណ៌ខៀវ ត្រូវអាបត្តិថុល្លច្ច័យ, គិតថា នឹងប៉ះពាល់

សំពត់ខៀវ ហើយប៉ះពាល់កាយវិញ ត្រូវអាបត្តិសង្ឃាទិសេស, គិតថា នឹងប៉ះពាល់សំពត់ខៀវហើយប៉ះពាល់សំពត់ខៀវ ត្រូវអាបត្តិថុល្លច្ច័យ ។

[៨២] ក៏វត្ថុមិស្សកន័យណា ដែលព្រះមានព្រះភាគត្រាស់ទុក ដោយន័យមានពាក្យថា ឥត្ថី ច បណ្ឌកោ ច : **ស្រីនិងខ្ទើយជាដើម**, ក្នុងមិស្សកវត្ថុសូម្បីនោះ អាបត្តិទាំងឡាយដែលព្រះអង្គត្រាស់ទុក ដោយអំណាចការសម្គាល់ និងការសម្គាល់ខុសក្នុងវត្ថុ ដែលអ្នកមិនភាន់ច្រឡំក្នុងព្រះបាលី គប្បីជ្រាប ។

[៨៣] ចំណែកក្នុងវារៈពោលអំពីរបស់ជាប់កាយជាមួយនឹងកាយ កាលភិក្ខុមានការសម្គាល់ក្នុងមនុស្សស្រីថា ជាមនុស្សស្រី និងចាប់របស់ជាប់នឹងកាយ ត្រូវអាបត្តិថុល្លច្ច័យ, ក្នុងបណ្ឌកៈដ៏សេស ត្រូវអាបត្តិទុក្កដគ្រប់ ៗ បទ, សូម្បីក្នុងវារៈ ពោលពីកាយជាមួយនឹងរបស់ជាប់កាយ ក៏មានន័យដូចគ្នានេះ ។

ក្នុងវារៈពោលពីរបស់ជាប់កាយជាមួយនឹងរបស់ដែលជាប់ដោយកាយ ក៏ក្នុងវារៈទាំងឡាយ មានវារៈពោលអំពីកាយជាមួយនឹងរបស់ដែលចោលទៅជាដើម គង់ត្រូវអាបត្តិទុក្កដដល់ភិក្ខុនោះ ដូចគ្នាគ្រប់បទ ។

[៨៤] តែវារៈជាដើមថា ឥត្ថី ច ហោតិ ឥត្ថីសញ្ញី សារត្តោ ច ឥត្ថី ច នំ ភិក្ខុស្ស កាយេន កាយំ : ស្រីជាប្រាកដ ភិក្ខុសំគាល់ថា ជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីនោះសោត ... នូវកាយរបស់ភិក្ខុនោះ ដោយកាយ (របស់ខ្លួន) ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃសេចក្តីតម្រេកខ្លាំងរបស់មាតុគ្រាមក្នុងភិក្ខុ ។

បណ្តាបទទាំងនោះ ច្រើនបទថា ឥត្ថី ច នំ ភិក្ខុស្ស កាយេន កាយំ : ស្រីនោះសោត ... នូវកាយរបស់ភិក្ខុនោះ ដោយកាយ(របស់ខ្លួន) មានសេចក្តីថា ស្រីដែលមានសេចក្តីតម្រេកខ្លាំងក្នុងភិក្ខុ ទើបទៅកាន់ឱកាសដែលលោកអង្គុយ ឬដេកហើយចាប់ពាល់កាយរបស់ភិក្ខុនោះ ដោយកាយរបស់ខ្លួន ។

ពាក្យថា សេវនាធិប្បាយោ កាយេន វាយមតិ ផស្សំ បដិវិជានាតិ : ភិក្ខុមានសេចក្តីប្រាថ្នានឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស មានសេចក្តីថា ភិក្ខុដែលស្រីនោះចាប់ពាល់ហើយ ឬប៉ះយ៉ាងនោះហើយ ជាអ្នកមានសេចក្តីប្រាថ្នាក្នុងការសេព បើកទ្រាក់ ឬកម្រើកកាយ សូម្បីតិច ៗ ដើម្បីទទួលដឹងផស្សៈ, លោកត្រូវសង្ឃាទិសេស ។

ត្រូវអាបត្តិសង្ឃាទិសេស ២ ក្នុងបទថា ស្រី ២ នាក់ នេះ ។ ក្នុងស្រីនិងបណ្ឌកៈត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេសដោយឧបាយនេះ ។ ពាក្យថា "ស្រីនោះសោត ក៏ស្មាបអង្អែលនូវនិស្សគ្គិយវត្ថុរបស់ភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន), ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ, តែមិនដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិទុក្កដ" ដូច្នេះ នៅមានត្រឹមណា, ប្រភេទរបស់អាបត្តិ គប្បីជ្រាបតាមន័យមុនទុំះឯង ត្រឹមនោះ ។

ក៏ឯក្នុងពាក្យនេះ ពាក្យថា កាយេន វាយមតិ ន ច ផស្សំ បដិវិជានាតិ : ក៏ព្យាយាមដោយកាយ តែមិនដឹងច្បាស់នូវផស្ស មានសេចក្តីថា ភិក្ខុឃើញមនុស្សស្រីគ្រវែងផ្កាឈើ ឬផ្លែឈើដែលខ្លួនគ្រវែងទៅ ដោយផ្កាឈើ ឬផ្លែឈើសម្រាប់គ្រវែងរបស់នាង ទើបធ្វើកាយវិការគឺ ផ្ទាត់ម្រាម ឬញាក់ចិញ្ចើម ឬព្រិចភ្នែក ឬធ្វើវិការបែបនោះយ៉ាងដទៃ ភិក្ខុនេះ ហៅថា ព្យាយាមដោយកាយ តែមិនទទួលដឹងផស្សៈ ។ សូម្បីភិក្ខុនេះឈ្មោះថា ត្រូវទុក្កដព្រោះមានសេចក្តីព្យាយាមដោយកាយ ។ មនុស្សស្រី ២ នាក់ ត្រូវអាបត្តិទុក្កដ ២, បណ្ឌកៈនឹងមនុស្សស្រី ត្រូវទុក្កដ ២ ដូចគ្នា ។

# អធិប្បាយអាបត្តិនិងអនាបត្តិដោយលក្ខណៈ

[៨៥] ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រភេទនៃអាបត្តិដោយពិស្តារ ដោយអំណាចនៃវត្ថុយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សម្តែងអាបត្តិ និងអនាបត្តិដោយសង្ខេប ដោយអំណាចលក្ខណៈ ទើបត្រាស់ពាក្យថា សេវនាធិប្បាយោ ជាដើម ។

បណ្តាន័យទាំងនោះ ន័យដំបូងត្រូវអាបត្តិសង្ឃាទិសេស ដោយគ្រប់អង្គ ៣ គឺ ភិក្ខុដែលស្រីមកប៉ះពាល់ ១ មានបំណងក្នុងការសេពក៏ព្យាយាមដោយកាយ ១ ដឹងច្បាស់នូវផស្សៈ ១ ។ ន័យទីពីរត្រូវអាបត្តិទុក្កដ ដោយគ្រប់អង្គ ២ គឺ ព្រោះព្យាយាមដូចក្នុងការប៉ះពាល់និស្សគ្គិយវត្ថុដោយនិស្សគ្គិយវត្ថុ ១ ព្រោះមិនដឹងច្បាស់នូវផស្សៈ ដូចគ្នាក្នុងការមិនប៉ះ ១ ។ ន័យទី ៣ មិនត្រូវអាបត្តិដល់លោកដែលមិនព្យាយាមដោយកាយ ។

ពិតមែន ភិក្ខុណាមានសេចក្តីប្រាថ្នានឹងសេព តែមានការស្ងៀមទទួលដឹង គឺ ត្រេកអរសោយផស្សៈតែម្យ៉ាង, មិនត្រូវអាបត្តិដល់ភិក្ខុនោះ ព្រោះមិនមានអាបត្តិក្នុងអាការត្រឹមតែថា ចិត្តុប្បាទ ។

ចំណែកន័យទី ៤ សូម្បីសេចក្តីទទួលដឹងផស្សៈក៏មិនមាន ដូច

ក្នុងការត្រូវនិស្សគ្គិយវត្ថុ ដោយនិស្សគ្គិយវត្ថុ, មានត្រឹមតែចិត្តុប្បាទតែម្យ៉ាងប៉ុណ្ណោះ; ព្រោះហេតុនោះ ទើបមិនត្រូវអាបត្តិ ។ មិនត្រូវអាបត្តិព្រោះអាការទាំងពួង របស់ភិក្ខុដែលប្រាថ្នានឹងឱ្យផុត ។

ក៏ឯក្នុងឋានៈនេះ គប្បីជ្រាបអធិប្បាយថា ភិក្ខុណាត្រូវមនុស្សស្រីចាប់ នឹងឱ្យស្រីនោះផុតពីសរីរៈរបស់ខ្លួន ទើបប្រាន ឬវាយ, ភិក្ខុនេះឈ្មោះថា ព្យាយាមដោយកាយ ទទួលដឹងផស្សៈ ។ ភិក្ខុណាឃើញមនុស្សស្រីកំពុងមក ប្រាថ្នានឹងឱ្យផុតពីស្រីនោះ ទើបសំឡុតគម្រាមឱ្យចៀសចេញទៅ, ភិក្ខុនេះ ឈ្មោះថា ព្យាយាមដោយកាយ តែមិនទទួលដឹងផស្សៈ ។ ភិក្ខុណាឃើញទីឃជាតិដូច្នោះ លូនឡើងលើកាយ តែមិនរលាស់ដោយគិតថា វាចូរទៅសន្សឹម ៗ, វាត្រូវយើងរលាស់ចូល នឹងប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស, ឬដឹងថា ស្រីប៉ះខ្លួន តែស្ងៀមព្រងើយធ្វើជាមិនដឹងដោយគិតថា ស្រីនេះដឹងថា ភិក្ខុនេះ មិនមានសេចក្ដីត្រូវការយើង ហើយនឹងចៀសទៅខ្លួនឯង ឬភិក្ខុកម្លោះត្រូវមនុស្សស្រីមានកម្លាំងសង្កត់ទុកជាប់ សូម្បីចង់គេចចេញក៏ដោយ តែត្រូវស្ងៀមព្រងើយ ព្រោះត្រូវចាប់ទុកយ៉ាងមាំ, ភិក្ខុនេះ ឈ្មោះថា មិនបានព្យាយាមដោយកាយតែទទួលដឹងផស្សៈ ។ ចំណែកភិក្ខុណាឃើញមនុស្សស្រីមក ហើយជាអ្នកស្ងៀមព្រងើយដោយគិតថា នាងចូរមកចុះ, យើងនឹងវាយ ឬប្រាន

នាងហើយចៀសចេញទៅអំពីនោះ ភិក្ខុនេះ គប្បីជ្រាបថា មានសេចក្តីប្រាថ្នាទីផ្សួចផុតទៅ មិនព្យាយាមដោយកាយ ទាំងមិនទទួលដឹងផស្សៈ ។

[៨៦] បទថា **អសញ្ចិច្ច : ភិក្ខុមិនក្លែង** មានសេចក្តីថា មិនគិតថា យើងនឹងប៉ះមនុស្សស្រីនេះដោយឧបាយនេះ ។ ពិតមែន ព្រោះមិនគិតយ៉ាងនោះ កាលភិក្ខុសូម្បីប៉ះខ្លួនមាតុគ្រាម ដែលចូលក្នុងកាលទទួលបាត្រជាដើម រមែងមិនត្រូវអាបត្តិ ។

បទថា **អសតិយា : ភិក្ខុភ្លេចស្មារតី** មានសេចក្តីថា ភិក្ខុជាអ្នកបញ្ជូនចិត្តទៅក្នុងទីដទៃ គឺ មិនមានសេចក្តីនឹកថា យើងនឹងប៉ះមាតុគ្រាម ព្រោះមិនមានសតិយ៉ាងនេះ មិនត្រូវអាបត្តិដល់ភិក្ខុដែលប៉ះក្នុងវេលាលាតដៃនិងជើងជាដើម ។

បទថា **អជានន្តស្ស : ភិក្ខុមិនដឹង** មានសេចក្តីថា ភិក្ខុឃើញក្មេងស្រីមានភេទស្រដៀងក្មេងប្រុស មិនដឹងថា ជាមនុស្សស្រី ប៉ះដោយករណីយកិច្ចយ៉ាងណាមួយប៉ុណ្ណោះ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនដឹងថា ជាមនុស្សស្រី និងប៉ះពាល់ដោយអាការយ៉ាងនេះ ។

បទថា **អសាទិយន្តស្ស : ភិក្ខុមិនត្រេកអរ** មានសេចក្តីថា មិនត្រូវអាបត្តិ ដល់ភិក្ខុដែលមិនត្រេកអរនឹងការស្ទាបអង្អែលដោយកាយ

ដូចភិក្ខុដែលត្រូវមនុស្សស្រីចាប់ដៃគ្នានិងគ្នាហែហមនាំយកទៅ មិនត្រូវអាបត្តិ ដូច្នោះ ភិក្ខុឆតជាដើម មានន័យដូចពោលហើយនោះឯង ។ និងឧទាយីថេរៈជាអាទិកម្មិកៈក្នុងសិក្ខាបទនេះ មិនត្រូវអាបត្តិដល់លោកដែលជាអាទិកម្មិកៈនោះ ដូច្នេះឯង ។

បទភាជនីយវណ្ណនា ចប់

បណ្តាសមុដ្ឋានជាដើម សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិកសិក្ខាបទ រមែងកើតអំពីកាយនិងចិត្ត ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត មានវេទនា ២ គឺសុខវេទនា និងឧបេក្ខាវេទនា នេះឯង ។

## វិនីតវត្ថុក្នុងសង្ឃាទិសេសសិក្ខាបទទី ២

គប្បីជ្រាបវិនិច្ឆ័យ ក្នុងវិនីតវត្ថុទាំងឡាយតទៅនេះ ៖

[៨៨] ពីរបទថា មាតុយា មាតុប្បេមេន ៖ ចាប់ពាល់មាតាដោយសេចក្តីស្រឡាញ់មាតា សេចក្តីថា រមែងចាប់ពាល់កាយរបស់មាតាដោយសេចក្តីស្រឡាញ់ជាមាតា ។ ក្នុងរឿងកូនស្រីនិងបងប្អូនស្រី ក៏មានន័យនេះដូចគ្នា ។ ក្នុងព្រះបាលីនោះ ព្រះមានព្រះភាគពិន័យអាបត្តិ

ទុក្កដដូចគ្នាទាំងអស់ ដល់ភិក្ខុដែលចាប់ពាល់ ដោយសេចក្ដីស្រឡាញ់អាស្រ័យផុះថា "អ្នកនេះជាមាតារបស់យើង នេះជាធីតារបស់យើង នេះជាបងប្អូនស្រីរបស់យើង" ព្រោះដែលឈ្មោះថា មនុស្សស្រីសូម្បីទាំងអស់ ទោះជាមាតាក៏ដោយ ជាធីតាក៏ដោយ ជាសត្រូវដល់ព្រហ្មចរិយៈទាំងអស់ ។

ក៏កាលភិក្ខុរលឹកដល់ព្រះអាជ្ញារបស់ព្រះមានព្រះភាគនេះ បើសូម្បីថា ឃើញមាតាត្រូវក្រសែទឹកបន្សាត់ទៅ មិនគួរចាប់ពាល់ដោយដៃឡើយ ។ តែភិក្ខុដែលឆ្លាតគប្បីនាំទូក ឬបន្ទះក្ដារ ឬកំណាត់ដើមចេក ឬកំណាត់ឈើចូលទៅឱ្យកាលទូកជាដើមនោះ មិនមាន សូម្បីសំពត់កាសាវៈក៏គួរនាំទៅដាក់ទុកខាងមុខ តែមិនគួរពោលថា "ចូរចាប់ត្រង់នេះ" ។ កាលមាតាចាប់ហើយ គប្បីទាញមកដោយធ្វើក្នុងចិត្តថា "យើងទាញបរិក្ខារមក" ។ ក៏បើមាតាខ្លាច គប្បីទៅខាងមុខ ៗ ហើយលួងលោមថា "កុំខ្លាច", បើមាតា ត្រូវទឹកបន្សាត់ទៅប្រញាប់ឡើង-ក ឬ ចាប់ត្រង់ដៃរបស់ភិក្ខុដែលជាបុត្រ ភិក្ខុកុំរលាស់ឬពោលថា "ចៀស ចៀសទៅស្រីចាស់"ឡើយ គប្បីនាំទៅឱ្យដល់លើគោក ។ កាលមាតាជាប់ល្បាប់ភក់ក្ដី ធ្លាក់ចុះទៅក្នុងអណ្ដូងក្ដី មានន័យដូចគ្នានេះ ។ អធិប្បាយថា ភិក្ខុគប្បីបោះខ្សែ ឬសំពត់ទៅក្នុងភក់ ឬអណ្ដូង ដឹងសភាពដែលមាតាយកដៃចាប់ហើយទាញឡើង តែកុំគប្បីចាប់ពាល់ឡើយ ។

# អធិប្បាយវត្ថុដែលជាអនាមាស

ក៏មិនមែនតែរាងកាយរបស់មាតុគ្រាមតែម៉្យាងប៉ុណ្ណោះ ដែលជាអនាមាស សូម្បីសំពត់ស្លៀកនិងសំពត់ដណ្តប់ក្តី វត្ថុជាគ្រឿងប្រដាប់ក្តី ដោយហោចទៅសូម្បីកម្រងស្មៅក៏ដោយ ចិញ្ចៀនស្លឹកត្នោតក៏ដោយ ក៏ជាអនាមាសទាំងអស់ ។ ក៏ឯសំពត់ស្លៀកនិងសំពត់ដណ្តប់នោះតាំងទុកដើម្បីត្រូវការប្រើជាគ្រឿងប្រដាប់ប៉ុណ្ណោះ ។ ក៏ប្រសិនបើមាតុគ្រាមដាក់សំពត់ស្លៀក ឬសំពត់ដណ្តប់ទុកក្នុងទីជិតជើង ដើម្បីត្រូវការឱ្យផ្លាស់ជាចីវរ សំពត់នោះ សមគួរ ។ ក៏បណ្តាគ្រឿងប្រដាប់ ភណ្ឌៈដែលជាកប្បិយ មានគ្រឿងប្រដាប់សីសៈជាដើម ដែលមាតុគ្រាមប្រគេនថា "លោកម្ចាស់ សូមលោកម្ចាស់មេត្តាទទួលវត្ថុនេះចុះ" ភិក្ខុគួរទទួលទុកដើម្បីជាគ្រឿងប្រើ មានស្រោមកាំបិតកោរនិងម្ជុលជាដើម ។ ចំណែកភណ្ឌៈដែលធ្វើដោយមាស ប្រាក់ និងកែវមុក្តាជាដើម ជាអនាមាសពិត, សូម្បីគេប្រគេន ក៏មិនគួរទទួល ។

មួយទៀត មិនមែនតែគ្រឿងប្រដាប់ដែលតាក់តែងរាងកាយរបស់ស្រីទាំងនោះតែម៉្យាងប៉ុណ្ណោះ ដែលជាអនាមាស ។ ទោះជារូបឈើក្តី រូបភ្លុកក្តី រូបដែកក្តី រូបសំណក្តី រូបគំនូរក្តី (រូបថតក្តី) រូបដែលសម្រេចដោយរតនៈគ្រប់យ៉ាងក្តី ដែលគេធ្វើសណ្ឋាននៃស្រី ដោយ

ហោចទៅសូម្បីរូបដែលសូនដោយម្សៅ ក៏ជាអនាមាសទាំងអស់នោះ ។ តែបានរបស់ដែលគេប្រគេនថា "វត្ថុនេះចូរជារបស់លោកម្ចាស់" វៀររបស់ដែលសម្រេចដោយរតនៈគ្រប់យ៉ាង ទម្លាយរូបដ៏សេស បង្អោនយកវត្ថុដែលគួរជាគ្រឿងឧបករណ៍ ចូលក្នុងគ្រឿងឧបករណ៍ និងវត្ថុដែលគួរប្រើប្រាស់ ចូលក្នុងរបស់សម្រាប់ប្រើប្រាស់ ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់ គួរ ។

មួយទៀត សូម្បីធញ្ញជាតិ ៧ ប្រភេទ ក៏ជាអនាមាសដូចគ្នានឹងរូបស្ត្រី ដូច្នោះ ។ ព្រោះដូច្នោះ កាលដើរទៅតាមវាលស្រែ កុំដើរចាប់ពាល់គ្រាប់ធញ្ញជាតិ សូម្បីដែលកើតនៅក្នុងវាលស្រែនោះទៅបណ្ដើរ ។ បើមានធញ្ញជាតិដែលគេហាលទុកក្បែរទ្វារផ្ទះ ឬក្បែរមក និងផ្លូវខាង (បើ) មានមកដើរ កុំដើរជាន់ ។ កាលមកដើរមិនមាន គប្បីអធិដ្ឋានឱ្យជាមកហើយដើរទៅចុះ ។ មនុស្សទាំងឡាយ ក្រាលអាសនៈប្រគេនលើគំនរធញ្ញជាតិក្នុងផ្ទះ នឹងអង្គុយក៏គួរ ។ ជនពួកខ្លះចាក់ធញ្ញជាតិគរទុកក្នុងរោងឆាន់បើអាចនឹងឱ្យនាំចេញបាន ក៏គប្បីឱ្យនាំចេញ បើមិនអាចកុំជាន់ធញ្ញជាតិ គប្បីដាក់នូវតាំងក្នុងទីមួយហើយអង្គុយចុះ ។ បើមិនមានឱកាស ពួកអ្នកស្រុកក្រាលអាសនៈ ប្រគេននៅលើគំនរធញ្ញជាតិនុ៎ះឯង គប្បីអង្គុយចុះ ។ សូម្បីក្នុងធញ្ញជាតិដែលនៅលើទូក ក៏មានន័យយ៉ាងនេះដូចគ្នា ។ សូម្បីអបរណ្ណជាតិមានសណ្ដែកបាយ និងសណ្ដែករាជ

មាសជាដើមក្តី ផ្លែឈើមានត្នោតនិងខ្នុរជាដើមក្តី ដែលកើតក្នុងទីនោះ ភិក្ខុមិនគួរចាប់លេង ។ សូម្បីក្នុងអបរណ្ណជាតិ និងផ្លែឈើដែលអ្នកស្រុក ប្រមូលជាគំនរទុក ក៏មានន័យដូច្នេះដូចគ្នា ។ តែការដែលភិក្ខុកាន់យកផ្លែឈើដែលជ្រុះអំពីដើមក្នុងព្រៃ ដោយតាំងចិត្តថា "នឹងឱ្យដល់ពួកអនុបសម្បន្ន" គួរ ។

## រតនៈ ១០ ប្រការ

បណ្តារតនៈ ១០ ប្រការទាំងនេះ គឺ មុក្តា មណី ពិទូរ្យ ស័ង្ខ សិលា ប្រវាឡ ប្រាក់ មាស ទទឹម មរកត មុក្តា តាមធម្មជាតិមិនទាន់បានច្នៃនិងចោះ ភិក្ខុចាប់ពាល់បាន ។ អាចារ្យពួកខ្លះពោលថា រតនៈដ៏សេស ជាអនាមាស តែក្នុងមហាបច្ចរីលោកពោលថា មុក្តា ដែលច្នៃហើយក្តី ដែលមិនទាន់ច្នៃក្តី ជាអនាមាស និងភិក្ខុទទួលដើម្បីប្រយោជន៍ជាមូលតម្លៃនៃវត្ថុ រមែងមិនគួរ តែទទួលដើម្បីជាថ្នាំដល់អ្នកកើតរោគឃ្លង់ គួរ ។ មណីប្រភេទពណ៌ខៀវ និងលឿងជាដើម សូម្បីទាំងអស់ដោយហោចទៅសូម្បីកែវផលឹកធម្មជាតិដែលគេខាត់ ច្នៃ និង ក្រឡឹងហើយ ជាអនាមាស ។ តែមណីតាមធម្មជាតិផុតអំពីអណ្តូងកើត លោកពោលថា ភិក្ខុនឹងទទួលយកទុក ដើម្បីជាមូលតម្លៃនៃវត្ថុមានបាត្រជាដើមក៏គួរ ។ សូម្បីមណីនោះ លោកហាមទុកក្នុងមហាបច្ចរី ។ កញ្ចក់កែវ

ដែលគេស្លធ្វើទុក តែម្យ៉ាងប៉ុណ្ណោះ លោកពោលថា គួរ ។ សូម្បីក្នុងពិទូរ្យ ក៏មានវិនិច្ឆ័យដូចគ្នានឹងកែវមណី ។ ស័ង្ខនឹងជាស័ង្ខសម្រាប់ផ្លុំ (ត្រែ ស័ង្ខ) ក្តី ដែលគេខាត់និងច្នៃហើយក្តី ប្រដាប់ដោយរតនៈ (ស្រេះដោយរតនៈ) ក្តី ជាអនាមាស ។ ស័ង្ខសម្រាប់ជួសទឹក ផឹក ដែលខាត់ហើយក្តី មិនទាន់បានខាត់ក្តី ជារបស់គួរចាប់ពាល់បានពិត ។ មួយទៀត រតនៈដ៏សេស ភិក្ខុទទួលទុក ដើម្បីប្រើជាថ្នាំបន្តក់ភ្នែកជាដើមក្តី ដើម្បីជាមូលតម្លៃនៃវត្ថុក្តី គួរ ។

សិលា ដែលខាត់និងច្នៃហើយ ប្រដាប់ដោយរតនៈ មានពណ៌ដូចសណ្តែកបាយប៉ុណ្ណោះ ជាអនាមាស ។ សិលាដ៏សេស ភិក្ខុកាន់យកមកដើម្បីប្រើជាថ្មសំលៀងកាំបិតជាដើម ក៏បាន ។ ក្នុងពាក្យនេះ អាចារ្យពួកខ្លះពោលថា បទថា រតនសំយុត្តា បានដល់ សិលាដែលស្លរំលាយផ្សំជាមួយនឹងមាស ។

កែវប្រវាឡដែលខាត់និងច្នៃហើយ ជាអនាមាស ។ ប្រវាឡដ៏សេសជាអាមាស (គួរចាប់ពាល់បាន) និងភិក្ខុទទួលទុក ដើម្បីចាយវាយជាមូលតម្លៃនៃវត្ថុ គួរ ។ តែក្នុងមហាបច្ចរីពោលថា ប្រវាឡដែលខាត់ហើយក៏ដោយ មិនបានខាត់ក៏ដោយ ជាអនាមាសទាំងអស់ នឹងទទួលទុក មិនសមគួរ ។

មាសនិងប្រាក់ សូម្បីគេធ្វើជារូបពណ៌គ្រប់វត្ថុគ្រប់យ៉ាង ជាអនាមាសនិងជារបស់មិនគួរទទួលទុក ចាប់ផ្តើមតាំងពីនៅជារ៉ែ ។ បានឮថា ឧត្តរាជឱរសឱ្យសាងព្រះចេតិយមាស បញ្ជូនទៅប្រគេនព្រះមហាបទុមត្ថេរៈ ។ ព្រះថេរៈហាមថា មិនគួរ ។ ផ្កាឈូកមាសនិងផ្កាយមាសជាដើម មាននៅត្រង់ទីលានព្រះចេតិយ, សូម្បីវត្ថុទាំងនោះក៏ជាអនាមាស តែពួកភិក្ខុដែលនៅថែទាំព្រះចេតិយតាំងនៅក្នុងឋានជាអ្នកចោលរូបិយៈ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុទាំងនោះនឹងស្ទាបអង្អែលមើលក៏គួរ ។ តែពាក្យនោះ លោកហាមទុកក្នុងកុរុន្ទី ។ លោកអនុញ្ញាតត្រឹមតែប៉ុណ្ណេះថា នឹងសម្អាតសំបុកពីងពាងលើព្រះចេតិយមាស គួរ ។ លោកពោលទុកក្នុងអដ្ឋកថាទាំងពួងថា សូម្បីលោហៈដែលកាឡៃមាស[1]

(១) វិមតិវិនោទនីដីកា. អារកូដលោហន្តិ សុវណ្ណវណ្ណោ កិត្តិមលោហវិសេសោ ។ តិវិធញ្ហិ កិត្តិមលោហំ កំសលោហំ វដ្ដលោហំ. ហារកូដលោហន្តិ តត្ថ តិបុតម្ពេ មិស្សេត្វា កតំ កំសលោហំ នាម ។ សីសតម្ពេ មិស្សេត្វា កតំ វដ្ដលោហំ ។ រសតម្ពេ មិស្សេត្វា កតំ ហារកូដលោហំ នាម ប្រែថា លោហៈប្លមពិសេស មានពណ៌ដូចមាស ឈ្មោះថា អារកូដលោហៈ. ក៏លោហៈធ្វើបន្លំមាន ៣ យ៉ាង គឺ កង្សលោហៈ វដ្ដលោហៈ ហារកូដលោហៈ. បណ្ដាលោហៈទាំងនោះ លោហៈដែលគេធ្វើផ្សំសំណាបាហាំង និងស្ពាន់ ឈ្មោះថា កង្សលោហៈ. ដែលគេ ធ្វើផ្សំសំណាភក់និងស្ពាន់ ឈ្មោះថា វដ្ដលោហៈ ដែលគេធ្វើផ្សំបារតនិងស្ពាន់ ឈ្មោះថា ហារកូដលោហៈ ។ សូម្បីក្នុងសារត្ថទីបនី ក៏ពង្រីកសេចក្ដីដោយទំនងនេះ គួរតែជាសំរិទ្ធិ ។

ក៏មានគតិដូចមាសដែរ ចាត់ជាអនាមាស ។ ចំណែកគ្រឿងប្រើប្រាស់ក្នុងសេនាសនៈ ជាកប្បិយទាំងអស់; ព្រោះដូច្នោះ គ្រឿងបរិក្ខារប្រចាំសេនាសនៈ សូម្បីគ្រប់យ៉ាងដែលធ្វើដោយមាស និងប្រាក់ជាអាមាស (គួរចាប់ពាល់បាន) ។ ពួកអ្នកស្រុកសាងមណ្ឌបកែវ ជាស្ថានទីសម្ដែងព្រះធម៌វិន័យដល់ភិក្ខុទាំងឡាយ មានសសរកែវផលឹក ប្រដាប់ប្រដាដោយក្នុងកែវ ។ ការដែលភិក្ខុទាំងឡាយ នឹងថែរក្សាគ្រឿងឧបករណ៍ទាំងអស់ក្នុងរតនមណ្ឌបនោះ គួរ ។

ត្បូងទទឹមនិងមរកត ដែលខាត់និងច្នៃហើយ ជាអនាមាស ដែលនៅមិនបានខាត់និងច្នៃក្រៅនេះ លោកពោលថា ជាអាមាស ភិក្ខុនឹងទទួលទុកដើម្បីប្រើជាមូលតម្លៃនៃវត្ថុ គួរ ។ តែក្នុងមហាបច្ចរីពោលថា ត្បូងទទឹមនិងមរកតដែលខាត់ហើយក្ដី ដែលនៅមិនទាន់បានខាត់ក្ដី ជាអនាមាស ដោយប្រការទាំងពួង និងភិក្ខុទទួលទុក មិនគួរ ។

អាវុធគ្រប់ប្រភេទ ជាអនាមាស សូម្បីគេប្រគេន ដើម្បីប្រយោជន៍ចំណាយជាមូលតម្លៃនៃវត្ថុ ក៏មិនគួរទទួលទុក, ឈ្មោះថា ការលក់ដូរសស្ត្រា រមែងមិនសមគួរ ។ សូម្បីជង្ឃសុទ្ធ ៗ ក្ដី ខ្សែធ្នូក្ដី ជន្លួញក្ដី កង្វើរ ដោយហោចទៅ សូម្បីកាំបិត និងពូថៅជាដើម ដែលគេធ្វើសម្រាប់ជាអាវុធ ក៏ជាអនាមាស ។ បើមានអ្នកណា ៗ យកលំពែង ឬស្នមកដាក់ទុកក្នុងវិហារ កាលនឹងជម្រះវិហារ គប្បីបញ្ចូន

ដំណឹងទៅប្រាប់ដល់ពួកម្ចាស់របស់ថា ចូរនាំចេញទៅ ។ បើពួកគេមិននាំទៅ កុំឱ្យរបស់នោះកម្រើក ហើយគប្បីជម្រះវិហារចុះ ។ ភិក្ខុឃើញដាវក្ដី លំពែងក្ដី ស្នក្ដី ធ្លាក់នៅក្នុងសមរភូមិប្រយុទ្ធ គប្បីយកថ្ម ឬរបស់អ្វី ៗ ដំដាវចេញហើយ កាន់យកទៅដើម្បីប្រើធ្វើជាកាំបិត គួរ ។ សូម្បីភិក្ខុញែករបស់ក្រៅនេះចេញហើយ កាន់យករបស់យ៉ាងណាមួយដើម្បីប្រើជាកាំបិត យ៉ាងណាមួយដើម្បីប្រើជាឈើច្រត់ជាដើម គួរ ។ ចំណែកគ្រឿងអាវុធដែលគេប្រគេនថា "សូមលោកម្ចាស់ ទទួលអាវុធនេះទុក ភិក្ខុនឹងទទួលសូម្បីទាំងអស់ដោយតាំងចិត្តថា យើងនឹងធ្វើឱ្យវិនាសអស់ហើយធ្វើឱ្យជាកប្បិយភណ្ឌ: ដូច្នេះ គួរ ។ គ្រឿងចាប់សត្វមានលបជាក់ត្រី និងអន្ទាក់ទាក់សត្វជាដើមក្ដី គ្រឿងការពារព្រួញ មានខែល និងសំណាញ់ជាដើមក្ដី ជាអនាមាសគ្រប់យ៉ាង ។

ក៏បណ្ដាអន្ទាក់សត្វ និងគ្រឿងការពារព្រួញដែលបានមកដើម្បីជាគ្រឿងប្រើប្រាស់ គ្រាដំបូង ភិក្ខុនឹងកាន់យកសំណាញ់ដោយតាំងចិត្តថា យើងនឹងចងទុកដើម្បីរុំជាឆត្រ ទុកខាងលើនៃអាសនៈ ឬព្រះចេតិយ គួរ ។ សូម្បីគ្រឿងការពារព្រួញទាំងអស់ ភិក្ខុទទួលទុកដើម្បីប្រើជាមូលតម្លៃនៃភណ្ឌ: ក៏សមគួរ ។ ព្រោះថា គ្រឿងការពារព្រួញនោះ ជាគ្រឿងការពារនូវការបៀតបៀនអំពីអ្នកដទៃ មិនមែនជាគ្រឿងធ្វើការបៀតបៀន ដូច្នេះឯង, នឹងទទួលខែលដោយតាំងចិត្តថា យើងនឹងធ្វើជាភាជនៈ

ដាក់ឈើស្នុន់ ដូច្នេះ ក៏គួរ ។

គ្រឿងតន្ត្រីមានពិណានិងស្គរជាដើម ដែលរឹតបន្តឹងដោយស្បែកជាអនាមាស ។ តែក្នុងកុរុន្ទីលោកពោលថា តូស្គរ (ស្បែករឹតបន្តឹងស្គរ) ក្តី តូពិណា (ខ្សែរឹតបន្តឹងពិណា) ក្តី ស្នូកទទេក្តី[1] ស្បែកគេបិទទុកត្រង់កណ្តាប់មាត់ក្តី ដងពិណាក្តី ជាអនាមាសទាំងអស់ ។ ទោះជារឹតបន្តឹងដោយខ្លួនឯង ឬឱ្យអ្នកដទៃគេរឹតបន្តឹង ក្តី នឹងប្រគំដោយខ្លួនឯង ឬឱ្យអ្នកដទៃគេប្រគំក្តី មិនបានទាំងអស់នោះ ។ សូម្បីឃើញគ្រឿងតន្ត្រីដែលពួកមនុស្សធ្វើការបូជា ហើយចោលទុកក្នុងលានព្រះចេតិយ កុំធ្វើឱ្យ

(១) សារត្ថទីបនី ពន្យល់ថា ភេរីសង្ឃាដោតិ សង្ឃាដិតចម្មភេរី ។ វីណាសង្ឃាដោតិ សង្ឃាដិតចម្មវីណា ។ ចម្មវិនទ្ធានំ ភេរីវីណានមេតំ អធិវចនំ តុច្ឆបោក្ខរន្តិ អវិនទ្ធចម្មំ ភេរីបោក្ខរំ វីណាបោក្ខរញ្ច ។ ប្រែថា ស្គរដែលពាសស្បែកហើយ ឈ្មោះថា ភេរីសង្ឃាដៈ ។ ពិណាដែលរឹតបន្តឹងខ្សែហើយ ឈ្មោះថា វីណាសង្ឃាដៈ ។ ពាក្យទាំងពីរនេះ ជាឈ្មោះនៃស្គរ ដែលពាសស្បែក និងពិណាដែលរឹតបន្តឹងខ្សែហើយ ។ ក្នុងទីកន្លែងខ្លះថា ស្បែករឹតពាសស្គរ ឈ្មោះថា ភេរីសង្ឃាដៈ ខ្សែរឹតបន្តឹងពិណា ឈ្មោះថា វីណាសង្ឃាដៈ ក៏មាន ដូចក្នុងវិមតិវិនោទនីដីកា អាងដល់អដ្ឋកថាកុរុន្ទី ពន្យល់ទុកថា ភេរីអាទិនំ វិនទ្ធោបករណសមុហោ ភេរីវីណាសង្ឃាដោតិ វេទិតព្វំ. គប្បីជ្រាបថា ប្រជុំគ្រឿងឧបករណ៍ដំឡើងស្គរជាដើម ឈ្មោះថា ភេរីវីណាសង្ឃាដៈ. ស្នូកស្គរ និងស្នូកពិណា ដែលមិនទាន់បានដំឡើងស្បែក និងរឹតបន្តឹងខ្សែ ឈ្មោះថា តុច្ឆបោក្ខរៈ ។

ឃ្លាតចាកទីឡើយ គប្បីបោសទៅក្នុងចន្លោះ ៗ ។ តែក្នុងមហាបច្ចរី លោកពោលថា ក្នុងវេលាចាក់សម្រាម គប្បីនាំទៅដោយកំណត់ថា ជាសម្រាម ហើយដាក់ទុកក្នុងចំណែកម្ខាង គួរ ។ សូម្បីទទួលទុក ដើម្បីប្រើជាមូលតម្លៃនៃវត្ថុ ក៏គួរ ។ តែដែលបានមកដើម្បីត្រូវការទើងប្រើប្រាស់ ទើងកាន់យកដើម្បីត្រូវការធ្វើឱ្យជាបរិក្ខារនោះ ៗ ដោយតាំងចិត្តយ៉ាងនេះថា យើងនឹងធ្វើស្នូកពិណ និងស្នូកស្គរឱ្យជាភាជនៈដាក់ឈើស្ទន់ ស្បែកនឹងធ្វើជាស្រោមកាំបិត ហើយធ្វើតាមដែលតាំងចិត្តយ៉ាងនោះ ៗ គួរ ។

[៨៩] រឿងស្រីជាប្រពន្ធពីដើម មានសេចក្ដីជាក់ច្បាស់ហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងយក្ខស្រី ដូច្នេះ ៖

សូម្បីថា ភិក្ខុដល់សេចក្ដីស្ទាបអង្អែលកាយជាមួយនឹងនាងទេវីរបស់ស្ដេចបរនិម្មិតវសវត្តី ក៏ត្រូវថុល្លច្ច័យតែម្យ៉ាង ។

រឿងបណ្ឌកៈ និងរឿងស្រីដេកលក់ ប្រាកដហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងស្រីស្លាប់ ដូច្នេះ ៖

ត្រូវអាបត្តិថុល្លច្ច័យក្នុងវេលាល្មមនឹងត្រូវអាបត្តិបារាជិក ក្រៅពីនោះ ត្រូវអាបត្តិទុក្កដ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងតិរច្ឆាន ដូច្នេះ ៖

( ស្ទាបអង្អែលកាយ ) នឹងនាងនាគមាណវិកាក្តី នឹងនាងសុបណ្ណ-មាណវិកាក្តី នឹងនាងកិន្នរីក្តី នឹងមេគោក្តី ត្រូវអាបត្តិទុក្កដទាំងអស់ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងតុក្កតាឈើ ដូច្នេះ ៖

មិនមែនតែឈើម៉្យាងប៉ុណ្ណោះ ដោយហោចទៅ សូម្បីក្នុងរូបស្រីដែលគេគូរចិត្រកម្មទុក ក៏ត្រូវអាបត្តិទុក្កដដូចគ្នា ។

[៩០] រឿងស្រីច្រើននាក់ចាប់កៀកភិក្ខុ មានអត្ថភ្លឺច្បាស់ទាំងអស់នោះ ។

[៩១] គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងស្ពាន ដូច្នេះ ៖

ស្ពានដែលមនុស្សដើរបានតែម្នាក់ក្តី ស្ពានដែលជាមករទេះឆ្លងក្តី ត្រឹមតែភិក្ខុធ្វើប្រយោគដោយតាំងចិត្តថា "យើងនឹងអង្រួនស្ពាន" ដូច្នេះ រង្គើក៏ដោយ មិនរង្គើក៏ដោយ ជាអាបត្តិទុក្កដ ។

[៩២] រឿងមគ ប្រាកដច្បាស់ហើយនុ៎ះឯង ។

[៩៣] គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងដើមឈើ ដូច្នេះ ៖

ដើមឈើខ្នាតធំប៉ុនដើមព្រីងធំក្តី ជាដើមឈើតូចក្តី ភិក្ខុអាចអង្រួនក៏ដោយ មិនអាចអង្រួនក៏ដោយ ជាអាបត្តិទុក្កដ ព្រោះហេតុត្រឹមតែមានសេចក្តីព្យាយាម ។

[៩៤] សូម្បីក្នុងរឿងទូក ក៏មានន័យយ៉ាងនេះដែរ ។

[៩៥] គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងខ្សែ ដូច្នេះ ៖

ភិក្ខុអាចទាញខ្សែឱ្យឃ្លាតចាកឋានបាន ត្រូវអាបត្តិថុល្លច្ច័យ ព្រោះខ្សែនោះ ។ ខ្សែប្រភេទណាជាខ្សែសរសៃធំ រមែងមិនឃ្លាត ចាកឋាន សូម្បីត្រឹមតែបន្តិចបន្តួចត្រូវអាបត្តិទុក្កដ ព្រោះខ្សែនោះ ។ សូម្បីក្នុងកំណាត់ឈើក៏មានន័យយ៉ាងនេះដូចគ្នា ។ ពិតមែន សូម្បីដើមឈើធំដែលដួលរលំលើផែនដី ក៏ទ្រង់កាន់យកហើយដោយ ទណ្ឌស័ព្ទដូចគ្នាក្នុងរឿងកំណាត់ឈើនេះ ។

[៩៦] រឿងបាត្រប្រាកដច្បាស់ហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងស្រីកំពុងថ្វាយបង្គំ ដូច្នេះ ៖

ស្រីប្រាថ្នាទឹងចាប់ជើងទាំងពីរ ហើយថ្វាយបង្គំ ភិក្ខុគប្បីហាម គប្បីបិទបាំងជើងទុក ឬគប្បីអង្គុយស្ងៀម ។ ព្រោះថា ភិក្ខុដែលអង្គុយស្ងៀម សូម្បីត្រេកអរ ក៏មិនត្រូវអាបត្តិ ។

រឿងខាងចុងបង្អស់ ប្រាកដច្បាស់ហើយនោះឯង ។

កាយសំសគ្គវណ្ណនា ចប់

## ៣. ទុដ្ឋុល្លវាចាសិក្ខាបទវណ្ណនា

[៩៧] ទុដ្ឋុល្លវាចាសិក្ខាបទថា តេន សមយេន ពុទ្ធោ ភគវា : សម័យនោះ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ដ៏មានព្រះភាគជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ៖

គប្បីជ្រាបវិនិច្ឆ័យក្នុងទុដ្ឋុល្លវាចាសិក្ខាបទនោះ ដូច្នេះ ៖

### អធិប្បាយសិក្ខាបទវិភង្គ សង្ឃាទិសេសទី ៣

បទថា អាធិស្ស : ចំពោះ បានដល់ ប្រាថ្នាដល់ ។

ប្រើនបទថា វណ្ណម្បិ ភណតិ : ពោលសរសើរខ្លះ ជាដើម នឹងមានច្បាស់នៅខាងមុខ ។

បទថា អច្ឆិន្នកា : គ្មានសេចក្ដីខ្មាស បានដល់ ដាច់ការក្រែងខ្លាចបាប ។

បទថា ធុត្តិកា : ជាស្រីអ្នកលេង គឺអ្នកមានកលមាយា ។

បទថា អហិរិកាយោ : ឥតមានអៀនខ្មាស គឺ ជាស្រីមិនមានអៀនខ្មាស ។

បទថា ឱហសន្តិ : ញញឹមញញែម បានដល់ ញញឹមពព្រាយហើយ សើចតិច ៗ ។

បទថា ឧល្លបន្តិ : និយាយបញ្ឆោរ សេចក្ដីថា រមែងពោល

ពាក្យប្រលោមមានប្រការផ្សេង ៗ លើកតម្កើងដោយន័យជាដើមថា "ឱ ព្រះគុណម្ចាស់" ។

បទថា ឧដ្ឋក្ខន្តិ **: សើចក្អាកក្អាយ** បានដល់ រមែងសើចឮខ្លាំង ។

បទថា ឧប្បណ្ឌេន្តិ **: ចំអន់** សេចក្ដីថា ធ្វើការចំអកចំអន់(ជាមួយនឹងឧទាយី) ដោយន័យជាដើមថា នេះជាបណ្ឌកៈ នេះមិនមែនមនុស្សប្រុស ។

[៩៨] បទថា សារត្តោ **: ត្រេកអរ** បានដល់ តម្រេកហើយដោយសេចក្ដីត្រេកអរ ដោយអំណាចនៃសេចក្ដីពេញចិត្តក្នុងវាចាអាក្រក់ ។

បទថា អបេក្ខវា បដិពទ្ធចិត្តោ **: មានសេចក្ដីអាឡោះអាល័យ មានចិត្តប្រតិព័ទ្ធ** មានន័យដូចពោលហើយនុ៎ះឯង[១], ក្នុងសិក្ខាបទនេះ គប្បីប្រកបពាក្យដោយអំណាចនៃសេចក្ដីត្រេកអរក្នុងវាចាតែម្យ៉ាង ។

ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងមាតុគ្រាមដែលទ្រង់ប្រាថ្នាក្នុងពាក្យថា មាតុគាមំ ទុដ្ឋុល្លាហិ វាចាហិ **: និយាយចំមាតុគ្រាមដោយសំដីអាក្រក់** នេះ ទើបត្រាស់ពាក្យថា មាតុគាមោ ជាដើម ។

បណ្ដាបទទាំងនោះ ដោយពាក្យថា ជាស្រីដែលដឹងក្ដី អាចជ្រាប

---

១. ក្នុងទំព័រ ៤៥-៤៦ ខាងដើម ។

ពាក្យដែលជាសុភាសិតទុព្ភាសិត (វាចាអាក្រក់ និងសុភាព)បាន នេះ ព្រះឧបាលីសម្ដែងថា ស្រីដែលឆ្លាត អាចជ្រាបពាក្យដែលជាប្រយោជន៍ និងឥតប្រយោជន៍ ពាក្យដែលទាក់ទិននឹងអសទ្ធម្ម និងសទ្ធម្ម ទ្រង់ប្រាថ្នាយកក្នុងសិក្ខាបទនេះ, ចំណែកស្រីដែលល្ងង់ខ្លៅ ឥតប្រាជ្ញា សូម្បីជាមនុស្សធំ(ឬចាស់) ក៏ទ្រង់មិនប្រាថ្នាយកក្នុងសិក្ខាបទនេះ ។

បទថា ឱភាសេយ្យ : និយាយចង់ សេចក្ដីថា គប្បីនិយាយចែចង់ គឺ និយាយដោយអសទ្ធម្ម មានប្រការផ្សេង ៗ ។ ក៏ព្រោះឈ្មោះថា ការនិយាយចែចង់របស់ភិក្ខុដែលនិយាយយ៉ាងនេះ ដោយសេចក្ដីជាអជ្ឈាចារ គឺ ជាការប្រព្រឹត្តកន្លងល្មើស ខេត្តដែននៃសេចក្ដីសង្រួមដោយអំណាចនៃរាគៈ ; ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងសេចក្ដីនោះ ទើបត្រាស់ថា បទថា ឱភាសេយ្យ គឺ ហៅថា អជ្ឈាចារ : សេចក្ដីប្រព្រឹត្តល្មើស ។

ពាក្យថា តំ ក្នុងពាក្យថា យថាតំ នេះ ត្រឹមតែជានិបាត ។ សេចក្ដីថា ដូចបុរសកម្លោះនិយាយចែចង់ស្រីក្រមុំ ដូច្នោះ ។

[៩៩] ពាក្យជាដើមថា ទ្វេ មគ្គេ អាទិស្ស : ចំពោះទ្វារមគ្គទាំងពីរ ដូច្នេះ ព្រះមានព្រះភាគត្រាស់ហើយ ដើម្បីទ្រង់សម្ដែងអាការដែលជាហេតុឱ្យត្រូវអាបត្តិសង្ឃាទិសេស ដល់ភិក្ខុដែលនិយាយចែចង់(ស្រី) ។

# អធិប្បាយបទភាជនី សង្ឃាទិសេសទី ៣

បណ្ដាបទទាំងនោះ ពីរបទថា ទ្វេ មគ្គេ បានដល់ វច្ចមគ្គ នឹងបស្សាវមគ្គ ។ ពាក្យដ៏សេសប្រាកដហើយតាំងពីដំបូង ក្នុងឧទ្ទេសនុ៎ះឯង ។ ក៏ក្នុងឧទ្ទេសពាក្យថា និយាយសរសើរ គឺ និយាយថា នាងជាអ្នកប្រកបព្រមដោយលក្ខណៈរបស់ស្រី គឺ ដោយសុភលក្ខណៈ, អាបត្តិមិនទាន់ដល់ទីបំផុតទេ ។ និយាយថា វច្ចមគ្គនិងបស្សាវមគ្គរបស់នាងជាយ៉ាងនេះ, នាងជាមនុស្សប្រកបព្រមដោយលក្ខណៈរបស់ស្ត្រី គឺ ដោយសុភលក្ខណៈដូច្នេះ ដោយហេតុដូច្នោះ, អាបត្តិ រមែងដល់ទីបំផុត គឺត្រូវអាបត្តិសង្ឃាទិសេស ។

[១០០] ក៏ពីរបទថា វណ្ណេតិ បសំសតិ : និយាយស្ញើចពណ៌នា នេះ ជាវេវចនៈរបស់បទថា និយាយសរសើរ ។

បទថា ខុំសេតិ : ជេរ សេចក្ដីថា រមែងនិយាយចាក់ដោតដោយជន្ទញ គឺវាចា ។

បទថា វម្ភេតិ : តិះដៀល គឺ និយាយរុកកួន ។

បទថា គរហតិ : និន្ទា គឺ រមែងពោលទោស ។

តែកាលមិនទាន់និយាយជាប់តនឹង ១១ បទ មានបទថា

អនិមិត្តាសិ ជាដើម ដែលមកក្នុងបាលីខាងមុខ អាបត្តិមិនទាន់ដល់ទីបំផុត, សូម្បីភ្ជាប់ហើយ កាលនិយាយភ្ជាប់ដោយ ៣ បទទាំងនេះថា មេសិខិរណី មេមានទ្វារមគ្គរលាយចូលគ្នា, មេឧភតោព្យញ្ជនក ដូច្នេះប៉ុណ្ណោះ ក្នុងបណ្ដា ១១ បទទាំងនោះ ទើបត្រូវអាបត្តិសង្ឃាទិសេស ។ សូម្បីក្នុងការនិយាយសូមថា "នាងចូរឱ្យដល់យើង" អាបត្តិមិនទាន់ដល់ទីបំផុត ដោយពាក្យនិយាយ ត្រឹមតែប៉ុណ្ណោះ តែកាលនិយាយភ្ជាប់ដោយមេថុនធម្មយ៉ាងនេះថា "នាងចូរឱ្យមេថុនធម្ម" ត្រូវអាបត្តិសង្ឃាទិសេស ។ សូម្បីក្នុងពាក្យនិយាយអង្វរថា "កាលណាមាតារបស់នាងជ្រះថ្លា"ជាដើម អាបត្តិមិនទាន់ដល់ទីបំផុត ដោយពាក្យនិយាយត្រឹមតែប៉ុណ្ណោះ តែកាលនិយាយភ្ជាប់ដោយមេថុនធម្ម ដោយន័យជាដើមថា "កាលណាមាតារបស់នាងជ្រះថ្លា, កាលណាអាត្មាបានមេថុនធម្មរបស់នាង" ឬថា "កាលមាតារបស់នាងជ្រះថ្លាហើយ អាត្មានឹងបានមេថុនធម្ម" ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេស ។ សូម្បីក្នុងពាក្យសួរជាដើមថា "នាងឱ្យដល់ស្វាមីយ៉ាងណា ?" កាលនិយាយពាក្យថា "មេថុនធម្ម" ប៉ុណ្ណោះ ទើបត្រូវអាបត្តិសង្ឃាទិសេស មិនមានដោយប្រការដទៃទេ ។ សូម្បីក្នុងពាក្យនិយាយសាកសួរថា "បានឮថា នាងឱ្យដល់ស្វាមីយ៉ាងនេះឬ" ក៏មានន័យដូចគ្នានេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការប្រាប់ដូច្នេះ ៖

ពីរបទថា **បុដ្ឋោ ភណតិ : ភិក្ខុដែលស្ត្រីសួរហើយនិយាយ** មានសេចក្តីថា ភិក្ខុត្រូវមនុស្សស្រីសួរថា “កាលឱ្យយ៉ាងណា ទើបនឹងជាទីស្រឡាញ់របស់ស្វាមី ?” ហើយប្រាប់ ។ ក៏ក្នុងការប្រាប់នោះ សូម្បីកាលនិយាយថា “ចូរឱ្យយ៉ាងនេះ កាលឱ្យយ៉ាងនេះ នាងនឹងជាទីស្រឡាញ់របស់ស្វាមី” អាបត្តិមិនទាន់ដល់ទីបំផុត, តែកាលភ្ជាប់ដោយមេថុនធម្មប៉ុណ្ណោះ ដោយន័យជាដើមថា “នាងចូរឱ្យ ចូរបង្អោនចូលទៅនូវមេថុនធម្មយ៉ាងនេះ, កាលឱ្យ កាលបង្អោនចូលទៅនូវមេថុនធម្មយ៉ាងនេះ នឹងជាទីស្រឡាញ់” ត្រូវអាបត្តិសង្ឃាទិសេស ។ សូម្បីក្នុងការពោលទូន្មាន ក៏មានន័យដូចគ្នា ។

វិនិច្ឆ័យក្នុងអក្កោសនិទ្ទេស គប្បីជ្រាបដូច្នេះ ៖

បទថា **អនិមិត្តាសិ : មេគ្មាននិមិត្ត** គឺ នាងជាមនុស្សប្រាសចាកនិមិត្ត ។ មានអធិប្បាយថា រន្ធបស្សាវៈរបស់នាងមានប្រមាណប៉ុនរន្ធសោប៉ុណ្ណោះ ។

បទថា **និមិត្តមត្តាសិ : មេមានហេតុគ្រាន់តែជានិមិត្ត** គឺ និមិត្តស្ត្រីរបស់នាង មិនពេញបរិបូណ៌, មានអធិប្បាយថា គ្រាន់តែជាគ្រឿងសម្គាល់ប៉ុណ្ណោះ ។

បទថា អលោហិតា : មេគ្មានឈាម គឺ មានរដូវប្រសូតស្ងួត ។

បទថា ធុវលោហិតា : មេមានឈាមជានិច្ច បានដល់ មានរដូវប្រសូតដែលសើមជោគទៅដោយលោហិតជានិច្ច ។

បទថា ធុវចោឡា : មេមានកំណាត់សំពត់ជានិច្ច គឺ មានសំពត់ចុកនៅជានិច្ច, មានអធិប្បាយថា នាងប្រើសំពត់ចុកជានិច្ច ។

បទថា បគ្ឃរន្តិ : មេហូរឈាមជានិច្ច គឺ តែងហូរចេញ, មានអធិប្បាយថា ទឹកមូត្ររបស់នាងហូរចេញជានិច្ច ។

បទថា សិខរណី : មេសិខរណី បានដល់ មានសាច់ខ្នាយលៀនចេញមកខាងក្រៅ ។ ស្រីដែលមិនមាននិមិត្ត លោកហៅថា ស្រីបណ្ឌកៈ, ស្រីដែលមានពុកមាត់និងពុកចង្កា រូបរាងស្រដៀងមនុស្សប្រុស លោកហៅថា ស្រីស្រដៀងមនុស្សប្រុស ។

បទថា សម្ភិន្នា : មេមានទ្វារមគ្គរលាយចូលគ្នា សេចក្តីថា មានរដូវទ្វារវច្ចមគ្គ និងរដូវទ្វាររបស្សាវមគ្គលាយចូលគ្នា ។

បទថា ឧភតោព្យញ្ជនា : មេឧភតោព្យញ្ជនកៈ សេចក្តីថា ជាអ្នកប្រកបដោយភេទទាំងពីរគឺ គ្រឿងសម្គាល់ភេទស្ត្រី ១ គ្រឿងសម្គាល់ភេទបុរស ១ ។

ក៏បណ្ដាបទទាំង ១១ នេះ ៣ បទសុទ្ធ ៗ នេះ គឺ **សិខរណីសិ** (មេមានសិរ), **សម្ភិន្នាសិ** (មេមានទ្វារមគ្គរលាយចូលគ្នា), **ឧភតោ-ព្យញ្ជនាសិ** (មេមានភេទពីរ), ប៉ុណ្ណោះ រមែងដល់ទីបំផុត ។ ៣ បទនេះ និង៣ បទមុន ៗ គឺ បទពោលអំពីវច្ចមគ្គបស្សាវមគ្គ និងមេថុនធម្មរួមជា ៦ បទសុទ្ធ ៗ ធ្វើឱ្យត្រូវអាបត្តិបាន ដោយប្រការដូច្នេះ ។

បទដ៏សេសជាដើមថា នាងជាអ្នកមិនមាននិមិត្ត ដែលភ្ជាប់ដោយបទថា មេគ្មាននិមិត្ត ដោយមេថុនធម្មហើយទុ៎ះឯង ដោយន័យជាដើមថា នាងចូរឱ្យមេថុនធម្មដល់អាត្មា ឬថា នាងជាអ្នកមិនមាននិមិត្ត ចូរឱ្យមេថុនធម្មដល់អាត្មា គប្បីជ្រាបថា ជាបទធ្វើឱ្យត្រូវអាបត្តិបាន ។

[១០៤] ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងប្រភេទនៃអាបត្តិដោយពិស្ដារ ដោយអំណាចនៃអាការមានការនិយាយសរសើរជាដើមទាំងនេះ ទាក់ទិនដល់វច្ចមគ្គ និងបស្សាវមគ្គរបស់ភិក្ខុដែលមានតម្រេក មានចិត្តប្រែប្រួលនិយាយបែចង់មាតុគ្រាម ទើបត្រាស់ពាក្យថា **ឥត្ថី ច ហោតិ ឥត្ថីសញ្ញី : ស្រីជាប្រាកដ** ភិក្ខុសំគាល់ថា **ស្រីពិតមែន** ជាដើម ។ សេចក្ដីនៃបទទាំងនោះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងកាយសំសគ្គៈទុ៎ះឯង ។ ចំណែកសេចក្ដីប្លែកគ្នាដូចតទៅនេះ ៖

បទថា អធក្ខកំ : ខាងក្រោមដងកាំបិត គឺ ខាងក្រោមតាំងពីផ្ទឹងដងកាំបិតចុះមក ។

បទថា ឧព្ភជានុមណ្ឌលំ : ខាងលើមណ្ឌលជង្គង់ គឺ ខាងលើតាំងពីមណ្ឌលជង្គង់ឡើងទៅ ។

បទថា អព្ភក្ខកំ : ខាងលើដងកាំបិត គឺ លើតាំងពីផ្ទឹងដងកាំបិតឡើងទៅ ។

បទថា អធោជានុមណ្ឌលំ : ខាងក្រោមមណ្ឌលជង្គង់ គឺ ក្រោមតាំងពីមណ្ឌលជង្គង់ចុះមក ។

ក៏ផ្ទឹងដងកាំបិត និងមណ្ឌលជង្គង់ សង្គ្រោះចូលក្នុងខេត្តដែននៃទុក្កដ ក្នុងសិក្ខាបទនេះ ដូចក្នុងកាយសំសគ្គៈរបស់នាងភិក្ខុនី ។ ពិតមែនព្រះពុទ្ធទាំងឡាយ រមែងទ្រង់បញ្ញត្តិគរុកាបត្តិមិនឱ្យមានចំណែកនៅសេសសល់នោះឯង ។

[១០៥] បទថា កាយបដិពទ្ធំ : វត្ថុដែលជាប់នឹងកាយ បានដល់ សំពត់ខ្លះ ផ្កាឈើខ្លះ គ្រឿងប្រដាប់ខ្លះ ។

# អនាបត្តិវារ

[១០៦] បទថា អត្ថបុរេក្ខារស្ស : ភិក្ខុដែលកំពុងអធិប្បាយសេចក្តី សេចក្តីថា អ្នកពោលអត្ថនៃបទជាដើមថា អនិមិត្តាសិ ឬអ្នកធ្វើការស្វាធ្យាយអដ្ឋកថា ។

បទថា ធម្មបុរេក្ខារស្ស : ភិក្ខុដែលកំពុងបង្រៀនធម៌ សេចក្តីថា អ្នកប្រាប់ ឬស្វាធ្យាយព្រះបាលី ។ កាលភិក្ខុអធិប្បាយអត្ថ អធិប្បាយធម៌ ពោលយ៉ាងនេះ ឈ្មោះថា មិនត្រូវអាបត្តិដល់អ្នកអធិប្បាយអត្ថ និង អធិប្បាយធម៌ ។

បទថា អនុសាសនីបុរេក្ខារស្ស : ភិក្ខុដែលកំពុងប្រៀនប្រដៅ សេចក្តីថា កាលភិក្ខុប្រាថ្នាប្រៀនប្រដៅពោលយ៉ាងនេះថា "ឥឡូវនេះនាងក៏ជាមនុស្សមិនមាននិមិត្ត, ជាមនុស្សភេទពីរ, ឥឡូវនេះ នាងគួរធ្វើសេចក្តីមិនប្រមាទចុះ, នាងកុំជាមនុស្សយ៉ាងនេះតទៅឡើយ" ឈ្មោះថា មិនត្រូវអាបត្តិដល់អ្នកប្រាថ្នាក្នុងការទូន្មាន ។ ចំណែកភិក្ខុណា កាលប្រាប់បាលីដល់ពួកនាងភិក្ខុនី លះទំនងនិយាយតាមប្រក្រតីចេញ សើចចំអកនិយាយដដែល ៗ ថា "នាងជាស្រីមានសិរ, ជាស្រីមានទ្វាររលាយចូលគ្នា, ជាស្រីភេទពីរ" ភិក្ខុនោះ ត្រូវអាបត្តិពិត ។ មិនត្រូវអាបត្តិដល់ភិក្ខុឆ្កួត ។ ឧទាយីថេរៈជាដើមបញ្ញត្តិ ក្នុងសិក្ខាបទនេះ មិនត្រូវអាបត្តិ

ដល់លោកអ្នកជាដើមបញ្ញត្តិដូច្នេះឯង ។

បទភាជនីយវណ្ណនា ចប់

បណ្តាបកិណ្ណកៈមានសមុដ្ឋានជាដើម សិក្ខាបទនេះ មានសមុដ្ឋាន ៣ រមែងកើតអំពីកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា ២ ដូច្នេះឯង ។

## វិនីតវត្ថុក្នុងតតិយសង្ឃាទិសេស

[១០៨] បណ្តាវិនីតវត្ថុ គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងលោហិត ដូច្នេះ ៖

ភិក្ខុនោះពោលសំដៅដល់និមិត្ត ដែលមានលោហិតរបស់ស្រី, ស្រីក្រៅនេះមិនដឹង ; ព្រោះដូច្នោះ ទើបត្រូវអាបត្តិទុក្កដ ។

បទថា កក្កសលោមំ : មានរោមខ្ទី បានដល់ មានរោមច្រើន ដោយ រោមខ្ទី ៗ ។

បទថា អាកិណ្ណលោមំ : មានរោមក្រញាញ់ បានដល់ មានរោមសំពីងសំពោង ។

បទថា ខរលោមំ : រោមខ្លាំង គឺ រោមរឹង ។

[១០៩] បទថា **ឱយលោមំ : មានរោមវែង** បានដល់ មានសរសៃរោមមិនខ្លី ។ ពាក្យទាំងអស់ភិក្ខុទាំងនោះ ពោលសំដៅដល់និមិត្តរបស់ស្រីទាំងអស់នោះ ។

[១១០] ភិក្ខុនោះពោលសំដៅដល់អសទ្ធម្មថា "វត្ថុរបស់នាងឱ្យគេព្រោះហើយឬ" ស្រីនោះមិនយល់ ទើបពោលថា "ករុណាលោកម្ចាស់ស្រែខ្ញុំគេមិនទាន់ព្រោះទេ" ។

ពូជដែលឈ្មោះថា ព្រោះហើយ បានដល់ ពូជដែលគេឱ្យតាំងឡើងថ្មី (ឱ្យសាបព្រោះ) ក្នុងឱកាសដែលពូជទាំងឡាយ តាំងមិនជាប់ (មិនដុះ) ឬក្នុងឱកាសដែលមានពូជត្រូវពួកសត្វល្អិត ធ្វើឱ្យវិនាសអស់ហើយចាក់ឱ្យស្មើដោយទឹក ក្នុងស្រែព្រោះមានទឹក (និង)ពូជដែលគេរាស់ឱ្យស្មើដោយរនាស់មានធ្មេញ ៨ ជដែលទៀត ដើម្បីត្រូវការធ្វើឱ្យពូជទាំងឡាយ ដែលធ្លាក់ចុះទៅមិនស្មើគ្នា ឱ្យស្មើគ្នាក្នុងស្រែព្រោះទីទួល ។ បណ្ដាពូជទាំងនោះ ស្រីនេះពោលសំដៅយកពូជយ៉ាងណាមួយ ។

[១១១] ក្នុងរឿងមក ពាក្យថា មករបស់នាងរាបស្រួលទេឬ ? ភិក្ខុនោះពោលសំដៅដល់មកអន្តជាតិ ។ ពាក្យដ៏សេសមានសេចក្ដីជាក់ច្បាស់ទាំងនោះឯង ។

ទុដ្ឋុល្លវាចាសិក្ខាបទវណ្ណនា ចប់

# ៤. អត្ថកាមបារិចរិយសិក្ខាបទវណ្ណនា

[១១៤] អត្ថកាមបារិចរិយសិក្ខា បទថា តេន សមយេន ពុទ្ធោ ភគវា ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ វិនិច្ឆ័យក្នុងអត្ថកាមបារិចរិយសិក្ខាបទនោះ គប្បីជ្រាបដូច្នេះ ៖

## ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងឧទាយីភិក្ខុ

បទថា កុលុបគោ : ចូលទៅកាន់ត្រកូល សេចក្តីថា ជាអ្នកចូលទៅកាន់ត្រកូល គឺ ជាអ្នកខ្វល់ខ្វាយជានិច្ចក្នុងការចូលរកត្រកូលដើម្បីត្រូវការបច្ច័យ ៤ ។

បទថា ចីវរបិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារំ : ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ គឺ ចីវរផង បិណ្ឌបាតផង សេនាសនៈផង គិលានប្បច្ចយភេសជ្ជបរិក្ខារផង ។

ក៏ក្នុងពាក្យថា គិលានប្បច្ចយភេសជ្ជបរិក្ខារ នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ដែលឈ្មោះថា បច្ច័យ ព្រោះអត្ថថា ធ្វើការបំបាត់ ។ ពាក្យថា បច្ច័យ ជាឈ្មោះនៃភេសជ្ជៈដែលសប្បាយប្រភេទណាមួយ ។ ឈ្មោះថាការងាររបស់ពេទ្យ ព្រោះពេទ្យនោះអនុញ្ញាត ដូច្នោះ ទើបឈ្មោះថា

ភេសជ្ជៈ ។ គិលានប្បច្ច័យផង ភេសជ្ជៈផង ឈ្មោះថា គិលានប្បច្ចយភេសជ្ជៈ ។ មានពាក្យអធិប្បាយថា ការងាររបស់ពេទ្យ មានប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ប្រភេទណាមួយ ជាទីសប្បាយដល់អ្នកជម្ងឺ ។ ក៏គ្រឿងហោមព័ទ្ធ លោកហៅថា បរិក្ខារក្នុងពាក្យជាដើមថា "សត្តហិ នគរបរិក្ខារេហិ សុបរិក្ខតំ ហោតិ : នគរដែលរៀបចំល្អហើយ ដោយនគរបរិក្ខារ ៧ យ៉ាង"(១) ដូច្នេះ ។ គ្រឿងប្រដាប់លោកក៏ហៅថា បរិក្ខារ ក្នុងពាក្យជាដើមថា "រថោ សីលបរិក្ខារោ ឈានក្ខោ ចក្កវីរិយោ : រថ គឺ អរិយមគ្គ (នោះ) មានសីលជាគ្រឿងពាស មានឈានជាភ្លៅ មានវីរិយជាកង់"(២) ដូច្នេះ ។ គ្រឿងគាំទ្រលោកហៅថា បរិក្ខារ ក្នុងប្រយោគជាដើមថា "យេ ចិមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា : គ្រឿងបម្រុងជីវិតទាំងឡាយនេះ ដែលបព្វជិតគប្បីប្រមូលមក"(៣) ដូច្នេះ ។ ក្នុងបទថា គិលានប្បច្ចយ-ភេសជ្ជបរិក្ខារំ នេះ រមែងគួរទាំងគ្រឿងគាំទ្រ ទាំងគ្រឿងរក្សាការពារ ។

ពិតមែន គិលានប្បច្ចយភេសជ្ជៈនោះ ជារបងសម្រាប់ការពារជីវិតខ្លះ ព្រោះមិនឱ្យឱកាសដល់ការកើតឡើងនៃអាពាធដែលញុំាងជីវិតឱ្យ

---

១. អង្គ. សត្ត. មហាវគ្គ. ៤៧. ៦៤/១៩៤ ។ ២. សំយុ. មហា. អវិជ្ជាវគ្គ. ៣៧. ២៤/១២ ។ ៣. មជ្ឈិ. មូល. វនបត្ថសូត្រ. ២០. ២៣៥/៣៩៥ ។

វិនាស, ជាគ្រឿងគាំទ្រខ្លះ ព្រោះជាហេតុឱ្យជីវិតនោះ ប្រព្រឹត្តទៅបាន យូរ, ព្រោះដូច្នោះ ទើបហៅថា បរិក្ខារ គប្បីជ្រាបសេចក្ដីយ៉ាងនេះថា គិលានប្បច្ចយភេសជ្ជៈនោះផង ជាបរិក្ខារផង ដោយន័យដូចពោលមក នេះ ព្រោះដូច្នោះ ទើបឈ្មោះថា គិលានប្បច្ចយភេសជ្ជបរិក្ខារ ។ ពាក្យ ថា **គិលានប្បច្ចយភេសជ្ជបរិក្ខារនោះ** បណ្ឌិតគប្បីជ្រាបដោយសេចក្ដី យ៉ាងនេះ ។

បទថា វិសលំ **: អាក្រក់** គឺ ថោកទាប លាមក ។ ន័យមួយ ទៀត អ្នកដែលឈ្មោះថា វិសលៈ ព្រោះអត្ថថា ហូរចេញមក ។ អធិប្បាយថា រមែងបង្ហូរចេញ ។

បទថា និដ្ឋុហិត្វា **: ខាកស្ដោះ** គឺ ស្ដោះទឹកមាត់ឱ្យធ្លាក់ទៅ ។

ដោយពាក្យថា កិស្សាហំ តេន ហាយាមិ **: អញអន់ដោយអ្វី** ដូច្នេះ ស្រីនោះសម្ដែងថា យើងនឹងអន់ជាងស្រីដទៃណា ដូចម្ដេច ? ពោលដោយអ្វី ? គឺពោលដោយភោគៈក្ដី ដោយគ្រឿងតែងខ្លួនក្ដី ដោយ រូបរាងក្ដី ស្រីឈ្មោះណាហ្នុំ នឹងជាស្រីល្អក្រៃលែងជាងយើងទៅ ? ។

បទថា សន្តិកេ **: ក្នុងសំណាក់** បានដល់ ឈរក្នុងទីជិត ៗ គឺ ក្នុងទីមិនឆ្ងាយដោយជុំវិញ ។ សូម្បីដោយបទភាជនៈ លោកក៏សម្ដែង សេចក្ដីយ៉ាងនេះដូចគ្នា ។

បទថា **អត្តកាមបារិចរិយាយ : ការបម្រើខ្លួនដោយកាម** សេចក្តីថា ការបម្រើដោយកាម ពោលគឺ មេថុនធម្ម ឈ្មោះថា កាមបារិចរិយា ។ ការបម្រើដោយកាមដើម្បីប្រយោជន៍ដល់ខ្លួន ឈ្មោះថា អត្តកាមបារិចរិយា ។ ម្យ៉ាងទៀត ការបម្រើដែលខ្លួនប្រាថ្នា គឺ ប្រាថ្នា ព្រោះដូច្នោះ ទើបឈ្មោះថា អត្តកាមា ។ អធិប្បាយថា ដែលភិក្ខុប្រាថ្នាហើយ ដោយអំណាចនៃសេចក្តីតម្រេកក្នុងមេថុន ការបម្រើនោះផង ដែលខ្លួនឱ្យប្រាថ្នាផង ព្រោះដូច្នោះ ទើបឈ្មោះថា អត្តកាមបារិចរិយានៃការបម្រើដោយកាម ដើម្បីប្រយោជន៍ដល់ខ្លួន (ឬនៃការបម្រើដែលខ្លួនប្រាថ្នា) នោះ ។

## អធិប្បាយសិក្ខាបទវិភង្គចតុត្ថសង្ឃាទិសេស

ពីរបទថា *វណ្ណំ ភាសេយ្យ : ពោលសរសើរ* សេចក្តីថា គប្បីប្រកាសគុណ គឺ អានិសង្ស ។ បណ្តាអត្ថវិកប្បទាំងពីរនោះ អត្ថវិកប្បនេះថា ការបម្រើកាមដើម្បីប្រយោជន៍ខ្លួន បានសេចក្តីថា គឺ ចំណង់ដើម្បីខ្លួន ១ ហេតុដើម្បីខ្លួន ១ ការបម្រើដើម្បីខ្លួន ១ ព្យញ្ជនៈដ៏សេសក្នុងអត្ថវិកប្បនេះថា ការបម្រើនោះផង ដែលខ្លួនប្រាថ្នាផង ឈ្មោះថា អត្តកាមបារិចរិយា បានសេចក្តីថា គឺ សេចក្តីប្រាថ្នាដើម្បីខ្លួន ១ ការបម្រើដើម្បីខ្លួន ១ ព្យញ្ជនៈដ៏សេស ព្រោះហេតុនោះ ដើម្បីមិនធ្វើ

សេចក្តីអើពើក្នុងព្យញ្ជនៈ សម្តែងតែសេចក្តីប៉ុណ្ណោះ ទើបព្រះមានព្រះភាគត្រាស់បទភាជនៈថា "ចំណងដើម្បីខ្លួន ហេតុដើម្បីខ្លួន សេចក្តីប្រាថ្នាដើម្បីខ្លួន ការបម្រើដើម្បីខ្លួន" ។ ពិតមែន កាលត្រាស់ពាក្យថា "ចំណងដើម្បីខ្លួន ហេតុដើម្បីខ្លួន ការបម្រើដើម្បីខ្លួន" បណ្ឌិតទាំងឡាយនឹងជ្រាបថា "ការបម្រើដោយកាម ដើម្បីប្រយោជន៍ដល់ខ្លួន" លោកពោលហើយដោយពាក្យមានប្រមាណប៉ុណ្ណេះ សូម្បីកាលលោកពោលពាក្យថា "សេចក្តីប្រាថ្នាដើម្បីខ្លួន ការបម្រើដើម្បីខ្លួន" បណ្ឌិតទាំងឡាយក៏នឹងជ្រាបថា ការបម្រើដែលខ្លួនប្រាថ្នា ដោយអត្ថថា ដែលខ្លួនត្រូវការចង់បាន លោកពោលដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ ព្រះមានព្រះភាគ ទឹងទ្រង់សម្តែងអាការក្នុងការសរសើរគុណនៃការបម្រើខ្លួនដោយកាមនោះ ទើបត្រាស់ពាក្យថា ឯតទគ្គំ ជាដើម ។ ពាក្យនោះ មានសេចក្តីជាក់ច្បាស់តែម្តង ដោយឧទ្ទេស និងដោយនិទ្ទេស ។

ចំណែកបទសម្ពន្ធ និងវិនិច្ឆ័យអាបត្តិក្នុងសិក្ខាបទនេះ គប្បីជ្រាបដូច្នេះ ៖

ពាក្យថា ឯតទគ្គំ ។បេ ។ បរិចរេយ្យ : ស្រីណា គប្បីបម្រើនូវភិក្ខុមានសីល មានធម៌ជាកុសល ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ

ប្រហែលដូចអាត្មា ដោយធម៌នេះ ម្នាលប្អូនស្រី ការបម្រើនេះរបស់ស្រីនោះ ជាការប្រសើរជាងការបម្រើទាំងអស់ មានសេចក្ដីថា ស្រីណាបម្រើអ្នកប្រព្រឹត្តព្រហ្មចរិយមានសីល មានកល្យាណធម៌ដូចអាត្មា ដោយធម៌នោះ ៗ ដែលឈ្មោះថា ការបម្រើនេះណារបស់ស្រីនោះ ដែលបម្រើអ្នកប្រព្រឹត្តព្រហ្មចរិយ មានសីលមានកល្យាណធម៌ដូចអាត្មាយ៉ាងនោះ ៗ ការបម្រើនេះ ប្រសើរជាងការបម្រើទាំងឡាយ ៗ

ពីរបទថា មេថុនូបសញ្ហិតេន សង្ឃាទិសេសោ : ប្រកបដោយមេថុនធម្ម ត្រូវអាបត្តិសង្ឃាទិសេស មានសេចក្ដីថា ភិក្ខុណា កាលពោលគុណនៃការបម្រើខ្លួនដោយកាមយ៉ាងនោះ គប្បីពោលដោយពាក្យទាក់ទិនទឹងមេថុនធំ ៗ គឺសំដៅចំពោះមេថុនធំ ៗ ត្រូវអាបត្តិសង្ឃាទិសេសដល់ភិក្ខុនោះ ។

[១១៥] ឥឡូវនេះ លោកពិន័យអាបត្តិសង្ឃាទិសេសដល់ភិក្ខុដែលពោលដោយពាក្យទាក់ទិនទឹងមេថុនប៉ុណ្ណោះ ; ព្រោះហេតុនោះទើបមិនត្រូវអាបត្តិសង្ឃាទិសេស ដល់ភិក្ខុដែលពោលគុណនៃការបម្រើដោយពាក្យមានជាដើមយ៉ាងនេះថា អាត្មាក៏ជាក្សត្រិយ៍ នាងក៏ជាក្សត្រិយ៍ នាងក្សត្រិយ៍សមគួរឱ្យដល់ក្សត្រិយ៍ ព្រោះមានជាតិស្មើគ្នា ៗ តែជាសង្ឃាទិសេសដល់ភិក្ខុដែលពោលបរិយាយសូម្បីច្រើន មានពាក្យថា

អាត្មាក៏ជាក្សត្រិយ៍ នាងក៏ជាក្សត្រិយ៍ជាដើម ហើយពោលដោយពាក្យអាស្រ័យនឹងមេថុនចំ ៗ យ៉ាងនេះថា នាងសមគួរឱ្យមេថុនដល់អាត្មា ។

[១១៦] ពាក្យថា ឥត្ថី ច ហោតិ : ស្រីពិត ជាដើម មានន័យដូចពោលហើយក្នុងកាលមុននុ៎ះឯង ។ ឧទាយីភិក្ខុជាអាទិកម្មិកៈ ក្នុងសិក្ខាបទនេះ មិនត្រូវអាបត្តិដល់លោកអ្នកជាអាទិកម្មិកៈដូច្នេះឯង ។

បទភាជនីយវណ្ណនា ចប់

បកិណ្ណកៈទាំងពួងមានសមុដ្ឋានជាដើម ដូចទុដ្ឋុល្លវាចាសិក្ខាបទ ។ សូម្បីវិនីតវត្ថុទាំងឡាយ ក៏មានអត្ថជាក់ច្បាស់ទាំងនោះ ដោយប្រការដូច្នេះ ។

ពណ៌នាសង្ឃាទិសេសសិក្ខាបទទី ៤ ចប់

## ៥. សញ្ចរិត្តសិក្ខាបទវណ្ណនា

[១២១] *សញ្ចរិត្តសិក្ខាបទថា* តេន សមយេន ពុទ្ធោ ភគវា : *សម័យ*នោះឯង ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគជាដើម *ខ្ញុំ*ព្រះករុណា នឹងពោលតទៅ ។

ក្នុងសញ្ចរិត្តសិក្ខាបទនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

### ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងឧទាយីភិក្ខុ

បទថា បណ្ឌិតា : មានប្រាជ្ញា បានដល់ អ្នកប្រកបដោយសេចក្តីឆ្លាត គឺ អ្នកមានបញ្ញាជាគ្រឿងប្រព្រឹត្តិទៅ ។

បទថា ព្យត្តា : អង់អាច បានដល់ អ្នកប្រកបដោយភាពជាអ្នកអាច គឺជាអ្នកដឹងឧបាយ អ្នកក្លាហាន ។

បទថា មេធាវិនី : ឆ្លៀវឆ្លាស សេចក្តីថា ជាអ្នកប្រកបដោយបញ្ញា ធ្វើឱ្យអ្នកដទៃឃើញហើយ ឃើញទៀត ។

បទថា ទក្ខា : វាងវៃ គឺ ជាអ្នកប៉ិនប្រសប់ ។

បទថា អនលសា : មិនខ្ជិលច្រអូស គឺ ជាអ្នកដល់ព្រមដោយសេចក្តីប្រឹងប្រែងព្យាយាម ។

បទថា ឆន្នា : សមគ្នា បានដល់ សមគួរ ។

បទថា គរហិតា វិយ : ដូចជាអៀនអន់ពេកណាស់ មានអធិប្បាយថា មើលទៅហាក់ដូចជាការលំបាក គឺដូចជាមិនល្អ ដូចជាការដែលគួរខ្មាសដល់ពួកខ្ញុំព្រះករុណា ។

ពីរបទថា កុមារិកាយ វត្តុំ : ការដែលយើងនិយាយព្រោះនាងកុមារី សេចក្តីថា ការដែលនឹងនិយាយ ព្រោះហេតុនៃក្មេងស្រីថា "ពួកលោកចូរទទួលយកក្មេងស្រីនេះទៅ" (ដូចជាការលំបាក) ។

បណ្តាអាវាហៈជាដើម ដែលឈ្មោះថា អាវាហៈ បានដល់ ការនាំក្មេងស្រីមកពីត្រកូលដទៃ ដើម្បីក្មេងប្រុស ។ ដែលឈ្មោះថា វិវាហៈ បានដល់ ការបញ្ជូនក្មេងស្រីរបស់ខ្លួនទៅកាន់ត្រកូលដទៃ ។

បទថា វារេយ្យានិ : ដល់គ្នានិងគ្នា សេចក្តីថា ការស្តីដណ្តឹងថា ពួកលោកចូរឱ្យក្មេងស្រីក្រមុំ ដល់ក្មេងប្រុសកម្លោះរបស់ពួកយើង ឬធ្វើការកំណត់ថ្ងៃ ឬក្សរ និងយាម ។

[១២២] បទថា បុរាណគណកិយា : ជាប្រពន្ធហោរាចាស់ សេចក្តីថា ភរិយារបស់គ្រូទាយម្នាក់ ។ ស្រីនោះ កាលគ្រូទាយនោះនៅមានជីវិត ប្រាកដឈ្មោះថា គណកី : ម្ចាលអ្នកស្រី ។ និងកាលគ្រូទាយស្លាប់ហើយ ដល់ការហៅថា បុរាណគណកី ។

បទថា តិរោគាមោ : ស្រុកក្រៅ បានដល់ ខាងក្រៅស្រុក ។

អធិប្បាយថា ស្រុកដទៃ ។

បទថា មនុស្សា : មនុស្សទាំងឡាយ បានដល់ ពួកអ្នកស្រុក អ្នកដឹងរឿងដែលឧទាយីភិក្ខុ ជាអ្នកពេញចិត្តខ្វល់ខ្វាយក្នុងការនាំពាក្យ ចែចូវនេះ ។

[១២៣] បទថា សុណិសាភោគេន : ដោយការបម្រើជាកូនប្រសា សេចក្តីថា ពួកសាវករបស់អាជីវកទាំងនោះ ប្រើប្រាស់ស្រីនោះ ដូចមនុស្សទាំងឡាយ ប្រើស្រីកូនប្រសារ មានការឱ្យជាំបាយឱ្យធ្វើម្ហូប និងឱ្យថែទាំរក្សាជាដើម ។

ត្រើនបទថា តតោ អបរេន ទាសីភោគេន : តពីនោះមក ...ដោយការបម្រើជាទាសីទៅវិញ សេចក្តីថា កាលកន្លងទៅបាន ១ ខែ ពួកសាវករបស់អាជីវកទាំងនោះ ប្រើប្រាស់នាងនោះ ដូចដែលមនុស្សទាំងឡាយ ប្រើប្រាស់ទាសីមានការធ្វើស្រែ ចាក់សម្រាម និងដងទឹកជាដើម ។

បទថា ទុគ្គតា : សេចក្តីក្រីក្រ គឺ ជាអ្នកក្រលំបាក, ម៉្យាងទៀត សេចក្តីថា ទៅកាន់ត្រកូលដែលខ្វនទៅហើយ ជាអ្នករងទុក្ខ មានសេចក្តីលំបាក ។

ត្រើនបទថា មាយ្យោ ឥមំ កុមារិកំ : អ្នកទាំងអស់គ្នា កុំ (ប្រើប្រាស់) នាងកុមារីនេះ សេចក្ដីថា លោកកុំប្រើប្រាស់ក្មេងស្រីនេះ ដូចជាទាសីឡើយ ។

ដោយបទថា អាហារូបហារោ : ទាក់ទង ពួកសាវករបស់អាជីវកសម្ដែងថា ការធានារាប់រងនិងការយល់ព្រម គឺ ការទទួលនិងការឱ្យ ពួកយើងមិនបានទទួលមក មិនបានប្រគល់ឱ្យអ្វី ៗ គឺ ថា ពួកយើងមិនមានការទិញដូរ គឺ ការជួញដូរជាមួយនឹងលោក ។

ពាក្យថា សមណោន ភវិតព្វំ អព្យាវដេន សមណោ អស្ស សុស្សមណោ : សមណមិនត្រូវខ្វល់ខ្វាយទេ សមណត្រូវតែជាសមណល្អ មានសេចក្ដីថា ពួកសាវករបស់អាជីវករុករានឧទាយីថេរៈនោះ យ៉ាងនេះថា ធម្មតាថា សមណៈត្រូវជាអ្នកមិនខ្វល់ខ្វាយ គឺ ត្រូវជាអ្នកមិនព្យាយាមក្នុងការងារបែបនេះ, ព្រោះថា សមណៈយ៉ាងនេះ គប្បីជាសមណៈល្អ ហើយពោលថា "លោកចូរទៅវិញទៅ យើងមិនស្គាល់លោកទេ" ។

[១២៤] បទថា សង្ខិតោ : បរិបូណ៌ដោយគ្រឿងស្អិតស្អាង សេចក្ដីថា ជាអ្នកសម្បូរដោយគ្រឿងឧបករណ៍គ្រប់យ៉ាង ឬជាអ្នកតាក់តែងប្រដាប់ប្រដាហើយ ។

[១២៦] បទថា ធុត្តា : ពួកអ្នកលេង បានដល់ ពួកអ្នកលេងស្រី ។

បទថា បរិចារេន្តា : ជាអ្នកញុំាងស្រីឱ្យបម្រើ សេចក្តីថា ញុំាងឥន្ទ្រិយទាំងឡាយ ឱ្យត្រាច់ទៅរីករាយក្នុងអារម្មណ៍មានរូបជាដើម ដែលភ្លើតភ្លើនដោយជុំវិញយ៉ាងនេះផង យ៉ាងនោះផង, មានអធិប្បាយថា តែងលេង គឺតែងត្រេកអរ ។

បទថា អព្ភុតមកំសុ : ជនទាំងឡាយ ក៏តាំងភ្នាល់គ្នា សេចក្តីថា ពួកអ្នកលេងធ្វើការភ្នាល់គ្នាថា បើឧទាយីភិក្ខុនឹងធ្វើ លោកឈ្នះភ្នាល់ប៉ុណ្ណេះ បើនឹងមិនធ្វើ យើងនឹងឈ្នះភ្នាល់ប៉ុណ្ណេះ លោកពោលទុកក្នុងមហាបច្ចរីថា ក៏ការធ្វើភ្នាល់គ្នា មិនគួរដល់ភិក្ខុទាំងឡាយ, បើភិក្ខុណាធ្វើ, អ្នកបរាជ័យនឹងត្រូវធ្វើសេចក្តីវិនាសឱ្យដល់ភិក្ខុនោះ ។

វេលាមិនយូរ ហៅថា តំខណិកំ : មួយរំពេចនោះ ក្នុងពាក្យថា កថំ ហិ ឆាម អយ្យោ ឧទាយិ តង្ខណិកំ : មិនសមបើលោកម្ចាស់ឧទាយី...ស្រីដែលបុរសគប្បីសេពមួយរំពេចនោះសោះ នេះ ។ បទថា តង្ខណិកំ : មួយរំពេចនោះ បានដល់ ការនាំពាក្យថែចូវ មានការធ្វើអស់កាលមិនយូរ ។

# អធិប្បាយការប្រព្រឹត្តនិយាយដឹកនាំ

[១២៧] ពាក្យថា សញ្ចរិត្តំ សមាបជ្ជេយ្យ : ប្រព្រឹត្តនិយាយដឹកនាំ សេចក្តីថា គប្បីដល់ភាវៈប្រព្រឹត្តនិយាយដឹកនាំ ។ ក៏ព្រោះភិក្ខុដែលដល់ភាវៈ នាំ ពាក្យចែចូវនោះ ត្រូវអ្នកណា ៗ បញ្ជូនទៅហើយ ចាំបាច់ត្រូវតែទៅក្នុងទីកន្លែងណាមួយ, ស្រីនិងប្រុសដែលលោកប្រាថ្នាយកក្នុងសិក្ខាបទនេះ ដោយព្រះបាលីជាដើមថា ឥត្ថិយា វា បុរិសមតឹ : ប្រាប់សេចក្តីប្រាថ្នាប្រុសដល់ស្រីក្តី ខាង មុខន៊ុះឯង, ដូច្នោះ ដើម្បីទ្រង់សម្តែងអត្ថនោះ ទើបព្រះមានព្រះភាគត្រាស់បទភាជនៈ នៃពាក្យថា ឥត្ថិយា វា បុរិសមតឹ នោះ យ៉ាងនេះថា ភិក្ខុត្រូវស្រីបញ្ជូនទៅ ក្នុងសំណាក់បុរស ឬថា ត្រូវបុរសបញ្ជូនទៅក្នុងសំណាក់នៃស្រី ដូច្នេះ ។

ក្នុងពាក្យថា ឥត្ថិយា វា បុរិសមតឹ បុរិសស្ស វា ឥត្ថីមតឹ : ប្រាប់សេចក្តីប្រាថ្នាប្រុសដល់ស្រីក្តី ប្រាប់សេចក្តីប្រាថ្នាស្រីដល់ប្រុសក្តី នេះ បណ្ឌិតគប្បីជ្រាបបាលីដ៏សេសថា អារោចេយ្យ ប្រែថា គប្បីប្រាប់ ។ ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទថា បុរិសស្ស វា ឥត្ថីមតឹ នោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា រមែងប្រាប់សេចក្តីប្រាថ្នារបស់ប្រុសដល់ស្រី, ប្រាប់សេចក្តីប្រាថ្នា របស់ស្រីដល់ប្រុស

ដូច្នេះ ។

ឥឡូវនេះ កាលនឹងទ្រង់សម្ដែងប្រយោជន៍ គឺ សេចក្ដីប្រាថ្នា សេចក្ដីត្រូវការ អធ្យាស្រ័យ សេចក្ដីពេញចិត្ត សេចក្ដីគាប់ចិត្តរបស់ប្រុស និងស្រីទាំងនោះ ដែលភិក្ខុប្រាប់ ទើបត្រាស់ថា "ឱ្យបានគ្នាជាប្រពន្ធក្ដី ជាប្ដីឬជាសាហាយក្ដី" ។

បណ្ដាបទទាំងពីរនោះ បទថា ជាយត្តនេ **: ឱ្យបានគ្នាជាប្ដីប្រពន្ធក្ដី** គឺ ក្នុងភាពជាប្ដីប្រពន្ធ ។

បទថា ជារត្តនេ **: ជាសហាយក្ដី** គឺ ក្នុងភាពជាសហាយស្មន់; អធិប្បាយ ថា កាលភិក្ខុប្រាប់សេចក្ដីប្រាថ្នារបស់ប្រុសដល់ស្រី ឈ្មោះថា រមែងប្រាប់ក្នុងភាពជាប្រពន្ធ, កាលប្រាប់សេចក្ដីប្រាថ្នារបស់ស្រីដល់ប្រុស ឈ្មោះថា រមែងប្រាប់ក្នុងភាពជាសហាយស្មន់, ន័យមួយទៀត កាលប្រាប់សេចក្ដីប្រាថ្នារបស់ប្រុសទុំះឯងដល់ស្រី ឈ្មោះថា ប្រាប់ក្នុងភាពជាប្រពន្ធ គឺ ក្នុងភាពជាភរិយាត្រឹមត្រូវតាមច្បាប់ខ្លះ ក្នុងភាពជាសហាយស្មន់ គឺ ក្នុងភាពជាមិច្ឆាចារខ្លះ ។ ក៏ព្រោះថា ភិក្ខុកាលនឹងប្រាប់ភាពជាប្រពន្ធ និងជាសហាយស្មន់នេះ ចាំបាច់ត្រូវពោលពាក្យមានជាដើមថា "ឮថា នាងនឹងត្រូវជាភរិយារបស់ប្រុសនោះ", ដូច្នោះ ដើម្បី

សម្តែងអាការនៃពាក្យត្រូវពោលនោះ ទើបត្រាស់បទភាជនៈនៃបទទាំងពីរនោះថា ពាក្យថា ក្នុងភាពជាប្រពន្ធ គឺ នាងនឹងជាភរិយា, ពាក្យថា ក្នុងភាពជាសហាយស្មន់ គឺ នាងនឹងជាសហាយស្មន់ ដូច្នេះ ។

ដោយឧបាយនេះឯង សូម្បីក្នុងការប្រាប់សេចក្តីប្រាថ្នារបស់ស្រីដល់ប្រុស បណ្ឌិតគប្បីជ្រាបអាការដែលភិក្ខុចាំបាច់ត្រូវពោលថា "លោកនឹងជាប្តី, លោកនឹងជាស្វាមី, នឹងជាសហាយស្មន់" ។

ពីរបទថា **អន្តមសោ តំខណិកាយបិ : ដោយហោចទៅសូម្បីតែស្រីដែលបុរសគប្បីសេពមួយរំពេចនោះ** មានសេចក្តីថា ស្រីដែលព្រះមានព្រះភាគត្រាស់ហៅថា **តំខណិកា** ព្រោះស្រីដែលប្រុសគប្បីនៅរួមតែក្នុងខណៈនោះ គឺ ត្រឹមតែមួយភ្លែត, សេចក្តីថា ជាប្រពន្ធត្រឹមតែមួយស្របក់ ដោយកំណត់យ៉ាងទាបទីបំផុតទាំងអស់ ។ កាលភិក្ខុប្រាប់សេចក្តីប្រាថ្នារបស់ប្រុសយ៉ាងនេះថា "នាងនឹងជាប្រពន្ធមួយស្របក់" ដល់ស្រីនោះ ក៏ត្រូវអាបត្តិសង្ឃាទិសេស ។ ដោយឧបាយនេះនុ៎ះឯង សូម្បីភិក្ខុដែលប្រាប់សេចក្តីប្រាថ្នារបស់ស្រីដល់ប្រុសយ៉ាងនេះថា លោកនឹងជាប្តីមួយស្របក់ បណ្ឌិតគប្បីជ្រាបថា ត្រូវអាបត្តិសង្ឃាទិសេស ។

## អធិប្បាយស្រី ១០ ពួក

[១២៨] ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងពួកស្រីដែលទ្រង់ប្រាថ្នាក្នុងពាក្យថា ឥត្ថិយា វា បុរិសមតី នេះ ដោយប្រភេទហើយ ទ្រង់ សម្តែងប្រភេទនៃអាបត្តិ ដោយអំណាចភាពជាអ្នកនាំពាក្យថៃចូវ ក្នុងស្រីទាំងនោះ ទើបត្រាស់ពាក្យថា ទស ឥត្ថិយោ : ស្រីមាន ១០ ពួក ជាដើម ។

[១៣០] បណ្តាបទទាំងនោះ បទថា មាតុរក្ខិតា : មាតាថែរក្សា បានដល់ ស្រីដែលមាតារក្សា គឺ មាតារក្សាដោយប្រការដែលនឹងសម្រេចការនៅរួមជាមួយបុរសមិនបាន ។ ព្រោះហេតុនោះ ទើបព្រះឧបាលីពោលសូម្បីបទភាជនៈនៃបទថា មាតុរក្ខិតា : មាតាថែរក្សានោះថា មាតា រមែងរក្សាគ្រប់គ្រង ញុំាងខ្លួនឱ្យធ្វើភាពជាធំ ញុំាងអំណាចឱ្យប្រព្រឹត្តទៅ ។

បណ្តាបទទាំងនោះ បទថា រក្ខតិ : ថែរក្សា សេចក្តីថា មិនឱ្យទៅក្នុងទីណាមួយ ។ បទថា គោបេតិ : គ្រប់គ្រង សេចក្តីថា រមែងឃាត់ឃាំងទុកក្នុងទីគ្រប់គ្រង ដោយប្រការដែលពួកបុរសដទៃមិនអាចឃើញ ។

ពីរបទថា ឥស្សរិយំ ការេតិ : ជាធំ សេចក្ដីថា ហាមការនៅតាមអំពើចិត្តនៃស្រីនោះ ប្រព្រឹត្តសង្កត់សង្កិន ។

ពីរបទថា វសំ វត្តេតិ : ត្រួតត្រាលើ សេចក្ដីថា ញុំាងអំណាចរបស់ខ្លួនឱ្យប្រព្រឹត្តទៅ ក្នុងខាងលើនៃស្រីនោះយ៉ាងនេះថា ទាងចូរធ្វើវត្ថុនេះ, កុំធ្វើយ៉ាងនេះ ។ សូម្បីស្រីទាំងឡាយ មានស្រីដែលបិតារក្សាជាដើម ក៏គប្បីជ្រាបដោយឧបាយនេះ ។

គោត្រ ឬ ធម៌ រមែងរក្សាមិនបាន, ប៉ុន្តែថា ស្រីដែលជនអ្នកមានគោត្រស្មើគ្នា និងដែលជនអ្នកប្រព្រឹត្តធម៌រួមគ្នា គឺ ជនអ្នកបួសឧទ្ទិសព្រះសាស្ដាជាមួយគ្នា និងជនអ្នករាប់បញ្ចូលក្នុងគណៈតែមួយរួមគ្នារក្សាហើយលោកហៅថា ស្រីដែលគោត្ររក្សា ស្រីដែលធម៌រក្សា ។ ព្រោះដូច្នោះ លោកទើបពោលបទភាជនៈនៃបទទាំងនោះ ដោយន័យជាដើមថា សគោត្តា រក្ខន្តិ : ស្រីដែលជនមានគោត្រស្មើគ្នាថែរក្សា ។ ស្រីដែលប្រព្រឹត្តទៅមួយអន្លើដោយការរក្សា ឈ្មោះថា ស្រីមានការរក្សា ។ ស្រីប្រព្រឹត្តទៅមួយអន្លើដោយអាជ្ញាជុំវិញ ឈ្មោះថា ស្រីមានអាជ្ញាជុំវិញ ។ និទ្ទេសនៃស្រីទាំងនោះប្រាកដច្បាស់ហើយទុំះឯង ។ បណ្ដាស្រីទាំង ១០ ចំពូកនេះ ពីរពួកក្រោយតែប៉ុណ្ណោះ កាលគប់រកប្រុសដទៃ រមែងជាមិច្ឆាចារៈ, ពួកក្រៅនេះ មិនជាមិច្ឆាចារៈទេ ។

[១៣១] បណ្ដាស្រីដែលគេទិញដោយទ្រព្យជាដើម ស្រីដែលគេទិញមកដោយទ្រព្យតិចខ្លះ ច្រើនខ្លះ ឈ្មោះថា **ធនក្កីតា** ។ ក៏ព្រោះស្រីនោះ ត្រឹមតែគេទិញមកដោយទ្រព្យប៉ុណ្ណោះ មិនទាន់ឈ្មោះថា ជាភរិយា, តែដែលឈ្មោះថា ភរិយា ក៏ព្រោះគេទិញមកដើម្បីប្រយោជន៍ដល់ការនៅរួម, ដូច្នោះ ក្នុងនិទ្ទេសនៃបទថា ធនក្កីតានោះ ទើបព្រះឧបាលីថេរៈពោលថា ប្រុសទិញមកដោយទ្រព្យហើយឱ្យនៅ ។

ស្រីណា រមែងនៅដោយសេចក្ដីពេញចិត្ត គឺ ដោយសេចក្ដីត្រេកអររបស់ខ្លួន, ហេតុនោះ ស្រីនោះ ឈ្មោះថា ឆន្ទវាសិនី ។ ក៏ព្រោះហេតុដែលស្រីនោះ ព្រមជាភរិយាដោយហេតុត្រឹមតែសេចក្ដីពេញចិត្តរបស់ខ្លួនមួយចំណែក ក៏ទេ, តែដែលឈ្មោះថា ជាភរិយា ព្រោះជាអ្នកដែលប្រុសទទួលព្រមហើយ, ដូច្នោះ ក្នុងនិទ្ទេសនៃបទថា ឆន្ទវាសិនី នោះ លោកទើបពោលថា ប្រុសដែលស្រឡាញ់ រមែងញុំាងស្រីជាទីស្រឡាញ់ឱ្យនៅ ។

ស្រីណា រមែងនៅដោយភោគៈ, ហេតុនោះ ស្រីនោះ ឈ្មោះថា ភោគវាសិនី ។ ពាក្យថា ភោគវាសិនី នោះ ជាឈ្មោះនៃស្រីក្នុងជនបទ អ្នកបានឧបករណ៍នៃផ្ទះ មានត្បាល់ អង្រែជាដើម ហើយចូលដល់ភាពជាភរិយា ។

ស្រីណា រមែងនៅដោយផ្ទាំងសំពត់, ហេតុនោះ ស្រីនោះ ឈ្មោះថា បដវាសិនី ពាក្យថា បដវាសិនី នោះ ជាឈ្មោះនៃស្រីកំណាន់ចិត្ត ជាអ្នកបានត្រឹមតែសំពត់ស្លៀកខ្លះ សំពត់ដណ្តប់ខ្លះ ហើយចូលដល់ភាពជាភរិយា ។

ពាក្យថា ឱទបត្តកិនី នោះ ជាឈ្មោះនៃស្រីដែលពួកញាតិ កាន់ដៃរបស់គូស្រករឱ្យជ្រលក់ចុះក្នុងភាជន៍ទឹកជាមួយគ្នា ហើយពោលថា អ្នកទាំងពីរចូររីករាយរកគ្នា មិនបែកគ្នា ដូចទឹកនេះចុះ ដូច្នេះ ហើយកំណត់កាន់យក ។ សូម្បីក្នុងនិទ្ទេសនៃបទថា ឱទបត្តកិនី នោះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា ញាតិឱ្យប្រុសនោះ ចាប់ភាជនៈទឹករួមនឹងស្រីនោះ ហើយឱ្យនៅ ។

ទំនួលរបស់ស្ត្រីនោះដែលបុរសនាំចុះ គឺ ដាក់ចុះហើយហេតុនោះ ស្ត្រីនោះ ឈ្មោះថា ឱភដចុម្ពដា, គឺ បណ្តាស្ត្រីទាំងឡាយ មានស្ត្រីទូលឧសជាដើមណាមួយ ។ ពាក្យថា ឱភដចុម្ពដា នោះ ជាឈ្មោះនៃស្ត្រីដែលបុរសលើកទំនួលចុះអំពីសីសៈ ហើយឱ្យនៅក្នុងផ្ទះ ។

បទថា ធាសី ច បានដល់ ស្ត្រីជាទាសីផង ជាភរិយារបស់ខ្លួនផង ។ ស្ត្រីធ្វើការងារក្នុងផ្ទះដើម្បីតម្លៃឈ្នួល ឈ្មោះថា ស្ត្រីធ្វើការងារ, បុរសខ្លះមិនមានសេចក្តីត្រូវការដោយភរិយារបស់ខ្លួន ទើបសម្រេចការ

គ្រប់គ្រងផ្ទះនឹងស្ត្រីនោះ; ស្ត្រីនេះ លោកហៅថា ជាស្ត្រីធ្វើការងារផង ជាភរិយាផង ។

ស្ត្រីដែលទង់នាំមកហើយ គឺ ស្ត្រីដែលគេចាប់ពីកងទ័ពមកធ្វើជាភរិយា ឈ្មោះថា **ធជាហដា** ។ មានពាក្យអធិប្បាយថា ស្ត្រីអ្នកដែលកងទ័ពលើកទង់ឡើងហើយទៅប្រយុទ្ធគ្នា ឯព្រំប្រទល់របស់សត្រូវហើយនាំមក ។ បុរសណាមួយ ធ្វើស្ត្រីនោះឱ្យជាភរិយា, ស្ត្រីនេះឈ្មោះថា **ធជាហដា** ។ ស្ត្រីដែលបុរសគប្បីនៅរួមត្រឹមតែមួយស្របក់ មានន័យដូចពោលហើយនុ៎ះឯង ។ ជាមិច្ឆាចារដល់ស្ត្រីទាំង ១០ ពួកនេះ ព្រោះការគប់រកប្រុសដទៃ ។ ក៏ក្នុងស្ត្រីទាំង ២០ ពួកនេះ ជាមិច្ឆាចារដល់ពួកបុរស, និងក៏ជាការប្រព្រឹត្តនិយាយជីកនាំដល់ភិក្ខុផង ។

## អធិប្បាយនិក្ខេបបទរឿងប្រុសបញ្ជូនភិក្ខុ

[១៣២-១៨៥] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **បុរិសោ ភិក្ខុំ បហិណតិ : បុរសបញ្ជូនភិក្ខុ** ជាដើម ដូចតទៅនេះ ៖

ភិក្ខុនោះទទួលពាក្យ ដែលប្រុសនោះពោលយ៉ាងនេះថា "បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សាថា បានឮថា នាងចូរជាធនក្កីតាភរិយារបស់ប្រុស ឈ្មោះនេះទៅ" ដូច្នេះ ដោយបញ្ចេញវាចាដោយអាការយ៉ាងណាមួយថា "ល្អណាស់ឧបាសក ?"

ឬថា "ចូរសម្រេច" ឬថា "អាត្មានឹងប្រាប់" ឬដោយកាយវិការមានងក់ក្បាលជាដើម ឈ្មោះថា ទទួល ។

កាលទទួលយ៉ាងនោះហើយ ទៅកាន់សំណាក់ស្រីនោះ ប្រាប់ពាក្យបង្គាប់នោះ ឈ្មោះថា ប្រាប់ ។

កាលពាក្យបង្គាប់នោះដែលលោកប្រាប់ហើយ ស្រីនោះទទួលថា "ល្អណាស់" ឬហាមឃាត់ ឬនៅស្ងៀម ព្រោះខ្មាសក៏ដោយ, ភិក្ខុត្រឡប់មកប្រាប់ដំណឹងនោះដល់ប្រុសនោះ ឈ្មោះថា ត្រឡប់មកប្រាប់ ។ ដោយអាការត្រឹមតែប៉ុណ្ណេះ ត្រូវអាបត្តិសង្ឃាទិសេស ព្រោះគ្រប់អង្គ ៣ ពោលគឺ ទទួលពាក្យ ១ ប្រាប់ ១ ត្រឡប់មកប្រាប់ ១ ។ តែស្រីនោះនឹងជាកិរិយារបស់ប្រុសនោះ ឬអត់ក៏ដោយ, នោះមិនមែនជាហេតុ ។

ព្រះមហាបទុមត្ថេរៈពោលថា ក៏បើភិក្ខុនោះ ដែលប្រុសពឹងពាក់ទៅកាន់សំណាក់របស់ស្រីដែលមាតារក្សា មិនជួបស្រីនោះ ទើបប្រាប់ពាក្យបង្គាប់នោះ ដល់មាតារបស់ស្រីនោះ ឈ្មោះថា ប្រាប់ក្រៅពាក្យបង្គាប់, ព្រោះដូច្នោះ ទើបខុសសង្កេត ។

ចំណែកព្រះមហាសុមត្ថេរៈពោលថា ទោះជាមាតា ឬបិតា ក៏ដោយ, ដោយហោចទៅសូម្បីជាទាសីក្នុងផ្ទះ ឬអ្នកដទៃណាមួយ នឹងញុំាងកិរិយានោះ ឱ្យសម្រេចបាន, កាលពាក្យបង្គាប់នោះដែលភិក្ខុនោះសូម្បីប្រាប់ហើយដល់អ្នកនោះ ជាការប្រាប់ហើយតែម្តង, ព្រោះដូច្នោះ

គង់ត្រូវអាបត្តិដូចគ្នាក្នុងវេលា គ្រប់អង្គ ៣, ភិក្ខុណាប្រាថ្នានឹងពោលថា ពុទ្ធំ បច្ចក្ខាមិ បែរទៅជាពោលខុសថា ធម្មំ បច្ចក្ខាមិ សិក្ខាគប្បីជាការលោកលាហើយមិនមែនឬ ? សេចក្តីនេះ យ៉ាងណា, ម្យ៉ាងទៀត ភិក្ខុប្រាថ្នានឹងពោលថា បឋមំ ឈានំ សមាបជ្ជាមិ គប្បីពោលខុសទៅថា ទុតិយំ ឈានំ សមាបជ្ជាមិ លោកគប្បីជាអ្នកត្រូវបារាជិកពិតមិនមែនឬ សេចក្តីនេះយ៉ាងណា, ពាក្យជាគ្រឿងញ៉ាំងឧបមេយ្យឱ្យដល់ព្រមនេះ ក៏យ៉ាងនោះ ។

ក៏ពាក្យរបស់ព្រះសូមត្ថេរៈនុ៎ះឯង សមដោយបទនេះថា ភិក្ខុទទួលតែឱ្យអន្តេវាសិកប្រាប់ ហើយត្រឡប់មកប្រាប់ដោយខ្លួនឯង ត្រូវសង្ឃាទិសេស, ព្រោះដូច្នោះ ពាក្យរបស់លោកជាការពោលត្រឹមត្រូវហើយ ។

កាលភិក្ខុដែលប្រុសបង្គាប់ថា លោកមេត្តាប្រាប់ស្រីដែលមាតារក្សា ហើយទៅប្រាប់ សូម្បីដល់ជនដទៃមានមាតាជាដើម អ្នកអាចនឹងប្រាប់ដល់ស្រីនោះបាន, សេចក្តីខុសសង្កេត រមែងមិនមាន យ៉ាងណា ; ក្នុងកាលគួរនឹងប្រាប់ថា បានឮថា នាងចូរជាធនក្កីតាភរិយារបស់ប្រុសឈ្មោះនេះ សូម្បីកាលភិក្ខុប្រាប់ដោយអំណាពាក្យថា អ្នកនៅរួមដោយសេចក្តីស្រឡាញ់ជាដើម ពាក្យណាមួយ ដែលត្រាស់ទុកក្នុងបាលីយ៉ាង

នេះថា “បានឮថា នាងចូរជាភរិយា អ្នកនៅដោយសេចក្តីស្រឡាញ់របស់ប្រុសឈ្មោះនេះ” ឬដោយអំណាចពាក្យទាំងឡាយ សូម្បីដែលមិនបានត្រាស់ទុក តែសម្តែងសេចក្តីនៅរួមគ្នា មានជាដើមយ៉ាងនេះថា “បានឮថា នាងចូរជាភរិយា ប្រពន្ធ បជាបតី មាតារបស់បុត្រ មេផ្ទះ ស្រីម្ចាស់ផ្ទះ មេចុងភៅ នាងបម្រើ ស្រីបម្រើកាមរបស់ប្រុសឈ្មោះនេះ” ដូច្នេះ ពាក្យណាមួយ សេចក្តីខុសសង្កេត រមែងមិនមានយ៉ាងនោះឯង, គង់ត្រូវអាបត្តិពិត ព្រោះគ្រប់អង្គ ៣ ។

តែកាលភិក្ខុ ដែលប្រុសពឹងពាក់ថា “មេត្តានិយាយនឹងស្រីដែលមាតារក្សា ហើយទៅនិយាយនឹងស្រីពួកដទៃ មានស្រីដែលបិតារក្សា”ជាដើម ស្រីណាមួយ ជាការខុសសង្កេត ។ សូម្បីក្នុងបទថា បិតុរក្ខិតំ ព្រូហិ ជាដើម ក៏ន័យនេះឯង ។ ពិតមែន សេចក្តីប្លែកគ្នាក្នុងបទថា បិតុរក្ខិតំ ព្រូហិ ជាដើមនេះ ក៏ត្រឹមតែសេចក្តីផ្សេងនៃបេយ្យាលដោយអំណាចនៃចក្ក មានឯកមូលកចក្ក និងទុមូលកចក្កជាដើម និងដោយអំណាចនៃអ្នកផ្តើម មានជាដើមយ៉ាងនេះ គឺ មាតារបស់ប្រុសពឹងពាក់ភិក្ខុ, មាតារបស់ស្រីដែលមាតាគ្រប់គ្រងពឹងពាក់ភិក្ខុ, ស្រីដែលមាតារក្សាពឹងពាក់ភិក្ខុប៉ុណ្ណោះ ។ តែសេចក្តីប្លែកគ្នានោះ អ្នកសិក្សាអាចជ្រាបបានតាមព្រះបាលីនុ៎ះឯង ព្រោះមានន័យដូចបានពោលទុកហើយក្នុងកាល

មុន ព្រោះហេតុនោះ ទើបខ្ញុំព្រះករុណាមិនបានធ្វើសេចក្តីអើពើ ដើម្បីសម្តែងវិភាគនៃសេចក្តីប្លែកគ្នានោះទេ ។

## អធិប្បាយរឿងភិក្ខុទទួលពាក្យជាដើម

[១៨៦] ក៏ក្នុង២ ចតុក្កៈ មានពាក្យថា បដិគ្គណ្ហាតិ : ទទួលពាក្យជាដើម ក្នុងចតុក្កៈទី ១ ត្រូវអាបត្តិសង្ឃាទិសេស ព្រោះគ្រប់អង្គ ៣ ដោយបទដើម, ត្រូវអាបត្តិថុល្លច្ច័យព្រោះគ្រប់អង្គ ២ ដោយបទកណ្តាល, ត្រូវអាបត្តិទុក្កដ ព្រោះគ្រប់អង្គ ២ ដោយបទដើម, ត្រូវអាបត្តិទុក្កដ ព្រោះគ្រប់អង្គ ១ ដោយពីរបទត្រង់កណ្តាល, មិនត្រូវអាបត្តិ ព្រោះមិនមានអង្គ ដោយបទមួយចុងបង្អស់ ។

បណ្តាបទទាំងនោះ បទថា បដិគ្គណ្ហាតិ : ទទួល បានដល់ទទួលពាក្យបង្គាប់របស់អ្នកពឹងពាក់ ។

បទថា វីមំសតិ : ទៅនិយាយល្បងមើល បានដល់ ទៅកាន់ទីដែលគេពឹងពាក់ទៅហើយ ប្រាប់ពាក្យបង្គាប់នោះ ។

បទថា បច្ចាហរតិ : ត្រឡប់មកប្រាប់ បានដល់ ត្រឡប់មកប្រាប់ដល់អ្នកពឹងពាក់ដែលជាអ្នកផ្តើម ។

ពាក្យថា ន បច្ចាហរតិ : មិនបានវិលមកប្រាប់វិញ បានដល់

ប្រាប់ហើយ ចៀសចេញទៅអំពីទីនោះ ។

ពាក្យថា បដិគ្គណ្ហាតិ ន វីមំសតិ : ទទួល តែមិនប្រាប់បានដល់ អ្នកដែលប្រុសពឹងពាក់ថា "លោកម្ចាស់មេត្តាទៅប្រាប់ស្រីឈ្មោះនេះ" ទទួលពាក្យបង្គាប់របស់គេថា "ចម្រើនពរ ឧបាសក អាត្មាប្រាប់បាន" ហើយទោះជាភ្លេច ឬមិនភ្លេចពាក្យបង្គាប់នោះក៏ដោយ ទៅកាន់សំណាក់របស់ស្រីនោះ ដោយករណីយកិច្ចយ៉ាងណាដទៃ អន្ទ្រយពោលពាក្យណាមួយបន្តិចបន្តួច, ដោយអាការត្រឹមតែប៉ុណ្ណេះ លោកហៅថា បដិគ្គណ្ហាតិ ន វីមំសតិ : ទទួល តែមិនប្រាប់ ។

លំដាប់នោះ ស្រីនោះនិយាយដោយខ្លួនឯងចំពោះភិក្ខុនោះថា "បានឮថា ឧបដ្ឋាករបស់លោកម្ចាស់ចង់បានខ្ញុំព្រះករុណា" ដូច្នេះ, កាលនិយាយយ៉ាងនេះហើយ ទើបនិយាយថា "ខ្ញុំព្រះករុណា នឹងជាភរិយារបស់គេ"ក្តី ឬថា "នឹងមិនជា..."ក្តី, ភិក្ខុនោះមិនទទួលព្រម មិនជំទាស់ពាក្យរបស់ស្រីនោះ នៅស្ងៀមព្រងើយ ក្រោកចាកទីអង្គុយមកកាន់សំណាក់របស់ប្រុសនោះ ប្រាប់ដំណឹងនោះ, ដោយអាការត្រឹមតែប៉ុណ្ណេះ លោកហៅថា ឈ្មោះថា ន វីមំសតិ បច្ចាហរតិ : មិននិយាយល្បងមើល គ្រាន់តែត្រឡប់មក ប្រាប់វិញ ។

បទថា ន វីមំសតិ ន បច្ចាហរតិ : មិននិយាយល្បងមើល

មិនបានត្រឡប់មកប្រាប់វិញ បានដល់ ទទួលក្នុងវេលាដែលប្រាប់ពាក្យបន្ទាប់តែម្យ៉ាង ប៉ុណ្ណោះ, ប៉ុន្តែថា មិនធ្វើកិច្ចពីរយ៉ាងក្រៅនេះ ។

បទថា ន បដិគ្គណ្ហាតិ វីមំសតិ បច្ចាហរតិ : មិនទទួលពាក្យ តែបាននិយាយល្បងមើល ហើយនាំសេចក្តីមកប្រាប់វិញ បានដល់ បុរសណាដែលពោលពាក្យបែបនោះ ក្នុងទីដែលភិក្ខុឈរ ឬអង្គុយ ។ ភិក្ខុសូម្បីដែលគេមិនបានពឹងពាក់ទេ តែដូចជាត្រូវគេពឹងពាក់ទើបទៅកាន់សំណាក់របស់ស្រី ហើយប្រាប់ដោយន័យជាដើមថា "បានឮថា នាងចូរជាភរិយារបស់បុរសឈ្មោះនេះ" ហើយត្រឡប់មក ប្រាប់សេចក្តីពេញចិត្ត ឬមិនពេញចិត្តរបស់ស្រីនោះ ដល់បុរសនេះ ។ កាលភិក្ខុមិនត្រឡប់មកទេ ប្រាប់ហើយ, ដោយន័យនោះឯង លោកហៅថា មិនទទួល តែប្រាប់ និងមិនត្រឡប់មកប្រាប់ ។ ភិក្ខុដែលទៅហើយដោយន័យនោះឯង តែមិនប្រាប់ ស្តាប់ពាក្យរបស់ស្រីនោះ និយាយហើយ មកប្រាប់ដល់បុរសនេះ តាមន័យដែលពោលហើយ ក្នុងបទទី ៣ នៃបឋមចតុក្កៈ លោកហៅថា មិនទទួល មិនប្រាប់ តែត្រឡប់មកប្រាប់ ។ បទទី ៤ ជាក់ច្បាស់ហើយនោះឯង ។

[១៨៧] ន័យទាំងឡាយជាដើមថា ពឹងពាក់ភិក្ខុច្រើនរូបជាក់ច្បាស់ហើយដូចគ្នា ។ ដូចឧបមាថា ភិក្ខុសូម្បីច្រើនរូប រមែងត្រូវអាបត្តិ

ព្រោះវត្ថុតែមួយ យ៉ាងណា, គប្បីជ្រាបអាបត្តិច្រើន ព្រោះវត្ថុច្រើនសូម្បីភិក្ខុតែមួយរូប ដូច្នោះ ។

តើយ៉ាងណា ? បុរសពឹងពាក់ភិក្ខុថា "លោកម្ចាស់ សូមលោកម្ចាស់មេត្តាទៅកាន់ប្រាសាទឈ្មោះឯណោះ មានស្រីប្រមាណ ៦០ ឬ ៧០ នាក់, លោកម្ចាស់មេត្តាប្រាប់ស្រីទាំងនោះថា "បានឮថា ពួកនាងចូរជាភរិយារបស់បុរសឈ្មោះនេះ" ។ ភិក្ខុនោះទទួលហើយ ទៅកាន់ប្រាសាទនោះតែម្ដង ប្រាប់ហើយនាំដំណឹងនោះត្រឡប់មកវិញ ។ លោកត្រូវអាបត្តិស្មើចំនួនស្រី ។ ពិតមែន សូម្បីក្នុងគម្ពីរបរិវារ ព្រះមានព្រះភាគក៏បានត្រាស់ពាក្យនេះទុកថា ៖

"ភិក្ខុត្រូវគរុកាបត្តិទាំង៦៤ ជាអាបត្តិដែលខ្លួនកែបាន ក្នុងខណៈជាមួយគ្នា ដោយគ្រាន់តែឈានទៅ ទឹងពោលដោយវាចា ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ"[១] ។

បានឮថា បញ្ហានេះ លោកអាស្រ័យអំណាចនៃអត្ថនេះ ពោលហើយ ។ ចំណែកពាក្យថា អាបត្តិ ៦៤ ក្នុងគាថានេះ ព្រះមានព្រះភាគត្រាស់ ដើម្បីសេចក្ដីពីរោះនៃពាក្យ ។ តែកាលភិក្ខុធ្វើយ៉ាងនោះ រមែងត្រូវអាបត្តិរាប់រយក៏បាន រាប់ពាន់ក៏បាន ដូច្នេះឯង ។ដូចជាត្រូវអាបត្តិ

១. វិន. បរិ. សេទមោចនគាថា. ១៣. ៣៩៧/៤០៧ ។

ច្រើន ព្រោះស្រីច្រើននាក់ដល់ភិក្ខុមួយរូប ដែលប្រុសមួយនាក់ពីងពាក់ទៅ យ៉ាងណា, ប្រុសមួយនាក់ ពីងពាក់ភិក្ខុច្រើនរូបទៅកាន់សំណាក់របស់ស្រីមួយនាក់, ត្រូវអាបត្តិសង្ឃាទិសេស ដល់ភិក្ខុទាំងអស់គ្រប់រូបយ៉ាងនោះ ។

ប្រុសមួយនាក់ ពីងពាក់ភិក្ខុច្រើនរូប ទៅកាន់សំណាក់របស់ស្រីចំនួនច្រើននាក់ ត្រូវអាបត្តិសង្ឃាទិសេសតាមចំនួនស្រី ។ ប្រុសច្រើននាក់ ពីងពាក់ភិក្ខុមួយរូបទៅកាន់សំណាក់របស់ស្រីមួយនាក់ ជាសង្ឃាទិសេសតាមចំនួនរបស់ប្រុស ។ ប្រុសច្រើននាក់ ពីងពាក់ភិក្ខុមួយរូប ទៅកាន់សំណាក់របស់ស្រីច្រើននាក់ជាសង្ឃាទិសេសតាមចំនួនវត្ថុ ។ ប្រុសច្រើននាក់ ពីងពាក់ភិក្ខុច្រើនរូបជាមួយគ្នាទៅកាន់សំណាក់ស្រីមួយនាក់ ជាសង្ឃាទិសេសតាមចំនួនវត្ថុ ។ ប្រុសច្រើននាក់ ពីងពាក់ភិក្ខុច្រើនរូបទៅកាន់សំណាក់នៃស្រីច្រើននាក់ ជាសង្ឃាទិសេសតាមចំនួនវត្ថុ ។ សូម្បីក្នុងពាក្យថា ស្រីមួយនាក់ពីងពាក់ភិក្ខុតែមួយរូបជាដើម ក៏មានន័យដូចគ្នានេះ ។ ក៏ក្នុងសញ្ចរិត្តសិក្ខាបទនេះ ឈ្មោះថាភាពជាអ្នកត្រូវចំណែកគ្នា និងមិនត្រូវចំណែកគ្នាមិនជាប្រមាណ ។ កាលភិក្ខុធ្វើការនាំពាក្យថែចូវ ដល់បិតាមាតាក្តី ដល់សហធម្មិក ទាំង ៥ ក្តី ត្រូវអាបត្តិទាំងអស់នោះឯង ។ ចតុក្កៈថា ប្រុសពីងពាក់ភិក្ខុថា "ទៅចុះ

លោកម្ចាស់” លោកពោលទុកដើម្បីសម្តែងប្រភេទនៃអាបត្តិ ដោយអំណាចនៃអង្គ ។

ក្នុងបទចុងនៃចតុក្កៈនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ត្រើនបទថា អន្តេវាសី វិមំសិត្វា ពហិទ្ធា បច្ចាហរតិ : ឯកូនសិស្សនោះ បាននិយាយល្បងមើល ហើយក៏ត្រឡប់ទៅប្រាប់បុរសដើមក្រៅពីអាចារ្យដែលប្រើនោះ មានសេចក្តីថា អន្តេវាសិកមកហើយមិនប្រាប់ដល់អាចារ្យចេញទៅមកដទៃប្រាប់ដល់ប្រុសនោះ ។

ត្រើនបទថា អាបត្តិ ឧភិន្នំ ថុល្លច្ចយស្ស : ត្រូវអាបត្តិថុល្លច្ច័យទាំងពីររូប មានសេចក្តីថា ត្រូវអាបត្តិថុល្លច្ច័យដល់អាចារ្យដោយអង្គ ២ គឺ ព្រោះទទួល ១ ព្រោះប្រើឱ្យប្រាប់ ១ ។ ត្រូវអាបត្តិថុល្លច្ច័យដល់អន្តេវាសិកដោយអង្គ ២ គឺ ព្រោះប្រាប់ ១ ព្រោះត្រឡប់មកប្រាប់ ១ ។ ពាក្យដ៏សេសប្រាកដច្បាស់ហើយនោះឯង ។

[១៨៨] ពីរបទថា គច្ឆន្តោ សម្បាទេតិ : ភិក្ខុទទួលពាក្យទៅនិយាយល្បងមើល បានដល់ ទទួល និងប្រាប់ ។

ពីរបទថា អាគច្ឆន្តោ វិសំវាទេតិ : ហើយត្រឡប់មកប្រាប់វិញដោយពាក្យកុហក បានដល់ មិនត្រឡប់មកប្រាប់ ។

ពីរបទថា គច្ឆន្តោ វិសំវាទេតិ : ភិក្ខុកាលទៅមិនទទួលបន្ទាប់ បានដល់ មិនទទួល ។

ពីរបទថា អាគច្ឆន្តោ សម្បាទេតិ : តែបាននិយាយល្បងផង វិលមកប្រាប់វិញផង បានដល់ ប្រាប់ និងត្រឡប់មកប្រាប់ ។

ក្នុងបទទាំងពីរយ៉ាងនេះ ត្រូវអាបត្តិថុល្លច្ច័យដោយអង្គ ២ ។ ក្នុងបទទី ៣ ត្រូវអាបត្តិ, ក្នុងបទទី ៤ មិនត្រូវអាបត្តិ ។

[១៨៩] ក្នុងពាក្យថា អនាបត្តិ សង្ឃស្ស វា ចេតិយស្ស វា គិលានស្ស វា ករណីយេន គច្ឆតិ ឧម្មត្តកស្ស អាទិកម្មិកស្ស : ភិក្ខុដែលទៅ(កាន់សំណាក់ស្រីនិងប្រុស) ដោយកិច្ចដែលត្រូវធ្វើ ចំពោះសង្ឃក្តី ចំពោះចេតិយក្តី ចំពោះបុគ្គលក្តី ភិក្ខុឆ្កួត ភិក្ខុដើមបញ្ញត្តិ មិនត្រូវអាបត្តិឡើយ នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

មានឧបោសថាគារ ឬការងារណាមួយ របស់ភិក្ខុសង្ឃដែលធ្វើ មិនទាន់រួច, ឧបាសកពឹងពាក់ភិក្ខុឱ្យទៅកាន់សំណាក់របស់ឧបាសិកា ឬ ឧបាសិកាពឹងពាក់ភិក្ខុទៅកាន់សំណាក់របស់ឧបាសក ដើម្បីត្រូវការអាហារ និងតម្លៃឈ្នួលសម្រាប់ពួកអ្នកធ្វើការងារ (ពួកជាង) ក្នុងការសាង ឧបោសថាគារជាដើមនោះ, កាលភិក្ខុទៅ ដោយករណីយ៍របស់សង្ឃ

ដូច្នេះ មិនត្រូវអាបត្តិ ។ សូម្បីក្នុងចេតិយកម្មដែលកំពុងធ្វើ ក៏មានន័យដូចគ្នានេះ ។ មិនត្រូវអាបត្តិដល់ភិក្ខុដែលឧបាសកពឹងពាក់ហើយ ទៅកាន់សំណាក់របស់ឧបាសិកា ឬដែលឧបាសិកាពឹងពាក់ហើយ ទៅកាន់សំណាក់របស់ឧបាសក ដើម្បីត្រូវការថ្នាំសម្រាប់ភិក្ខុអាពាធ ។ ភិក្ខុឆ្កួតនិងភិក្ខុដែលជាអាទិកម្មិកៈ មានន័យដូចពោលហើយនុ៎ះឯង ។

បណ្ដាបកិណ្ណកៈមានសមុដ្ឋានជាដើម សិក្ខាបទនេះ មានសមុដ្ឋាន ៦ កាលភិក្ខុទទួលដំណឹង ដោយកាយវិការ មានងក់ក្បាលជាដើម ទៅប្រាប់ដោយមេដៃ ហើយត្រឡប់មកប្រាប់ដោយមេដៃ, អាបត្តិកើតអំពីកាយ ។ កាលអ្នកណាមួយ ពោលដល់ភិក្ខុដែលអង្គុយក្នុងសាលាឆាន់រង់ចាំ ស្រីឈ្មោះនេះ នឹងមក, លោកគប្បីជ្រាបចិត្តរបស់នាងហើយទទួលថា "ល្អណាស់" ប្រាប់ចំពោះនាងអ្នកមករក កាលនាងត្រឡប់ទៅហើយ ប្រាប់ក្នុងកាលបុរសនោះត្រឡប់មករក, អាបត្តិកើតអំពីវាចា ។ សូម្បីកាលភិក្ខុទទួលពាក្យបង្គាប់ដោយវាចាថា "ចម្រើនពរ ឧបាសក អាត្មាប្រាប់បាន" ហើយទៅកាន់ផ្ទះរបស់ស្រីនោះដោយករណីយ៍ដទៃ ឬជួបស្រីនោះក្នុងវេលាទៅទីដទៃ ហើយប្រាប់ដោយបញ្ចេញវាចានុ៎ះឯង មិនទាន់ចៀសទៅអំពីទីនោះដោយហេតុដទៃនុ៎ះឯង ចៃដន្យជួបបុរសនោះដើរចូលទៀតហើយប្រាប់, អាបត្តិរមែងកើតដោយវាចាតែម្យ៉ាង ។ តែ

អាបត្តិ រមែងកើតដោយមកកាយ និងវាចា សូម្បីដល់ព្រះវីណាស្រេព ដែលមិនដឹងព្រះបញ្ញត្តិ ។

តើយ៉ាងណា ? ក៏បើថា មាតានឹងបិតារបស់ភិក្ខុនោះ វឹងក្រោធគ្នា ជាអ្នកលះលែងដាច់គ្នាហើយ ។ ក៏បិតារបស់ព្រះថេរៈនោះ និយាយចំពោះភិក្ខុនោះ ដែលមកកាន់ផ្ទះថា "នែកូន មាតារបស់លោកកូន ចោលញោមចាស់ជរាទៅកាន់ត្រកូលញាតិបាត់ហើយ, សូមលោកម្ចាស់ ទៅជម្រាបដំណឹងឱ្យមាតានោះ (ត្រឡប់មក) ដើម្បីប្រណិបត្តិញោមចុះ" ។ បើភិក្ខុនោះទៅនិយាយចំពោះមាតានោះ ហើយត្រឡប់មកប្រាប់ដំណឹងការមក ឬមិនមកនៃមាតានោះ ដល់បិតា ត្រូវអាបត្តិសង្ឃាទិសេស ។

សមុដ្ឋានទាំង ៣ នេះ ជាអចិត្តកសមុដ្ឋាន ។ តែកាលភិក្ខុជ្រាបព្រះបញ្ញត្តិហើយ សូម្បីធ្វើការដឹកនាំដោយន័យទាំង ៣ នេះឯង អាបត្តិរមែងកើតអំពីកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ។ សមុដ្ឋានទាំង ៣ នេះ ជាសចិត្តកសមុដ្ឋាន ដោយចិត្តដែលដឹងព្រះបញ្ញត្តិ ។ ជាកិរិយា នោសញ្ញាវិមោក្ខ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម និងក្នុងសិក្ខាបទនេះ មានចិត្ត ៣ ដោយអំណាចនៃកុសលចិត្តជាដើម មានវេទនា ៣ ដោយអំណាចនៃសុខវេទនាជាដើម ដូច្នេះឯង ។

## វិនីតវត្ថុក្នុងបញ្ចមសង្ឃាទិសេស

[១៩១] បណ្ដាវិនីតវត្ថុទាំងឡាយ ក្នុងរឿង ៥ ខាងដើម ត្រូវអាបត្តិទុក្កដ ដោយត្រឹមតែទទួល ។

[១៩២] ក្នុងរឿងឈ្លោះគ្នា មានវិនិច្ឆ័យដូច្នេះ ៖

បទថា សម្មោទនីយំ អកាសិ **: បាននិយាយផ្សះផ្សា** សេចក្ដីថា ឱ្យស្រីនោះយល់ព្រមហើយ បានធ្វើផ្ទះឱ្យជាស្ថានទីគួរត្រឡប់ទៅទៀត ។

បទថា នាលំវចនីយា **: មិនទាន់លែងដាច់ទេ** មានអត្ថថា មិនទាន់លះលែងគ្នា ។ ពិតមែន ស្រីណាដែលស្វាមីបោលហើយក្នុងជនបទណា ៗ ដោយប្រការណា ៗ រមែងផុតភាវៈជាភរិយា, ស្រីនេះលោកហៅថា អ្នកលះលែងគ្នា ។ តែស្រីនេះ មិនមែនជាអ្នកលែងលះគ្នា ។ នាងឈ្លោះគ្នាដោយហេតុណាមួយហើយចេញទៅ ។ ព្រោះហេតុនោះឯង ក្នុងរឿងឈ្លោះគ្នានេះ ទើបព្រះមានព្រះភាគត្រាស់ថា មិនជាអាបត្តិ ។ ក៏ព្រោះព្រះមានព្រះភាគពិន័យថុល្លច្ច័យ ក្នុងនាងយក្ខិណី ព្រោះកាយសំសគ្គៈ ; ដូច្នោះ សូម្បីក្នុងទុដ្ឋុល្លសិក្ខាបទជាដើមនេះ នាងយក្ខិណីនិងនាងប្រេត បណ្ឌិតគប្បីជ្រាបថា ជាវត្ថុនៃថុល្លច្ច័យដូចគ្នា ។ តែក្នុងអដ្ឋកថាទាំងឡាយ លោកមិនបានពិចារណាពាក្យនេះទុក ។ ពាក្យដ៏សេសគ្រប់រឿង មានអត្ថជាក់ច្បាស់ទាំងអស់នោះឯង ។

សញ្ចរិត្តសិក្ខាបទវណ្ណនា ចប់

# ៦. កុដិការសិក្ខាបទវណ្ណនា

[១៩៤] កុដិការសិក្ខាបទថា តេន សមយេន : សម័យនោះ ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងកុដិការសិក្ខាបទនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

## ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងភិក្ខុក្នុងដែនអាឡវី

បទថា អឡ្វីកា[1] : នៅក្នុងដែនអាឡវី មានសេចក្តីថា ពួកក្មេងប្រុសកើតក្នុងដែនអាឡវី ឈ្មោះថា អឡ្វីកា ។ ក្មេងកម្លោះទាំងនោះ សូម្បីក្នុងវេលាបួសហើយ ក៏ប្រាកដឈ្មោះថា អឡ្វិកា ដូចគ្នា ។ លោកពោលពាក្យថា អឡ្វិកា ភិក្ខូ : ពួកភិក្ខុនៅក្នុងដែនអាឡវី សំដៅយកភិក្ខុដែនអាឡវីទាំងអស់នោះ ។

បទថា សញ្ញាចិកាយោ : ដែលមានគ្រឿងឧបករណ៍ សូមពីគេមកខ្លួនឯង បានដល់ មានគ្រឿងឧបករណ៍ ដែលខ្លួនសូមគេយកមកដោយខ្លួនឯង ។

បទថា ការាបេន្តិ : ប្រើគេឱ្យសាង បានដល់ ធ្វើដោយខ្លួនឯងខ្លះ ប្រើឱ្យអ្នកដទៃធ្វើខ្លះ ។ បានឮថា ពួកភិក្ខុទាំងនោះ លះបោលធុរៈ

១. ថៃ. ភូមា. អឡ្វកា ។

ទាំងពីរ គឺ វិបស្សនាធុរៈ និងគន្ថធុរៈ លើកនវកម្មប៉ុណ្ណោះឡើងជាធុរៈសំខាន់ ។

បទថា **អស្សាមិកាយោ : ឥតមានទាយកជាម្ចាស់របស់** បានដល់ មិនមានអ្នកជាធំ, អធិប្បាយថា វៀរចាកអ្នកសាងប្រគេន ។

បទថា **អត្តុទ្ទេសិកាយោ : ចំពោះជាទីនៅរបស់ខ្លួន** បានដល់ ចំពោះខ្លួនឯង, អធិប្បាយថា ដែលភិក្ខុប្រារព្ធដើម្បីប្រយោជន៍ដល់ខ្លួន ។

បទថា **អប្បមាណិកាយោ : ធំហួសប្រមាណ** បានដល់ មិនមានប្រមាណកំណត់* ទុកយ៉ាងនេះថា នឹងដល់សេចក្ដីសម្រេចដោយគ្រឿងឧបករណ៍ត្រឹមតែប៉ុណ្ណេះ ឬពង្រីកទទឹងបណ្ដោយមិនមានប្រមាណ អធិប្បាយថា ធំមិនមានប្រមាណ ។

ភិក្ខុទាំងនេះ មានការសូមប៉ុណ្ណោះច្រើន ការងារដទៃមានតិច, ព្រោះហេតុនោះ ទើបឈ្មោះថា ជាអ្នកច្រើនទៅដោយការសូម ។ ពួកភិក្ខុទាំងនោះ ជាអ្នកច្រើនដោយការសូម ក៏គប្បីជ្រាបយ៉ាងនេះ ។ តែដោយសេចក្ដីក្នុងពីរបទថា **យាចនពហុលា វិញ្ញត្តិពហុលា : សូម**ញឹក ៗ ញយ ៗ នេះ មិនមានហេតុផ្សេងគ្នា ។ ពាក្យនោះ ជាឈ្មោះ

(១) ដីកាវិមតិនិងសារត្ថទីបនី ជា អប្បរិច្ឆិន្នប្បមាណាយោ ប្រែថា មិនបានកំណត់ប្រមាណទុក, ឬមិនមានកំណត់និងមិនមានប្រមាណ ។

របស់ពួកភិក្ខុដែលសូមច្រើនដងថា "លោកចូរឱ្យបុរស, ចូរឱ្យហត្ថកម្ម ដែលបុរសត្រូវធ្វើ (កម្លាំងការងារ)" ។ បណ្ដាបុរសនិងហត្ថកម្មនោះ ទឹងសូមបុរសដោយសេចក្ដីជាច់មូល មិនគួរ ។ ទឹងសូមថា "ពួកលោក ចូរឱ្យបុរសដើម្បីប្រយោជន៍ដល់ការរួមដៃ ដើម្បីប្រយោជន៍ដល់ការធ្វើការ ងារ" គួរ, ហត្ថកម្មដែលបុរស គប្បីធ្វើលោកហៅថា កម្លាំងការងារ, ទឹងសូមកម្លាំងការងារ គួរ ។

## ការចេញមាត់សូម

ដែលឈ្មោះថា ហត្ថកម្ម មិនមែនជាវត្ថុយ៉ាងណាមួយ, ព្រោះ ហេតុនោះ ហត្ថកម្មនោះ វៀរការងារជាចំណែករបស់ពួកព្រានម្រឹគ និង អ្នកប្រមង់(នេសាទ)ជាដើមចេញ ការងារដ៏សេសជាកប្បិយទាំង អស់ ។ កាលគេសួរថា "លោកម្ចាស់និមន្តមកមានហេតុដូចម្ដេច ? មាន ការងារដែលអ្នកណាទឹងត្រូវធ្វើឬ ?" ឬថា មិនសួរ ទឹងសូម ក៏គួរ ។ មិនមានទោស ព្រោះការសូមជាបច្ច័យ ។ ព្រោះហេតុនោះ ពួកព្រាន ម្រឹគជាដើម ភិក្ខុមិនគួរសូមកិច្ចការចំណែកផ្ទាល់ខ្លួនគេ, ទាំងដែលមិន បានកំណត់ឱ្យបានពិតប្រាកដ មិនគួរសូមថា "ពួកលោកចូរឱ្យ ហត្ថកម្ម" ។ ព្រោះពួកព្រានម្រឹគជាដើមនោះ ត្រូវភិក្ខុសូមយ៉ាងនេះ ហើយ ទឹងត្រូវទទួលពាក្យថា "បាន លោកម្ចាស់" ហើយនិមន្តភិក្ខុឱ្យ

ត្រឡប់ទៅ គប្បីសម្លាប់ម្រឹគមកប្រគេនបាន ។ តែគួរសូមកំណត់ឱ្យប្រាកដថា “ក្នុងវិហារមានកិច្ចការយ៉ាងណាមួយ ចាំបាច់ត្រូវធ្វើ, ពួកលោកចូរឱ្យហត្ថកម្មក្នុងវិហារនោះ” ។ ការដែលភិក្ខុនឹងសូមហត្ថកម្មយ៉ាងណាមួយចំពោះអ្នកស្រែ ឬអ្នកដទៃ សូម្បីអ្នកខ្វល់ខ្វាយក្នុងការងាររបស់ខ្លួន ដែលកាន់យកគ្រឿងឧបករណ៍ មានផាលនិងនង្គ័លជាដើម កំពុងដើរទៅដើម្បីភ្ជួរស្រែក្តី ដើម្បីព្រោះក្តី ដើម្បីច្រូតក្តី សមគួរពិត ។

ចំណែកអ្នកណា ជាអ្នកស៊ីដែល ឬជាមនុស្សមិនមានការងារអ្នកដទៃណាមួយ អ្នកជជែកគ្នាពីរឿងឥតប្រយោជន៍ ឬគិតតែពីខាងដេក, សូម្បីមិនសូមបុរសបែបនេះ នឹងពោលថា “នែ អ្នកឯងចូរមកធ្វើការងារនេះ ឬវត្ថុនេះ” ហើយឱ្យធ្វើការងារតាមដែលត្រូវការ គួរ ។ តែដើម្បីសម្តែងថា “ហត្ថកម្មជាកប្បិយគ្រប់យ៉ាង” អាចារ្យទាំងឡាយទើបពោលន័យនេះទុក ។

ក៏បើថា ភិក្ខុប្រាថ្នានឹងឱ្យសាងប្រាសាទ, គប្បីទៅកាន់ស្រុកនៃពួកជាងដាប់ថ្ម ដើម្បីត្រូវការសសរ ហើយពោលថា “ឧបាសក ការបានហត្ថកម្ម គួរ” ។ កាលគេសួរថា “គួរធ្វើយ៉ាងណា លោកម្ចាស់” គប្បីប្រាប់ថា “គប្បីសែងសសរថ្មទៅប្រគេន” ។ បើពួកគេសែងទៅប្រគេន ឬប្រគេនសសររបស់ខ្លួនដែលជញ្ជូនមករក្សាទុកហើយ គួរ ។ សូម្បីបើពួកគេពោលថា “ពួកខ្ញុំព្រះករុណាមិនមានពេលនឹងធ្វើហត្ថកម្ម លោក

ម្ចាស់, សូមលោកម្ចាស់ឱ្យអ្នកជទៃ ជញ្ជូនទៅចុះ, ពួកខ្ញុំព្រះករុណានឹងឱ្យតម្លៃឈ្នួលដល់គេ” ដូច្នេះ, នឹងប្រើឱ្យអ្នកជទៃជញ្ជូនទៅហើយប្រាប់ថា “ពួកលោកចូរឱ្យតម្លៃឈ្នួលដល់ពួកអ្នកជញ្ជូនសសរថ្មចុះ” ដូច្នេះ ក៏គួរ ។

ដោយឧបាយដូចគ្នានេះ ការដែលភិក្ខុនឹងទៅកាន់សំណាក់ពួកជាងសិល្បៈនោះ ៗ ដើម្បីប្រាថ្នាគ្រប់ ៗ វត្ថុដែលត្រូវការ គឺ ទៅកាន់សំណាក់ជាងឈើ ដើម្បីត្រូវការឈើសាងប្រាសាទទៅកាន់សំណាក់ជាងឥដ្ឋ ដើម្បីត្រូវការឥដ្ឋ ទៅកាន់សំណាក់ជាងប្រក់ដំបូលផ្ទះ ដើម្បីត្រូវការប្រក់ដំបូល ទៅកាន់សំណាក់ជាងគំនូរដើម្បីត្រូវការចិត្រកម្ម ហើយសូមហត្ថកម្ម សមគួរ ។ សូម្បីទទួលយករបស់ ដែលខ្លួនបានដោយអំណាចការសូមហត្ថកម្មក្ដី ដោយការបន្ថែមឱ្យតម្លៃឈ្នួល និងប្រាក់ខែ ដោយការដាច់មូលក្ដី សមគួរគ្រប់យ៉ាង កាលនឹងនាំរបស់មកពីព្រៃគួរឱ្យនាំរបស់ទាំងអស់ដែលអ្នកណាមួយ មិនបានឃុំគ្រង ( មិនហួងហែង ) មក ។

មួយទៀត មិនមែនតែប្រាថ្នានឹងសាងប្រាសាទតែម្យ៉ាង សូម្បីប្រាថ្នានឹងឱ្យធ្វើគ្រែ តាំង បាត្រ ធម្មក្រក និងចីវរជាដើម ក៏គប្បីឱ្យនាំមក, បានឈើ លោហៈ និងអំបោះជាដើមហើយ ចូលទៅរកពួកជាងសិប្បៈនោះ ៗ គប្បីសូមហត្ថកម្មដោយន័យដូចពោលទុំះឯង ។ ក៏វត្ថុសូម្បីដែលខ្លួនបានមកដោយអំណាចនៃការសូមហត្ថកម្មក្ដី ដោយការបន្ថែមឱ្យតម្លៃឈ្នួលនិងប្រាក់ខែ ដោយការដាច់មូលក្ដី គប្បីទទួលយក

ទាំងអស់ ។ ក៏បើពួកអ្នកការងារមិនប្រាថ្នានឹងធ្វើ, ចាំតែយកតម្លៃឈ្នួលនិងប្រាក់ខែ, របស់ជាអកប្បិយមានប្រាក់ជាដើម មិនគួរឱ្យ ។ នឹងស្វែងរកបាយជាដើម ដោយភិក្ខាចារវត្តឱ្យ គួរ ។

ភិក្ខុឱ្យជាងធ្វើបាត្រ ដោយអំណាចនៃហត្ថកម្មហើយ ឱ្យដុតទំនងតែមួយដូចគ្នានោះ ហើយចូលទៅកាន់ស្រុកដើម្បីត្រូវការប្រេងលាបបាត្រដែលដុតថ្មី កាលអ្នកស្រុកយល់ថា "មកដើម្បីភិក្ខា ហើយនាំបបរ ឬបាយមក (ប្រគេន)" គប្បីយកដៃបិទបាត្រ ។ បើឧបាសិកាសួរថា "ហេតុដូចម្ដេចលោកម្ចាស់" ភិក្ខុគប្បីប្រាប់ថា "បាត្រដុតថ្មី ត្រូវការនាំប្រេងសម្រាប់លាប" ។ បើឧបាសិកាពោលថា "សូមមេត្តាឱ្យបាត្រមកចុះលោកម្ចាស់" ហើយទទួលយកបាត្រទៅលាបប្រេង ដាក់បបរ ឬបាយឱ្យពេញ ហើយប្រគេន, មិនឈ្មោះថា ជាវិញ្ញត្តិ នឹងទទួល គួរ ដូច្នេះឯង ។

ពួកភិក្ខុត្រាច់ទៅបិណ្ឌបាត តាំងពីព្រឹកព្រហាម ទៅដល់បន្ទប់ឆាន់មិនឃើញទីអង្គុយ ឈរចាំ ។ បើទីបន្ទប់ដូច្នោះ ពួកឧបាសិកាឃើញពួកភិក្ខុឈរ ក៏នាំគ្នាយកអាសនៈមក ។ ពួកភិក្ខុដែលអង្គុយហើយ កាលនឹងទៅ គប្បីប្រាប់ជាមុនសិន សឹមទៅ ។ តែសូម្បីកាលពួកភិក្ខុមិនពោលលាជាមុនក៏ដោយ ហើយចេញទៅ បើមានរបស់បាត់ ក៏មិនជាសំណងដែរ ។ តែការប្រាប់លាហើយសឹមទៅ ជាទំនៀម ។

បើអាសនៈជារបស់អ្នកស្រុក ដែលភិក្ខុទាំងឡាយបង្គាប់ថា "ពួក

លោកចូរនាំអាសនៈមក” ទើបនាំមកឱ្យ; ភិក្ខុទាំងឡាយ ត្រូវតែប្រាប់លាហើយសឹមទៅ ។ កាលពួកភិក្ខុទៅមិនប្រាប់លា ជាការខូចទំនៀមនិងរបស់បាត់ ជាសំណាងផង ; សូម្បីក្នុងព្រំសម្រាប់ក្រាល ក៏មានន័យយ៉ាងនេះដែរ ។

វុយមានច្រើន[1] គប្បីពោលថា ចូរយកផ្ចិតបក់វុយមក ។ ពួកអ្នកស្រុកនាំមែកស្ពោជាដើមមកឱ្យ គប្បីឱ្យធ្វើកប្បិយសិន សឹមទទួល ។ ភាជន៍ទឹកក្នុងបន្ទប់ឆាន់មិនមានទឹក មិនគួរពោលថា “ចូរនាំធម្មក្រកមក” ។ ព្រោះកាលជ្រះធម្មក្រកចូលទៅក្នុងភាជនៈទទេ នឹងធ្វើភាជន៍បែក ។ តែនឹងទៅកាន់ទន្លេ ឬបឹង ហើយពោលថា ចូរនាំទឹកមក គួរ, នឹងពោលថា ចូរនាំមកពីផ្ទះ ក៏មិនគួរដែរ ។ កុំបរិភោគទឹកដែលគេនាំមកឱ្យ ។

ភិក្ខុទាំងឡាយដែលធ្វើភត្តកិច្ចឯបន្ទប់ឆាន់ ឬសេនាសនៈព្រៃគ្គីស្លឹកឈើ ឬផ្លែឈើដែលគួរស៊ីជាមួយនឹងឧត្តរិភង្គយ៉ាងណាមួយ ដែលមិនមានអ្នកហួងហែងកើតក្នុងទីនោះ បើពួកលោកនឹងឱ្យអ្នកធ្វើការងារយ៉ាងណាមួយនាំមក គួរ នឹងឱ្យនាំមកដោយអំណាចនៃហត្ថកម្មហើយឆាន់, តែមិនគួរប្រើពួកភិក្ខុ ឬ សាមណេរ ដែលជាអលជ្ជីឱ្យធ្វើហត្ថកម្ម, ក្នុងរឿងបុរិសត្ថករ (កម្លាំងការងារមនុស្ស) មានន័យប៉ុណ្ណោះសិន ។

(១) អត្ថយោជនា. មច្ឆិកាតិ មក្ខិកា. មក្ខិកាតិបិ អត្ថិ ។

តែការដែលភិក្ខុបង្គាប់ឱ្យគេនាំគោ មកពីស្ថានទីនៃជនមិនមែនជាញាតិ និងអ្នកមិនបានបវារណា រមែងមិនគួរ ។ ត្រូវអាបត្តិទុក្កដ ដល់ភិក្ខុដែលឱ្យនាំមក ។ នឹងសូមដោយដាច់មូលតម្លៃ សូម្បីអំពីស្ថានទីនៃញាតិនិងអ្នកបវារណា ក៏មិនគួរ ។ នឹងសូមដោយន័យ ជារបស់ខ្ចី គួរក្នុងទីទាំងពួង ។ និងគប្បីរក្សាថែទាំគោដែលឱ្យនាំមកហើយយ៉ាងនេះ រួចស្រេចហើយ គប្បីប្រគល់ឱ្យម្ចាស់របស់វាយកទៅវិញ ។ បើជើង ឬស្នែងរបស់វាបាក់ ឬខូចទៅ, បើម្ចាស់របស់ព្រមយកវាទៅវិញ, ការព្រមទទួលនោះ ជាការល្អ, បើម្ចាស់របស់មិនព្រមទទួលទេ, ជាសំណង ។ ប្រសិនបើម្ចាស់របស់ពោលថា "ពួកខ្ញុំព្រះករុណា ប្រគេនលោកម្ចាស់ចុះ" មិនគួរទទួល ។ តែកាលម្ចាស់របស់វាពោលថា "ពួកខ្ញុំព្រះករុណាថ្វាយវត្ត" គប្បីពោលថា "ពួកលោកចូរប្រាប់ដល់បុគ្គលអ្នកធ្វើការផាវត្ត ដើម្បីប្រយោជន៍ដល់ ការចិញ្ចឹមវា" ។ នឹងពោលជាមួយពួកជន មិនមែនញាតិ និងមិនបានបវារណាថា "ពួកលោកចូរប្រគេនរទេះ" ដូច្នេះក្តី មិនគួរ ។ រមែងជាវិញ្ញត្តិពិត គឺ ត្រូវអាបត្តិទុក្កដ ។ តែក្នុងឋានៈនៃញាតិនិងអ្នកបវារណា គួរ ។ ជារបស់ខ្ចី ក៏គួរ, ធ្វើការផារ សម្រេចហើយគប្បីសងវិញ ។ បើកង់ជាដើមបែកបាក់ទៅ គប្បីធ្វើឱ្យដូចដើមហើយសងវិញ ។ កាលវិនាសអស់ ជាសំណង ។ កាលម្ចាស់របស់ពោលថា "ពួកខ្ញុំព្រះករុណា ប្រគេនលោកម្ចាស់ចុះ" ធម្មតាគ្រឿងឈើ

គួរទទួលទុកបាន ។ ក្នុងកាំបិត ពូថៅ ដឹង ចប និងពន្លាកក្តី ក្នុងរុក្ខជាតិ មានវល្លិជាដើមក្តី ដែលមានម្ចាស់ហួងហែង ក៏មានន័យដូចគ្នានេះ ។ ក៏ក្នុងពួករុក្ខជាតិ មានវល្លិជាដើម ដែលល្មមជាគរុភណ្ឌបានប៉ុណ្ណោះ ទើបជាវិញ្ញត្តិ ទាបជាងនោះ មិនជាវិញ្ញត្តិទេ ។

តែភិក្ខុនឹងឱ្យនាំយកវត្ថុណាមួយ ដែលមិនមានអ្នកហួងហែងមកគួរ ។ ព្រោះថា ក្នុងទីមានអ្នករក្សាឃុំគ្រងប៉ុណ្ណោះ លោកហៅថាវិញ្ញត្តិ ។ វិញ្ញត្តិនោះ រមែងមិនគួរក្នុងបច្ច័យទាំងពីរ (គឺ ចីវរ និងបិណ្ឌបាត) ដោយប្រការទាំងពួង ។ តែក្នុងសេនាសនប្បច្ច័យ ត្រឹមតែចេញមាត់សូមថា "លោកចូរនាំមក ចូរឱ្យប៉ុណ្ណោះ" មិនគួរ ។ បរិកថា ឱភាស និងនិមិត្តកម្ម គួរ ។

បណ្តាបរិកថា ឱភាស និងនិមិត្តកម្មនោះ ពាក្យនិយាយរបស់ភិក្ខុដែលត្រូវការរោងឧបោសថ បន្ទប់ឆាន់ ឬសេនាសនៈដទៃ ៗ ដោយន័យជាដើមថា ការសាងសេនាសនៈបែបនេះក្នុងឱកាសនេះ គួរហ្ន៎ ឬថាប្រពៃហ្ន៎ ឬសមគួរហ្ន៎ ដូច្នេះ ឈ្មោះថា បរិកថា ។ ភិក្ខុសួរថា "ឧបាសក ពួកលោកនៅទីណា ?" ពួកឧបាសកឆ្លើយថា "នៅឯប្រាសាទលោកម្ចាស់" និយាយតទៅថា "ក៏ប្រាសាទមិនគួរដល់ភិក្ខុទាំងឡាយ ឬឧបាសក" ពាក្យនិយាយមានជាដើមយ៉ាងនេះ ឈ្មោះថា ឱភាស ។ ក៏ការធ្វើមានជាដើមយ៉ាងនេះ គឺ ភិក្ខុឃើញពួកអ្នកស្រុកហើយរឹតបន្តឹងខ្សែ

ឱ្យបោះបង្គោល កាលពួកអ្នកស្រុកសួរថា "លោកម្ចាស់ នេះឱ្យធ្វើអ្វីហ្នឹង ?" ឆ្លើយថា "ពួកអាត្មានឹងសាងទីនៅអាស្រ័យក្នុងទីនេះ" ឈ្មោះថា និមិត្តកម្ម ។ ចំណែកក្នុងគិលានបច្ច័យ សូម្បីវិញ្ញត្តិ ក៏គួរ ចាំបាច់ពោលទៅថ្វីដល់បរិកថាជាដើមនោះ ។

ពាក្យថា មនុស្សា ឧបទ្ទុតា យាចនាយ ឧបទ្ទុតា វិញ្ញត្តិយា : ពួកមនុស្សដែលភិក្ខុទាំងនោះ ចេះតែបៀតបៀនដោយការសូមញឹកញយហួសពេក មានសេចក្តីថា ពួកអ្នកស្រុកត្រូវបៀតបៀនដោយការសូម និងដោយការចេញមាត់សូមវត្ថុនោះ ៗ របស់ភិក្ខុទាំងអស់នោះ ។

បទថា ឧព្ពិជ្ជន្តិបិ : ភ្ញាក់ផ្អើលខ្លះ មានសេចក្តីថា រមែងបានទទួលសេចក្តីភ័យតក់ស្លុត គឺភ័យញ័ររន្ធត់ទៅថា "ពួកភិក្ខុនឹងឱ្យនាំអ្វីទៅហ្ន៎"

បទថា ឧត្តសន្តិបិ : តក់ស្លុតខ្លះ មានសេចក្តីថា ជួបភិក្ខុដែលចូលមក ភ្លាមនោះ ក៏ភ័យតក់ស្លុតទៅ ដូចជួបពស់ដូច្នោះ ។

បទថា បលាយន្តិបិ : លបរត់ទៅខ្លះ មានសេចក្តីថា រមែងចៀសចេញទៅក្នុងទីឆ្ងាយ ដោយមកណាមួយ ។

ពីរបទថា អញ្ញេនបិ គច្ឆន្តិ : គេចទៅទីដទៃ មានសេចក្តីថា លះមកដែលភិក្ខុដើរចេញទៅ ហើយត្រឡប់ដើរដោយបំណាងទៅមកឆ្វេងឬមកស្តាំ, បិទទ្វារវិញខ្លះ ក៏មាន ។

# ពន្យល់អត្ថក្នុងសំពួនៃរឿងមណិកណ្ឋនាគរាជ

[១៩៧] ពីរបទថា ភូតបុព្វំ ភិក្ខវេ : **ម្នាលភិក្ខុទាំងឡាយ ក្នុងកាលពីដើម** ជាដើម មានសេចក្តីថា លុះព្រះមានព្រះភាគទ្រង់តិះដៀលភិក្ខុទាំងនោះ ដោយប្រការដូច្នេះ និងត្រាស់ធម្មីកថា ឱ្យសមគួរដល់រឿងរ៉ាវនោះ ហើយកាលទឹងទ្រង់ធ្វើទោសនៃវិញ្ញត្តិ ឱ្យប្រាកដច្បាស់ទៀត ទើបទ្រង់សម្តែង ៣ រឿងនេះ ដោយន័យជាដើមថា ភូតបុព្វំ ភិក្ខវេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា មណិកណ្ឋោ : **ឈ្មោះមណិកណ្ឋ** មានសេចក្តីថា បានឮថា ស្តេចនាគនោះប្រដាប់កែវមណីមានតម្លៃច្រើន ដែលផ្តល់ឱ្យនូវវត្ថុបំណងគ្រប់យ៉ាងទុកត្រង់-ក ត្រាច់ទៅ ; ព្រោះដូច្នោះ ទើបប្រាកដនាមថា មណិកណ្ឋនាគរាជ ។

ពាក្យថា ឧបរិ មុទ្ធនិ មហន្តំ ផណំ ករិត្វា អដ្ឋាសិ : **ហើយបើកពពារដ៏ធំបាំងពីខាងលើសីសៈនៃឥសីប្អូននោះ** មានសេចក្តីថា បានឮថា បណ្តាឥសីទាំង ២ នោះ ឥសីប្អូននោះ មានប្រក្រតីនៅដោយមេត្តា ; ព្រោះហេតុនោះ ស្តេចនាគនោះ ទើបឡើងមកពីទន្លេ និម្មិតភេទជាទេវតា អង្គុយក្នុងសំណាក់នៃឥសីនោះ ពោលសម្មោទនីកថា លះភេទទេវតានោះហើយ ត្រឡប់ក្លាយជាភេទពីដើមរបស់ខ្លួនទន្ទុះឯង ព័ទ្ធវង់ជុំវិញ

ឥសីនោះ កាលនឹងធ្វើអាការជ្រះថ្លា ទើបបើកពពារយ៉ាងធំខាងលើក្បាល នៃឥសីនោះ ដូចបាំងឆត្រទុក នៅមួយស្របក់ហើយ ទើបចៀសចេញទៅ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា “ហើយបើពពារដ៏ធំបាំងពីខាងលើសីសៈនៃឥសីប្អូននោះ” ដូច្នេះ ។

ពាក្យថា មណិមស្ស កណ្ឋេ បិលន្ធំ : កែវមណីជាគ្រឿងប្រដាប់ព្ធដ៏ក មានសេចក្ដីថា កែវមណីដែលស្ដេចនាគនោះប្រដាប់ទុក គឺពាក់ទុកត្រង់ក ។

ពីរបទថា ឯកមន្តំ អដ្ឋាសិ : ក៏ស្ថិតនៅក្នុងទីដ៏សមគួរមួយ មានសេចក្ដីថា ស្ដេចនាគនោះមកហើយ ដោយភេទជាទេវតានោះ ពោលសរសើរនៅទីងតាបស បានឈរក្នុងប្រទេសមួយ ។

បទថា មមន្នបានំ : បាយទឹករបស់ខ្ញុំ បានដល់ បាយផង ទឹកផង របស់យើង ។

បទថា វិបុលំ : ជាច្រើន បានដល់ ច្រើនណាស់ ។

បទថា ឧឡារំ : ដ៏ផ្ចិតផ្ចង់ បានដល់ ប្រណីត ។

បទថា អតិយាចកោសិ : លោកជាអ្នកសូមសូមហួសពេក បានដល់ ជាអ្នកសូមច្រើនហួសប្រមាណ ។ មានពាក្យអធិប្បាយថា លោកជាអ្នកសូមដដែល ៗ ។ បទថា សុស្វ : មនុស្សក្រមោះ មាន

សេចក្តីថា ក្មេងកម្លោះ គឺ មនុស្សសម្បូរណ៌ដោយកម្លាំង បានដល់បុរសដែលនៅក្នុងវ័យកម្លោះ ។

ថ្មខ្មៅ លោកហៅថា ថ្មសំលៀង, ដាវដែលគេសំលៀងហើយលើថ្មសំលៀងនោះ លោកហៅថា **សត្ថរធោត** : ដែលមានដាវសំលៀងដោយថ្មខ្មៅក្នុងដៃ ។ ដាវដែលសំលៀងល្អហើយលើថ្មសំលៀង មាននៅក្នុងដៃរបស់បុរសនោះ ; ព្រោះហេតុនោះ បុរសនោះ ទើបឈ្មោះថា អ្នកកាន់ដាវដែលសំលៀងល្អហើយលើថ្មសំលៀង, អធិប្បាយថា មានដៃកាន់ដាវដែលខាត់និងសំលៀងល្អហើយលើថ្ម ។ លោកអង្វរសូមកែវនឹងយើង ធ្វើឱ្យយើងភ័យខ្លាច ដូចបុរសមានដាវក្នុងដៃនោះ ធ្វើឱ្យអ្នកដទៃភ័យខ្លាចដូច្នោះ ។

ពាក្យថា **មំ សេលមយាចមានោ**[1] : លោកសូមកែវមណីនឹងខ្ញុំ មានសេចក្តីថា តែងអង្វរសូមនូវកែវមណី ។

ពាក្យថា **ន តំ យាចេ** : មិនគួរសូមរបស់នោះអំពីគេ មានសេចក្តីថា មិនគួរសូមរបស់នោះ ។

សួរថា វត្ថុណា ?

ឆ្លើយថា វត្ថុដែលខ្លួនដឹងថា ជាទីស្រឡាញ់របស់គេ ។

---

១. ថៃ. សេលំ មំ យាចមានោ ; ភូមា. តាសេសិ មំ សេលំ យាចមានោ ។

ពាក្យថា យស្ស បិយំ ជិគីសេ : បុគ្គលដឹងថា របស់ណាជាទីស្រឡាញ់របស់គេ មានសេចក្តីថា ខ្ញនគប្បីដឹងថា វត្ថុណាជាទីស្រឡាញ់របស់សត្វនោះ (មិនគួរសូមរបស់នោះ)

ពាក្យថា កិមង្គំ បន មនុស្សភូតានំ : នឹងបាច់ពោលទៅថ្វីដល់មនុស្ស មានសេចក្តីថា ក្នុងពាក្យថា (ការអង្វរសូមនោះ) មិនជាទីពេញចិត្តរបស់ពួកសត្វទៅហើយ ចំណែកឯមនុស្សវិញ នឹងចាំបាច់ពោលទៅថ្វីដល់ការអង្វរសូមនេះ ។

## ពន្យល់អត្ថក្នុងសព្ទនៃរឿងសត្វមួយហ្វូងធំ

[១៩៨] ប្រើនបទថា សកុណសង្ឃស្ស សទ្ទេន ឧព្វាឡ្ហោ : ធុញទ្រាន់អផ្សុកដោយសំឡេងនៃហ្វូងសត្វស្លាប មានសេចក្តីថា បានឮថា ហ្វូងបក្សីនោះ ធ្វើសំឡេងឮទ្រហឹងអ៊ឹងកង ជាប់តគ្នាទៅរហូតដល់អស់បឋមយាម និងបច្ឆិមយាម, ភិក្ខុនោះ ជាអ្នកអផ្សុកហើយដោយសំឡេងបក្សីនោះ ទើបបានទៅកាន់សំណាក់របស់ព្រះមានព្រះភាគ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ក៏ចូលមករកតថាគតដល់ទីនៅ" ។

ក្នុងពាក្យថា កុតោ ច ត្វំ ភិក្ខុ អាគច្ឆសិ : ម្នាលភិក្ខុ ចុះ

អ្នកមកពីទីណា នេះ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុនោះអង្គុយនៅហើយ (ក្នុងសំណាក់នៃព្រះមានព្រះភាគនេះ) មិនមែនកំពុងមក, តែការដែលនឹងពោលយ៉ាងនេះ ក្នុងអតីតកាលជិតបច្ចុប្បន្ន រមែងមានបាន ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុ ចុះអ្នកមកពីទីណា" អធិប្បាយថា លោកជាអ្នកមកហើយអំពីទីកន្លែងណា ? ។

សូម្បីក្នុងពាក្យថា តតោ អហំ ភគវា អាគច្ឆាមិ : បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គបានជាមកអំពីទីនោះ នេះ ក៏មានន័យយ៉ាងនោះដូចគ្នា ។

បទថា ឧព្វាឡ្ហោ : ព្រោះសេចក្តីអផ្សុក មានសេចក្តីថា ជាអ្នកត្រូវសំឡេងបៀតបៀនហើយ គឺ បង្កឱ្យកើតសេចក្តីរំខាន ។

ក្នុងពាក្យថា សោ សកុណសង្ឃោ ភិក្ខុ បត្តំ យាចតិ : ហ្វូងបក្សីនោះ ក៏គិតគ្នាថា ភិក្ខុចេះតែសូមស្លាប នេះ មានវិនិច្ឆ័យដូច្នេះ ៖

ហ្វូងសត្វ រមែងមិនដឹងពាក្យនិយាយរបស់ភិក្ខុ, តែព្រះមានព្រះភាគ ទ្រង់ធ្វើឱ្យវាដឹងដោយអានុភាពរបស់ព្រះអង្គ ។

## ពន្យល់អត្ថក្នុងសំព្ទនៃរឿងបិតារបស់រដ្ឋបាល

[១៩៩] ពាក្យថា អថាហន្តេ ន ជានាមិ : តែញោមមិនស្គាល់ជនទាំងនោះឡើយ មានសេចក្តីថា អើ យើងក៏មិនស្គាល់ជនទាំងនោះថា ជនទាំងនេះ ជាមនុស្សពួកណា ឬថា ជនទាំងនេះ ជាមនុស្សរបស់អ្នកណា ។

ពីរបទថា សម្ភម្ម យាចន្តិ : រមែងចូលមកបោមសូម មានសេចក្តីថា ជនទាំងនោះ នាំគ្នាមក គឺរួមគ្នាជាពួក ៗ មកសូម ។

ពាក្យថា យាចកោ អប្បិយោ ហោតិ : អ្នកស្ទូរសូមរមែងមិនជាទីស្រឡាញ់ មានសេចក្តីថា បុគ្គលជាអ្នកស្ទូរសូម រមែងមិនជាទីស្រឡាញ់ ( របស់អ្នកឱ្យ ) ។

ពាក្យថា យាចំ អទទមប្បិយោ : អ្នកមិនឱ្យរបស់ដែលគេសូម ក៏មិនជាទីស្រឡាញ់របស់អ្នកសូម មានសេចក្តីថា វត្ថុដែលអ្នកដទៃសូម លោកហៅថា យាចំ ។ សូម្បីអ្នកមិនឱ្យនូវប្រយោជន៍ដែលគេសូម រមែងមិនជាទីស្រឡាញ់ ( របស់អ្នកសូម ) ។

ម្យ៉ាងទៀត បទថា យាចំ : របស់ដែលគេសូម បានដល់របស់បុគ្គលអ្នកសូមនោះ ។

ពាក្យថា អទទមប្បិយោ : អ្នកមិនឱ្យ ក៏មិនជាទីស្រឡាញ់

របស់អ្នកសូម មានសេចក្តីថា អ្នកមិនឱ្យ(ដល់អ្នកសូម) រមែងមិនជាទីស្រឡាញ់ (របស់អ្នកសូម) ។

ពាក្យថា មា មេ វិទ្ទេសណា អហុ : ដោយគិតថា មិនឱ្យជាទីស្អប់ខ្ពើមដល់ខ្ញុំ មានសេចក្តីថា ភាពជាអ្នកមិនជាទីស្រឡាញ់ កុំបីមានដល់អាត្មា, អធិប្បាយថា អាត្មាកុំបានជាទីស្អប់ខ្ពើម គឺ មិនជាទីស្រឡាញ់របស់លោក ឬថា លោកបានជាទីស្អប់ខ្ពើម គឺ មិនជាទីស្រឡាញ់របស់អាត្មា ។

[២០០] បទថា ទុស្សំហារានិ : សន្សំរកបានដោយកម្រ សេចក្តីថា រួបរួមមកបានដោយលំបាក ដោយឧបាយទាំងឡាយ មានកសិកម្មនិងគោរក្ខកម្មជាដើម ។ ការសូម ដែលភិក្ខុឱ្យប្រព្រឹត្តទៅដោយខ្លួនឯង លោកហៅថា សំយាចិកា ក្នុងពាក្យថា សញ្ញាចិកាយ បទ ភិក្ខុនា : ភិក្ខុកាលឱ្យគេធ្វើកុដិ នេះ ។ ព្រោះហេតុនោះ បទថា សញ្ញាចិកាយ ទើបមានរូបសេចក្តីដែលលោកពោលទុកថា "ដោយការសូមរបស់ខ្លួន" ។ អធិប្បាយថា ដោយឧបករណ៍ទាំងឡាយដែលខ្លួនសូមមកដោយខ្លួនឯង ។ ពីព្រោះថា កុដិនោះ ឈ្មោះថា ភិក្ខុធ្វើដោយគ្រឿងឧបករណ៍ដែលខ្លួនសូមមកដោយខ្លួនឯង គឺសូមយកមកធ្វើដោយខ្លួនឯង; ដូច្នោះ ដើម្បីសម្តែងបរិយាយនៃអត្ថនោះ លោកទើបពោលបទភាជនៈនៃបទថា សញ្ញាចិកាយ នោះយ៉ាងនេះថា "សូមបុរសដោយខ្លួនឯងក្តី"ជាដើម ។

## ពន្យល់អត្ថក្នុងសិក្ខាបទវិភង្គ ការបូកលាបកុដិ

[២០១] បទថា ឧល្លិត្តា : កុដិដែលលាបខាងក្នុងបានដល់ បូកលាបកំបោរទុកខាងក្នុង ។

បទថា អវលិត្តា : កុដិដែលលាបខាងក្រៅ បានដល់ បូកលាបកំបោរទុកខាងក្រៅ ។

បទថា ឧល្លិត្តាវលិត្តា : កុដិដែលលាបទាំងខាងក្នុងទាំងខាងក្រៅ មានពាក្យអធិប្បាយថា បូកលាបកំបោរទុកទាំងខាងក្នុងទាំងខាងក្រៅ ។

ក្នុងបទភាជនៈនៃបទថា ការយមានេន : កាលឱ្យគេធ្វើ នេះពាក្យត្រឹមតែថា ការាបេន្តេន នេះប៉ុណ្ណោះ ជាពាក្យដែលព្រះឧបាលីពោលទុក ព្រោះថា កាលមានពាក្យយ៉ាងនេះ ព្យញ្ជនៈ រមែងស្មើគ្នា, តែព្រោះហេតុដែលភិក្ខុសូម្បីឱ្យសាងកុដិ ដោយអាការសូមយកដោយខ្លួនឯង គប្បីបដិបត្តិដោយន័យដូចពោលហើយ ក្នុងសិក្ខាបទនេះនុ៎ះឯង, ដូច្នោះដើម្បីសម្តែងអត្ថនេះថា ភិក្ខុដែលសាងដោយខ្លួនឯងក៏ដោយ ឱ្យអ្នកដទៃសាងក៏ដោយ ទាំងពីរពួកនេះសង្គ្រោះដោយបទថា ការយមានេន នេះឯង ទើបពោលថា ករោន្តោ វា ការាបេន្តោ វា : ធ្វើខ្លួនឯងក្តី ឱ្យគេធ្វើក្តី ដូច្នេះជាដើម ។ ក៏បើថា ព្រះឧបាលីនឹងពោលថា ករោន្តេន វា ការាបេន្តេន វា ព្យញ្ជនៈនឹងត្រូវខុសទៅ ។ ព្រោះថា

ភិក្ខុប្រើឱ្យគេធ្វើ មិនបានឈ្មោះថា ជាអ្នកធ្វើដោយខ្លួនឯងទេ ។ ព្រោះដូច្នោះ គប្បីជ្រាបថា ក្នុងបទភាជនៈនេះ ព្រះឧបាលីសម្ដែងត្រឹមតែសេចក្ដីប៉ុណ្ណោះ ។

បទថា អត្តុទ្ទេសំ : ចំពោះជាទីនៅនៃខ្លួន មានសេចក្ដីថា ខ្លួនជាទីចំពោះនៃកុដិនោះយ៉ាងនេះថា កុដិនេះរបស់យើង ព្រោះដូច្នោះ កុដិនោះទើបឈ្មោះថា ចំពោះខ្លួនឯង ។ កុដិដែលចំពោះខ្លួនឯងនោះ ក៏ព្រោះកុដិចំពោះខ្លួននោះ រមែងមានដើម្បីប្រយោជន៍ដល់ខ្លួន ; ដូច្នោះ ព្រះឧបាលីកាលនឹងសម្ដែងបរិយាយនៃអត្ថនោះ ទើបពោលថា បទថា អត្តុទ្ទេសំ គឺ ដើម្បីប្រយោជន៍ដល់ខ្លួន ។

ពីរបទថា បមាណិកា ការេតព្វា : គប្បីធ្វើឱ្យប្រកបដោយប្រមាណ គឺ គប្បីសាងឱ្យបានប្រមាណ ។

ពីរបទថា តត្រិទំ បមាណំ : ប្រមាណនោះ គឺ ប្រមាណនៃកុដិនោះ ។

បទថា សុគតវិទត្ថិយា : ដោយចំអាមព្រះសុគត មានសេចក្ដីថា ដែលមានឈ្មោះថា មួយចំអាមព្រះសុគត គឺ ៣ ចំអាមរបស់មជ្ឈិមបុរស ក្នុងបច្ចុប្បន្ននេះ ស្មើនឹង ១ ហត្ថ ១ ចំអាម ដោយហត្ថជាងឈើ ។

ពីរបទថា **ពាហិរិមេន មានេន : វាស់តាមទីដែលជាខាងក្រៅ** បានដល់ ១២ ចំអាម ដោយវាស់ក្រៅជញ្ជាំងផ្ទះនៃកុដិ ។ តែកាលនឹងវាស់ មិនគប្បីកំណត់យកទីបំផុតដុំដីស្អិតធំដែលខ្ទង់ឱ្យតាំងទុកពីជំបូងបង្អស់ ។ គប្បីវាស់ដោយទីបំផុតដុំដីលាយអង្កាម (ដុំឥដ្ឋ) ។ ការលាបកំបោរសខាងលើនៃដុំដីលាយអង្កាម ជាអព្វោហារិក ។ បើភិក្ខុមិនមានសេចក្តីត្រូវការដោយដុំដីលាយអង្កាម សាងឱ្យសម្រេចដោយដុំដីស្អិតធំប៉ុណ្ណោះ, ដីស្អិតធំនុ៎ះឯង ជាខេត្តកំណត់ ។

បទថា **តិរិយំ : ទទឹង** គឺ ដោយចំណែកទូលាយ ។

បទថា **សត្ត : ៧ ចំអាម** គឺ ៧ ចំអាមព្រះសុគត ។

បទថា **អន្តរា : ខាងក្នុងនេះ** មាននិទ្ទេសដូច្នេះ ៖

គឺ ដោយការវាស់ទីផ្ទៃខាងក្នុងមានអធិប្បាយថា មិនកាន់យកទីបំផុតខាងក្រៅជញ្ជាំង វាស់យកទីបំផុត គឺវាស់ចំត្រង់ជ្រុងជញ្ជាំងផ្ទៃខាងក្នុងឱ្យបានផ្ទៃកទទឹងប្រវែង ៧ ចំអាមព្រះសុគត ។

ចំណែកភិក្ខុណាអាងលេសថា យើងនឹងធ្វើឱ្យបានប្រមាណ តាមដែលត្រាស់ទុកពិត ៗ តែគប្បីធ្វើប្រមាណផ្ទៃកបណ្តោយ ១១ ចំអាម ផ្ទៃកទទឹង ៨ ចំអាម ឬប្រមាណផ្ទៃកបណ្តោយ ១៣ ចំអាម ផ្ទៃកទទឹង ៦ ចំអាម ។ ការធ្វើនោះមិនសមគួរដល់ភិក្ខុនោះ ។ ពិតមែន ប្រមាណ

សុប្បីដែលហួសទៅតែម្ខាង ក៏ចាត់ថា ហួសទៅដូចគ្នា ។ ចំអាមចូរលើកទុក ទឹងបន្ទយផ្នែកបណ្ដោយ បន្ថែមផ្នែកទទឹង ឬបន្ថយផ្នែកទទឹងបន្ថែមផ្នែកបណ្ដោយ សុប្បីត្រឹមតែមួយចុងសរសៃសក់ ក៏មិនគួរ ។ ទឹងបាច់ពោលទៅថ្វីក្នុងការពង្រីកបន្ថែមទាំងពីរផ្នែកហ្ន៎ ។

សមពិត ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា "ភិក្ខុធ្វើខ្លួនឯងក្ដី ប្រើគេឱ្យធ្វើក្ដី (នូវកុដិ) ឱ្យកន្លងហួសប្រមាណ ដោយបណ្ដោយក្ដី ដោយទទឹងក្ដី សុប្បីប្រមាណប៉ុនចុងសក់ ត្រូវអាបត្តិទុក្កដរាល់ប្រយោគ"[១] ដូច្នេះជាដើម ។ ក៏កុដិមានប្រមាណតាមដែលពោលទុកប៉ុណ្ណោះ ទើបសមគួរ ។

ចំណែកកុដិណា ផ្នែកបណ្ដោយមានប្រមាណដល់ ៦០ ហត្ថ ផ្នែកទទឹងមានប្រមាណ ៣ ហត្ថ ឬខ្វះ ៣ ហត្ថ ជាទីដែលគ្រែបានខ្ទាតបង្វិលបែរទៅខាងនេះ ខាងឯណោះមិនបាន, កុដិនេះមិនដល់ការរាប់ថាកុដិ, ព្រោះដូច្នោះ សុប្បីកុដិនេះ ក៏សមគួរ ; តែក្នុងមហាបច្ចរីលោកពោលកុដិទទឹង ៤ ហត្ថទុកដោយកំណត់យ៉ាងខ្ពី ។ ខ្ពីជាងកុដិទទឹង ៤ ហត្ថនោះ មិនចាត់ថា ជាកុដិ ; ក៏កុដិសុប្បីត្រូវប្រមាណ តែសង្ឃនៅមិនទាន់បានសម្ដែងទីឱ្យក្ដី មានអន្តរាយក្ដី មិនមានឧបចារដើរដោយជុំវិញ

---

១. វិន. សង្ឃា. កុដិការ. ២. ២០៨/២០០ ។

ក្តី មិនគួរ ។ កុដិបានប្រមាណ សង្ឃសម្តែងទីឱ្យហើយ មិនមានអន្តរាយ មានឧបចារដើរបានជុំវិញ ទើបគួរ ។

ភិក្ខុកាលសាងកុដិទាប(ខ្លី)ជាងប្រមាណក្តី កុដិមានប្រមាណ ៤-៥ ហត្ថក្តី គប្បីសាងកុដិក្នុងកន្លែងដែលសង្ឃសម្តែងទីឱ្យហើយប៉ុណ្ណោះ ។ ក៏ឯកាលភិក្ខុធ្វើឱ្យកន្លងហួសប្រមាណទៅ ត្រូវគរុកាបត្តិក្នុងវេលាលាបរួច ។ ក្នុងអធិការនៃការសាងកុដិ ឱ្យកន្លងហួសប្រមាណនោះ អ្នកសិក្សាគប្បីជ្រាបការលាប, ការមិនលាប, ឱកាសគួរលាប, និងឱកាសមិនគួរលាប ។

គឺ យ៉ាងណា ? គឺ ដែលឈ្មោះថា ការលាបនោះ បានដល់ ការលាប ២ យ៉ាងគឺ ការលាបដោយដីស្អិត ១ ការលាបដោយកំបោរស ១ ក៏វៀរលែងតែការលាប ២ យ៉ាងនេះចេញ ការលាបដ៏សេស មានប្រភេទលាបដោយផេះ និង អាចម៍គោជាដើមមិនចាត់ជាការលាប ។ បើសូម្បីមានការលាបដោយភក់ ក៏មិនចាត់ជាការលាបដែរ ។

ដែលឈ្មោះថា ឱកាសគួរលាបនោះ បានដល់ ជញ្ជាំងផ្ទៃ និងដំបូល ។ ក៏ឱកាសមិនគួរលាបដ៏សេស វៀរលែងតែជញ្ជាំងនិងដំបូលចេញ មានសសរ ធ្នឹម ទ្វារ បង្អួច និងបំពង់ផ្សែងជាដើម សូម្បីទាំងអស់ គប្បីជ្រាបថា ឱកាសមិនគួរលាប ។

# ផ្ទៃដីគួរសាងកុដិនិងមិនគួរសាង

[២០២] ពាក្យថា ភិក្ខូ អភិនេតព្វា វត្ថុទេសនាយ : ត្រូវនាំពួកភិក្ខុមកដើម្បីសម្តែងទីឱ្យ មានសេចក្តីថា ភិក្ខុដែលបំណងនឹងសាងកុដិ គប្បីនាំភិក្ខុទាំងឡាយទៅ ដើម្បីប្រយោជន៍ដល់ការសម្តែងទីឱ្យក្នុងទីដែលខ្លួនត្រូវការនឹងឱ្យសាងកុដិ ។

ក៏ពាក្យថា តេន កុដិការកេន : រូបភិក្ខុអ្នកធ្វើកុដិនោះ ជាដើម ព្រះមានព្រះភាគត្រាស់ទុក ដើម្បីទ្រង់សម្តែងវិធីដែលនឹងនាំភិក្ខុទាំងនោះទៅ ដើម្បីសម្តែងទីសាង ។

បណ្តាបទទាំងនោះបទថា កុដិវត្ថុំ សោធេត្វា : ត្រូវជម្រះទីកុដិ ព្រះមានព្រះភាគទ្រង់សម្តែងថា ភិក្ខុដែលសាងកុដិ កុំគប្បីនាំភិក្ខុទាំងឡាយទៅកាន់ព្រៃមានផែនដីដែលមិនស្មើ គប្បីឱ្យជម្រះទីសាងកុដិជាមុន ពង្រាបផ្ទៃដីឱ្យរាបស្មើដូចមណ្ឌលសីមាហើយ ខាងក្រោយមកចូលទៅរកសង្ឃ សូមហើយទើបនាំទៅ ។

ពីរបទថា ឯវមស្ស វចនីយោ : ពោលពាក្យយ៉ាងនេះ មានសេចក្តីថា សង្ឃគួរជាអ្នកដែលភិក្ខុនោះ គប្បីប្រាប់យ៉ាងនេះ, តែខាងមុខព្រះមានព្រះភាគទ្រង់សំដៅដល់ភិក្ខុច្រើនរូប ត្រាស់ពហុវចនៈថា ឧត្តិយម្បិ យាចិតព្វា : គប្បីសូមជាគម្រប់ពីរដងផង ។

ពាក្យថា នោ ចេ សព្វោ សង្ឃោ ឧស្សហតិ[១] : បើសង្ឃទាំងអស់មិនអាច មានសេចក្តីថា បើសង្ឃទាំងពួងមិនប្រាថ្នា, គឺ ភិក្ខុទាំងនោះជាអ្នកខ្វល់ខ្វាយក្នុងកិច្ច មានការសាធ្យាយ និងមនសិការជាដើម ។

ពីរបទថា សារម្ភំ អនារម្ភំ : នូវទីដែលមានហេតុទាស់ និងទីដែលមិនមានហេតុទាស់ បានដល់ មានអន្តរាយ (ឬចង្រៃ) មិនមានអន្តរាយ ។

ពីរបទថា សបរិក្កមនំ អបរិក្កមនំ : មានជាយជុំវិញ មិនមានជាយជុំវិញ បានដល់ មានឧបចារ មិនមានឧបចារ ។

បទថា បត្តកល្លំ : មានកាលសមគួរដល់ (សង្ឃ) ហើយ មានសេចក្តីថា វេលានៃការត្រួតមើលនេះដល់ហើយ ព្រោះហេតុនោះ ទើបឈ្មោះថា មានកាលដល់ហើយ ។ បត្តកាលនោះឯង ឈ្មោះថា បត្តកល្លំ ។ ក៏ឯអបលោកនកម្មនេះ សូម្បីធ្វើអបលោកន៍ដោយន័យនៃការសូធ្យប្រកាសសម្មតិកម្ម ដើម្បីត្រូវការត្រួតមើលផ្ទៃដី ក៏គួរ ។ តែតទៅខាងមុខកម្មដែលធ្វើក្នុងការសម្តែងទី គួរធ្វើដោយញត្តិ និងអនុសាវនាតាមដែលពោលហើយប៉ុណ្ណោះ ។ នឹងធ្វើដោយអបលោកន៍ មិនគួរ ។

១. ថៃ. សចេ សព្វោ សង្ឃោ ន ឧស្សហតិ ។

[២០៤] បទថា **គិបិល្លិកានំ**[1] **:** ពួកសត្វស្រមោចក្រហម មានសេចក្ដីថា ស្រមោចទាំងឡាយ មានប្រភេទជាស្រមោចក្រហម ស្រមោចខ្មៅ និងស្រមោចល្អៀងជាដើម ប្រភេទណាមួយ ។ បាលីថា **កបីលកានំ** ក៏មាន ។

បទថា **អាសយោ :** កន្លែងអាស្រ័យនៅ គឺ ស្ថានទីនៅជាប្រចាំ ។ គប្បីជ្រាបទីអាស្រ័យ គឺ ទីនៅជាប្រចាំសូម្បីរបស់ពួកសត្វតូច ៗ មានសត្វកណ្ដៀរជាដើម ដូចរបស់ពួកស្រមោចដូច្នោះ, តែពួកសត្វតូច មានស្រមោចក្រហមជាដើមនោះ មកដើម្បីរកចំណីក្នុងទីណាហើយទៅ, ប្រទេសដែលសព្វរដូច្នោះ សូម្បីរបស់សត្វគ្រប់ពួក លោកមិនហាម ។ ព្រោះដូច្នោះ ការកាប់ឆ្ការដើមឈើជាដើម ក្នុងឱកាសនោះចេញ ពង្រាបឱ្យរាបស្មើស្អាតហើយសាង គួរ ។ ស្ថានទាំង ៦ នេះ ព្រះមានព្រះភាគហាមទុក ព្រោះសេចក្ដីអាណិតសត្វ ។

បទថា **ហត្ថីនំ វា :** ពួកដំរីក្ដី មានសេចក្ដីថា ស្ថានទីនៅប្រចាំ ឬស្ថានទីរកស៊ីប្រចាំរបស់ហ្វូងដំរី រមែងមិនសមគួរ ។ ទីអាស្រ័យរបស់សត្វកាចមានសីហៈជាដើមក្ដី មកដើរប្រចាំរបស់ពួកសត្វសាហាវមានសីហៈជាដើម ទីចៀសទៅរកចំណីក្ដី មិនសមគួរ ។ តែលោកមិនបាន

១. ថៃ. កិបីលិកានំ ។

សំដៅយកផ្ទៃដីជាទីត្រាច់ទៅនៃសត្វសាហាវទាំងនេះ ។

ពីរបទថា យេសំ កេសញ្ចិ : ណាមួយ មានសេចក្ដីថា សូម្បីពួកសត្វ តិរច្ឆានដែលសាហាវដទៃ ។ ស្ថានទាំង ៧ នេះ ជាទីមានភ័យចំពោះមុខ ទ្រង់ហាមដើម្បីប្រយោជន៍ដល់ការរួចផុតអំពីការបៀតបៀនដល់ភិក្ខុទាំងឡាយ ។ ស្ថានដ៏សេសជាស្ថានទីមានហេតុទាស់មានប្រការផ្សេង ៗ ។

បណ្ដាបទទាំងនោះ បទថា បុព្វណ្ណនិស្សិតំ : ជាទីតាំងនៅនៃបុព្វណ្ណជាតិ មានសេចក្ដីថា ដែលអាស្រ័យស្រែបុព្វណ្ណជាតិ គឺ តាំងនៅជិតស្រែសាបព្រោះ ធញ្ញជាតិ ៧ ប្រភេទ ។ សូម្បីក្នុងបទថា អបរណ្ណនិស្សិតំ : ជាទីតាំងនៅនៃអបរណ្ណជាតិ ជាដើម ក៏មានន័យយ៉ាងនេះដូចគ្នា ។ តែក្នុងបទថា អបរណ្ណនិស្សិតំ ជាដើម លោកពោលទុកក្នុងអដ្ឋកថាទាំងឡាយ មានកុរុន្ទីជាដើមថា ដែលឈ្មោះថា ទីសម្លាប់ចោរនោះ បានដល់ផ្ទះរបស់បុរស ជាភ្នាក់ងារ គឺផ្ទះរបស់អ្នកមានពៀរវេរាដែលគេសាងទុក ដើម្បីប្រើជាទីកន្លែងសម្លាប់ពួកចោរ ។

ផ្ទៃដីជាក់អាជ្ញាដល់អ្នកធ្វើខុស មានការកាត់ដៃនិងជើងជាដើម ហៅថា ទីសម្រាប់ផ្ដាលទោស ។ ព្រៃធំជាទីចោលសាកសព ហៅថា ទីព្រៃស្មសាន ។ មកដែលមនុស្សទើងត្រូវដើរកន្លងទៅ គឺ មកសញ្ចរ ហៅថា កន្លែងមកទៅមក ។ បទដ៏សេសជាក់ច្បាស់ទាំងអស់ ។

# លក្ខណៈការសាងកុដិ

[២០៥] ពាក្យថា ន សក្កា ហោតិ យថាយុត្តេន សកដេន : បានទីងទីដែលមិនអាចបង្វិលរទេះ មានសេចក្តីថា ជាកន្លែងដែលរទេះទឹមដោយគោស្ទាវ ២ មិនអាចនឹងចតកង់ម្ខាង ទុកក្នុងទីទឹកធ្លាក់អំពីសំយាបផ្ទះ កង់ម្ខាងទុកខាងក្រៅហើយបង្វិលទៅបាន ។ តែក្នុងកុរុន្ទីពោលថា ទឹមដោយគោស្ទាវ ៤ ក៏ដោយ ។

ច្រើនបទថា សមន្តា និស្សេណិយា អនុបរិគន្តុំ : បង្វិលបង្អោងជុំវិញដោយស្រួលបាន មានសេចក្តីថា ជាកន្លែងដែលមនុស្សទាំងឡាយ ឈរប្រេក់ផ្ទះនៅត្រង់ជណ្តើរ ឬបង្អោង មិនអាចវិលទៅជុំវិញដោយជណ្តើរ ឬបង្អោងបាន, ភិក្ខុមិនគួរឱ្យសាងកុដិ ក្នុងទីមានហេតុទាស់និងឥតមានឧបចារបែបនេះ ដូចពោលមកដូច្នេះ ។ តែគួរឱ្យសាងក្នុងទីមិនមានហេតុទាស់និងមានឧបចារ ។

ពីរបទ (អនារម្ភំ សបរិក្កមនំ)នោះ មកហើយក្នុងព្រះបាលីនុ៎ះឯង ដោយបដិបក្ខន័យនៃពាក្យពោលហើយ ។

[២០៨] ពាក្យជាដើមយ៉ាងនេះថា សញ្ញាចិកា ឆាម : ហៅថា សូមគ្រឿងឧបករណ៍គេមកខ្លួនឯង ព្រះមានព្រះភាគ ត្រាស់ទៀតដើម្បីប្រកាសសេចក្តីនៃពាក្យថា សញ្ញាចិកា ជាដើម ដែលត្រាស់ទុក

(ក្នុងបទបញ្ញត្តិ)យ៉ាងនេះថា "សារម្ភេ ចេ ភិក្ខុ វត្ថុស្មឹ អបរិក្កមនេ សញ្ញាចិកាយ កុដឹ ការេយ្យ : បើភិក្ខុឱ្យគេធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង ក្នុងទីដែលមានហេតុទាស់ និងមិនមានឧបចារ" ។

ពីរបទថា បយោគេ ទុក្កដំ : ត្រូវអាបត្តិទុក្កដរាល់ប្រយោគ មានសេចក្ដីថា ភិក្ខុត្រិះរិះថា "យើងនឹងឱ្យសាងកុដិ ដែលសង្ឃមិនបានសម្ដែងទីឱ្យ ឬឱ្យហួសប្រមាណ" ដោយន័យដូចត្រាស់ទុកក្នុងបាលីយ៉ាងនេះ ហើយសំលៀងកាំបិត ឬពូថៅ ដើម្បីត្រូវការនាំឈើមកពីព្រៃ ត្រូវអាបត្តិទុក្កដ, ភិក្ខុចូលទៅកាន់ព្រៃ ត្រូវអាបត្តិទុក្កដ, កាត់ស្មៅស្រស់ក្នុងព្រៃ ត្រូវអាបត្តិបាចិត្តិយ និងអាបត្តិទុក្កដ, កាត់ស្មៅដែលស្ងួត ត្រូវអាបត្តិទុក្កដ ។ សូម្បីក្នុងដើមឈើ ក៏មានន័យយ៉ាងនេះដែរ ។

ប្រយោគតាំងពីដើមយ៉ាងនេះ គឺ ភិក្ខុកាប់ឆ្ការផ្ទៃដី, ជីក កាយដីរាស់វែងជាដើមទៅ ដរាបដល់បោះបង្គំគំពេង ឈ្មោះថា បុព្វប្បយោគ ។ ក្នុងបុព្វប្បយោគនេះ គ្រប់កន្លែង, ក្នុងឋានៈនៃបាចិត្តិយ ត្រូវអាបត្តិបាចិត្តិយ និង ទុក្កដ, ក្នុងឋានៈនៃទុក្កដ ត្រឹមតែជាអាបត្តិទុក្កដ ។ ចាប់តាំងពីបោះបង្គំគំពេងការនោះទៅ ឈ្មោះថា សហប្បយោគ ។

ក្នុងសហប្បយោគនោះ មានវិនិច្ឆ័យដូច្នេះ ៖

ក្នុងកុដិដែលគប្បីសាងដោយសសរច្រើនដើម ភិក្ខុឱ្យលើកសសរដើមដំបូងក្នុងកុដិនោះ ត្រូវអាបត្តិទុក្កដ ។ ក្នុងកុដិដែលគប្បីរៀបដោយឥដ្ឋច្រើនដុំ ភិក្ខុរៀបភ្ជាប់ឥដ្ឋដុំដំបូង ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រកបគ្រឿងឧបករណ៍ណាមួយ ចូលដោយឧបាយយ៉ាងនេះ ។ ត្រូវអាបត្តិទុក្កដគ្រប់ប្រយោគនៃការប្រកបគ្រឿងឧបករណ៍នោះ ។ កាលចាំងឈើ ត្រូវអាបត្តិទុក្កដគ្រប់ ៗ វារៈដែលលើកដៃ, កាលទៅដើម្បីត្រូវការចាំងឈើនោះ ត្រូវអាបត្តិទុក្កដគ្រប់ជំហាន ។

ក៏កាលភិក្ខុគិតថា យើងនឹងលាបកុដិជញ្ជាំងឈើ ឬជញ្ជាំងសិលា ឬជញ្ជាំងឥដ្ឋ ដោយហោចទៅសូម្បីបណ្ណសាលា ព្រមទាំងជញ្ជាំងនិងដំបូលដែលសាងហើយយ៉ាងនេះ ហើយលាបដោយកំបោរស ឬដីស្អិត ត្រូវអាបត្តិទុក្កដគ្រប់ ៗ ប្រយោគ, ជាអាបត្តិទុក្កដ ដរាបដែលមិនទាន់ត្រូវអាបត្តិថុល្លច្ច័យ ។ តែអាបត្តិទុក្កដនេះ បន្ថែមឡើងដោយការបូកច្រើនដង ដូចគ្នា ។ មិនត្រូវអាបត្តិ ព្រោះការផាត់ពណ៌សនិងពណ៌ក្រហមឬ ព្រោះចិត្រកម្ម ។

ពាក្យថា **ឯកំ បិណ្ឌំ អនាគតេ : កាលនៅតែបូក ១ ដុំនឹងហើយ** មានសេចក្តីថា ក្នុងកាលនៃការសាងកុដិមិនទាន់ដល់បូកមួយដុំចុង

ក្រោយ ។ មានពាក្យអធិប្បាយថា ក្នុងខណៈដែលគួរពោលបានថា កុដិនឹងសម្រេចដោយឥដ្ឋ ២ ជុំ ក្នុងកាលឥឡូវនេះ ក្នុងបណ្ដាឥដ្ឋ ២ ជុំនោះ ត្រូវអាបត្តិថុល្លច្ច័យក្នុងការដាក់ឥដ្ឋជុំដំបូង ។

ពាក្យថា **តស្មឹ បិណ្ឌេ អាគតេ : កាលបូកជុំនោះហើយស្រេច** មានសេចក្ដីថា ក្នុងកាលធ្វើកុដិ មួយជុំ (ទៀត) ណាមិនទាន់មកដល់ ត្រូវអាបត្តិថុល្លច្ច័យ, កាលជុំនោះ ដែលជាជុំចុងបង្អស់មកដល់ហើយ គឺមួយជុំដែលភិក្ខុដាក់ហើយ ដាក់ចុះហើយ ត្រូវអាបត្តិសង្ឃាទិសេស ព្រោះការបូកភ្ជាប់គ្នាហើយ ។ និងកាលភិក្ខុលាបយ៉ាងនេះ កាលភ្ជាប់ការបូកផ្ទៃកក្នុងដោយការបូកផ្ទៃកក្នុងធ្វើឱ្យជញ្ជាំងនិងដំបូលឱ្យជាប់គ្នា ឬកាលភ្ជាប់ការបូកផ្ទៃកក្រៅដោយការបូកផ្ទៃកក្រៅហើយ ទើបត្រូវអាបត្តិសង្ឃាទិសេស ។

ក៏បើភិក្ខុមិនទាន់តាំងទ្វារព័ន្ធ (ក្របទ្វារ) ឬបង្អួចឡើយ បូកដោយដីស្អិត, និងកាលតាំងក្របទ្វារនិងបង្អួចនោះ ហើយនឹងពង្រីកឱកាសនៃក្របទ្វារនិងបង្អួចនោះថ្មី ឬមិនពង្រីកក៏ដោយ ការបូកមិនទាន់ជាប់គ្នា នៅរក្សាទុកសិន ។ តែកាលបូកថ្មីល្មមជាប់គ្នា ក៏ត្រូវអាបត្តិសង្ឃាទិសេស ។ បើក្របទ្វារនិងបង្អួចនោះ ដែលភិក្ខុតាំងទុកនៅជាប់តគ្នានឹងការបូក ដែលឱ្យទុកតាំងពីដំបូងតែម្ដង, ជាសង្ឃាទិសេសតាំងពី

ដំបូងដូចគ្នា ។ ដើម្បីការពារកណ្ដៀរ នឹងបូកជញ្ជាំងឥដ្ឋ មិនឱ្យដល់ដំបូលប្រមាណ ៨ ធ្នាប់មិនត្រូវអាបត្តិ ។ ដើម្បីការពារកណ្ដៀរដូចគ្នា នឹងធ្វើជញ្ជាំងថ្មខាងក្រោមមិនបូកជញ្ជាំងនោះ បូកតែខាងលើ, ការបូកឈ្មោះថា មិនទាន់ជាប់តគ្នា, មិនត្រូវអាបត្តិដូចគ្នា ។

ភិក្ខុធ្វើបង្អួចនិងបំពង់ភ្លើងដោយឥដ្ឋសុទ្ធ ក្នុងកុដិជញ្ជាំងឥដ្ឋ ត្រូវអាបត្តិដោយភ្ជាប់នឹងការបូកតែម្ដង ។ ភិក្ខុបូកបណ្ណសាលា, ត្រូវអាបត្តិដោយភ្ជាប់នឹងការបូកដូចគ្នា, ដើម្បីត្រូវការពន្លឺក្នុងបណ្ណសាលានោះ ទើបបូកវៀរទីទុកប្រមាណ ៨ ធ្នាប់, ការបូកឈ្មោះថា មិនទាន់ជាប់តគ្នា, មិនទាន់ត្រូវអាបត្តិដូចគ្នា ។

បើភិក្ខុធ្វើទុកក្នុងចិត្តថា យើងបានបង្អួចហើយ នឹងទុកដាក់ត្រង់នេះ ហើយទើបធ្វើ, កាលជាប់តាំងបង្អួចសម្រេចហើយ ជាអាបត្តិដោយភ្ជាប់ការបូក ។ បើភិក្ខុធ្វើជញ្ជាំងដោយដីស្អិត, ត្រូវអាបត្តិ ព្រោះការភ្ជាប់គ្មាននឹងការបូកដំបូល ។ ភិក្ខុមួយរូប ទុកចន្លោះឱ្យនៅសល់មួយសិន ។ ភិក្ខុរូបទៀត ឃើញមួយដុំដែលមិនបានបូកនោះ ធ្វើទុកក្នុងចិត្តថា "នេះត្រូវអាបត្តិទុកក្ដ" ទើបបូកឱ្យជិត ដោយបំណងក្នុងកិច្ចវត្ត មិនត្រូវអាបត្តិទាំងពីររូប ។

## ពន្យល់អត្ថក្នុងបទភាជនីចតុក្កៈ ធ្វើឱ្យត្រូវអាបត្តិផ្សេងៗ

[២០៩] ចតុក្កៈ ៣៦ មានជាដើមយ៉ាងនេះថា ភិក្ខុ កុដឹ ករោតិ : ភិក្ខុធ្វើកុដិ ព្រះមានព្រះភាគត្រាស់ទុក ដើម្បីទ្រង់សម្តែងប្រភេទនៃអាបត្តិ ។ បណ្តាចតុក្កៈទាំង ៣៦ នោះ គប្បីជ្រាបអាបត្តិដែលលាយឡំគ្នាដោយអំណាចនៃទុក្កដ និងសង្ឃាទិសេសទាំងនេះ គឺ ទុក្កដ ព្រោះមានអន្តរាយ, ទុក្កដ ព្រោះមិនមានឧបចារ, សង្ឃាទិសេស ព្រោះធ្វើកន្លងហួសប្រមាណ, សង្ឃាទិសេស ព្រោះសង្ឃមិនបានសម្តែងទីឱ្យ ។

[២១១] ក៏ក្នុងពាក្យជាដើមថា អាបត្តិ ទ្វិន្នំ សង្ឃាទិសេសានំ ទ្វិន្នំ ទុក្កដានំ : ត្រូវអាបត្តិទុក្កដពីរ ត្រូវអាបត្តិសង្ឃាទិសេសពីរ បណ្ឌិតគប្បីជ្រាបសេចក្តីដោយន័យជាដើមថា ត្រូវអាបត្តិទុក្កដ ២ ព្រមដោយសង្ឃាទិសេស ២ ។

[២១៨] ក៏ក្នុងពាក្យជាដើមថា សោ ចេ វិប្បកតេ អាគច្ឆតិ : កាលបើការដែលធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់ មានអត្ថវិនិច្ឆ័យដូចតទៅនេះ ៖

បទថា សោ : ភិក្ខុនោះ បានដល់ ភិក្ខុដែលបង្គាប់ហើយចៀសចេញទៅ ។

បទថា វិប្បកតេ : កាលការដែលធ្វើកុដិមិនទាន់ស្រេច បាន

ដល់ កាលកសាងកុដិមិនទាន់សម្រេច ។

ពីរបទថា អញ្ញស្ស វា ធាតព្វា : ឬត្រូវឱ្យកុដិនោះដល់ភិក្ខុដទៃក្តី មានសេចក្តីថា គប្បីលះបង់ឱ្យដល់បុគ្គលដទៃ ឬដល់សង្ឃ ។

ពីរបទថា ភិន្ទិត្វា វា បុន កាតព្វា : ឬត្រូវទម្លាយបង់ហើយធ្វើថ្មីទៀត មានសេចក្តីថា កុដិចាត់ថា ជាទីរុះរើហើយ ដោយហេតុមានប្រមាណប៉ុន្មាន ? បើសសរកប់ចុះក្នុងផែនដី គប្បីដកឡើង ។ បើតាំងទុកលើថ្ម គប្បីនាំចេញ ។ គប្បីរើរុះជញ្ជាំងឥដ្ឋនៃកុដិចេញ ដរាបដល់ឥដ្ឋមង្គល (សិលាឫក្សឬបឋមសិលា) ។ ដោយសង្ខេប កុដិដែលត្រូវទម្លាយបំបែកឱ្យរាបស្មើផែនដី រមែងចាត់ថា ជាការរុះរើហើយ ។ កាលមានជញ្ជាំងឥដ្ឋនៅសល់សូម្បីប្រមាណ ៤ ធ្នាប់ ពីផែនដីឡើងទៅ កុដិចាត់ថា មិនទាន់បានរុះរើឡើយ ។ ពាក្យដ៏សេសក្នុងចតុក្កៈទាំងអស់ប្រាកដច្បាស់ហើយ ។ ពិតមែន ក្នុងចតុក្កៈទាំងពួង មិនមានពាក្យអ្វីដទៃដែលគប្បីដឹងបានលំបាក តាមផ្លូវនៃព្រះបាលីឡើយ ។

[២១៩] ក៏ក្នុងពាក្យថា អត្តនា វិប្បកតំ : ភិក្ខុធ្វើកុដិមិនទាន់ស្រេចដោយខ្លួនឯង ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ដែលឈ្មោះថា ញ៉ាំងកុដិដែលខ្លួនចាប់ផ្តើមទុកឱ្យសម្រេចដោយខ្លួនឯង គឺ កាលភិក្ខុដាក់ជុំចុងបង្អស់ ចូលក្នុងកុដិដែលខ្លួនមានសេចក្តី

ប្រាថ្នាទីធ្លីឱ្យជារបស់សាងហើយសម្រេចដោយដីស្អិតចំនួនច្រើន ឬ ដោយដីស្អិតផ្សំអង្កាម ឈ្មោះថា អត្តនា បរិយោសាបេតិ : ហើយ ភិក្ខុ(រូបនោះ)ធ្វើបង្ហើយដោយខ្លួនឯង ។

ពីរបទថា បរេហិ បរិយោសាបេតិ : ហើយភិក្ខុ(រូបនោះ) ឱ្យពួកភិក្ខុដទៃទៀតធ្វើបង្ហើយ មានសេចក្ដីថា ប្រើអ្នកដទៃឱ្យធ្វើសម្រេច ដើម្បីប្រយោជន៍ដល់ខ្លួន ។

ក្នុងពាក្យនេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា កំកុដិដែលខ្លួនឯង ឬ ដែលអ្នកដទៃ ឬថា ទាំងពីរចំណែក ធ្វើបន្សល់ទុកក៏ដោយ, កំឯភិក្ខុ ញ៉ាំងកុដិនោះ ធ្វើឱ្យស្រេចដោយខ្លួនឯងក្ដី ប្រើអ្នកដទៃឱ្យធ្វើសម្រេចក្ដី ប្រើអ្នកដែលរួមជាគូ គឺខ្លួនឯង និងអ្នកដទៃសាងឱ្យសម្រេចក្ដី ដើម្បី ប្រយោជន៍ដល់ខ្លួន ជាសង្ឃាទិសេសទាំងអស់ ។

តែក្នុងកុរុន្ទី លោកពោលថា ភិក្ខុ ២-៣ រូប រួមគ្នាធ្វើ ពោលថា ពួកយើងនឹងនៅ, នៅរក្សាទុកសិន, មិនទាន់ត្រូវអាបត្តិ ព្រោះមិនទាន់ ចែកគ្នា, ចែកគ្នាថា "ទីនេះរបស់លោក ទីនេះរបស់ខ្ញុំ" ហើយជួយគ្នាធ្វើ, ត្រូវអាបត្តិ, សាមណេរនឹងភិក្ខុធ្វើរួមគ្នា, នៅរក្សារហូតដល់អស់វេលា ដែលនៅមិនបានបែងចែកគ្នា, ចែកគ្នាដោយន័យមុនហើយជួយគ្នាធ្វើ ត្រូវអាបត្តិដល់ភិក្ខុ ដូច្នេះ ។

# អនាបត្តិវារវណ្ណនា

[២២០] ក្នុងពាក្យថា អនាបត្តិ លេណេ : ដំណើរដែលមិនត្រូវអាបត្តិនោះ គឺ ភិក្ខុធ្វើលេណ ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

មិនត្រូវអាបត្តិដល់ភិក្ខុដែលធ្វើលេណសូម្បីឱ្យធំ ព្រោះការលាបក្នុងលេណនេះ មិនជាប់តគ្នា ។ សម្រាប់ភិក្ខុដែលធ្វើសូម្បីគុហា គឺ គុហាឥដ្ឋក្តី គុហាសិលាក្តី គុហាឈើក្តី គុហាដីក្តី សូម្បីឱ្យធំក៏មិនត្រូវអាបត្តិ ។

បទថា តិណកុដិកាយ : កុដិស្មៅ មានសេចក្តីថា ប្រាសាទសូម្បីមានផ្ទៃ ៧ ជាន់ តែដំបូលប្រក់ដោយស្មៅនិងស្លឹកឈើ លោកក៏ហៅថា កុដិស្មៅ ។ តែក្នុងអដ្ឋកថាទាំងឡាយ លោកហៅ កុដិដែលគេធ្វើដំបូលឱ្យប្រទាក់គ្នាដូចក្រឡាសំណាញ់ ដោយឈើដៃរណែងទាំងឡាយ ហើយប្រក់ដោយស្មៅទាំងឡាយ ឬស្លឹកឈើទាំងឡាយនុ៎ះឯងថា ទ្រង់មាន់ មិនត្រូវអាបត្តិ ព្រោះកុដិដែលគេប្រក់ហើយនោះ ។ សូម្បីធ្វើផ្ទះដំបូលប្រក់ស្មៅឱ្យធំ ក៏គួរ ។ ព្រោះថា ភាវៈមានការបូកលាបកំបោរខាងក្នុងជាដើមជាលក្ខណៈនៃកុដិ ។ និងភាវៈមានលាបកំបោរខាងក្នុងជាដើមនោះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់សំដៅដល់ដំបូលប៉ុណ្ណោះ ។

ក៏ពាក្យថា "កំទេចស្មៅក៏ជ្រុះមកក្នុងពេងចង្ក្រម ។ បេ ។ ម្នាល ភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យគាបជំបូល ហើយបូកទាំងខាងក្នុងនិងខាងក្រៅ"[១]ជាដើម ជាគ្រឿងសាធកក្នុងកុដិស្មៅនេះ ។ ព្រោះដូច្នោះ ផ្ទះណា មានស្លាបពីរខាង ឬជាប់កំពូលមូល ឬ ៤ ជ្រុងជារបស់ដែលគេសាងដោយសង្ខេបថា នេះជាជំបូលរបស់ផ្ទះនេះ កាលការបូកភ្ជាប់គ្នានឹងដោយការបូកជញ្ជាំងរបស់ផ្ទះនោះហើយ ត្រូវអាបត្តិ ។ ក៏បើថា ភិក្ខុទាំងឡាយ ប្រក់ដោយស្មៅខាងលើ ដើម្បីរក្សាគ្រឿងលាបរបស់ផ្ទះដែលមានជំបូល លាបកំបោរទុកទាំងខាងក្នុងនិងខាងក្រៅ មិនឈ្មោះថា ជាកុដិស្មៅ ដោយអាការត្រឹមតែប៉ុណ្ណោះ ។

សួរថា ក៏ក្នុងកុដិស្មៅនេះ មិនត្រូវអាបត្តិ ព្រោះសង្ឃមិនបានសម្តែងទីឱ្យ និងធ្វើកន្លងហួសប្រមាណជាបច្ច័យប៉ុណ្ណោះ ឬថា សូម្បីព្រោះមានហេតុទាស់ និងមិនមានឧបចារជាបច្ច័យឬ ?

ឆ្លើយថា មិនត្រូវអាបត្តិ សូម្បីគ្រប់ករណី ។

ពិតយ៉ាងនោះ ព្រះមានព្រះភាគទ្រង់សំដៅដល់កុដិដូច្នេះ ទើបត្រាស់ទុកក្នុងគម្ពីរបរិវារថា ៖

"ភិក្ខុធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍គេមក ដោយខ្លួន

---

១. វិន. ចុល្ល. ខុទ្ទកវត្ថុក្ខន្ធក. ១០. ១៩៣/១៧១ ។

៦៩  ឥតមានពួកភិក្ខុសម្តែងទីឱ្យ  ធ្វើឱ្យកន្លងហួសប្រមាណ
មានហេតុទាស់  មិនមានទីឧបចារ  តែភិក្ខុមិនត្រូវអាបត្តិ
ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ”[១] ។

ចំណែកពាក្យដែលព្រះមានព្រះភាគត្រាស់ទុកក្នុងបាលី មានជាដើមថា “ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ ៣”[២] ដូច្នេះ ត្រាស់ ព្រោះការមិនសាងតាមដែលបង្គាប់ទុកជាបច្ច័យ ។

ពីរបទថា អញ្ញស្សត្ថាយ : កុដិសម្រាប់ភិក្ខុដទៃ មានសេចក្តីថា មិនត្រូវអាបត្តិ ដល់ភិក្ខុដែលសាងកុដិ សូម្បីមិនត្រូវលក្ខណៈរបស់កុដិ ដើម្បីប្រយោជន៍ដល់អ្នកដទៃ គឺ ឧបជ្ឈាយ៍ក៏ដោយ អាចារ្យក៏ដោយ សង្ឃក៏ដោយ ។

ពាក្យថា វាសាគារំ ឋបេត្វា សព្វត្ថ : ទីសេនាសនៈទាំងពួងវៀរលែងតែធ្វើកុដិសម្រាប់នៅរបស់ខ្លួន មានសេចក្តីថា ភិក្ខុឱ្យសាងអាគារដទៃ វៀរអាគារដើម្បីប្រយោជន៍ជាទីនៅរបស់ខ្លួនចេញ ដោយតាំងចិត្តថា នឹងជារោងឧបោសថក៏ដោយ ផ្ទះជាទីរក្សាកាយក៏ដោយ ជាសាលាឆាន់ក៏ដោយ ជារោងភ្លើងក៏ដោយ; មិនត្រូវអាបត្តិ ព្រោះអាគារទាំងអស់

១. វិន. បរិ. សេទមោចនគាថា. ១៣. ៣៨៤/៤០២ ។  ២. វិន. សង្ឃា. កុដិការ. ២. ២១៧/២១៧ ។

មានរោងឧបោសថជាដើម ។ បើសូម្បីភិក្ខុនោះ មានសេចក្ដីរំពឹងក្នុងចិត្តថា "ទីងជារោងឧបោសថផង យើងនឹងនៅផង" ដូច្នេះក្ដី ថា "ផ្ទះជាទីរក្សាកាយផង ជាសាលាឆាន់ផង ... ជារោងភ្លើងផង យើងនឹងនៅផង" ដូច្នេះក្ដី សូម្បីកាលឱ្យសាងរោងឧបោសថជាដើម ត្រូវអាបត្តិពិត ។ តែក្នុងមហាបច្ចរី លោកពោលថា "មិនត្រូវអាបត្តិ" ហើយពោលថា "ត្រូវអាបត្តិ ដល់ភិក្ខុដែលសាង ដើម្បីប្រយោជន៍ដល់កុដិជាទីនៅរបស់ខ្លួនប៉ុណ្ណោះ" ។

បទថា **អនាបត្តិ : ដំណើរដែលមិនត្រូវអាបត្តិនោះ** មានសេចក្ដីថា មិនត្រូវអាបត្តិដល់ភិក្ខុឆ្កួត និងដល់ពួកភិក្ខុដែនអាឡ្វីជាដើមបញ្ញត្តិជាដើម ។

ក្នុងសមុដ្ឋានជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយាផង ជាកិរិយានិងជាអកិរិយាផង ។ ពិតមែន សិក្ខាបទនេះ រមែងកើតដោយការធ្វើរបស់ភិក្ខុដែលឱ្យសង្ឃសម្តែងទីឱ្យ ហើយសាងឱ្យកន្លងហួសប្រមាណទៅ, កើតទាំងដោយការធ្វើ ទាំងដោយការមិនធ្វើរបស់ភិក្ខុដែលមិនឱ្យសង្ឃសម្តែងទីឱ្យ ហើយសាង, ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

កុដិការសិក្ខាបទវណ្ណនា ចប់

# ៧. វិហារការសិក្ខាបទវណ្ណនា

[២២១] វិហារការសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។

## ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងព្រះឆន្នៈ

គប្បីជ្រាបវិនិច្ឆ័យ ក្នុងវិហារការសិក្ខាបទនោះ ដូចតទៅនេះ ៖

បទថា កោសម្ពិយំ : ទៀបក្រុងកោសម្ពី បានដល់ ជិតនគរដែលមានឈ្មោះយ៉ាងនេះ ។

បទថា ឃោសិតារាមេ : ក្នុងឃោសិតារាម បានដល់ ក្នុងអារាម (វត្ត) របស់លោកឃោសិតសេដ្ឋី ។

បានឮថា វិហារ (វត្ត) នោះ លោកសេដ្ឋីនាមថា ឃោសិតឱ្យសាង; ព្រោះដូច្នោះ ទើបហៅថា "វត្តឃោសិតារាម ។

បទថា ឆន្នស្ស : ឆន្នភិក្ខុ បានដល់ ព្រះឆន្នៈធ្លាប់ជាឧបដ្ឋាកក្នុងកាលដែលព្រះអង្គនៅជាព្រះពោធិសត្វ ។

ពាក្យថា វិហារវត្ថុំ ភន្តេ ជានាហិ : បពិត្រលោកដ៏ចម្រើនសូមលោកម្ចាស់ជ្រាបទីសម្រាប់សង់វិហារ មានសេចក្ដីថា បពិត្រលោកដ៏ចម្រើន លោកមេត្តាត្រួតមើលស្ថានទីសាងវិហារចុះ ។ ក៏ក្នុងពាក្យថា វិហារវត្ថុំ នេះ ដែលឈ្មោះថា វិហារ មិនមែនវិហារទាំងអស់ គឺ

អាវាស ( ទីលំនៅ ) មួយខ្ទង់ ។ ព្រោះហេតុនោះឯង គហបតីឧបដ្ឋាក របស់ព្រះឆន្ន: ទើបពោលថា "ខ្ញុំព្រះករុណានឹងឱ្យមនុស្សធ្វើវិហារ ប្រគេនលោកម្ចាស់" ។

ក្នុងពាក្យថា **ចេតិយរុក្ខំ : ឈើដែលគេសន្មតជាចេតិយ** នេះ មានវិនិច្ឆ័យដូច្នេះ ៖

ដែលឈ្មោះថា ចេតិយ ព្រោះអត្ថថា ដែលពួកជនធ្វើសេចក្តី គោរព ។ ពាក្យថា **ចេតិយរុក្ខំ** នេះ ជាឈ្មោះនៃទេវស្ថានទាំងឡាយ ដែលគួរដល់ការបូជា ។ ដើមឈើដែលអ្នកស្រុកសន្មតថា ចេតិយ ឈ្មោះថា រុក្ខចេតិយ ។ ដែលអ្នកស្រុកបូជាហើយ ឬជាទីបូជារបស់ អ្នកស្រុក ; ព្រោះដូច្នោះ ដើមឈើនោះ ទើបឈ្មោះថា គាមបូជិត: ( ដែលអ្នកស្រុកនាំគ្នាបូជា ) ។ ក្នុងបទដ៏សេសក៏មានន័យដូច្នេះ ។

ម្យ៉ាងទៀត ក្នុងជនបទនិងរដ្ឋនេះ ចំណែកមួយក្នុងរដ្ឋសីមានៃព្រះ រាជាមួយព្រះអង្គ គប្បីជ្រាបថា ជនបទ ។ ព្រំដែនទាំងអស់ គប្បីជ្រាប ថា រដ្ឋ ។ ពិតមែន ក្នុងកាលខ្លះ សូម្បីអ្នកព្រំដែនទាំងអស់ ក៏ធ្វើការ បូជាដើមឈើនោះ ។ ព្រោះហេតុនោះ លោកទើបពោលថា "ដែលអ្នក ដែនធ្លាប់គោរពបូជា" ។

ដោយបទថា **ឯកិន្ទ្រិយំ : ដែលមានឥន្ទ្រិយតែមួយ** នេះ ពួក អ្នកស្រុកពោលសំដៅយកកាយិន្ទ្រិយ ។

បទថា **ជីវសញ្ញិនោ :** មានសេចក្ដីសំគាល់ថា ឈើជាសភាវៈមានជីវិត គឺ មានការសម្គាល់ថា ជាសត្វ ។

[២២២] បទថា **មហល្លកំ :** វិហារ មានសេចក្ដីថា កាលវិហារធំជាងកុដិដែលសូមដោយខ្លួនឯង ដោយភាពជាវិហារមានម្ចាស់មានដល់វិហារនោះ ; ព្រោះហេតុនោះ ទើបឈ្មោះថា មហល្លកៈ ។ ម្យ៉ាងទៀត ព្រោះឱ្យសង្ឃសម្ដែងទីឱ្យហើយសាង សូម្បីឱ្យលើសប្រមាណក៏គួរ ; ដូច្នោះ វិហារនោះ ទើបឈ្មោះថា មហល្លកៈ ព្រោះទំហំនៃវិហារធំនោះជារបស់ធំជាងប្រមាណខ្លះ ។ ក៏ព្រោះវិហារនោះដែលធំជាងប្រមាណនោះបាន ព្រោះជារបស់មានម្ចាស់នុ៎ះឯង ; ដូច្នោះ ដើម្បីសម្ដែងសេចក្ដីនោះ ព្រះឧបាលីទើបពោលបទភាជនៈថា “វិហារដែលមានម្ចាស់ តថាគតហៅថា វិហារធំ” ។

ពាក្យដ៏សេសទាំងអស់ ព្រមទាំងសមុដ្ឋានជាដើម អ្នកសិក្សាគប្បីជ្រាបដោយន័យដូចពោលមកហើយ ក្នុងកុដិការសិក្ខាបទនុ៎ះឯង ។ ពិតមែន ក្នុងសិក្ខាបទនេះ មានសេចក្ដីប្លែកគ្នាត្រឹមតែជារបស់មានម្ចាស់អ្នកកសាងការមិនមានសមុដ្ឋានអំពីការធ្វើ និងការមិនមានកំណត់ប្រមាណប៉ុណ្ណោះ និងចតុក្កៈថយចុះទៅ ក៏ព្រោះមិនមានកំណត់ប្រមាណ ដូច្នេះឯង ។

វិហារការសិក្ខាបទវណ្ណនា ចប់

# ៨. ទុដ្ឋទោសសិក្ខាបទវណ្ណនា

[២៣៨] ទុដ្ឋទោសសិក្ខាបទថា តេន សមយេន ពុទ្ធោ ភគវា : សម័យនោះ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទុដ្ឋទោសសិក្ខាបទនោះ ដូច្នេះ ៖

## ប្រវត្តិវេឡុវ័នវិហារ

ពាក្យថា **វេឡុវ័ន** ក្នុងពាក្យថា **នៅវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន** ជាឈ្មោះនៃឧទ្យាននោះ ។ បានឮថា ឧទ្យាននោះបានហោមព័ទ្ធជុំវិញទៅដោយគុម្ពឫស្សីនិងកំពែងកំពស់ ១៨ ហត្ថ ប្រកបដោយក្លោងទ្វារនិងប៉ម មានពណ៌ខៀវស្រស់ជាទីរីករាយចិត្ត ។ ព្រោះហេតុនោះ ទើបគេហៅថា វេឡុវ័ន ។ មួយទៀត ជនទាំងឡាយបានឱ្យចំណីដល់ពួកសត្វកង្ហែនក្នុងឧទ្យាននេះ, ព្រោះហេតុនោះ ឧទ្យាននោះ ទើបឈ្មោះថា **កលន្ទកនិវាបៈ** ។

បានឮថា ក្នុងកាលមុនព្រះរាជាមួយអង្គ ស្តេចបានយាងទៅប្រពាតក្នុងឧទ្យាននោះ ទ្រង់ស្រវឹងជោកដោយទឹកចណ្ឌហើយ ផ្ទុំលក់ពេលថ្ងៃ ។ សូម្បីបរិវាររបស់ព្រះអង្គ ក៏និយាយគ្នាថា "ព្រះរាជាផ្ទុំលក់ហើយ" ត្រូវផ្កាឈើនិងផ្លែឈើទាក់ទាញចិត្តឱ្យរីករាយហើយ ទើបនាំគ្នា

ចៀសទៅក្នុងទីនោះ ៗ ។ ខណៈនោះ ពស់វែកលូនចេញមកពីរូងឈើមួយដើម ព្រោះក្លិនសុរា លូនតម្រង់មករកព្រះរាជា រុក្ខទេវតាឃើញពស់វែកនោះហើយគិតថា "យើងនឹងថ្វាយជីវិតដល់ព្រះរាជា" ទើបប្លែងភេទជាសត្វកង្ហែន មកធ្វើសំឡេងស្រែកជិតព្រះកាណ៌នៃព្រះរាជា ។ ព្រះរាជាទ្រង់ភ្ញាក់ពីការផ្ទំឡើង ។ ពស់ក៏លូនត្រឡប់ទៅ ។ ទ្រង់ទតឃើញហេតុនោះ ហើយទ្រង់ត្រិះរិះថា "សត្វកង្ហែននេះឱ្យជីវិតយើង" ទើបផ្ដើមឱ្យចំណីដល់សត្វកង្ហែនទាំងឡាយ និងទ្រង់ឱ្យប្រកាសព្រះរាជទានអភ័យដល់ហ្វូងសត្វកង្ហែនក្នុងឧទ្យាននោះ ព្រោះដូច្នោះ វេឡុវ័ននោះ ទើបដល់ការរាប់ថា កលន្ទកនិវាបៈ (ជាទីឱ្យចំណីដល់សត្វកង្ហែន) ចាប់តាំងពីកាលនោះមក ។ ពិតណាស់ ពាក្យថា កលន្ទកៈនេះ ជាឈ្មោះរបស់ពួកសត្វកង្ហែន ។

## ពន្យល់អត្ថក្នុងរឿងព្រះទព្វមល្លបុត្រ

ពាក្យថា ទព្វៈ ជានាមនៃព្រះថេរៈនោះ ។

បទថា មល្លបុត្តោ : មល្លបុត្ត គឺ ជាឱរសរបស់ព្រះបាទមល្លរាជ ។

ពាក្យថា ជាតិយា សត្តវស្សេន អរហត្តំ សច្ឆិកតំ : មានអាយុ ៧ ឆ្នាំ អំពីកំណើត បានសម្រេចអរហត្តផល មានសេចក្ដីថា

បានឮថា ព្រះថេរៈនេះ បណ្ឌិតគប្បីជ្រាបថា មានអាយុត្រឹមតែ ៧ ឆ្នាំ កាលបព្វជ្ជា បានសេចក្តីសង្វេគហើយ សម្រេចព្រះអរហត្តផល ក្នុងខណៈកោរសក់ស្រេចនោះឯង ។

ពាក្យថា យំកិញ្ចិ សាវកេន បត្តព្វំ សព្វំ តេន អនុប្បត្តំ : គុណជាតិឯណានីមួយ ដែលសាវកត្រូវដល់ គុណជាតិទាំងអស់ (នោះ) ក៏ព្រះទព្វមល្លបុត្តនោះបានដល់ដោយលំដាប់ហើយ មានសេចក្តីថា គុណជាតិនេះ គឺ វិជ្ជា ៣ បដិសម្ភិទា ៤ អភិញ្ញា ៦ លោកុត្តរធម៌ ៩ ឈ្មោះថា ដែលសាវកគប្បីសម្រេច, គុណជាតិនោះ ព្រះថេរៈនោះបានសម្រេចហើយគ្រប់យ៉ាង ។

ពាក្យថា នត្ថិ ចស្ស កិញ្ចិ ឧត្តរិ ករណីយំ : កិច្ចអ្វីបន្តិចបន្តួច (សោឡសកិច្ច) ដែលព្រះទព្វមល្លបុត្តនោះគប្បីធ្វើតទៅទៀត ក៏មិនមានឡើយ មានសេចក្តីថា ឥឡូវនេះ កិច្ចដែលត្រូវធ្វើឱ្យក្រៃលែងឡើងទៅ សូម្បីបន្តិចបន្តួច ក៏មិនមានដល់ព្រះថេរៈនោះ ពីព្រោះកិច្ច ១៦ ប្រការ ក្នុងអរិយសច្ចៈ៤ ដែលលោកធ្វើសម្រេចហើយដោយមគ្គ៤ ។

ពាក្យថា កតស្ស វា បតិចយោ : កិច្ចដែលព្រះទព្វមល្លបុត្តបានធ្វើហើយ នឹងធ្វើកិច្ចនោះឱ្យចម្រើនទៀត មានសេចក្តីថា សូម្បីការនឹងបន្ថែមកិច្ចដែលធ្វើសម្រេចហើយនោះ ក៏មិនមាន ដូចគ្នានឹងសំពត់

ដែលជ្រលក់ហើយ មិនត្រូវជ្រលក់ដដែលទៀត ដូចរបស់គ្រឿងអូបដែលកិនហើយ មិនត្រូវកិនដដែលទៀត និងដូចផ្កាឈើដែលរីកហើយមិនត្រឡប់រីកទៀត ដូច្នោះឯង ។

[២៣៩] បទថា រហោគតស្ស : ទីស្ងាត់ បានដល់ ទៅក្នុងទីស្ងាត់ ។

បទថា បដិសល្លីនស្ស : សម្ងំនៅក្នុងកម្មដ្ឋាន បានដល់ ចៀសចេញពីអារម្មណ៍នោះ ៗ ហើយនៅសម្ងំ ។ មានពាក្យអធិប្បាយថា ដល់ភាពជាបុគ្គលម្នាក់ឯង ។

ពាក្យថា អជ្ជខោ អាយស្មតោ ទព្វស្ស មល្លបុត្តស្ស ឯតទហោសិ យន្នូនាហំ សង្ឃស្ស សេនាសនញ្ច បញ្ញាបេយ្យំ ភត្តានិ ច ឧទ្ទិសេយ្យំ : កាលនោះ ព្រះទព្វមល្លបុត្តដ៏មានអាយុបានត្រិះរិះដូច្នេះថា បើដូច្នោះ មានតែអញត្រូវរៀបចំសេនាសនៈផង ត្រូវចាត់ចែងចង្ហាន់ទាំងឡាយផងដល់សង្ឃ មានសេចក្តីថា បានឮថា ព្រះថេរៈឃើញថា "កិច្ចរបស់ខ្លួនធ្វើរួចស្រេចហើយ" ទើបត្រិះរិះថា "យើងនៅទ្រទ្រង់ទុកនូវសរីរៈចុងក្រោយនេះ, ក៏ឯសរីរៈចុងក្រោយនោះ តាំងនៅក្នុងមកនៃភាពជារបស់មិនទៀង មិនយូរឡើយក៏នឹងរលត់ទៅជាធម្មតា ដូចប្រទីបតាំងនៅមុខខ្យល់អ៊ីចឹង, (បើដូច្នោះ) អញគប្បីធ្វើការខ្វល់ខ្វាយបម្រើសង្ឃ

វេហូតដល់វេលាមិនទាន់និព្វាន ឬយ៉ាងណាហ្ន៎” ចាប់ភ្លឹកនឹកពិចារណាឃើញយ៉ាងនេះថា “ពួកកុលបុត្រជាច្រើន ក្នុងដែនក្រៅទាំងឡាយ បួសមិនបានឃើញព្រះមានព្រះភាគឡើយ, លោកទាំងនោះ រមែងនាំគ្នាមកសូម្បីអំពីទីឆ្ងាយ ដោយបំណងថា យើងទាំងឡាយនឹងចូលគាល់ នឹងថ្វាយបង្គំព្រះមានព្រះភាគ បណ្តាកុលបុត្រនោះ សេនាសនៈមិនគ្រប់គ្រាន់ដល់លោកពួកណា, លោកពួកនោះ ត្រូវដេកសូម្បីលើផ្ទាំងសិលា, ក៏ឯយើងអាចនិម្មិតសេនាសនៈ មានប្រាសាទ វិហារ អឌ្ឍយោគជាដើម ព្រមទាំងគ្រែ តាំង និងកម្រាល ឱ្យសម្រេចតាមសេចក្តីប្រាថ្នារបស់កុលបុត្រជាច្រើននោះ ដោយអានុភាពរបស់ខ្លួន និងក្នុងថ្ងៃស្អែកឡើងបណ្តាកុលបុត្រទាំងនេះ ពួកខ្លះមានកាយនឿយហត់ពន់ពេកណាស់, កុលបុត្រទាំងនោះនឹងឈរខាងមុខភិក្ខុទាំងឡាយ ហើយឱ្យចែកសូម្បីនូវភត្តាហារដោយគារវៈមិនបានទេ, ក៏យើងនេះឯង អាចចែកសូម្បីនូវភត្តាហារដល់កុលបុត្រទាំងនោះបាន” ។ គ្រានោះឯង ព្រះទព្វមល្លបុត្រដែលពិចារណាយ៉ាងនេះ បានមានសេចក្តីសម្រេចចិត្តនេះថា “បើដូច្នោះ យើងគួរចាត់ចែងសេនាសនៈ និងចែកភត្តាហារដល់សង្ឃ” ។

សួរថា ក៏ឋានៈទាំង ២ ប្រការនេះ គួរដល់ភិក្ខុដែលតាមប្រកបតែសេចក្តីត្រេកអរក្នុងការនិយាយជាដើម មិនមែនឬ ? ចំណែកព្រះទព្វមល្លបុត្រនេះជាព្រះខីណាស្រព មិនមានសេចក្តីត្រេកអរក្នុងធម៌ជា

គ្រឿងឃឹតយូរ, ព្រោះហេតុអ្វី ទើបឋានៈ ២ ប្រការនេះ ប្រាកដជាក់ច្បាស់ដល់លោកដ៏មានអាយុនេះហ្ន៎ ?

ឆ្លើយថា ព្រោះសេចក្តីប្រាថ្នាក្នុងកាលមុនមកជាស់តឿន ។

បានឮថា ព្រះពុទ្ធគ្រប់ព្រះអង្គ ទ្រង់មានពួកសាវកដែលសម្រេចឋាននូវនេះ ដូចគ្នា, និងព្រះទព្វមល្លបុត្រនេះ កើតជាតិមុនក្នុងត្រកូលមួយ ក្នុងកាលនៃព្រះមានព្រះភាគទ្រង់ព្រះនាមថា បទុមុត្តរៈ ឃើញអានុភាពរបស់ភិក្ខុដែលសម្រេចឋាននូវនេះ និមន្តព្រះមានព្រះភាគព្រមទាំងភិក្ខុ ៦៨០,០០០ រូប ថ្វាយមហាទានរហូតដល់អស់ ៧ ថ្ងៃ ហើយក្រាបចុះទៀបបាទមូល បានធ្វើសេចក្តីប្រាថ្នាថា "ក្នុងកាលនៃព្រះពុទ្ធដូចជាព្រះអង្គដែលកើតឡើងក្នុងអនាគត សូមឲ្យខ្ញុំព្រះអង្គ គប្បីជាអ្នករៀបចំសេនាសនៈ និងភត្តុទ្ទេសកៈ ដូចសាវករបស់ព្រះអង្គឈ្មោះនេះ" ព្រះមានព្រះភាគទ្រង់បញ្ជូនអនាគតំសញ្ញាណប្រមើលមើលទៅ បានទតឃើញហើយ ។ ក៏កាលទតឃើញហើយ ទើបទ្រង់ព្យាករណ៍ថា "ដោយកាលកន្លងទៅនៃមួយសែនកប្បអំពីកប្បនេះ ព្រះពុទ្ធទ្រង់ព្រះនាមថា គោតមទ្រង់នឹងឧប្បត្តិឡើង, ក្នុងកាលនោះអ្នកនឹងកើតជាបុត្ររបស់មល្លក្សត្រិយ៍នាមថា ទព្វៈ មានអាយុ ៧ ខួបអំពីកំណើត នឹងចេញបព្វជ្ជា ហើយធ្វើឱ្យច្បាស់នូវព្រះអរហត្តផល នឹងបានឋាននូវនេះ" ។ ចាប់ផ្តើមតាំងពីនោះមក លោកបំពេញកុសលមានទានសីលជាដើម បាន

ដោយសម្បត្តិក្នុងទេវតានិងមនុស្ស ក្នុងកាលនៃព្រះមានព្រះភាគរបស់យើង បានធ្វើឱ្យជាក់ច្បាស់នូវព្រះអរហត្តផល ដូចដែលព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ព្យាករណ៍ហើយនុ៎ះឯង ។ លំដាប់នោះ កាលព្រះទព្វមល្លបុត្រនៅក្នុងទីស្ងាត់ ក៏ត្រិះរិះថា "យើងគប្បីធ្វើការខ្វល់ខ្វាយដល់សង្ឃបែបណាហ្ន៎" ឋានៈ ២ នេះប្រាកដជាក់ច្បាស់ហើយ ព្រោះសេចក្តីប្រាថ្នាក្នុងកាលមុននោះជាស់តឿន ដូច្នេះឯង ។

គ្រានោះ លោកបានមានសេចក្តីរំពឹងនេះថា "យើងមិនជាឥស្សរៈក្នុងខ្លួនឯង, យើងនៅក្នុងសំណាក់មួយជាមួយនឹងព្រះសាស្តា, ប្រសិនបើព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឱ្យយើងសោត, យើងនឹងសមាទានឋានៈទាំង ២ នេះ" ហើយបានចូលទៅគាល់ព្រះមានព្រះភាគ ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យបានពោលថា អថខោ អាយស្មា ទព្វោ មល្លបុត្តោ ។បេ ។ ភត្តានិ ច ឧទ្ទិសិតុំ : ក្នុងពេលនោះ ព្រះទព្វមល្លបុត្តដ៏មានអាយុ ។ល ។ ត្រូវចាត់ចែងចង្ហាន់ទាំងឡាយផងដល់ព្រះសង្ឃ ដូច្នេះ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ញ៉ាំងព្រះទព្វមល្លបុត្រនោះ ឱ្យសប្បាយរីករាយដោយព្រះតម្រាស់ថា "ម្នាលទព្វ ប្រពៃណាស់ហើយ ៗ" ទើបត្រាស់ថា "បើដូច្នោះ អ្នកចូររៀបចំសេនាសនៈផង និងចូរចាត់ចែង

ចង្ហាន់ទាំងឡាយផង ដល់ព្រះសង្ឃចុះ, ព្រោះថា ភិក្ខុដែលឃ្លាតឆ្ងាយចាកការលំអៀង ព្រោះអគតិបែបនេះ រមែងសមគួរបាត់ការហានៈទាំង ២ នេះ” ។

ពីរបទថា ភគវតោ បច្ចស្សោសិ : ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគ សេចក្តីថា ព្រះទព្វមល្លបុត្រក្រាបទូលរាប់រងព្រះតម្រាស់របស់ព្រះមានព្រះភាគ គឺ ទូលទទួលនៅចំពោះព្រះភក្ត្រ ។ មានពាក្យអធិប្បាយថា ទូលរាប់រងព្រមទទួល ។

[២៤០] ក្នុងពាក្យថា បឋមំ ឧញ្ញោ យាចិតព្វោ : មុនដំបូងត្រូវសង្ឃអង្វរទព្វភិក្ខុ នេះ មានពាក្យសួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទ្រង់ឱ្យភិក្ខុទាំងឡាយសូមអង្វរ ?

ឆ្លើយថា ដើម្បីការពារសេចក្តីតិះដៀល និន្ទា ។

ពិតមែន ព្រះមានព្រះភាគទ្រង់ឃើញថា “ក្នុងអនាគត ឧបទ្រវៈធំនឹងកើតដល់ទព្វៈ ដោយអំណាចនៃភិក្ខុឈ្មោះមេត្តិយៈ និងភុម្មជកៈព្រោះអាស្រ័យហានៈនេះ, បណ្តាភិក្ខុទាំងនោះ ពួកខ្លះនឹងតិះដៀលថា លោកទព្វៈនេះជាអ្នកស្ងៀមព្រងើយ, មិនធ្វើការងាររបស់ខ្លួន មកបាត់ការហានៈដូច្នេះ ព្រោះហេតុអ្វី ? លំដាប់នោះ ភិក្ខុពួកដទៃទៀតនឹងពោលថា ទោសអ្វីរបស់ភិក្ខុនេះ, លោកនេះដែលភិក្ខុទាំងនោះឯង សូមតែងតាំងឱ្យ

ចាត់ចែងហើយ, លោកនឹងផុតពីសេចក្តីតិះដៀលនិន្ទាដោយអាការយ៉ាងនេះ” ។ សូម្បីកាលឱ្យសូម ដើម្បីដោះសេចក្តីតិះដៀលយ៉ាងនេះហើយ ព្រោះកាលសង្ឃមិនបានសន្មតដដែលទៀត ភិក្ខុ (ដែលចាត់ចែងនោះ) ពោលពាក្យអ្វី ៗ កណ្តាលជំនុំសង្ឃ នឹងកើតការពោលទោសថា “ជាធម្មតាថា ព្រោះហេតុអ្វី ទើបភិក្ខុនេះធ្វើសំឡេងខ្លាំង សម្តែងភាពជាធំកណ្តាលជំនុំសង្ឃហ្ន៎” តែកាលសង្ឃបានសន្មតហើយ ភិក្ខុនោះនិយាយ, នឹងមានអ្នកពោល (គាំទ្រ) ថា “ពួកលោកកុំបាននិយាយអ្វី ៗ, ភិក្ខុនេះសង្ឃបានសន្មតហើយ ចូរឱ្យភិក្ខុនោះនិយាយបានតាមសប្បាយចុះ”, មួយទៀត ភិក្ខុពោលបង្កាច់ចំពោះភិក្ខុដែលសង្ឃមិនបានសន្មតដោយពាក្យមិនពិត ត្រូវអាបត្តិស្រាលត្រឹមតែទុក្កដ, តែអ្នកពោលមួលបង្កាច់ភិក្ខុដែលសង្ឃសន្មតហើយ ត្រូវអាបត្តិបាចិត្តិយដែលធ្ងន់ជាង, ពេលនោះភិក្ខុដែលសង្ឃសន្មតហើយ នឹងជាអ្នកត្រូវពួកភិក្ខុសូម្បីអ្នកចងវេរាកម្ចាត់បានលំបាកក្រៃលែង ព្រោះត្រូវអាបត្តិធ្ងន់, ដូច្នោះ ដើម្បីឱ្យសង្ឃសន្មតលោក (ទព្វៈ) ដ៏មានអាយុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា

ព្យត្តេន ភិក្ខុនា : ភិក្ខុមួយរូបដែលឈ្លាសវាងវៃ ជាដើម ។

សួរថា ក៏ការឱ្យសម្មតិ ២ យ៉ាង ដល់ភិក្ខុមួយរូបគួរឬ ?

ឆ្លើយថា មិនមែនត្រឹមតែ ២ យ៉ាងប៉ុណ្ណោះទេ, បើអាចនឹងឱ្យ

សម្មតិទាំង ១៣ យ៉ាង ក៏គួរ ។ តែកាលភិក្ខុទាំងឡាយ មិនអាចសូម្បី សម្មតិតែម្យ៉ាង ក៏មិនសម, គួរឱ្យដល់ភិក្ខុ ២ ឬ ៣ រូប ។

[២៤១] បទថា សភាគានំ : ស្មើគ្នា មានសេចក្ដីថា អ្នកស្មើគ្នាដោយគុណ មិនមែនអ្នកស្មើគ្នាដោយជាមិត្តស្និទ្ធស្នាលនឹងគ្នា ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា យេ តេ ភិក្ខូ សុត្តន្តិកា តេសំ ឯកជ្ឈំ : ភិក្ខុទាំងឡាយណា ជាអ្នករៀនព្រះសូត្រ (ទព្វមល្លបុត្តក៏រៀបចំសេនាសនៈ) ក្នុងទីជាមួយគ្នា ដើម្បីភិក្ខុទាំងឡាយនោះ ជាដើម ។ ក៏ភិក្ខុដែលទ្រទ្រង់ព្រះសូត្រមានចំនួនប៉ុន្មាន, ព្រះទព្វថេរៈជ្រើសរើសភិក្ខុទាំងនោះ ចាត់ចែងសេនាសនៈ ដែលសមគួរដល់ភិក្ខុទាំងនោះឯង រួមគ្នា, ដល់ពួកភិក្ខុដ៏សេសក៏យ៉ាងនោះ ។

បទថា កាយទឡ្ហីពហុលា : ច្រើនដោយការថ្នមខ្លួន បានដល់ ជាអ្នកច្រើនទៅ ដោយការធ្វើរាងកាយឱ្យរឹងមាំ, អធិប្បាយថា ជាអ្នកច្រើនទៅដោយការទំនុកបម្រុងរាងកាយ ។

ពាក្យថា ឥមាយបិមេ អាយស្មន្តោ រតិយា : លោកដ៏មានអាយុទាំងឡាយនេះ (នឹងនៅ)ទល់ភ្លឺដោយពោលនូវតិរច្ឆានកថានេះ បានដល់ សេចក្ដីត្រេកអរក្នុងតិរច្ឆានកថា ដែលជាហេតុជំទាស់ចំពោះមកសួគ៌នេះ ។

បទថា អច្ចិស្សន្តិ គឺ វិហរិស្សន្តិ : នឹងនៅ ។

ពាក្យថា តេជោធាតុំ សមាបជ្ជិត្វា តេនេវ អាលោកេន : ព្រះទព្វមល្លបុត្តក៏ចូលកាន់តេជោធាតុ ដោយពន្លឺនៃតេជោធាតុ ដើម្បីភិក្ខុទាំងឡាយនោះ មានសេចក្ដីថា ព្រះទព្វមល្លបុត្តដ៏មានអាយុនោះ ចូលចតុត្ថជ្ឈាន មានតេជោកសិណជាអារម្មណ៍ ចេញហើយអធិដ្ឋានម្រាមដៃឱ្យភ្លឺដោយអភិញ្ញា (ចាត់ចែងសេនាសនៈ) ដោយពន្លឺដែលភ្លឺអំពីម្រាមដៃ ដែលតេជោធាតុសមាបត្តិឱ្យកើតហើយនោះ ។ ក៏អានុភាពរបស់ព្រះថេរៈយ៉ាងនេះ បានប្រាកដហើយ ក្នុងសាកលជម្ពូទ្វីប ក្នុងកាលមិនយូរឡើយ ។ ភិក្ខុទាំងឡាយស្ដាប់ដំណឹងនោះ ចង់ឃើញឥទ្ធិបាដិហារ្យរបស់លោក បាននាំគ្នាមក ។ ពួកភិក្ខុខ្លះក្លែងមកក្នុងវេលាវិកាល ក៏មាន ។

ពាក្យថា តេ សញ្ចិច្ច ទូរេ អបទិស្សន្តិ[1] : ភិក្ខុទាំងឡាយនោះ (ខ្លះ) ក៏ក្លែងបន្លំទៅរកទីឆ្ងាយ មានសេចក្ដីថា ពួកភិក្ខុនោះ ទាំងដែលដឹងប្រាកដ ក៏នាំគ្នាអាងដល់ស្ថានទីឆ្ងាយ ៗ ។

តើអាងយ៉ាងណា ? គឺ អាងយកដោយន័យនេះថា "លោកម្ចាស់ទព្វៈ សូមលោកម្ចាស់ចាត់ចែងសេនាសនៈ ឱ្យពួកខ្ញុំព្រះករុណាជិតភ្នំគិជ្ឈកូដ" ដូច្នេះជាដើម ។

---

១. ថៃ. ភូមា. អបទិសន្តិ ។

ពាក្យថា អង្គុលិយា ជលមានាយ បុរតោ បុរតោ គច្ឆតិ : មានម្រាមដៃដ៏ភ្លឺរុងរឿង ដើរទៅក្នុងទីខាងមុខ ៗ មានសេចក្តីថា បើមានភិក្ខុតែមួយរូប លោកទៅដោយខ្លួនឯង, បើមានច្រើនរូប លោកនិម្មិតអត្តភាពជាច្រើន ឱ្យដូចគ្នានឹងខ្លួនរបស់លោកទាំងអស់ ។

ក៏ក្នុងពាក្យថា សេនាសនំ បញ្ញាបេតិ អយំ មញ្ចោ : រៀបចំក្រាលសេនាសនៈ (ដោយរបៀបយ៉ាងនេះ គឺ) នេះគ្រែ ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

កាលព្រះថេរៈពោលថា នេះគ្រែ សូម្បីអត្តភាពនិម្មិតក៏ពោលថា នេះគ្រែក្នុងទីនៃខ្លួន ៗ ទៅដល់ហើយ ។ សូម្បីក្នុងបទទាំងពួងក៏យ៉ាងនេះ ។ ពិតមែន សភាពយ៉ាងនេះ ជាប្រក្រតីធម្មតារបស់អត្តភាពនិម្មិត គឺ ៖

> កាលអ្នកមានឫទ្ធិមួយនាក់និយាយ អត្តភាពនិម្មិតទាំង
> អស់ក៏និយាយផង កាលអ្នកមានឫទ្ធិម្នាក់អង្គុយស្ងៀម
> អត្តភាពនិម្មិតទាំងអស់នោះ ក៏ស្ងៀមផង ។

ក៏ក្នុងវិហារណា គ្រែ តាំងជាដើម មិនសម្បូរណ៍, លោករមែងឱ្យបរិបូណ៌ដោយអានុភាពរបស់ខ្លួន, ការនិយាយក្រៅរឿងរបស់អត្តភាពដែលព្រះថេរៈនោះនិម្មិត រមែងមិនមាន ។

ពាក្យថា សេនាសនំ បញ្ញាបេត្វា បុនទេវ វេឡុវនំ បច្ចាគច្ឆតិ : រៀបចំក្រាលសេនាសនៈ (យ៉ាងនេះ ដល់ភិក្ខុទាំងឡាយហើយ) ក៏និមន្តត្រឡប់មកវត្តវេឡុវ័នវិញ មានសេចក្ដីថា លោករមែងមិនអង្គុយជជែកគ្នារឿងជនបទនឹងភិក្ខុទាំងនោះ ត្រឡប់មកកាន់ទីនៅរបស់ខ្លួនវិញភ្លាម ។

## ពន្យល់អត្ថក្នុងរឿងភិក្ខុមេត្តិយៈនិងភិក្ខុភុម្មជកៈ

[២៨២] បទថា មេត្តិយភុម្មជកា : មេត្តិយភិក្ខុនិងភុម្មជកភិក្ខុទាំងឡាយ បានដល់ ភិក្ខុទាំងនេះ គឺ ភិក្ខុឈ្មោះមេត្តិយៈ ១ ភិក្ខុឈ្មោះភុម្មជកៈ ១ ជាប្រធាន នៃពួកភិក្ខុឆព្វគ្គិយ ។

ពីរបទថា លាមកានិ ច ភត្តានិ : ទាំងភត្តណា ដែលថោកទាប បានដល់ សេចក្ដីនេះ គឺ សេនាសនៈដែលថោកថយ ត្រូវបានដល់ពួកភិក្ខុថ្មី មិនជារឿងគួរអស្ចារ្យឡើយ ។ តែភិក្ខុទាំងឡាយដាក់ស្លាកទុកក្នុងល្អី ឬថ្នក់ចីវរ ច្របល់ចូលគ្នាហើយចាប់ឡើងម្ដងមួយ ៗ ចែកភត្តឱ្យទៅ, ភត្តសូម្បីទាំងនោះជារបស់ថោកថយអន់ជាងគេទាំងអស់ រមែងសម្រេចដល់ភិក្ខុមេត្តិយៈ និងភុម្មជកៈនោះ ព្រោះជាអ្នកមានបុណ្យតិច ។

សូម្បីភត្តណាមួយ ដែលគួរចែកឱ្យដល់តាមលំដាប់ ឈ្មោះថា

ឯកភាវិកភត្តជារបស់ប្រណីតសែនប្រណីត គប្បីប្រមូលឱ្យចែកតាំងពីព្រះថេរៈ ដរាបដល់ព្រះនវកៈ, សូម្បីភត្តនោះ ក្នុងថ្ងៃដែលត្រូវបានដល់ភិក្ខុមេត្តិយៈ និងភុម្មជកៈនេះ ក្លាយជារបស់ថោកថយ ឬពួកអ្នកស្រុកល្មមឃើញភិក្ខុ ២ រូបនោះ មិនប្រគេនរបស់ប្រណីត ត្រឡប់ជាប្រគេនរបស់ថោកថយ ។

បទថា អភិសង្ខារិកំ : ដែលតាក់តែង បានដល់ ដែលគេផ្សំគ្រឿងផ្សេង ៗ អធិប្បាយថា ដែលគេត្រៀមដោយល្អ គឺ ឱ្យសម្រេចដោយល្អ ។

បទថា កាណាជកំ : បាយចុងអង្ករ បានដល់ បាយលាយផ្សំនឹងកុណ្ឌក[1] ។

បទថា ពិលង្គទុតិយំ : មានទឹកជ្រក់ជាគម្រប់ពីរ បានដល់គូនឹងទឹកជ្រក់ ។

[២៨៣] បទថា កល្យាណភត្តិកោ : ឈ្មោះកល្យាណភត្តិកមានសេចក្តីថា ភត្តដ៏ល្អ គឺ ដែលឆ្ងុយឆ្ងាញ់និងប្រណីតរបស់ឧបាសកនោះ មាន, ព្រោះហេតុនោះ ឧបាសកនោះ ទើបឈ្មោះថា កល្យាណ

---

១. ផង់អង្ករ ល្អងអង្ករ ពាក្យនេះប្រើក្លាយមកជា កន្ទក់ គេច្រើនប្រើធ្វើជាបបរឱ្យជ្រូកស៊ី ។

ភត្តិកៈ ឧបាសកនោះ ប្រាកដឈ្មោះ តាមភត្តុទ្ទ៑ះឯង ព្រោះជាអ្នកប្រគេនភត្តប្រណីត ។

ពីរបទថា ចតុក្កភត្តំ ទេតិ : តែងប្រគេន(និច្ចភត្ត) ៤ សម្រាប់ បានដល់ ប្រគេនភត្តាហារមួយថ្ងៃ ៗ ៤ សម្រាប់ ។ តែដោយវោហារនៃតន្ទិតលោកពោលថា ចតុក្កភត្ត ។

ពីរបទថា ឧបតិដ្ឋិត្វា បរិវិសតិ : ចូលទៅបម្រើអង្គាស មានសេចក្ដីថា ឧបាសកនោះលះបង់ការងារទាំងអស់ ធ្វើការបូជានិងធ្វើសក្ការៈ ហើយឈរអង្គាសនៅក្នុងទីជិត ៗ ។

ពីរបទថា ឱទនេន បុច្ឆន្តិ : សួររកបាយ មានសេចក្ដីថា ពួកអ្នកកាន់បាយចូលទៅរកហើយ សួរថា "ខ្ញុំព្រះករុណានិងប្រគេនបាយ ឬលោកម្ចាស់ ?" យ៉ាងនេះ ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃករណៈ ។ ក្នុងសូបៈជាដើមក៏មានន័យយ៉ាងនេះ ។

បទថា ស្វាតនាយ : ត្រូវវេនទទួលចង្ហាន់ក្នុងថ្ងៃស្អែក មានសេចក្ដីថា ការឆាន់ភត្តាហារដែលមានក្នុងថ្ងៃស្អែកនេះ ឈ្មោះថា ស្វាតនៈ ។ ដើម្បីប្រយោជន៍ដល់ការឆាន់ភត្តាហារក្នុងថ្ងៃស្អែកនោះ ឈ្មោះថា ស្វាតនាយ ។ មានពាក្យអធិប្បាយថា ដើម្បីប្រយោជន៍ដល់ការឆាន់ភត្តាហារដែលគួរធ្វើក្នុងថ្ងៃស្អែក ។

ពីរបទថា ឧទ្ទិដ្ឋំ ហោតិ : ជាចង្ហាន់ដែលភត្តុទ្ទេសកភិក្ខុសម្តែងឱ្យ បានដល់ ជារបស់ដែលភត្តុទ្ទេសកៈប្រគេនឱ្យដល់ហើយ ។

ព្រះថេរៈមិនបានទឹកដល់ ( រឿងនោះ ) ទើបពោលពាក្យនេះ ថា មេត្តិយភុម្មជកានំ ខោ គហបតិ : ម្នាលគហបតិ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុទាំងឡាយ ដូច្នេះ ។

ពិតមែន សេចក្ដីដែលភិក្ខុមេត្តិយៈនិងភុម្មជកៈនោះ ជាអ្នកមានបុណ្យតិច ដ៏មានកម្លាំងយ៉ាងនេះ សូម្បីព្រះអរហន្តទាំងឡាយ ជាអ្នកដល់ព្រមដោយសតិដ៏បរិបូណ៌, ក៏មិនមានសេចក្ដីទឹកដល់ ។

ដោយពាក្យថា ជេ : ហន់ ក្នុងពាក្យថា យេ ជេ : នែហន់នេះ គហបតីហៅនាងទាសី ។

ពាក្យថា ហិយ្យោ ខោ អាវុសោ អម្ហាកំ : ម្នាលអាវុសោ ( ចង្ហាន់សង្ឃបានសម្ដែងឡើងហើយ ) ដល់យើងទាំងឡាយ អំពីថ្ងៃម្សិលមិញ មានសេចក្ដីថា ភិក្ខុមេត្តិយៈនិងភុម្មជកៈ ប្រឹក្សាគ្នារហូតដល់អស់រាត្រី ពោលសំដៅដល់ចំណែកនៃថ្ងៃដែលកន្លងហើយថា ហិយ្យោ ( ថ្ងៃម្សិលមិញ ) ។

បទថា ន ចិត្តរូបំ : ក៏ដេកមិនលក់ បានដល់ មិនសមតាមចិត្តនឹកគិត ( ថាយើងនឹងសិង ) ។ ភិក្ខុទាំងពីររូបនោះសិងមិនលក់ ដូច

ដែលខ្លួនធ្លាប់សិងលក់តាមត្រូវការក្នុងកាលមុន ។ មានពាក្យអធិប្បាយថា សិងបានបន្តិចបន្តួចប៉ុណ្ណោះ ។

បទថា ពហារាមកោដ្ឋកេ : ខាងក្រៅក្លោងទ្វារវត្តវេឡុវ័ន បានដល់ ខាងក្រៅស៊ុមទ្វារនៃវេឡុវ័នវិហារ ។

បទថា បត្តក្ខន្ធា : ឱនក បានដល់ មានកធ្លាក់ គឺ អង្គុយកោងឆ្អឹងក ។

បទថា បជ្ឈាយន្តា : ជ្រប់ បានដល់ កំពុងសោកសៅ ។

[២៨៤] ពាក្យថា យតោ និវាតំ តតោ បវាតំ : ទីកន្លែងណា ដែលមិនធ្លាប់មានខ្យល់ ទីកន្លែងនោះត្រឡប់ជាមានខ្យល់ទៅវិញ មានសេចក្តីថា ក្នុងទីណាមិនធ្លាប់មានខ្យល់ គឺមិនមានខ្យល់សូម្បីតែបន្តិច, ក្នុងទីនោះកើតមានខ្យល់បក់ខ្លាំងឡើង ។

ពាក្យថា ឧទកំ មញ្ញេ អាធិត្តំ : ដូចជាទឹកធ្លាប់ត្រជាក់ប្រែជាក្តៅ បានដល់ ដូចទឹកត្រូវដាំឱ្យក្តៅ ។

## ព្រះទព្វមល្លបុត្រត្រូវដេញដោលសួរ

[២៨៥] ពាក្យថា សរសិ ត្វំ ទព្វ ឯវរូបំ កត្តា : ម្នាលទព្វៈ អ្នករលឹកឃើញឬទេ អ្នកឯងបានធ្វើយ៉ាងនោះមែនឬទេ សេចក្តីថា

ម្នាលទព្វៈ អ្នកធ្វើកម្មបែបនេះ តើរលឹកបានឬទេ ? ម្យ៉ាងទៀត សេចក្តីថា ម្នាលទព្វៈ អ្នកនៅរលឹកពាក្យតាមដែលនាងភិក្ខុនីពោលមិនបានឬ ? ក៏ក្នុងពាក្យនេះ បណ្ឌិតគប្បីប្រកបឃើញសេចក្តីយ៉ាងនេះថា លោកជាអ្នកធ្វើកម្មដូចដែលនាងភិក្ខុនីនេះពោល មែនឬទេ ? តែបាឋៈរបស់ពួកអាចារ្យដែលសូធ្យថា កត្វា ប្រាកដត្រង់តែម្តង ។

ដោយពាក្យថា យថា មំ ភន្តេ ភគវា ជានាតិ : បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គដោយពិតហើយនេះ ព្រះថេរៈទូលបង្ហាញប្រាប់ថា យ៉ាងណា ? ទូលបង្ហាញប្រាប់ថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ជាព្រះសព្វញ្ញូ និងខ្ញុំព្រះអង្គក៏ជាព្រះខីណាស្រព, ការសេពវត្ថុកាមមិនមានដល់ខ្ញុំព្រះអង្គឡើយ, ព្រះមានព្រះភាគ រមែងទ្រង់ជ្រាបខ្ញុំព្រះអង្គនោះ, ខ្ញុំព្រះអង្គនឹងត្រូវពោលអ្វី ក្នុងការសេពវត្ថុកាមនោះហ្ន៎ ? គប្បីជ្រាបខ្ញុំព្រះអង្គដូចយ៉ាងដែលព្រះមានព្រះភាគទ្រង់ជ្រាបនុ៎ះឯង" ។

ក្នុងពាក្យថា ន ខោ ទព្វ ទព្វា ឯវំ និព្វេឋេន្តិ : ម្នាលទព្វៈ អ្នកប្រាជ្ញទាំងឡាយ មិនពោលបណ្តោះបណ្តោយ៉ាងនេះទេ នេះ បណ្ឌិតគប្បីឃើញសេចក្តីយ៉ាងនេះថា ម្នាលទព្វៈ អ្នកឆ្លាត គឺ បណ្ឌិតរមែងមិនពោលបណ្តោះបណ្តោ ដូចដែលលោកពោលបណ្តោះបណ្តោពាក្យចោទសួរ

ព្រោះមាន ( ការជឿ ) អ្នកដទៃជាបច្ច័យទេ, ម្យ៉ាងទៀត បណ្ឌិតទាំងឡាយរមែងពោលបកស្រាយនូវពាក្យចោទសួរ ដោយកម្មដែលខ្លួនដឹងនោះឯងទាំងអស់ ។

ដោយពាក្យថា សចេ តយា កតំ : **បើអំពើដែលអ្នកបានធ្វើហើយ** នេះ ព្រះមានព្រះភាគទ្រង់សម្ដែងថា យ៉ាងណា ? ទ្រង់សម្ដែងថា ព្រោះថា អ្នកណា ៗ មិនអាចធ្វើបុគ្គលដែលមិនបានធ្វើ ( ខុស ) ឱ្យជាអ្នកធ្វើ ( ខុស ) ឬអ្នកធ្វើ ( ខុស ) ឱ្យជាអ្នកមិនធ្វើ ( ខុស ) ដោយកម្លាំងបរិស័ទ ឬដោយកម្លាំងស្និទ្ធស្នាលរបស់បក្ខពួកបាន ; ព្រោះហេតុនោះ កម្មណាដែលធ្វើដោយខ្លួនឯង ឬមិនបានធ្វើក៏ដោយ គួរនិយាយតែកម្មនោះប៉ុណ្ណោះ ។

សួរថា ក៏ព្រោះហេតុអ្វី ? ព្រះមានព្រះភាគ សូម្បីទ្រង់ជ្រាបហើយតែមិនត្រាស់ថា "តថាគតដឹងប្រាកដ លោកជាព្រះខីណាស្រព, ទោសរបស់លោកមិនមាន, ភិក្ខុនីនេះពោលកុហក" ។

ឆ្លើយថា ព្រោះទ្រង់មានសេចក្ដីអាណិតអ្នកដទៃ ។ ក៏បើថា ព្រះមានព្រះភាគគប្បីត្រាស់គ្រប់ ៗ រឿងដែលព្រះអង្គទ្រង់ជ្រាប, ព្រះអង្គត្រូវអ្នកដទៃដែលត្រូវអាបត្តិបារាជិកហើយសួរ ចាំបាច់ត្រូវត្រាស់ពាក្យថា តថាគតដឹងប្រាកដ, អ្នកជាបារាជិក ។ បន្ទាប់ពីនោះ បុគ្គលនោះគប្បីចងអាឃាតថា "កាលមុនព្រះមានព្រះភាគនេះ ទ្រង់ធ្វើឱ្យព្រះទព្វមល្លបុត្រ

បរិសុទ្ធិបាន ឥឡូវនេះ ទ្រង់ធ្វើយើងឱ្យជាអ្នកបរិសុទ្ធិមិនបាន, តទៅនេះ យើងនឹងនិយាយអ្វីដល់អ្នកណាបានហ្ន៎ ? សូម្បីក្នុងឋានៈដែលជាព្រះសាស្តា ក៏ទ្រង់នៅតែដល់សេចក្តីលំអៀងក្នុងពួកសាវក, ភាពជាព្រះសព្វញ្ញូរបស់ព្រះសាស្តានេះ នឹងមានមកពីទីណាហ្ន៎” ដូច្នេះហើយ ត្រូវជាអ្នកចូលដល់អបាយ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ជ្រាបហើយ ក៏មិនត្រាស់ ព្រោះទ្រង់មានសេចក្តីអាណិតអ្នកដទៃនេះ ។ មានពាក្យដែលគួរពោលបន្ថែមបន្តិចបន្តួចទៀត, ព្រះមានព្រះភាគមិនត្រាស់ព្រោះទ្រង់ចៀសវាងពាក្យតិះដៀល ។

ក៏បើថា ព្រះមានព្រះភាគ គប្បីត្រាស់យ៉ាងនេះ, នឹងមានការពោលតិះដៀលយ៉ាងនេះថា “ឈ្មោះថា ការចេញចាកអាបត្តិរបស់ព្រះទព្វមល្លបុត្រធ្ងន់, តែបានព្រះសម្មាសម្ពុទ្ធជាសាក្សី ទើបចេញបាន” ។ មួយទៀត ពួកបាបភិក្ខុយល់លក្ខណៈនៃការចេញចាកអាបត្តិនេះ យ៉ាងនេះថា “សូម្បីក្នុងសម័យពុទ្ធកាលសេចក្តីបរិសុទ្ធិ ឬមិនបរិសុទ្ធិ រមែងមានដោយសាក្សី, ពួកយើងដឹងប្រាកដ, បុគ្គលនេះជាអ្នកមិនបរិសុទ្ធិ” ដូច្នេះ គប្បីធ្វើឱ្យភិក្ខុ សូម្បីអ្នកមានសេចក្តីខ្មាសវិនាសឯង ។ ន័យមួយទៀត សូម្បីក្នុងអនាគត ពួកភិក្ខុកាលរឿងវិនិច្ឆ័យហើយ នឹងឱ្យភិក្ខុអ្នកចោទចោទ ហើយឱ្យភិក្ខុអ្នកជាប់ចោទឱ្យរលឹកថា បើលោកធ្វើ ចូរពោលថា

"ខ្ញុំព្រះករុណា ធ្វើ" ហើយកាន់យកតែបដិញ្ញារបស់ពួកលជ្ជីភិក្ខុ ធ្វើកម្ម; ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទឹងទ្រង់តាំងបែបផែនក្នុងលក្ខណៈនៃវិន័យ ទើបមិនត្រាស់ថា "តថាគតដឹងប្រាកដ" ត្រាស់ថា "បើលោកធ្វើ ចូរពោលថា ខ្ញុំព្រះករុណាធ្វើ" ដូច្នេះ ។

ពាក្យថា ឆាភិជានាមិ សុបិនន្តេនបិ មេថុនំ ធម្មំ បដិសេវិតា : ខ្ញុំព្រះអង្គ សូម្បីយល់សប្តិសេពមេថុនធម្ម ក៏មិនដែលស្គាល់សោះឡើយ មានសេចក្តីថា សូម្បីដោយការយល់សប្តិខ្ញុំព្រះអង្គ ក៏នៅមិនស្គាល់ការសេពមេថុនធម្ម ។ មានពាក្យអធិប្បាយថា ខ្ញុំព្រះអង្គមិនបានសេព ។ ម្យ៉ាងទៀត មានសេចក្តីបញ្ជាក់ដែលលោកពោលទុកថា "ខ្ញុំព្រះអង្គ សូម្បីតែយល់សប្តិសេពមេថុនធម្ម ក៏មិនដែលស្គាល់សោះឡើយ" ។ តែបាលីរបស់ពួកអាចារ្យអ្នកសូធ្យថា បដិសេវិត្វា ប្រាកដត្រង់តែម្តង ។

ពាក្យថា បគេវ ជាគរោ : នឹងបាច់ពោលទៅថ្វីដល់ការរលឹក (នោះ) មានសេចក្តីថា សូម្បីខ្ញុំព្រះអង្គនៅភ្ញាក់ ក៏មិនស្គាល់មកពីមុនទុំះឯង ។

ពាក្យថា តេនហិ ភិក្ខវេ មេត្តិយំ ភិក្ខុនឹ ឆាសេថ : ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរឱ្យមេត្តិយាភិក្ខុនីសឹកចេញ

មានពាក្យអធិប្បាយថា ព្រោះពាក្យរបស់ព្រះទព្វមល្លបុត្រ និងភិក្ខុនី មេត្តិយានេះ មិនជាប់គ្នា ; បើដូច្នោះ អ្នកទាំងឡាយ ចូរឱ្យមេត្តិយាភិក្ខុនីសឹកចេញ ។ ក្នុងពាក្យនោះ នាសនៈមាន ៣ យ៉ាង គឺ លិង្គនាសនៈ១ សំវាសនាសនៈ ១ ទណ្ឌកម្មនាសនៈ ១ ។ បណ្ដានាសនៈទាំងនោះ នាសនៈនេះថា "សង្ឃត្រូវឱ្យវិនាសតែភិក្ខុសាមណេរដែលប្រទូស្ត"[១] ឈ្មោះថា **លិង្គនាសនៈ** ។ "ពួកភិក្ខុធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិក្ដី មិនសម្ដែងអាបត្តិក្ដី ព្រោះមិនលះបង់ទិដ្ឋិលាមកចេញក្ដី"[២] នេះឈ្មោះថា **សំវាសនាសនៈ** ។ ពួកភិក្ខុធ្វើទណ្ឌកម្ម (ដល់សមណុទ្ទេស) ថា "នែមនុស្សក្រៅការ អ្នកឯងចូរចៀសចេញទៅ ចូរវិនាសទៅ"[៣] នេះឈ្មោះថា ទណ្ឌកម្មនាសនៈ ។ តែក្នុងឋានៈនេះ ព្រះមានព្រះភាគទ្រង់សំដៅយកលិង្គនាសនៈ ទើបត្រាស់ថា "អ្នកទាំងឡាយ ចូរឱ្យមេត្តិយាភិក្ខុនី សឹកចេញ" ដូច្នេះ ។

ដោយពាក្យថា ឥមេ ច ភិក្ខូ អនុយុញ្ជថ :ម្យ៉ាងទៀត អ្នកទាំងឡាយ ចូរសាកសួរភិក្ខុទាំងឡាយនេះមើល នេះ ព្រះមានព្រះភាគទ្រង់សម្ដែងព្រះបំណងនេះថា ភិក្ខុនីនេះ មិនមែនអ្នកធ្វើតាមធម្មតារបស់

១. វិន. បារា. មេថុនធម្មសិក្ខាបទ. ១. ៤៦/១១១ ។ ២. វិន. មហា. បញ្ចសតិកក្ខន្ធកៈ. ៨. ១៣២/២៧៥៨ ។ ៣. វិន. បាចិ. សប្បាណកវគ្គ. ៤. ២៩១/២៩៩ ។

ខ្លួន, គង់ត្រូវពួកភិក្ខុដទៃញុះញង់ពិតប្រាកដ; ព្រោះហេតុនោះ ពួកលោកចូរដេញដោលសួរ គឺចូរស្វែងរក ចូរដឹងភិក្ខុដែលញុះញង់ទាំងនេះ ។

សួរថា ក៏ភិក្ខុនីមេត្តិយា ព្រះមានព្រះភាគទ្រង់ត្រាស់ឱ្យសឹកចេញដោយបដិញ្ញា ឬទ្រង់ឱ្យសឹកដោយមិនប្ដេជ្ញា ។

ឆ្លើយថា ក្នុងការព្រមាននេះ មានពាក្យដែលនឹងត្រូវពោលបន្ថែមខ្លះបន្តិចបន្តួច, ដំបូងបើទ្រង់ឱ្យសឹកដោយបដិញ្ញា, ព្រះថេរៈជាអ្នកធ្វើ ( ខុស ), បើទ្រង់ឱ្យសឹកដោយមិនប្ដេជ្ញា, ព្រះថេរៈជាអ្នកមិនធ្វើ ( ខុស ) មិនមានទោស ។

## យល់អត្ថន័យព្រះវិន័យខុស ព្រមព្រៀងគ្នាមិនបាន

សូម្បីក្នុងកាលនៃព្រះបាទភាតិយរាជ ព្រះថេរៈស្នាក់នៅឯមហាវិហារ និងអភ័យគិរីវិហារ បានមានការវិវាទគ្នា ( ទាស់ទែងគ្នា ) ព្រោះតែវាទៈនេះឯង ។ ចំណែកភិក្ខុនៅអភ័យគិរីវិហារ អាងសូត្ររបស់ខ្លួនពោលថា ក្នុងវាទៈរបស់ពួកលោក ព្រះថេរៈជាអ្នកធ្វើ ( ខុស ) ។ ចំណែកភិក្ខុខាងមហាវិហារអាងសូត្ររបស់ខ្លួនពោលថា ក្នុងវាទៈរបស់ពួកលោក ព្រះថេរៈជាអ្នកមិនធ្វើ ( ខុស ) ។ បញ្ហាទើបព្រមព្រៀងគ្នាមិនបាន ។ ព្រះរាជាទ្រង់ជ្រាប ( ដំណឹងនោះ ) ហើយត្រាស់ឱ្យព្រះថេរៈ

ទាំងឡាយប្រជុំគ្នា ទ្រង់បង្គាប់អាមាត្យជាតិព្រាហ្មណ៍នាមថា ទីយការាយនៈថា លោកចូរស្តាប់ ពាក្យរបស់ព្រះថេរៈទាំងឡាយ ។ បានឮថា អាមាត្យជាបណ្ឌិត ឆ្លាតក្នុងភាសាដទៃ ។ អាមាត្យនោះពោលថា លោកម្ចាស់ សូមព្រះថេរៈពោលសូត្រចុះ ។ លំដាប់នោះ ព្រះថេរៈខាងអភ័យគិរីវិហារ បានពោលសូត្ររបស់ខ្លួនថា "ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរឱ្យមេត្តិយា ភិក្ខុនីសឹកចេញ ដោយបដិញ្ញារបស់ខ្លួន" ។ អាមាត្យឆ្លើយប្រាប់ថា ព្រះគុណម្ចាស់ដ៏ចម្រើន ក្នុងវាទៈរបស់ពួកលោក ព្រះថេរៈជាអ្នកធ្វើ ( ខុស ) មានទោស ។

ចំណែកព្រះថេរៈខាងមហាវិហារ បានពោលសូត្ររបស់ខ្លួនថា "ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ពួកលោកចូរឱ្យនាងភិក្ខុនីមេត្តិយាសឹកចេញ" ។ អាមាត្យឆ្លើយប្រាប់ថា ព្រះគុណម្ចាស់ដ៏ចម្រើន ក្នុងវាទៈរបស់ពួកលោក ព្រះថេរៈមិនមែនអ្នកធ្វើ ( ខុស ) មិនមានទោស ។ ក៏ក្នុង២ សូត្រនេះ សូត្រណាត្រូវហ្ន៎ ? សូត្រដែលពោលខាងក្រោយត្រូវ, ព្រោះសូត្រនេះ ព្រះអដ្ឋកថាចារ្យទាំងឡាយពិចារណាទុកហើយ ។

ភិក្ខុតាមកម្ចាត់ភិក្ខុដោយអន្តិមវត្ថុ ដែលមិនមានមូល ជាសង្ឃាទិសេស, តាមកម្ចាត់នាងភិក្ខុនី ត្រូវអាបត្តិទុក្កដ ។ តែក្នុងកុរុន្ទីពោលថា ត្រូវអាបត្តិបាចិត្តិយ ព្រោះមុសាវាទ ។ ក្នុងន័យមុន និងន័យក្រោយនោះ មានការពិចារណាដូចតទៅនេះ ៖

ន័យដើម ត្រឹមតែត្រូវអាបត្តិទុក្កដប៉ុណ្ណោះ ត្រូវមុន ព្រោះមានសេចក្តីប្រាថ្នានឹងតាមកម្ចាត់ ។ សួរថាកាលមានការពោលកុហក ក៏ជាសង្ឃាទិសេសដល់ភិក្ខុ ព្រោះភិក្ខុផងគ្នា និងសួរថាកាលមានការពោលកុហក ក៏ត្រូវអាបត្តិបាចិត្តិយ ព្រោះឱមសវាទប៉ុណ្ណោះ ដល់ភិក្ខុដែលមានសេចក្តីឃើញថា "បរិសុទ្ធិ" ចោទភិក្ខុដែលមិនបរិសុទ្ធិ ដោយសេចក្តីប្រាថ្នានឹងជេរ មិនមែនត្រូវអាបត្តិបាចិត្តិយ ព្រោះសម្បជានមុសាវាទទេយ៉ាងណា, សួរថាក្នុងអធិការនេះ ក៏យ៉ាងនោះ ត្រូវអាបត្តិបាចិត្តិយ ព្រោះសម្បជានមុសាវាទ មិនត្រឹមត្រូវទេ ព្រោះមានសេចក្តីប្រាថ្នានឹងតាមកម្ចាត់ ។ ត្រឹមតែជាអាបត្តិទុក្កដប៉ុណ្ណោះ ត្រូវហើយ ។ សួរថាន័យក្រោយ ត្រូវអាបត្តិបាចិត្តិយតែម្យ៉ាង ក៏ត្រូវព្រោះជាមុសាវាទ ។ តែដោយប្រមាណព្រះបាលី ត្រូវអាបត្តិសង្ឃាទិសេសដល់ភិក្ខុ ព្រោះភិក្ខុផងគ្នា ដោយសេចក្តីប្រាថ្នានឹងតាមកម្ចាត់, មួយទៀត ត្រូវឱមសវាទព្រោះមានបំណងនឹងជេរ និង មិនមានពាក្យថា ត្រូវអាបត្តិទុក្កដដល់ភិក្ខុព្រោះតាមកម្ចាត់នាងភិក្ខុនី, មានពាក្យថា ជាអាបត្តិបាចិត្តិយៈ ព្រោះសម្បជានមុសាវាទ; ព្រោះហេតុនោះ ត្រូវអាបត្តិបាចិត្តិយៈតែម្យ៉ាង ទើបត្រូវ ។

ក៏ក្នុងវាទៈនោះ បណ្ឌិតគួរពិចារណា ដូចតទៅនេះ ៖

សួរថា កាលមិនមានសេចក្តីប្រាថ្នានឹងតាមកម្ចាត់ ( ចោទ ) ត្រូវ

អាបត្តិបាចិត្តិយ, កាលមានបំណងនឹងតាមកម្ចាត់នោះនឹងជាអ្វីហ្ន៎ ?

ឆ្លើយថា បណ្តាអាបត្តិបាចិត្តិយ និងសង្ឃាទិសេសនោះ ព្រោះសូម្បីកាលសម្រេចជាបាចិត្តិយ ដល់ភិក្ខុដែលនិយាយកុហកព្រះមានព្រះភាគ ក៏ទ្រង់ពិន័យបាចិត្តិយទុកដទៃផ្សេង ព្រោះការចោទ ដោយសង្ឃាទិសេសមិនមានមូល; ព្រោះដូច្នោះ កាលមានសេចក្តីប្រាថ្នានឹងចោទ ឱកាសនៃបាចិត្តិយ ព្រោះសម្បជានមុសាវាទ ទើបមិនប្រាកដ និងមិនអាចថា មិនត្រូវអាបត្តិដល់ភិក្ខុអ្នកចោទ ; ព្រោះដូច្នោះ បណ្តាន័យទាំងពីរនេះ ន័យដើមប្រាកដថា បរិសុទ្ធិជាង ។

មួយទៀត នាងភិក្ខុនីចោទនាងភិក្ខុនីដោយអន្តិមវត្ថុដែលមិនមានមូល ត្រូវអាបត្តិសង្ឃាទិសេស, ចោទភិក្ខុ ត្រូវអាបត្តិទុក្កដ ។ បណ្តាអាបត្តិសង្ឃាទិសេស និងទុក្កដនោះ អាបត្តិសង្ឃាទិសេស ជាវុដ្ឋានគាមី (ចេញបានដោយការប្រព្រឹត្តកម្ម) អាបត្តិទុក្កដ ជាទេសនាគាមី (ចេញបានដោយការសម្តែង) ការនាសនៈភិក្ខុនី ព្រោះអាបត្តិសង្ឃាទិសេស និងអាបត្តិទុក្កដទាំងនេះ ទើបមិនមាន ។ មួយទៀត នាងភិក្ខុនីមេត្តិយានោះ ឈរពោលកុហកចំពោះព្រះភក្ត្រព្រះមានព្រះភាគណាហ្ន៎ ព្រោះហេតុនោះ នាងទើបត្រូវអាបត្តិបាចិត្តិយ ព្រោះសម្បជានមុសាវាទ, សូម្បីព្រោះបាចិត្តិយនេះ នាសនៈក៏មិនមាន ។ តែព្រោះនាងភិក្ខុនីមេត្តិយានោះតាមប្រក្រតី ក៏ជាភិក្ខុនីអាក្រក់ទ្រុស្តសីល, និងឥឡូវនេះ នាងក៏ពោល

ដោយសម្គាល់ថា "យើងហ្នឹងឯង ជាអ្នកទ្រុស្តសីល", ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់បង្គាប់ឱ្យផ្សឹកនាងភិក្ខុនីនោះចេញ ព្រោះភាព ជាអ្នកមិនបរិសុទ្ធិនុះឯង ។

ពាក្យថា **អជេហ មេត្តិយភុម្មជ្ជកា : ទើបមេត្តិយភិក្ខុនិង ភុម្មជ្ជកភិក្ខុ** មានសេចក្តីថា កាលព្រះមានព្រះភាគត្រាស់ថា "អ្នកទាំង ឡាយ ចូរឱ្យនាងមេត្តិយា ភិក្ខុនីសឹកចេញ ម្យ៉ាងទៀត អ្នកទាំងឡាយ ចូរសាកសួរភិក្ខុទាំងនេះមើល" ហើយស្តេចក្រោកចាកអាសនៈចូលកាន់ វិហារ ។ ភិក្ខុទាំងនោះ ឃើញភិក្ខុនីនោះ ត្រូវភិក្ខុទាំងនោះកំពុងឱ្យសឹក ដោយពាក្យថា ពួកលោកចូរឱ្យសំពត់សដល់ភិក្ខុនីនេះ ឥឡូវនេះ ទើប បានប្រកាសសេចក្តីខុសរបស់ខ្លួន ព្រោះជាអ្នកមានសេចក្តីប្រាថ្នានឹងជួយ នាងភិក្ខុនីនោះឱ្យផុតពីកំហុស ។ ដើម្បីសម្តែងសេចក្តីនេះ ព្រះធម្មសង្គា ហកាចារ្យទាំងឡាយ ទើបពោលពាក្យថា **អជេហ មេត្តិយភុម្មជកាជា** ដើម ។

## ពន្យល់អត្ថក្នុងសិក្ខាបទវិភង្គសង្ឃាទិសេសទី ៨

[២៨៦] ពីរបទថា **ទុដ្ឋោ ទោសោ : មានសេចក្តីក្រោធប្រទូស្ត** បានដល់ ជាអ្នកត្រូវទោសៈប្រទូសរ៉ាយ និងជាអ្នកប្រទូសរ៉ាយ ។ ពិត

មែន កាលទោសៈកើតឡើងហើយ បុគ្គលរមែងជាអ្នកឈ្មោះថា ត្រូវទោសៈនោះប្រទូសរ៉ាយហើយ គឺ ឱ្យលះភាពជាប្រក្រតីចេញ ; ព្រោះដូច្នោះ លោកទើបហៅថា ទុដ្ឋៈ (ប្រទូស្ត) ។ និងអ្នកមានសេចក្ដីប្រទូស្តនោះ រមែងប្រទូសរ៉ាយអ្នកដទៃ គឺ ធ្វើអ្នកដទៃឱ្យវិនាស ; ព្រោះដូច្នោះ លោកទើបហៅថា ទោសៈ ។ ដោយប្រការយ៉ាងនេះ ពាក្យថា ទុដ្ឋោ ទោសោ នេះ សម្ដែងដោយសេចក្ដីផ្សេងនៃអាការរបស់បុគ្គលត្រឹមតែម្នាក់ ព្រោះហេតុនោះ លោកទើបពោលថា "ពីរបទថា ទុដ្ឋោ ទោសោ : មានសេចក្ដីក្រោធប្រទូស្ត បានដល់ ជាអ្នកត្រូវទោសៈប្រទូសរ៉ាយ និងជាអ្នកប្រទូសរ៉ាយ" ។ ក្នុងពាក្យថា ទុដ្ឋោ ទោសោ នោះ អ្នកសិក្សា គួរស្វែងរកលក្ខណៈនៃសព្ទ ។ ក៏ព្រោះថា បុគ្គលដែលតាំងនៅក្នុងភាពជាអ្នកក្រោធជាដើមតែម្ដង ; ព្រោះហេតុនោះ ក្នុងបទភាជនៈនៃពីរបទថា ទុដ្ឋោ ទោសោ នោះ ទើបលោកពោលពាក្យ មានពាក្យថា កុបិតោ : ខឹង ជាដើម ។

បណ្ដាបទទាំងនោះ បទថា កុបិតោ : ខឹង បានដល់ ភាវៈកម្រើក គឺ ដែលឃ្លាតចាកភាពប្រក្រតី ។

បទថា អនត្តមនោ : អន់ចិត្ត បានដល់ អ្នកមិនមានចិត្តជារបស់ខ្លួន គឺ មានចិត្តមិនតាំងនៅក្នុងអំណាចរបស់ខ្លួន ។ម្យ៉ាងទៀត អ្នកមាន

ចិត្តដែលបីតិ និងសុខមិនផ្សព្វផ្សាយ គឺ មានចិត្តធ្លាក់ចេញពីបីតិនិងសុខទៅ; ព្រោះហេតុនោះ ទើបឈ្មោះថា អនត្តមនៈ (មិនត្រូវចិត្ត) ។

បទថា អនភិរទ្ធោ : **មិនត្រេកអរ** គឺ មិនប្រសព្វសេចក្ដីសុខ, ម្យ៉ាងទៀត អ្នកមិនដល់ សេចក្ដីភ្លឺថ្លា ; ដូច្នោះ ទើបឈ្មោះថា អនភិរទ្ធៈ (មិនពេញចិត្ត) ។ ចិត្តរបស់គេនោះ ត្រូវបដិឃៈប៉ះខ្ទប់ហើយ ; ហេតុនោះ គេទើបឈ្មោះថា **អាហតចិត្ត** : មានចិត្តគឺទោសៈខ្ទាំងខ្ទប់ ។ ចម្រើង គឺ បដិឃៈ ពោលគឺ សេចក្ដីដែលចិត្តរឹងកំព្រឹសនិងចិត្តសាំញ៉ាំដូចសម្រាម កើតហើយដល់បុគ្គលនោះ ; ព្រោះដូច្នោះអ្នកនោះ ទើបឈ្មោះថា **ខិលជាត** : មានចិត្តចង្អៀតចង្អល់ ។

បទថា អប្បតីតោ : **មានចិត្តអាក់អន់** បានដល់ មិនដល់ចំពោះ (មិនរីករាយ) គឺ វៀរចាកបីតិ និងសុខជាដើម, សេចក្ដីថា ដែលបីតិនិងសុខជាដើមមិនជ្រួតជ្រាប ។ តែក្នុងបទភាជនៈព្រះឧបាលីពោលថា តេន ច កោបេន : **ព្រោះសេចក្ដីខឹងនោះផងជាដើម** ដើម្បីសម្ដែងធម៌ទាំងឡាយ ដែលមានអំណាចធ្វើមិនឱ្យរីករាយស្រស់ថ្លា ។

បណ្ដាបទទាំងនោះ ពាក្យថា តេន ច កោបេន : **ព្រោះសេចក្ដីខឹងនោះផង** បានដល់ ព្រោះសេចក្ដីក្រោធដែលជាហេតុឱ្យហៅភិក្ខុនោះថា អ្នកមានសេចក្ដីទាស់ចិត្ត និងក្រោធ ។ ពិតមែន ពាក្យទាំង

ពីរនេះ ជាអាការតែមួយដូចគ្នា ព្រោះឱ្យលះភាពប្រក្រតី ។

ពាក្យថា តេន ច ទោសេន : ព្រោះទោសៈនោះផង បានដល់ ព្រោះទោសៈដែលជាហេតុឱ្យហៅភិក្ខុនោះថា មានទោសៈ ។ ដោយបទទាំង ២ នេះ ព្រះឧបាលីសម្តែងសង្ការក្ខន្ធ ដូចគ្នា ។

ពាក្យថា តាយ ច អនត្តមនតាយ : ព្រោះអន់ចិត្តនោះផង បានដល់ ព្រោះសេចក្តីមិនត្រូវចិត្តដែលជាហេតុឱ្យហៅភិក្ខុនោះថា អ្នកអន់ចិត្ត ។

ពាក្យថា តាយ ច អនភិរទ្ធិយា : ព្រោះមិនត្រេកអរនោះផង បានដល់ ព្រោះសេចក្តីមិនពេញចិត្ត ដែលជាហេតុឱ្យហៅភិក្ខុនោះថា អ្នកមិនត្រេកអរ ។ ដោយពាក្យទាំងពីរនេះព្រះឧបាលីសម្តែងវេទនាខន្ធ ។

## អធិប្បាយរឿងអធិករណ៍មានមូលនិងមិនមានមូល

ក្នុងពាក្យថា អមូលកេន បារាជិកេន : ដោយអាបត្តិបារាជិក មិនមានមូល នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

បារាជិកនោះ មិនមានមូល ; ព្រោះហេតុនោះ ទើបឈ្មោះថា អមូលកៈ ។ ក៏សេចក្តីដែលបារាជិកនោះ មិនមានមូលនោះ ទ្រង់ប្រាថ្នា យកដោយអំណាចនៃអ្នកចោទ មិនមែនដោយអំណាចនៃអ្នកជាប់ចោទ ;

ព្រោះដូច្នោះ ដើម្បីទ្រង់សម្តែងសេចក្តីនោះ ក្នុងបទភាជនៈព្រះឧបាលីទើបពោលថា ដែលឈ្មោះថា មិនមានមូល គឺ មិនបានឃើញ មិនបានឮ មិនបានរង្កៀស ។

ដោយបទភាជនៈថា អទិដ្ឋំ : មិនឃើញ ជាដើមនោះ លោកសម្តែងអធិប្បាយទុកថា បារាជិកដែលអ្នកចោទ មិនបានឃើញ មិនបានឮ មិនបានរង្កៀស ក្នុងខ្លួនបុគ្គលដែលជាប់ចោទ ឈ្មោះថា មិនមានមូល ព្រោះមិនមានមូល ពោលគឺ ការឃើញ ការបានឮ និងការរង្កៀសនេះ ។ ក៏អ្នកជាប់ចោទនោះ នឹងត្រូវបារាជិកនោះ ឬមិនត្រូវក៏ដោយ, ការដែលអ្នកជាប់ចោទត្រូវ ឬមិនត្រូវនេះ មិនជាប្រមាណក្នុងសិក្ខាបទនេះ ។

ក្នុងបទថា អទិដ្ឋំ ជាដើមនោះ ដែលឈ្មោះថា មិនបានឃើញ គឺ មិនបានឃើញដោយចក្ខុប្រសាទ ឬដោយទិព្វចក្ខុរបស់ខ្លួន ។ ឈ្មោះថា មិនបានឮ គឺ មិនបានឮអ្នកណាមួយ គេនិយាយគ្នាយ៉ាងនោះ ។ ដែលឈ្មោះថា មិនបានរង្កៀស គឺ មិនបានរង្កៀសដោយចិត្ត ។

ដែលឈ្មោះថា **បានឃើញ** គឺ ខ្លួនឯង ឬអ្នកដទៃបានឃើញដោយចក្ខុប្រសាទ ឬដោយទិព្វចក្ខុ ។ ដែលឈ្មោះថា **បានឮ** គឺ បានឮមកដូចយ៉ាងដែលបានឃើញនុ៎ះឯង ។

ដែលឈ្មោះថា បានវង្វៀស គឺ ខ្លួនឯង ឬអ្នកដទៃវង្វៀស ។ ក្នុងរឿងបានឃើញជាដើម ខ្លួនឯងបានឃើញមក ទើបឈ្មោះថា បានឃើញ ។ តែលក្ខណៈទាំងអស់នេះ គឺអ្នកដទៃបានឃើញខ្លួនឯងបានឮ អ្នកដទៃបានឮ អ្នកដទៃបានវង្វៀស តាំងនៅក្នុងឋានដែលខ្លួនបានឮមកប៉ុណ្ណោះ ។ ក៏រឿងដែលវង្វៀសមាន ៣ យ៉ាង គឺ វង្វៀសដោយអំណាចបានឃើញ ១ វង្វៀសដោយអំណាចបានឮ ១ វង្វៀសដោយអំណាចបានជ្រាប ១ ។ ក្នុងរឿងវង្វៀស ៣ យ៉ាងនោះ ដែលឈ្មោះថា វង្វៀសដោយអំណាចបានឃើញ គឺ ភិក្ខុមួយរូបចូលទៅកាន់គុម្ពឈើមួយជិតស្រុក ដោយការបន្ទោបង់ឧច្ចារៈនិងបស្សាវៈ, ស្រីសូម្បីអ្នកណាមួយ ក៏ចូលទៅកាន់គុម្ពឈើនោះ ដោយករណីយកិច្ចយ៉ាងណាមួយដូចគ្នា ហើយត្រឡប់ទៅ, ទាំងភិក្ខុក៏មិនបានឃើញមនុស្សស្រី ទាំងមនុស្សស្រីក៏មិនបានឃើញភិក្ខុ, ទាំងពីរនាក់ក៏ចៀសទៅតាមពេញចិត្ត មិនបានឃើញគ្នាឡើយ, ភិក្ខុមួយរូបទៀត កំណត់ចំណាំយកអាការដែលអ្នកទាំងពីរ ចេញទៅពីគុម្ពឈើនោះ ទើបវង្វៀសថា ជនទាំងនេះធ្វើកម្មហើយ ឬនឹងធ្វើពិតប្រាកដនេះ ឈ្មោះថា វង្វៀសដោយអំណាចបានឃើញ ។

ដែលឈ្មោះថា វង្វៀសដោយអំណាចបានឮ គឺ អ្នកខ្លះ ក្នុងលោកនេះ បានឮពាក្យបដិសណ្ឋារៈបែបនោះរបស់ភិក្ខុជាមួយ នឹងមាតុគ្រាម ក្នុងឱកាសដែលងងឹត ឬកំបាំង អ្នកដទៃសូម្បីមាននៅក្នុងទីជិត ក៏

មិនជ្រាបថា មាន ឬមិនមាន, គេរង្កៀសថា ជនទាំងនេះធ្វើកម្មហើយ ឬថា នឹងធ្វើពិតប្រាកដ នេះឈ្មោះថា រង្កៀសដោយអំណាចបានឮ ។

ដែលឈ្មោះថា រង្កៀសដោយអំណាចបានជ្រាប គឺ នៅពេលយប់ ពួកអ្នកលេងជាច្រើន កាន់យកផ្កាឈើ គ្រឿងក្រអូប សាច់ និងសុរាជាដើម ហើយ ទៅកាន់វិហារជាយដែនមួយកន្លែង ព្រមទាំងស្ត្រីទាំងឡាយ នាំគ្នាលេងតាមសប្បាយក្នុងមណ្ឌបឬក្នុងសាលាឆាន់ជាដើម ចោលផ្កាឈើជាដើមឱ្យខ្ចាត់ខ្ចាយ ហើយនាំគ្នាទៅ, ក្នុងថ្ងៃស្អែក ពួកភិក្ខុឃើញអាការប្លែកនោះហើយនាំគ្នាស៊ើបរកមើលថា "នេះជាកម្មរបស់អ្នកណា ?" ក៏ក្នុងបណ្តាភិក្ខុទាំងនោះ ភិក្ខុរូបខ្លះ ក្រោកឡើងពីព្រឹកព្រលឹមបដិបត្តិមណ្ឌប ឬសាលាឆាន់ដោយប្រាថ្នាវត្តជាធំ ចាំបាច់ត្រូវចាប់ពាល់ផ្កាឈើជាដើម, រូបខ្លះត្រូវធ្វើការបូជាដោយផ្កាឈើជាដើម ដែលខ្លួននាំមកពីត្រកូលឧបដ្ឋាក, រូបខ្លះត្រូវផឹកថ្នាំត្រាំ ឈ្មោះថា អរិដ្ឋៈ ដើម្បីជាភេសជ្ជៈ ។ គ្រានោះ ពួកភិក្ខុទាំងនោះជាអ្នកសង្កេតរកមើលថា កម្មនេះរបស់អ្នកណា ? ទើបធុំក្លិនដៃនិងក្លិនមាត់ ហើយរង្កៀសភិក្ខុទាំងនោះ, នេះឈ្មោះថា រង្កៀសដោយអំណាចបានជ្រាប ។

ក្នុងរឿងបានឃើញជាដើមនោះ រឿងដែលបានឃើញ មានមូលក៏មាន មិនមានមូលក៏មាន, រឿងបានឃើញទុះឯង មានមូលដោយអំណាចនៃសញ្ញាក៏មាន មិនមានមូលដោយអំណាចនៃសញ្ញាក៏មាន ។ សូម្បីក្នុង

រឿងបានឮ ក៏ន័យនេះ ។ តែក្នុងរឿងដែលរង្កៀស, រឿងដែលរង្កៀស ដោយអំណាចបានឃើញ មានមូលក៏មាន, មិនមានមូលក៏មាន, រឿង ដែលរង្កៀសដោយអំណាចបានឃើញនុ៎ះឯង មានមូលដោយអំណាចនៃ សញ្ញាក៏មាន, មិនមានមូលដោយអំណាចនៃសញ្ញាក៏មាន ។ ក្នុងរឿង ដែលរង្កៀសដោយការបានឮ និងការបានជ្រាបក៏ន័យនេះ ។

ក្នុងពាក្យថា មានមូលជាដើមនោះ រឿងបានឃើញដែលឈ្មោះថា មានមូល គឺ គេបានឃើញភិក្ខុត្រូវបារាជិកពិត ៗ ហើយពោលថា ខ្ញុំព្រះ ករុណាឃើញ ។ ដែលឈ្មោះថា មិនមានមូល គឺ គេឃើញភិក្ខុចេញ មកពីឱកាសកំបាំង តែមិនឃើញការប្រព្រឹត្តល្មើស ពោលថា ខ្ញុំព្រះ ករុណាឃើញ ។ រឿងដែលឃើញនុ៎ះឯង ឈ្មោះថា មានមូលដោយ អំណាចនៃសញ្ញា គឺគេត្រឹមតែបានឃើញប៉ុណ្ណោះ ជាអ្នកមានការសម្គាល់ ថា បានឃើញ ហើយចោទ ។ ដែលឈ្មោះថា មិនមានមូលដោយ អំណាចនៃសញ្ញា គឺ ក្នុងកាលខាងដើម គេឃើញការប្រព្រឹត្តល្មើស ដោយបារាជិក ខាងក្រោយត្រឡប់កើតមានការសម្គាល់ថា មិនបាន ឃើញ ។ អ្នកនោះធ្វើឱ្យមិនមានមូលដោយសញ្ញា ហើយចោទថា ខ្ញុំព្រះ ករុណាឃើញ ។ សូម្បីរឿងដែលរង្កៀសដោយអំណាចនៃការបានឮ និងបានជ្រាប ក៏គប្បីជ្រាបដោយពិស្តារតាមន័យនេះឯង ។ ក៏ក្នុង សិក្ខាបទនេះ កាលភិក្ខុចោទភិក្ខុដែលខ្លួនឃើញ សូម្បីដោយអាការគ្រប់

យ៉ាងដោយបារាជិកដែលមានមូល ឬ មានមូលដោយអំណាចនៃសញ្ញា មិនត្រូវអាបត្តិ ។ ត្រូវអាបត្តិតែចំពោះភិក្ខុដែលចោទដោយបារាជិកដែលមិនមានមូល ឬមិនមានមូលដោយអំណាចនៃសញ្ញា ។

បទថា អនុទ្ធំសេយ្យ **: ចោទ** បានដល់ គប្បីកម្ចាត់ គឺ គប្បីចោទ គម្រាម គ្របសង្កត់ ។ ក៏ព្រោះភិក្ខុចោទដោយខ្លួនឯងក្តី ប្រើឱ្យអ្នកដទៃចោទក្តី ឈ្មោះថា រមែងធ្វើការកម្ចាត់ទាំងអស់ ; ដូច្នោះ ក្នុងបទភាជនៈព្រះឧបាលី ទើបពោលថា "ចោទខ្លួនឯងក្តី ឱ្យអ្នកដទៃចោទក្តី" ។

ក្នុងពីរបទថា ចោទេតិ វា ចោទាបេតិ វា នោះ បទថា ចោទេតិ **: ចោទខ្លួនឯង** មានសេចក្តីថា ភិក្ខុចោទ(ភិក្ខុដទៃ)ដោយខ្លួនឯង ដោយពាក្យជាដើមថា "លោកត្រូវអាបត្តិបារាជិក" ដូច្នេះ ជាសង្ឃាទិសេសដល់ភិក្ខុនោះ គ្រប់ ៗ ពាក្យនិយាយ ។

បទថា ចោទាបេតិ **: ឱ្យអ្នកដទៃចោទ** មានសេចក្តីថា បង្គាប់ភិក្ខុដទៃអ្នកឈរជិតខ្លួន, ភិក្ខុដែលទទួលបង្គាប់នោះ ចោទភិក្ខុនោះ តាមពាក្យរបស់ភិក្ខុដែលបង្គាប់នោះ, ជាសង្ឃាទិសេសដល់ភិក្ខុដែលបង្គាប់ឱ្យចោទគ្រប់ ៗ ពាក្យនិយាយដូចគ្នា ។ ឯភិក្ខុដែលទទួលបង្គាប់នោះចោទថា "រឿងដែលខ្ញុំព្រះករុណាបានឃើញ បានឮមក មាន" ដូច្នេះ ក៏ជាសង្ឃាទិសេសដល់ភិក្ខុទាំងពីររូបគ្រប់ ៗ ពាក្យនិយាយដូចគ្នា ។

# អធិប្បាយលក្ខណៈនៃការចោទផ្សេងៗ

[២៥០] ក៏ឯដើម្បីសេចក្ដីឆ្លាតក្នុងប្រភេទនៃការចោទ ក្នុងសិក្ខាបទនេះ បណ្ឌិតគប្បីជ្រាបចតុក្កៈជាដើមថា "វត្ថុតែម្យ៉ាង និងអ្នកចោទក៏ម្នាក់" ជាមុនសិន ។ បណ្ដាចតុក្កៈទាំងនោះ ភិក្ខុមួយរូបចោទភិក្ខុមួយរូបដោយវត្ថុតែមួយ ។ ការចោទនេះ មានវត្ថុតែមួយ អ្នកចោទក៏តែម្នាក់ ។ ភិក្ខុមានចំនួនច្រើនជាមួយគ្នា ចោទភិក្ខុមួយរូបដោយវត្ថុមួយ ដូចពួកភិក្ខុឆព្វគ្គិយ ៥០០ រូប មានភិក្ខុមេត្តិយៈ និងភិក្ខុភុម្មជកៈជាប្រធាន ចោទព្រះទព្វមល្លបុត្រ ដូច្នោះ, ការចោទនេះ មានវត្ថុតែមួយ មានអ្នកចោទផ្សេងគ្នា ។ ភិក្ខុមួយរូប ចោទភិក្ខុមួយរូប ដោយវត្ថុច្រើន, ចោទនេះមានវត្ថុផ្សេង ៗគ្នា មានអ្នកចោទតែម្នាក់ ។ ភិក្ខុមានចំនួនច្រើនជាមួយគ្នា ការចោទភិក្ខុច្រើនរូបជាមួយគ្នា ដោយវត្ថុច្រើន, ការចោទនេះមានវត្ថុផ្សេងគ្នា មានអ្នកចោទផ្សេងគ្នា ។

សួរថា ក៏អ្នកណា រមែងបានដើម្បីចោទ អ្នកណា រមែងមិនបាន ?

ឆ្លើយថា ភិក្ខុរូបខ្លះជឿពាក្យរបស់អ្នកចោទដែលទន់ខ្សោយ រមែងមិនបានដើម្បីចោទមុន ។

ដែលឈ្មោះថា អ្នកចោទទន់ខ្សោយ គឺ កាលពួកភិក្ខុច្រើនជាមួយ

គ្នា អន្តិយប្រជុំសន្ទនាគ្នា ភិក្ខុមួយរូបនិយាយដល់វត្ថុបារាជិក ប្រារព្ធដល់ភិក្ខុមួយរូបមិនចំពោះ ។ ភិក្ខុដទៃបានឮពាក្យរបស់ភិក្ខុនោះ ទើបទៅប្រាប់ដល់ភិក្ខុសាមីខ្លួនក្រៅនេះ ។ ភិក្ខុរូបនោះ ទើបទៅរកលោក ពោលថា "បានឮថា លោកនិយាយយ៉ាងនេះ ៗ ដល់ខ្ញុំព្រះករុណាឬ ?" លោកទើបឆ្លើយថា "ខ្ញុំព្រះករុណា មិនដឹងហេតុជាយ៉ាងហ្នឹង, តែក្នុងខណៈដែលនិយាយ មានពាក្យដែលខ្ញុំព្រះករុណានិយាយមិនចំពោះ, បើខ្ញុំព្រះករុណាដឹងថា ពាក្យនិយាយនេះ នឹងកើតទុក្ខដល់លោកមានអាយុ, ខ្ញុំព្រះករុណា នឹងមិនគប្បីនិយាយពាក្យសូម្បីប៉ុណ្ណោះឡើយ" ។ នេះឈ្មោះថាអ្នកចោទទន់ខ្សោយ ។ អ្នកចោទរូបខ្លះកាន់យកពាក្យនិយាយសន្ទនានោះរបស់លោក មិនបានដើម្បីចោទភិក្ខុនោះ ។ តែព្រះមហាបទុមត្ថេរៈ មិនជឿពាក្យនេះ ពោលថា "ភិក្ខុដែលបរិបូណ៌ដោយសីល រមែងបានដើម្បីចោទភិក្ខុ ឬភិក្ខុនី និងភិក្ខុនីដែលមានសីលបរិបូណ៌, រមែងបានដើម្បីចោទចំពោះភិក្ខុនីប៉ុណ្ណោះ ដូច្នេះ ។ ចំណែកព្រះមហាសុមត្ថេរៈពោលថា "សហធម្មិកទាំង ៥ រមែងបាន" ដូច្នេះ ។ ចំណែកព្រះគោទត្តត្ថេរៈពោលថា "អ្នកណា ៗ នឹងមិនបានដើម្បីចោទក៏ទេ" ហើយអាងសូត្រនេះថា ស្តាប់ពាក្យរបស់ភិក្ខុហើយទើបចោទ, ស្តាប់ពាក្យរបស់ភិក្ខុនីហើយទើបចោទ, ។ល ។ ស្តាប់ពាក្យរបស់ពួកសាវកតិរ្ថិយហើយ ទើបចោទ ។ ក្នុងវាទៈរបស់ព្រះថេរៈទាំង ៣ រូប គប្បីពិន័យតាម

បដិញ្ញារបស់អ្នកជាប់ចោទប៉ុណ្ណោះ ។

ក៏ធម្មតាការចោទនេះ កាលភិក្ខុសូម្បីបញ្ជូនទូតក្តី សំបុត្រក្តី ដំណឹងក្តី ទៅចោទ មិនទាន់ដល់ទីបំផុតទេ ។ តែកាលបុគ្គលឈរក្នុងទីជិត ៗ ចោទដោយមេដៃ ឬដោយការបញ្ចេញវាចាប៉ុណ្ណោះ ទើបដល់ទីបំផុត ។ ពិតមែន ការពោល លាសិក្ខាបទតែម្យ៉ាង មិនដល់ទីបំផុតដោយមេដៃ ។ ចំណែកការតាមកម្ចាត់នេះ និងការអួតឧត្តរិមនុស្សធម្មដែលមិនមានពិត រមែងដល់តែម្តង ។ ភិក្ខុណា កំណត់ចោទភិក្ខុមួយរូប ក្នុងស្ថានដែលភិក្ខុពីររូបឈរជាមួយគ្នា, បើរូបដែលគេកំណត់ចោទនោះដឹងខ្លួន, ការចោទនោះ រមែងដល់ទីបំផុត, មួយរូបទៀត ដឹងមិនទាន់ដល់ទីបំផុត ។ អ្នកចោទសំដៅចោទទាំងពីររូប, មួយរូបដឹង ឬថា ដឹងទាំងពីររូបក៏ដោយ រមែងដល់ទីបំផុត ។ ក្នុងអ្នកចោទច្រើនរូបជាមួយគ្នា ក៏ន័យនេះ ។ ជាធម្មតាថា នឹងដឹងបានក្នុងវេលានោះភ្លាម ធ្វើបានលំបាក ។ តែកាលគិតនឹកដល់សេចក្តីដឹងតាមប្រក្រតី[១] ទើបដឹង ក៏ចាត់ថា ជាការដឹងបានដូចគ្នា ។ បើដឹងបានជាខាងក្រោយ មិនទាន់ដល់ទីបំផុត ។ ពិតមែន សិក្ខាបទទាំងនេះ គឺ ការលាសិក្ខា អភូតារោចនសិក្ខាបទ ទុដ្ឋុល្លវាចាសិក្ខាបទ អត្តកាមសិក្ខាបទ ទុដ្ឋទោសសិក្ខាបទនិងភូតារោចនសិក្ខាបទទាំងអស់មានសេចក្តីកំណត់ តែម្យ៉ាងដូចគ្នាទាំងអស់នោះឯង ។

# អត្ថាធិប្បាយការចោទ ២ និង ៤ យ៉ាងជាដើម

ក៏ការចោទទាំង ២ នេះ ដោយអំណាចកាយនិងវាចាយ៉ាងនេះ នៅចែកជា ៣ យ៉ាងបានទៀត គឺ ចោទតាមដែលបានឃើញ ចោទតាមដែលបានឮ ចោទតាមដែលរង្កៀស ។

នៅមានការចោទ៤ យ៉ាងទៀត គឺ ចោទដោយសីលវិបត្តិ១ ចោទដោយអាចារវិបត្តិ១ ចោទដោយទិដ្ឋិវិបត្តិ១ ចោទដោយអាជីវវិបត្តិ១ ។ បណ្ដាការចោទ ៤ យ៉ាងនោះ ការចោទ ដោយសីលវិបត្តិ គប្បីជ្រាបដោយ១ វិមតិវិនោទនីដីកា. សមយេនាតិ បកតិយា ជានទក្ខណេ, ប្រែថា ពាក្យថា សម័យ គឺ ក្នុងខណៈដឹងបានតាមប្រក្រតី ។

អំណាចកងនៃអាបត្តិធ្ងន់ ២ កង ។ ចោទដោយអាចារវិបត្តិ គប្បីជ្រាបដោយអំណាចនៃកងអាបត្តិដ៏សេស ។ ចោទដោយទិដ្ឋិវិបត្តិ គប្បីជ្រាបដោយអំណាចនៃមិច្ឆាទិដ្ឋិ និងអន្តគ្គាហិកទិដ្ឋិ ។ ចោទដោយអាជីវវិបត្តិ គប្បីជ្រាបដោយអំណាចនៃសិក្ខាបទ ៦ ដែលទ្រង់បញ្ញត្តិ ព្រោះអាជីវៈជាហេតុ ។

ការចោទនៅមាន ៤ យ៉ាងទៀត គឺ ចោទបញ្ជាក់វត្ថុ១ ចោទបញ្ជាក់អាបត្តិ១ ការហាមសំវាស១ ការហាមសាមីចិកម្ម១ ។ បណ្ដាការចោទ ៤ យ៉ាងនោះ ចោទដែលប្រព្រឹត្តទៅយ៉ាងនេះថា "លោកសេព

មេថុនធម្ម, លោកលួចទ្រព្យ, លោកសម្លាប់មនុស្ស, លោកអួតគុណវិសេសដែលមិនជាពិត” ឈ្មោះថា ចោទបញ្ជាក់វត្ថុ ។ ចោទដែលប្រព្រឹត្តទៅដោយន័យមានជាដើមយ៉ាងនេះថា “លោកត្រូវមេថុនធម្មបារាជិកបត្តិ” ឈ្មោះថា ចោទបញ្ជាក់អាបត្តិ ។ ចោទដែលប្រព្រឹត្តទៅយ៉ាងនេះថា “ឧបោសថក្តី បវារណាក្តី សង្ឃកម្មក្តី រួមនឹងលោកមិនមាន” ឈ្មោះថា ការហាមសំវាស ។ តែដោយអាការត្រឹមតែប៉ុណ្ណោះការចោទមិនទាន់ដល់ទីបំផុត ។ កាលនិយាយជាប់តដោយពាក្យជាដើមថា “លោកមិនជាសមណៈ មិនមែនពួកសក្យបុត្រ” ទើបដល់ទីបំផុត ។ ការមិនធ្វើកម្មមានការក្រាបថ្វាយបង្គំ ក្រោកទទួល ផ្គងអញ្ជលី និងបក់ផ្លិតជាដើម ឈ្មោះថា ការហាមសាមីចិកម្ម ។

ការមិនធ្វើសាមីចិកម្មនោះ គប្បីជ្រាបក្នុងវេលាដែលភិក្ខុកំពុងធ្វើការក្រាបថ្វាយបង្គំជាដើមតាមលំដាប់ មិនធ្វើដល់ភិក្ខុមួយរូប ធ្វើដល់ភិក្ខុដ៏សេស ។ ក៏ដោយអាការត្រឹមតែប៉ុណ្ណោះ ឈ្មោះថា ចោទ ។ ចំណែកអាបត្តិមិនទាន់ដល់ទីបំផុត ។ តែកាលត្រូវសួរថា “ហេតុដូចម្តេច លោកទើបមិនធ្វើការក្រាបថ្វាយបង្គំជាដើមដល់យើងហ្ន៎ ?” ហើយនិយាយជាប់ត ដោយពាក្យជាដើមថា “លោកមិនមែនសមណៈ លោកមិនមែនពួកសក្យបុត្រទាំងឡាយ” អាបត្តិទើបដល់ទីបំផុត ។ ក៏ភិក្ខុប្រាប់វត្ថុដែលខ្លួនត្រូវការដោយបបរនិងបាយជាដើម, ដោយពាក្យត្រឹមតែប៉ុណ្ណោះ មិនទាន់

ចាត់ជាការចោទ ។ ក្នុងបាតិមោក្ខដ្ឋបនក្ខន្ធកៈ ព្រះឧបាលីថេរៈពោលការចោទទុកដល់ ១១០ យ៉ាងទៀត គឺ ការចោទដែលមិនប្រកបដោយធម៌ ៥៥ ដែលប្រកបដោយធម៌ ៥៥ យ៉ាងនេះ គឺ ចាប់ផ្ដើមតាំងពីព្រះតម្រាស់ដែលត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ការបញ្ឈប់បាដិមោក្ខ មិនប្រកបដោយធម៌១, ប្រកបដោយធម៌១ ។ល។ ការបញ្ឈប់បាដិមោក្ខមិនប្រកបដោយធម៌ ១០ យ៉ាង ប្រកបដោយធម៌ ១០ យ៉ាង"[១] ។ ការចោទទាំងនោះ ជា ៣៣០ គឺ របស់ភិក្ខុដែលចោទដោយការបានឃើញខ្លួនឯង ១១០, របស់ភិក្ខុដែលចោទដោយការបានឮ ១១០, របស់ភិក្ខុដែលចោទដោយសេចក្ដីរង្កៀស ១១០ ។ ការចោទទាំងនោះ យក ៣ គុណ គឺ សម្រាប់ភិក្ខុដែលចោទដោយកាយ (៣៣០), អ្នកចោទដោយវាចា (៣៣០), អ្នកចោទដោយកាយនិងវាចា (៣៣០), ទើបរួមជា ៩៩០ ។ ការចោទទាំង ៩៩០ នោះ របស់ភិក្ខុដែលចោទដោយខ្លួនឯងក្ដី ប្រើឱ្យអ្នកដទៃចោទក្ដី មានចំនួនប៉ុណ្ណោះដូចគ្នា ; ព្រោះដូច្នោះ ទើបជាការចោទ ១,៩៨០ យ៉ាង ។ បណ្ឌិតគប្បីជ្រាបទៀតថា ការចោទមានច្រើនពាន់ ដោយអំណាចការចោទដែលមានមូលនិងមិនមានមូល ក្នុងការផ្សេងនៃមូលមានរឿងដែលបានឃើញជាដើម ។

១. វិន. ចុល្ល. បាតិមោក្ខដ្ឋបនក្ខន្ធកៈ. ១១. ១៣២/២១៩ ។

## អធិប្បាយអ្នកចោទ និងអ្នកជាប់ចោទតាមន័យអដ្ឋកថា

មួយទៀត ព្រះអដ្ឋកថាចារ្យតាំងនៅក្នុងឋានៈនេះហើយ នាំយកសូត្រជាច្រើន ដែលព្រះមានព្រះភាគត្រាស់ហើយ ក្នុងឧបាលីបញ្ចកៈជាដើម យ៉ាងនេះថា "ម្នាលឧបាលី បើភិក្ខុមានសេចក្តីប៉ុនប៉ងនឹងកាន់យកនូវអត្តាទាន(អធិករណ៍) ត្រូវកាន់យកនូវអត្តាទាន ដែលប្រកបដោយអង្គ ៥"[១] និងថា "ម្នាលឧបាលី ភិក្ខុអ្នកចោទមានប្រាថ្នានឹងចោទភិក្ខុដទៃ លុះតែតាំងធម៌ ៥ ប្រការក្នុងខ្លួនឯង ទើបគួរចោទភិក្ខុដទៃបាន"[២] ដូច្នេះ ហើយពោលលក្ខណៈអធិករណ៍ ទំនៀមរបស់អ្នកចោទ ទំនៀមរបស់អ្នកជាប់ចោទ កិច្ចដែលសង្ឃត្រូវធ្វើ និងទំនៀមរបស់ភិក្ខុអ្នកពោល (អ្នកដេញដោលសួរ) ទាំងអស់ ដោយពិស្តារទុកក្នុងអដ្ឋកថា ។ ខ្ញុំព្រះករុណានឹងពណ៌នាលក្ខណៈអធិករណ៍ជាដើមនោះ ក្នុងទីតាមដែលមកហើយនុ៎ះឯង ។

ក៏កាលរឿងត្រូវនាំចូលកណ្តាលជំនុំសង្ឃហើយ ដោយអំណាចនៃការចោទណាមួយ បណ្តាការចោទដែលមានប្រភេទ ដូចពោលហើយនេះ សង្ឃគប្បីសួរអ្នកចោទ និងអ្នកជាប់ចោទថា "ពួកលោកពេញចិត្តដោយការវិនិច្ឆ័យរបស់ពួកយើងឬ ?" បើអ្នកចោទនិងអ្នកជាប់ចោទពោលថា

១.២. វិន. ចុល្ល.បាតិមោក្ខដ្ឋបនក្ខន្ធកៈ. ១១. ១៦៣/២៤២, ១៦៩/២៤៩ ។

“ពួកខ្ញុំព្រះករុណាពេញចិត្ត” សង្ឃគប្បីទទួលអធិករណ៍នោះ ។ តែបើទាំងពីរចំណែកពោលថា “សូមពួកលោកវិនិច្ឆ័យសិនចុះ លោកម្ចាស់ បើការវិនិច្ឆ័យនោះគួរដល់ពួកខ្ញុំព្រះករុណា, ពួកខ្ញុំព្រះករុណាព្រមទទួល”, គប្បីពោលពាក្យមានជាដើមថា “ពួកលោកចូរថ្វាយបង្គំព្រះចេតិយសិន” ហើយគប្បីវិសជ្ជនាធ្វើព្រះសូត្រឱ្យវែង ។ បើពួកលោកនៀយហត់ហួតដល់អស់រាត្រីយូរ ជាអ្នកមានបរិស័ទចៀសចេញទៅជាច់បក្ខពួក ទើបសូមអង្វរថ្មី, ព្រះវិន័យធរគប្បីហាមឃាត់ ៣ ដង ហើយគប្បីវិនិច្ឆ័យអធិករណ៍របស់ពួកលោក ក្នុងវេលាពួកលោកអស់មានះ( សេចក្តីក្រអឺតក្រទម ) ។ និងពួកភិក្ខុដែលសង្ឃសន្មតកាលទឹងវិនិច្ឆ័យ បើមានបរិស័ទច្រើនដោយពួកអលជ្ជី, គប្បីវិនិច្ឆ័យអធិករណ៍នោះ ដោយឧព្វាហិកាញត្តិ, បើបរិស័ទច្រើនដោយពួកជនពាល, គប្បីពោលថា ពួកលោកចូរស្វែងរកព្រះវិន័យធរ ដែលពេញចិត្តរបស់ពួកលោក ៗ ចុះ ឱ្យស្វែងរកព្រះវិន័យធរដោយខ្លួនឯង ហើយគប្បីរម្ងាប់អធិករណ៍នោះ ដោយធម៌ ដោយវិន័យ ដោយសត្ថុសាសនៈ ដែលជាគ្រឿងរម្ងាប់អធិករណ៍នោះ ។

ក៏ក្នុងធម្មវិន័យនិងសត្ថុសាសនៈនោះ រឿងដែលពិត ឈ្មោះថាធម៌ ។ ការចោទនិងការឱ្យរលឹក ឈ្មោះថា វិន័យ ។ ញត្តិសម្បត្តិ និងអនុស្សាវនាសម្បត្តិឈ្មោះថា សត្ថុសាសនៈ ។ ព្រោះដូច្នោះ កាលអ្នកចោទលើករឿងឡើង ព្រះវិន័យធរគប្បីសួរអ្នកជាប់ចោទថា រឿងនេះ

ពិត ឬមិនពិត ? ព្រះវិន័យធរ ដេញដោលសួររឿងយ៉ាងនេះហើយ ចោទដោយរឿងដែលពិត ឱ្យអ្នកជាប់ចោទរលឹកហើយ គប្បីរម្ងាប់អធិករណ៍នោះដោយញត្តិសម្បត្តិ និងអនុស្សាវនាសម្បត្តិ ។

បើថា ក្នុងអ្នកចោទ និងអ្នកជាប់ចោទនោះ អ្នកចោទជាអលជ្ជី ចោទអ្នកជាប់ចោទជាលជ្ជី និងអ្នកចោទអលជ្ជីនោះ ជាបុគ្គលពាល មិនឆ្លាត, ព្រះវិន័យធរមិនគប្បីឱ្យការសាកសួរដល់លោក ។ តែគប្បីពោលយ៉ាងនេះ លោកចោទភិក្ខុនោះ ព្រោះរឿងអ្វី ? ពិតមែន អ្នកចោទនោះនឹងពោលថា "លោកដ៏ចម្រើន ដែលឈ្មោះថា "លោកចោទភិក្ខុនោះព្រោះរឿងអ្វី" នេះ តើដូចម្ដេច ?" គប្បីបញ្ជូនលោកចេញទៅដោយពាក្យថា លោកមិនស្គាល់សូម្បីត្រឹមតែពាក្យថា "លោកចោទភិក្ខុនោះព្រោះរឿងអ្វី", លោកជាមនុស្សល្ងង់បែបនេះ មិនគួរចោទអ្នកដទៃទេ ។ ព្រះវិន័យធរមិនគប្បីឱ្យការសាកសួរដល់លោក ។ តែបើអ្នកចោទអលជ្ជីនោះ ជាបណ្ឌិតឈ្លាសវៃ អាចនឹងគ្របសង្កត់ឱ្យសម្រេចបាន ដោយរឿងដែលបានឃើញ ឬដោយរឿងដែលបានឮ, គប្បីឱ្យការសាកសួរដល់អ្នកចោទនោះ ហើយធ្វើកម្មតាមបដិញ្ញារបស់អ្នកជាប់ចោទជាលជ្ជីនុ៎ះឯង ។ បើលជ្ជីចោទអលជ្ជី, និងលជ្ជីនោះជាមនុស្សល្ងង់ មិនឈ្លាសវៃ មិនអាចនឹងឱ្យពាក្យឆ្លើយ តបដល់ពាក្យសាកសួរបាន, ព្រះវិន័យធរគប្បីឱ្យន័យដល់លោកថា "លោកចោទភិក្ខុនោះ ព្រោះរឿងអ្វី ? ព្រោះរឿងនៃសីល

វិបត្តិ ឬព្រោះរឿងនៃវិបត្តិណាមួយ ក្នុងបណ្ដាអាចារវិបត្តិ”ជាដើម ។

សួរថា ក៏ព្រោះហេតុអ្វី ទើបគួរឱ្យន័យយ៉ាងនេះដល់លជ្ជីនេះប៉ុណ្ណោះ មិនគួរឱ្យដល់អលជ្ជីក្រៅនេះហ្ន៎ ? ការលំអៀង ព្រោះអគតិមិនសមគួរដល់ពួកព្រះវិន័យធរ មិនមែនឬ ?

ឆ្លើយថា ការលំអៀងព្រោះអគតិ មិនសមគួរឡើយ ។ តែការឱ្យន័យនេះ មិនចាត់ជាការលំអៀងព្រោះអគតិ ។ ការនេះ ឈ្មោះថា ជាការអនុគ្រោះធម៌ ។ ពិតណាស់ សិក្ខាបទព្រះមានព្រះភាគទ្រង់បញ្ញត្តទុកដើម្បីត្រូវការសង្កត់សង្កិនពួកអលជ្ជី និងដើម្បីត្រូវការលើកតម្កើងពួកលជ្ជី ។

ក្នុងលជ្ជីនិងអលជ្ជីទាំងនោះ អលជ្ជីបានន័យហើយ នឹងសង្កត់សង្កិនចេញទៅ ។ ចំណែកលជ្ជីបានន័យហើយ នឹងពោលអះអាងក្នុងរឿងដែលបានឃើញ ដោយសេចក្ដីបន្តជាប់គ្នានឹងរឿងដែលបានឃើញក្នុងរឿងដែលបានឮ ដោយសេចក្ដីបន្តជាប់គ្នានឹងរឿងដែលបានឮ ។ ព្រោះដូច្នោះ ការអនុគ្រោះធម៌ ទើបសមគួរដល់លជ្ជីនោះ ។ ក៏បើថា លជ្ជីនោះជាបណ្ឌិតឈ្លាសវៃ អះអាងនិយាយ, តែអលជ្ជីមិនឱ្យបដិញ្ញាដោយបដិសេធថា សូម្បីរឿងនេះក៏មិនមាន, រឿងនោះក៏មិនមាន ។ គប្បីពិន័យតាមបដិញ្ញារបស់អលជ្ជីដូចគ្នា ។

# រឿងធ្វើតាមបដិញ្ញារបស់អ្នកជាប់ចោទលជ្ជី និងអលជ្ជី

ក៏ឯដើម្បីសម្តែងសេចក្តីនោះ អ្នកសិក្សាគប្បីជ្រាបរឿងដូចតទៅនេះ ៖

បានឮថា ព្រះថេរៈចូឡាភ័យ អ្នកទ្រទ្រង់ព្រះត្រៃបិដក សម្តែងវិន័យដល់ភិក្ខុទាំងឡាយ ខាងក្រោមលោហៈប្រាសាទ ផ្អាកក្នុងវេលាល្ងាច ។ ក្នុងវេលាព្រះថេរៈនោះផ្អាក ភិក្ខុ ២ រូប ដែលមានទំនាស់គ្នាក្នុងរឿងក្តី បានញុំាងពាក្យឱ្យប្រព្រឹត្តទៅ ។ មួយរូបមិនឱ្យបដិញ្ញាដោយបដិសេធថា សូម្បីរឿងនេះក៏មិនមាន, រឿងនោះក៏មិនមាន ។ គ្រានោះកាលបឋមយាមនៅសល់តិច ព្រះថេរៈកើតគំនិតថា មិនបរិសុទ្ធក្នុងបុគ្គលនោះថា "អ្នកនេះ អះអាងនិយាយ, តែអ្នកនេះមិនឱ្យបដិញ្ញា និងរឿងនាំមកជាឧទាហរណ៍មានច្រើន, កម្មនេះ នឹងជារបស់ដែលបុគ្គលនោះ ធ្វើហើយពិតប្រាកដ" ។ គ្រានោះ ព្រះថេរៈបានឱ្យសញ្ញាត្រង់ផែនក្បឿងជូតជើង ដោយដងផ្លិតហើយពោលថា "អ្នកមានអាយុ យើងមិនសមគួរនឹងវិនិច្ឆ័យ, លោកចូរឱ្យអ្នកដទៃវិនិច្ឆ័យចុះ" ។ ពួកភិក្ខុសួរថា "តើព្រោះហេតុអ្វី លោកម្ចាស់ ?" ព្រះថេរៈបានប្រាប់សេចក្តីនោះ ។ សេចក្តីក្តៅក្រហាយកើតឡើង ក្នុងកាយរបស់បុគ្គលអ្នកជាប់ចោទ ។ គ្រានោះ អ្នកជាប់ចោទថ្វាយបង្គំព្រះថេរៈ ហើយពោលថា "ធម្មតាព្រះ

វិន័យធរអ្នកសមរម្យដើម្បីវិនិច្ឆ័យ គួរជាអ្នកដូចលោកម្ចាស់ទុំះឯង និងអ្នកចោទក៏គួរដូចជាលោកម្ចាស់នេះឯង" ហើយស្លៀកសំពត់សពោលថា "ខ្ញុំព្រះករុណា បានធ្វើឱ្យលោកម្ចាស់លំបាកយូរមកហើយ" សូមខមាទោសព្រះថេរៈហើយចៀសចេញទៅ ។ អលជ្ជីភិក្ខុត្រូវលជ្ជីភិក្ខុចោទយ៉ាងនេះ កាលរឿងសូម្បីជាច្រើនកើតឡើងហើយ ក៏មិនឱ្យបដិញ្ញា ។ អលជ្ជីភិក្ខុនោះ ព្រះវិន័យធរមិនគួរពោលឡើយថា "ជាអ្នកបរិសុទ្ធិ" ទាំងមិនគួរពោលថា "ជាអ្នកមិនបរិសុទ្ធិ" ។ បុគ្គលនេះ ឈ្មោះថាស្លាប់ទាំងរស់ ឈ្មោះថា ស្អុយទាំងស្រស់ ។ ក៏បើថា រឿងសូម្បីដទៃដូច្នោះ កើតឡើងដល់គេ, ព្រះវិន័យធរមិនត្រូវវិនិច្ឆ័យ ។ គេនឹងត្រូវវិនាសទៅយ៉ាងនោះឯង ។

មួយទៀត បើអលជ្ជីភិក្ខុចោទអលជ្ជីភិក្ខុផងគ្នា, ព្រះវិន័យធរគួរនិយាយណែនាំអ្នកចោទនោះថា "នែអ្នកមានអាយុអ្នកនេះមិន អាចមានអ្នកណា ៗ ពោលប្រាប់អ្វី តាមពាក្យរបស់អ្នកមានអាយុបាន", ពោលយ៉ាងនោះដូចគ្នា ចំពោះខាងអ្នកជាប់ចោទក្រៅនេះ ហើយបញ្ចូនទៅដោយពាក្យថា "ពួកលោកទាំងពីរចូរសម្ភោគបរិភោគរួមគ្នាចុះ", មិនគប្បីធ្វើការវិនិច្ឆ័យដល់អលជ្ជីទាំងពីរនោះ ដើម្បីប្រយោជន៍ដល់សីល, តែដើម្បីប្រយោជន៍ដល់បាត្រនិងចីវរ និងបរិវេណជាដើម បានសាក្សីសមគួរហើយ ទើបគួរធ្វើ ។

បើលជ្ជីភិក្ខុ ចោទលជ្ជីភិក្ខុផងគ្នា និងការវិវាទរបស់ពួកលោកមាន ត្រឹមតែរឿងបន្តិចបន្តួចប៉ុណ្ណោះ, ព្រះវិន័យធរគប្បីឱ្យសម្រុះសម្រួលគ្នា ឱ្យសម្តែងទោសកន្លងល្មើស ហើយបញ្ចូនទៅដោយពាក្យថា ពួកលោក ចូរកុំធ្វើយ៉ាងនេះ ។ ក៏បើក្នុងអ្នកចោទនិងអ្នកជាប់ចោទនោះ អ្នកជាប់ ចោទនិយាយភ្លាំងភ្លាត់ខុសទៅ, តាំងពីដើម អ្នកជាប់ចោទមិនទាន់ឈ្មោះ ថា ជាអលជ្ជី ។ និងអ្នកជាប់ចោទនោះ មិនឱ្យបដិញ្ញាដើម្បីត្រូវការរក្សា បក្ខពួកនោះ ភិក្ខុច្រើនពួកក្រោកឡើងពោលថា "ពួកយើងមិនជឿ ពួក យើងមិនជឿ" អ្នកជាប់ចោទនោះ នឹងជាអ្នកបរិសុទ្ធិតែម្តង ឬ ពីរដង តាមបដិញ្ញារបស់ពួកច្រើននោះចុះ ។ តែបើលោកមិនតាំងនៅក្នុងឋាន (ជាលជ្ជី) ចាប់ផ្តើមតាំងពីវេលានិយាយខុសទៅ ។ គប្បីឱ្យការវិនិច្ឆ័យ[១] ។

## អង្គរបស់អ្នកចោទ និងអ្នកជាប់ចោទ

កាលរឿងត្រូវនាំមកស្មើរសូមក្នុងទីប្រជុំសង្ឃ ដោយអំណាចនៃ ការចោទយ៉ាងណាមួយដូច្នេះ ព្រះវិន័យធរជ្រាបការបដិបត្តិក្នុងអ្នកជាប់ ចោទ និងអ្នកចោទហើយ គប្បីជ្រាបវិនិច្ឆ័យដោយអំណាចនៃខាងដើម

១. សារត្ថទីបនី មាន ន បដិសេធ ជា វិនិច្ឆយោ ន ទាតព្វោតិ អលជ្ជិភាវំបន្នត្តា ទាតព្វោ : ពាក្យថា មិនគប្បីឱ្យវិនិច្ឆ័យ គឺមិនគប្បីឱ្យវិនិច្ឆ័យ ព្រោះដល់ភាពជាអលជ្ជី ។

កណ្តាល និងទីបំផុតជាដើម ដើម្បីស្គាល់សម្បត្តិ និងវិបត្តិនៃការចោទនោះឯង ។ គឺ យ៉ាងណា ? គឺ ការចោទមានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត ?

ការសូមឱកាសថា "ខ្ញុំព្រះករុណាប្រាថ្នា នឹងពោលចំពោះលោក, សូមលោកដ៏មានអាយុ ធ្វើឱកាសឱ្យដល់ខ្ញុំព្រះករុណា" ដូច្នេះ ឈ្មោះថា ខាងដើមនៃការចោទ ។

ការចោទហើយឱ្យអ្នកជាប់ចោទ រលឹកតាមវត្ថុដែលលើកឡើង បរិយាយប្តឹងហើយវិនិច្ឆ័យ ឈ្មោះថា កណ្តាលនៃការចោទ ។

ការរម្ងាប់ដោយឱ្យអ្នកជាប់ចោទតាំងនៅក្នុងអាបត្តិ ឬ អនាបត្តិ ឈ្មោះថា ទីបំផុតនៃការចោទ ។

ការចោទ មានមូលប៉ុន្មាន ? មានវត្ថុប៉ុន្មាន ? មានភូមិប៉ុន្មាន ? ការចោទមានមូល ២ គឺ មូលមានហេតុ ១ មូលមិនមានហេតុ ១ (មូលមានមូល ១ មូលមិនមានមូល ១) ។ មានវត្ថុ ៣ គឺ បានឃើញ ១ បានឮ ១ បានរង្កៀស ១ ។ មានភូមិ ៥ គឺ និយាយតាមកាល មិននិយាយដោយកាលមិនគួរ ១ និយាយតាមពិត មិននិយាយដោយពាក្យមិនពិត ១ និយាយដោយពាក្យផ្អែមល្ហែម មិននិយាយដោយពាក្យអាក្រក់ ១ និយាយពាក្យប្រកបដោយប្រយោជន៍ មិននិយាយពាក្យដែលមិនប្រកបដោយប្រយោជន៍ ១ មានចិត្តប្រកបដោយមេត្តានិយាយ

មិនសម្លឹងទោសនិយាយ ១ ។

ក៏ក្នុងការចោទនេះ បុគ្គលជាអ្នកចោទ គប្បីតាំងនៅ ក្នុងធម៌ ១៥ យ៉ាង ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងឧបាលិបញ្ចកៈ ដោយន័យជាដើមថា យើងជាអ្នកមានកាយសមាចារបរិសុទ្ធិឬហ្ន៎ ។ អ្នកជាប់ចោទ គប្បីតាំងនៅក្នុងធម៌ ២ យ៉ាងគឺ ក្នុងសេចក្ដីពិត និងសេចក្ដីមិនក្រោធ ។

ពាក្យថា អប្បេវ ឆាម នំ ឥមម្ហា ព្រហ្មចរិយា ចាវេយ្យំ : អញត្រូវធ្វើដូចម្ដេច ឱ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយបាន មានសេចក្ដីថា សូម្បីដូចម្ដេចហ្ន៎ ? យើងនឹងឱ្យបុគ្គលនោះ ឃ្លាតចាកព្រហ្មចរិយធម៌ (ការប្រព្រឹត្តដ៏ប្រសើរ) នេះបាន ។ មានពាក្យអធិប្បាយថា គប្បីតាមកម្ចាត់ដោយសេចក្ដីប្រាថ្នាយ៉ាងនេះថា "បើយើងឱ្យបុគ្គលនេះឃ្លាតចាកព្រហ្មចរិយធម៌នេះបាន ជាការល្អហ្ន៎" ។ តែក្នុងបទភាជនៈ ព្រះឧបាលិពោលពាក្យជាដើមថា គប្បីឱ្យភិក្ខុនោះឃ្លាតចាកភិក្ខុភាវ ដើម្បីសម្ដែងត្រឹមតែបរិយាយនៃពាក្យថា គប្បីឱ្យឃ្លាតចាកព្រហ្មចរិយធម៌នេះ ប៉ុណ្ណោះ ។

បទទាំងឡាយមានខណៈជាដើម ជាវេវចនៈរបស់សម័យ ។

[២៤៧] ច្រើនបទថា តំ ខណំ តំ លយំ តំ មហុត្តំ វីតិវត្តេ : ក្នុងខណៈនោះ ស្របក់នោះ ពេលនោះកន្លងទៅ បានដល់ ក្នុងខណៈ

នោះ ក្នុងស្របក់នោះ ក្នុងពេលរំពេចនោះ កន្លងទៅហើយ ពិតមែន ពាក្យថា តំ ខណំ ជាដើមនេះ ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។

ក្នុងសមនុគ្គាហិយមាននិទ្ទេស ពាក្យថា យេន វត្ថុនា អនុទ្ធំសិតោ ហោតិ **: (ភិក្ខុនោះ) គេចោទដោយវត្ថុណា** មានសេចក្តីថា អ្នកជាប់ចោទត្រូវអ្នកចោទតាមកម្ចាត់ គឺ គម្រាមកំហែង គ្របសង្កត់ដោយវត្ថុណា ក្នុងបណ្តាវត្ថុនៃបារាជិក ៤ ។

ពាក្យថា តស្មឹ វត្ថុស្មឹ សមនុគ្គាហិយមានោ **: គេសាកសួរក្នុងវត្ថុនោះ** មានសេចក្តីថា ក្នុងរឿងដែលអ្នកចោទចោទប្រកាន់នោះ ។ អ្នកចោទនោះ ត្រូវព្រះវិន័យធរពោលការដេញដោលសួរ សញ្ជឹងគិតគឺពិចារណា ដោយន័យជាដើមថា "លោកឃើញអ្វី ? លោកឃើញថាយ៉ាងណា ?"

ក្នុងអសមនុគ្គាហិយមាននិទ្ទេស ពាក្យថា ន កេនចិ វុច្ចមានោ **: ឥតមានអ្នកណាមួយសាកសួរ** គឺ អ្នកពោលសេចក្តី ឬអ្នកណាមួយ (មិនសាកសួរ) ។ម្យ៉ាងទៀត សេចក្តីថា មិនត្រូវអ្នកពោលការសាកសួរ ដោយបណ្តាវត្ថុដែលបានឃើញជាដើម យ៉ាងណាមួយ ។

ក៏បណ្ឌិតគប្បីជ្រាបសេចក្តីសម្ពន្ធនៃបទមាតិកាទាំង ២ នេះ ដោយពាក្យថា ភិក្ខុ ច ទោសំ បតិដ្ឋាតិ **: ភិក្ខុអ្នកចោទនោះ ក៏**

ប្តេជ្ញាទោស(ដោយខ្លួនឯង) នេះខាងមុខ ។ ពិតមែន មានសេចក្តីបញ្ជាក់ដែលលោកពោលទុកដូច្នេះថា "ឯវំ សមនុគ្គាហិយមានោ វា អសមនុគ្គាហិយមានោ វា ភិក្ខុ ច ទោសំ បតិដ្ឋាតិ បដិច្ច តិដ្ឋតិ បដិជានាតិ សង្ឃាទិសេសោ : ក៏ឯភិក្ខុនោះគេសាកសួរក្តី គេមិនសាកសួរក្តី ភិក្ខុអ្នកចោទនោះ ក៏ប្តេជ្ញាទោស យ៉ាងនេះ អះអាង អាស្រ័យទោស: គឺ បដិញ្ញា, ត្រូវអាបត្តិសង្ឃាទិសេស" ។ ក៏ពាក្យនេះ ព្រះមានព្រះភាគត្រាស់ទុក ដើម្បីសម្តែងកាលប្រាកដនៃភាពជាអធិករណ៍ មិនមានមូលប៉ុណ្ណោះ ។ តែភិក្ខុអ្នកចោទ រមែងត្រូវអាបត្តិ ក្នុងខណៈដែលខ្លួនចោទនុ៎ះឯង ។

## អធិប្បាយពាក្យថា អធិករណំជាដើម

[២៤៨] ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ពាក្យថា អធិករណំ ឆាម : ដែលហៅថា អធិករណៈជាដើម ដើម្បីមិនត្រាស់លក្ខណៈអធិករណ៍មិនមានមូល នោះ សម្តែងតែលក្ខណៈដែលនៅមិនធ្លាប់មានប៉ុណ្ណោះ ព្រោះលក្ខណៈនៃអធិករណ៍មិនមានមូល បានត្រាស់ទុកហើយក្នុងកាលមុន ក្នុងពាក្យថា អមូលកញ្ចេវ តំ អធិករណំ ហោតិ : អធិករណ៍នោះប្រាកដជាគ្មានមូល នេះ ។

ព្រោះអធិករណ៍ក្នុងពាក្យថា **អធិករណំ នាម : ដែលហៅថា អធិករណ:** នោះ ដោយអត្ថ គឺ ហេតុ រមែងមានសូម្បីតែម្យ៉ាង ដោយអំណាចនៃវត្ថុមានផ្សេងគ្នា ; ព្រោះហេតុនោះដើម្បីសេចក្តីផ្សេងគ្នានោះនៃអធិករណ៍នោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យមានជាដើមថា **ចត្តារិ អធិករណានិ វិវាទាធិករណំ : អធិករណ៍នោះ មាន ៤ យ៉ាង គឺ វិវាទាធិករណ៍** ដូច្នេះ ។

សួរថា ក៏អធិករណ៍នោះ រមែងជាអធិករណ៍តែមួយ ដោយអត្ថ គឺ ហេតុយ៉ាងណា អត្ថគឺ ហេតុយ៉ាងនោះ តើមានន័យយ៉ាងណា ?

ឆ្លើយថា អត្ថ គឺហេតុនោះ គឺ ភាពដែលអធិករណ៍ជាហេតុគប្បីធ្វើក្រៃលែង (រម្ងាប់) ដោយសមថ:ទាំងឡាយ ។ ព្រោះហេតុនោះសមថ:ទាំងឡាយនោះឯង ប្រារព្ធគឺ អាស្រ័យសំដៅយកអធិកិច្ចយ៉ាងណាប្រព្រឹត្តទៅ, អធិកិច្ចយ៉ាងនោះ គប្បីជ្រាបថា អធិករណ៍ ។ តែក្នុងអដ្ឋកថាទាំងឡាយពោលថា អាចារ្យពួកខ្លះពោលសេចក្តីប្រកាន់យកអធិករណ៍, ពួកខ្លះពោលចេតនាថា អធិករណ៍, ពួកខ្លះពោលសេចក្តីមិនពេញចិត្តថា អធិករណ៍, ពួកខ្លះពោលវោហារថា អធិករណ៍, ពួកខ្លះពោលបញ្ញត្តិថា អធិករណ៍ ។

ព្រះអដ្ឋកថាចារ្យទាំងនោះ ពិចារណាដដែលទុកយ៉ាងនេះថា បើ

សេចក្តីប្រកាន់គប្បីជាអធិករណ៍សោត, ភិក្ខុមួយរូបកាន់យករឿងក្តីប្រឹក្សាគ្នាជាមួយនឹងភិក្ខុដែលជាសភាគគ្នា ឃើញទោសក្នុងរឿងក្តី នោះ ហើយលះបង់ចេញទៀត, អធិករណ៍នោះរបស់លោក ជាការដល់សេចក្តីរម្ងាប់ទៅ ។ បើចេតនាគប្បីជាអធិករណ៍សោត, ចេតនាដែលកើតឡើងថា "យើងនឹងកាន់យករឿងក្តីនេះ" រមែងរលត់ទៅ ។ បើសេចក្តីមិនពេញចិត្តគប្បីជាអធិករណ៍សោត, ភិក្ខុសូម្បីកាន់យករឿងក្តីដោយការមិនពេញចិត្ត ខាងក្រោយ មិនបានសេចក្តីវិនិច្ឆ័យ ឬចំណែកអ្នកជាប់ចោទសូមខមាទោសហើយ រមែងលះបង់ចោល ។ បើវោហារគប្បីជាអធិករណ៍សោត, ភិក្ខុត្រាច់និយាយ រមែងជាអ្នកស្ងៀមមិនមានសំឡេងក្នុងខាងក្រោយ, អធិករណ៍នោះរបស់លោក នឹងជាការដល់សេចក្តីរម្ងាប់ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ បញ្ញត្តិទើបចាត់ជាអធិករណ៍ ។

តែពាក្យរបស់ព្រះអដ្ឋកថាទាំងឡាយនេះ ជំទាស់នឹងព្រះបាលី មានជាដើមយ៉ាងនេះថា "មេថុនធម្មបារាជិកបត្តិ មានចំណែកជាមួយគ្នានឹងមេថុនធម្មបារាជិកបត្តិ អទិន្នាទានបារាជិកបត្តិ មានចំណែកជាមួយគ្នានឹងអទិន្នាទានបារាជិកបត្តិ មនុស្សវិគ្គហបារាជិកបត្តិ មានចំណែកជាមួយគ្នានឹងមនុស្សវិគ្គហបារាជិកបត្តិ ឧត្តរិមនុស្សធម្មបារាជិកបត្តិ មានចំណែកជាមួយគ្នានឹងឧត្តរិមនុស្សធម្មបារាជិកបត្តិ ។ អាបត្តាធិករណ៍យ៉ាងនេះ (ហៅ

ថា ) មានចំណែកជាមួយគ្នានឹងអាបត្តាធិករណ៍”[1] និងថា “វិវាទាធិករណ៍ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន”[2] ដូច្នេះ ។

ការពិត ព្រះអដ្ឋកថាចារ្យទាំងនោះ មិនបានប្រាថ្នាពាក្យដែលបញ្ញត្តិជាកុសលជាដើម ។ និងធម៌ គឺ បារាជិក ដែលមកក្នុងពាក្យថា អមូលកេន បារាជិកេន ធម្មេន : ដោយអាបត្តិបារាជិកមិនមានមូលនេះ ទឹងបានឈ្មោះថា ជាបញ្ញត្តិ ក៏ទេ ។ ព្រោះហេតុអ្វី ? ព្រោះជាអកុសលដោយចំណែកតែមួយ ។

ពិតមែន សូម្បីព្រះមានព្រះភាគក៏បានត្រាស់ពាក្យនេះហើយថា “អាបត្តាធិករណំ សិយា អកុសលំ សិយា អព្យាកតំ : អាបត្តាធិករណ៍ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន”[3] ។ និងបារាជិកមិនមានមូលនោះណា ដែលទ្រង់និទ្ទេសទុក ក្នុងព្រះបាលីនេះថា អមូលកេន បារាជិកេន ដូច្នេះ ។ ព្រះបាលីថា អមូលកញ្ចេវ តំ អធិករណំ ហោតិ : អធិករណ៍នោះប្រាកដជាគ្មានមូល នេះ ជាបដិនិទ្ទេសនៃបារាជិកមិនមានមូលនោះឯង មិនមែននៃបញ្ញត្តិ ។ ពិតមែន ព្រះមានព្រះភាគបានទ្រង់និទ្ទេសបារាជិកដទៃ ហើយទ្រង់បដិនិទ្ទេសបារាជិកដទៃ

---

១ វិន. សង្ឃា. ទុតិយទុដ្ឋទោស. ២. ២៦៨/២៧៨ ។ ២ វិន. ចុល្ល. សមថក្ខន្ធកៈ. ១០. ៦៦/៧១ ។ ៣. វិន. ចុល្ល. សមថក្ខន្ធកៈ. ១០. ៧៤/៧៤ ។

ក៏ទេ ។ តែបុគ្គលនោះត្រូវអ្នកចោទ សម្គាល់កាន់យកថា កន្លងធម៌ គឺ បារាជិក ដោយបញ្ញត្តិណា គឺ ដោយការចោទប្រកាន់យ៉ាងណា, បញ្ញត្តិ សូម្បីនោះ ចាត់ថា មិនមានមូល ក៏ព្រោះអធិករណ៍ពោលគឺ បារាជិកជា របស់មិនមានមូល, តែចាត់ជាអធិករណ៍ ក៏ព្រោះបញ្ញត្តិនោះប្រព្រឹត្តទៅ ក្នុងអធិករណ៍ ; ព្រោះហេតុនោះ ពាក្យថា បញ្ញត្តិជាអធិករណ៍ គួរត្រូវ ដោយបរិយាយនេះ ។ តែអធិករណ៍ដែលចាត់ថា មិនមានមូល រមែង មិនមានដោយប្រក្រតីរបស់ខ្លួន, ទោះជាមាន ក៏ត្រឹមតែថា បញ្ញត្តិ ប៉ុណ្ណោះ ។ សូម្បីព្រោះហេតុនោះ ពាក្យថា បញ្ញត្តិចាត់ជាអធិករណ៍ ក៏ គួរនឹងត្រឹមត្រូវ ។

ចំណែកសេចក្តីដែលបញ្ញត្តិចាត់ជាអធិករណ៍ ដោយបរិយាយដូច ពោលមកនោះ រមែងត្រូវក្នុងសិក្ខាបទនេះប៉ុណ្ណោះ មិនត្រូវគ្រប់ ៗ សិក្ខាបទ ។ ពិតមែន ការបញ្ញត្តិអធិករណ៍មានវិវាទាធិករណ៍ជាដើម មិនមែនអត្ថ គឺ ហេតុ ។ តែអត្ថ គឺ ហេតុ ក៏បានដល់ សេចក្តីដែល អធិករណ៍ទាំងនោះ ជាហេតុដែលនឹងធ្វើក្រៃលែង ( រម្ងាប់ ) ដោយសម ថៈទាំងឡាយ ដូចពោលហើយក្នុងកាលមុន ។ អត្ថ គឺ ហេតុនេះ ដូច ពោលមកនេះ វិវាទយ៉ាងណាមួយក្នុងលោកនេះ ជាវិវាទផង ជា អធិករណ៍ផង ; ព្រោះហេតុនោះ ទើបឈ្មោះថា វិវាទាធិករណ៍ ។ ក្នុង អធិករណ៍ដ៏សេស ក៏ន័យនេះ ។

បណ្ដាអធិករណ៍ ៤ មានវិវាទាធិករណ៍ជាដើមនោះ វិវាទដែលអាស្រ័យភេទករវត្ថុ ១៨ យ៉ាង កើតឡើងយ៉ាងនេះ គឺ ពួកភិក្ខុក្នុងធម្មវិន័យនេះ វិវាទគ្នាថា នេះធម៌ ឬថា មិនមែនជាធម៌ ឈ្មោះថា **វិវាទាធិករណ៍** ។

ការចោទប្រកាន់គ្នាអាស្រ័យវិបត្តិ ៤ កើតឡើងយ៉ាងនេះ គឺ ភិក្ខុក្នុងធម្មវិន័យនេះ រមែងចោទភិក្ខុដោយសីលវិបត្តិខ្លះ ឈ្មោះថា **អនុវាទាធិករណ៍** ។

ចំពោះអាបត្តិប៉ុណ្ណោះឈ្មោះថា អាបត្តាធិករណ៍ យ៉ាងនេះ គឺ កងអាបត្តិទាំង ៥ ឈ្មោះថា អាបត្តាធិករណ៍ ។ កងអាបត្តិទាំង ៧ ឈ្មោះថា **អាបត្តាធិករណ៍** ។

"កិច្ចរបស់សង្ឃ ឬកម្មដែលសង្ឃត្រូវធ្វើបាន (មាន ៤ យ៉ាងនេះ) គឺ អបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម និងញត្តិចតុត្ថកម្ម"[១] គប្បីជ្រាបថា **កិច្ចាធិករណ៍** ។

តែក្នុងអត្ថនេះប្រាថ្នាយកអាបត្តាធិករណ៍ ពោលគឺ អាបត្តិបារាជិកប៉ុណ្ណោះ ។ អធិករណ៍ដ៏សេសមានវិវាទាធិករណ៍ជាដើម លោកពោលទុកដោយអំណាចនៃការពង្រីកសេចក្ដី ។ ពិតមែន អត្ថនៃសព្ទថា

១. វិន. ចុល្ល. សមថក្ខន្ធកៈ. ១០. ៥២/៦០ ។

អធិករណ៍ មានប៉ុណ្ណេះ ។ ក្នុងអត្ថទាំងនោះ បារាជិកប៉ុណ្ណោះប្រាថ្នាយក ក្នុងអធិការនេះ ។ បារាជិកនោះ ជាអធិករណ៍មិនមានមូល ដោយមូល មានការបានឃើញជាដើមនុ៎ះឯង ។ និងភិក្ខុនេះ តាំងនៅអាស្រ័យទោសៈ គឺ កាលពោលពាក្យជាដើមថា "ខ្ញុំព្រះករុណានិយាយលេងសោះទេ" ឈ្មោះថា វមែងបដិញ្ញា ។ ជាសង្ឃាទិសេសដល់ភិក្ខុនោះ ក្នុងខណៈ ដែលខ្លួនចោទនុ៎ះឯង ។ នេះជាសេចក្ដីនៃសិក្ខាបទនោះ ដែលមាននិទ្ទេស (ការពង្រីក) តាមលំដាប់នៃបទមុន ។

## ពន្យល់អត្ថក្នុងបទភាជនី

[២៥១-២] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់លើកអាបត្តិ ឡើងសម្ដែងដោយពិស្ដារដោយអំណាចនៃរឿងរបស់ការចោទ មានរឿង ដែលមិនបានឃើញជាដើម ដែលត្រាស់ទុកដោយសង្ខេបហើយនោះ ទើបត្រាស់ពាក្យមានជាដើមថា អទិដ្ឋស្ស ហោតិ ដូច្នេះ ។

បណ្ដាបទទាំងនោះ ពាក្យថា អទិដ្ឋស្ស ហោតិ **: តែភិក្ខុអ្នក ចោទនោះមិនឃើញទេ** បានដល់ (អ្នកជាប់ចោទ) ជាអ្នកដែលអ្នកចោទ នោះមិនបានឃើញ ។ អធិប្បាយថា បុគ្គលដែលត្រូវធម៌ដល់បារាជិកនោះ ជាអ្នកដែលអ្នកចោទនេះមិនបានឃើញ ។ សូម្បីក្នុងបទថា អស្សុតស្ស ហោតិ **: តែភិក្ខុអ្នកចោទនោះមិនឮទេ** ជាដើម ក៏មានន័យដូចគ្នានេះ ។

ពីរបទថា ទិដ្ឋោ មយា : ខ្ញុំបានឃើញ មានពាក្យអធិប្បាយថា លោកជាអ្នកដែលយើងឃើញហើយ ។ សូម្បីក្នុងបទថា សុតោ មយា : ខ្ញុំបានឮ ជាដើម ក៏មានន័យយ៉ាងនេះ ។ បទដ៏សេសក្នុងអធិករណ៍ មានរឿងដែលមិនបានឃើញជាមូលជាក់ច្បាស់ហើយតែម្តង ។ ចំណែកក្នុងអធិករណ៍ ដែលមានមូលដោយរឿងដែលបានឃើញ គប្បីជ្រាបភាពជាអធិករណ៍មិនមានមូល ព្រោះសេចក្តីមិនមាននៃមូល មានរឿងដែលបានឮជាដើម ដែលត្រាស់ទុកយ៉ាងនេះថា បើអ្នក ចោទចោទភិក្ខុនោះថា "ខ្ញុំព្រះករុណាបានឮ"ជាដើម ។

ក៏ក្នុងវារៈរបស់អ្នកចោទនេះទាំងអស់នុ៎ះឯង រមែងជាសង្ឃាទិសេសដូចគ្នា គ្រប់ពាក្យនិយាយ ដោយអំណាចនៃពាក្យនិយាយមួយពាក្យ ៗ ក្នុងបណ្តាពាក្យទាំងនេះ ដែលមកហើយក្នុងទីដទៃថា "លោកជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនល្អ គួរឱ្យគេរង្កៀស មានអំពើអាក្រក់បិទបាំងទុក មិនមែនសមណៈ តែប្តេជ្ញាខ្លួនថា ជាសមណៈ មិនមែនជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ តែប្តេជ្ញាថា ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយក្នុងមានចិត្តជោកដោយរាគៈ កខ្វក់ដូចជាសម្រាម"[១] ជាសង្ឃាទិសេស

១. វិន. ចុល្ល. បាតិមោក្ខដ្ឋបនក្ខន្ធកៈ. ១១. ១២៣/២១០ ; អង្គុ. អដ្ឋ. បហារាទសូត្រ; ខុទ្ទ. មហា. បុរាភេទសុត្តនិទ្ទេស ។

គ្រប់ពាក្យនិយាយ ដោយអំណាចពាក្យមួយ ៗ ក្នុងបណ្ដាពាក្យទាំងនេះ ដែលមកហើយក្នុងសិក្ខាបទនេះថា លោកជាអ្នកត្រូវអាបត្តិបារាជិក ជាអ្នកមិនមែនសមណៈ មិនមែនវង្សនៃសក្យបុត្រ ដូច្នោះ ។

ក៏ពាក្យសុទ្ធ ៗ ទាំងនេះថា "ឧបោសថ ឬបវារណា ឬសង្ឃកម្ម រួមនឹងលោក រមែងមិនមាន" មិនទាន់ដល់ទីបំផុតទេ ។ តែពាក្យនិយាយ ដែលជាប់តដោយបទណាមួយហើយប៉ុណ្ណោះ បណ្ដាបទថា ទុស្សីល ជាដើមយ៉ាងនេះថា "លោកជាបុគ្គលទុស្សីល ឧបោសថក្ដី រួមនឹងលោកមិនមាន" និងបណ្ដាបទថា "លោកត្រូវអាបត្តិបារាជិក"ជាដើម រមែងដល់ទីបំផុត គឺ ធ្វើឱ្យត្រូវអាបត្តិសង្ឃាទិសេស ។

តែព្រះមហាបទុមត្ថេរៈពោលថា ចំពោះបទជាដើមថា ជាអ្នកទុស្សីល មានធម៌អាក្រក់តែម្យ៉ាង ដែលមិនបានមកក្នុងបាលីនៃសិក្ខាបទនេះ ដែលដល់ទីបំផុត មិនមែនត្រឹមប៉ុណ្ណោះទេ, សូម្បីបទទាំងនេះ គឺលោកជាបុគ្គលអាក្រក់ លោកជាសាមណេរធំ លោកជាមហាឧបាសក លោកជាជេដ្ឋព្វតិកៈ[១] លោកជានិគ្រន្ថ លោកជាអាជីវក លោកជាតាបសលោកជាបរិព្វាជក លោកជាបណ្ឌកៈ លោកជាថេយ្យសំវាស លោកជាអ្នកចូលអន្យតិរ្ថិយ លោកជាតិរច្ឆាន លោកជាអ្នកសម្លាប់មាតា លោកជាអ្នក

១. អ្នកប្រព្រឹត្តតាមវតរបស់ព្រះនាងដ៏ប្រសើរ ឈ្មោះកលីទេវី ជាមេលទ្ធិមួយ ។

សម្លាប់បិតា លោកជាអ្នកសម្លាប់ព្រះអរហន្ត លោកជាអ្នកបំបែកសង្ឃ លោកជាអ្នកធ្វើលោហិតុប្បាទ លោកជាភិក្ខុទូសកៈ លោកជាអ្នកមានភេទពីរ រមែងដល់ទីបំផុតតែម្តង ។

[២៥៣] ព្រះមហាបទុមត្ថេរៈទុំះឯង ពោលក្នុងបទថា ធិដ្ឋេ វេមតិកោ : តែជាអ្នកសង្ស័យនឹងភិក្ខុដែលខ្លួនបានឃើញហើយ ជាដើមថា ជាអ្នកសង្ស័យដោយចំណែកណា រមែងមិនជឿដោយចំណែកនោះ, មិនជឿដោយចំណែកណា រមែងរលឹកមិនបានដោយចំណែកនោះ, រលឹកមិនបានដោយចំណែកណា រមែងជាអ្នកវង្វេងភ្លេចដោយចំណែកនោះ ។

ចំណែកព្រះមហាសុមត្ថេរៈចែកបទមួយ ៗ ចេញជា ២ បទ ហើយ សម្តែងន័យចំពោះម្យ៉ាង ៗនៃបទមាតិកាសួម្បីទាំង ៤ ។ គឺយ៉ាងណា ? គឺ គប្បីជ្រាបន័យថា ធិដ្ឋេ វេមតិកោ នេះ ជាមុនសិន, ភិក្ខុជាអ្នកសង្ស័យក្នុងការឃើញខ្លះ, ក្នុងបុគ្គលខ្លះ, បណ្តាការឃើញនិងបុគ្គលនោះ រមែងជាអ្នកសង្ស័យក្នុងការឃើញយ៉ាងនេះថា ជាបុគ្គលដែលយើងឃើញ ឬមិនមែនអ្នកដែលយើងឃើញ, ជាអ្នកមានសេចក្តីសង្ស័យក្នុងបុគ្គលយ៉ាងនេះថា "អ្នកនេះមែនឬដែលយើងឃើញ ឬ អ្នកដទៃ" ។ រមែងមិនជឿការឃើញខ្លះ បុគ្គលខ្លះ, រមែងរលឹកមិនបាននូវ

ការឃើញខ្លះ បុគ្គលខ្លះ, រមែងជាអ្នកភ្លេចការឃើញខ្លះ បុគ្គលខ្លះ ដោយប្រការយ៉ាងនេះ ។

ក៏បណ្ដាបទទាំងនេះ បទថា វេមតិកោ បានដល់ កើតសេចក្ដីសង្ស័យ ។

ពីរបទថា **នោ កប្បេតិ : កំណត់មិនបាន** បានដល់ រមែងមិនជឿ ។

បទថា **ន សរតិ : រលឹកមិនបាន** មានសេចក្ដីថា កាលអ្នកដទៃមិនដាស់ តឿន ក៏រលឹកមិនបាន ។ តែកាលណា អ្នកដទៃដាស់តឿនលោកឱ្យរលឹកថា "ក្នុងស្ថានទីឈ្មោះឯណោះ ក្នុងវេលាឯណោះលោកម្ចាស់" កាលនោះ ទើបរលឹកបាន ។

បទថា **បម្មុដ្ឋោ : ភ្លេច** មានសេចក្ដីថា បុគ្គលសូម្បីដែលអ្នកដទៃដាស់តឿនឱ្យរលឹកហើយដោយឧបាយនោះ ៗ ក៏រលឹកមិនបានឡើយ ។ សូម្បីវារៈនៃបុគ្គលដែលឱ្យចោទ ក៏គប្បីជ្រាបដោយឧបាយនេះ ។ ក៏ក្នុងចោទាបកវារនោះ ដកបទថា មយា ចេញតែម្យ៉ាង, បទដ៏សេស ក៏ដូចគ្នានឹងចោទកវារនោះឯង ។

[២៥៨-២៦២] តអំពីចោទាបកវារនោះទៅ ដើម្បីសម្ដែងប្រភេទនៃអាបត្តិ និងប្រភេទនៃអនាបត្តិ ទើបទ្រង់តាំងចតុក្កៈថា អសុទ្ធេ

សុទ្ធទិដ្ឋិ : យល់ឃើញថា បរិសុទ្ធ ក្នុងបុគ្គលដែលមិនបរិសុទ្ធ ជាដើម ហើយទ្រង់សម្តែងពង្រីកតែមួយបទចេញទៅតាមប្រភេទមួយយ៉ាង ៗ ៤ ប្រភេទ ។ ចតុក្កៈទាំងអស់នោះ អ្នកសិក្សាអាចនឹងដឹងបានតាមន័យនៃព្រះបាលីនុ៎ះឯង ។ ក៏ក្នុងការចោទនេះ គប្បីជ្រាបសេចក្តីផ្សេងគ្នានៃសេចក្តីប្រាថ្នាតែម្យ៉ាង ។ ពិតមែន ធម្មតាថា សេចក្តីប្រាថ្នានេះ មានច្រើនយ៉ាង គឺ សេចក្តីប្រាថ្នាក្នុងការឱ្យឃ្លាត សេចក្តីប្រាថ្នាក្នុងការជេរ សេចក្តីប្រាថ្នាក្នុងការផ្ចាញ់ សេចក្តីប្រាថ្នាក្នុងការចេញ (ចាកអាបត្តិ) សេចក្តីប្រាថ្នាក្នុងការបញ្ឈប់ឧបោសថនិងបវារណា សេចក្តីប្រាថ្នាក្នុងការដេញដោលសួរ សេចក្តីប្រាថ្នាក្នុងការពោលធម៌ ។

បណ្តាសេចក្តីប្រាថ្នាទាំងនោះ ក្នុងសេចក្តីប្រាថ្នា ៤ យ៉ាង ខាងដើមត្រូវអាបត្តិទុក្កដ ដល់ភិក្ខុដែលមិនឱ្យធ្វើឱកាស, និងជាអាបត្តិសង្ឃាទិសេស សូម្បីដល់ភិក្ខុដែលឱ្យធ្វើឱកាស ហើយតាមកម្ចាត់ (ចោទ) ដោយបារាជិកដែលមិនមានមូលក្នុងទីចំពោះមុខ, ត្រូវអាបត្តិបាចិត្តិយ ដល់ភិក្ខុដែលតាមកម្ចាត់ (ចោទ) ដោយអាបត្តិសង្ឃាទិសេសមិនមានមូល, ត្រូវអាបត្តិទុក្កដ ដល់ភិក្ខុដែលតាមកម្ចាត់ដោយអាចារវិបត្តិ, ត្រូវអាបត្តិបាចិត្តិយដល់ភិក្ខុដែលពោលដោយបំណងនឹងជេរ, ត្រូវអាបត្តិទុក្កដ ដល់ភិក្ខុដែលពោលដោយកងអាបត្តិសូម្បីទាំង ៧ កង ក្នុងទីកំបាំងមុខ, ត្រូវអាបត្តិទុក្កដតែម្យ៉ាង ដល់ភិក្ខុដែលធ្វើកម្មទាំង ៧ យ៉ាង

ក្នុងទីកំបាំងមុខនោះឯង ។

ចំណែកក្នុងកុរុន្ទី លោកពោលថា កិច្ចដោយការសូមឱកាស រមែងមិនមានដល់ភិក្ខុដែលពោលថា “លោកត្រូវអាបត្តិឈ្មោះនេះ ចូរសម្តែងអាបត្តិនោះចេញ” ដោយសេចក្តីប្រាថ្នានឹងឱ្យចេញចាកអាបត្តិ ។ ក្នុងអដ្ឋកថាទាំងអស់នោះឯង មិនមានការសូមឱកាសសម្រាប់ភិក្ខុដែលបញ្ឈប់ឧបោសថ និងបវារណា ។ តែគប្បីដឹងខេត្រដែននៃការបញ្ឈប់ ដូច្នេះ ៖

ក៏កាលសូធ្យមិនទាន់ហួស វេ អក្សរ នេះថា សុណាតុ មេ ភន្តេ សង្ឃោ អជ្ជុបោសថោ បណ្ណរសោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឧបោសថំ ករេ ដូច្នេះ ត្រឹមនេះ រមែងបានដើម្បីបញ្ឈប់ ។ តែបន្ទាប់អំពីនោះទៅ កាលដល់ យ អក្សរហើយ រមែងមិនបានដើម្បីបញ្ឈប់ ។ ក្នុងបវារណាក៏មានន័យយ៉ាងនេះ ។

ឱកាសកម្ម រមែងមិនមាន សូម្បីដល់ភិក្ខុដែលដេញដោលសួរក្នុងកាលរឿងត្រូវនាំចូលស្នើរសូមហើយ ពោលដោយប្រាថ្នា នឹងដេញដោលសួរថា រឿងយ៉ាងនេះ មានដល់លោកឬ ? សូម្បីសម្រាប់ព្រះធម្មកថិក ដែលអង្គុយនៅលើធម្មាសនៈពោលធម៌មិនចំពោះដោយន័យជាដើមថា ភិក្ខុណាធ្វើយ៉ាងនេះ ៗ, ភិក្ខុនេះ មិនមែនសមណៈ ដូច្នេះ ក៏មិនត្រូវមានការសូមឱកាស ។ ប៉ុន្តែថា ពោលចំពោះកំណត់ថា អ្នក

ឯណោះ ៗ មិនមែនសមណៈ មិនមែនឧបាសក ដូច្នេះ ចុះអំពីធម្មាសនៈហើយគួរសម្តែងអាបត្តិសិន សឹមទៅ ។ មួយទៀត គប្បីជ្រាបសេចក្តីនៃពាក្យដែលលោកពោលទុកក្នុងទីនោះ ៗ ថា អនោកាសំ ការេត្វា យ៉ាងនេះថា ឱកាសំ អការេត្វា : ហើយមិនឱ្យភិក្ខុធ្វើឱកាស ។ ពិតមែន ដែលឈ្មោះថា ឱកាស មិនសមគួរ ឱកាសណាមួយដែលអ្នកចោទឱ្យធ្វើឱកាសហើយ នៅតែត្រូវអាបត្តិទីងមិនមាន ក៏ទេ, តែអ្នកចោទមិនឱ្យអ្នកត្រូវចោទធ្វើឱកាស ទើបបានជាត្រូវអាបត្តិ ដូច្នេះឯង ។ ពាក្យដ៏សេសងាយយល់ទាំងអស់ ។

បណ្តាសមុដ្ឋានជាដើម សិក្ខាបទនេះ មានសមុដ្ឋាន ៣ គឺ កើតអំពីកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខសចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ទុដ្ឋទោសសិក្ខាបទវណ្ណនា ចប់

# ៩. អញ្ញភាគិយសិក្ខាបទវណ្ណនា

[២៦៤] ទុតិយទុដ្ឋទោសសិក្ខាបទថា តេន សមយេន ពុទ្ធោ ភគវា : សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគជាម្ចាស់ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទុដ្ឋទោសសិក្ខាបទនោះ ដូចតទៅនេះ ៖

## ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងភិក្ខុមេត្តិយៈនិងភុម្មជកៈ

ពាក្យថា ហន្ទ មយំ អាវុសោ ឥមំ ឆកលកំ ទព្វំ បល្លបុត្តំ ឆាម ករោម : អើអាវុសោ ពួកយើងនឹងសន្មតពពែឈ្មោលនេះ ឱ្យជាឈ្មោះទព្វមល្លបុត្ត មានសេចក្តីថា បានឮថា ភិក្ខុមេត្តិយៈនិងភុម្មជកៈនោះ មិនអាចឱ្យមនោរថរបស់ខ្លួនសម្រេចក្នុងរឿងដំបូង បានទទួលការសង្កត់សង្កិនដល់សេចក្តីឈឺចិត្តចងគំនុំ ពោលថា "ចាំមើលចុះ ពួកយើងគង់តែនឹងដឹងជាមិនខាន" ទើបត្រាច់ទៅស្វែងរកហេតុបង្ករឿងរ៉ាវប្រភេទនោះ ។ តមកថ្ងៃមួយ បានប្រទះឃើញហើយសប្បាយចិត្តក្រឡេកមើលគ្នានិងគ្នាទៅវិញទៅមក ហើយបានពោលយ៉ាងនេះថា "អើអាវុសោ ពួកយើងនឹងសន្មតពពែឈ្មោលនេះ ឱ្យជាឈ្មោះទព្វមល្លបុត្ត" ។ មានពាក្យអធិប្បាយថា ពួកយើងនឹងតាំងឈ្មោះឱ្យពពែឈ្មោលនោះ យ៉ាងនេះថា ពពែនេះឈ្មោះថា ទព្វមល្លបុត្រ ។ សូម្បីក្នុង

ពាក្យថា មេត្តិយំ នាម ភិក្ខុនឹ : ជាឈ្មោះនាងមេត្តិយាភិក្ខុនី នេះ ក៏ន័យនេះ ។

ពាក្យថា តេ ភិក្ខូ មេត្តិយភុម្មជកេ ភិក្ខូ អនុយុញ្ជិំសុ : ភិក្ខុទាំងឡាយ បានជម្រះសួរមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ មានសេចក្ដីថា ពួកភិក្ខុទាំងនោះ ដេញដោលសួរយ៉ាងនេះថា "លោកដ៏មានអាយុទាំងឡាយ ពួកលោកទាំងអស់គ្នា ឃើញព្រះទព្វមល្លបុត្រជាមួយនឹងនាងមេត្តិយាភិក្ខុនីក្នុងទីណា ?"

ពួកលោកឆ្លើយថា "ក្បែរជើងភ្នំគិជ្ឈកូដ" ។

ភិក្ខុទាំងឡាយសួរថា "ក្នុងវេលាណា ?"

ពួកលោកឆ្លើយថា "ក្នុងវេលាទៅភិក្ខាចារ" ។

ពួកភិក្ខុ សួរព្រះទព្វមល្លបុត្រថា "លោកទព្វៈដ៏មានអាយុ ពួកភិក្ខុទាំងនេះ ពោលយ៉ាងនេះ, តើក្នុងវេលានោះ លោកដ៏មានអាយុនៅក្នុងទីឯណា ?"

ព្រះទព្វមល្លបុត្រឆ្លើយថា "ខ្ញុំព្រះករុណា ចែកភត្តាហារនៅក្នុងវត្តវេឡុវ័ន" ។

"តើក្នុងវេលានោះ មានអ្នកណាខ្លះជ្រាបថា លោកដ៏មានអាយុនៅក្នុងវត្តវេឡុវ័ន ?"

"ព្រះករុណាលោកម្ចាស់ មានព្រះភិក្ខុសង្ឃ" ។

ពួកភិក្ខុទាំងនោះ ទើបសួរសង្ឃថា "លោកទាំងឡាយបានជ្រាបទេថា លោកដ៏មានអាយុទព្វៈនេះ នៅក្នុងវត្តវេឡុវ័នក្នុងវេលានោះ ?"

ភិក្ខុសង្ឃឆ្លើយថា "ព្រះករុណា លោកដ៏មានអាយុទាំងឡាយ ពួកយើងដឹងថា ព្រះទព្វថេរៈនៅតែក្នុងវេឡុវ័នប៉ុណ្ណោះ តាំងពីថ្ងៃដែលលោកបានទទួលសន្មតហើយ" ។

លំដាប់នោះ ភិក្ខុទាំងឡាយ ទើបពោលនឹងមេត្តិយៈ និងភុម្មជកៈថា "លោកដ៏មានអាយុ ពាក្យរបស់លោកទាំងពីរមិនសមគ្នា, ពួកលោកអាងលេស បន្តិចបន្តួចពោលនឹងពួកយើងទេដឹង ?"

ភិក្ខុមេត្តិយៈ និងភុម្មជកៈទាំងពីរនោះ ត្រូវពួកភិក្ខុទាំងនោះ ដេញដោលសួរយ៉ាងនោះ ក៏បានពោលថា "ករុណា មែនហើយ លោកដ៏មានអាយុ" ទើបបាន ប្រាប់រឿងរ៉ាវនោះ ។

ក្នុងពាក្យថា កឹ បន តុម្ហេ អាវុសោ អាយស្មន្តំ ទព្វំ មល្លបុត្តំ អញ្ញភាគិយស្ស អធិករណស្ស : នៃអាវុសោ អ្នកទាំងពីរ កាន់យកអធិករណ៍ដ៏ជាចំណែកដទៃ ( ហើយចោទ )ទព្វមល្លបុត្តដ៏មានអាយុនេះ មានវិនិច្ឆ័យដូច្នេះ ៖

ពាពេនេះ ( អធិករណ៍ពោលគឺ ពាពេនេះ ) នៃចំណែកដទៃ ឬ

ចំណែកដទៃនៃពពែនោះ មាន ; ព្រោះហេតុនោះ ពពែនោះ ទើបឈ្មោះថា អញ្ញភាគិយៈ (មានចំណែកដទៃ) ។ សត្វដែលទទួលរង គប្បីជ្រាបថា អធិករណ៍ ។ អធិប្បាយថា ទីតាំងនៃរឿង ។ ព្រោះថា ពពែដែលពួកភិក្ខុមេត្តិយៈ និងភុម្មជកៈ ពោលថា ឈ្មោះថា ទព្វមល្លបុត្រនោះ រមែងមានដល់ចំណែក គឺ កោដ្ឋាស បក្ខពួក ពោលគឺ កំណើតសត្វតិរច្ឆាន និងភាពជាពពែដទៃអំពីចំណែក គឺ កោដ្ឋាស បក្ខពួក ពោលគឺ កំណើតមនុស្ស និងភាពជាភិក្ខុរបស់ព្រះទព្វមល្លបុត្រ, ម្យ៉ាងទៀត ចំណែកដទៃនោះ មានប្រាកដដល់ពពែនោះ ព្រោះហេតុនោះ ពពែនោះ ទើបបានការរាប់ថា មានចំណែកដទៃ ។ ក៏ព្រោះពពែនោះ ជាទីទទួលរង ជាទីតាំងនៃរឿងរបស់សញ្ញា គឺ ការតាំងឈ្មោះនៃពួកភិក្ខុមេត្តិយៈ និងភុម្មជកៈនោះ អ្នកពោលថា "ពួកយើងនឹងសន្មតពពែនេះឱ្យឈ្មោះថា ទព្វមល្លបុត្រ", ព្រោះដូច្នោះ ពពែនោះ គប្បីជ្រាបថា អធិករណ៍ ។ ពិតមែន ភិក្ខុទាំងនោះ សំដៅដល់ពពែនោះ ទើបបានពោលថា អញ្ញភាគិយស្ស អធិករណស្ស ជាដើម, មិនបានពោលសំដៅដល់អធិករណ៍យ៉ាងណាមួយ មានវិវាទាធិករណ៍ជាដើម ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះអធិករណ៍ទាំងនោះ មិនមាន ។

ព្រោះថា ភិក្ខុទាំងនោះ មិនបានកាន់យកឯកទេសយ៉ាងណាមួយ ឱ្យត្រឹមតែជាលេសនៃអធិករណ៍ ៤ យ៉ាង (គឺបានកាន់យក) អធិករណ៍ណាមួយដែលមានចំណែកដទៃ ៗ និងឈ្មោះថា លេសនៃអធិករណ៍ ៤ ក៏មិនមាន ។ ពិតមែន លេសទាំងឡាយ មានលេស គឺជាតិជាដើម ព្រះមានព្រះភាគត្រាស់ទុកសម្រាប់បុគ្គលទាំងនោះ មិនបានត្រាស់ទុកសម្រាប់អធិករណ៍ មានវិវាទាធិករណ៍ជាដើម ។ និងឈ្មោះថា ទព្វមល្លបុត្រ នេះ ជាឯកទេសយ៉ាងណាមួយរបស់ពពែនោះ ជាសត្វតាំងនៅក្នុងភាពជាអធិករណ៍មានចំណែកដទៃ និងត្រឹមតែជាលេស ដើម្បីតាមកម្ចាត់ព្រះថេរៈ ដោយបារាជិកដែលមិនមានមូល ។

ក៏បណ្តាទេសនិងលេសនេះ ចំណែកដែលឈ្មោះថា ទេស ព្រោះអត្ថថា ប្រាកដគឺ ត្រូវអាងដល់ ត្រូវហៅថា ពពែនេះ មានសេចក្តីសម្ព័ន្ធដល់ចំណែកដទៃនោះ ។ ពាក្យថា ទេសនេះ ជាឈ្មោះនៃចំណែកណាមួយ បណ្តាចំណែកមានជាតិជាដើម ។ ដែលឈ្មោះថា លេស ព្រោះអត្ថថា រួម គឺ សូម្បីប្រកាន់វត្ថុដទៃទុក បានដល់ ជាប់នៅត្រឹមតែបន្តិចបន្តួច ដោយគ្រាន់តែជាវោហារប៉ុណ្ណោះ ។ ពាក្យថា លេស នេះ ជាឈ្មោះនៃចំណែកណាមួយ ក្នុងបណ្តាចំណែកមានជាតិជាដើមដូចគ្នា ។ ពាក្យដទៃក្រៅចាកពាក្យទាំងពីរនោះ មានសេចក្តីជាក់ច្បាស់ទាំងអស់នោះឯង ។ សូម្បីក្នុងសិក្ខាបទបញ្ញត្តិ ក៏មានអត្ថយ៉ាងនេះដូចគ្នា ។

## អធិប្បាយអធិករណ៍ជារឿងដទៃនិងជារឿងនោះ

[២៦៦] ក៏បណ្ឌិតគប្បីជ្រាបសន្និដ្ឋាន ក្នុងបទភាជនៈថា អញ្ញភាគិយស្ស អធិករណស្ស កិញ្ចិ ទេសំ លេសមត្តំ ឧបាទាយ បារាជិកេន ធម្មេន អនុទ្ធំសេយ្យ : បានកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ ជាចំណែកដទៃមកជាគ្រឿងអាង ហើយចោទដោយអាបត្តិបារាជិក, អធិករណ៍ដែលជារឿងដទៃនោះ ជាក់ច្បាស់ហើយដោយអំណាចនៃហេតុដែលកើតឡើងនុ៎ះឯង; ព្រោះហេតុនោះ អធិករណ៍ដែលជារឿងដទៃនោះ ព្រះមានព្រះភាគ ទើបទ្រង់មិនចែកទុកក្នុងបទភាជនៈ ។ ក៏ឯអធិករណ៍ ៤ ពួកណា ដែលព្រះមានព្រះភាគត្រាស់ហើយ ដោយអំណាចនៃការលើកសេចក្តីឡើង ដោយពាក្យសាមញ្ញថា អធិករណ៍ ។ សេចក្តីដែលអធិករណ៍ទាំងនោះជារឿងដទៃ និងសេចក្តីដែលអធិករណ៍ទាំងនោះជារឿងនោះ មិនទាន់ប្រាកដផង ដែលព្រះវិន័យធរទាំងឡាយ គួរជ្រាបផង ; ព្រោះហេតុនោះ កាលព្រះអង្គនឹងទ្រង់អាស្រ័យអធិករណ៍ដែលបានដោយពាក្យសាមញ្ញ ធ្វើសេចក្តីដែលអធិករណ៍ទាំងនោះ ជារឿងដទៃនិងជារឿងនោះ ៗ ឱ្យជាក់ច្បាស់ ទើបត្រាស់បទភាជនៈថា អញ្ញភាគិយស្ស អធិករណស្សាតិ

អាបត្តញ្ញភាគិយំ វា ហោតិ អធិករណញ្ញភាគិយំ វា : ពាក្យថា របស់អធិករណ៍ ជាចំណែកដទៃ គឺចំណែកដទៃនៃអាបត្តិ ឬចំណែកដទៃនៃអធិករណ៍ជាដើម ។

[២៦៧] ក៏សេចក្តីដែលអធិករណ៍ទាំងពួងជារឿងនោះ និងជារឿងដទៃនេះ ដែលអ្នកសិក្សាគប្បីជ្រាបថា ទ្រង់ប្រមូលមកហើយ ដើម្បីសម្តែងសូម្បីនូវពាក្យចោទដោយអំណាចនៃអធិករណ៍ ដែលជារឿងដទៃនៃអាបត្តិ ដែលត្រាស់ទុកហើយក្នុងទីបំផុតនុ៎ះឯង ។ ការដែលពិត កាលនិទ្ទេសថា កតមញ្ច អាបត្តិ អាបត្តិយា អញ្ញភាគិយា ហោតិ ដូច្នេះ ដែលព្រះអង្គគួរប្រារព្ធដល់ ព្រោះក្នុងឧទ្ទេសនោះ ទ្រង់បានលើកឡើងទុកជាមុនថា អាបត្តញ្ញភាគិយំ វា : ចំណែកដទៃនៃអាបត្តិក្តីជាដើម, សេចក្តីនេះនឹងមកក្នុងគ្រាពិចារណា អធិករណ៍ជាចំណែកនោះ នៃអាបត្តធិករណ៍នុ៎ះឯង ; ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះមានព្រះភាគមិនបានទ្រង់ប្រារព្ធយ៉ាងនោះ ទ្រង់កំណត់យកបទចុងបំផុតតែម្តង ប្រារព្ធនិទ្ទេសថា កតមញ្ច អធិករណំ អធិករណស្ស អញ្ញភាគិយំ : (សួរថា) អធិករណ៍ ដែលមានចំណែកផ្សេងពីអធិករណ៍នោះ តើដូចម្តេច ដូច្នេះ ។

ក្នុងវារៈទាំងពីរនោះ អញ្ញភាគិយវារ មានសេចក្តីងាយយល់តែ

មួង ។ ពិតមែន អធិករណ៍តែម្យ៉ាង ៗ ចាត់ជារឿងដទៃ គឺ ជាចំណែកដទៃ ជាចំណែកដទៃនៃអធិករណ៍ ៣ យ៉ាង ក្រៅនេះ ព្រោះមានវត្ថុជាវិសភាគគ្នា ។

ចំណែកក្នុងតព្ភាគិយវារ មានវិនិច្ឆ័យថា វិវាទាធិករណ៍ ចាត់ជារឿងនោះជាចំណែកនោះ ជាចំណែកនោះនៃវិវាទាធិករណ៍ ក៏ព្រោះមានវត្ថុជាសភាគគ្នា ។ អនុវាទាធិករណ៍ ជារឿងនោះនៃអនុវាទាធិករណ៍ ក៏ដូចគ្នា ។ គឺយ៉ាងណា ? គឺ ព្រោះថា វិវាទដែលអាស្រ័យភេទករវត្ថុ ១៨ កើតឡើងតាំងពីសម័យពុទ្ធកាល និងវិវាទដែលអាស្រ័យភេទករវត្ថុ កើតឡើងក្នុងកាលឥឡូវនេះ រមែងជាវិវាទាធិករណ៍តែម្យ៉ាងដូចគ្នាពិត ព្រោះមានវត្ថុជាសភាគគ្នា ។

មួយទៀត អនុវាទដែលអាស្រ័យវិបត្តិ ៤ កើតឡើងតាំងពីពុទ្ធកាល និងអនុវាទដែលអាស្រ័យវិបត្តិ ៤ កើតក្នុងកាលឥឡូវនេះ រមែងឈ្មោះថា ជាអនុវាទាធិករណ៍តែម្យ៉ាងដូចគ្នាពិត ព្រោះមានវត្ថុជាសភាគគ្នា ។ ចំណែកអាបត្តាធិករណ៍ មិនចាត់ជារឿងនោះដោយចំណែកតែមួយនៃអាបត្តាធិករណ៍ ព្រោះមានវត្ថុទាំងជាសភាគគ្នា ទាំងជាវិសភាគគ្នា និងព្រោះគប្បីឃើញដូចការកើតឡើងឯង ; ព្រោះហេតុនោះ អាបត្តាធិករណ៍លោកទើបពោលថា ជារឿងនោះ នៃអាបត្តាធិករណ៍ក៏មាន ជារឿងដទៃនៃ

អាបត្តាធិករណ៍ក៏មាន ។ ក្នុងតព្ភាគិយៈ និងអញ្ញភាគិយៈនោះ អញ្ញភាគិយៈទុះឯង ទ្រង់អធិប្បាយមុន សូម្បីក្នុងអាបត្តាធិករណ៍និទ្ទេសនេះ ព្រោះអញ្ញភាគិយៈ ទ្រង់បានអធិប្បាយមកមុនហើយតាំងពីដើម ។ សេចក្តីដែលអាបត្តាធិករណ៍ជារឿងដទៃ ក្នុងអាបត្តាធិករណ៍និទ្ទេសនោះ និងសេចក្តីដែលអាបត្តាធិករណ៍ជារឿងនោះ (ដែលពោលទុកក្នុងទំព័រ ១៧៨ )ខាងដើម អ្នកសិក្សាគប្បីជ្រាបតាមន័យ ដែលពោលហើយទុះឯង ។

[២៦៨] ក៏ក្នុងពាក្យថា កិច្ចាធិករណំ កិច្ចាធិករណស្ស តព្ភាគិយំ : កិច្ចាធិករណ៍ក៏មានចំណែកជាមួយគ្នានឹងកិច្ចាធិករណ៍ដែរនេះ មានវិនិច្ឆ័យដូច្នេះ ៖

អធិករណ៍ដែលអាស្រ័យសង្ឃកម្ម ៤ កើតឡើង តាំងពីសម័យពុទ្ធកាល និងអធិករណ៍ដែលអាស្រ័យសង្ឃកម្ម ៤ កើតឡើងក្នុងកាលឥឡូវនេះ រមែងជាកិច្ចាធិករណ៍ដូចគ្នាពិត ព្រោះជាសភាគគ្នា និងព្រោះបានឃើញស្រដៀងគ្នា ។

សួរថា អធិករណ៍ដែលអាស្រ័យសង្ឃកម្មកើតឡើង ឈ្មោះថាកិច្ចាធិករណ៍ឬថា អធិករណ៍នោះជាឈ្មោះនៃសង្ឃកម្មទាំងឡាយប៉ុណ្ណោះ ។

ឆ្លើយថា អធិករណ៍នោះ ជាឈ្មោះនៃសង្ឃកម្មទាំងឡាយ

ប៉ុណ្ណោះ ។ សូម្បីកាលជាយ៉ាងនេះ ព្រះមានព្រះភាគ ក៏ត្រាស់ហៅអធិករណ៍ដែលអាស្រ័យសង្ឃកម្មកើតឡើងថា កិច្ចាធិករណ៍ ព្រោះអាស្រ័យកម្មលក្ខណៈដែលភិក្ខុដាក់ចិត្តដល់, ពាក្យដែលត្រាស់ទុកថា "ឈ្មោះថា សង្ឃកម្មនេះនិងកម្មនេះ គួរធ្វើយ៉ាងនេះ" កើតឡើងនិងព្រោះអាស្រ័យសង្ឃកម្មមុន ៗ កើតឡើង ។

[២៦៩] ក៏ព្រោះពីរបទថា លេសោ ឬ លេសមត្តោ ដែលមាននៅក្នុងពាក្យថា អញ្ញភាគិយស្ស អធិករណស្ស កិញ្ចិ ទេសំ លេសមត្តំ ឧបាទាយ : បានកាន់យកហេតុបន្តិចបន្តួចមកជាគ្រឿងអាង នេះ ផ្សេងគ្នាដោយព្យញ្ជនៈ ដោយអត្ថដូចគ្នាតែម្យ៉ាង ដោយន័យដូចពោលហើយក្នុងកាលមុនទុំះឯង[១] ; ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា លេសោ ជាម ទស លេសា ជាតិលេសោ ជាមលេសោ : ដែលហៅថា "គ្រឿងអាង" នោះ គ្រឿងអាងមាន ១០ យ៉ាង គឺ គ្រឿងអាងជាតិ១ នាម១ ដូច្នេះ ។ បណ្ដាលេស គឺ ជាតិជាដើមនោះ ជាតិ (កំណើត) ទុំះឯង ឈ្មោះថា លេស គឺជាតិ ។ ក្នុងលេសដ៏សេស ក៏ន័យនេះ ។

១. នៅក្នុងទំព័រ ១៩០ ។

# ពន្យល់អត្ថក្នុងសិក្ខាបទវិភង្គផ្នែកលេស

[២៧០] ឥឡូវនេះ ព្រះមានព្រះភាគដើម្បីទ្រង់សម្ដែងលេសនោះឯង ដោយពិស្ដារសម្ដែងឱ្យឃើញព្រមទាំងវត្ថុ ដោយប្រការដែលនឹងមានការអាងលេសនោះតាមកម្មាត់ ទើបត្រាស់ពាក្យជាដើមថា ជាតិលេសោ នាម ខត្តិយោ ទិដ្ឋោ ហោតិ : ដែលហៅថា គ្រឿងអាង គឺជាតិនោះបានដល់ ភិក្ខុអ្នកចោទឃើញភិក្ខុជាក្សត្រ ដូច្នេះ ។

បណ្ដាបទទាំងនេះ ពាក្យថា ខត្តិយោ ទិដ្ឋោ ហោតិ : ភិក្ខុអ្នកចោទ ឃើញភិក្ខុជាក្សត្រ មានសេចក្ដីថា បុគ្គលដទៃណា ជាជាតិក្សត្រិយ៍ រមែងជាអ្នកដែលដើមចោទនេះឃើញហើយ ។

ពាក្យថា បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ : ត្រូវអាបត្តិបារាជិកបានដល់ ជាអ្នកត្រូវបណ្ដាបារាជិកមានមេថុនធម្មជាដើម យ៉ាងណាមួយ ។

ពាក្យថា អញ្ញំ ខត្តិយំ បស្សិត្វា ចោទេតិ : លុះឃើញភិក្ខុដទៃជាក្សត្រដែរ ហើយចោទ មានសេចក្ដីថា ខាងក្រោយអ្នកចោទនោះឃើញភិក្ខុដទៃអ្នកមានជាតិជាក្សត្រិយ៍ ដែលជាគូវេរារបស់ខ្លួនហើយកាន់យកលេស គឺ ជាតិក្សត្រិយ៍នោះ ចោទយ៉ាងនេះថា ក្សត្រិយ៍ត្រូវធម៌ គឺ បារាជិកខ្ញុំព្រះករុណាបានឃើញហើយ, លោកជាក្សត្រិយ៍

ជាអ្នកត្រូវធម៌ គឺ បារាជិក ។

ម្យ៉ាងទៀត ចោទថា លោក គឺ ក្សត្រិយ៍នោះ មិនមែនអ្នកដទៃជាអ្នកត្រូវធម៌គឺ បារាជិក, លោកជាអ្នកមិនមែនសមណៈ ជាអ្នកមិនមែនវង្សនៃសក្យបុត្រ, មិនមានឧបោសថ បវារណា ឬថា សង្ឃកម្ម រួមនឹងលោក ត្រូវសង្ឃាទិសេសគ្រប់ ៗ ពាក្យនិយាយ ។

ក៏ក្នុងពាក្យថា **ខត្តិយោ មយា ទិដ្ឋោ : ខ្ញុំបានឃើញលោកជាក្សត្រ** ជាដើមនេះ អ្នកសិក្សាគប្បីជ្រាបសេចក្ដីដែលក្សត្រិយ៍ទាំងនោះជាអ្នកមានចំណែកដទៃ ដោយអំណាចនៃក្សត្រិយ៍ អ្នកមិនដូចគ្នានិងគ្នានោះ ៗ មានលក្ខណៈ ខ្ពស់ ឬដែលខ្លួនបានឃើញហើយជាដើម និងសេចក្ដីដែលក្សត្រិយ៍ទាំងនោះ ជាអធិករណ៍ ដោយអំណាចនៃភាពជាអ្នកទទួលវេបញ្ញត្តិ គឺ ជាតិក្សត្រិយ ។ អ្នកសិក្សាគប្បីជ្រាបយោជនាក្នុងបទទាំងពួងដោយឧបាយនេះនុ៎ះឯង ។

[២៧៥] គប្បីជ្រាបវិនិច្ឆ័យក្នុងបតលេសនិទ្ទេស ដូច្នេះ ៖

បាត្រដីស្អិតមានសណ្ឋានល្អ មានសម្បុរស្និទ្ធ មានពណ៌ដូចមេក្លៀង ដូចនិងបាត្រលោហៈ លោកហៅថា បាត្រលោហ ។ បាត្រដីតាមប្រក្រតី លោកហៅថា បាត្រដីធម្មតា ។ ក៏ព្រោះត្រាស់និទ្ទេសនៃលេស គឺ អាបត្តិទុកដោយសង្ខេបដោយបទតែមួយប៉ុណ្ណោះ ;

ដូច្នោះ ដើម្បីសម្ដែងលេស គឺ អាបត្តិនោះដោយពិស្ដារ ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា យើងបានឃើញភិក្ខុដែលត្រូវអាបត្តិសង្ឃាទិសេស ដូច្នេះ ។

សួរថា ក៏ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគមិនត្រាស់និទ្ទេសនៃលេស គឺ អាបត្តិនោះទុកក្នុងអធិការនៃលេស គឺ អាបត្តិនោះទេ តែត្រឡប់មកត្រាស់ទុកដទៃផ្សេង ក្នុងនិទ្ទេសនៃបទថា សង្ឃាទិសេសោ នេះហ្ន៎ ?

ឆ្លើយថា ក៏ព្រោះក្នុងនិទ្ទេសនៃលេស មិនមានសភាគគ្នា ។

ពិតមែន និទ្ទេសនៃលេសទាំងឡាយ ត្រាស់ទុកដោយអំណាចនៃការឃើញភិក្ខុរូបដទៃ ហើយចោទភិក្ខុមួយរូបទៀត ។ តែនិទ្ទេសនៃលេស គឺ អាបត្តិនេះត្រាស់ដោយអំណាចការឃើញ ភិក្ខុតែមួយរូបនុ៎ះឯង ត្រូវអាបត្តិដទៃ ហើយចោទដោយអាបត្តិដទៃ ។

សួរថា បើយ៉ាងនោះ អធិករណ៍មានចំណែកដទៃ នឹងមានបានយ៉ាងណា ?

ឆ្លើយថា មានបាន ព្រោះអាបត្តិ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ពាក្យនេះថា អធិករណ៍ជាចំណែកដទៃនៃអាបត្តិ និងលេសដែលដើមចោទអាងហើយ សូម្បីដោយអាការយ៉ាងនេះ ។ ពិត

មែន ភិក្ខុនោះ ត្រូវសង្ឃាទិសេសណា, អធិករណ៍ គឺ សង្ឃាទិសេសនោះ ជាអធិករណ៍មានចំណែកដទៃនៃបារាជិក ។ ក៏ដែលឈ្មោះថាលេសនៃអធិករណ៍មានចំណែកដទៃនោះ គឺ ភាពត្រូវអាបត្តិទូទៅដល់អាបត្តិទាំងពួង ដូចភាពជាក្សត្រិយ៍ទូទៅដល់ក្សត្រិយ៍ទាំងពួងដូច្នោះ ។ ន័យទាំងឡាយមានអាបត្តិដ៏សេសជាមូល និងចោទាបកវារ អ្នកសិក្សាគប្បីជ្រាបដោយឧបាយនេះ ។

[២៨៩] ពាក្យថា អនាបត្តិ តថាសញ្ញី ចោទេតិ វា ចោទាបេតិ វា : អាបត្តិមិនមានដល់ភិក្ខុអ្នកចោទមានសេចក្ដីសំគាល់ពិត ហើយចោទដោយខ្លួនឯង ឬឱ្យអ្នកដទៃចោទ មានសេចក្ដីថា ភិក្ខុណា មានការសម្គាល់យ៉ាងនេះថា អ្នកនេះ ត្រូវបារាជិកតែម្ដង ចោទដោយខ្លួនឯង ឬ ប្រើឱ្យអ្នកដទៃចោទយ៉ាងនោះ មិនត្រូវអាបត្តិដល់ភិក្ខុនោះ ។ បទដ៏សេសទាំងអស់ងាយយល់ទាំងអស់ ។

សូម្បីបកិណ្ណកៈមានសមុដ្ឋានជាដើម ក៏ដូចគ្នានឹងបឋមទុដ្ឋទោសសិក្ខាបទនុ៎ះឯង ។

អញ្ញភាគិយសិក្ខាបទវណ្ណនា ចប់

# ១០. សង្ឃភេទសិក្ខាបទវណ្ណនា

[២៩០] សង្ឃភេទសិក្ខាបទថា តេន សមយេន ពុទ្ធោ ភគវា : សម័យនោះឯង ព្រះពុទ្ធដ៏ទ្រង់មានជោគជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងសង្ឃភេទសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

## ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងភិក្ខុទេវទត្ត

ក្នុងពាក្យថា អថខោ ទេវទត្តោ : គ្រានោះ ភិក្ខុឈ្មោះទេវទត្តជាដើមនេះ មានវិនិច្ឆ័យដូច្នេះ ៖

រឿងភិក្ខុទេវទត្ត រឿងដែលភិក្ខុទេវទត្តបួស និងហេតុដែលទៅរកបក្ខពួក មានភិក្ខុកោកាលិកជាដើម ហើយពោលបបួលថា "ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរមក ពួកយើងនឹងធ្វើការបំបែកសង្ឃនឹងទម្លាយចក្ររបស់ព្រះគោតម" ដូច្នេះជាដើម ទាំងអស់មកហើយក្នុងសង្ឃភេទក្ខន្ធកៈ[1]នោះឯង ។

ចំណែករឿងសូមវត្ថុ ៥ នឹងមកក្នុងសង្ឃភេទក្ខន្ធកៈនោះដូចគ្នាក៏ពិតមែនហើយ តែថា ខ្ញុំព្រះករុណានឹងពោលក្នុងរឿងសូមវត្ថុ ៥ នេះមុនហើយទើបនឹងឆ្លងទៅ ព្រោះរឿងមកក្នុងសង្ឃភេទសិក្ខាបទនេះ ក៏មាន ។

---

១. វិន. ចុល្ល. សង្ឃភេទក្ខន្ធកៈ. ១១. ១/១ ។

ពាក្យថា សាធុ ភន្តេ : បពិត្រព្រះពុទ្ធជាម្ចាស់ សូមទ្រង់ព្រះមេត្តាករុណាចុះ បានដល់ ការទូលសូមព្រះវរោកាស ។

ពាក្យថា ភិក្ខូ យាវជីវំ អារញ្ញិកា អស្សុ : សូមឱ្យភិក្ខុទាំងឡាយ នៅតែក្នុងព្រៃជាវត្តអស់មួយជីវិត មានសេចក្តីថា ភិក្ខុទាំងអស់សមាទានអារញ្ញិកធុតង្គហើយ ចូរជាអ្នកនៅព្រៃជាវត្ត គឺ ចូរនៅតែក្នុងព្រៃប៉ុណ្ណោះ អស់មួយជីវិត ។

ដោយពាក្យថា យោ គាមន្តំ ឱសរេយ្យ វជ្ជំ នំ ផុសេយ្យ : ភិក្ខុណានៅក្នុងស្រុក ភិក្ខុនោះត្រូវទោស ភិក្ខុទេវទត្តពោលដោយបំណងថា ភិក្ខុណា គឺ សូម្បីភិក្ខុមួយរូបលះបង់ព្រៃចូលកាន់ស្រុក ដើម្បីត្រូវការទីងនៅ, ភិក្ខុនោះគប្បីត្រូវទោស គឺ ទោសចូរត្រូវភិក្ខុនោះ បានដល់ សូមព្រះមានព្រះភាគទ្រង់ពិន័យភិក្ខុនោះដោយអាបត្តិ, សូម្បីក្នុងវត្ថុដ៏សេសក៏មានន័យដូចគ្នានេះ ។

ពីរបទថា ជនំ សញ្ញាបេស្សាម : ហើយពួកយើងឯងនឹងពន្យល់ជន មានសេចក្តីថា ពួកយើងនឹងញ៉ាំងប្រជាជនឱ្យយល់ថា "ពួកយើងជាអ្នកមានសេចក្តីប្រាថ្នាតិចជាដើម" ។ ម្យ៉ាងទៀត មានពាក្យអធិប្បាយថា ពួកយើងនឹងឱ្យប្រជាជនត្រេកអរពេញចិត្ត គឺ នឹងឱ្យជ្រះថ្លា ។

## បំណងរបស់ព្រះមានព្រះភាគក្នុងសេចក្តីនេះ

[២៩១] ចំណែកព្រះមានព្រះភាគ លុះទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទេវទត្តដែលទូលសូមវត្ថុ ៥ នេះប៉ុណ្ណោះ ក៏ទ្រង់ជ្រាបបានថា "ទេវទត្តនេះ មានសេចក្តីត្រូវការនឹងបំបែកសង្ឃ ទើបសូម ។ ក៏ព្រោះវត្ថុ ៥ នោះ កាលព្រះមានព្រះភាគទ្រង់អនុញ្ញាត រមែងប្រព្រឹត្តទៅដើម្បីអន្តរាយដល់មគ្គរបស់ពួកកុលបុត្រជាច្រើន ; ដូច្នោះព្រះមានព្រះភាគ ទើបទ្រង់បដិសេធថា "កុំទេវទត្ត" ហើយត្រាស់ថា "ភិក្ខុណាចង់នៅព្រៃ, ភិក្ខុនោះចូរនៅចុះ" ដូច្នេះជាដើម ។

មួយទៀត ក្នុងពាក្យថា យោ ឥច្ឆតិ : ភិក្ខុណាចង់ ជាដើមនេះ កុលបុត្រគួរជ្រាបសេចក្តីប្រាថ្នារបស់ព្រះមានព្រះភាគហើយ ជ្រាបសេចក្តីសមគួរដល់ខ្លួន ។ ពិតមែន សេចក្តីប្រាថ្នារបស់ព្រះមានព្រះភាគ ក្នុងពាក្យថា យោ ឥច្ឆតិ ជាដើមនេះដូចតទៅនេះ ៖

ភិក្ខុមួយរូប មានអធ្យាស្រ័យធំ មានឧស្សាហៈច្រើន រមែងអាចវៀរសេនាសនៈជិតដែនស្រុកចេញហើយ នៅក្នុងព្រៃធ្វើទីបំផុតនៃទុក្ខបាន ។ ភិក្ខុមួយរូបដែលមានកម្លាំងទន់ខ្សោយ មានកម្លាំងតិច រមែងមិនអាចនឹងនៅក្នុងព្រៃ, អាចតែនៅក្នុងគាមខេត្តប៉ុណ្ណោះ (ទើបធ្វើទីបំផុតទុក្ខបាន) ។ មួយរូបមានកម្លាំងច្រើនមានធាតុប្រព្រឹត្តទៅស្មើ សម្បូរណ៍

ដោយអធិវាសនខន្តិមានចិត្តតាំងមាំក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ រមែង អាចទាំងក្នុងព្រៃ ទាំងក្នុងខេត្តស្រុកបានទាំងអស់នោះ ។ មួយរូបមិន អាចទាំងក្នុងខេត្តស្រុក ទាំងក្នុងព្រៃ គឺ ជាបទបរមបុគ្គល ។

បណ្តាភិក្ខុទាំងនោះ ភិក្ខុណា មានអធ្យាស្រ័យធំ មានឧស្សាហៈ ច្រើន រមែងអាចវៀរសេនាសនៈជិតស្រុកចេញ ហើយនៅក្នុងព្រៃ ធ្វើទី បំផុតទុក្ខបាន, ភិក្ខុរូបនោះ ចូរនៅក្នុងព្រៃប៉ុណ្ណោះចុះ, ការនៅក្នុងព្រៃនេះ សមគួរដល់លោក ។ សូម្បីពួកសទ្ធិវិហារិកជាដើមរបស់លោកសិក្សា តាម នឹងសម្គាល់ភាពដែលខ្លួនគួរនៅក្នុងព្រៃផង ។ មួយទៀត ភិក្ខុរូប ណា មានកម្លាំងទន់ខ្សោយ មាកម្លាំងតិច រមែងអាចនឹងធ្វើទីបំផុតទុក្ខបាន ក្នុងស្រុកប៉ុណ្ណោះ ក្នុងព្រៃមិនអាច, ភិក្ខុនោះចូរនៅតែក្នុងស្រុកនោះ ក៏ បាន ។ ចំណែកភិក្ខុរូបណា ដែលមានកម្លាំងរឹងមាំ មានធាតុប្រព្រឹត្តទៅ ស្មើ សម្បូរណ៍ដោយអធិវាសនខន្តិ មានចិត្តតាំងមាំ ក្នុងឥដ្ឋារម្មណ៍និង អនិដ្ឋារម្មណ៍ រមែងអាចទាំងក្នុងព្រៃ ទាំងក្នុងស្រុកតែម្តង ។ សូម្បីរូប នេះ ចូរលះសេនាសនៈជិតស្រុកចេញហើយ នៅក្នុងព្រៃចុះ, ការនៅក្នុង ព្រៃនេះសមគួរដល់លោក ។ សូម្បីពួកសទ្ធិវិហារិកជាដើមរបស់លោក សិក្សាតាម នឹងសម្គាល់សេចក្តីដែលខ្លួនគួរនៅព្រៃ ។

ចំណែកភិក្ខុណា ដែលមិនអាចទាំងក្នុងដែនស្រុក ទាំងក្នុងព្រៃ ជាបទបរមបុគ្គល, សូម្បីរូបនេះ ក៏ចូរនៅក្នុងព្រៃនោះចុះ ។ ព្រោះថា

ការសេពធុតង្គគុណ និងការចម្រើនកម្មដ្ឋាននេះរបស់លោក នឹងជាឧបនិស្ស័យដើម្បីមគ្គនិងផលតទៅ (ក្នុងអនាគត) ។ សូម្បីពួកសទ្ធិវិហារិកជាដើមរបស់លោកកាលសិក្សាតាម នឹងសម្គាល់ភាពដែលខ្លួនគួរនៅព្រៃ ដូច្នេះឯង ។ ភិក្ខុនេះណា ដែលជាអ្នកមានកម្លាំងទន់ខ្សោយ មានកម្លាំងតិចយ៉ាងនេះ កាលនៅក្នុងស្រុកប៉ុណ្ណោះ ទើបអាចធ្វើទីបំផុតទុក្ខបាន ក្នុងព្រៃមិនអាច ។ ព្រះមានព្រះភាគទ្រង់សំដៅដល់បុគ្គលដូច្នេះ ទើបត្រាស់ថា **យោ ឥច្ឆតិ គាមន្តេ វិហរតុ : ភិក្ខុណាចង់នៅស្រុក ភិក្ខុនោះចូរនៅចុះ** ដូច្នេះ ។ និងបុគ្គលនេះ បានឱ្យឱកាសសូម្បីដល់អ្នកដទៃ ។

ក៏បើថា ព្រះមានព្រះភាគ គប្បីទ្រង់ទទួលតាមវាទៈរបស់ភិក្ខុទេវទត្តសោត, បុគ្គលណា ដែលមានកម្លាំងទន់ខ្សោយ មានកម្លាំងតិចតាមប្រក្រតី, (ឬ) សូម្បីបុគ្គលណាអាចនៅក្នុងព្រៃសម្រេចបានតែក្នុងវេលានៅជាកម្លោះ តមកក្នុងវេលាខ្លួនចាស់ទ្រុឌទ្រោមចុះ ឬក្នុងវេលាកើតធាតុកម្រើក ព្រោះខ្យល់និងប្រម៉ាត់ជាដើម នៅព្រៃមិនសម្រេច, តែកាលនៅក្នុងស្រុកប៉ុណ្ណោះ ទើបអាចធ្វើទីបំផុតទុក្ខបាន ។ បុគ្គលទាំងនោះ នឹងសាបសូន្យអរិយមគ្គទៅ មិនគប្បីសម្រេចអរហត្តផលបាន, សត្ថុសាសនៈគប្បីក្លាយជាក្រៅធម៌ក្រៅវិន័យ សាំញ៉ាំ មិនប្រព្រឹត្តទៅដើម្បីនាំ

ចេញចាកទុក្ខ, ទាំងព្រះសាស្តានឹងមិនមែនជាព្រះសព្វញ្ញូរបស់បុគ្គលទាំងនោះ ទាំងគប្បីតិះដៀលថា "ទ្រង់លះចោលវាទៈរបស់ព្រះអង្គចេញហើយ ទៅតាំងនៅក្នុងវាទៈរបស់ភិក្ខុទេវទត្តវិញ" ដូច្នេះ ។

ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សង្គ្រោះបុគ្គលទាំងឡាយបែបនេះ ទើបទ្រង់បដិសេធវាទៈរបស់ភិក្ខុទេវទត្ត ។ ក្នុងរឿងនៃភិក្ខុដែលកាន់ត្រាច់ចរបិណ្ឌបាតជាវត្តក្តី ក្នុងរឿងនៃភិក្ខុដែលកាន់សំពត់បង្សុកូលជាវត្តក្តី ក្នុងរឿងនៃភិក្ខុដែលកាន់នៅគល់ឈើជាវត្តរហូតដល់ ៨ ខែក្តី គប្បីជ្រាបវិនិច្ឆ័យដោយឧបាយនេះឯង ។ តែព្រះមានព្រះភាគទ្រង់ហាមសេនាសនៈ គល់ឈើរហូតដល់ ៤ ខែ (រដូវភ្លៀង) ប៉ុណ្ណោះ ។

## កប្បិយមំសៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងត្រី និងសាច់ ដូច្នេះ ៖

បទថា **តិកោដិបរិសុទ្ធំ : ដែលបរិសុទ្ធដោយទីបំផុត ៣ ប្រការ** បានដល់ បរិសុទ្ធិដោយចំណែក ៣ ។ អធិប្បាយថា វៀរចាកត្រីសាច់ដែលមិនបរិសុទ្ធិ មានការឃើញជាដើម ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "មិនបានឃើញ មិនបានឮ មិនបានរង្កៀស" ។

បណ្ដាសាច់ ៣ យ៉ាងនោះ សាច់ដែលឈ្មោះថា មិនបានឃើញ គឺ មិនឃើញអ្នកស្រុកសម្លាប់ម្រឹគនិងត្រី យកមកដើម្បីប្រយោជន៍ដល់ពួកភិក្ខុ ។ ដែលឈ្មោះថា មិនបានឮ គឺ មិនបានឮថា ពួកអ្នកស្រុកសម្លាប់ម្រឹគ ត្រី យកមកដើម្បីប្រយោជន៍ដល់ពួកភិក្ខុ, ចំណែកដែលមិនបានរង្កៀស អ្នកសិក្សាគួរស្គាល់សាច់ដែលរង្កៀសដោយការឃើញ រង្កៀសដោយការបានឮ និងដែលរង្កៀសផុតពីហេតុទាំងពីរនោះ ហើយគប្បីជ្រាបដោយចំណែកផ្ទុយគ្នានៃសាច់ទាំងបីយ៉ាងនោះ ។

គឺ យ៉ាងណា ? គឺ ថា ពួកភិក្ខុក្នុងធម្មវិន័យនេះ ឃើញពួកអ្នកស្រុកកាន់អន្ទាក់និងសំណាញ់ជាដើម កំពុងចេញទៅអំពីស្រុក ឬកំពុងដើរចូលទៅក្នុងព្រៃ ។ និងក្នុងថ្ងៃស្អែក ពួកអ្នកស្រុកនាំបិណ្ឌបាត មានត្រីនិងសាច់មកប្រគេនដល់ភិក្ខុទាំងនោះ ដែលចូលទៅកាន់ស្រុកនោះដើម្បីបិណ្ឌបាត ។ ភិក្ខុទាំងនោះ រង្កៀសដោយការបានឃើញនោះថា "ពួកអ្នកស្រុកធ្វើសាច់ដើម្បីប្រយោជន៍ដល់ពួកភិក្ខុឬហ្ន៎ ?" សាច់នេះឈ្មោះថា រង្កៀសដោយបានឃើញមក, នឹងទទួលសាច់នោះ មិនគួរ ។ នឹងទទួលសាច់ដែលមិនបានរង្កៀសយ៉ាងនោះ គួរ ។ កំបើពួកអ្នកស្រុកទាំងនោះ សួរថា "លោកម្ចាស់ តើហេតុដូចម្ដេច ទើបលោកម្ចាស់មិនទទួល ?" បានស្ដាប់សេចក្ដីនោះហើយ និយាយថា "សាច់នេះ ពួកខ្ញុំព្រះករុណា មិនបានធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយទេ, ពួកខ្ញុំព្រះ

ករុណាធ្វើដើម្បីប្រយោជន៍ដល់ខ្លួនខ្លះ ដើម្បីប្រយោជន៍ដល់ពួករាជការជាដើមខ្លះ” ដូច្នេះ, សាច់នោះ គួរ ។

ភិក្ខុទាំងឡាយមិនឃើញដោយខ្លួនឯង, តែបានស្ដាប់ថា “បានឮថាពួកអ្នកស្រុកមានដៃកាន់អន្ទាក់ និងសំណាញ់ចេញពីស្រុក ឬដើរចូលទៅក្នុងព្រៃ” និងក្នុងថ្ងៃស្អែកពួកអ្នកស្រុកនាំបិណ្ឌបាតមានត្រីនិងសាច់មកប្រគេនដល់ភិក្ខុទាំងនោះ ដែលចូលទៅកាន់ស្រុកនោះ ដើម្បីបិណ្ឌបាត ។ ពួកលោកសង្ស័យដោយការបាន ឮនោះថា “គេធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយ ឬយ៉ាងណាហ្ន៎ ?” សាច់នេះ ឈ្មោះថាវង្វៀសដោយបានឮមក ។ នឹងទទួលសាច់នោះ មិនគួរ ។ ដែលមិនបានសង្ស័យយ៉ាងនេះ កាលទទួល ក៏គួរ ។ ក៏បើពួកអ្នកស្រុកទាំងនោះសួរថា “លោកម្ចាស់ តើហេតុដូចម្ដេច បានជាលោកម្ចាស់មិនទទួល ?” បានស្ដាប់សេចក្ដីនោះហើយ ទើបនិយាយថា “សាច់នេះ ពួកខ្ញុំព្រះករុណាមិនបានធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយទេ, ពួកខ្ញុំព្រះករុណាធ្វើដើម្បីប្រយោជន៍ដល់ខ្លួនឯងខ្លះ ដើម្បីប្រយោជន៍ដល់ពួករាជការជាដើមខ្លះ” ដូច្នេះ, សាច់នោះគួរ ។

មួយទៀត ភិក្ខុទាំងឡាយមិនបានឃើញ មិនបានស្ដាប់មកឡើយ, តែកាលពួកភិក្ខុទាំងនោះ ចូលទៅកាន់ស្រុកនោះដើម្បីបិណ្ឌបាត អ្នកស្រុកទទួលបាត្រទៅហើយ គាត់តែងបិណ្ឌបាតមានត្រីសាច់ នាំមក

ប្រគេន ។ ពួកភិក្ខុរង្កៀសថា "សាច់នេះ គេធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយ ឬយ៉ាងណាហ្ន៎ ?" នេះឈ្មោះថា សាច់ដែលរង្កៀសផុតពីហេតុទាំងពីរនោះ ។ សូម្បីសាច់ ដូច្នោះ ក៏មិនសមគួរទទួល ។ ដែលមិនបានរង្កៀសយ៉ាងនោះ កាលទទួល ក៏គួរ ។ ក៏បើថា ពួកអ្នកស្រុកទាំងនោះសួរថា "ហេតុដូចម្តេច បានជាពួកលោកម្ចាស់មិនទទួល ?" ហើយបានស្តាប់សេចក្តីនោះ ទើបនិយាយថា "សាច់នេះ ពួកខ្ញុំព្រះករុណា មិនបានធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយទេ, ពួកខ្ញុំព្រះករុណា ធ្វើដើម្បីប្រយោជន៍ដល់ខ្លួនខ្លះ ដើម្បីប្រយោជន៍ដល់ពួករាជការជាដើមខ្លះ", ឬថា "ពួកខ្ញុំព្រះករុណាបានបវត្តមំសៈសាច់របស់សត្វដែលស្លាប់ហើយ ចំពោះដែលជាកប្បិយប៉ុណ្ណោះ ទើបផ្សំឱ្យសម្រេចដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយ" សាច់នោះ គួរ ។

សូម្បីក្នុងសាច់ដែលគេធ្វើដើម្បីប្រយោជន៍នៃបេតកិច្ច ដល់អ្នកស្លាប់ទៅហើយក្តី ដើម្បីប្រយោជន៍ដល់ការងារមង្គលជាដើមក្តី ក៏មានន័យយ៉ាងនេះដូចគ្នា ។ ពិតមែន សាច់ប្រភេទណា ៗ ដែលគេមិនបានធ្វើដើម្បីភិក្ខុទាំងឡាយឡើយ និងភិក្ខុក៏មិនមានសេចក្តីសង្ស័យក្នុងសាច់ណា, សាច់នោះ គួរទាំងអស់ ។

ក៏បើថា សាច់ដែលគេធ្វើឧទ្ទិសពួកភិក្ខុក្នុងវិហារមួយ និងពួកលោកមិនជ្រាបថា "គេធ្វើដើម្បីប្រយោជន៍ខ្លួន", តែភិក្ខុពួកដទៃដឹង, ពួក

ណាដឹងមិនគួរដល់ពួកទាំងអស់នោះ ។ ពួកភិក្ខុដទៃមិនដឹង តែពួកលោកប៉ុណ្ណោះដឹង, រមែងមិនគួរចំពោះពួកលោកប៉ុណ្ណោះ, តែគួរសម្រាប់ពួកភិក្ខុដទៃ ។ សូម្បីពួកលោកដឹងប្រាកដថា "គេធ្វើដើម្បីប្រយោជន៍ដល់ពួកយើង", សូម្បីភិក្ខុពួកដទៃក៏ដឹងថា "គេធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងនេះ" មិនគួរដល់ពួកលោកទាំងអស់ ។ ពួកភិក្ខុទាំងអស់មិនដឹង, រមែងគួរដល់ពួកលោកទាំងអស់ ។ បណ្ដាសហធម្មិកទាំង ៥ សាច់ដែលគេធ្វើចំពោះ ដើម្បីប្រយោជន៍ដល់សហធម្មិករូបណាមួយក៏ដោយ រមែងមិនសមគួរដល់សហធម្មិកទាំងអស់នោះ ។

សួរថា ក៏បើថា មានបុគ្គលខ្លះអ្នកសម្លាប់សត្វ ចំពោះភិក្ខុមួយរូបដាក់ក្នុងបាត្រឱ្យពេញហើយ ប្រគេនដល់ភិក្ខុរូបនោះ និងលោកក៏ដឹងប្រាកដដែរថា សាច់គេធ្វើដើម្បីប្រយោជន៍ខ្លួន ទទួលទៅហើយប្រគេនដល់ភិក្ខុរូបដទៃ ភិក្ខុរូបដទៃនោះឆាន់ដោយជឿភិក្ខុនោះ, អ្នកណាត្រូវអាបត្តិហ្ន៎ ?

ឆ្លើយថា "មិនត្រូវអាបត្តិសូម្បីទាំងពីររូប" ។

ព្រោះថា សាច់ដែលគេធ្វើចំពោះភិក្ខុណា មិនត្រូវអាបត្តិដល់ភិក្ខុនោះ ព្រោះលោកមិនបានឆាន់, និងមិនត្រូវអាបត្តិដល់ភិក្ខុ ក្រៅនេះព្រោះមិនដឹង ។ ពិតមែន ក្នុងការទទួលកប្បិយមំសៈ មិនត្រូវអាបត្តិ ។ តែភិក្ខុមិនដឹងឆាន់សាច់ដែលគេធ្វើចំពោះ ខាងក្រោយទើបដឹង កិច្ចដោយការសម្ដែងអាបត្តិ មិនមាន ។ ចំណែកភិក្ខុមិនដឹងឆាន់អកប្បិយមំសៈ

សួរឡើងក្រោយទើបដឹង គប្បីសម្ដែងអាបត្តិ ។ ពិតមែន ត្រូវអាបត្តិដល់ភិក្ខុដែលដឹងហើយ ឆាន់សាច់ដែលគេធ្វើចំពោះ ។ និងត្រូវអាបត្តិដូចគ្នា សូម្បីដល់ភិក្ខុដែលមិនដឹង ឆាន់អប្បិយមំសៈ ។ ព្រោះហេតុនោះ ភិក្ខុដែលខ្លាចក្រែងចំពោះអាបត្តិសូម្បីកាលកំណត់រូបការណ៍ គប្បីសួរមុនហើយ ទើបទទួលប្រគេនសាច់, នឹងទទួលប្រគេនដោយតាំងចិត្តថា "ក្នុងវេលាឆាន់យើងនឹងសួរ ហើយបានយើងឆាន់" គួរសួរមុនសិនហើយសឹមឆាន់ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះសាច់ដឹងបានលំបាក ។

សេចក្ដីពិត សាច់ខ្លាឃ្មុំ ក៏ដូចនិងសាច់ជ្រូក ។ សាច់ខ្លាដំបងជាដើម ក៏ដូចនឹងសាច់ម្រឹគជាដើម ។ ព្រោះហេតុនោះ ទើបលោកអាចារ្យទាំងឡាយ ពោលថា ការសួរហើយ សឹមទទួលប្រគេននុ៎ះឯង ជាធម្មទំនៀម ។

## ពន្យល់អត្ថក្នុងផ្នែកភិក្ខុទេវទត្តទូលសូមវត្ថុ ៥ យ៉ាង

[២៩២] ពីរបទថា ហដ្ឋោ ឧទគ្គោ : ត្រេកអរ រីករាយ បានដល់ ជាអ្នកត្រេកអរហើយ និងមានកាយចិត្តត្រដែតឡើងហើយ ។

បានឮថា ភិក្ខុទេវទត្តនោះគិតថា "ព្រះមានព្រះភាគទ្រង់មិន

អនុញ្ញាតវត្ថុ ៥ ទាំងនេះទេ, ឥឡូវនេះ យើងនឹងអាចធ្វើសង្ឃភេទ” ដូច្នេះ ទើបបានសម្ដែងអាការលោតកញ្ឆែងដល់ភិក្ខុកោកាលិក, មិនដឹងថា “ខ្លួននឹងកើតក្នុងអវិចីហើយសោយនូវទុក្ខធំ សូម្បីដែលជិតចូលមកព្រោះសង្ឃភេទជាបច្ច័យ” រីករាយសប្បាយចិត្តថា “ឥឡូវនេះ យើងបានឧបាយដើម្បីបំបែកសង្ឃ” ដូចបុរសអ្នកប្រាថ្នានឹងស៊ីថ្នាំពិសឱ្យស្លាប់ ឬប្រាថ្នានឹងយកខ្សែចងកឱ្យស្លាប់ ឬប្រាថ្នានឹងយកសស្ត្រាមកសម្លាប់ខ្លួនឱ្យស្លាប់ បានវត្ថុយ៉ាងណាមួយមានថ្នាំពិសជាដើម មិនស្គាល់ទុក្ខ គឺសេចក្ដីស្លាប់សូម្បីជិតចូលមក ព្រោះការស៊ីថ្នាំពិសជាដើមនោះជាបច្ច័យ ជាអ្នករីករាយសប្បាយចិត្ត ដូច្នោះ ទើបក្រោកចាកទីអង្គុយព្រមដោយបរិស័ទ ថ្វាយបង្គំព្រះមានព្រះភាគដោយភាពជាអ្នករីករាយនោះឯង បានធ្វើប្រទក្សិណហើយចៀសទៅ ។

ក៏ក្នុងពាក្យថា តេ មយំ ឥមេហិ បញ្ចហិ វត្ថូហិ សមាទាយ វត្តាម : តែពួកយើងទាំងនោះ នាំគ្នាសមាទានវត្ថុ ៥ នេះវិញ នេះ សូម្បីកាលភិក្ខុទេវទត្តគួរនឹងពោលពាក្យថា ឥមានិ បញ្ច វត្ថូនិ : វត្ថុ ៥ នេះ ដូច្នេះ មិនទាន់បានសង្កេតសេចក្ដីខុសភ្លាត់នៃវិភត្តិដោយអំណាចនៃវិតក្កៈរឿយ ៗ ថា តេ មយំ ឥមេហិ បញ្ចហិ វត្ថូហិ ជនំ សញ្ញាបេស្សាម : ពួកយើងនោះ នឹងញ៉ាំងជនឱ្យយល់ដោយវត្ថុទាំង ៥

នេះ ដូច្នេះ ទើបពោលតាមគួរដល់សេចក្ដីរំពឹងរឿយ ៗ នុ៎ះឯងថា តេ មយំ ឥមេហិ បញ្ចហិ វត្ថូហិ ... ពួកយើងនោះ ... ដោយវត្ថុទាំង ៥ នេះ ដូចគ្នានឹងអ្នកមានចិត្តវើវវាយដូច្នោះឯង ។

[២៩៣] ពីរបទថា ធុតា សល្លេខវុត្តិនោ : ជាអ្នកកម្ចាត់កិលេសធម៌ ជាអ្នកប្រព្រឹត្តក្នុងធម៌ផូរផង់ មានសេចក្ដីថា អ្នកឈ្មោះថា ធុតៈ ព្រោះជាអ្នកប្រកបដោយបដិបទាដែលកម្ចាត់នូវកិលេសចេញ, និងអ្នកឈ្មោះថា មានសេចក្ដីប្រព្រឹត្តជុសខាត់ ព្រោះភិក្ខុទាំងនេះ មានការប្រព្រឹត្តជុសខាត់កិលេសទាំងឡាយ ។

បទថា ពាហុល្លិកោ : ជាអ្នកប្រព្រឹត្តលោភ មានសេចក្ដីថា ភាវៈដែលបច្ច័យ ៤ មានចីវរជាដើម មានច្រើនឈ្មោះថា ពាហុល្លៈ ។ សេចក្ដីដែលបច្ច័យបួនជាច្រើន កើតមានដល់ព្រះគោតមនោះ; ហេតុនោះ ព្រះគោតមនោះ ឈ្មោះថា ពាហុល្លិកៈ ម្យ៉ាងទៀត ព្រះគោតមនោះ ជាអ្នកប្រកប គឺ តាំងនៅក្នុងសេចក្ដីមានបច្ច័យច្រើននោះ ; ហេតុនោះ ទើបឈ្មោះថា ពាហុល្លិកៈ( ជាអ្នកមានសេចក្ដីប្រាថ្នាច្រើន ) ។

ពីរបទថា ពាហុល្លាយ ចេតេតិ : តែងត្រិះរិះដ៏ច្រើន មានសេចក្ដីថា រមែងគិត គឺ រមែងត្រិះរិះ រមែងសញ្ចឹងគិត ដើម្បីត្រូវការបច្ច័យច្រើន ។ អធិប្បាយថា អ្នកដល់សេចក្ដីខ្វល់ខ្វាយយ៉ាងនេះថា

"ធ្វើយ៉ាងណាហ្ន៎ ភាពជាអ្នកមានបច្ច័យ មានចីវរជាដើមច្រើន នឹងមានដល់យើងនិងសាវករបស់យើង" ។

## ពន្យល់អត្ថក្នុងផ្នែកត្រាស់ប្រជុំសង្ឃហើយទ្រង់បញ្ញត្តិសិក្ខាបទ

ច្រើនបទថា ធម្មឹ កថំ កត្វា[1] : ទ្រង់សម្តែងធម្មីកថា មានសេចក្តីថា ទ្រង់ធ្វើធម្មីកថា ដែលសមគួរក្នុងខណៈនោះ គឺ សមរម្យក្នុងខណៈនោះ ដល់ភិក្ខុទេវទត្តនិងដល់ភិក្ខុទាំងឡាយជាច្រើនប្រការ ដោយន័យដែលត្រាស់ទុកក្នុងខន្ធកៈ មានជាដើមយ៉ាងនេះថា "កុំទេវទត្ត អ្នកកុំចូលចិត្តនឹងការបំបែកសង្ឃឡើយ, ម្នាលទេវទត្ត ដ្បិតការបំបែកសង្ឃមានទោសធ្ងន់ណាស់ ម្នាលទេវទត្ត ប្រសិនបើអ្នកណាមួយបំបែកសង្ឃដែលកំពុងព្រមព្រៀងគ្នា, (អ្នកនោះ) នឹងទទួលទោសលាមកអាក្រក់តាំងនៅអស់មួយកប្ប, ឆេះនៅក្នុងនរកអស់ ១ កប្ប, ម្នាលទេវទត្ត បើអ្នកណាមួយ ធ្វើសង្ឃដែលបែកគ្នាហើយឱ្យព្រមព្រៀងគ្នាទៅវិញ, (អ្នកនោះ) តែងទទួលនូវបុណ្យដ៏ប្រសើរ ហើយនឹងរីករាយក្នុងឋានសួគ៌អស់ ១ កប្ប"[2] ដូច្នេះ ។

---

១. ពាក្យនេះ មិនមានក្នុងសិក្ខាបទនេះ ប្រហែលជានៅក្នុង ។បេ ។

២. វិន. ចុល្ល. សង្ឃភេទក្ខន្ធកៈ. ១១. ៥០/៥៩ ។

[២៩៤] បទថា សមគ្គស្ស : ដែលព្រមព្រៀងគ្នា បានដល់អ្នករួមគ្នា, អធិប្បាយថា អ្នកមិនបែកគ្នាទាំងមកចិត្តនិងមកកាយ ។ ពិតមែន សូម្បីក្នុងបទភាជនៈ ព្រះមានព្រះភាគក៏បានទ្រង់សម្តែងសេចក្តីយ៉ាងនេះដូចគ្នា ។

ពិតមែន ព្រះមានព្រះភាគកាលត្រាស់ថា សមានសំវាសកោ : ដែលមានសំវាសស្មើគ្នា ក៏ជាការដែលទ្រង់សម្តែងសេចក្តីមិនបែកគ្នាមកចិត្ត ។

កាលត្រាស់ថា សមានសីមាយំ ឋិតោ : ឋិតនៅក្នុងសីមាជាមួយគ្នា រមែងជាការទ្រង់សម្តែងសេចក្តីមិនបែកគ្នាមកកាយ ។ គឺយ៉ាងណា ? គឺ ថា ភិក្ខុដែលមានសំវាសស្មើគ្នា វៀរចាកអ្នកមានសំវាសផ្សេងគ្នាដោយលទ្ធិ ឬអ្នកមានសំវាសផ្សេងគ្នាដោយកម្ម ឈ្មោះថា ជាអ្នកមិនបែកគ្នាមកចិត្ត ព្រោះមានចិត្តស្មើគ្នា, អ្នកតាំងនៅក្នុងសីមាស្មើគ្នា ឈ្មោះថា ជាអ្នកមិនបែកគ្នាមកកាយ ព្រោះឱ្យកាយសាមគ្គី ។

ពីរបទថា ភេទនសំវត្តនិកំ វា អធិករណំ : អធិករណ៍ដែលនាំឱ្យសង្ឃបែកគ្នា បានដល់ ហេតុដែលប្រព្រឹត្តទៅដើម្បីបែកគ្នា គឺដើម្បីត្រូវការបំបែកសង្ឃ ។

ពិតមែន ក្នុងឱកាសនេះ ហេតុលោកប្រាថ្នាយកថា អធិករណ៍

ដូចក្នុងប្រយោគថា "កាមហេតុ កាមនិទានំ កាមាធិករណំ : មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឱ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម"[១] ។ ក៏ព្រោះអធិករណ៍នោះមាន ១៨ ប្រការ; ដូច្នោះ ក្នុងបទភាជនៈទើបព្រះមានព្រះភាគត្រាស់ថា "ភេទករវត្ថុ ១៨"[២] ។ ក៏ភេទករវត្ថុទាំងនោះមកហើយក្នុងខន្ធកៈ ដោយន័យជាដើមថា "ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សម្តែងសភាពមិនមែនជាធម៌ថា ជាធម៌"[៣] ដូច្នេះ ។ ព្រោះហេតុនោះ ខ្ញុំព្រះករុណានឹងពណ៌នាសេចក្តីនៃភេទករវត្ថុទាំងនោះ ក្នុងសង្ឃភេទក្ខន្ធកៈនោះឯង ។ មួយទៀត សង្ឃភេទនេះសូម្បីណា អាស្រ័យវត្ថុទាំងនេះ រមែងមានដោយហេតុដទៃទៀត ៥ ប្រការ គឺ ដោយកម្ម ១ ដោយឧទ្ទេស ១ ដោយវោហារ ១ ដោយអនុស្សាវនា ១ ដោយការចាប់ស្លាក ១, ខ្ញុំព្រះករុណានឹងប្រកាសសង្ឃភេទនោះ ក្នុងអនាគតស្ថានទុំះឯង ។ តែដោយសង្ខេបក្នុងពាក្យថា កាន់យកអធិករណ៍ដែលប្រព្រឹត្តទៅដើម្បីសេចក្តីបែកគ្នា នេះអ្នកសិក្សាគប្បីជ្រាបសេចក្តីយ៉ាងនេះថា កាន់យកហេតុដែលប្រព្រឹត្តទៅដើម្បីត្រូវការបំបែកសង្ឃ គឺ ដែលអាចឱ្យសម្រេចការបំបែកសង្ឃបាន ។

---

១. មជ្ឈិ. មូល. មហាទុក្ខក្ខន្ធសូត្រ. ២០. ១៩៨/៣១៥ ។

២. វិន. បរិ. កតិបុច្ឆាវារៈ. ១២. ៨៤២/៣៦៤ ។

៣. វិន. ចុល្ល. សង្ឃភេទក្ខន្ធកៈ. ១១. ៧៥/៨៤ ។

បទថា បគ្គយ្ហ : ផ្គងឡើង បានដល់ ផ្គង គឺ លើកតម្កើងធ្វើឱ្យប្រាកដ ។

បទថា តិដ្ឋេយ្យ : តាំងនៅ មានសេចក្ដីថា ធ្វើឱ្យដូចដែលខ្លួនកាន់យកហើយគឺ ដូចដែលខ្លួនលើកតម្កើងហើយទុំះឯង ហើយគប្បីតាំងនៅ ។ ក៏ព្រោះអធិករណ៍នោះ រមែងជាការដែលភិក្ខុផ្គងនិងតាំងនៅយ៉ាងនោះ សម្ដែងហើយនិងមិនលះបង់ចេញ; ដូច្នោះ ក្នុងបទភាជនៈ ទើបព្រះមានព្រះភាគត្រាស់ថា "សម្ដែង" និងថា "មិនលះបង់" ដូច្នេះ ។

[២៩៥] ពាក្យថា ភិក្ខូហិ ឯវមស្ស វចនីយោ : ភិក្ខុទាំងឡាយ ត្រូវពោលហាម ដោយពាក្យយ៉ាងនេះ មានសេចក្ដីថា ភិក្ខុនោះជាអ្នកដែលពួកលជ្ជីភិក្ខុដទៃទីឯគប្បីពោលយ៉ាងនេះ ។

ក៏ក្នុងបទភាជនៈនៃបទថា ភិក្ខូហិ នោះ មានវិនិច្ឆ័យដូច្នេះ ៖

ពាក្យថា យេ បស្សន្តិ : ភិក្ខុណាបានឃើញ មានសេចក្ដីថា ភិក្ខុពួកណាឃើញ ភិក្ខុនោះ អ្នកសរសើរលើកតម្កើងនៅចំពោះមុខ ។

ពាក្យថា យេ សុណន្តិ : ភិក្ខុណាបានឮ មានសេចក្ដីថា សូម្បីភិក្ខុពួកណា បានឮថា "ពួកភិក្ខុក្នុងវិហារឈ្មោះឯណោះ កាន់យកអធិករណ៍ដែលប្រព្រឹត្តទៅដើម្បីសេចក្ដីផ្សេងគ្នាលើកតម្កើង" ។

ពាក្យថា សមេតាយស្មា សង្ឃេន : សូមឱ្យលោកម្ចាស់ព្រម

ព្រៀងជាមួយនឹងសង្ឃទៅ មានសេចក្ដីថា លោកដ៏មានអាយុ សូមចូលរួមសមាគម ចូរជាអ្នកមានលទ្ធិជាមួយគ្នាព្រមដោយសង្ឃ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា សមគ្គោ ហិ សង្ឃោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតិ : ព្រោះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅជាសុខ ។

បណ្ដាបទទាំងនោះ បទថា សម្មោទមានោ : រីករាយរកគ្នា មានសេចក្ដីថា រីករាយនៅដោយល្អប្រកបដោយសម្បត្តិ (មានសីលជាដើម) របស់គ្នានិងគ្នា ។

បទថា អវិវទមានោ : មិនវិវាទគ្នា មានសេចក្ដីថា មិនវិវាទគ្នាយ៉ាងនេះថា "នេះធម៌ នេះមិនមែនធម៌" ។

សង្ឃនោះមានឧទ្ទេសតែមួយរួមគ្នា ; ព្រោះហេតុនោះ ទើបឈ្មោះថា ឯកុទ្ទេស : មានឧទ្ទេសជាមួយគ្នា ។ អធិប្បាយថា មានបាដិមោក្ខុទ្ទេស ប្រព្រឹត្តទៅរួមគ្នាមិនបែកគ្នា ។

ពីរបទថា ផាសុ វិហរតិ : តែងនៅជាសុខសប្បាយ បានដល់រមែងនៅជាសុខ ។

ពាក្យថា ឥច្ចេតំ កុសលំ : ការលះបង់បាននេះ ជាការល្អ

មានសេចក្តីថា ការលះបង់ចេញបាននោះ ជាកុសលគឺ រួចផុតភ័យ បានដល់ ជាសុវត្ថិភាពដល់ភិក្ខុនោះ ។

ពាក្យថា នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស : បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ បានដល់ ភិក្ខុដែលត្រូវសូធ្យ ៣ ដង ហើយមិនលះបង់ចេញត្រូវ អាបត្តិទុក្កដ ។

ពាក្យថា សុត្វា ន វទន្តិ អាបត្តិ ទុក្កដស្ស : ភិក្ខុទាំងឡាយបានឮហើយ មិនពោល( ហាម ) ត្រូវអាបត្តិទុក្កដ មានសេចក្តីថា ត្រូវអាបត្តិទុក្កដសូម្បីដល់ពួកភិក្ខុអ្នកបានឮហើយមិនពោល( ហាម ) ក្នុងទីឆ្ងាយប៉ុន្មាន ទើបត្រូវអាបត្តិទុក្កដ ដល់ពួកភិក្ខុដែលបានឮ ហើយមិនពោល( ហាម ) ។ ក្នុងវិហារជាមួយគ្នា មិនមានពាក្យដែលនឹងពោលឡើយ ។ ចំណែកក្នុងអដ្ឋកថា លោកពោលថា ក្នុងចម្ងាយមកកន្លះយោជន៍ដោយជុំវិញចាត់ជាភារៈរបស់ភិក្ខុទាំងឡាយ ។ ការផុតពីអាបត្តិរមែងមិនមាន សូម្បីដល់ភិក្ខុដែលបញ្ជូនទូត ឬ សំបុត្រទៅប្រាប់ ។ គប្បីទៅហាមខ្លួនឯងតែម្តងថា លោកដ៏មានអាយុ ការបំបែកសង្ឃមានទោសធ្ងន់, លោកកុំព្យាយាមដើម្បីបំបែកសង្ឃ ។ តែភិក្ខុដែលអាចសូម្បីឆ្ងាយ ក៏គួរទៅ ។ ពិតមែន សូម្បីដែលឆ្ងាយ ៗ ចាត់ជាភារៈរបស់ពួកភិក្ខុមិនអាពាធតែម្តង ។ ឥឡូវនេះ ដើម្បីទ្រង់សម្តែងត្រឹមតែ

សេចក្ដីប៉ុណ្ណោះក្នុងពាក្យថា "ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ : ភិក្ខុនោះ កាលភិក្ខុទាំងឡាយ ពោល(ហាម)យ៉ាងនេះ"ជាដើម ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា "សោ ភិក្ខុ សង្ឃមជ្ឈម្បិ អាកឌ្ឍិត្វា វត្តព្វោ : ភិក្ខុនោះ ត្រូវតែភិក្ខុទាំងឡាយចាប់ទាញមកកាន់កណ្ដាលជំនុំសង្ឃហើយពោល(ហាម)" ដូច្នេះ ។

បណ្ដាបទទាំងនោះ ពីរបទថា សង្ឃមជ្ឈម្បិ អាកឌ្ឍិត្វា : ចាប់ទាញមកកាន់កណ្ដាលជំនុំសង្ឃ មានសេចក្ដីថា បើភិក្ខុនោះ ដែលពួកភិក្ខុពោលហាមនៅដោយន័យមុន មិនទាន់លះបង់ចេញ សូម្បីពួកភិក្ខុចាប់ត្រង់ដៃនិងត្រង់ជើងទាញខ្លួនមកកាន់កណ្ដាលជំនុំសង្ឃ ហើយគប្បីពោលប្រដៅលោកដល់ ៣ ដងទៀត ដោយន័យជាដើមថា មា អាយស្មា : លោកម្ចាស់ កុំ ដូច្នេះ ។

[២៩៦] ពីរបទថា យាវតតិយំ សមនុភាសិតព្វោ : សូម្បីសមនុភាសនកម្ម ជាកំណត់បីដង មានសេចក្ដីថា សង្ឃគប្បីសូត្រសមនុភាសនៈជាគម្រប់ ៣ ដងជាមុន ។ មានពាក្យអធិប្បាយថា សង្ឃគប្បីធ្វើកម្មដោយ សមនុភាសនកម្មវាចា ៣ ដង ។ ក៏ក្នុងបទភាជនៈនៃបទថា យាវតតិយំ សមនុភាសិតព្វោ នោះ ដើម្បីកាន់យកតែសេចក្ដីសម្ដែងសមនុភាសនវិធី ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា សោ

ភិក្ខុ សមនុភាសិតព្វោ ឯវញ្ច បន ភិក្ខវេ សមនុភាសិតព្វោ : ភិក្ខុទាំងឡាយគប្បីសូធ្យសមនុភាសនកម្មដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសូធ្យសមនុភាសនកម្មយ៉ាងនេះ ដូច្នេះ ។

[២៩៧] ក្នុងពាក្យថា សមនុភាសិតព្វោ ជាដើមនោះ ពាក្យថា ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា បដិប្បស្សម្ភន្តិ : សូធ្យញត្តិចប់ ត្រូវអាបត្តិទុក្កដ, សូធ្យកម្មវាចាពីរជង ត្រូវអាបត្តិថុល្លច្ច័យ, មានសេចក្តីថា អាបត្តិទាំង ៣ គឺ ទុក្កដដែលភិក្ខុត្រូវក្នុងទីបំផុតញត្តិ និងថុល្លច្ច័យ ដែលត្រូវព្រោះកម្មវាចា ២ ជង រមែងរម្ងាប់ទៅដោយកម្មវាចាទី ៣ លុះសូធ្យដល់ យ អក្សរ យ៉ាងនេះថា យស្ស នក្ខមតិ សោ ភាសេយ្យ, ភិក្ខុនោះ រមែងតាំងនៅក្នុងសង្ឃាទិសេសតែម្តង ។

សួរថា អាបត្តិដែលត្រូវហើយរម្ងាប់ទៅ ឬថា អាបត្តិដែលមិនបានត្រូវរម្ងាប់ ។

ឆ្លើយថា ព្រះមហាសុមត្ថេរៈពោលទុកមុនថា ភិក្ខុណាលះបង់កម្មនោះក្នុងវេលាចប់, ភិក្ខុនោះ រមែងមិនត្រូវអាបត្តិទាំងនោះ ; ព្រោះហេតុនោះ អាបត្តិដែលមិនបានត្រូវទើបរម្ងាប់ទៅ ចំណែកព្រះមហាបទុមត្ថេរៈពោលថា អាបត្តិដែលត្រូវហើយ រមែងរម្ងាប់ទៅ ដូចអសាធារណាបត្តិ

រម្ងាប់ទៅព្រោះភេទត្រឡប់ដូច្នោះ, នឹងប្រយោជន៍អ្វី ដោយអាបត្តិដែលនៅមិនបានត្រូវរម្ងាប់ទៅហ្ន៎ ?

## ពន្យល់អត្ថក្នុងបទភាជនីដោយកម្មប្រកបដោយធម៌ជាដើម

[២៩៨] ពីរបទថា **ធម្មកម្មេ ធម្មកម្មសញ្ញី** : ភិក្ខុសំគាល់ក្នុងកម្មដែលសង្ឃធ្វើត្រូវតាមធម៌ថា កម្មធ្វើត្រូវតាមធម៌ មានសេចក្ដីថា បើសមនុភាសនកម្មនោះជាកម្មប្រកបដោយធម៌ លោកមានការសម្គាល់ក្នុងសមនុភាសនកម្មនោះថា ជាកម្មប្រកបដោយធម៌ ។ ក្នុងបទទាំងពួងក៏មានន័យដូចគ្នានេះ ។ ការសម្គាល់ក្នុងបទថា **កម្មសញ្ញី** នេះ មិនអាចផុតបាន ព្រោះកម្មជារបស់ប្រកបដោយធម៌ កាលមិនលះបង់យ៉ាងនោះ រមែងត្រូវអាបត្តិ ។

[២៩៩] បទថា **អសមនុភាសន្តស្ស** : ដល់ភិក្ខុដែលសង្ឃមិនទាន់បានសូត្រប្រកាសហាម មានសេចក្ដីថា កាលមិនត្រូវសូធ្យសមនុភាសនៈសូម្បីមិនព្រមលះបង់ ក៏មិនត្រូវអាបត្តិសង្ឃាទិសេស ។

បទថា **បដិនិស្សជ្ជន្តស្ស** : ដល់ភិក្ខុដែលបានលះបង់ មានសេចក្ដីថា មិនត្រូវដោយអាបត្តិសង្ឃាទិសេសដល់ភិក្ខុដែលលះបង់មុនញត្តិ ឬក្នុងខណៈញត្តិ ឬក្នុងវេលាចប់ញត្តិ ឬដែលត្រឹមតែសូធ្យមិនទាន់ដល់

យ អក្សរ នៃអនុសាវនាទី ១ ក្តី ទី ២ ក្តីទី ៣ ក្តី ។

បទថា អាទិកម្មិកស្ស : ដល់ភិក្ខុជាអាទិកម្មិក មានសេចក្តីថា ក៏ក្នុងសិក្ខាបទនេះ ភិក្ខុទេវទត្តជាដើមបញ្ញត្តិ ព្រោះបាលីដែលមកក្នុងគម្ពីរបរិវារថា "ព្រោះរឿងរ៉ាវដែលភិក្ខុទេវទត្តព្យាយាមដើម្បីបំបែកសង្ឃដែលព្រមព្រៀងគ្នា"[១] ។ ក៏ភិក្ខុទេវទត្តនុ៎ះឯងជាដើមបញ្ញត្តិនៃការព្យាយាមដើម្បីបំបែកសង្ឃប៉ុណ្ណោះ មិនបានជាដើម បញ្ញត្តិនៃការមិនព្រមលះបង់ទេ ។ ព្រោះថា កម្មនោះ សង្ឃមិន បានធ្វើដល់លោក ។

បើមានពាក្យសួរថា ក៏ពាក្យដែលពោលនេះ តើគួរជ្រាបបានយ៉ាងណា ?

ឆ្លើយថា គប្បីជ្រាបបាន ដោយព្រះសូត្រ ។ ដូចឧបមាថា កម្មរមែងប្រាកដថា សង្ឃធ្វើហើយដល់អរិដ្ឋភិក្ខុ ព្រោះបាលីដែលមកក្នុងគម្ពីរបរិវារៈថា "ព្រោះរឿងដែលអរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត កាលបើសង្ឃសូធ្យសមនុភាសនកម្ម ជាគម្រប់បីដងហើយមិនលះបង់ទិដ្ឋិអាក្រក់ចេញ"[២] ដូច្នេះ យ៉ាងណា, កម្មនឹងបានប្រាកដថា សង្ឃធ្វើដល់ភិក្ខុទេវទត្ត ដូច្នោះ ក៏ទេ ។

សូម្បីបើអ្នកណាមួយ នឹងពោលដោយហេតុត្រឹមតែសេចក្តីពេញ

---

១. វិន. បរិ. មហាវិភង្គវារៈ. ១២. ១៨/២១ ។ ២. វិន. បរិ. ១២. ១៣៣/៨៤ ។

ចិត្តរបស់ខ្លួនប៉ុណ្ណោះថា "កម្មដែលសង្ឃធ្វើហើយដល់ភិក្ខុទេវទត្តនោះ នឹងមានសោត សូម្បីយ៉ាងនោះ ដែលឈ្មោះថា អនាបត្តិ រមែងមិនមានដល់ភិក្ខុដែលជាដើមបញ្ញត្តិ ព្រោះការមិនលះបង់ចេញ" ។ ពិតមែន ដែលឈ្មោះថា អនាបត្តិ រមែងមិនប្រាកដដល់ភិក្ខុដែលកន្លងសិក្ខាបទ ដែលទ្រង់បញ្ញត្តិហើយ ក្រៅអំពីសិក្ខាបទដែលទ្រង់អនុញ្ញាតទុកដោយចំពោះ ។

សូម្បីពាក្យថា **អាទិកម្មិកស្ស** ក្នុងអនាបត្តិវារនៃអរិដ្ឋសិក្ខាបទដែលលោកសរសេរទុកក្នុងគម្ពីរទាំងឡាយ ក៏សរសេរទុកដោយសេចក្តីភាំងភាត់ ។ ក៏ឯសេចក្តីនៃពាក្យនោះ ជាពាក្យដែលលោកសរសេរទុកដោយសេចក្តីភាំងភាត់ គប្បីជ្រាបដោយព្រះបាលីសម្រាប់លើកអាបត្តិក្នុងកម្មក្ខន្ធកៈយ៉ាងនេះថា "សង្ឃត្រូវចោទអរិដ្ឋភិក្ខុជាមុនសិន, លុះចោទហើយត្រូវរំលឹក, លុះរំលឹកហើយ ត្រូវលើកអាបត្តិឡើង" ។ កម្មនោះសង្ឃមិនបានធ្វើដល់ភិក្ខុទេវទត្ត ដែលជាអាទិកម្មិកៈ ព្រោះការព្យាយាមដើម្បីបំបែកសង្ឃ ដោយប្រការដូច្នេះ; ព្រោះហេតុនោះ អាបត្តិនុ៎ះឯងឈ្មោះថា មិនទាន់កើត, តែភិក្ខុទេវទត្តនោះ ត្រូវហៅថា អ្នកជាដើមបញ្ញត្តិ ព្រោះធ្វើសេចក្តីយល់ថា ព្រះមានព្រះភាគ ទ្រង់ប្រារព្ធលោកបញ្ញត្តិសិក្ខាបទ ។ អនាបត្តិលោកពោលហើយ សម្រាប់ភិក្ខុទេវទត្តនោះ ព្រោះមិនមានអាបត្តិនុ៎ះឯង ដោយប្រការដូច្នេះ ។

ឯអនាបត្តិនោះ សម្រេចដោយបទនេះឯងថា អសមនុភាសន្តស្ស សូម្បីដោយពិត, តែថា សង្ឃមិនបានធ្វើសមនុភាសនកម្មតែម្យ៉ាង ដល់ភិក្ខុណាភិក្ខុនោះ លោកហៅ ឈ្មោះថា អ្នកមិនត្រូវសូធ្យសមនុភាសនៈ, មិនហៅថា អ្នកជាដើមបញ្ញត្តិ ។ ចំណែកភិក្ខុទេវទត្តនេះ គង់ជាដើមបញ្ញត្តិពិត, ព្រោះហេតុនោះ លោកទើបពោលបទថា អាទិកម្មិកស្ស ទុក ។

វិនិច្ឆ័យក្នុងសមនុភាសន៍នៃសិក្ខាបទទាំងពួង វៀរតែអរិដ្ឋសិក្ខាបទចេញ គប្បីជ្រាបដោយឧបាយនេះ ។ ពាក្យដ៏សេសក្នុងបទទាំងពួងងាយយល់ទាំងអស់ ។

បណ្ដាបកិណ្ណកៈមានសមុដ្ឋានជាដើម សិក្ខាបទនេះ មានអង្គ ៣ មានសមុដ្ឋានតែមួយ, ឈ្មោះថា សមនុភាសនសមុដ្ឋាន រមែងតាំងឡើងមកកាយ មកវាចានិងមកចិត្ត, តែជាអកិរិយា ព្រោះកាលភិក្ខុមិនធ្វើកាយវិការ ឬបញ្ចេញវាចាឡើយថា យើងនឹងលះបង់ចេញ ទើបត្រូវ, ជាសញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដោយប្រការដូច្នេះ ។

សង្ឃភេទសិក្ខាបទវណ្ណនា ចប់

# ១១. តេនានុវត្តកសិក្ខាបទវណ្ណនា

[៣០០] ទុតិយសង្ឃភេទសិក្ខាបទថា តេន សមយេន ពុទ្ធោ ភគវា : សម័យនោះ ព្រះពុទ្ធដ៏មានឥស្សរិយយសជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងទុតិយសង្ឃភេទសិក្ខាបទនោះ មានវិនិច្ឆ័យដូច្នេះ ៖

## ពន្យល់អត្ថក្នុងរឿងភិក្ខុប្រព្រឹត្តតាមភិក្ខុដែលបំបែកសង្ឃ

បទថា អនុវត្តកា : ប្រព្រឹត្តតាម មានសេចក្ដីថា អ្នកបដិបត្តិតាម ដោយប្រកាន់យកសេចក្ដីឃើញ សេចក្ដីពេញចិត្ត និងសេចក្ដីគាប់ចិត្តនៃភិក្ខុទេវទត្តនោះ (អ្នកបង្ករហេតុដើម្បីបំបែកសង្ឃ) ។ ភិក្ខុពួកណានិយាយពាក្យជាពួក គឺ ពាក្យមានក្នុងបក្ខពួកនៃការមិនសាមគ្គីគ្នា ; ព្រោះហេតុនោះ ភិក្ខុទាំងនោះ ទើបឈ្មោះថា អ្នកពោលពាក្យជាពួក ។

[៣០១] ក៏ក្នុងបទភាជនៈ ព្រះមានព្រះភាគត្រាស់ទុកថា "តាំងនៅក្នុងសេចក្ដីសរសើរភិក្ខុជាអ្នកបំបែកសង្ឃនោះផង ក្នុងពួកនៃភិក្ខុនោះផង" ។ អធិប្បាយថា តាំងនៅហើយ ដើម្បីត្រូវការសរសើរ និងដើម្បីត្រូវការសេចក្ដីចម្រើននៃបក្ខពួក ដល់ភិក្ខុទេវទត្តដែលខ្នះខ្នែងដើម្បីបំបែកសង្ឃនោះ ។ ពួកភិក្ខុដែលពោលពាក្យជាបក្ខពួក រមែងជាបុគ្គលបែបនេះដោយនិយម ; ព្រោះហេតុនោះ លោកទើបពោលពាក្យនេះ ។ តែព្រោះភិក្ខុច្រើនជាង ៣ រូប ជាអ្នកមិនគួរដល់កម្ម ព្រោះសង្ឃនឹងធ្វើកម្ម

ដល់សង្ឃមិនបាន; ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ឯកោ វា ទ្វេ វា តយោ វា ដូច្នេះ ។

បទថា ជានាតិ នោ : លោកដឹងពួកយើង សេចក្តីថា លោកដ៏មានអាយុនោះ រមែងដឹងសូម្បីសេចក្តីពេញចិត្តជាដើមរបស់ពួកយើង ។

បទថា ភាសតិ : ទើបពោល មានសេចក្តីថា រមែងពោលនឹងពួកយើងថា "ពួកខ្ញុំព្រះករុណានឹងធ្វើយ៉ាងនេះ" ។

ពាក្យថា អម្ហាកំបេតំ ខមតិ : អំពើនេះ ក៏គាប់ចិត្តដល់ពួកយើងទាំងឡាយ មានសេចក្តីថា លោកដ៏មានអាយុនោះ រមែងធ្វើវត្ថុណា, វត្ថុនោះ រមែងជាទីពេញចិត្ត សូម្បីដល់ពួកយើង ។

[៣០២] ពាក្យថា សមេតាយស្មន្តានំ សង្ឃេន : សូមលោកម្ចាស់ទាំងឡាយព្រមព្រៀងជាមួយនឹងសង្ឃទៅ មានសេចក្តីថា ចិត្តរបស់លោកដ៏មានអាយុទាំងឡាយ ចូរដល់ព្រម គឺ ចូរមកព្រម, អធិប្បាយថា ចូរធ្វើដំណើរទៅកាន់ភាពសាមគ្គីជាមួយនឹងសង្ឃ ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ ប្រាកដច្បាស់ហើយទាំងអស់ ព្រោះមានន័យដូចពោលហើយក្នុងសិក្ខាបទមុន និងព្រោះមានអត្ថដែលងាយយល់ ។ សូម្បីសមុដ្ឋានជាដើម ក៏ដូចគ្នានឹងសិក្ខាបទមុននោះឯង ។

ភេទានុវត្តកសិក្ខាបទវណ្ណនា ចប់

# ១២. ទុព្ពចសិក្ខាបទវណ្ណនា

[៣០៧] ទុព្ពចសិក្ខាបទថា តេន សមយេន ពុទ្ធោ ភគវា : សម័យនោះ ព្រះសម្ពុទ្ធអ្នកមានឥស្សរិយយសជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងទុព្ពចសិក្ខាបទនោះ មានវិនិច្ឆ័យដូច្នេះ ៖

## ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងភិក្ខុឆន្នៈ

ពីរបទថា អនាចារំ អាចរតិ : ប្រព្រឹត្តអនាចារ មានសេចក្តីថា រមែងធ្វើការកន្លងល្មើសមកកាយទ្វារនិងវចីទ្វារ មានច្រើនប្រការ ។

ពាក្យថា កឹ នុ ខោ នាម : សំគាល់ថា លោកត្រូវពោលប្រដៅខ្ញុំឬ នេះ ជាការពោលគ្រុបសង្កត់ ( អ្នកដទៃ ) ។

ពាក្យថា អហំ ខោ នាម : ខ្ញុំឯងទេតើ ជាពាក្យលើក ( ខ្លួន ) ។

ដោយពាក្យថា តុម្ហេ វចនីយា : ទើបត្រូវពោលប្រដៅលោកទាំងឡាយ លោកសម្តែងថា "យើងគួរ ពោលនឹងពួកលោកថា ពួកលោកចូរធ្វើយ៉ាងនេះ កុំធ្វើយ៉ាងនេះ" ។

បើមានអ្នកមកសួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះឆន្នភិក្ខុពោលសំដៅយកសេចក្តីប្រាថ្នាជាដើមយ៉ាង

នេះថា “ព្រះមានព្រះភាគ ទ្រង់សេះកណ្ឋកៈស្តេចចេញពីរាជវាំងជាមួយនឹងយើង ទ្រង់ព្រះផ្នួសហើយ” ។ កាលពោលថា “ព្រះធម៌របស់យើង” ហើយ កាលនឹងសម្តែងបញ្ចប់ក្នុងសេចក្តីរបស់ខ្លួន ៗទៀត ទើបពោលថា “ព្រះធម៌នេះ ព្រះអយ្យបុត្តជាម្ចាស់របស់យើងបានត្រាស់ដឹងហើយ” ដូច្នេះ ។ មានពាក្យអធិប្បាយថា ព្រោះថា សច្ចធម៌ ៤ ដែលព្រះអយ្យបុត្តជាម្ចាស់របស់យើងត្រាស់ដឹងហើយ; ដូច្នោះ សូម្បីព្រះធម៌ក៏ជារបស់យើង ។ តែសម្គាល់ព្រះសង្ឃថា “តាំងនៅក្នុងបក្ខពួកនៃអ្នកគួរវេរបស់ខ្លួន” ទើបមិនពោលថា “ព្រះសង្ឃរបស់យើង” ។ តែប្រាថ្នានឹងពោលបញ្ចិតបញ្ចៀងរុករានសង្ឃ ទើបពោលពាក្យជាដើមថា សេយ្យថាបិឆាម ដូច្នេះ ។

បទថា តិណាកដ្ឋបណ្ណសដំ[1] : ស្មៅ កំណាត់ឈើ ស្លឹកឈើស្ងួត បានដល់ ស្មៅ ឈើ និងស្លឹកឈើស្ងួត ដែលរង្គោះរង្គោយធ្លាក់ទៅក្នុងស្ថានទីនោះ ៗ ។ ម្យ៉ាងទៀត ស្មៅផង ឈើស្រោយមិនមានខ្លឹមផង ; ហេតុនោះ ទើបឈ្មោះថា ស្មៅនិងឈើ ។ ស្លឹកឈើចាស់ឈ្មោះថា បណ្ណសដៈ ( ស្លឹកឈើស្ងួត ) ។

បទថា ឧស្សាទេយ្យ[1] : បក់បោកប្រមូល បានដល់ បក់ទៅរួម

១. ភូមា. ឧស្សារេយ្យ ។

ជាគំនរទុក ។

បទថា បព្វតេយ្យា : ចាកភ្នំ បានដល់ កើតអំពីភ្នំ ។ ពិតមែន ទន្លេនោះមានក្រសែដែលហូរត្របាញ់ ; ព្រោះដូច្នោះ ទើបលោកបញ្ចូល យកតែទន្លេនោះប៉ុណ្ណោះ ។

ក្នុងពាក្យថា សង្ខសេវាលបណកំ : ចកធំសារាយនិងចកបាយ ទា នេះ មានវិនិច្ឆ័យដូច្នេះ ៖

សារាយដែលមានស្លឹក មានឫសវែង ហៅថា ចកធំ ។ សារាយ ពណ៌ខៀវ ហៅថា សារាយ ។ សារាយដ៏សេសមានស្លែទឹក និង ចកតូច ៗជាដើម សូម្បីទាំងអស់ដល់ការរាប់ថា ចកបាយទា ។

ដោយពាក្យថា ឯកតោ ឧស្សាធិតា : មករួមជាមួយគ្នាបាន លោកសម្តែងថា សូម្បីដែលអ្នកណា ៗ ប្រមូលមកហើយ គឺ ធ្វើជា គំនរទុកក្នុងទីតែមួយរួមគ្នា ។

[៣០៨] បទថា ទុព្វចជាតិកោ : ភិក្ខុមានជាតិដែលគេប្រដៅ ក្រ បានដល់ មានភាវៈនៃបុគ្គលអ្នកប្រដៅបានដោយលំបាក ។ អធិប្បាយថា អ្នកដែលអ្នកណា ៗ មិនអាចពោលប្រដៅបាន ។ សូម្បី ក្នុងបទភាជនៈនៃបទថា ទុព្វចជាតិកោ នោះ បទថា ទុព្វចោ : ស្តី

ប្រដៅបានដោយក្រ បានដល់ អ្នកដែលគេពោលទូន្មានបានលំបាក គឺ ដោយលំបាក ។ មានពាក្យអធិប្បាយថា ដែលអ្នកណា ៗ មិនអាចពោលថាបានដោយងាយឡើយ ។

បទថា **ទោវចស្សករណេហិ : ជាហេតុធ្វើឱ្យប្រដៅក្រ** គឺ (ដោយធម៌) ដែលធ្វើភាពជាអ្នកប្រដៅបានដោយលំបាក ។ អធិប្បាយថា ក៏ធម៌ទាំងឡាយពួកណា រមែងធ្វើបុគ្គលឱ្យជាអ្នកប្រដៅបានដោយលំបាក, ជាអ្នកប្រកបដោយធម៌ទាំងអស់នោះ ។

ក៏បណ្ឌិតគប្បីជ្រាបធម៌ទាំងនោះ មាន ១៩ យ៉ាង[១] គឺ ភាពជាអ្នកមានសេចក្តីប្រាថ្នាលាមក១ សេចក្តីលើកខ្លួនគ្របសង្កត់អ្នកដទៃ១ ភាពជាអ្នកក្រោធច្រើន១ ការចងសេចក្តីក្រោធទុក ព្រោះសេចក្តីក្រោធជាហេតុ១ ភាពជាអ្នកឆេវឆាវច្រើន ព្រោះសេចក្តីក្រោធជាហេតុ១ ភាពជាអ្នកបញ្ចេញវាចាជិតចំពោះសេចក្តីក្រោធ ព្រោះសេចក្តីក្រោធជាហេតុ១ ជាអ្នកត្រឡប់ឈ្លោះប្រកែកនឹងអ្នកចោទ១ ភាពជាអ្នកត្រឡប់រុករានអ្នកចោទ១ ភាពជាអ្នកចោទត្រឡប់ទៅរកអ្នកចោទ១ ភាពជាអ្នកប្តូររឿងដទៃដោយរឿងដទៃ១ ភាពជាអ្នកមិនឆ្លើយតបដោយការប្រព្រឹត្តរបស់ខ្លួន១

---

១. ក្នុងអនុមានសូត្រ មានត្រឹមតែ ១៦ ។

ភាពជាអ្នកមើលងាយ១ វាយឫកស្មើ១ ភាពជាអ្នកឫស្យា១ ជាអ្នកកំណាញ់១ ភាពជាអ្នកអួតអាង១ មាយាពុតត្បុត១ ភាពជាអ្នករឹងត្អឹងមើលងាយអ្នកដទៃ១ ភាពជាអ្នកប្រកាន់តែសេចក្ដីឃើញរបស់ខ្លួន ភាពជាអ្នកចចេសរឹងរូស ភាពជាអ្នកដកបានលំបាក១ ដែលមកហើយក្នុងអនុមានសូត្រ តាមលំដាប់ដោយន័យមានជាដើមថា "ម្នាលអាវុសោទាំងឡាយ ចុះធម៌ដែលធ្វើឱ្យជាអ្នកប្រដៅក្រ តើដូចម្ដេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ (ធម៌ដែលធ្វើឱ្យជាអ្នកប្រដៅក្រនោះ មាន ១៦ យ៉ាង គឺ) ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្ដីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្ដីប្រាថ្នាលាមក"[១] ដូច្នេះ ។

អ្នកណា មិនអត់ទ្រាំ មិនអត់ធន់ចំពោះឱវាទ, ព្រោះហេតុនោះ អ្នកនោះ ឈ្មោះថា អក្ខម: ។ អ្នកណា កាលមិនបដិបត្តិ តាមដែលលោកទូន្មាន មិនទទួលអនុសាសនីដោយចំណែកខាងស្ដាំ ; ព្រោះហេតុនោះ អ្នកនោះ ឈ្មោះថា មានប្រក្រតីមិនទទួលនូវអនុសាសនីដោយចំណែកខាងស្ដាំ ។

បទថា ឧទ្ទេសបរិយាបន្នេសុ : ដែលរាប់បញ្ចូលក្នុងឧទ្ទេស

១. មជ្ឈិ. មូល. អនុមានសូត្រ. ២០. ២២២/៣៥៤ ។

បានដល់ រាប់បញ្ចូលក្នុងឧទ្ទេស គឺ រួមចុះក្នុងខាងក្នុង ។ សេចក្ដីថា ប្រព្រឹត្តទៅខាងក្នុងបាដិមោក្ខុទ្ទេស ព្រោះលោកសង្គ្រោះយ៉ាងនេះថា "យស្ស សិយា អាបត្តិ សោ អាវិករេយ្យ : លោកអង្គណា មាន អាបត្តិ, ត្រូវលោកអង្គនោះប្រាប់"[១] ។

[៣១០] ពីរបទថា សហធម្មិកំ វុច្ចមានោ : ពោលពាក្យប្រកបដោយធម៌ បានដល់ ដែលភិក្ខុទាំងឡាយពោលប្រដៅប្រកបដោយធម៌ ។ នេះជាទុតិយាវិភត្តិចុះ ក្នុងអត្ថនៃតតិយាវិភត្តិ ។ អធិប្បាយថា ដែលភិក្ខុទាំងឡាយ ពោល ប្រដៅដោយសិក្ខាបទដែលព្រះពុទ្ធទ្រង់បញ្ញត្តិទុក ដែលបានទាមថា សហធម្មិក ព្រោះជាសិក្ខាដែលសហធម្មិកទាំង ៥ គប្បីសិក្សា ឬព្រោះជារបស់សហធម្មិកទាំង ៥ នោះ ។

ពាក្យថា វិរមថាយស្មន្តោ មម វចនាយ : សូមពួកលោកម្ចាស់វៀរចាកការពោលប្រដៅខ្ញុំ មានសេចក្ដីថា ពួកលោកពោលប្រដៅខ្ញុំព្រះករុណាដោយពាក្យណា, ចូរលើកអំពីពាក្យនោះ តាមពាក្យរបស់ខ្ញុំព្រះករុណា ។ មានពាក្យអធិប្បាយថា ពួកលោកចូរកុំពោលពាក្យនោះ

១. វិន. មហា. ឧបោសថខន្ធកៈ. ៦. ១៤៩/៣៤០ ។

ចំពោះខ្ញុំព្រះករុណា ។

[៣០៩] ពាក្យថា វទេតុ សហធម្មេន : ពោលប្រដៅភិក្ខុទាំងឡាយ ដោយសហធម៌ មានសេចក្តីថា លោកដ៏មានអាយុ ចូរពោលដោយសិក្ខាបទដែលជាសហធម៌ ឬ ដោយពាក្យសូមឲ្យជ្រែដែលជាសហធម៌ គឺ ប្រព្រឹត្តទៅដើម្បីសេចក្តីជ្រះថ្លា ។

សព្ទថា យទិទំ ជានិបាត ចុះក្នុងអត្ថ គឺ សម្តែងហេតុនៃសេចក្តីចម្រើន ។ ដោយពាក្យថា យទិទំ : ដោយអាការ នោះ រមែងជាការដែលលោកសម្តែងហេតុនៃសេចក្តីចម្រើនរបស់បរិស័ទយ៉ាងនេះថា ការនិយាយណែនាំនូវប្រយោជន៍ដល់គ្នា និងការញ៉ាំងគ្នាឲ្យចេញចាកអាបត្តិនេះណា, បរិស័ទចម្រើនហើយ ដោយការពោលប្រដៅគ្នា និងដោយការញ៉ាំងគ្នា ឲ្យចេញចាកអាបត្តិនោះ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់នោះ ។ សូមឲ្យសមុដ្ឋានជាដើម ក៏ដូចគ្នានឹងបឋមសង្ឃភេទសិក្ខាបទនោះឯង ។

ទុព្វចសិក្ខាបទវណ្ណនា ចប់

# ១៣. កុលទូសកសិក្ខាបទវណ្ណនា

[៣១៤] កុលទូសកសិក្ខាបទថា តេន សមយេន ពុទ្ធោ ភគវា : សម័យនោះព្រះពុទ្ធជាម្ចាស់ដ៏មានបុញ្ញសិរីជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងកុលទូសកសិក្ខាបទនោះ មានវិនិច្ឆ័យដូច្នេះ ៖

## ពន្យល់អត្ថក្នុងរឿងភិក្ខុអស្សជិនិងភិក្ខុបុនព្វសុកៈ

ពាក្យថា អស្សជិបុនព្វសុកា នាម : ភិក្ខុពីររូបឈ្មោះអស្សជិនិងបុនព្វសុកៈ បានដល់ អស្សជិភិក្ខុ១ បុនព្វសុកភិក្ខុ១ ។

បទថា កិដាគិរិស្មឹ : ទៀបកិដាគិរីជនបទ បានដល់ ក្នុងជនបទដែលមានឈ្មោះយ៉ាងនោះ ។

ក្នុងពាក្យថា អាវាសិកា ហោន្តិ : ជាអ្នកនៅក្នុងអាវាស នេះមានវិនិច្ឆ័យដូច្នេះ ៖

អាវាសរបស់ភិក្ខុទាំងនេះ មាន ; ហេតុនោះ ភិក្ខុទាំងនេះ ទើបឈ្មោះថា អាវាសិកៈ (ម្ចាស់អាវាស) ។ វិហារលោកហៅថាអាវាស ។ វិហារនោះជាប់ទាក់ទងដល់ភិក្ខុពួកណា ដោយភាពជាអ្នកមាននាទីក្នុងការកសាងវត្តថ្មី ៗ និងការជុសជុលរបស់ចាស់ជាដើម, ភិក្ខុទាំងនោះឈ្មោះថា អាវាសិកៈ (ម្ចាស់អាវាស) ។ តែភិក្ខុពួកណា ត្រឹមតែនៅក្នុងវិហារតែម្យ៉ាង, ភិក្ខុទាំងនោះ លោកហៅថា នេវាសិកៈ (ម្ចាស់ទី

កន្លែង ) ។ ភិក្ខុអស្សជិ និងបុនព្វសុកៈនេះបានជាម្ចាស់អាវាស ។

ពីរបទថា អលជ្ជិនោ បាបភិក្ខូ : ជាភិក្ខុលាមកឥតខ្មាស បានដល់ ជាពួកភិក្ខុលាមក មិនមានសេចក្ដីខ្មាស ។ ព្រោះថា ភិក្ខុអស្សជិនិងភិក្ខុបុនព្វសុកៈ ទាំងនោះ ជាភិក្ខុឆព្វគ្គិយដែលជាប្រធាននៃភិក្ខុឆព្វគ្គិយទាំងឡាយ ។

## ប្រវត្តិពួកភិក្ខុឆព្វគ្គិយៈ

បានឮថា ជន ៦ នាក់[១] ក្នុងក្រុងសាវត្ថីជាសម្លាញ់នឹងគ្នា ប្រឹក្សាគ្នាថា "ការងារកសិកម្មជាដើមជាការងារដែលលំបាក, ណ្ហើយចុះ សម្លាញ់ទាំងឡាយ ពួកយើងនឹងនាំគ្នាបួស, ក៏ពួកយើងកាលនឹងបួស គួរបួសក្នុងឋានអ្នកជួយរលាស់ចេញ ក្នុងកាលមានកិច្ចការកើតឡើង"[២] ដូច្នេះហើយបានបួសក្នុងសំណាក់នៃព្រះអគ្គសាវកទាំងពីរ ។ ពួកលោកមានវស្សាគ្រប់ ៥ វស្សា ទន្ទេញមាតិកាបានរត់មាត់ហើយ ប្រឹក្សាគ្នាថា ធម្មតាថា "ជនបទពេលខ្លះ ក៏មានភិក្ខាសម្បូរ ពេលខ្លះ មានភិក្ខាខ្សត់ខ្សោយ, ពួកយើងកុំនៅរួមក្នុងទីកន្លែងជាមួយគ្នាឡើយ ចូរបែកគ្នានៅក្នុងទី ៣ កន្លែង" ។

---

( ១ ) ៦ នាក់ គឺ បណ្ឌុកៈ ១ លោហិតកៈ ១ មេត្តិយៈ ១ ភុម្មជកៈ ១ អស្សជិ ១ បុនព្វសុកៈ ១ បួសហើយ ហៅថា ភិក្ខុឆព្វគ្គិយៈ ប្រែថា ភិក្ខុមានពួក ៦ ។

( ២ ) យោជនា. និត្ថរណកដ្ឋានេតិ ឧប្បន្នកិច្ចស្ស និត្ថរណដ្ឋានេតិ ។

លំដាប់នោះ ពួកលោកទើបពោលនឹងភិក្ខុឈ្មោះបណ្ឌុកៈ និងលោហិតកៈថា "លោកដ៏មានអាយុទាំងឡាយ ដែលឈ្មោះថា ក្រុងសាវត្ថី មានត្រកូល៥ លាន ៧ សែនត្រកូល នៅគ្រប់គ្រង ជាមុខនៃសេចក្តីចម្រើនរបស់ដែនកាសី និងកោសលទាំងពីរទំហំប្រមាណ ៣០០ យោជន៍ ប្រដាប់ដោយពួកស្រុក ៨ ម៉ឺនតំបន់, ពួកលោកចូរឱ្យសាងសំណាក់ក្នុងស្ថានទីជិត ៗ ក្រុងសាវត្ថីនោះឯង ហើយដាំស្វាយ ខ្នុរ និងដូងជាដើម សង្គ្រោះត្រកូលដោយផ្កានិងផ្លែឈើទាំងនោះ ឱ្យពួកក្មេងកម្លោះរបស់ត្រកូលបួសហើយពង្រីកបរិស័ទឱ្យចម្រើនចុះ ។

ពោលនឹងពួកភិក្ខុឈ្មោះថា មេត្តិយៈនិងភុម្មជកៈថា លោកដ៏មានអាយុ ឈ្មោះថា ក្រុងរាជគ្រឹះមានពួកមនុស្ស ១៨ កោដិនៅគ្រប់គ្រងជាមាត់មកនៃសេចក្តីចម្រើនរបស់ដែនអង្គៈ និងមគធទាំងពីរ ទំហំ ៣០០ យោជន៍ ប្រដាប់ដោយពួកស្រុក ៨ ម៉ឺនតំបន់, ពួកលោកចូរឱ្យសាងសំណាក់ក្នុងទីជិត ៗ ក្រុងរាជគ្រឹះនោះហើយ ដាំស្វាយ ខ្នុរ និងដូងជាដើម សង្គ្រោះត្រកូលដោយផ្កានិងផ្លែឈើទាំងនោះ ឱ្យពួកក្មេងកម្លោះរបស់ត្រកូលបួសហើយ ពង្រីកបរិស័ទឱ្យចម្រើនចុះ ។

ពោលនឹងពួកភិក្ខុឈ្មោះថា អស្សជិនិងបុនព្វសុកៈថា "លោកដ៏មានអាយុ ដែលឈ្មោះថា កិដាគីរីជនបទ ដែលមានមេឃ ( ភ្លៀង ) ២ រដូវជំនួយហើយ រមែងបានសន្ទូង ៣ ដង, ពួកលោកចូរឱ្យសាង

សំណាក់ ក្នុងទីជិត ៗ គិជាគិរីជនបទនោះឯង ដាំស្វាយ ខ្នុរ និងដូងជាដើមទុក សង្គ្រោះត្រកូលដោយផ្កា និងផ្លែឈើទាំងនោះ ឱ្យពួកក្មេងកម្លោះរបស់ត្រកូលបួស ហើយពង្រីកបរិស័ទឱ្យចម្រើនចុះ ។

ពួកភិក្ខុឆព្វគ្គិយទាំងនោះ បានធ្វើយ៉ាងនោះ បណ្ដាពួកភិក្ខុឆព្វគ្គិយទាំងនោះ ពួកនីមួយ ៗ មានភិក្ខុជាបរិវារ ៥០០ រូប រួមជាចំនួនភិក្ខុ ១,៥០០ រូបជាង ដោយប្រការយ៉ាងនេះ ។

បណ្ដាភិក្ខុទាំងនោះ ភិក្ខុឈ្មោះបណ្ឌុកៈ និងលោហិតកៈព្រមទាំងបរិវារជាអ្នកមានសីល ត្រាច់ទៅកាន់ជនបទជាទីចារិករួមនឹងព្រះមានព្រះភាគ ។ ពួកលោកតែងបន្តឱ្យកើតរឿងថ្មី ៗ ដែលនៅមិនធ្លាប់មានអ្នកណាធ្វើ, តែមិនញ៉ាំញីសិក្ខាបទដែលទ្រង់បញ្ញត្តិហើយទេ ។ ចំណែកពួកភិក្ខុឆព្វគ្គិយក្រៅនេះទាំងអស់ជាអលជ្ជី រមែងបន្តឱ្យកើតរឿងថ្មី ៗ ដែលនៅមិនធ្លាប់មានអ្នកណាធ្វើផង រមែងនាំគ្នាញ៉ាំញីសិក្ខាបទដែលទ្រង់បញ្ញត្តិទុកហើយផង ។ ព្រោះហេតុនោះ ព្រះធម្មសង្គាហកៈទាំងឡាយ ទើបពោលថា អលជ្ជិនោ បាបភិក្ខូ : ជាភិក្ខុលាមក ឥតខ្មាស ដូច្នេះ ។

បទថា ឯវរូបំ : មានសភាពយ៉ាងនេះ បានដល់ មានកំណើតយ៉ាងនេះ ។

ពីរបទថា អនាចារំ អាចរន្តិ : ប្រព្រឹត្តអនាចារ សេចក្ដីថា

រមែងប្រព្រឹត្តកន្លងមារយាទដែលមិនគួរប្រព្រឹត្ត គឺ ធ្វើវត្ថុដែលមិនគួរធ្វើ ។

បទថា មាលាវច្ឆំ : កូនឈើផ្កា បានដល់ ដើមឈើមានផ្កាក្រពុំ (គុម្ពផ្កា) ។

ពិតមែន ដើមផ្កាក្តី គុម្ពផ្កាក្តី ដែលផ្កានៅក្រពុំ លោកហៅថា គុម្ពផ្កាទាំងអស់នោះ ។ ក៏ភិក្ខុទាំងនោះ ដាំដោយខ្លួនឯងខ្លះ ឱ្យអ្នកដទៃដាំខ្លះ នូវគុម្ពផ្កាមានប្រភេទផ្សេងគ្នាច្រើនណាស់ ។ ព្រោះហេតុនោះ ព្រះធម្មសង្គាហកៈទាំងឡាយ ទើបពោលថា មាលាវច្ឆំ រោបេន្តិបិ រោបាបេន្តិបិ : ដាំកូនឈើផ្កាដោយខ្លួនឯងខ្លះ ប្រើគេឱ្យដាំខ្លះ ដូច្នេះ ។

បទថា សិញ្ចន្តិ : ស្រោចដោយខ្លួនឯង បានដល់ រមែងស្រោចទឹកដោយខ្លួនឯងខ្លះ ។

បទថា សិញ្ចាបេន្តិ : ប្រើគេឱ្យស្រោច បានដល់ រមែងប្រើឱ្យអ្នកដទៃស្រោចខ្លះ ។

## អធិប្បាយលក្ខណៈ ៥ មានអកប្បិយវោហារជាដើម

ក៏ក្នុងអធិការនេះ អ្នកសិក្សាគប្បីជ្រាបលក្ខណៈ ៥ យ៉ាង ទាំងនេះ គឺអកប្បិយវោហារ ១ កប្បិយវោហារ ១ បរិយាយ ១ ឱភាស ១ និមិត្តកម្ម ១ ។

បណ្តាលក្ខណៈទាំង ៥ នោះ ដែលឈ្មោះថា **អកប្បិយវោហារ** បានដល់ ការកាត់ដោយខ្លួនឯង ការប្រើឱ្យកាត់វត្ថុខៀវស្រស់ទាំងឡាយ, ការជីកដោយខ្លួនឯង ការប្រើឱ្យគេជីករណ្តៅ, ការដាំដោយខ្លួនឯង ការប្រើឱ្យដាំគុម្ពផ្កា, ការជីកដោយខ្លួនឯង ការប្រើឱ្យពូនទំនប់ការពារ, ការស្រោចទឹកដោយខ្លួនឯង ការប្រើឱ្យស្រោចទឹក, ការធ្វើបង្ហូរទឹកឱ្យត្រង់ទៅ ការជ្រួចទឹកដែលជាកប្បិយ ការស្រោចដោយទឹកលាងដៃលុបមុខលាងជើងនិងទឹកងូត ។

ដែលឈ្មោះថា **កប្បិយវោហារ** បានដល់ ពាក្យថា ចូរដឹងដើមឈើនេះ, ចូរដឹងរណ្តៅនេះ, ចូរដឹងគុម្ពផ្កានេះ, ចូរដឹងទឹកក្នុងទីនេះ និងការធ្វើបង្ហូរទឹកដែលស្ងួតឱ្យត្រង់ ។

ដែលឈ្មោះថា **បរិយាយ** បានដល់ ពាក្យមានជាដើមថា បណ្ឌិតគួរឱ្យដាំដើមឈើទាំងឡាយ មានដើមផ្កាជាដើម នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ក្នុងកាលមិនយូរឡើយ ។

ដែលឈ្មោះថា **ឱភាស** បានដល់ ការឈរកាន់ចបកាប់ និងចបជីកជាដើម និងគុម្ពផ្កាទាំងឡាយ ។ ពិតមែន ពួកសាមណេរជាដើមឃើញព្រះថេរៈឈរយ៉ាងនោះ ដឹងថា ព្រះថេរៈប្រាថ្នានឹងប្រើឱ្យធ្វើហើយមកធ្វើ ។

ដែលឈ្មោះថា **និមិត្តកម្ម** បានដល់ ការនាំចបកាប់ ចបជីក

កាំបិត ពូថៅ និងភាជន៍ទឹក មកដាក់ក្នុងទីជិត ៗ ។

លក្ខណៈទាំង ៥ ប្រការនេះ រមែងមិនគួរក្នុងការដាំដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូល ។ ដើម្បីប្រយោជន៍ដល់ការបរិភោគផ្លែ កិច្ច ២ យ៉ាង គឺ អកប្បិយវោហារ និងកប្បិយវោហារប៉ុណ្ណោះមិនគួរ ។ កិច្ច ៣ យ៉ាងក្រៅនេះគួរ ។ តែក្នុងមហាបច្ចរីលោកពោលថា សូម្បីកប្បិយវោហារ ក៏គួរ ។ និងការដាំណា រមែងគួរដើម្បីប្រយោជន៍ដល់ការបរិភោគរបស់ខ្លួន, ការដាំនោះ ក៏គួរដើម្បីប្រយោជន៍ដល់បុគ្គលដទៃ ដល់សង្ឃ ឬដល់ចេតិយផង ។ តែការប្រើឱ្យដាំ ដើម្បីត្រូវការអារាម ដើម្បីត្រូវការព្រៃ និងដើម្បីត្រូវការម្លប់ត្រឹមតែជាអកប្បិយវោហារតែម្យ៉ាងមិនសមគួរ ។ ដ៏សេស គួរ ។ និងមិនមែនគួរតែកិច្ចដ៏សេសតែម្យ៉ាងទេ, សូម្បីការធ្វើចង្អូរឱ្យត្រង់ក្តី ការស្រោចទឹកដែលជាកប្បិយក្តី ការធ្វើបន្ទប់ងូតទឹកហើយងូតដោយខ្លួនឯងក្តី និងការចាក់ទឹកលាងដៃ លាងជើងនិងលាងមុខចុះក្នុងទីដាំដើមឈើនោះក្តី យ៉ាងណាមួយ ក៏សមគួរ ។ តែក្នុងមហាបច្ចរីនិងក្នុងកុរុន្ទី លោកពោលថា សូម្បីដាំដោយខ្លួនឯង ក្នុងកប្បិយ បថវី ក៏គួរ ។ សូម្បីនឹងបរិភោគផ្លែឈើដែលដាំដោយខ្លួនឯង ឬប្រើឱ្យដាំដើម្បីប្រយោជន៍ដល់អារាមជាដើម ក៏គួរ ។ ក្នុងការបេះដោយខ្លួនឯង និងព្រោះការប្រើឱ្យគេបេះផ្លែឈើ សូម្បីតាមប្រក្រតីក៏ត្រូវអាបត្តិបាចិត្តិយ ។ តែ (ក្នុងការបេះ និងក្នុងការ

ប្រើឱ្យបេះ) ដើម្បីត្រូវការទ្រព្យត្រកូល ត្រូវអាបត្តិបាចិត្តិយផង ជាអាបត្តិទុក្កដផង ។ ព្រោះការក្រេងផ្កាឈើ មានការក្រេងសន្តត់ចុះជាដើម មានក្នុងផ្កាសម្រាប់ប្រដាប់ទ្រង់ជាទីបំផុត ត្រូវអាបត្តិទុក្កដតែម្យ៉ាង ដល់ភិក្ខុ ដែលធ្វើដើម្បីត្រូវការទ្រព្យត្រកូល ឬដើម្បីប្រការដទៃ ។

សួរថា ព្រោះហេតុអ្វី ។

ឆ្លើយថា ព្រោះជាអនាចារ និងព្រោះជាបាបសមាចារដូចត្រាស់ទុកក្នុងពាក្យថា **បាបសមាចារោ** នេះ ។

បើមានអ្នកជំទាស់ថា ហេតុអ្វី ក្នុងការក្រេងដើម្បីប្រយោជន៍ដល់ការបូជាព្រះរតនត្រ័យ ទើបមិនជាអនាបត្តិ ដូចក្នុងការដាំដើមឈើដើម្បីប្រយោជន៍ដល់អារាមជាដើមហ្ន៎ ?

ឆ្លើយថា ជាអនាបត្តិដូចគ្នា ។ ដូចក្នុងការដាំដើមឈើ ដើម្បីប្រយោជន៍ដល់អារាមជាដើមនោះ ជាអនាបត្តិព្រោះកប្បិយវោហារ និងអាការមានបរិយាយជាដើមយ៉ាងណា, សូម្បីក្នុងការដាំដើមឈើ ដើម្បីប្រយោជន៍ដល់ការបូជាព្រះរតនត្រ័យ ក៏ជាអនាបត្តិដែរ ។

មានអ្នកជំទាស់ថា ក៏ក្នុងការដាំដើមឈើនោះ សូម្បីដាំដោយខ្លួនឯង ក្នុងកប្បិយបថវី រមែងគួរមិនមែនឬ ?

ឆ្លើយថា ពាក្យនោះ លោកពោលហើយក្នុងមហាបច្ចរី និងកុរុន្ទី,

តែក្នុងមហាអដ្ឋកថាមិនបានពោលទុក ។ បើសូម្បីលោកនឹងឆ្លល់ថា ទោះជាពាក្យដែលពោលហើយក្នុងអដ្ឋកថាក្រៅនេះ នឹងជាប្រមាណបានក៏ពិត, តែការស្រោចទឹកដែលជាកប្បិយ លោកបានពោលទុកក្នុងមហាអដ្ឋកថា, ការស្រោចទឹកដែលជាកប្បិយនោះយ៉ាងណា ? សូម្បីការស្រោចទឹកដែលជាកប្បិយនោះ ក៏មិនខុស ។

ជាការពិតណាស់ ក្នុងការដាំនិងការស្រោចទឹក កាលលោកពោលថា "នូវគុម្ពឈើផ្កា" ដូច្នេះ ក្នុងកាលលោកគួរនឹងពោលពីការមិនប្លែកគ្នាថា ដាំដោយខ្លួនឯងខ្លះ ឱ្យអ្នកដទៃដាំខ្លះ ស្រោចដោយខ្លួនឯងខ្លះ ឱ្យអ្នកដទៃស្រោចខ្លះ នូវដើមឈើ ដូច្នេះ ឈ្មោះថា រមែងឱ្យជ្រាបអធិប្បាយថា ពាក្យថា គុម្ពផ្កា នេះ ពោលសំដៅយកដើមឈើដែលមានផ្កា និងផ្លែ ដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូលប៉ុណ្ណោះ, តែនៅមានបរិយាយក្នុងការដាំ ដើម្បីប្រយោជន៍ដល់អារាមជាដើមយ៉ាងដទៃ ; ព្រោះហេតុនោះ ពាក្យណាដែលព្រះអដ្ឋកថាចារ្យទាំងឡាយ ជ្រាបសេចក្តីមានបរិយាយ ក្នុងការដាំដើម្បីប្រយោជន៍ដល់អារាមជាដើមនោះ និងសេចក្តីមិនមានបរិយាយក្នុងការដាំ ដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូលនេះហើយ ពោលទុកក្នុងអដ្ឋកថាទាំងឡាយ, ពាក្យនោះ ជាពាក្យដែលលោកពោលត្រឹមត្រូវពិត ។ ពិតមែន ពាក្យនេះ ខ្ញុំព្រះករុណា ក៏បានពោលហើយថា ៖

ព្រះអដ្ឋកថាចារ្យទាំងឡាយ ក្នុងកាលមុនបានរចនាអដ្ឋកថាទាំងឡាយ មិនបានលះមតិរបស់ព្រះសាវកទាំងឡាយ ដែលដឹងធម៌និងវិន័យ ដូចដែលព្រះពុទ្ធត្រាស់ហើយតែម្តង ព្រោះហេតុនោះឯង ពាក្យណាដែលពោលហើយក្នុងអដ្ឋកថាទាំងឡាយ, ពាក្យនោះទាំងអស់ វៀរពាក្យដែលសរសេរដោយពាក្យភ្លាំងភ្លាត់ចេញហើយ រមែងជាប្រមាណរបស់បណ្ឌិតទាំងឡាយ ដែលមានសេចក្តីគោរពនូវសិក្ខាក្នុងព្រះសាសនា ព្រោះហេតុអ្វី ? ។

ការដាំជាដើមនិងការក្រងជាដើមគ្រប់ ៗ យ៉ាង គប្បីជ្រាបតាមន័យដែលពោលហើយ ។ ក្នុងវិស័យនៃការក្រងជាដើមនោះ គប្បីមានពាក្យសួរថា បើការក្រងជាដើម ដើម្បីប្រយោជន៍ដល់ការបូជាព្រះរតនត្រ័យ ត្រូវអាបត្តិទៅហើយ, ចុះហេតុអ្វីបានជាការនាំទៅជាដើម ជាអនាបត្តិហ្ន៎ ? មានពាក្យឆ្លើយថា ព្រោះនាំទៅដើម្បីប្រយោជន៍ដល់កុលស្ត្រីជាដើម ទើបត្រូវអាបត្តិ ។ ពិតមែន ក្នុងហរណាធិការ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានពោលទុកឱ្យពិសេសហើយថា គេ កុលត្ថីនំ : ភិក្ខុនោះ (នាំផ្កា) ដើម្បីស្រីនៃត្រកូលជាដើម ។ ព្រោះហេតុនោះ ទើបមិនត្រូវអាបត្តិដល់ភិក្ខុដែលនាំទៅ ដើម្បីប្រយោជន៍ដល់

ព្រះពុទ្ធជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឯកតោ វណ្ដិកំ : មានទងតែម្ខាង** បានដល់ កម្រងផ្កាដែលចាត់ធ្វើរមទងផ្កាចូលគ្នា ( កម្រងផ្កាតទង ) ។

បទថា **ឧភតោ វណ្ដិកំ : មានទងទាំងពីរ** បានដល់ កម្រងផ្កាដែលធ្វើបែកទងផ្កាឈើទុកពីរខាង ( កម្រងផ្កាវៀនទង ) ។

ចំណែកក្នុងបទថា **មញ្ជរិកំ : ផ្កាឈើចាក់រំលេចទងជាដើម** មានវិនិច្ឆ័យថា បុប្ផវិកត្តដែលធ្វើដូចកង ហៅថា **មញ្ជរិក** ( ផ្កាកង )

កម្រងផ្កាដែលធ្វើដោយយកម្ជុល ឬចំរៀកឈើចាក់ផ្កាដូចផ្កាសិន្ទុវារៈជាដើម ឈ្មោះថា **វិធូតិកា : ផ្កាឈើដែលដោតជាចង្កោម** ។

បទថា **វដំសកោ : ផ្កាកម្រងសម្រាប់ប្រដាប់ក្បាល** បានដល់ មកុដតូច ( ផ្កាឈើប្រដាប់ក្បាល ) ។

កម្រងផ្កាឈើសម្រាប់ប្រដាប់ត្រចៀក ឈ្មោះ **អាវេឡា : ផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀត** ( ផ្កាភួង ) ។

កម្រងផ្កាឈើដែលតាំងនៅត្រង់ទ្រូង ស្រដៀងកែវមុក្ដាហារ ឈ្មោះថា **ឧរច្ឆទ : ផ្កាកម្រងសម្រាប់ប្រដាប់ទ្រូង** ។ ពណ៌នាចំពោះបទក្នុងព្រះបាលីនេះប៉ុណ្ណោះសិន ។

## ការវិនិច្ឆ័យអាបត្តិក្នុងការដាំដោយខ្លួនឯងជាដើម

គប្បីជ្រាបវិនិច្ឆ័យអាបត្តិដោយពិស្តារតាំងពីដើម ដូចតទៅនេះ ៖

ត្រូវអាបត្តិបាចិត្តិយ និងទុក្កដ ដល់ភិក្ខុដែលដាំគុម្ពផ្កាដោយខ្លួនឯង ក្នុងអកប្បិយបឋវី ដើម្បីប្រយោជន៍ដល់ការទ្រទ្រង់ត្រកូល ។ ភិក្ខុប្រើឱ្យគេដាំដោយអកប្បិយវោហារក៏ដូចគ្នា, ក្នុងការដាំដោយខ្លួនឯងក្តី ប្រើឱ្យដាំក្តី ក្នុងកប្បិយបឋវីត្រូវអាបត្តិទុក្កដតែម៉្យាង ។ ក្នុងបឋវីសូម្បីទាំងពីរ ព្រោះការប្រើឱ្យគេដាំគុម្ពផ្កាសូម្បីច្រើន ដោយការបង្គាប់តែមួយដង ត្រូវអាបត្តិបាចិត្តិយ និងអាបត្តិទុក្កដ ឬត្រូវអាបត្តិទុក្កដសុទ្ធដល់ភិក្ខុនោះ តែមួយប៉ុណ្ណោះ, ការប្រើឱ្យដាំដោយកប្បិយវោហារ ក្នុងផ្ទៃដីដែលជាកប្បិយ ឬ ផ្ទៃដីដែលជាអកប្បិយ ដើម្បីជាប្រយោជន៍ដល់ការបរិភោគ មិនត្រូវអាបត្តិ ។ សូម្បីដើម្បីប្រយោជន៍ដល់អារាមជាដើមក្នុងអកប្បិយបឋវី ក៏គង់ជាអាបត្តិបាចិត្តិយដល់ភិក្ខុដែលដាំដោយខ្លួនឯង ឬប្រើឱ្យគេដាំដោយពាក្យដែលជាអកប្បិយ ។ តែន័យនេះ លោកមិនបាន ចែកទុកឱ្យល្អិតក្នុងមហាអដ្ឋកថា, ចែកទុកតែក្នុងមហាបច្ចរី ដូច្នេះឯង ។

ក៏ក្នុងការស្រោចដោយខ្លួនឯង និងការប្រើឱ្យគេស្រោច មានវិនិច្ឆ័យអាបត្តិដូច្នេះ ៖

ត្រូវអាបត្តិបាចិត្តិយក្នុងទីទាំងពួង ដោយទឹកដែលជាអកប្បិយ ។ ដើម្បីប្រយោជន៍ដល់ការទ្រុស្តត្រកូលនិងបរិភោគ ជាអាបត្តិទុក្កដក៏មាន ។ តែដើម្បីប្រយោជន៍ដល់ការទាំងពីរនោះប៉ុណ្ណោះ ត្រូវអាបត្តិទុក្កដ ដោយទឹកដែលជាកប្បិយ, ក៏ក្នុងការទ្រុស្តត្រកូលនិងការបរិភោគនេះ ដើម្បីត្រូវការបរិភោគមិនជាអាបត្តិក្នុងការប្រើឱ្យគេស្រោចទឹកដោយកប្បិយវោហារ តែក្នុងឋានៈនៃអាបត្តិ អ្នកសិក្សាគប្បីជ្រាបអាបត្តិច្រើន ព្រោះមានប្រយោគច្រើន ដោយអំណាចខ្សែទឹកដាច់ ។ ក្នុងការបេះដោយខ្លួនឯង ដើម្បីប្រយោជន៍ដល់ការទ្រុស្តត្រកូល ត្រូវអាបត្តិទុក្កដ និងបាចិត្តិយតាមចំនួនផ្កាឈើ ។ ក្នុងការបូជាព្រះរតនត្រ័យជាដើមយ៉ាងដទៃ ត្រូវអាបត្តិបាចិត្តិយតែម្យ៉ាង ។ តែភិក្ខុដែលបេះផ្កាឈើច្រើន ដោយប្រយោគតែមួយ ព្រះវិន័យធរគប្បីពិន័យដោយអំណាចនៃប្រយោគ ។ ក្នុងការប្រើឱ្យបេះ ដើម្បីប្រយោជន៍ដល់ការទ្រុស្តត្រកូល អ្នកដែលភិក្ខុប្រើតែម្តងសូម្បីបេះច្រើនដង ក៏ជាអាបត្តិបាចិត្តិយនិងទុក្កដដល់ភិក្ខុនោះតែមួយ ៗ ប៉ុណ្ណោះ ។ ក្នុងការបេះដើម្បីបូជាព្រះរតនត្រ័យជាដើម យ៉ាងដទៃត្រូវអាបត្តិបាចិត្តិយតែម្យ៉ាង ។

## អត្ថាធិប្បាយបុប្ផវិកតិ ៦ ប្រភេទ

ក្នុងការក្រងផ្កាឈើទាំងឡាយ មានការក្រងសង្កត់ចុះជាដើម អ្នកសិក្សាគប្បីជ្រាបបុប្ផវិកតិទាំង ៦ ប្រភេទ គឺ គន្ថិមំ ក្រងសង្កត់ចុះ ១ គោប្ផិមំ ក្រងគួបឬក្រងត្រួត ១ វេធិមំ ក្រងចាក់ឬដោត ១ វេឋិមំ ក្រងពាន់ឬក្រងចង ១ បូរិមំ ក្រងវង់ ១ វាយិមំ ក្រងកម្រង ១ ។

បណ្ដាបុប្ផវិកតិ ៦ ប្រភេទនោះ ដែលឈ្មោះថា គន្ថិមៈ គប្បីឃើញក្នុងផ្កាឧប្បល និងផ្កាបទុមជាដើមដែលមានធាង ឬក្នុងផ្កាឈើទាំងឡាយដទៃដែលមានទងវែង ។ ពិតមែន ផ្កាឈើដែលក្រងសង្កត់ធាងនឹងធាង ឬទងនឹងទងនុ៎ះឯង ឈ្មោះ គន្ថិមៈ ។ សូម្បីគន្ថិមៈនោះ ភិក្ខុឬភិក្ខុនីនឹងធ្វើដោយខ្លួនឯងក្ដី ប្រើឱ្យគេធ្វើដោយពាក្យជាអកប្បិយក្ដី រមែងមិនគួរ ។ តែនឹងប្រើឱ្យធ្វើដោយកប្បិយវាចាជាដើមថា "ចូរដឹងយ៉ាងនេះ, ធ្វើបានយ៉ាងនេះហើយ នឹងល្អ, ចូរធ្វើផ្កាឈើទាំងឡាយនេះ កុំឱ្យខាត់ខាយ" ដូច្នេះ គួរ ។

ការយកអំបោះ ឬសរសៃធ្មៃជាដើម ក្រងត្រួតផ្កាឈើមានផ្កាម្លិះជាដើម ដោយអំណាចរបៀបផ្កាឈើមានទងម្ខាង និងមានទងពីរខាង (ដោយអំណាចកម្រងផ្កាតទង និងកម្រងផ្កាវៀនទង) ឈ្មោះថា គោប្ផិមៈ ។ មនុស្សទាំងឡាយត្បាញធ្មៃ ឬខ្សែពីរសរសៃ និងក្រងផ្កាឈើ

មិនមានទងជាដើមក្នុងផ្លែ ឬខ្សែនោះ ហើយរែតបន្តឹងទុកតាមលំដាប់, សូម្បីផ្កាឈើនេះ ក៏ឈ្មោះថា គោប្ផិមៈ ដូចគ្នា ។ គោប្ផិមៈទាំងអស់ មិនគួរដោយន័យមុនដូចគ្នា ។

ដែលឈ្មោះថា **វេធិមៈ** ដោត គឺ ផ្កាឈើដែលមនុស្សទាំងឡាយ ដោតផ្កាឈើដែលមានទង មានផ្កាម្លិះជាដើមត្រង់ទង ឬដោតផ្កាឈើ ដែលមិនមានទង មានផ្កាពិកុលជាដើមខាងក្នុងប្រហោងផ្កា ដោយជក់ត្នោតជាដើម ហើយក្រងទុកនេះ ឈ្មោះថា វេធិមៈ ។ សូម្បីផ្កាឈើនោះ ក៏មិនសមគួរ ដោយន័យមុនដូចគ្នា ។

ក៏មនុស្សពួកខ្លះយកបន្លា ឬជក់ត្នោតជាដើមដោតភ្ជាប់ដើមចេក ហើយចាក់ផ្កាឈើទុកត្រង់បន្លាស្រួចជាដើមនោះ ។ ពួកខ្លះដោតផ្កាឈើ ទុកត្រង់មែកឈើមានបន្លា ។ ពួកខ្លះដោតផ្កាឈើទុកត្រង់បន្លា ដែលបោះ ទុកត្រង់ឆត្រនិងជញ្ជាំង ដើម្បីធ្វើឆត្រផ្កាឈើនិងផ្ទះកំពូលផ្កាឈើ ។ ពួកខ្លះដោតផ្កាឈើទុកត្រង់បន្លាដែលចងទុកត្រង់ពិតានធម្មាសនៈ ។ ពួកខ្លះ ចាក់ផ្កាឈើមានផ្កាកណ្ណិការជាដើម ដោយចម្រៀកឈើ និងធ្វើឱ្យដូច ឆត្រវត ។ ផ្កាឈើដែលធ្វើយ៉ាងនោះឱឡារិកក្រៃលែងណាស់នោះឯង ។

ក៏ការដែលនឹងចងបន្លាទុកត្រង់ពិតានធម្មាសនៈ ដើម្បីដោតផ្កាឈើក្តី និងដោតផ្កាឈើតែមួយដោយបន្លាជាដើមក្តី នឹងយកផ្កាឈើដោតចូលក្នុងផ្កាឈើជាមួយគ្នាក្តី មិនគួរ ។ ក៏ការនឹងសៀតផ្កាឈើទាំងឡាយ ទុក

ក្នុងប្រហោងនៃពិតានក្រឡាសំណាញ់ វេទិកា ធ្មេញនាគ ដែលដាក់ផ្កាឈើនិងប្រហោងស្លឹកត្នោតជាដើម ឬថា ក្នុងចន្លោះប្រហោងផ្កាអសោកមិនមានទោស ។ ព្រោះផ្កាឈើយ៉ាងនោះមិនចាត់ជាវេធិមៈ ។ សូម្បីក្នុងខ្សែធម្មតា (ខ្សែសម្រាប់ចាក់ផ្កាឈើ) ក៏មានន័យយ៉ាងនេះដូចគ្នា ។ ផ្កាឈើដែលមានឈ្មោះថា វេធិមៈ គប្បីឃើញក្នុងកម្រងផ្កាឈើនិងបាច់ផ្កាឈើ ។ អធិប្បាយថា មនុស្សពួកខ្លះ កាលនឹងធ្វើកម្រងផ្កាឈើបន្តោងចុង (ធម្មាសនៈជាដើម) ទើបក្រងផ្កាឈើទាំងឡាយ[១] ដើម្បីសម្តែងអាការជាចង្កោមនៅខាងក្រោម ពួកខ្លះ ចងតែផ្កាឧប្បលជាដើមត្រង់ទងនីមួយ ៗមាន ៨ ផ្កាខ្លះ ១០ ផ្កាខ្លះ ដោយអំបោះ ឬដោយធ្មៃធ្វើឱ្យជាបាច់ផ្កាឧប្បល ឬជាបាច់ផ្កាឈូកធំ ។ ការធ្វើផ្កាឈើយ៉ាងនោះ មិនគួរទាំងអស់ ដោយន័យមុនដូចគ្នា ។ សូម្បីការដែលនឹងយកសំពត់កាសាវៈរុំផ្កាឧប្បលជាដើម ដែលពួកសាមណេរដកឡើងដាក់លើគោកឱ្យជាបង្វេច ក៏មិនគួរ ។ តែនឹងយកធ្មៃឬទងរបស់ផ្កាឧប្បលជាដើមនោះឯង ចងចូលជាមួយនឹងគ្នា ឬធ្វើឱ្យជាបង្វេចស្ពាយ គួរ ។

ដែលឈ្មោះថា បង្វេចស្ពាយនោះ គឺ ពួកភិក្ខុប្រមូលយកជាយទាំងពីរខាងរបស់សំពត់កាសាវៈ ដែលពាក់ទុកលើកចូលមកហើយ ធ្វើ

(១) សារត្ថទីបនី. មត្ថកទាមន្តិ ធម្មាសនាទិមត្ថកេ ផលម្ពកទាមំ ។

ឱ្យជាស្បោង (ស្បោងសំពត់) ដាក់ផ្កាឈើចុះក្នុងស្បោងនោះ ដូចថង់ស្បោង នេះ លោកហៅថា បង្វេចស្ពាយ ។ ការធ្វើផ្កាឈើដូច្នោះ គួរ ។ មនុស្សទាំងឡាយយកទងចាក់ស្លឹកឈូក និងយកស្លឹកខ្ចប់ផ្កាឧប្បលជាដើម កាន់ទៅ ។ សូម្បីក្នុងវិស័យដែលយកស្លឹកឧប្បលជាដើម ខ្ចប់កាន់ទៅនោះនឹងចងស្លឹកបទុម ខាងលើផ្កាឈើទាំងឡាយប៉ុណ្ណោះ គួរ ។ តែទងបទុមមិនគួរចងទុកខាងក្រោមផ្កា (តែការចងទងបទុមទុកខាងក្រោមផ្កា មិនគួរ) ។

ដែលឈ្មោះថា បូរិមៈ គប្បីឃើញក្នុងភួងកម្រងផ្កា និងផ្កាឈើបន្ទះ ។ អធិប្បាយថា អ្នកណាយកភួងកម្រងផ្ការុំព័ទ្ធចេតិយក្តី ដើមពោធិព្រឹក្សក្តី វេទិកាក្តី នាំវិលត្រឡប់មកឱ្យហួសទីដើម (ហានពីដើម) ទៅ, សូម្បីដោយការរុំព័ទ្ធត្រឹមតែប៉ុណ្ណោះ ផ្កាឈើរបស់អ្នកនោះ ឈ្មោះថា បូរិមៈ ។ នឹងបាច់ពោលទៅថ្វីសម្រាប់អ្នកដែលរុំព័ទ្ធច្រើនគ្រា ។ កាលស៊កចូលទៅមកចន្លោះធ្មេញនាគ* (ជណ្តើរកែវ) ។ បពេញឱ្យសំយុងចុះមក ហើយត្រឡប់មករុំជុំវិញធ្មេញនាគទៀត សូម្បីផ្កាឈើនេះក៏ឈ្មោះថា បូរិមៈ ។ តែនឹងស៊កទងផ្កាឈើចូលទៅក្នុងធ្មេញនាគ សមគួរ ។

---

(១) នាគទន្តកំ ប្រែថា ធ្មេញនាគ, ធ្មេញមង្ករ, និងជណ្តើរកែវក៏បាន ។

មនុស្សទាំងឡាយ រមែងធ្វើបន្ទះផ្កាឈើ (ផ្កាឈើផ្ទាំង) ដោយក្នុងកម្រង ផ្កា ។ សូម្បីក្នុងវិស័យផ្កាឈើបន្ទះនោះ នឹងទាញបន្ទឹងកម្រងផ្កាទៅត្រឹមតែមួយជង់ គួរ ។ កាលនាំត្រឡប់មកទៀត ចាត់ជាការក្រងវង់តែម្តង ។ ផ្កាឈើប្រភេទនោះ មិនគួរគ្រប់យ៉ាង ដោយន័យមុនដូចគ្នា ។ ក៏ការបានកម្រងផ្កាឈើដែលគេធ្វើដោយកម្រងផ្កាសូម្បីជាច្រើនហើយ ចងទុកខាងលើនៃអាសនៈជាដើម គួរ ។ ក៏ការយកក្នុងកម្រងផ្កាដែលវែងច្រើនឡើងទៅ ឬរុំព័ទ្ធទៅមួយគ្រាហើយ (កាលដល់ចំណាំងដើម) ទៀត ឱ្យដល់ភិក្ខុដទៃ សមគួរ ។ សូម្បីភិក្ខុនោះ ក៏គួរធ្វើយ៉ាងនោះដូចគ្នា ។

ដែលឈ្មោះថា **វាយិមៈ** គប្បីឃើញក្នុងផ្កាឈើក្រឡាសំណាញ់ផ្កាឈើផែន និងផ្កាឈើរូបភាព ។ កាលភិក្ខុធ្វើក្រឡាសំណាញ់ផ្កាឈើសូម្បីលើព្រះចេតិយត្រូវអាបត្តិទុក្កដគ្រប់ ៗ ប្រហោងក្រឡាសំណាញ់តែមួយក្រឡា ។ ក្នុងជញ្ជាំង ឆត្រ ដើមពោធិព្រឹក្ស និងសសរជាដើម ក៏មានន័យយ៉ាងនេះដូចគ្នា ។ ក៏ការដែលភិក្ខុនឹងចងក្រងបន្ទះផ្កាឈើ សូម្បីដែលអ្នកដទៃធ្វើឱ្យពេញហើយ ក៏មិនបាន ។ មនុស្សទាំងឡាយ រមែងធ្វើរូបដំរី និងរូបសេះជាដើមដោយផ្កាឈើ ដែលក្រងផ្គួបទុកទាំងឡាយនុ៎ះឯង ។ សូម្បីរូបដំរី និងរូបសេះជាដើមទាំងនោះ ក៏តាំងនៅក្នុងឋានៈនៃវាយិមៈ ផ្កាឈើនោះ រមែងមិនគួរទាំងអស់ តាមន័យមុនដូចគ្នា ។

តែកាលទឹងដាក់ផ្កាឈើ (តាមប្រក្រតីមិនបានក្រង) ក្នុងផ្នែកដែលពួកមនុស្សដង់ទៃធ្វើទុកហើយ ធ្វើសូម្បីឱ្យជារូបដំរីនិងរូបសេះជាដើម គួរ ។ តែក្នុងមហាបច្ចរី លោកពោលបុប្ផវិកតិ្តទុក ៨ ប្រភេទ រួមជាមួយភួងរំយោល និងភួងដូចព្រះចន្ទមួយចំហៀង ។ បណ្តាភួងរំយោលនិងភួងដូចព្រះចន្ទមួយចំហៀងនោះ ភួងឰ្យរដែលបន្ទោងក្នុងចន្លោះភួងព្រះចន្ទមួយចំហៀង លោកហៅឈ្មោះថា **គលម្ពកៈ** (ភួងរំយោល) ។ ការរុំព័ទ្ធភួងកម្រងផ្កាត្រឡប់ទៅត្រឡប់មក (ដែលគេធ្វើ) ដោយអាការដូចព្រះចន្ទមួយចំហៀង លោកហៅឈ្មោះថា **អឌ្ឍចន្ទកៈ** (ភួងព្រះចន្ទមួយចំហៀង) ។ សូម្បីផ្កាឈើទាំងពីរប្រភេទនោះ ក៏ចាត់ចូលក្នុងបូរិមៈ (កម្រងវង់) ដូចគ្នា ។ ចំណែកក្នុងកុរុន្ទី លោកពោលថា សូម្បីការចាត់កម្រងផ្កាពីរបីភួងចូលជាមួយនឹងគ្នា ហើយធ្វើឱ្យជាកម្រងផ្កាឈើ ក៏ឈ្មោះថា វាយិមៈ ដូចគ្នា ។ សូម្បីការធ្វើភួងផ្កាឈើនោះ ក្នុងមហាអដ្ឋកថានេះ ក៏ចាត់ចូលក្នុងឋាននៃបូរិមៈដូចគ្នា ។ និងមិនមែនតែកម្រងផ្កាឈើតែម៉្យាងប៉ុណ្ណោះទេ, កម្រងផ្កាឈើធ្វើដោយម្សៅក្តី កម្រងផ្កាឈើធ្វើស្រដៀងគ្រាប់ឃ្លីក្តី កម្រងផ្កាឈើដែលធ្វើស្រដៀងធ្មេញសុនខ(១)

(១) អត្ថយោជនា : ខរបត្តទាមន្តិ សុនខទន្តសទិសំ កតបុប្ផទាមំ, វេឡាទីហិ កតបុប្ផទាមន្តិបិ កេចិ. ប្រែថា កម្រងផ្កាឈើដែលធ្វើស្រដៀងធ្មេញសុនខ ឈ្មោះថា ខរបត្តាទាមៈ, អាចារ្យពួកខ្លះ ពោលថា កម្រងផ្កាឈើធ្វើដោយឫស្សីជាដើម ក៏មាន ។

(ដែលធ្វើដោយឫស្សីក៏ថាបាន) ដែលលោកពោលទុកក្នុងកុរុទិក្តិ ពួកភិក្ខុក្តី ពួកភិក្ខុនីក្តី នឹងធ្វើដោយខ្លួនឯង ក៏មិនគួរ នឹងប្រើឱ្យគេធ្វើក៏មិនគួរ ព្រោះសិក្ខាបទជាសាធារណបញ្ញត្តិ ។ តែនឹងពោលពាក្យដែលជាកប្បិយ មានការបូជាជាគ្រឿងសម្គាល់ សមគួរក្នុងទីទាំងពួង ។ បរិយាយ ឱភាស និងនិមិត្តកម្ម សមគួរទាំងនោះឯង ។

## ការប្រព្រឹត្តអនាចារផ្សេងៗ

បទថា តុវដ្ដេន្តិ បានដល់ និបជ្ជន្តិ : ដេក ។

បទថា លាសេន្តិ : កែក្រាយ មានសេចក្តីថា ពួកភិក្ខុអស្សជិនិងបុនព្វសុកៈនោះក្រោកឡើងដូចអណ្តែតខ្លួនព្រោះបីតិ ហើយឱ្យនាងរបាំដ៏ជំនាញលោតរាំ ច្រៀងរាំពត់ពែនរបាំ គឺ ឱ្យចង្វាក់ (រាំច្រៀង) ។[១]

ពីរបទថា នច្ចន្តិយាបិ នច្ចន្តិ : រាំជាមួយស្រីកំពុងរាំខ្លះ មានសេចក្តីថា ក្នុងវេលាដែលស្រីរាំពត់ពែនច្រៀង សូម្បីពួកភិក្ខុអស្សជិ និងបុនព្វសុកៈនោះ ក៏រាំច្រៀងទៅខាងមុខ ឬខាងក្រោមនៃស្រីរបាំនោះ ។

---

(១) សារត្ថទីបនី ពន្យល់ថា សម្តែងន័យក្រៃលែង ១ មានអធិប្បាយថា ប្រកាសសេចក្តីប្រាថ្នា របស់ខ្លួនហើយក្រោកឡើងសម្តែងអាការរាំពត់ពែនមុន ដោយពោលថា គួរ រាំពត់ពែនយ៉ាងនេះ តែអាចារ្យពួកខ្លះពោលថា សិកម្រាមដៃចូលមាត់ ធ្វើសំឡេងវិលខ្លួនដូចចក្រ ឈ្មោះថា ស្រែក វេវកៈ ។

ពីរបទថា **នច្ចន្តិយាបិ គាយន្តិ : ច្រៀងជាមួយស្រីកំពុងរាំខ្លះ** មានសេចក្ដីថា ក្នុងខណៈដែលស្រីរបាំនោះរាំ ពួកភិក្ខុទាំងនេះ រមែងច្រៀងបន្ទរទៅតាមការរាំពត់ពែន ៗ ក្នុងពាក្យគ្រប់ ៗ បទ ក៏មានន័យយ៉ាងនេះ ។

ពីរបទថា **អដ្ឋបទេបិ កីឡន្តិ : លេងបាស្កាមានក្រឡាប្រាំបីខ្លះ** មានសេចក្ដីថា រមែងលេងបាស្កាលើបន្ទះក្ដាបាស្កាមួយជួរ ៗ ៨ ក្រឡា ។ ក្នុង**បាស្កាមានក្រឡាដប់** ក៏ដូចគ្នា ។

បទថា **អាកាសេបិ : បាស្កាក្នុងអាកាសខ្លះ** មានសេចក្ដីថា លេងបាស្កាក្នុងអាកាស ដូចលេងបាស្កាមួយជួរ ៗ ៨ ក្រឡា និងមួយជួរ ៗ ១០ ក្រឡាដូច្នោះ ។

បទថា **បរិហារបថេ : មកវាងដែលខ្វនគូរវាង** មានសេចក្ដីថា ធ្វើរង្វង់វិលមានគំនូសផ្សេង ៗ លើផែនដីហើយ លេងរត់វាងជុំវិញទៅតាម គំនូសខ្សែជុំវិញក្នុងរង្វង់នោះ (លេងដណ្ដើមទាង) ។

ពីរបទថា **សន្តិកាយបិ កីឡន្តិ : លេងផ្ទាត់គ្រាប់មានគ្រួសជាដើម** បានដល់ លេងល្បែងផ្ទាត់គ្រាប់បាស្កា ដុំថ្ម និងគ្រាប់គ្រួសខ្លះ ។ អធិប្បាយថា គ្រាប់បាស្កា ដុំថ្ម និងគ្រប់គ្រួសជាដើមដែលទុករួមគ្នា យកក្រចកប៉ុណ្ណោះ ឆ្កឹះចេញ និងឆ្កឹះចូលមិនឱ្យកម្រើក ។ បើថា ក្នុង

បណ្ដាគ្រាប់បាស្កា ដុំថ្ម និងគ្រាប់គ្រួសទាំងនោះ ណាមួយកម្រើក ជាអ្នកបរាជ័យ ។

បទថា ខលិកាយ : បាស្កាក្នុងលានសម្រាប់លេង បានដល់ លេងបោះកងលើបន្ទះក្ដារបាស្កា ។

បទថា ឃដិកាយ : ហឹង មានសេចក្ដីថា ការលេងហ៊ឹង លោកហៅថា ឃដិកា លេងដោយឈើហ៊ឹងនោះ ។ សេចក្ដីថា ត្រាច់យកឈើវែងវាយឈើខ្លីលេង ។

បទថា សលាកហត្ថេន : រលាស់ទឹកលាក់ឱ្យទាយរូប មានសេចក្ដីថា លេងយកជក់ជ្រលក់ដោយទឹកល័ក្ខ ទឹកចត់ ឬទឹកផ្សំម្សៅ ហើយសួរថា នឹងជារូបអ្វី ? ទើបចុចជក់នោះចុះលើផែនដី ឬលើជញ្ជាំង សម្ដែងរូបដំរីនិងរូបសេះជាដើម ។

បទថា អក្ខេន : អន្ទញ់ ប្រែថា គ្រាប់បាស្កា ។

បទថា បង្គចិរេន : ផ្លុំប៉ីស្លឹក មានសេចក្ដីថា រមូរស្លឹកឈើ លោកហៅថា បង្គចិរៈ, លេងផ្លុំប៉ីស្លឹកឈើនោះ ។

បទថា វង្កកេន : នង្គ័លតូច បានដល់ នង្គ័លតូច ៗ ជាគ្រឿងលេងរបស់ពួកក្មេងអ្នកស្រុក ។

បទថា មោក្ខចិកាយ : ដាំដូង មានសេចក្ដីថា ការលេងដាំដូង

លោកហៅថា **មោក្ខចិកា** ។ អធិប្បាយថា លេងចាប់កំណាត់ឈើទុកក្នុងអាកាស ឬដាក់សីសៈចុះលើផែនដី ហើយបង្វិលខ្លួនជុំវិញ ដោយយក( ជើង )ខាងក្រោមទៅទុកខាងលើ យក( ក្បាល )ខាងលើចុះមកដាក់ខាងក្រោម ។ ( លេងចាប់ស្មា ឬ ឱនសីសៈចុះទាល់នឹងផែនដីហើយដាំដូង ) ។

បទថា ចិង្គុលេន : **កង្ហារ** មានសេចក្តីថា កង្ហារដែលវិលដោយត្រូវខ្យល់បក់ ដែលធ្វើដោយស្លឹកត្នោតជាដើម ហៅថា ចិង្គុលកៈ, លេងដោយកង្ហារនោះ ។

បទថា បត្តាឡ្ហកេន : **វាល់ដីខ្សាច់** មានសេចក្តីថា កន្ទោងស្លឹកឈើ ហៅថា បត្តាឡ្ហកៈ, លេងវាល់ខ្សាច់ជាដើម ដោយកន្ទោងស្លឹកឈើនោះ ។

បទថា រថកេន : **រថតូច** បានដល់ រថតូច ៗ ។

បទថា ធនុកេន : **ធ្នូតូច** បានដល់ ធ្នូតូច ៗ ។

បទថា អក្ខរិកាយ : **សរសេរខ្យល់ឱ្យទាយ** មានសេចក្តីថា ការលេងទាយអក្សរក្នុងអាកាស ឬត្រង់ខ្នង ហៅថា អក្ខរិកា, លេងដោយល្បែងទាយអក្សរនោះ ។

បទថា មនេសិកាយ : **ទាយចិត្ត( ស្តេចចង់ )** មានសេចក្តីថា

លេងដោយល្បែងទាយសេចក្ដីគិតមកចិត្ត ដែលលោកហៅថា **មនេសិកា** ។

បទថា **យថាវដ្ឋេន : កុំផ្ទែងត្រាប់គេ** មានសេចក្ដីថា ការលេងសម្ដែងប្រកបឬកពាររបស់មនុស្សពិការ មានមនុស្សខ្វាក់ភ្នែក មនុស្សខ្វក និងមនុស្សគមជាដើម ដែលលោកហៅថា លេងត្រាប់តាមមនុស្សពិការ ។ ភិក្ខុអស្សជិនិង បុនព្វសុក:លេងដោយការលេងត្រាប់តាមអ្នកពិការ ដូចពួកជនអ្នកវេលម្អកលេង (ជនពួកលេងកាយកម្ម) ដូច្នោះ ។

ពីរបទថា **ហត្ថិស្មិម្បិ សិក្ខន្តិ : ហាត់ដំរីខ្លះ** មានសេចក្ដីថា រមែងសិក្សាសិល្ប:ដែលគួរសិក្សា មានដំរីជានិមិត្ត ។ សូម្បីក្នុងសិល្ប: មានសេះជាដើម ក៏មានន័យយ៉ាងនេះ ។

បទថា **ធាវន្តិបិ : ស្ទុះរត់ទៅខ្លះ** បានដល់ រត់ដេញទៅតាមក្រោយ ។

បទថា **អាធាវន្តិបិ : ស្ទុះរត់មកខ្លះ** មានសេចក្ដីថា រត់បែរមុខវិលត្រឡប់មករហូតដល់អស់ចម្ងាយមកដែលខ្លួនរត់ទៅ (ស្ទុះរត់មកវិញ) ។

បទថា **និព្វុជ្ឈន្តិ : ចំបាប់គ្នា** បានដល់ រមែងធ្វើការបោកចំបាប់គ្នា ។

ពីរបទថា ឧលាដិកម្បិ ទេន្តិ : ដាក់ម្រាមដៃលើថ្ងាស់ មានសេចក្តីថា រមែងប៉ះដៃត្រង់ថ្ងាស់ខ្លួនហើយ ប៉ះត្រង់ថ្ងាស់របស់ស្រីបាំនោះ ព្រមទាំងនិយាយថា ល្អណាស់ ល្អហើយប្អូនស្រី ។

ពីរបទថា វិវិធម្បិ អនាចារំ : ប្រព្រឹត្តអនាចារផ្សេង ៗខ្លះ មានសេចក្តីថា ប្រព្រឹត្តអនាចារផ្សេង ៗមានស្គររមាត់ជាដើម (ពិណពាទ្យមាត់, ហួចជាដើម) សូម្បីដទៃ ៗ ដែលមិនបានមកក្នុងព្រះបាលី ។

## ពន្យល់អត្ថក្នុងផ្នែកអ្នកកិដាគិរីជួបភិក្ខុអាគន្តុកៈ

[៣១៥] បទថា បាសាទិកេន : គួរជាទីជ្រះថ្លា បានដល់ ដែលនាំមកនូវសេចក្តីជ្រះថ្លា គឺ សមគួរដល់សមណៈ ។

បទថា អភិក្កន្តេន : ឈានដើរទៅមុខ គឺ មានការដើរ ។

បទថា បដិក្កន្តេន : ឈានថយក្រោយ គឺ មានការថយត្រឡប់ ។

បទថា អវលោកិតេន : ក្រឡេកមើលទៅមុខ គឺ ការមើល មើលទៅខាងមុខ ។

បទថា វិលោកិតេន : ក្រឡេកមើលទៅចំហៀង គឺ មើលខាងឯណេះខ្លះខាងឯណោះខ្លះ ។

បទថា សម្មិញ្ជិតេន : បត់ចូល គឺ ការបត់ថ្នាំងអវយវៈចូល ។

បទថា បសារិតេន : លាចេញ គឺ ការលាតថ្នាំងទាំងនោះឯងចេញ ។ ក្នុងបទទាំងពួងជាតតិយាវិភត្តិចុះក្នុងអត្ថប្រាប់ឥត្ថម្ភូត ។ មានពាក្យអធិប្បាយថា ជាអ្នកមានការដើរទៅខាងមុខ ថយត្រឡប់ ក្រឡេកឆ្វេង ក្រឡេកស្តាំ បត់ចូល លាតចេញ ដែលគួរជ្រះថ្លា ព្រោះត្រូវឃុំគ្រងដោយសតិសម្បជញ្ញៈ ។

បទថា ឱក្ខិត្តចក្ខុ : មានភ្នែកសង្រួមចុះ គឺ មានចក្ខុសម្លឹងចុះខាងក្រោម ។

បទថា ឥរិយាបថសម្បន្នោ : មានឥរិយាបថរំទំ មានសេចក្តីថា មានឥរិយាបថរៀបរយ ព្រោះមានកិរិយាឈានទៅខាងមុខជាដើម ដែលគួរជ្រះថ្លានោះ ។

បទថា ក្វាយំ កាត់បទជា កោ អយំ : លោកអ្វីនេះ ?

បទថា អពលពលោ វិយ : ដូចជាសង្រួមហួសពេក មានសេចក្តីថា បានឮថា ជនទាំងឡាយហៅមនុស្សទន់ខ្សោយថា អពល : អត់កម្លាំង ។ ក៏ពាក្យពោលដដែលនេះ ប្រព្រឹត្តទៅក្នុងអត្ថថា យ៉ាងក្រៃលែង, ព្រោះដូច្នោះ ទើបមានពាក្យអធិប្បាយថា ដូចមនុស្សទន់ខ្សោយហួសពេក ។

ដោយបទថា មន្ទមន្ទោ : ដូចជាទន់ល្វន់ពេក អ្នកស្រុក រមែងសម្តែងគុណពិត ៗ ដោយទោសយ៉ាងនេះថា ជាមនុស្សទន់ខ្សោយពេកណាស់ គឺ ទន់ជ្រាយណាស់ ព្រោះជាមនុស្សសម្រេចឥរិយាបថ មានការឈានដើរជាដើមមិនរហ័សរហួន ។

បទថា ភាកុដិកភាកុដិកោ វិយ : ដូចជាមុខស្រពោនពេក មានសេចក្តីថា ព្រោះលោកជាអ្នកមានចក្ខុសម្លឹងចុះ អ្នកស្រុកទើបសម្គាល់និយាយគ្នាថា ភិក្ខុនេះធ្វើមុខក្រញូវ មានមុខជ្រួញ ចិញ្ចើមខ្វូរត្រាច់ទៅដូចអ្នកខឹងក្រោធ ។

បទថា សណ្ហោ : ពោលពាក្យផ្អែម គឺ ជាអ្នកផ្អែមល្ហែម ។ អធិប្បាយថា ជាអ្នកឆ្លាត ដឹកនាំជនជាឧបាសកទៅក្នុងឋានៈដែលគួរយ៉ាងនេះថា "អើញោមស្រី ញោមប្រុស បងស្រី ប្អូនស្រី, លោកមិនមែនជាអ្នកមិនមានកម្លាំងពលៈដូចភិក្ខុរូបនេះទេ" ។

បទថា សខិលោ : ពោលពាក្យពីរោះ បានដល់ ជាអ្នកប្រកបដោយភាពជាអ្នកមានវាចាទន់ភ្លន់ ។

បទថា សុខសំភាសា : ពោលពាក្យជាសុខ នេះ ជាពាក្យសម្តែងហេតុនៃពាក្យមុន ។ ពិតមែន ជនអ្នកមានការនិយាយចរចា

---

១. ថៃ. អពឡពឡោ ។

ផ្អែមល្ហែម ជាសម្មោទនិយកថា មិនគ្រោតគ្រាត ស្រួលត្រចៀក លោកហៅថា អ្នកមានវាចាពីរោះ ។ ព្រោះហេតុនោះ អ្នកស្រុកទើបពោលថា (លោកម្ចាស់របស់ពួកយើង) ជាអ្នកនិយាយពីរោះ និយាយផ្អែមល្ហែម ។ ក៏ក្នុងពាក្យនេះមានអធិប្បាយដូច្នេះថា លោកម្ចាស់របស់ពួកយើងឃើញពួកឧបាសកឧបាសិកាហើយ ពោលសម្មោទនីយកថាពីរោះ ព្រោះដូច្នោះ ទើបលោកជាអ្នកនិយាយពីរោះ ផ្អែមល្ហែម មិនជាអ្នកទន់ខ្សោយនិងទន់ជ្រាយដូចភិក្ខុនេះឡើយ ។

បទថា **មិហិតបុព្វង្គមា : មានមុខញញឹមញញែមជាមុន** មានវិគ្រោះថា ភិក្ខុទាំងនេះ មានការញញឹមញញែមប្រព្រឹត្តទៅមុននិយាយ ; ព្រោះហេតុនោះ ទើបឈ្មោះថា អ្នកមានការញញឹមញញែមជាខាងមុខ ។ សេចក្តីថា ភិក្ខុទាំងនោះញញឹមញញែមមុន ទើបនិយាយខាងក្រោយ ។

បទថា **ឯហិស្វាគតវាទិនោ : តែងនិយាយថា អ្នកចូរមក អ្នកមកល្អហើយ** មានសេចក្តីថា ឃើញឧបាសកហើយច្រើនតែនិយាយយ៉ាងនេះថា "មកចុះ អ្នកមកល្អហើយ" មិនជាអ្នកមានមុខក្រញូវ ព្រោះជាអ្នកមានមុខជ្រួញចិញ្ចើមខ្ញូវដូចភិក្ខុនេះទេ ។ ពួកអ្នកកិដាគិរីជនបទ កាលសម្តែងភាពជាអ្នកមានមុខមិនក្រញូវ ព្រោះជាអ្នកមានប្រក្រតីញញឹមញញែមមុនជាដើម ដោយអត្ថយ៉ាងនេះហើយ កាលនឹងសម្តែងដោយ

សរុបទៀត ទើបបានពោលថា មានមុខមិនក្រញូវមានមុខរីកស្រស់ស្រាយ តែងនិយាយមុន ។

ម្យ៉ាងទៀត អ្នកសិក្សាគប្បីជ្រាប ទាំង ៣ បទ មានបទថា អភាកុដិកា : **មានមុខមិនស្រពោន** ជាដើមនេះ សម្ដែងសេចក្ដីមិនមាននៃអាការសូម្បីទាំង ៣ ដោយមកផ្លាស់ប្ដូរលំដាប់គ្នា ។

គឺ យ៉ាងណា ? គឺ បណ្ដាបទទាំង ៣ មានបទថា **អភាកុដិកា** ជាដើមនោះ ដោយបទថា អភាកុដិកា នេះ លោកសម្ដែងការមិនមានអាការមុខក្រញូវ ជ្រួញចិញ្ចើម ។

ដោយបទថា ឧត្តានមុខា : **មានមុខស្រើប** នេះ លោកសម្ដែងសេចក្ដីមិនមាននៃអាការទន់ខ្សោយនិងទន់ជ្រាយ ។ ក៏ភិក្ខុពួកណា ជាអ្នកមានមុខរីករាយដោយការបើកភ្នែកទាំងពីរសម្លឹងមើល ។ ភិក្ខុទាំងនោះ ឈ្មោះថា មិនជាអ្នកទន់ខ្សោយនិងទន់ជ្រាយ ។

ដោយបទថា បុព្វភាសិនោ : **តែងនិយាយមុន** នេះ លោកសម្ដែងសេចក្ដីមិនមាននៃអាការទន់ខ្សោយនិងទន់ជ្រាយ ។ ក៏ភិក្ខុពួកណា រមែងរាក់ទាក់មុនថា "នៃញោមស្រី ញោមប្រុស" ដូច្នេះ ព្រោះជាអ្នកឆ្លាតក្នុងការឱភាប្រាស្រ័យ, ភិក្ខុទាំងនោះ មិនជាអ្នកអត់កម្លាំងពលំទេ ដូច្នេះឯង ។

## ឧបាសកនិមន្តភិក្ខុអាគន្តុកៈទៅកាន់ផ្ទះ

បទថា ឯហិ ភន្តេ ឃរំ គមិស្សាម : លោកម្ចាស់និមន្តមក យើងនឹងទៅផ្ទះ មានសេចក្តីថា បានឮថា ឧបាសកនោះ កាលភិក្ខុពោល តបថា "ម្នាលអាវុសោ អាហារបិណ្ឌបាតមិនទាន់បានទេ" ដូច្នេះ ទើបពោលថា "ពួកភិក្ខុទាំងឯង ធ្វើឱ្យលោកមិនបានបិណ្ឌបាតនោះ សូម្បីលោកម្ចាស់នឹងត្រាច់ទៅពេញស្រុកទាំងអស់ ក៏នឹងមិនបានឡើយ" ប្រាថ្នានឹងប្រគេនបិណ្ឌបាត ទើបពោលថា "លោកម្ចាស់និមន្តមក យើងនឹងទៅផ្ទះ" ។

សួរថា តើវាចានេះ ជាវិញ្ញត្តិ ឬមិនជាវិញ្ញត្តិទេ ?

ឆ្លើយថា មិនជាវិញ្ញត្តិវាចាទេ ។ ធម្មតាបញ្ហាដែលគេសួរហើយនេះ គួរនឹងឆ្លើយ ។ ព្រោះដូច្នោះ បើសូម្បីថា ក្នុងរាល់ថ្ងៃនេះ អ្នកណា ៗ សួរភិក្ខុដែលចូលទៅកាន់ចន្លោះស្រុកក្នុងវេលាព្រឹកក្តី ក្នុងវេលាល្ងាចក្តី ថា "បពិត្រលោកម្ចាស់ លោកម្ចាស់ត្រាច់ទៅធ្វើអ្វី" ការដែលភិក្ខុប្រាប់សេចក្តីប្រាថ្នាដែលខ្លួនត្រាច់ទៅហើយកាលគេសួរថា បានហើយឬមិនទាន់បាន បើមិនទាន់បានក៏ប្រាប់ថា "មិន ទាន់បាន" ហើយទទួលយកវត្ថុដែលគេប្រគេនគួរ ។

បទថា ធុរេដ្ឋា : ខូចហើយ មានសេចក្តីថា មិនបានទ្រុឌទ្រោមចុះដោយការញុំាងសេចក្តីជ្រះថ្លាជាដើមឱ្យវិនាសទៅ, តែទ្រុឌទ្រោមចុះដោយអំណាចនៃបុគ្គលអ្នកទ្រោមចុះ ។

ទានទាំងឡាយទុំះឯង លោកហៅថា ទានបថ ។ម៉្យាងទៀត ទានប្រចាំ លោកហៅថា ទានបថ មានពាក្យអធិប្បាយថា ទានវត្ត ។

បទថា ឧបច្ឆិន្នានិ : គេឈប់ឱ្យហើយ បានដល់ ត្រូវពួកទាយកកាត់ដាច់ហើយ ។ អធិប្បាយថា ឥឡូវនេះ ពួកទាយកទាំងនោះ មិនថ្វាយទាននោះ ។

បទថា ភិជ្ជន្តិ : រត់ខ្ចាត់ខ្ចាយ មានសេចក្តីថា ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ ជាអ្នកបែកគ្នាទៅ គឺ បែកខ្ចាយគ្នាទៅ, មានពាក្យអធិប្បាយថា រមែងនាំគ្នាចៀសចេញទៅ ។

បទថា សណ្ឋហេយ្យុំ : រៀបរយល្អឡើងវិញ មានសេចក្តីថា គប្បីតាំងនៅដោយប្រពៃ គឺ គប្បីជាទីពំនាក់របស់ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ ។

ភិក្ខុនោះទទួលសាសន៍របស់ឧបាសកដែលមានសទ្ធា មានសេចក្តីជ្រះថ្លា ដោយពាក្យថា ឯវមាវុសោ : អើអាវុសោ ដូច្នេះឯង ។ បានឮថា ការនាំដំណឹងដែលជាកប្បិយបែបនេះទៅ រមែងគួរ ។ ព្រោះដូច្នោះ

ភិក្ខុមិនគប្បីធ្វើសេចក្ដីរវៀសក្នុងដំណឹងទាំងឡាយ ដូច្នេះថា "សូមលោកម្ចាស់ថ្វាយបង្គំព្រះយុគលបាទរបស់ព្រះមានព្រះភាគតាមពាក្យរបស់ខ្ញុំព្រះករុណាទាំងឡាយ" ដូច្នេះក្ដី ថា "សូមលោកម្ចាស់ថ្វាយបង្គំព្រះចេតិយ ព្រះបដិមា ដើមពោធិព្រឹក្ស ព្រះសង្ឃថេរៈ" ដូច្នេះក្ដី ថា "សូមលោកម្ចាស់ធ្វើការបូជាដោយរបស់ក្រអូប ធ្វើការបូជាដោយផ្កាឈើចំពោះព្រះចេតិយ" ដូច្នេះក្ដី ថា "សូមលោកម្ចាស់និមន្តឱ្យភិក្ខុទាំងឡាយប្រជុំគ្នា, ពួកយើងនឹងថ្វាយទាន នឹងស្ដាប់ធម៌" ដូច្នេះក្ដី ដំណឹងទាំងនេះ ជាកប្បិយសាសន៍ (ដំណឹងសមគួរ) មិនជាប់ដោយគិហិកម្មរបស់ពួកគ្រហស្ថ ដោយប្រការដូច្នេះឯង ។

[៣១៦] ពាក្យថា កុតោ ច ត្វំ ភិក្ខុ អាគច្ឆសិ : ម្យ៉ាងទៀត អ្នកទើបនឹងមកពីណា មានសេចក្ដីថា ភិក្ខុនោះនៅអង្គុយហើយ មិនមែនកំពុងមក ។ តែដោយអត្ថភិក្ខុនោះជាអ្នកមកហើយ ។ សូម្បីកាលជាយ៉ាងនេះ ពាក្យបច្ចុប្បន្នកាលក្នុងអត្ថអតីតដែលជិតនឹងបច្ចុប្បន្នកាល រមែងមាន ; ព្រោះដូច្នោះ ទើបមិនមានខុស ។ សូម្បីក្នុងពាក្យថា តតោ អហំ ភគវា អាគច្ឆាមិ : ខ្ញុំព្រះអង្គ ទើបនឹងមកពីកិដាគិរិជនបទនោះ នេះ ក្នុងទីបំផុតក៏មានន័យនេះដូចគ្នា ។

# ទ្រង់ត្រាស់ឱ្យដាក់បព្វាជនីយកម្មពួកភិក្ខុឆព្វគ្គិយ

[៣១៩] ក្នុងពាក្យថា បឋមំ អស្សជិបុនព្វសុកា ភិក្ខូ ចោទេតព្វា : ដំបូងពួកអ្នកត្រូវតឿនភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកសិន នេះ មានវិនិច្ឆ័យដូចតទៅនេះ អស្សជិ និងបុនព្វសុកៈ ដែលសង្ឃគប្បីឱ្យធ្វើឱកាសថា "ពួកខ្ញុំព្រះករុណា ត្រូវការនិយាយនឹងពួកលោក" ហើយគប្បីចោទដោយវត្ថុ និងអាបត្តិ, គ្រាចោទហើយ គប្បីឱ្យរលឹកដល់អាបត្តិដែលពួកលោកនៅរលឹកមិនបាន ។ បើពួកលោកបដិញ្ញាវត្ថុនិងអាបត្តិ ឬបដិញ្ញាចំពោះអាបត្តិ មិនបដិញ្ញាវត្ថុ គប្បីលើកអាបត្តិឡើងពិន័យ ។ ថាបដិញ្ញាចំពោះវត្ថុ មិនបដិញ្ញាអាបត្តិ, សូម្បីក្នុងការបដិញ្ញាយ៉ាងនោះ ក៏គប្បីលើកអាបត្តិឡើងតែម្តងថា ត្រូវអាបត្តិឈ្មោះនេះ ព្រោះវត្ថុនេះ ។ បើពួកលោកមិនបដិញ្ញាទាំងវត្ថុ មិនបដិញ្ញាទាំងអាបត្តិ មិនគប្បីលើកអាបត្តិឡើងពិន័យ ។

ក៏ព្រះមានព្រះភាគ ទ្រង់ពិន័យអាបត្តិតាមបដិញ្ញាហើយ កាលនឹងទ្រង់សម្តែងថា សង្ឃគប្បីដាក់បព្វាជនីយកម្មយ៉ាងនេះ ទើបត្រាស់ពាក្យមានជាដើមថា ព្យត្តេន ភិក្ខុនា : ភិក្ខុដែលឆ្លាសអង់អាច ដូច្នេះ ។ ពាក្យនោះ ងាយយល់ទាំងអស់ ។ ក៏ភិក្ខុដែលត្រូវសង្ឃដាក់បព្វាជនីយកម្មយ៉ាងនេះហើយ មិនគួរនៅក្នុងវត្តដែលខ្លួនធ្លាប់នៅ ឬក្នុង

ស្រុកដែលខ្លួនធ្វើកុលទូសកកម្ម ។ កាលទីងនៅក្នុងវត្តនោះ មិនគប្បីត្រាច់ទៅបិណ្ឌបាតក្នុងស្រុកជិតខាង ។

សូម្បីនឹងនៅក្នុងវត្តជិតខាង ក៏មិនគួរត្រាច់ទៅបិណ្ឌបាតក្នុងស្រុកនោះ ។ តែព្រះឧបតិស្សត្ថេរ ត្រូវពួកអន្តេវាសិកតវ៉ាថា "លោកម្ចាស់ធម្មតា នគរធំមានប្រមាណដល់ ១២ យោជន៍" ដូច្នេះហើយ ទើបពោលថា "ភិក្ខុធ្វើកុលទូសកកម្មក្នុងថ្នល់ណា, លោកហាមតែថ្នល់នោះ" ។ លំដាប់នោះ លោកត្រូវពួកអន្តេវាសិកតវ៉ាថា "សូម្បីថ្នល់ក៏ធំមានប្រមាណប៉ុននគរនោះឯង" ហើយទើបពោលថា "ភិក្ខុធ្វើកុលទូសកកម្មក្នុងលំដាប់ផ្ទះជួរណា លោកហាមលំដាប់ផ្ទះជួរនោះ" ដូច្នេះ ។ លោកត្រូវពួកអន្តេវាសិកតវ៉ាទៀតថា "លោកហាមផ្ទះ ក៏មានខ្នាតប៉ុនថ្នល់តែម្តង" ទើបពោលថា "លោកហាម ៧ ដំបូលផ្ទះខាងឯណោះនិងខាងនេះ" ។ ក៏ពាក្យទាំងអស់នោះ ត្រឹមតែជាមនោរថរបស់ព្រះថេរៈប៉ុណ្ណោះ ។ បើសូម្បីវត្តធំមានទំហំ ៣ យោជន៍ និងនគរធំទំហំ ១២ យោជន៍, ភិក្ខុដែលធ្វើកុលទូសកកម្ម នៅក្នុងវត្តនឹងត្រាច់ទៅក្នុងនគរ (នោះ) មិនបានឡើយ ដូច្នេះឯង ។

[៣២០] ពាក្យថា តេ សង្ឃេន បព្វាជនីយកម្មកតា : ភិក្ខុអម្បាលនោះ ដែលសង្ឃធ្វើបព្វាជនិយកម្មហើយ មានសេចក្តីថា សួរថា

សង្ឃបានធ្វើកម្មដល់ពួកភិក្ខុអស្សជិ និងបុនព្វសុកៈនោះ យ៉ាងណា ?

ឆ្លើយថា សង្ឃមិនបានទៅសង្កត់សង្កិនធ្វើកម្មឡើយ, ដោយការពិត កាលពួកត្រកូលអារាធនា និមន្តមកហើយ ធ្វើភត្តដើម្បីសង្ឃ ព្រះថេរៈទាំងឡាយក្នុងទីនោះ ៗ សម្ដែងសេចក្ដីបដិបត្តិរបស់សមណៈ ឱ្យពួកមនុស្សយល់ថា នេះជាសមណៈ នេះមិនមែនសមណៈ ហើយឱ្យភិក្ខុ ១ រូប ២ រូប ចូលកាន់សីមាហើយ បានធ្វើបព្វាជនីយកម្មដល់ពួកភិក្ខុទាំងអស់ ដោយឧបាយនេះចុះ ។

ក៏កាលភិក្ខុដែលត្រូវសង្ឃដាក់បព្វាជនីយកម្មយ៉ាងនេះហើយ បំពេញវត្ត ១៨ ប្រការឱ្យបរិបូរណ៍ហើយសូម (ការរម្ងាប់) កម្មដែលសង្ឃគប្បីរម្ងាប់ ។ និងសូម្បីភិក្ខុដែលមានកម្មរម្ងាប់ហើយនោះ ខូនធ្វើកុលទូសកកម្មទុកក្នុងត្រកូលពួកណាក្នុងកាលមុន មិនគួរទទួលបច្ច័យអំពីត្រកូលទាំងអស់នោះ ។ សូម្បីបានសម្រេចដល់នូវការអស់ទៅនៃអាសវៈហើយ ក៏មិនគួរទទួល, បច្ច័យទាំងនោះ ចាត់ជារបស់មិនសមគួរពិត ។

កាលភិក្ខុត្រូវទាយកសួរថា "ហេតុដូចម្ដេច លោកទើបមិនទទួល ?" ឆ្លើយថា "ព្រោះបានធ្វើទុកយ៉ាងនេះក្នុងកាលមុន" ដូច្នេះ, បើពួកអ្នកស្រុកពោលថា "ពួកខ្ញុំព្រះករុណាមិនប្រគេនដោយហេតុយ៉ាងនោះ, ប្រគេនព្រោះលោកម្ចាស់មានសីលក្នុងកាល ឥឡូវនេះ (ផ្សេង)" ដូច្នេះ គួរទទួលបាន ។ កុលទូសកកម្មជាកម្មដែលភិក្ខុ ធ្វើចំពោះក្នុង

ស្ថានទីឱ្យទានតាមប្រក្រតី, នឹងទទួលទានតាម ប្រក្រតីអំពីស្ថានទីនោះឯង គួរ ។ ទានដែលទាយកប្រគេនបន្ថែម មិនគួរទទួល ។

បទថា **ន សម្មា វត្តន្តិ : មិនប្រព្រឹត្តតាមដោយស្រួល** មានសេចក្ដីថា ក៏ពួកភិក្ខុអស្សជិបុនព្វសុកៈទាំងនោះ រមែងមិនប្រព្រឹត្តដោយប្រពៃ ក្នុងវត្ត ១៨ ប្រការ ។

ពាក្យថា **ន លោមំ បាតេន្តិ : មិនសម្ងបរោម គឺមិនព្រមតាម** មានសេចក្ដីថា ឈ្មោះថា ជាអ្នកមានរោមមិនក្រាបចុះ( សម្ងបរោម ) ហើយ ព្រោះមិនប្រតិបត្តិតាមវត្តបដិបត្តិដ៏សមគួរ ។

ពាក្យថា **ន នេត្ថារំ វត្តន្តិ : មិនព្រមប្រតិបត្តិតាមទំនងជាទីវៀនចេញ** មានសេចក្ដីថា រមែងមិនបដិបត្តិ តាមមកជាគ្រឿងវៀនចេញ ។

ពាក្យថា **ភិក្ខូ ន ខមាបេន្តិ : មិនអង្វរភិក្ខុទាំងឡាយឱ្យអត់ទោស** មានសេចក្ដីថា រមែងមិនធ្វើឱ្យភិក្ខុទាំងឡាយអត់ទោសយ៉ាងនេះថា "ពួកខ្ញុំព្រះករុណាធ្វើខុសហើយ លោកម្ចាស់, តែពួកខ្ញុំព្រះករុណានឹងមិនធ្វើដូច្នេះទៀតទេ, សូមលោកម្ចាស់ទាំងឡាយ អត់ទោសដល់ពួកខ្ញុំព្រះករុណាចុះ" ។

បទថា **អក្កោសន្តិ : ត្រឡប់ជាជេរប្រទេច គឺ រមែងជេរការ**

កសង្ឃ ដោយអក្កោសវត្ថុ ១០ ។

បទថា បរិភាសន្តិ : បន្ទោសការកសង្ឃ គឺ រមែងសម្តែងភ័យដល់ភិក្ខុទាំងអស់នោះ ។

ពាក្យថា ឆន្ទគាមិតា ទោសគាមិតា មោហគាមិតា ភយគាមិតា បាបេន្តិ : សង្ឃលុះក្នុងសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីល្ងង់ សេចក្តីខ្លាច មានសេចក្តីថា រមែងឱ្យដល់ គឺ ប្រកបដោយសេចក្តីលំអៀង ព្រោះស្រឡាញ់គ្នាខ្លះ ។ល។ ដោយសេចក្តីលំអៀងព្រោះខ្លាចខ្លះ យ៉ាងនេះថា ភិក្ខុទាំងនេះ ជាអ្នកមានសេចក្តីលំអៀងព្រោះស្រឡាញ់ ។ល។ និងមានសេចក្តីលំអៀងព្រោះខ្លាច ។

បទថា បក្កមន្តិ : ហើយភិក្ខុទាំងនោះចៀសចេញទៅ មានសេចក្តីថា បណ្តាសមណៈ ៥០០ ដែលជាបរិវាររបស់ភិក្ខុអស្សជិ និងបុនព្វសុកៈនោះ ពួកខ្លះ ក៏ចៀសទៅកាន់ទិស ។

បទថា វិព្ភមន្តិ : សឹកទៅ គឺ ពួកខ្លះក៏សឹកជាគ្រហស្ថ ។

ក្នុងពាក្យថា កថំ ហិ នាម អស្សជិបុនព្វសុកា : ហេតុដូចម្តេច ក៏ពួកភិក្ខុឈ្មោះ អស្សជិ និងបុនព្វសុកៈ នេះ លោកហៅភិក្ខុសូម្បីទាំងអស់ថា អស្សជិបុនព្វសុកៈ ដោយអំណាចនៃភិក្ខុទាំងពីររូបជាប្រធាន ។

## អត្ថាធិប្បាយកុលទូសកកម្មមានការឱ្យផ្កាឈើជាដើម

[៣២១] ក្នុងពាក្យថា គាមំ : ស្រុក នេះ សូម្បីនគរលោកក៏ប្រកាន់យកដោយគាមស័ព្ទដូចគ្នា ។ ព្រោះហេតុនោះ ក្នុងបទភាជនៈនៃបទនោះ លោកទើបពោលថា ស្រុកក្តី និគមក្តី នគរក្តី ឈ្មោះថា ស្រុក និងនិគម ។ បណ្តាស្រុកជាដើមនោះ ស្រុកដែលមិនមានកំពែងជារបងលោមព័ទ្ធ មានរានផ្សារ គប្បីជ្រាបថា និគម ។

ភិក្ខុណាប្រទូសរ៉ាយនូវត្រកូលទាំងឡាយ; ហេតុនោះ ភិក្ខុនោះឈ្មោះថា កុលទូសកៈ ។ ក៏កាលនឹងប្រទូសរ៉ាយ មិនមែនប្រទូសរ៉ាយដោយវត្ថុខូចទាំងឡាយ មានរបស់មិនស្អាត និងភក់ជាដើមទេ, ដោយសភាពពិត រមែងធ្វើសេចក្តីជ្រះថ្លារបស់ត្រកូលទាំងឡាយនោះឱ្យវិនាសទៅ ដោយការបដិបត្តិអាក្រក់របស់ខ្លួន, ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទនោះ លោកទើបពោលថា បុប្ផេន វា ជាដើម ។

[៣២២] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា បុប្ផេន[1] : ដោយ (ឱ្យ) ផ្កា ជាដើមនោះដូច្នេះ ៖

ភិក្ខុណានាំទៅឱ្យដោយខ្លួនឯងក្តី ឱ្យគេនាំទៅឱ្យក្តី ហៅមកឱ្យ

---
១. ថៃ. បុប្ផទានេន ។

ដោយខ្លួនឯងក្តី ឱ្យគេហៅមកឱ្យក្តី ឬថា ឱ្យផ្កាឈើដែលជារបស់ខ្លួនយ៉ាងណាមួយដល់បុគ្គលទាំងឡាយ ដែលចូលទៅរកដោយខ្លួនឯង ដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូល, ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ ឱ្យផ្កាឈើរបស់អ្នកដទៃ ក៏ត្រូវអាបត្តិទុក្កដដូចគ្នា ។ ឱ្យដោយថេយ្យចិត្ត ព្រះវិន័យធរគប្បីពិន័យតាមតម្លៃវត្ថុ ។ សូម្បីក្នុងរបស់សង្ឃ ក៏មានន័យយ៉ាងនេះដូចគ្នា ។ ចំណែកសេចក្តីប្លែកគ្នា ដូចតទៅនេះ ត្រូវអាបត្តិថុល្លច្ច័យដល់ភិក្ខុដែលឱ្យផ្កាឈើដែលគេកំណត់ទុក ដើម្បីប្រយោជន៍ដល់សេនាសនៈ ដោយភាពនៃខ្លួនជាធំ ។

សួរថា ឈ្មោះថា ផ្កាឈើ គួរឱ្យដល់អ្នកណា មិនគួរឱ្យដល់អ្នកណា ?

ឆ្លើយថា កាលនឹងឱ្យដល់មាតាបិតាមុន នាំទៅឱ្យដោយខ្លួនឯងក្តី ឱ្យគេនាំយកទៅឱ្យក្តី ហៅមកឱ្យដោយខ្លួនឯងក្តី ឱ្យគេហៅមកឱ្យក្តី គួរ ។ សម្រាប់ញាតិដ៏សេសឱ្យគេហៅមកឱ្យប៉ុណ្ណោះ ទើបគួរ ។ ក៏ការឱ្យផ្កាឈើនោះ ដើម្បីប្រយោជន៍ដល់ការបូជាព្រះរតនត្រ័យ ទើបគួរ ។ តែនឹងឱ្យផ្កាឈើដល់អ្នកណា ៗ ដើម្បីប្រយោជន៍ដល់ការប្រដាប់ ឬដើម្បីប្រយោជន៍ដល់ការបូជាសិវលិង្គជាដើម មិនគួរ ។ ក៏កាលនឹងប្រើឱ្យគេនាំទៅជូនដល់មាតាបិតា គួរប្រើសាមណេរដែលជាញាតិប៉ុណ្ណោះឱ្យ

នាំយកទៅជូន ។ បើសាមណេរមិនមែនញាតិក្រៅពីនេះ មានបំណងនាំទៅដោយខ្លួនឯងប៉ុណ្ណោះ ទើបគួរឱ្យនាំយកទៅ ។ ភិក្ខុដែលចែកផ្កាឈើដែលបានទទួលសម្មតិ នឹងឱ្យចំណែកពាក់កណ្ដាលដល់ពួកសាមណេរដែលមកដល់ក្នុងវេលាចែកក៏គួរ ។

ក្នុងកុរុន្ទីលោកពោលថា គួរឱ្យចំណែកពាក់កណ្ដាលដល់គ្រហស្ថដែលមកដល់, ក្នុងមហាបច្ចរីពោលថា គួរឱ្យតែបន្តិច ។ ភិក្ខុដែលមិនបានទទួលសម្មតិ គួរអបលោកន៍ឱ្យ, ពួកសាមណេរដែលមានសេចក្ដីគោរពក្នុងអាចារ្យ និងឧបជ្ឈាយ៍ បាននាំផ្កាឈើជាច្រើនមកគរទុក ។ ព្រះថេរៈទាំងឡាយឱ្យដល់ពួកសទ្ធិវិហារិកជាដើម ឬដល់ពួកឧបាសកដែលមកដល់ពីព្រឹកព្រលឹម ដោយពោលថា "អ្នកចូរកាន់យកផ្កាឈើនេះ, អ្នកចូរកាន់យកផ្កាឈើនេះ" មិនចាត់ថា ជាការឱ្យផ្កាឈើ ។ ពួកភិក្ខុដែលកាន់យកទៅដោយគិតថា ពួកយើងនឹងបូជាព្រះចេតិយក្ដី កំពុងធ្វើការបូជាក្ដី ឱ្យដល់ពួកគ្រហស្ថដែលមកដល់ក្នុងទីនោះ ៗ ដើម្បីប្រយោជន៍ដល់ការបូជាព្រះចេតិយ ។ សូម្បីការឱ្យនេះ ក៏មិនចាត់ថា ជាការឱ្យផ្កាឈើ សូម្បីឃើញពួកឧបាសកកំពុងបូជាដោយផ្កាភក់ជាដើម ហើយពោលថា ឧបាសកទាំងឡាយ ផ្កាកណ្ណិការជាដើមនៅឯវត្តមាន, ពួកលោកចូរទៅបេះផ្កាកណ្ណិការជាដើមនោះមកបូជាចុះ ដូច្នេះ ក៏គួរ ។

ពួកអ្នកស្រុកសួរភិក្ខុទាំងឡាយ ដែលធ្វើការបូជាដោយផ្កាឈើ ហើយចូលទៅកាន់ស្រុក ស្តីបន្ទោសព្រោះល្ងាចពេកថា "ព្រោះហេតុអ្វី លោកម្ចាស់ បានជាពួកលោកម្ចាស់ចូលមកល្ងាចម្ល៉េះ ?" ពួកភិក្ខុឆ្លើយថា "ក្នុងវត្តមានផ្កាឈើច្រើន, ពួកអាត្មា បានធ្វើការបូជា (មុនចូលមក)" ។ ពួកអ្នកស្រុកដឹងថា "បានជ្រាបថា ក្នុងវត្តមានផ្កាឈើច្រើន ថ្ងៃស្អែកឡើង ទើបកាន់យករបស់ទំពាររបស់ឆាន់ជាច្រើនទៅកាន់វត្ត ធ្វើការបូជាដោយផ្កាឈើនិងថ្វាយទាន", ការនិយាយនោះ ក៏គួរ ។

ពួកអ្នកស្រុកសូមវារៈផ្កាឈើថា "លោកម្ចាស់ ពួកខ្ញុំព្រះករុណានឹងបូជាក្នុងថ្ងៃឈ្មោះឯណោះ" ហើយមកក្នុងថ្ងៃដែលអនុញ្ញាត ។ ពួកសាមណេរបានបេះ ផ្កាឈើទុកពីព្រឹកព្រលឹម ។ ពួកអ្នកស្រុកកាលមិនឃើញផ្កាឈើជាដើម ទើបនិយាយថា "ផ្កាឈើនៅទីណា លោកម្ចាស់" ព្រះថេរៈទាំងឡាយ ឆ្លើយថា "ពួកសាមណេររក្សាទុក, ក៏ពួកលោកចូរនាំគ្នាទៅបូជាចុះ" សង្ឃនឹងបូជាក្នុងថ្ងៃដទៃ ។ ពួកអ្នកស្រុកទាំងនោះ នាំគ្នាបូជា ថ្វាយទានហើយទៅ, ការនិយាយយ៉ាងនោះ ក៏គួរ ។

តែក្នុងមហាបច្ចរីនិងកុរុន្ទី លោកពោលថា ព្រះថេរៈទាំងឡាយរមែងមិនបានដើម្បីប្រើឱ្យពួកសាមណេរឱ្យ, បើពួកសាមណេរឱ្យផ្កាឈើទាំងនោះ ដល់ពួកអ្នកស្រុកទាំងនោះដោយខ្លួនឯងផ្ទុំះឯង, ការឱ្យនោះសមគួរ, តែព្រះថេរៈទាំងឡាយ គួរពោលពាក្យត្រឹមតែប៉ុណ្ណេះថា ពួក

សាមណេរបេះផ្កាឈើទាំងនេះទុក ។

តែបើថា ពួកអ្នកស្រុកសូមវារៈផ្កាឈើហើយ កាលពួកសាមណេរមិនបានបេះផ្កាឈើទុក កាន់យកយាគូនិងភត្តជាដើមមក ហើយពោលថា លោកទាំងឡាយចូរឱ្យសាមណេរទាំងឡាយ បេះឱ្យ ការប្រើឱ្យពួកសាមណេរជាញាតិប៉ុណ្ណោះបេះឱ្យ ទើបគួរ ។ ព្រះថេរៈទាំងឡាយលើកពួកសាមណេរ ដែលមិនមែនញាតិឡើងដាក់លើមែកឈើ ។ ពួកសាមណេរមិនគួរចុះ ហើយគេចចៀសចេញទៅ, គួរបេះឱ្យ ។

ក្នុងមហាបច្ចរីនិងកុរុន្ទីពោលថា ក៏បើថា ព្រះធម្មកថិករូបខ្លះនឹងពោលថា "ឧបាសកនិងឧបាសិកាទាំងឡាយ ផ្កាឈើក្នុងវត្តមានច្រើន, ពួកលោកចូរកាន់យកយាគូនិងភត្តជាដើម ទៅធ្វើការបូជាដោយផ្កាឈើចុះ" យាគូនិងភត្តជាដើមនោះ រមែងមិនសមគួរដល់ព្រះធម្មកថិកនោះប៉ុណ្ណោះ ។ តែក្នុងមហាអដ្ឋកថា លោកពោលទុកដោយមិនប្លែកគ្នាថា យាគូនិងភត្តជាដើមនោះ ជាអកប្បិយ មិនសមគួរ ។

សូម្បីផ្លែឈើដែលជារបស់ខ្លួន ទឹងឱ្យដល់មាតាបិតានិងពួកញាតិដ៏សេស រមែងគួរ ដោយន័យដូចពោលហើយនុ៎ះឯង ។ តែកាលដែលភិក្ខុឱ្យ ដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូល គប្បីជ្រាបថា ត្រូវអាបត្តិទុក្កដជាដើម ព្រោះផ្លែឈើរបស់ខ្លួន របស់អ្នកដទៃ របស់សង្ឃនិងរបស់ដែលគេកំណត់ទុក ដើម្បីប្រយោជន៍ដល់សេនាសនៈ ដោយ

ន័យដូចពោលហើយនុ៎ះឯង ។ ចំពោះផ្លែឈើដែលជារបស់ខ្លួន នឹងឱ្យដល់ពួកអ្នកជម្ងឺ ឬ ដល់ពួកឥស្សរជនដែលអស់ស្បៀងហើយចូលមកដល់ ក៏គួរ ។ មិនចាត់ជាការឱ្យផ្លែឈើ ។ សូម្បីភិក្ខុចែកផ្លែឈើដែលសង្ឃសម្មតិ នឹងឱ្យចំណែកពាក់កណ្តាលដល់ពួកអ្នកស្រុក ដែលមកដល់ក្នុងវេលាចែកផ្លែឈើដល់សង្ឃ ក៏គួរ ។ អ្នកមិនបានទទួលសម្មតិ គួរ អបលោកន៍ឱ្យ ។

សូម្បីក្នុងសង្ឃារាម សង្ឃក៏គួរធ្វើកតិកាទុក ដោយការកំណត់ផ្លែឈើ ឬដោយការកំណត់ដើមឈើ កាលពួកអ្នកជម្ងឺ ឬពួកអ្នកដទៃសូមផ្លែឈើ អំពីផ្លែ ឬអំពីដើមឈើដែលកំណត់ទុកនោះ គប្បីឱ្យផ្លែឈើ ៤-៥ ផ្លែ ឬគប្បីសម្តែងដើមឈើ តាមដែលកំណត់ទុកថា ពួកលោកកាន់យកអំពីដើមនេះបាន តែមិនគួរនិយាយថា ផ្លែឈើដើមនេះល្អ, ពួកលោកចូរកាន់យកអំពីដើមនេះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា ចុណ្ណេន : គ្រឿងលំអិតសម្រាប់ងូត នេះ ដូចតទៅនេះ ៖

ភិក្ខុឱ្យលំអិតស្រស់ ឬទឹកអម្ចត់យ៉ាងដទៃជារបស់ខ្លួន ដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូល ត្រូវអាបត្តិទុក្កដ ។ សូម្បីក្នុងរបស់អ្នកដទៃជាដើម ក៏គប្បីជ្រាបវិនិច្ឆ័យដោយន័យដូចពោលមកហើយ ។

ចំណែកសេចក្តីប្លែកគ្នាដូចតទៅនេះ ៖

ក្នុងលំអិតវិស័យនេះ សំបកឈើស្មូម្បីដែលសង្ឃរក្សា និងបម្រុងទុក ក៏ចាត់ជាគរុភណ្ឌពិត ។ ស្មូម្បីក្នុងពួកជីស្អិត ឈើស្ទន់ និងឫស្សី បណ្ឌិតស្គាល់របស់ដែលគួរ ជាគរុភណ្ឌហើយ គប្បីជ្រាបវិនិច្ឆ័យដូចពោលហើយក្នុងលំអិតនុ៎ះឯង ។ តែការឱ្យស្ទឹកឈើ មិនមកក្នុងបាលីនេះ ។ ស្មូម្បីការឱ្យស្ទឹកឈើនោះ ក៏គប្បីជ្រាបដោយន័យដូចពោលហើយដូចគ្នា ។ ខ្ញុំព្រះករុណាទឹងពណ៌នាការឱ្យស្ទឹកឈើទាំងអស់ដោយពិស្តារក្នុងការវិនិច្ឆ័យគរុភណ្ឌនៅខាងមុខ[១] ។

វេជ្ជកម្មវិធី ក្នុងបទថា វេជ្ជកាយ វា : ដោយកិរិយាធ្វើពេទ្យខ្លះនេះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលទុកហើយ ក្នុងតតិយបារាជិកវណ្ណនានុ៎ះឯង ។

ក្នុងពាក្យថា ជង្ឃបេសនិកេន : ដោយការបម្រើដោយស្មងខ្លះនេះ បានដល់ កម្ម គឺ ការងាររបស់ទូត និងការបញ្ជូនដំណឹងរបស់ពួកគ្រហស្ថលោកហៅថា ជង្ឃបេសនីយ:, ខនោះ ដែលភិក្ខុមិនគួរធ្វើ ។ ដោយថា កាលភិក្ខុទទួលសំបុត្រដំណឹងរបស់ពួកគ្រហស្ថហើយដើរទៅជាទុក្កដគ្រប់ជំហាន ។ ស្មូម្បីកាលឆាន់ភោជនដែលអាស្រ័យ កម្មនោះ

---

១. សមន្ត. ចុល្ល. សេនាសនក្ខន្ធកវណ្ណនា. ៦. ៤០២/៦៩១ ។

បានមកក៏ត្រូវអាបត្តិទុក្កដ គ្រប់ ៗ ពុំនូតដែលលេបចូល ។ សូម្បីកាលមិនទទួលសំបុត្រដំណឹងពីដំបូង ខាងក្រោយសម្រេចចិត្តថា "ឥឡូវនេះ គឺស្រុកនោះ ណ្ហើយចុះ យើងនឹងប្រាប់ដំណឹងនោះ ហើយចេញអំពីមក (ឆៀងចូលទៅ) ក៏ត្រូវអាបត្តិទុក្កដ គ្រប់ ៗ ជំហាន ។ កាលឆាន់ភោជនដែលបានពីប្រាប់ដំណឹងមក ត្រូវអាបត្តិទុក្កដដោយន័យមុនដូចគ្នា ។ តែភិក្ខុមិនទទួលដំណឹងមក កាលត្រូវគ្រហស្ថសួរថា "លោកម្ចាស់ អ្នកមានឈ្មោះនេះ ក្នុងស្រុកនោះ មានដំណឹងប្រព្រឹត្តទៅ យ៉ាងណា ? ដូច្នេះ នឹងប្រាប់ក៏គួរ ។ ក្នុងបញ្ហាដែលគេសួរ មិនមានទោស ។

តែនឹងបញ្ជូនដំណឹងរបស់ពួកសហធម្មិក ៥ របស់មាតាបិតា បណ្ឌុបលាសៈ និងវេយ្យាវច្ចកររបស់ខ្លួនគួរ ។ និងភិក្ខុបញ្ជូនដំណឹងដែលសមគួរ មានប្រការដូចពោលហើយក្នុងកាលមុន របស់ពួកគ្រហស្ថគួរ ។ ព្រោះដំណឹងដែលសមគួរនេះ រមែងមិនឈ្មោះថា ជាកម្ម គឺការនាំដំណឹងដោយស្មង ។ ក៏ឯបច្ច័យដែលកើតឡើងអំពីកុលទូសកកម្ម ៨ យ៉ាងនេះ រមែងមិនសមគួរដល់សហធម្មិកទាំង ៥ ដូចគ្នានឹងបច្ច័យដែលកើតឡើងអំពីការអួតឧត្តរិមនុស្សធម្ម ដែលមិនពិត និងការទិញដូរដោយរូបិយៈតែម្តង ។

ភិក្ខុនោះ មានការប្រព្រឹត្តលាមក; ព្រោះហេតុនោះ ទើបឈ្មោះថា បាបសមាចារ ។ ក៏ព្រោះបាបសមាចារ មានការដាំដើមផ្កាជាដើម ដែល

ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកហើយ ក្នុងសិក្ខាបទនេះ ; ដូច្នោះ ព្រះអង្គទើបត្រាស់ទុកក្នុងបទភាជនៈនៃបទថា បាបសមាចារនេះ ដោយន័យជាដើមថា មាលាវច្ឆំ រោបេតិបិ[1] : ដាំកូនឈើផ្កាខ្លួនឯងខ្លះ ដូច្នេះ ។

[៣២៣] បទថា តិរោក្ខា : ក្នុងទីខាងក្រៅ បានដល់កំបាំងមុខ ។

ក៏ពាក្យថា កុលានិ នេះ ក្នុងពាក្យថា កុលានិ ច តេន ទុដ្ឋានិ : ត្រកូលទាំងឡាយសោតដែលភិក្ខុនោះទ្រុស្តហើយ នេះត្រឹមតែជាវោហារ, តែដោយអត្ថន័យ ពួកអ្នកស្រុកត្រូវភិក្ខុនោះប្រទូសរ៉ាយ ; ដូច្នោះ ក្នុងបទភាជនៈនៃបទថា កុលានិ ច តេន ទុដ្ឋានិ ទើបព្រះមានព្រះភាគត្រាស់ពាក្យមានជាដើមថា បុព្វេ សទ្ធា ហុត្វា : ពីមុនមនុស្សទាំងឡាយមានសទ្ធា ដូច្នេះ ។

[៣២៤] បទថា ឆន្ទគាមិនោ : លុះក្នុងសេចក្ដីស្រឡាញ់ មានវិគ្រោះថា អ្នកឈ្មោះថា មានឆន្ទគាមិនៈ ព្រោះអត្ថថា រមែងលំអៀងព្រោះសេចក្ដីស្រឡាញ់ ។ ក្នុងបទដ៏សេស ក៏មានន័យយ៉ាងនេះ ។

ក្នុងពាក្យថា សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ : សូធ្យសមនុភាសនកម្មប្រកាសហាម ដើម្បីឱ្យលះបង់អំពើអាក្រក់នោះ

១. ថៃ. រោបេន្តិបិ ។

នេះ បណ្ឌិតគប្បីឃើញសេចក្តីយ៉ាងនេះថា ត្រូវអាបត្តិទុក្កដតែម្យ៉ាង ព្រោះកុលទូសកកម្ម ។ តែភិក្ខុនោះចៀសវាងពោលពាក្យណា ចំពោះសង្ឃថា ជាអ្នកមានសេចក្តីលំអៀង ព្រោះស្រឡាញ់គ្នាជាដើម សង្ឃគប្បីធ្វើសមនុភាសនកម្ម ដើម្បីលះបង់នូវពាក្យថា ជាអ្នកមានសេចក្តីលំអៀងព្រោះស្រឡាញ់គ្នាជាដើមនោះចេញ ។

ពាក្យដ៏សេសគ្រប់កន្លែង មានសេចក្តីងាយយល់ទាំងអស់ ។ សូម្បីសមុដ្ឋានជាដើម ក៏ដូចគ្នានឹងបឋមសង្ឃភេទសិក្ខាបទនោះឯង ។

កុលទូសកសិក្ខាបទវណ្ណនា ចប់

## ពន្យល់អត្ថបទសរុបសង្ឃាទិសេស

[៣៣០] ក្នុងពាក្យថា ឧទ្ទិដ្ឋា ខោ ។បេ ។ ឯវមេតំ ធារយាមិ : បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិទាំងឡាយឈ្មោះសង្ឃាទិសេសទាំង ១៣ ខ្ញុំសម្តែងឡើងហើយ ។ល ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ធម៌ទាំងនេះ មានការត្រូវតាំងពីដំបូង ; ព្រោះដូច្នោះ ទើបឈ្មោះថា បឋមាបត្តិកៈ អធិប្បាយថា គប្បីត្រូវក្នុងគ្រាដំបូង គឺ ក្នុងខណៈដែលកន្លងល្មើសតែម្តង ។ ចំណែកធម៌ទាំងឡាយក្រៅ នេះ គប្បីជ្រាប

ថា ជាយាវតតិយកៈ ដោយអត្ថថា មាន(អាបត្តិ) ព្រោះសមនុភាសនកម្មលើកទី ៣ ដូចរោគស្គម (កើត)មានក្នុងថ្ងៃទី ៣ និងទី ៤ គេហៅថា រោគទី ៣ ទី ៤ ដូច្នោះ ។

ពាក្យថា **យាវតិហំ ជានំ បដិច្ឆាទេតិ : ហើយដឹងច្បាស់បិទបាំងអស់ប៉ុន្មានថ្ងៃ** មានសេចក្ដីថា ដឹងប្រាកដ បិទបាំងទុក គឺមិនប្រាប់ដល់សព្រហ្មចារីទាំងឡាយថា ខ្ញុំព្រះករុណាត្រូវអាបត្តិឈ្មោះនេះ អស់ថ្ងៃមានប្រមាណប៉ុណ្ណេះ ។

បទថា **តាវតិហំ : អស់ប៉ុណ្ណោះថ្ងៃ** សេចក្ដីថា (ត្រូវនៅបរិវាសដោយសេចក្ដីមិនប្រាថ្នា) អស់ថ្ងៃមានប្រមាណប៉ុណ្ណោះ ។

ពាក្យថា **អកាមា បរិវត្ថព្វំ : ព្រោះខ្លួនមិនមានសេចក្ដីប្រាថ្នានឹងនៅបរិវាស** មានសេចក្ដីថា មិនមែនដោយសេចក្ដីប្រាថ្នាគឺ មិនមែនដោយអំណាច (របស់ខ្លួន), តាមការពិត គប្បីសមាទានបរិវាសនៅដោយសេចក្ដីមិនប្រាថ្នា គឺ ដោយមិនមែនអំណាច (របស់ខ្លួន) ។

ពីរបទថា **ឧត្តរឹ ឆារត្តំ : អស់ ៦ រាត្រីតទៅទៀត** គឺ អស់ ៦ រាត្រី បន្ថែមឡើងអំពីបរិវាស ។

បទថា **ភិក្ខុមានត្តាយ : ភិក្ខុមានត្ត** បានដល់ ដើម្បីសេចក្ដីរាប់អានរបស់ភិក្ខុទាំងឡាយ, មានពាក្យអធិប្បាយថា ដើម្បីប្រយោជន៍ឱ្យ

ភិក្ខុទាំងឡាយត្រេកអរ ។

ភិក្ខុសង្ឃនោះ ឈ្មោះថា **វីសតិគណៈ** ព្រោះមានគណៈរាប់បាន ២០ រូប ។

បទថា **តត្ថ : ក្នុងទីនោះ** មានសេចក្តីថា ក្នុងសីមាដែលភិក្ខុសង្ឃមានគណៈ ២០ រូប ដោយកំណត់យ៉ាងតិចបំផុត ។

បទថា **អព្ភេតព្វោ : គប្បីឱ្យអព្ភាន** មានសេចក្តីថា ដែលភិក្ខុសង្ឃគប្បីអព្ភាន គឺ គប្បីរាប់រក, មានពាក្យអធិប្បាយថា គប្បីហៅចូលដោយអំណាចនៃអព្ភានកម្ម មួយយ៉ាងទៀត មានសេចក្តីថា សង្ឃគប្បីហៅចូលពួក ។

បទថា **អនព្ភិតោ : មិនបានឈ្មោះថា សង្ឃឱ្យអព្ភាន** បានដល់ជាអ្នកដែលសង្ឃមិនបានអព្ភាន គឺ មិនបានរាប់រក, មានពាក្យអធិប្បាយថា មិនទាន់បានធ្វើអព្ភានកម្ម ។ ម្យ៉ាងទៀត មានសេចក្តីថា សង្ឃមិនទាន់បានហៅចូលពួក ។

បទថា **សាមីចិ : ជាការដ៏សមគួរ** បានដល់ តាមធម្មតា ។ មានពាក្យអធិប្បាយថា ឱវាទានុសាសនីដែលស្រេបតាមលោកុត្តរធម៌ជាសាមីចិ គឺ ជាធម្មតា ( សាមីចិកម្ម ) ។ បទដ៏សេសក្នុងពាក្យថា ឧទ្ទិដ្ឋា ខោ ជាដើមនេះ មានន័យដូចពោលហើយទាំងនោះឯង ។

## ចំនួនសិក្ខាបទក្នុងសង្ឃាទិសេសកណ្ឌនោះ គឺ

១. សុក្កវិស្សដ្ឋិសិក្ខាបទ ការបញ្ចេញទឹកសុក្កៈ
២. កាយសំសគ្គសិក្ខាបទ ការស្ទាបអង្អែលកាយស្រី
៣. ទុដ្ឋុល្លវាចាសិក្ខាបទ ការពោលពាក្យអាក្រក់
៤. អត្តកាមបារិចរិយសិក្ខាបទ ការឱ្យស្រីបម្រើខ្លួនដោយកាម
៥. សញ្ចរិត្តសិក្ខាបទ ការដឹកនាំបុរសស្ត្រីឱ្យបានគ្នាជាប្តីប្រពន្ធ
៦. កុដិការសិក្ខាបទ ការធ្វើកុដិ
៧. វិហារការសិក្ខាបទ ការធ្វើលំនៅ ( កុដិធំ )
៨. ទុដ្ឋទោសសិក្ខាបទ ការចោទអាបត្តិរកដើមហេតុគ្មាន
៩. អញ្ញភាគិយសិក្ខាបទ ការចោទអាងលេសណាទីមួយ
១០. សង្ឃភេទសិក្ខាបទ ការបំបែកសង្ឃ
១១. ភេទានុវត្តកសិក្ខាបទ ការប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃ
១២. ទុព្វចសិក្ខាបទ ការប្រដៅក្រ
១៣. កុលទូសកសិក្ខាបទ ការទូស្តត្រកូល

## តេរសកសង្ឃាទិសេសកណ្ឌ ចប់

# អនិយតកណ្ឌ

លោកដ៏មានអាយុទាំងឡាយ មួយទៀត ធម៌ គឺ អនិយត ២ សិក្ខាបទនេះឯង រមែងមកកាន់ឧទ្ទេស ។

## ១. បឋមអនិយតសិក្ខាបទវណ្ណនា

[៣៣១] អនិយតសិក្ខាបទទី ១ ថា តេន សមយេន ពុទ្ធោ ភគវា : សម័យនោះ ព្រះពុទ្ធដ៏មានបុណ្យសិរី ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងអនិយតសិក្ខាបទទី ១ នោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

### ពន្យល់អត្ថក្នុងមូលហេតុនៃបឋមបញ្ញត្តិជាដើម

ពាក្យថា កាលយុត្តំ សមុល្លបន្តោ : ហើយនិយាយគ្នាអស់កាលដ៏គួរ មានសេចក្ដីថា កំណត់កាលហើយពោលពាក្យជាប់ដោយរឿងអ្នកស្រុក ក្នុងវេលាដែលអ្នកណាមួយ មិនដើរឆ្លងទៅមក គឺ តាមសមគួរដល់វេលាដូច្នោះ មានជាដើមថា នាងមិនអផ្សុកទេឬ នាងមិនលំបាកចិត្តទេឬ នាងមិនស្រេកឃ្លានទេឬ ?

ពាក្យថា កាលយុត្តំ ធម្មំ ភណន្តោ : និយាយធម៌អស់កាលដ៏គួរ មានសេចក្ដីថា កំណត់កាលវេលាដែលមានអ្នកណាទៅមក គឺ

តាមសមគួរដល់វេលាដូច្នោះ ហើយពោលធម្មកថា មានជាដើមថា “នាងគួរធ្វើឧបោសថ, នាងគួរប្រគេនសលាកភត្ត” ដូច្នេះ ។

[៣៣២] នាងវិសាខានោះ ឈ្មោះថា មានបុត្រច្រើន ព្រោះនាងមានធីតានិងបុត្រច្រើន ។ បានឮថា នាងមានបុត្រប្រុស ១០ នាក់ និងបុត្រស្រី ១០ នាក់ ។ ឈ្មោះថា មានចៅច្រើន ព្រោះនាងមានចៅច្រើន ។ ដូចនាងវិសាខានោះ មានបុត្រប្រុសស្រី ២០ នាក់ នោះឯង, សូម្បីបុត្រប្រុសស្រីរបស់នាងម្នាក់ ៗ ក៏មានកូនម្នាក់ ២០ ៗ ដូច្នោះ ។ នាងទើបបានឈ្មោះថា មានកូននិងចៅជាបរិវារ ៤២០ នាក់ ដោយប្រការយ៉ាងនេះ ។

បទថា អភិមង្គលសម្មតា : ជាស្រីមានមង្គលដ៏ប្រសើរ គឺអ្នកដែលមនុស្សទាំងឡាយសន្មតថា ជាមង្គលដ៏ឧត្តម ។

បទថា យញ្ញេសុ : កាលបើមានធ្វើទានធំ គឺ ក្នុងទានតូចនិងទានធំ ។

បទថា ឆណេសុ : កាលបើមានអាវាហៈ និងវិវាហមង្គលជាដើម គឺ ក្នុងការផាររមហោស្រពដែលប្រព្រឹត្តទៅម្តង ៗ មានអាវាហមង្គល និងវិវាហមង្គលជាដើម ។

បទថា ឧស្សវេសុ : កាលបើមានមហោស្រព បានដល់ ក្នុងការ

ផ្ទះមហាស្រពន្ធ(សម្ភោធ) មានអាសាឡ្ហនក្ខត្តឫក្ស និងបវារណា នក្ខត្តឫក្សជាដើម (បុណ្យឆ្លងនក្ខត្តឫក្សថ្ងៃចូលវស្សា និងថ្ងៃចេញវស្សា) ។

បទថា បឋមំ ភោជេន្តិ : បរិភោគមុនគេជាដំបូង មានសេចក្ដីថា ជនទាំងឡាយ អញ្ជើញឱ្យទទួលទានអាហារជាមុន បណ្ដើរសូមពរថា "សូមឱ្យក្មេងទាំងនេះ ចូរជាអ្នកមិនមានរោគ មានអាយុវែង ស្មើដូចអ្នកនាងម្ចាស់ចុះ" ដូច្នេះ ។ សូមឱ្យជនពួកណា ជាអ្នកមានសទ្ធាជ្រះថ្លា, ជនទាំងនោះឱ្យភិក្ខុទាំងឡាយឆាន់ហើយ ទើបអញ្ជើញនាងវិសាខានោះឯងឱ្យទទួលទានអាហារមុនគេ ក្នុងលំដាប់ដែលភិក្ខុឆាន់ហើយនោះ ។

បទថា ន អាទិយតិ : ក៏នៅមិនអើពើសោះ មានសេចក្ដីថា ឧទាយីថេរៈមិនស្ដាប់ពាក្យរបស់នាង ។ម្យ៉ាងទៀត សេចក្ដីថា មិនអើពើ ។

បទថា អលំកម្មនិយេ : ល្មមធ្វើ(សេវនកិច្ច)បាន មានវិគ្រោះថា ទីអន្ធ័យដែលឈ្មោះថា កម្មនិយៈ ព្រោះអត្ថថា គួរដល់កម្ម គឺសមគួរដល់កម្ម ។ ដែលឈ្មោះថា អលង្កម្មនិយៈ ព្រោះអត្ថថា អាចដើម្បីធ្វើការបាន ក្នុងអាសនៈកំបាំងដែលល្មមនឹងធ្វើការបាននោះ សេចក្ដីថា ក្នុងស្ថានទីដូចដែលជនទាំងឡាយ កាលនឹងធ្វើអជ្ឈាចារអាចធ្វើកម្ម

នោះបាន ។ ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទថា អលំកម្មនិយេ នោះ លោកទើបពោលថា អាចនឹងសេពមេថុនធម្មបាន ។ មានពាក្យអធិប្បាយថា ក្នុងទីដែលអាចនឹងសេពមេថុនធម្មបាន ។

[៣៣៣] ពីរបទថា និសជ្ជំ កប្បេយ្យ : **អង្គុយ** បានដល់គប្បីធ្វើការអង្គុយ ។ អធិប្បាយថា គប្បីអង្គុយ ។ ក៏ព្រោះបុគ្គលអង្គុយមុន ហើយទើបដេក ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ការអង្គុយនិងការដេកទាំងពីរទុក ក្នុងបទភាជនៈនៃបទថា និសជ្ជំ កប្បេយ្យ នោះ ។

បណ្ដាបទទាំងនោះ បទថា ឧបនិសិន្នោ : **អង្គុយជិត** មានសេចក្ដីថា បុគ្គលអ្នកចូលទៅអង្គុយជិត ៗ នុ៎ះឯង អ្នកសិក្សា គប្បីជ្រាបថា ដេកជិត ។

ពីរបទថា ភិក្ខុ និសិន្នេ : **កាលបើភិក្ខុអង្គុយហើយ** សេចក្ដីថា កាលភិក្ខុអង្គុយហើយ ។

ពីរបទថា ឧភោ វា និសិន្នា : **អ្នកទាំងពីរអង្គុយក្ដី** មានសេចក្ដីថា សូម្បីទាំង២នាក់ អង្គុយមិនមុនមិនក្រោយគ្នា (អង្គុយព្រមគ្នា) ។

ក៏ក្នុងសិក្ខាបទទី ១ នេះ ពាក្យថា ទីកំបាំងត្រចៀក មិនបានមក

ក្នុងព្រះបាលី ក៏ពិតមែន ប៉ុន្តែគប្បីជ្រាបការកំណត់ ( អាបត្តិ ) ដោយទីកំបាំងភ្នែកប៉ុណ្ណោះ ។ បើថា មានបុរសដឹងក្តី អង្គុយនៅជិតទ្វារបន្ទប់ដែលបិទសន្ទះទ្វារទុក ក៏ការពារអាបត្តិមិនបានឡើយ ។ តែបើអង្គុយជិតទ្វារបន្ទប់ដែលមិនបានបិទសន្ទះទ្វារ ការពារអាបត្តិបាន ។ បានតែទីជិតទ្វារតែម្យ៉ាងក៏ទេ, សូម្បីអង្គុយក្នុងឱកាសខាងក្នុង១២ ហត្ថ បើជាបុរសភ្នែកល្អ មានចិត្តរវើរវាយខ្លះ គេដេកលក់ទៅខ្លះ ក៏ការពារអាបត្តិបាន ។ បុរសខ្វាក់ភ្នែក សូម្បីឈរក្នុងទីជិត ក៏ការពារអាបត្តិមិនបាន ។ ទោះជាបុរសភ្នែកល្អ ដេកលក់ទៅ ក៏ការពារអាបត្តិមិនបាន ។ ចំណែកស្ត្រីសូម្បីទាំង ១០០ នាក់ ក៏ការពារអាបត្តិមិនបានឡើយ ។

[៣៣៤] បទថា សទ្ធេយ្យវចសា : មានវាចាគួរជឿបាន បានដល់ មានពាក្យគួរជឿបាន ។ ក៏ព្រោះឧបាសិកានោះ ជាអរិយសាវិកាដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា អាគតផលា ជាដើមទុកក្នុងបទភាជនៈនៃបទថា សទ្ធេយ្យវចសា នោះ ។

ក្នុងពាក្យថា អាគតផលា : ស្រីដែលមានផលមកហើយ ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

ឧបាសិកានោះឈ្មោះថា អាគតផលា ព្រោះថា មានផលដែលមកហើយ ។ អធិប្បាយថា អ្នកបានសោតាបត្តិផលហើយ ។

បទថា **អភិសមេតាវិនី : ត្រាស់ដឹងសច្ចៈបួន** គឺ អ្នកបាន ត្រាស់ដឹងសច្ចៈ ៤ ។ ឧបាសិកានេះ យល់សាសនា គឺ ត្រៃសិក្ខាល្អ ; ព្រោះដូច្នោះ ទើបឈ្មោះថា អ្នកយល់សាសនាល្អ ។

[៣៣៥] ពាក្យថា **និសជ្ជំ ភិក្ខុ បដិជានមានោ : កាលភិក្ខុ ទទួលប្តេជ្ញាការអង្គុយ** មានសេចក្តីថា ឧបាសិកាដូច្នេះ ឃើញហើយទើប និយាយ ក៏ពិតមែនហើយ តែថា ភិក្ខុប្តេជ្ញាការអង្គុយតែម្យ៉ាង ព្រះវិន័យ ធរគប្បីពិន័យដោយធម៌ ៣ យ៉ាងណាមួយ កាលលោកមិនប្តេជ្ញា មិន គប្បីពិន័យ ។

ពាក្យថា **ម្យ៉ាងទៀត ឧបាសិកាមានវាចាគួរជឿបាននោះ** ពោល អំពីធម៌ណា ភិក្ខុនោះ គប្បីត្រូវពិន័យដោយធម៌នោះ មានសេចក្តីថា ឧបាសិកានោះ លើករឿងមេថុនធម្មជាដើមឡើង ព្រមដោយអាការមាន ការអង្គុយជាដើម អាការយ៉ាងណា, ភិក្ខុនោះ ក៏បដិញ្ញាផង គប្បីត្រូវ ពិន័យដោយអាការយ៉ាងនោះ ។ អធិប្បាយថា មិនគប្បីពិន័យដោយ អាការត្រឹមតែពាក្យរបស់ឧបាសិកា សូម្បីបែបនេះ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះធម្មតាថា រឿងដែលឃើញជាយ៉ាងនោះក៏មាន ជា យ៉ាងដទៃក៏មាន, ក៏ដើម្បីប្រកាសសេចក្តីនោះ ទើបអាចារ្យទាំងឡាយ នាំ

រឿងមកជាឧទាហរណ៍ដូចតទៅនេះ ៖

## រឿងព្រះថេរៈជាខីណាស្រពអង្គុយជាមួយមាតុគ្រាម

បានជ្រាបថា ក្នុងមល្លារាមវិហារ ព្រះថេរៈជាខីណាស្រពមួយរូប ទៅកាន់ត្រកូលឧបដ្ឋាក ក្នុងថ្ងៃមួយ អង្គុយហើយខាងក្នុងផ្ទះ ។ ចំណែកឧបាសិកាក៏ឈរផ្អែកបល្ល័ង្កសម្រាប់ដេក ។ លំដាប់នោះ ភិក្ខុអ្នកត្រាច់បិណ្ឌបាតជាវត្តមួយរូប ឈរត្រង់ជិតទ្វារបានឃើញ មានការសម្គាល់ថា "ព្រះថេរៈអង្គុយលើអាសនៈជាមួយនឹងឧបាសិកា" ទើបសម្លឹងមើលរឿយ ៗ ។ សូម្បីព្រះថេរៈក៏កំណត់ដឹងថា "ភិក្ខុរូបនេះ មានការយល់ក្នុងយើងថា មិនបរិសុទ្ធិ" ធ្វើភត្តកិច្ចហើយទៅកាន់វិហារ ចូលទៅកាន់ទីនៅរបស់ខ្លួនហើយអង្គុយនៅខាងក្នុងទុំឯង ។ ភិក្ខុរូបនោះ មកហើយដោយតាំងចិត្តថា "យើងនឹងចោទព្រះថេរៈ" ក្រហែមហើយបើកទ្វារ ។ ព្រះថេរៈជ្រាបចិត្តរបស់លោក ទើបហោះឡើងលើអាកាស អង្គុយដោយបល្ល័ង្ក (ពែនភ្នែន) ផ្អែកជហ្វាផ្ទះកំពូល ។

សូម្បីភិក្ខុនោះចូលទៅខាងក្នុងត្រួតមើលគ្រែ និងខាងក្រោមគ្រែ មិនឃើញព្រះថេរៈ ទើបងើយមើលខាងលើ ។ លំដាប់នោះ លោកឃើញព្រះថេរៈអង្គុយនៅលើអាកាស ទើបពោលថា "លោកម្ចាស់ លោកឈ្មោះថា មានឫទ្ធិច្រើនយ៉ាងនេះ សូមឱ្យប្រាប់នូវសេចក្តីដែល

លោកម្ចាស់អង្គុយលើអាសនៈ ជាមួយនឹងមាតុគ្រាមផងចុះ” ។ ព្រះថេរៈទើបពោលថា “លោកមានអាយុ នេះជាទោសរបស់ចន្លោះស្រុក តែយើងមិនអាចឱ្យលោកជឿបាន ទើបបានធ្វើយ៉ាងនេះ, លោកគួរនឹងជួយរក្សាយើងទុកផង” ព្រះថេរៈពោលយ៉ាងនេះហើយ ក៏ចុះមកក្រោមវិញ ។

## គប្បីពិន័យអាបត្តិតាមបដិញ្ញារបស់ភិក្ខុ

[៣៣៦] តពីនេះទៅ ពាក្យថា សា ចេ ឯវំ វទេយ្យ : បើឧបាសិកានោះ ចោទយ៉ាងនេះ ជាដើមទាំងអស់ព្រះមានព្រះភាគត្រាស់ដើម្បីសម្តែងអាការនៃហេតុរបស់ការបដិញ្ញា ។

បណ្តាបទទាំងនោះ ប្រើនបទថា មាតុគាមស្ស មេថុនំ ធម្មំ បដិសេវន្តោ : សេពមេថុនធម្មនឹងមាតុគ្រាម មានសេចក្តីថា អ្នកសេពមេថុនធម្មក្នុងទ្វារមគ្គរបស់មាតុគ្រាម ។

ពាក្យថា និសជ្ជាយ ការេតព្វោ : វិន័យធរត្រូវវិនិច្ឆ័យអាបត្តិដោយការអង្គុយ មានសេចក្តីថា ភិក្ខុប្តេជ្ញាការអង្គុយហើយ មិនប្តេជ្ញាការសេពមេថុនធម្ម កុំពិន័យដោយអាបត្តិមេថុនធម្មបារាជិក គប្បីពិន័យដោយអាបត្តិដែលត្រូវដោយហេតុត្រឹមតែអង្គុយ ។ អធិប្បាយថា គប្បីពិន័យដោយអាបត្តិបាចិត្តិយ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងចតុក្កៈទាំងអស់

ដោយន័យនេះ ។

[៣៤៣] បណ្ដាបទមានបទថា **គមនំ បដិជានាតិ** ជាដើម ដែលត្រាស់ទុក ដើម្បីទ្រង់សម្ដែងការកំណត់អាបត្តិ និងអនាបត្តិ ខាងចុងបំផុតនៃសិក្ខាបទ ។

ពីរបទថា **គមនំ បដិជានាតិ : ភិក្ខុទទួលប្ដេជ្ញានូវកិរិយាដើរ** មានសេចក្ដីថា រមែងប្ដេជ្ញាការដើរយ៉ាងនេះថា យើងជាអ្នកដើរទៅដើម្បីត្រេកអរការអង្គុយក្នុងទីកំបាំង ។

បទថា **និសជ្ជំ : នូវកិរិយាអង្គុយ** មានសេចក្ដីថា រមែងប្ដេជ្ញានូវការអង្គុយដោយសេចក្ដីត្រេកអរក្នុងការអង្គុយប៉ុណ្ណោះ ។

បទថា **អាបត្តឹ : នូវអាបត្តិ** បានដល់ បណ្ដាអាបត្តិទាំង ៣ អាបត្តិយ៉ាងណាមួយ ។

ពីរបទថា **អាបត្តិយា ការេតព្វោ : វិន័យធរត្រូវវិនិច្ឆ័យតាមអាបត្តិ** មានសេចក្ដីថា បណ្ដាអាបត្តិទាំង ៣ គប្បីពិន័យដោយអាបត្តិដែលភិក្ខុបដិញ្ញា ។

ពាក្យដ៏សេស ក្នុងបតុក្កៈនៃសិក្ខាបទនេះ មានអធិប្បាយងាយយល់ទាំងអស់ ។

ចំណែកក្នុងទុតិយចតុក្កៈ មានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា គមនំ នប្បដិជានាតិ : ភិក្ខុមិនទទួលប្ដេជ្ញានូវកិរិយាដើរ មានសេចក្ដីថា រមែងមិនប្ដេជ្ញាដោយអំណាចនៃសេចក្ដីត្រេកអរនឹងការអង្គុយក្នុងទីកំបាំង រមែងពោលថា យើងទៅដោយការងាររបស់ខ្លួនមានសលាកភត្តជាដើម, ចំណែកឧបាសិកានោះ មកកាន់ស្ថានទីដែលយើងអង្គុយដោយខ្លួនឯង ។ បទដ៏សេស សូម្បីក្នុងទុតិយចតុក្កៈនេះ ក៏មានអធិប្បាយងាយយល់ដូចគ្នា ។

តែបណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងចតុក្កៈទាំងពួង ដូចតទៅនេះ ៖

កិលេសដែលអាស្រ័យមេថុនធម្ម ត្រាស់ហៅថា សេចក្ដីត្រេកអរនឹងការអង្គុយក្នុងទីកំបាំង ។ ភិក្ខុណា ប្រាថ្នានឹងទៅកាន់សំណាក់នៃមាតុគ្រាម ដោយសេចក្ដីត្រេកអរនោះបន្តក់ភ្នែក ត្រូវអាបត្តិទុក្កដ, ស្លៀកសំពត់សម្រាប់ស្លៀក (ស្បង់) ចងវត្ថពន្ធចង្កេះ ដណ្ដប់ចីវរ ត្រូវអាបត្តិទុក្កដ គ្រប់ ៗ ប្រយោគក្នុងចតុក្កៈទាំងពួង ។ កាលដើរទៅ ត្រូវអាបត្តិទុក្កដ គ្រប់ ៗ ជំហាន ។ ដើរទៅហើយអង្គុយ ត្រូវអាបត្តិទុក្កដតែម្យ៉ាង, លុះមកាលមាតុគ្រាមមកអង្គុយ ត្រូវអាបត្តិបាចិត្តិយ ។ បើស្រីនោះក្រោកហើយអង្គុយ ៗ ដោយករណីយកិច្ចយ៉ាងណាមួយ ត្រូវអាបត្តិបាចិត្តិយក្នុងការអង្គុយគ្រប់វារៈ ។ ភិក្ខុប្រាថ្នាទៅរកស្រីណា មិនជួបស្រីនោះ, ស្រីដទៃមកអង្គុយ កាលកើតសេចក្ដីត្រេកអរ ក៏ត្រូវអាបត្តិ

បាចិត្តិយ ។ ក្នុងមហាបច្ចរី លោកពោលថា ព្រោះមានចិត្តមិនបរិសុទ្ធិ តាំងពីវេលាមក ត្រូវអាបត្តិដូចគ្នា ។ បើស្រីនាំគ្នាមកច្រើននាក់, ត្រូវអាបត្តិបាចិត្តិយ តាមចំនួនមនុស្សស្រី ។ បើពួកស្រី ៗទាំងនោះ មួងក្រោកមួងអង្គុយរឿយ ៗ ត្រូវអាបត្តិបាចិត្តិយច្រើន តាមចំនួននឹងកិរិយាដែលអង្គុយ ។ សូម្បីកាលភិក្ខុមិនកំណត់ទុកទៅអង្គុយដោយតាំងចិត្តថា "យើងនឹងសម្រេចសេចក្ដីត្រេកអរក្នុងទីកំបាំង ជាមួយស្រីដែលយើងជួបហើយទាំងអស់" ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបអាបត្តិច្រើន ដោយអំណាចនៃស្រីទាំងឡាយដែលមកហើយទាំងអស់នោះផង និងដោយអំណាចការអង្គុយញយ ៗនោះផង ដោយន័យដូចពោលហើយនុ៎ះឯង ។ បើសូម្បីថា ភិក្ខុទៅអង្គុយដោយចិត្តបរិសុទ្ធិ កើតសេចក្ដីត្រេកអរក្នុងទីកំបាំងជាមួយនឹងស្រីដែលមកកាន់សំណាក់ហើយអង្គុយ, មិនមានអាបត្តិឡើយ ។ សមុដ្ឋានជាដើម ដូចគ្នានឹងមេថុនធម្មសិក្ខាបទនោះឯង ។

បដិច្ឆន្នាសនសិក្ខាបទវណ្ណនា ចប់

# ២. នបជិច្ចន្នាសនសិក្ខាបទវណ្ណនា

[៣៤៤] អនិយតសិក្ខាបទទី ២ ថា តេន សមយេន ពុទ្ធោ ភគវា : សម័យនោះ ព្រះពុទ្ធដ៏មានបុញ្ញសិរី ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងអនិយតសិក្ខាបទទី ២ នោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ក្នុងពាក្យថា ភគវតា បដិក្ខិត្តំ : ព្រះមានព្រះភាគទ្រង់ហាមហើយជាដើម អ្នកសិក្សាគប្បីជ្រាបសម្ពន្ធយ៉ាងនេះថា ភិក្ខុតែមួយរូបគប្បីសម្រេចការអង្គុយណា ក្នុងទីកំបាំង គឺ អាសនៈកំបាំងល្មមនឹងធ្វើការ ( សេព ) បានជាមួយមាតុគ្រាមម្នាក់, ព្រះមានព្រះភាគទ្រង់ហាមការសម្រេចការអង្គុយនោះ ។ ពិតមែន កាលនឹងកាន់យកសេចក្ដីដោយប្រការដទៃ គួរនឹងត្រាស់ថា ឯកស្ស ឯកាយ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះលោកពោលពាក្យថា ទ្រង់ហាមហើយ ។ម្យ៉ាងទៀត ពាក្យថា ឯកោ នេះ គប្បីជ្រាបថា ជាបឋមាវិភត្តិចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។

## អធិប្បាយស្ថានទីកំបាំងធ្វើឱ្យត្រូវអាបត្តិ

[៣៤៥] ក៏ក្នុងពាក្យថា ន ហេវ ខោ បន បដិច្ឆន្នំ : ដែលគេមិនបានបិទបាំងមែន នេះ សូម្បីស្ថានទីលោមព័ទ្ធខាងក្រៅ ខាងក្នុងបើកចំហមានបរិវេណទីធ្លាជាដើម ក៏គប្បីជ្រាបថា រួមចូលក្នុងខាងក្នុង (រាប់បញ្ចូលក្នុងស្ថានទីមិនកំបាំង) ។ លោកពោលទុកក្នុងមហាបច្ចរីយថា ស្ថានទីសូម្បីបែបនេះ រាប់បញ្ចូលក្នុងទីមិនកំបាំងតែម្យ៉ាង ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យនៃសិក្ខាបទទី ១ នុ៎ះឯង ។ ក៏ក្នុងសិក្ខាបទនេះ មានសេចក្តីប្លែកគ្នាត្រឹមតែមួយនេះថា មនុស្សដឹងក្តីម្នាក់ជាស្រីក៏ដោយ ប្រុសក៏ដោយ មិនជាមនុស្សខ្វាក់ភ្នែក និងត្រចៀកថ្លង់ឈរឬអង្គុយនៅក្នុងឱកាសខាងក្នុង១២ ហត្ថមានចិត្តរវើរវាយទៅខ្លះ គេដេកលក់ទៅខ្លះ ក៏ការពារអាបត្តិបាន ។ ចំណែកមនុស្សត្រចៀកថ្លង់សូម្បីមានភ្នែកល្អ ឬមនុស្សខ្វាក់សូម្បីត្រចៀកមិនថ្លង់ ក៏ការពារមិនបាន ។ និងព្រះមានព្រះភាគទ្រង់បន្ថយអាបត្តិបារាជិកចុះមក ពិន័យអាបត្តិព្រោះវាចាអាក្រក់គ្រោតគ្រាត ។ ពាក្យដ៏សេសដូចគ្នានឹងសិក្ខាបទមុននុ៎ះឯង ។ សូម្បីក្នុងសិក្ខាបទទាំងពីរ មិនមានអាបត្តិដល់ភិក្ខុឆ្កួត និងភិក្ខុដែលជាដើមបញ្ញត្តិ ។

ក្នុងសមុដ្ឋានជាដើម សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតអំពីកាយចិត្ត វាចាចិត្ត កាយវាចាចិត្ត ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា ២ ដោយសុខវេទនា និង ឧបេក្ខាវេទនា ។ បទដ៏សេសមានអត្ថងាយយល់ទាំងអស់ហើយ ។

នបឋមានិយតសិក្ខាបទវណ្ណនា ចប់

ចំនួនសិក្ខាបទក្នុងអនិយតកណ្ឌនោះ គឺ

១. បឋមានិយតសិក្ខាបទ អំពីការអង្គុយឬដេកជាមួយមាតុគ្រាមក្នុងទីកំបាំងភ្នែក

២. ទុតិយានិយតសិក្ខាបទ អំពីការអង្គុយឬដេកជាមួយមាតុគ្រាមក្នុងទីមិនកំបាំងភ្នែក

## អនិយតកណ្ឌ ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## សង្ឃាទិសេស១៣ អនិយត២

## ទុតិយភាគ ២

ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## និស្សគ្គិយ៣០

## តតិយភាគ ៣

# និស្សគ្គិយបាចិត្តិយកណ្ឌ

ធម៌ (គឺអាបត្តិ)ទាំង ៣០ ណា ឈ្មោះថា និស្សគ្គិយ ដែលព្រះ សម្មាសម្ពុទ្ធ ទ្រង់សម្តែងហើយ ឥឡូវនេះ ខ្ញុំព្រះករុណា នឹងធ្វើ ការពណ៌នាបទ ដែលនៅមិនធ្លាប់ មានមកមុននៃធម៌ទាំងអស់នោះ ។

## ចីវរវគ្គទី ១

### ១. កឋិនសិក្ខាបទវណ្ណនា

[១] ក្នុងពាក្យនិទានថា សម័យនោះ ព្រះសម្ពុទ្ធជាម្ចាស់ ដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងគោតមកចេតិយ ទៀបក្រុងវេសាលី ។ វេលានោះឯង ត្រៃចីវរដែលព្រះមានព្រះភាគ ទ្រង់បានអនុញ្ញាតដល់ភិក្ខុទាំងឡាយរួចស្រេចហើយ ដូច្នេះជាដើម ដែលឈ្មោះថា ត្រៃចីវរនោះ បានដល់ ចីវរ ៣ ផ្ទាំងនេះ គឺ អន្តរវាសកៈ ១ ឧត្តរាសង្គៈ ១ សង្ឃាដិ ១ ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ដើម្បីប្រើប្រាស់ ។ ក៏ចីវរ ៣ ផ្ទាំងនេះ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតក្នុងទីណា ? ទ្រង់អនុញ្ញាតកាលណា ? និងទ្រង់អនុញ្ញាតព្រោះហេតុអ្វី ? ពាក្យទាំងអស់នោះមកហើយក្នុងរឿងពេទ្យជីវកក្នុងចីវរក្ខន្ធកៈនុ៎ះឯង ។

ពាក្យថា អញ្ញោនេវ តិចីវរេន គាមំ បវិសន្តិ : ចូលទៅកាន់ស្រុក (ស្រៀកដណ្តប់)ចីវរមួយត្រៃ មានសេចក្តីថា ពួកភិក្ខុឆព្វគ្គិយ គ្រងត្រៃចីវរចូលស្រុកមួយសម្រាប់ផ្សេងដទៃពីសម្រាប់ដែលប្រើគ្រងនៅក្នុងវត្ត និងសម្រាប់ដែលប្រើគ្រងស្រង់ទឹក ។ ប្រើចីវរមួយថ្ងៃ ៩ ផ្លាំង រាល់ថ្ងៃ ដោយអាការយ៉ាងនេះ ។

[២] ពីរបទថា ឧប្បន្នំ ហោតិ : កើតឡើង មានសេចក្តីថា អតិរេកចីវរនេះ កើតឡើងឱ្យឱកាសដល់អនុប្បញ្ញត្តិ ដោយអំណាចការបាន មិនមែនដោយអំណាចសេចក្តីសម្រេច ។

## ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងព្រះអានន្ទ

ពាក្យថា អាយស្មតោ សារិបុត្តស្ស ធាតុកាមោ ហោតិ : ចង់ប្រគេនចីវរនោះទៅព្រះសារីបុត្តដ៏មានអាយុ មានសេចក្តីថា បានឮថា ព្រះអានន្ទ រមែងរាប់អានព្រះសារីបុត្ត ដោយបានឃើញគុណដ៏ច្រើនរបស់ព្រះសារីបុត្តថា វៀរព្រះមានព្រះភាគ បុគ្គលដទៃដែលមានគុណវិសេសបែបនេះ មិនមានឡើយ ។ លោកបានចីវរដែលពេញចិត្ត បោកគក់ហើយ ធ្វើពិន្ទុកប្បៈហើយ ប្រគេនដល់ព្រះថេរៈនុ៎ះឯង សូម្បីគ្រប់គ្រាដែលបានចីវរ ។ ក្នុងវេលាមុនឆាន់ កាលបានយាគូនិងរបស់ទំពា ឬបិណ្ឌបាតដ៏ប្រណីតហើយ រមែងប្រគេនដល់ព្រះថេរៈដូចគ្នា ។ ក្នុង

វេលាក្រោយឆាន់ សូម្បីបានភេសជ្ជៈ មានទឹកឃ្មុំ និងទឹកអំពៅជាដើម ក៏ប្រគេនដល់ព្រះថេរៈនុ៎ះឯង ។ នាំក្មេងទាំងឡាយចេញចាកត្រកូលឧបដ្ឋាក ឱ្យបព្វជ្ជាឱ្យកាន់ឧបជ្ឈាយ៍ ក្នុងសំណាក់ព្រះថេរៈហើយ ធ្វើអនុស្សាវនាកម្មដោយខ្លួនឯង ។ ចំណែកព្រះសារីបុត្ត ក៏រាប់អានព្រះអានន្ទយ៉ាងក្រៃលែង ដោយធ្វើក្នុងចិត្តថា ធម្មតាថា កិច្ចដែលបុត្រនឹងធ្វើដល់បិតា ជាភារៈរបស់បុត្រច្បង ; ព្រោះដូច្នោះ កិច្ចណាដែលយើងត្រូវធ្វើចំពោះព្រះមានព្រះភាគ កិច្ចទាំងអស់នោះ ព្រះអានន្ទធ្វើហើយ, យើងអាស្រ័យព្រះអានន្ទ ទើបបានដើម្បីជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ។ ពាក្យទាំងអស់ថា សូម្បីព្រះថេរៈនោះ បានចីវរដែលពេញចិត្តហើយ ក៏ប្រគេនព្រះអានន្ទត្ថេរៈដូចគ្នាជាដើម ដូចគ្នានឹងពាក្យមុននុ៎ះឯង ។ ព្រះអានន្ទត្ថេរៈរាប់អានដោយគុណជាច្រើនយ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា រមែងជាអ្នកមានសេចក្តីប្រាថ្នានឹងប្រគេនចីវរនោះ សូម្បីដែលកើតឡើងក្នុងគ្រានោះ ដល់ព្រះសារីបុត្ត ។

ក៏ក្នុងពាក្យថា នវមំ វា ភគវា ទិវសំ ទសមំ វា : បពិត្រព្រះដ៏មានព្រះភាគជាម្ចាស់ ប្រហែលជាប្រាំបួនថ្ងៃ ឬដប់ថ្ងៃទៀត នេះ បើអ្នកណា ៗ នឹងមានសេចក្តីសង្ស័យថា ព្រះថេរៈដឹងបានយ៉ាងណា ?

ឆ្លើយថា ព្រះថេរៈដឹងបានដោយហេតុច្រើនយ៉ាង ។

## ហេតុដែលព្រះអានន្ទជ្រាបការមករបស់ព្រះសារីបុត្តបាន

បានឮថា ព្រះសារីបុត្តត្ថេរ កាលនឹងត្រាច់ទៅកាន់ចារិកក្នុងជនបទច្រើនតែលាព្រះអានន្ទត្ថេរៈមុនថា "ខ្ញុំព្រះករុណានឹងមកដោយកាលឈ្មោះថា ប្រមាណប៉ុណ្ណេះ ក្នុងចន្លោះនេះ លោកកុំលះព្រះមានព្រះភាគចោលឡើយ" ដូច្នេះ ហើយទើបចៀសទៅ ។ បើសូម្បីថា លោកមិនបានលាក្នុងទីចំពោះមុខ, ក៏តែងបញ្ជូនភិក្ខុទៅលាមុនទើបទៅ ។ បើថា លោកនៅចាំវស្សាក្នុងអាវាសដទៃ, និងភិក្ខុពួកណាមកមុន លោកក៏បញ្ជូនភិក្ខុពួកនោះទៅយ៉ាងនេះថា ពួកលោកចូរថ្វាយបង្គំ ព្រះយុគលបាទរបស់ព្រះមានព្រះភាគដោយសិរសា តាមពាក្យរបស់យើង, និងចូរទូលសួរដល់សេចក្តីមិនមានរោគរបស់ព្រះអានន្ទ ហើយប្រាប់ថា "យើងនឹងមកក្នុងថ្ងៃឈ្មោះឯណោះ" ឯព្រះថេរៈ រមែងមកក្នុងថ្ងៃដែលលោកកំណត់ទុកហើយនុ៎ះឯងជានិច្ច ។

ម្យ៉ាងទៀត ព្រះអានន្ទ រមែងជ្រាបបានដោយការអនុមាន (ការពិចារណា)ខ្លះ រមែងជ្រាបបានដោយន័យនេះខ្លះថា "ព្រះសារីបុត្ត កាលអត់ធន់ចំពោះសេចក្តីវិយោគ(ព្រាត់ប្រាស់) អំពីព្រះមានព្រះភាគនៅអស់ថ្ងៃមានប្រមាណប៉ុណ្ណេះ, ឥឡូវនេះ រាប់ពីនេះទៅ នឹងមិនហួសពីថ្ងៃឈ្មោះឯណោះ, លោកនឹងមកពិតប្រាកដ" ពិតមែន ជនទាំងឡាយអ្នក

ដែលមានបញ្ញាច្រើន រមែងមានសេចក្តីស្រឡាញ់ និងសេចក្តីគោរពក្នុងព្រះមានព្រះភាគច្រើន ដូច្នេះ ។ ព្រះថេរៈ រមែងជ្រាបបានដោយហេតុច្រើនយ៉ាង ដោយប្រការយ៉ាងនេះ ។ ព្រោះហេតុនោះ លោកទើបក្រាបទូលថា “បពិត្រព្រះមានព្រះភាគ ប្រហែលជាប្រាំបួនថ្ងៃ ឬដប់ថ្ងៃទៀត ( លោកនឹងនិមន្តមកដល់ )” ដូច្នេះ កាលព្រះអានន្ទត្ថេរៈក្រាបទូលយ៉ាងនេះហើយ ព្រោះសិក្ខាបទនេះ មានទោសមកព្រះបញ្ញត្តិ មិនមែន មានទោសមកលោក; ព្រោះហេតុនោះ គ្រានោះឯង ព្រះមានព្រះភាគ កាលនឹងទ្រង់ធ្វើថ្ងៃដែលព្រះអានន្ទក្រាបទូលនុ៎ះឯង ឱ្យជាកំណត់ ទើបទ្រង់បញ្ញត្តិសិក្ខាបទថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឱ្យអ្នករាល់គ្នាទុកអតិរេកចីវរ កំណត់ត្រឹមដប់ថ្ងៃ” ដូច្នេះ ។ ប្រសិនបើថា ព្រះថេរៈនេះ នឹងទូលសម្តែងឡើងកន្លះខែ ឬមួយខែ, សូម្បីកន្លះខែ ឬមួយខែនោះ ព្រះមានព្រះភាគ ក៏ទ្រង់អនុញ្ញាតដែរ ។

## ពន្យល់អត្ថក្នុងសិក្ខាបទវិភង្គការដោះកឋិន

[៣] បទថា **និដ្ឋិតចីវរស្មឹ** : កាលចីវរសម្រេចហើយ បានដល់ កាលចីវរសម្រេចហើយ ដោយការសម្រេចយ៉ាងណាមួយ ។ ក៏ព្រោះចីវរនេះ រមែងជាការសម្រេចហើយ ដោយការធ្វើខ្លះ ដោយហេតុ

មានការវិនាសអស់ជាដើមខ្លះ ; ដូច្នោះ ដើម្បីទ្រង់សម្តែងត្រឹមតែអត្ថប៉ុណ្ណោះ ក្នុងបទភាជនៈនៃបទថា និដ្ឋិតចីវរស្មឹ នោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យមានជាដើមថា ភិក្ខុនា ចីវរំ កតំ វា ហោតិ : ចីវរដែលភិក្ខុបានធ្វើរួចហើយក្តី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា កតំ : ធ្វើរួចហើយ គឺ ដែលភិក្ខុធ្វើហើយដោយកម្មមានសូចិកម្មជាទីបំផុត ។ ដែលឈ្មោះថា កម្មមានសូចិកម្មជាទីបំផុត បានដល់ ការធ្វើកម្មដែលគួរធ្វើដោយម្ជុលយ៉ាងណាមួយ មានការភ្ជាប់អន្ទាក់និងក្តុំជាទីបំផុត ហើយក៏រក្សាម្ជុលទុក (ក្នុងបំពង់ម្ជុល) ។

បទថា នដ្ឋំ : បាត់ គឺ ត្រូវពួកចោរជាដើមលួចយកទៅ ។ ពិតមែន សូម្បីចីវរនោះ លោកហៅថា សម្រេចហើយ ក៏ព្រោះសេចក្តីកន្លង ដោយការធ្វើនុ៎ះឯង សម្រេចហើយ ។

បទថា វិនដ្ឋំ : វិនាស គឺ ត្រូវពួកសត្វមានកណ្តៀរជាដើមកាត់ស៊ីហើយ ។

បទថា ទឌ្ឍំ : ឆេះ គឺ ត្រូវភ្លើងឆេះ ។

ពីរបទថា ចីវរាសា វា ឧបច្ឆិន្នា : សេចក្តីប្រាថ្នាក្នុងចីវរដាច់ស្រឡះក្តី មានសេចក្តីថា អស់សេចក្តីប្រាថ្នាក្នុងចីវរដែលកើតឡើងថា

យើងនឹងបានចីវរ ក្នុងត្រកូលឈ្មោះឯណោះក្តី ។ ពិតមែន គួរជ្រាបសេចក្តីដែលចីវរ សូម្បីទាំងនេះសម្រេចហើយ ព្រោះសេចក្តីកង្វល់ដោយការធ្វើនុ៎ះឯង សម្រេចហើយ ។

ពីរបទថា ឧព្ភតស្មឹ កឋិនេ : កឋិនដោះហើយ គឺ (កាលចីវរសម្រេចហើយ) និងកាលកឋិនដោះហើយ ។ ដោយបទថា ឧព្ភតស្មឹ កឋិនេ នេះ ព្រះមានព្រះភាគទ្រង់សម្តែងនូវការមិនមាននៃបលិពោធទី ២, ក៏កឋិននោះ ដែលភិក្ខុទាំងឡាយ រមែងដោះដោយមាតិកាមួយយ៉ាង ក្នុងបណ្តាមាតិកា ៨ ឬដោយការដោះក្នុងចន្លោះ; ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា អដ្ឋន្នំ មាតិកានំ : កឋិនដែលដោះដោយបណ្តាមាតិកា ៨ យ៉ាងជាដើម ក្នុងនិទ្ទេសនៃបទថា ឧព្ភតស្មឹ កឋិនេ នោះ ។

បណ្តាមាតិកា និងការដោះក្នុងចន្លោះនោះ មាតិកា(១) ៨ មកហើយក្នុងកឋិនក្ខន្ធកៈ យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ មាតិកានៃការដោះកឋិនទាំង ៨ ប្រការនេះ គឺ បក្កមនន្តិកា មានការចៀសចេញទៅជាកំណត់១ និដ្ឋានន្តិកា មានការធ្វើចីវរសម្រេចជាកំណត់១ សន្និដ្ឋានន្តិកា មានសេចក្តីសន្និដ្ឋានជាកំណត់១ នាសនន្តិកា មានចីវរ

១. វិន. មហា. ចីវរក្ខន្ធកៈ. ៨. ៥/៨ ។

វិនាសទៅជាកំណត់១ សវនន្តិកា មានការឮដំណឹងជាកំណត់១ អាសាវច្ឆេទិកា អស់សេចក្តីសង្ឃឹម១ សីមាតិក្កន្តិកា មានការកន្លងខេត្តកឋិនជាកំណត់១ សហុព្ភារា សង្ឃព្រមព្រៀងគ្នាដោះកឋិន១”[១] ។

សូម្បីការដោះកឋិនក្នុងចន្លោះ ក៏មកក្នុងភិក្ខុនីវិភង្គ[២] យ៉ាង នេះថា សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ កឋិនំ ឧទ្ធរេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ កឋិនំ ឧទ្ធរតិ ។ យស្សាយស្មតោ ខមតិ កឋិនស្ស ឧព្ភារោ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ឧព្ភតំ សង្ឃេន កឋិនំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ : បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ, បើការដកកឋិននេះ មានកាលដ៏សមគួរដល់សង្ឃហើយ, សង្ឃត្រូវដកនូវកឋិន ។ នេះជាវាចាប្រកាសសង្ឃឱ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ, ឥឡូវនេះ សង្ឃដកកឋិនចេញ ។ ការដកកឋិនគួរ ដល់លោកដ៏មានអាយុអង្គណា ត្រូវលោកដ៏មានអាយុអង្គនោះ នៅស្ងៀម, មិនគួរដល់លោកដ៏មានអាយុអង្គណា ត្រូវលោកដ៏មានអាយុអង្គនោះពោលឡើង,

១. វិន. ភិក្ខុនី. នគ្គវគ្គ. ៥. ២៥៣/២៣១ ។

កឋិនសង្ឃបានដកហើយ ការដកកឋិនសមគួរដល់សង្ឃ ហេតុនោះ ទើបសង្ឃនៅស្ងៀម ខ្ញុំសូមចាំទុកនូវកម្មនេះ ដោយអាការនៅស្ងៀមយ៉ាងនេះ ។

ខ្ញុំព្រះករុណានឹងពណ៌នាពាក្យដែលគួរពោលក្នុងមាតិកា និងអន្តវុត្តាភនោះទាំងអស់ ក្នុងអាគតដ្ឋាន[1]នុ៎ះឯង, តែកាលនឹងពោលក្នុងទីនេះ បាលីដែលគួរនឹងនាំមកក្ដី សេចក្ដីដែលគួរនឹងពោលក្ដី សូម្បីពោលហើយ តែក៏ជារឿងដែលមិនងាយដឹងបាន ព្រោះពោលទុកក្នុងឋានៈដែលមិនគួរ ។

បទថា ទសាហបរមំ : កំណត់ត្រឹមដប់ថ្ងៃ មានវិគ្រោះថា ១០ ថ្ងៃ ជាកំណត់យ៉ាងក្រៃលែងនៃកាលនោះ ; ព្រោះហេតុនោះ កាលនោះទើបឈ្មោះថា មាន ១០ ថ្ងៃជាយ៉ាងក្រៃលែង ។ អធិប្បាយថា ចីវរនោះ ដែលភិក្ខុគប្បីទ្រទ្រង់ទុក រហូតដល់អស់កាលមាន ១០ ថ្ងៃជាយ៉ាងក្រៃលែង ។ តែដើម្បីទ្រទ្រង់សម្ដែងតែអត្ថប៉ុណ្ណោះ ក្នុងបទភាជនៈ ទើបព្រះមានព្រះភាគត្រាស់ថា គប្បីទ្រទ្រង់ ទុកបាន ១០ ថ្ងៃជាយ៉ាងក្រៃលែង, ពិតមែន មានពាក្យអធិប្បាយថា ភាពនៃកាល មាន ១០ ថ្ងៃជាយ៉ាងក្រៃលែង ដែលត្រាស់ទុកក្នុងបទថា ទសាហបរមំ នេះភាវៈ នៃកាលៈមាន ១០ ថ្ងៃជាយ៉ាងក្រៃលែងនោះ មានសេចក្ដីដូច្នេះថា គប្បី

១. សមន្ត. មហា. កឋិនក្ខន្ធកវណ្ណនា. ៥. ៥/៣៩៩ ។

ទ្រង់ទុកបានរយៈកាលប្រមាណប៉ុណ្ណោះដែលនៅមិនកន្លងទៅ ។ ចីវរដែលឈ្មោះថា អតិរេក ព្រោះមិនរាប់បញ្ចូលក្នុងពួកចីវរដែលអធិដ្ឋាន និងវិកប្បទុក ; ព្រោះហេតុនោះ ទើបឈ្មោះថា អតិរេកចីវរ ។ ព្រោះហេតុនោះ ក្នុងបទភាជនៈនៃបទថា **អតិរេកចីវរំ** នោះ ទើបត្រាស់ថា ចីវរដែលមិនបានអធិដ្ឋាន និងមិនបានវិកប្បទុក ។

## អធិប្បាយកំណើតចីវរ ៦ ប្រភេទ

ពាក្យថា ឆន្នំ ចីវរានំ អញ្ញតរំ : បណ្ដាចីវរទាំង ៦ ចីវរណាមួយ មានសេចក្ដីថា បណ្ដាចីវរ ៦ យ៉ាង គឺ **ខោមំ** ចីវរដែលធ្វើដោយសម្បកឈើ ១ **កប្បាសិកំ** ចីវរដែលធ្វើដោយកប្បាស ១ **កោសេយ្យំ** ចីវរដែលធ្វើដោយសូត្រ ១ **កម្ពលំ** ចីវរដែលធ្វើដោយរោមសត្វ (វៀរលែងតែសក់និងរោមមនុស្សចេញ) ១ **សាណំ** ចីវរដែលធ្វើដោយសម្បកធ្មៃ ១ **ភង្គំ** ចីវរដែលធ្វើលាយដោយវត្ថុប្រាំយ៉ាងខាងដើម ១[១] ចីវរយ៉ាងណាមួយ ។ ព្រះមានព្រះភាគកាលទ្រង់សម្ដែងកំណើតនៃចីវរដោយពាក្យថា ឆន្នំ ជាដើមនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងខ្នាត (នៃចីវរនោះ) ទើបត្រាស់ថា "វិកប្បនុបគំ បច្ឆិមំ : (ចីវរ)

១. វិន. មហា. ចីវរក្ខន្ធកៈ. ៨. ៤៥/១០១ ។

ដែលតូចបំផុតគួរល្មមភិក្ខុវិកប្បបាន” ដូច្នេះ ។ ខាតនៃចីវរនោះ ផ្នែកបណ្ដោយ ២ ចំអាម ផ្នែកទទឹង ១ ចំអាម ។ ក្នុងខាតនៃចីវរនោះ មានព្រះបាលីដូច្នេះថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុវិកប្បចីវរយ៉ាងតូចបំផុត បណ្ដោយត្រឹម ៨ ធ្នាប់ ទទឹងត្រឹម ៤ ធ្នាប់ ដោយធ្នាប់ព្រះសុគត”(១) ។

ពាក្យថា តំ អតិក្កាមយតោ និស្សគ្គិយំ បាចិត្តិយំ : បើឱ្យកន្លងហួសពីរដប់ថ្ងៃនោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ មានសេចក្ដីថា កាលភិក្ខុញ៉ាំងចីវរមានកំណើត និងប្រមាណតាមដែលពោលហើយនោះឱ្យកន្លងកាលមាន ១០ ថ្ងៃជាយ៉ាងក្រៃលែង គឺ កាលមិនធ្វើដោយវិធីដែលទឹងមិនជាអតិរេកចីវរចេញ ក្នុងចន្លោះកាលមាន ១០ ថ្ងៃជាយ៉ាងក្រៃលែងនេះ ជានិស្សគ្គិយ បាចិត្តិយ ។ អធិប្បាយថា ចីវរនោះ ជានិស្សគ្គិយផង ត្រូវអាបត្តិបាចិត្តិយដល់ភិក្ខុនោះផង ។ម្យ៉ាងទៀត ការលះបង់ចេញ ឈ្មោះថា និស្សគ្គិយ ។ ពាក្យថា និស្សគ្គិយនោះ ជាឈ្មោះរបស់វិន័យកម្មដែលភិក្ខុគប្បីធ្វើ ក្នុងកាលជាចំណែកខាងដើម, ការលះបង់ចេញ មានដល់ធម្មជាតិនោះ ; ហេតុនោះ ធម្មជាតិនោះទើបឈ្មោះថា និស្សគ្គិយ ដូច្នេះឯង ។ និស្សគ្គិយនោះ គឺ អ្វី ? គឺ

១. វិន. មហា. ចីវរក្ខន្ធកៈ. ៨. ៦៦/១៤៣ ។

បាចិត្តិយ ។ ក្នុងពាក្យថា **តំ អតិក្កាមយតោ និស្សគ្គិយំ បាចិត្តិយំ** នេះ មានសេចក្តីដូច្នេះថា ត្រូវអាបត្តិបាចិត្តិយ មានការលះបង់ចេញ ជាវិន័យកម្មដល់ភិក្ខុដែលឱ្យកន្លងកាលនោះទៅ ។

តែក្នុងបទភាជនៈ ដើម្បីទ្រង់សម្តែងអត្ថវិកប្បជំបូងមុន ទើបព្រះមានព្រះភាគទ្រង់តាំងមាតិកាថា "បើឱ្យកន្លងហួសពីដប់ថ្ងៃនោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ" ហើយត្រាស់ពាក្យថា "កាលបើអរុណរះឡើងក្នុងថ្ងៃទី ១១ (ឡើងទៅ) ភិក្ខុត្រូវលះចេញ" ដូច្នេះ ។ ក៏ចីវរនោះ ដែលភិក្ខុគប្បីលះបង់ដល់បុគ្គលណា គប្បីលះចេញដោយវិធីយ៉ាងណា ដើម្បីទ្រង់សម្តែងបុគ្គល និងវិធីលះបង់នោះទៀត ទើបត្រាស់ពាក្យជាដើមថា សង្ឃស្ស វា ដូច្នេះ ។

បណ្តាបទទាំងនោះ ក្នុងពាក្យថា **ឯកាទសេ អរុណុគ្គមនេ : អរុណរះឡើងក្នុងថ្ងៃទី១១** នេះ អ្នកសិក្សាគប្បីជ្រាបថា ចីវរកើតឡើងក្នុងថ្ងៃណា អរុណនៃថ្ងៃនោះ អាស្រ័យថ្ងៃដែលចីវរកើតឡើង; ព្រោះហេតុនោះ ទើបជានិស្សគ្គិយ ក្នុងកាលអរុណថ្ងៃទី ១១ រះឡើងរួមទាំងថ្ងៃដែលចីវរកើត សូម្បីបើថា ចីវរជាច្រើនចង ឬបត់រួមគ្នារក្សាទុក ក៏ត្រូវអាបត្តិ ត្រឹមតែមួយ ។ ក្នុងចីវរដែលបត់ទុកមិនរួមគ្នា ត្រូវអាបត្តិ

ច្រើន តាមចំនួននៃវត្ថុ ។

## អធិប្បាយវិធីលះបង់ចេញ និងវិធីសម្តែងអាបត្តិ

[៤] ពាក្យថា និស្សជ្ជិត្វា អាបត្តិ ទេសេតព្វា : លុះ(ភិក្ខុនោះ)លះរួចហើយ ត្រូវសម្តែងអាបត្តិចេញ មានសេចក្តីថា សួរថា គប្បីសម្តែងអាបត្តិយ៉ាងណា ?

ឆ្លើយថា គប្បីសម្តែងដូចដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងខន្ធកៈ ។

សួរថា តើទ្រង់ត្រាស់ទុកក្នុងខន្ធកៈនោះ យ៉ាងណា ?

ឆ្លើយថា ទ្រង់ត្រាស់ទុកយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយក្រាបសំពះបាទាភិក្ខុចាស់ទាំងឡាយ អង្គុយច្រហោងផ្គងអញ្ជលី ពោលនឹងសង្ឃយ៉ាងនេះថា **អហំ ភន្តេ ឥត្ថន្នាមំ អាបត្តឹ អាបន្នោ តំ បដិទេសេមិ** : បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណា ត្រូវអាបត្តិឈ្មោះនេះហើយ សូមសម្តែងនូវអាបត្តិនោះចេញ"[១] ។

ក៏ក្នុងអធិការនេះ បើចីវរមានតែមួយផ្ទាំង គប្បីពោលថា **ឯកំ និស្សគ្គិយំ បាចិត្តិយំ** ... (ត្រូវហើយ) នូវនិស្សគ្គិយបាចិត្តិយមួយ ។

១. វិន. ចុល្ល. សមថក្ខន្ធក. ១០. ១០៦/១១៤-៥ ។

បើចីវរ ២ ផ្ទាំងគប្បីពោលថា ទ្វេ ... នូវអាបត្តិ ២ ។ បើចីវរច្រើនផ្ទាំង គប្បីពោលថា សម្ពហុលា[1] ... នូវអាបត្តិច្រើន ។ សូម្បីក្នុងការលះបង់ចេញ បើថាចីវរមានតែមួយផ្ទាំង គប្បីពោលតាមសមគួរដល់បាលីនុ៎ះឯងថា "ឥទំ មេ ភន្តេ ចីវរំ : លោកម្ចាស់ ចីវររបស់ខ្ញុំព្រះករុណាផ្ទាំងនេះ"ជាដើម ។ ប្រសិនបើថា មានចីវរ ២ ផ្ទាំង ឬច្រើនផ្ទាំង គប្បីពោលថា ឥមានិ មេ ភន្តេ ចីវរានិ ទសាហាតិក្កន្តានិ និស្សគ្គិយានិ ឥមានាហំ សង្ឃស្ស និស្សជ្ជាមិ : បពិត្រព្រះសង្ឃដ៏ចម្រើន ចីវររបស់ខ្ញុំព្រះករុណាទាំងនេះ កន្លង ១០ ថ្ងៃ ជានិស្សគ្គិយ, ខ្ញុំព្រះករុណា សូមលះបង់ចីវរទាំងនេះដល់សង្ឃ ។ កាលមិនអាចនឹងពោលបាលីបាន គប្បីពោលដោយភាសាដទៃក៏បាន ។ ភិក្ខុគប្បីទទួលអាបត្តិ ដោយន័យដូចពោលទុកក្នុងខន្ធកៈនុ៎ះឯងថា ភិក្ខុអ្នកឈ្លាសគប្បីទទួលអាបត្តិ ។ សមពិត ដូចដែលត្រាស់ទុកក្នុងខន្ធកៈនោះយ៉ាងនេះថា "ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ នឹកឃើញនូវអាបត្តិ បង្ហើបអាបត្តិ ធ្វើអាបត្តិឱ្យងាយ សម្តែងអាបត្តិ, បើកម្មមានកាលគួរដល់សង្ឃ ហើយ, ខ្ញុំ

១. ភូមា. សម្ពហុលានិ ។

ត្រូវទទួលនូវអាបត្តិរបស់ភិក្ខុឈ្មោះនេះ”(១) ដូច្នេះ ។

ភិក្ខុអ្នកទទួលអាបត្តិនោះ ត្រូវសួរថា បស្សសិ លោកឃើញឬទេ ។

ភិក្ខុអ្នកសម្តែងនោះត្រូវឆ្លើយថា : អាម បស្សាមិ ករុណា ខ្ញុំឃើញ ។

ភិក្ខុអ្នកទទួលត្រូវប្រាប់ថា : អាយតឹ សំវរេយ្យាសិ លោកត្រូវសង្រួមតទៅទៀតចុះ ។[២]

ភិក្ខុអ្នកសម្តែងត្រេកអរថា : សាធុ សុដ្ឋុ សំវរិស្សាមិ : ល្អណាស់ ខ្ញុំព្រះករុណា នឹងសង្រួមដោយល្អ ។[៣]

ក៏បើអាបត្តិ ២ ឬច្រើន អ្នកសិក្សាគប្បីជ្រាបសេចក្តីផ្សេងគ្នានៃវចនៈដោយន័យមុនន៏ុះឯង, សូម្បីក្នុងការឱ្យចីវរ (ត្រឡប់មកវិញ) ក៏គប្បីជ្រាបសេចក្តីផ្សេងគ្នានៃវចនៈ ដោយអំណាចនៃវត្ថុ គឺ សចេ្ឆ ឥមំ ចីវរំ ឥមានិ ចីវរានិ ... សង្ឃគប្បីឱ្យចីវរផ្ទាំងនេះ ... គប្បីឱ្យចីវរផ្ទាំងទាំងឡាយនេះ ... ។ សូម្បីក្នុងការលះបង់ដល់គណៈ និងដល់បុគ្គល ក៏មានន័យយ៉ាងនេះដូចគ្នា ។

១.២. វិន. ចុល្ល. សមថក្ខន្ធក. ១០. ១០៦/១១៤-៥ ។    ៣. សមន្ត. មហា.

ឧបោសថក្ខន្ធកវណ្ណនា ៥. ១៨៦/២៦៩ ។

[៥] ក៏ការសម្តែងនិងការទទួលអាបត្តិ ក្នុងអធិការនេះ មានបាលីដូចតទៅនេះ "តេន ភិក្ខវេ ភិក្ខុនា សម្ពហុលេ ភិក្ខូ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយា អហំ ភន្តេ ឥត្ថន្នាមំ អាបត្តឹ អាបន្នោ តំ បដិទេសេមិ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ត្រូវចូលទៅរកភិក្ខុច្រើនរូប ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ក្រាបសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលី គប្បីពោលយ៉ាងនេះនឹងភិក្ខុទាំងនោះថា បពិត្រលោកទាំងឡាយដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវអាបត្តិឈ្មោះនេះហើយ សូមសម្តែងនូវអាបត្តិនោះចេញ ។ ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវផ្តៀងភិក្ខុទាំងនោះថា សុណន្តុ[១] មេ អាយស្មន្តា អយំ ឥត្ថន្នាមោ ភិក្ខុ អាបត្តឹ សរតិ វិវរតិ ឧត្តានីករោតិ ទេសេតិ ។ យទាយស្មន្តានំ បត្តកល្លំ អហំ ឥត្ថន្នាមស្ស ភិក្ខុនោ អាបត្តឹ បដិគ្គណ្ហេយ្យំ : លោកមានអាយុទាំងឡាយ ចូរស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ នេះនឹកឃើញអាបត្តិ បង្ហើបអាបត្តិ ធ្វើអាបត្តិឱ្យងាយ សម្តែងអាបត្តិ ។ បើកម្មមានកាលដ៏សមគួរដល់លោកមានអាយុទាំងឡាយហើយ, ខ្ញុំគប្បីទទួលអាបត្តិរបស់ភិក្ខុឈ្មោះនេះ" ។

១. ថៃ. សុណាតុ ។

ភិក្ខុអ្នកទទួលនោះ ត្រូវពោលថា បស្សសិ លោកឃើញឬទេ ។ ភិក្ខុ (អ្នកសម្តែង)ត្រូវពោលថា អាម បស្សាមិ : ករុណា ខ្ញុំឃើញ ។ ភិក្ខុអ្នកទទួលត្រូវប្រាប់ថា អាយតឹ សំវរេយ្យាសិ : លោកត្រូវសង្រួមតទៅ ។[១]

ភិក្ខុអ្នកសម្តែងត្រេកអរថា សាធុ សុដ្ឋុ សំវរិស្សាមិ : ល្អណាស់ ខ្ញុំព្រះករុណា នឹងសង្រួមដោយល្អ ។[១]

[៦] ភិក្ខុនោះ គប្បីចូលទៅរកភិក្ខុ ១ រូប ហើយធ្វើចីវរឆៀងស្មាម្ខាង អង្គុយប្រហោង ផ្គងអញ្ជលីឡើងហើយពោលយ៉ាងនេះនឹងភិក្ខុនោះថា “អហំ អាវុសោ ឥត្ថន្នាមំ អាបត្តឹ អាបន្នោ តំ បដិទេសេមិ : ម្នាលលោកមានអាយុ ខ្ញុំត្រូវអាបត្តិឈ្មោះនេះហើយ, សូមសម្តែងអាបត្តិនោះចេញ” ។ ភិក្ខុអ្នកទទួលអាបត្តិនោះ ត្រូវពោលថា “បស្សសិ : លោកឃើញឬទេ” ។ ភិក្ខុអ្នកសម្តែង ត្រូវឆ្លើយថា “អាម បស្សាមិ : ករុណា ខ្ញុំឃើញហើយ” ។ អ្នកទទួល ត្រូវប្រាប់ថា “អាយតឹ សំវរេយ្យាសិ : លោកត្រូវសង្រួមតទៅទៀត” ។[៣]

ក្នុងវិស័យនៃការសម្តែងនិងទទួលអាបត្តិនោះ អ្នកសិក្សាគប្បីជ្រាប

១. វិន. ចុល្ល. សមថក្ខន្ធកៈ. ១០. ១០៦/១១៣ ។   ២. សមន្ត. មហា. ឧបោសថ

ក្ខន្ធកវណ្ណនា. ៥. ១៨៦/២៦៩ ។ ៣. វិន. ចុល្ល. សមថក្ខន្ធក. ១០. ១០៦/១១២ ។ ការបញ្ចូលឈ្មោះអាបត្តិនិងសេចក្តីផ្សេងនៃវចនៈ ដោយន័យមុននុ៎ះឯង ។ និងគប្បីជ្រាបបាលីសូម្បីក្នុងការលះបង់ដល់ភិក្ខុ២រូប ដូចក្នុងការលះបង់ដល់គណៈដូច្នោះ ។ ក៏បើថា គប្បីមានសេចក្តីប្លែកគ្នាសោត, ព្រះមានព្រះភាគគប្បីត្រាស់បាលីទុក មួយផ្នែកសូម្បីក្នុងការលះបង់ដល់ភិក្ខុ២ រូបនេះ ដូចដែលព្រះអង្គត្រាស់បារិសុទ្ធិឧបោសថដល់ភិក្ខុ៣រូបថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុបីរូប ធ្វើបារិសុទ្ធិឧបោសថដល់គ្នានិងគ្នា ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯបារិសុទ្ធិឧបោសថនោះ ត្រូវភិក្ខុធ្វើយ៉ាងនេះ ។ ត្រូវភិក្ខុដែលឆ្លាសឱ្យភិក្ខុទាំងឡាយនោះដឹង”[១] ។ ហើយត្រាស់បារិសុទ្ធិឧបោសថដល់ភិក្ខុ ២ រូប មួយផ្នែកផ្សេងទៀត ដោយន័យជាដើមថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុពីររូបធ្វើបារិសុទ្ធិឧបោសថបាន ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯឧបោសថនោះ ត្រូវភិក្ខុទាំងឡាយធ្វើយ៉ាងនេះ ។ ត្រូវភិក្ខុថេរៈធ្វើឧត្តរាសង្គឆៀងស្មាម្ខាង”[២] ដូច្នេះ ។ ក៏ព្រោះមិនមានសេចក្តីប្លែកគ្នា; ដូច្នោះ ទើបព្រះមានព្រះភាគមិនបានត្រាស់ទុក ទ្រង់រំលងចោលទៅ ព្រោះដូច្នោះ បាលីក្នុងការលះបង់ដល់ភិក្ខុ ២ រូបនេះ ជាបាលីដែលត្រាស់ទុកដល់គណៈដូចគ្នា ។

---

១. វិន. មហា. ឧបោសថក្ខន្ធក. ៦. ១៨៥/៤០០ ។ ២. វិន. មហា. ឧបោសថក្ខន្ធក. ៦. ១៨៥/៤០១ ។

ចំណែកក្នុងការទទួលអាបត្តិមានសេចក្តីប្លែកគ្នាដូច្នេះ ៖

បណ្តាភិក្ខុ ២ រូប ភិក្ខុណាមួយ កុំតាំងញត្តិ ដូចភិក្ខុដែលទទួលអាបត្តិ តាំងញត្តិក្នុងកាលភិក្ខុដែលត្រូវអាបត្តិលះបង់ដល់គណៈ ហើយសម្តែងអាបត្តិ គប្បីទទួលអាបត្តិដូចគ្នា នឹងបុគ្គលម្នាក់ទទួលដូច្នោះ ។ ពិតមែន ឈ្មោះថា ការតាំងញត្តិសម្រាប់ភិក្ខុ ២ រូប រមែងមិនមាន ។ ក៏ប្រសិនបើនឹងមាន, ព្រះមានព្រះភាគនឹងមិនគប្បីត្រាស់បារិសុទ្ធិឧបោសថទុកមួយផ្នែក សម្រាប់ភិក្ខុ ២ រូប សូម្បីក្នុងការឱ្យចីវរដែលលះបង់ហើយ នឹងពោលថា "ឥមំ ចីវរំ អយស្មតោ ទេម : ពួកខ្ញុំព្រះករុណា ឱ្យផ្ទាំងនេះដល់លោក" ដូចភិក្ខុតែមួយរូបពោលថា "ឥមំ ចីវរំ អាយស្មតោ ទម្មិ : ខ្ញុំព្រះករុណាឱ្យចីវរផ្ទាំងនេះដល់លោក" ដូច្នេះ ក៏គួរ ។ ពិតមែន សូម្បីញត្តិទុតិយកម្ម ដែលធ្ងន់ជាងនេះ ត្រាស់ថា គួរអបលោកន៍ធ្វើ ក៏មាន ។ វិន័យកម្មមានការលះបង់នេះ សមគួរដល់ញត្តិទុតិយកម្មទាំងអស់នោះ ។ តែចីវរដែលលះបង់ហើយ គួរឱ្យវិញតែម្តង, នឹងមិនឱ្យមិនបាន ។ ក៏ការឱ្យចីវរដែលលះបង់ចេញហើយនេះ ត្រឹមតែជាវិន័យកម្ម ។ ចីវរនោះ ក៏មិន ឈ្មោះថា ភិក្ខុនោះបានឱ្យដល់សង្ឃ ឬដល់គណៈ ឬដល់បុគ្គលឡើយ ទាំងនោះឯង ។

## ពន្យល់អត្ថក្នុងបទភាជនីអតិរេកចីវរកន្លង ១០ ថ្ងៃជាដើម

[៧] ពាក្យថា ទសាហាតិក្កន្តេ អតិក្កន្តសញ្ញី : កន្លងហួសដប់ថ្ងៃហើយ ភិក្ខុដឹងច្បាស់ថា កន្លង បានដល់ អ្នកមានការសម្គាល់ក្នុងចីវរដែលកន្លង ១០ ថ្ងៃហើយយ៉ាងនេះថា ចីវរនេះកន្លង (១០ ថ្ងៃ) ហើយ ។ ម្យ៉ាងទៀត សេចក្តីថា កាល ១០ ថ្ងៃកន្លងហើយ មានការសម្គាល់យ៉ាងនេះថា ១០ ថ្ងៃកន្លងទៅហើយ ។

ពាក្យថា និស្សគ្គិយំ ធាចិត្តិយំ មានសេចក្តីថា ការសម្គាល់ដែលពោលទុកក្នុងបទថា អតិក្កន្តសញ្ញី នេះការពារអាបត្តិមិនបាន, ដល់ភិក្ខុណាដែលមានការសម្គាល់យ៉ាងនេះ, ចីវរនោះ របស់ភិក្ខុសូម្បីនោះ ក៏ជានិស្សគ្គិយ និងភិក្ខុនោះ ក៏ត្រូវអាបត្តិបាចិត្តិយផង, ឬត្រូវអាបត្តិបាចិត្តិយ មានការលះបង់ចេញ ជាវិន័យកម្ម; ព្រោះដូច្នោះ អត្ថវិកប្បទាំង ២ រមែងត្រឹមត្រូវ ។ គ្រប់ ៗ បទក៏មានន័យដូច្នេះ ។

ពាក្យថា អវិស្សជ្ជិតេ វិស្សជ្ជិតសញ្ញី : ដែលភិក្ខុមិនទាន់បានលះ ហើយភិក្ខុសំគាល់ថា បានលះ បានដល់ អ្នកមានការសម្គាល់ក្នុងចីវរដែលខ្លួនមិនបានឱ្យវិញ មិនបានលះបង់ឱ្យដល់អ្នកណា ៗ យ៉ាងនេះថា យើងលះបង់ហើយ ។

ពាក្យថា អនដ្ឋេ នដ្ឋសញ្ញី : មិនទាន់បាត់ទេ ហើយភិក្ខុ

សំគាល់ថា បាត់ មានសេចក្ដីថា ចោរទាំងឡាយ រមែងលួចយកនូវចីវរជាច្រើនរបស់ភិក្ខុពួកដទៃដែលរក្សាទុករួម នឹងចីវររបស់ខ្លួន, បណ្ដាភិក្ខុទាំងនោះ ភិក្ខុរូបនេះ ជាអ្នកមានការសម្គាល់ក្នុងចីវររបស់ខ្លួនដែលមិនបានបាត់ទៅថា "បាត់ហើយ" ។ សូម្បីក្នុងចីវរដែលមិនបានវិនាសជាដើម ក៏មានន័យ ដូច្នេះ ។

ក៏ក្នុងបទថា អវិលុត្តេ : ចោរឥតបានប្លន់យកទេ នេះ គប្បីជ្រាបសន្និដ្ឋានថា ក្នុងចីវរដែលចោរមិនបានប្លន់យកទៅ ដោយអំណាចដែលទម្លាយបន្ទប់ហើយគម្រាមកំហែងប្លន់យកទៅ ។

ពាក្យថា អនិស្សជ្ជិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស : ភិក្ខុមិនបានលះ ហើយយកមកប្រើប្រាស់ ត្រូវអាបត្តិទុក្កដ មានសេចក្ដីថា ភិក្ខុមិនដោះចីវរដែលស្លៀកម្ដង ឬដណ្ដប់ម្ដងចេញចាកកាយហើយត្រាច់ទៅ សូម្បីរហូតដល់អស់មួយថ្ងៃ ជាអាបត្តិតែមួយប៉ុណ្ណោះ ។ ភិក្ខុដោះចេញហើយស្លៀក ឬដណ្ដប់ចីវរដែលនៅមិនលះបង់នោះ ត្រូវអាបត្តិទុក្កដ គ្រប់ ៗ ប្រយោគ ។ ចាត់ចីវរដែលស្លៀកមិនរៀបរយ ឬដណ្ដប់មិនរៀបរយឱ្យរៀបរយ មិនមានអាបត្តិ ។ មិនមានអាបត្តិដល់ភិក្ខុដែលប្រើប្រាស់ របស់ភិក្ខុដទៃ ។ ក៏ពាក្យមានជាដើមថា ភិក្ខុបានចីវរដែលអ្នកដទៃធ្វើហើយប្រើប្រាស់ដូច្នេះ ជាគ្រឿងសាធកក្នុងការមិនមានអាបត្តិ

នេះ ។ ទ្រង់សំដៅយកការប្រើប្រាស់ ពិន័យត្រូវអាបត្តិទុក្កដ ដល់ភិក្ខុដែលមានការសម្គាល់ក្នុងចីវរដែលមិនទាន់កន្លង ( ១០ ថ្ងៃ ) ថា "កន្លងហើយ" និងភិក្ខុដែលមានសេចក្តីសង្ស័យ ។

## ខាតចីវរដែលគួរអធិដ្ឋាននិងវិកប្ប

[៨] ក៏ក្នុងពាក្យថា អនាបត្តិ អន្តោទសាហំ អធិដ្ឋេតិ វិកប្បេតិ : វាក្យ:ដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុបានអធិដ្ឋាន បានវិកប្បក្នុងខាងក្នុងដប់ថ្ងៃ នេះ អ្នកសិក្សាគប្បីជ្រាបចីវរដែលគួរអធិដ្ឋាន និងដែលគួរវិកប្ប ។ ក្នុងចីវរដែលគួរអធិដ្ឋាននិងវិកប្បនោះ មានព្រះបាលីដូចតទៅនេះ ៖

"យានិ តានិ ភគវតា អនុញ្ញាតានិ តិចីវរន្តិ វា វស្សិកសាដិកាតិ វា និសីទន"ន្តិ វា បច្ចត្ថរណន្តិ វា កណ្ឌុប្បដិច្ឆាទីតិ វា មុខបុញ្ឆនចោឡកន្តិ វា បរិក្ខារចោឡន្តិ វា សព្វានិ តានិ អធិដ្ឋាតព្វានីតិ ន វេ ឧបាហុ វិកប្បេតព្វានីតិ ភគវតោ ឯតមត្ថំ អារោចេសុំ អនុជានាមិ ភិក្ខវេ តិចីវរំ អធិដ្ឋាតុំ ន វិកប្បេតុំ, វស្សិកសាដិកំ វស្សានំ ចាតុមាសំ អធិដ្ឋាតុំ តតោ បរំ វិកប្បេតុំ, និសីទនំ អធិដ្ឋាតុំ ន វិកប្បេតុំ,

បច្ចត្ថរណំ អធិដ្ឋាតុំ ន វិកប្បេតុំ, កណ្ឌុប្បដិច្ឆាទឹ យាវអាពាធា អធិដ្ឋាតុំ តតោ បរំ វិកប្បេតុំ, មុខបុញ្ឆនចោឡំ អធិដ្ឋាតុំ ន វិកប្បេតុំ, បរិក្ខារចោឡំ អធិដ្ឋាតុំ ន វិកប្បេតុំ : ក្នុងពេលនោះ ពួកភិក្ខុមានសេចក្តីត្រិះរិះដូច្នេះថា សំពត់ទាំងឡាយណា គឺ ត្រៃចីវរក្តី សំពត់សម្រាប់ងូតទឹកភ្លៀងក្តី សំពត់សម្រាប់ទ្រាប់អង្គុយក្តី សំពត់កម្រាលក្តី សំពត់សម្រាប់គ្របកមក្តី សំពត់សម្រាប់ជូតមុខក្តី សំពត់បរិក្ខារក្តី ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ សំពត់ទាំងអស់នោះ តើយើងគួរអធិដ្ឋាន ឬគួរវិកប្បទុក ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុអធិដ្ឋានត្រៃចីវរ មិនឱ្យវិកប្បទេ, ឱ្យអធិដ្ឋានសំពត់សម្រាប់ងូតទឹកភ្លៀងអស់ ៤ ខែនៃរដូវភ្លៀង បន្ទាប់អំពីកាល ៤ ខែនោះទៅត្រូវវិកប្បទុក, ឱ្យអធិដ្ឋានសំពត់សម្រាប់ទ្រាប់អង្គុយ មិនឱ្យវិកប្បទេ, ឱ្យអធិដ្ឋានសំពត់កម្រាល មិនឱ្យវិកប្បទេ, ឱ្យអធិដ្ឋានសំពត់សម្រាប់គ្របកម កំណត់ត្រឹមមានអាពាធ ហួសពីអាពាធនោះទៅ ត្រូវវិកប្បទុក, ឱ្យអធិដ្ឋានសំពត់សម្រាប់ជូតមុខ មិនឱ្យវិកប្បទេ, ឱ្យអធិដ្ឋានសំពត់បរិក្ខារ មិនឱ្យវិកប្បទេ"[១] ដូច្នេះ ។

---

១. វិន. មហា. ចីវរក្ខន្ធកៈ. ៨. ៦៦/១៤៣ ។

## ការអធិដ្ឋានត្រៃចីវរជាដើម

បណ្តាចីវរជាដើមទាំងនោះ ភិក្ខុកាលនឹងអធិដ្ឋានត្រៃចីវរ ជ្រលក់ហើយឱ្យកប្បៈពិន្ទុ គប្បីអធិដ្ឋានចីវរដែលបានប្រមាណប៉ុណ្ណោះ ។ ប្រមាណនៃចីវរនោះ ដោយកំណត់យ៉ាងខ្ពស់ តូចជាងសុគតចីវរ (ចីវររបស់ព្រះសុគត) ទើបគួរ ។ និងដោយកំណត់យ៉ាងទាបប្រមាណនៃសង្ឃាដិ និងឧត្តរាសង្គៈ មានបណ្តោយ ៥ ហត្ថក្តាប់ ទទឹង ៣ ហត្ថក្តាប់ ទើបគួរ ។ អន្តរវាសកៈ មានបណ្តោយ ៥ ហត្ថក្តាប់ ទទឹងសូម្បី ២ ហត្ថ ក៏គួរ ។ ព្រោះអាចបិទបាំងផ្ចិតដោយសំពត់ស្ទៀកខ្លះ សំពត់ដណ្តប់ខ្លះហើយ ។ ក៏ចីវរដែលលើស និងខ្វះជាងប្រមាណដូចពោលហើយ គប្បីអធិដ្ឋានថា បរិក្ខារចោឡៈ ។

ក្នុងវិស័យនៃការអធិដ្ឋានចីវរនោះ លោកពោលទុកថា "ការអធិដ្ឋានចីវរ មាន ២ យ៉ាង គឺ អធិដ្ឋានដោយកាយ ១, អធិដ្ឋានដោយវាចា ១"[១]; ដូច្នោះ ភិក្ខុគប្បីដកសង្ឃាដិផ្ទាំងចាស់ថា "ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ : យើងដកសង្ឃាដិផ្ទាំងនេះ" ហើយយកដៃចាប់សង្ឃាដិថ្មី ឬពាក់លើចំណែកនៃរាងកាយធ្វើការបងចិត្តថា "ឥមំ សង្ឃាដឹ អធិដ្ឋាមិ : យើងអធិដ្ឋានសង្ឃាដិនេះ" ហើយគប្បីធ្វើកាយវិការ អធិដ្ឋានដោយ

១. វិន. បរិ. ឯកុត្តរិក. ១៣. ៣១/១៨ ។

កយ នេះឈ្មោះថា ការអធិដ្ឋានដោយកាយ ។

កាលមិនពាល់ត្រូវចីវរនោះ ដោយចំណែកនៃរាងកាយណាមួយសោះ ការអធិដ្ឋាននោះ មិនគួរ ។

ចំណែកក្នុងការអធិដ្ឋានដោយវាចា គប្បីបញ្ចេញវាចាហើយអធិដ្ឋានដោយវាចា ។ ក្នុងការអធិដ្ឋានដោយវាចានោះ មានការអធិដ្ឋាន ២ វិធី ។ បើសំពត់សង្ឃាដិនៅក្នុងហត្ថបាស គប្បីបញ្ចេញវាចាថា "ឥមំ សង្ឃាដឹ អធិដ្ឋាមិ : ខ្ញុំអធិដ្ឋានសង្ឃាដិផ្ទាំងនេះ" ។ បើនៅខាងក្នុងបន្ទប់ ក្នុងប្រាសាទ ជាន់លើ ឬក្នុងវត្តជិត ៗ គប្បីកំណត់ទីរក្សាសង្ឃាដិទុកហើយបញ្ចេញវាចាថា "ឯតំ សង្ឃាដឹ អធិដ្ឋាមិ : ខ្ញុំអធិដ្ឋានសង្ឃាដិនោះ" ។ ក្នុងឧត្តរាសង្គ: និង អន្តរវាសក: ក៏មានន័យយ៉ាងនេះ ។ ពិតមែន ត្រឹមតែឈ្មោះប៉ុណ្ណោះដែលប្លែកគ្នា ។ ព្រោះដូច្នោះ គប្បីអធិដ្ឋានចីវរទាំងអស់ ដោយឈ្មោះរបស់ខ្លួនប៉ុណ្ណោះ យ៉ាងនេះថា សង្ឃាដឹ ឧត្តរាសង្គំ អន្តរវាសកំ ដូច្នេះ ។

បើភិក្ខុធ្វើចីវរមានសង្ឃាដិជាដើម ដោយសំពត់ដែលអធិដ្ឋានរក្សាទុក កាលជ្រលក់និងកប្បៈសម្រេចហើយគប្បីដកថា ខ្ញុំដកសំពត់នេះហើយអធិដ្ឋានថ្មី ។ តែកាលដេរផ្ទាំងសំពត់ថ្មី ឬខណ្ឌថ្មីដែលធំជាងចូលថែមទីងចីវរដែលអធិដ្ឋានហើយ គួរអធិដ្ឋានថ្មី ។ ក្នុងផ្ទាំងសំពត់ដែលប៉ុនគ្នាឬតូចជាង មិនមានកិច្ចដោយការអធិដ្ឋាន (ថ្មី) ។

សួរថា ក៏ត្រៃចីវរនឹងអធិដ្ឋានជាបរិក្ខារចោឡៈ គួរឬមិនគួរ ?

ឆ្លើយថា បានជ្រាបថា ព្រះមហាបទុមត្ថេរៈពោលថា ត្រៃចីវរគប្បីអធិដ្ឋានជាត្រៃចីវរតែម្យ៉ាង, បើអធិដ្ឋានជាបរិក្ខារចោឡៈ បាន, ការរក្សាដែលត្រាស់ទុកក្នុងឧទ្ទេសិតសិក្ខាបទ គប្បីជាការឥតប្រយោជន៍ ។ បានឮថា កាលព្រះមហាបទុមត្ថេរៈពោលយ៉ាងនេះ ពួកភិក្ខុដ៏សេសពោលថា សូម្បីបរិក្ខារចោឡៈ ព្រះមានព្រះភាគក៏ត្រាស់ថា គប្បីអធិដ្ឋាន ; ព្រោះហេតុនោះ ការអធិដ្ឋានត្រៃចីវរឱ្យជាបរិក្ខារចោឡៈ រមែងសមគួរ ។

សូម្បីក្នុងមហាបច្ចរី លោកក៏ពោលថា ឈ្មោះថា បរិក្ខារចោឡៈនេះជាហេតុនៃការរក្សា (ចីវរដោយសេចក្តីមិនជានិស្សគ្គិយ) ទុកមួយផ្នែក ។ នឹងអធិដ្ឋានត្រៃចីវរថា បរិក្ខារចោឡៈហើយប្រើប្រាស់ គួរ ។ ចំណែកក្នុងឧទ្ទេសិតសិក្ខាបទត្រាស់ការបរិហារទុកសម្រាប់ភិក្ខុដែលអធិដ្ឋានត្រៃចីវរ ហើយបរិហារ ។

បានឮថា សូម្បីព្រះមហាតិស្សថេរៈអ្នកពោលឧភតោវិភង្គ ដែលនៅត្រង់បុណ្ណវាលិកាពាមបានពោលថា ក្នុងកាលមុន ពួកយើងបានស្តាប់អំពីព្រះមហាថេរៈថា ពួកភិក្ខុដែលពេញចិត្តនៅក្នុងព្រៃ រក្សាចីវរទុកក្នុងរូងឈើជាដើម ទៅដើម្បីត្រូវការនឹងផ្តើមបំពេញព្យាយាម, និងកាលភិក្ខុទាំងនោះទៅដើម្បីប្រាថ្នានឹងស្តាប់ធម៌ក្នុងវត្តជិត ៗ កាលព្រះអាទិត្យរះឡើងហើយ ពួកសាមណេរ ឬពួកភិក្ខុកម្លោះ ទើបកាន់បាត្រចីវរមក

(ឱ្យ) ; ព្រោះដូច្នោះ ការទីងអធិដ្ឋានត្រៃចីវរជាបរិក្ខារចោឡៈ ដើម្បីប្រើប្រាស់ដោយសប្បាយ គួរ ។

សូម្បីក្នុងមហាបច្ចរីលោកក៏ពោលថា ក្នុងកាលមុន ពួកភិក្ខុដែលនៅព្រៃបានអធិដ្ឋានត្រៃចីវរជាបរិក្ខារចោឡៈទុំះឯង ហើយប្រើប្រាស់ដោយគិតថា "ក្នុងដែនដែលមិនចងសីមារក្សាបានលំបាក" ។

វស្សិកសាដកដែលមិនលើសប្រមាណ ដែលភិក្ខុគប្បីបញ្ចូលឈ្មោះហើយអធិដ្ឋានអស់ ៤ ខែរដូវភ្លៀងដោយន័យដូចពោលហើយទុំះឯង, តពីនោះគប្បីដកហើយវិកប្បទុក ។ ក៏វស្សិកសាដក នេះ សូម្បីជ្រលក់ល្មមធ្វើឱ្យខូចពណ៌, ក៏គួរ ។ តែពីរផ្ទាំងមិនគួរ ។

សំពត់និសីទនៈ គប្បីអធិដ្ឋានដោយន័យដូចពោលហើយទុំះឯង ។ ក៏ឯសំពត់និសីទនៈនោះ មានប្រមាណត្រឹមតែមួយផ្ទាំងប៉ុណ្ណោះ ។ ពីរផ្ទាំងមិនគួរ ។

សូម្បីសំពត់ក្រាលដេកក៏គួរអធិដ្ឋានដូចគ្នា ។ ក៏សំពត់ក្រាលដេកនោះ សូម្បីធំ ក៏គួរ តែមួយផ្ទាំង ក៏គួរ សូម្បីច្រើនផ្ទាំង ក៏គួរ ។ មានលក្ខណៈជាដើមថា ពណ៌ខៀវក្ដី ពណ៌លឿងក្ដី មានជាយក្ដី មានជាយជាក្បាច់ផ្កាឈើក្ដី រមែងគួរគ្រប់ប្រការ ។ ភិក្ខុអធិដ្ឋានម្ដង រមែងជាការអធិដ្ឋានហើយតែម្ដង ។

សំពត់រុំដំបៅបានប្រមាណ គប្បីអធិដ្ឋានក្នុងរយៈពេលដែលនៅ

មានអាពាធ, កាលអាពាធជាសះស្បើយហើយ គប្បីបច្ចុទ្ធរណ៍វិកប្បទុក ។ តែមួយផ្ទាំងប៉ុណ្ណោះ ទើបគួរ ។

សំពត់ជូតមុខ គប្បីអធិដ្ឋានដូចគ្នា ។ ភិក្ខុចាំបាច់ត្រូវ ប្រាថ្នាផ្ទាំងដទៃ ដើម្បីត្រូវការប្រើពេលដែលមួយផ្ទាំងទៀតនៅបោកគត់, ព្រោះដូច្នោះ ពីរផ្ទាំងក៏គួរ ។ តែព្រះថេរៈមួយពួកទៀតពោលថា ការអធិដ្ឋានសំពត់ជូតមុខនោះ ប្រាថ្នាការរក្សាទុកជាសំខាន់ សូម្បីច្រើនផ្ទាំង ក៏គួរ ។

ក្នុងបរិក្ខារចោឡៈ ឈ្មោះថា ការរាប់ចំនួនមិនមាន, គប្បីអធិដ្ឋានបានតាមចំនួនដែលត្រូវការនោះឯង ។ ថង់យាមក្តី សំពត់តម្រងទឹកក្តី យ៉ាងតូចបំផុត មានប្រមាណប៉ុនចីវរដែលគួរវិកប្ប គប្បីអធិដ្ឋានថាបរិក្ខារចោឡៈ ដូចគ្នា ។ សូម្បីទឹងរួមចីវរច្រើន ផ្ទាំងចូលជាមួយគ្នាហើយអធិដ្ឋានថា "ឥមានិ ចីវរានិ បរិក្ខារចោឡានិ អធិដ្ឋាមិ : ខ្ញុំអធិដ្ឋានចីវរទាំងនេះ ជាបរិក្ខារចោឡៈ" ដូច្នេះ ក៏សមគួរដូចគ្នា ។ សូម្បីភិក្ខុនឹងរក្សាទុកដើម្បីប្រយោជន៍ដល់ភេសជ្ជៈ នវកម្មនិងមាតាបិតាជាដើមក៏ចាំបាច់ត្រូវអធិដ្ឋានពិត ។ តែក្នុងមហាបច្ចរីលោកពោលថា មិនជាអាបត្តិ ។

ចំណែកក្នុងបរិក្ខារនៃសេនាសនៈទាំងនេះ គឺ ពូកគ្រែ ១ ពូកតាំង ១ ខ្នើយ ១ សំពត់បាវារ ១ សំពត់ព្រំ ១ និងក្នុងកម្រាលដែលគេប្រគេនទុក ដើម្បីប្រយោជន៍ដល់បរិក្ខារនៃសេនាសនៈ មិនមានកិច្ចដែលត្រូវអធិដ្ឋានឡើយ ។

## ហេតុឱ្យដាច់អធិដ្ឋាន

សួរថា ក៏ចីវរដែលអធិដ្ឋានហើយ កាលភិក្ខុប្រើប្រាស់ នឹងដាច់អធិដ្ឋានទៅដោយហេតុយ៉ាងណា ?

ឆ្លើយថា រមែងដាច់ដោយហេតុ ៩ យ៉ាងនេះ គឺ **អញ្ញស្សទានេន** ដោយឱ្យបុគ្គលដទៃ ១, **អច្ឆិន្ទិត្វា គហណេន** ដោយចោរប្លន់យកទៅ ១, **វិស្សាសគ្គាហេន** ដោយកាន់យកជាវិស្សាសៈ ១, **ហីនាយាវត្តនេន** ដោយសឹកទៅជាហីនភេទ* ១, **សិក្ខាបច្ចក្ខានេន** ដោយលាសិក្ខា* ១, **កាលំកិរិយាយ** ដោយកាលកិរិយា ១, **លិង្គបរិវត្តនេន** ដោយភេទត្រឡប់ ១, **បច្ចុទ្ធរណេន** ដោយដកអធិដ្ឋាន ១, **ឆិទ្ទភាវេន** ដោយភាពជាប្រហោងធ្លុះ ១ ៗ

បណ្តាហេតុ ៩ យ៉ាងនោះ ចីវរគ្រប់ប្រភេទ រមែងដាច់អធិដ្ឋានដោយហេតុ ៨ យ៉ាងខាងដើម ៗ តែចំពោះត្រៃចីវរដាច់អធិដ្ឋានដោយមានប្រហោងធ្លុះ លោកពោលទុកក្នុងអដ្ឋកថាគ្រប់កន្លែង ៗ និងការដាច់អធិដ្ឋាននោះ លោកពោលទុកដោយប្រហោងធ្លុះប្រមាណប៉ុនខ្នងក្រចក ៗ ក្នុងប្រហោងធ្លុះប្រមាណប៉ុនខ្នងក្រចកនោះ អ្នកសិក្សាគប្បីជ្រាបខាតប៉ុន

---

* ការសឹករបស់ភិក្ខុដែលត្រូវអាបត្តិបារាជិក ហៅថា ហីនាយាវត្តនេន; ការសឹករបស់ភិក្ខុ ដែលមិនត្រូវអាបត្តិបារាជិក ហៅថា សិក្ខាបច្ចក្ខានេន ៗ

ខ្នងក្រចក ដោយអំណាចនៃក្រចកកូនដៃ ។ និងប្រហោងធ្លុះ ជាប្រហោងធ្លុះតែម្តង ។ ក៏បើសូម្បីថា ខាងក្នុងប្រហោងធ្លុះមានសរសៃអំបោះមួយសរសៃមិនទាន់ដាច់, ក៏នៅរក្សា ។

បណ្តាត្រៃចីវរនោះ សម្រាប់សង្ឃាដិ និងឧត្តរាសង្គៈប្រហោងធ្លុះអំពីផ្នែក ក្នុងនៃសាច់ដែលមានប្រមាណត្រឹមតែ ១ ចំអាម អំពីជាយខាងបណ្តោយ, មានប្រមាណ ៨ ធ្នាប់ អំពីជាយខាងទទឹង រមែងធ្វើឱ្យដាច់អធិដ្ឋាន ។ តែសម្រាប់អន្តរវាសកៈ ប្រហោងធ្លុះអំពីផ្នែកក្នុងនៃសាច់ ដែលមានប្រមាណត្រឹមតែ ១ ចំអាម អំពីជាយខាងបណ្តោយ, មានប្រមាណ ៤ ធ្នាប់ អំពីជាយខាងទទឹង រមែងធ្វើឱ្យដាច់អធិដ្ឋាន ។ ប្រហោងធ្លុះតូចចុះមក មិនធ្វើឱ្យដាច់អធិដ្ឋាន ។ ព្រោះដូច្នោះ កាលមានប្រហោងធ្លុះចីវរនោះ រមែងតាំងនៅក្នុងឋាននៃអតិរេកចីវរ, គួរធ្វើសូចិកម្ម ហើយអធិដ្ឋានជាថ្មី ។

តែព្រះមហាសុមត្ថេរៈពោលថា ចីវរដែលបានប្រមាណ មានប្រហោងធ្លុះត្រង់ណាមួយ រមែងធ្វើឱ្យដាច់អធិដ្ឋាន, តែសម្រាប់ចីវរធំប្រហោងធ្លុះខាងក្រៅពីប្រមាណ មិនទាន់ធ្វើឱ្យដាច់អធិដ្ឋាន, ប្រហោងដែលធ្លុះខាងក្នុងទើបធ្វើឱ្យដាច់ ដូច្នេះ ។

ព្រះករវិយតិស្សត្ថេរៈពោលថា ចីវរតូច ធំ មិនជាប្រមាណ, ប្រហោងធ្លុះក្នុងទីដែលភិក្ខុកាលគ្រងចីវរត្រួតផ្គុំបត្គា ២ ខាង មូរមកពាក់

ទុកលើដៃឆ្វេងមិនទាន់ធ្វើឱ្យដាច់អធិដ្ឋាន, ប្រហោងធ្លុះផ្នែកខាងក្នុងរមែងធ្វើឱ្យដាច់, សូម្បីសម្រាប់អន្តរវាសកៈ ប្រហោងធ្លុះក្នុងទីនៃចីវរដែលភិក្ខុមូរឱ្យជារបុំ រមែងមិនធ្វើឱ្យដាច់, ប្រហោងធ្លុះដែលក្រោមចុះពីដែលមូរឱ្យជារបុំនោះ រមែងធ្វើឱ្យដាច់ ។

តែក្នុងអដ្ឋកថា អន្ទកៈ លោកធ្វើវាទៈរបស់ព្រះមហាសុមត្ថេរៈឱ្យជាគោលក្នុងត្រៃចីវរហើយពោលថា ចីវរប្រមាណយ៉ាងទាប រមែងរក្សាអធិដ្ឋានទុកបាន ទើបពោលពាក្យសូម្បីនេះបន្ថែមទុកថា ក្នុងបរិក្ខារចោឡៈខាងបណ្តោយ ៨ ធ្នាប់ ដោយធ្នាប់ព្រះសុគត ខាងទទឹង ៤ ធ្នាប់ ជាប្រហោងធ្លុះនៅក្នុងចំណែកណាមួយ រមែងដាច់អធិដ្ឋានបាន, ក្នុងបរិក្ខារចោឡៈផ្ទាំងធំ ប្រហោងធ្លុះដែលក្រោម ៨ធ្នាប់ និង ៤ធ្នាប់នោះ មិនទាន់ដាច់អធិដ្ឋាន, ក្នុងចីវរដែលគួរអធិដ្ឋានទាំងអស់ ក៏ន័យនេះ ដូច្នេះ ។

បណ្តាវាទៈទាំង ៤ នោះ ដែលឈ្មោះថា ប្រមាណយ៉ាងតូចដទៃ ៗដែលតូចជាងប្រមាណយ៉ាងតូច នៃចីវរដែលគួរ វិកប្បរបស់ចីវរដែលគប្បីអធិដ្ឋានសូម្បីទាំងអស់ រមែងមិនមាន ។ ព្រោះថា ប្រមាណនៃសំពត់និសីទនៈ សំពត់បិទដំបៅ និងសំពត់ងូតទឹកភ្លៀងដែលលោកពោលទុកនោះ ជាប្រមាណយ៉ាងធំ ព្រោះប្រមាណដ៏ក្រៃលែងជាងប្រមាណយ៉ាងធំនោះ គឺលោកបដិសេធហើយ, មិនមែនប្រមាណយ៉ាងតូចទេ ព្រោះប្រមាណយ៉ាងតូចចុះមកពីប្រមាណយ៉ាងធំនោះ គឺលោកមិន

បដិសេធហើយ ។ សូម្បីត្រៃចីវរដែលតូចជាងប្រមាណនៃសុគតចីវរ ចាត់ជាប្រមាណយ៉ាងធំដូចគ្នា ។ តែប្រមាណយ៉ាងតូចដែលលោកចែក ពោលទុកផ្សេង ដទៃក្នុងព្រះសូត្រមិនមាន ។

ការកំណត់ខ្នាតធំនៃសំពត់ជូតមុខ សំពត់កម្រាល និងសំពត់ បរិក្ខារចោឡៈមិនមានដូចគ្នា ។ តែលោកពោលកំណត់ទុក ដោយ ប្រមាណយ៉ាងតូច នៃខ្នាតចីវរដែលគួរវិកប្ប ។ ព្រោះដូច្នោះ ពាក្យណា ដែលលោកពោលទុកមុន ក្នុងអដ្ឋកថាអន្ធកៈថា ប្រមាណយ៉ាងតូច រមែងរក្សាការអធិដ្ឋានទុកបាន ហើយសម្ដែងប្រមាណយ៉ាងតូច ៨ ធ្នាប់ និង ៤ ធ្នាប់ ដោយធ្នាប់ព្រះសុគតនៃបរិក្ខារចោឡៈប៉ុណ្ណោះ ក្នុងបណ្ដា ត្រៃចីវរនិងបរិក្ខារចោឡៈជាដើមនោះ និង សំដៅយកប្រមាណយ៉ាងតូច នៃត្រៃចីវរជាដើមក្រៅនេះ ដែលមានប្រភេទ ៥ ហត្ថក្ដាប់ជាដើម ទើប ពោលថា ក្នុងចីវរដែលគួរអធិដ្ឋានទាំងអស់ ក៏ន័យនេះ, ពាក្យដែល លោកពោលទុកក្នុងអដ្ឋកថាអន្ធកៈនោះ រមែងមិនសមគ្នា ។ សូម្បីក្នុង វាទៈរបស់ព្រះករវិយតិស្សត្ថេរៈ លោកក៏សម្ដែងប្រហោង ធ្លុះអំពីជា យខាងបណ្ដោយប៉ុណ្ណោះ អំពីជាយខាងទទឹង លោកមិនបានសម្ដែងទុក; ព្រោះដូច្នោះ វាទៈរបស់ព្រះករវិយតិស្សត្ថេរៈនោះ ក៏មិនបានកំណត់ទុក ។

ក្នុងវាទៈរបស់ព្រះមហាសុមត្ថេរៈ លោកពោលទុកថា ប្រហោង ធ្លុះក្នុងទីកន្លែងណាមួយនៃចីវរដែលបានប្រមាណ រមែងធ្វើឱ្យដាច់អធិដ្ឋាន,

ប្រហោងធ្លុះខាងក្រៅអំពីប្រមាណនៃចីវរខ្នាតធំ រមែងមិនធ្វើឱ្យជាប់អធិដ្ឋាន, តែលោកក៏មិនបានពោលពាក្យនេះថា ចីវរឈ្មោះនេះ ចាត់ជាចីវរដែលបានប្រមាណ, ដែលធំជាងចីវរដែលបានប្រមាណនេះ ចាត់ជាចីវរធំ ។

ម្យ៉ាងទៀត ក្នុងវិស័យនៃត្រៃចីវរជាដើមនេះ អាចារ្យទាំងឡាយប្រាថ្នាយកពាក្យថា ខ្នាតដែលផ្សេងគ្នាមាន ៥ ហត្ថក្តាប់ជាដើម ជាប្រមាណយ៉ាងតូចនៃត្រៃចីវរជាដើម, បើក្នុងចីវរធំនោះ ប្រហោងធ្លុះខាងក្រៅអំពីប្រមាណយ៉ាងតូច មិនគប្បីធ្វើឱ្យជាប់អធិដ្ឋានសោត, ប្រហោងធ្លុះខាងក្រៅអំពីប្រមាណយ៉ាងតូច សូម្បីនៃបាត្រខ្នាតធំ ឬនៃបាត្រខ្នាតកណ្តាលក៏មិនគប្បីធ្វើឱ្យជាប់អធិដ្ឋាន, តែ (ប្រហោងធ្លុះខាងក្រៅអំពីប្រមាណយ៉ាងតូច) នឹងមិនធ្វើឱ្យជាប់អធិដ្ឋាន ក៏ទេ; ព្រោះដូច្នោះ វាទៈសូម្បីនេះក៏មិនបានកំណត់ខ្នាតទុក ។

តែអដ្ឋកថា វាទៈដំបូងទាំងអស់នេះ ជាប្រមាណ ក្នុងអធិការវិនិច្ឆ័យត្រៃចីវរជាដើមនេះ ។ ព្រោះហេតុអ្វី ? ព្រោះមានកំណត់ ។ ពិតមែន ប្រមាណយ៉ាងតូចនៃត្រៃចីវរ ប្រមាណប្រហោងធ្លុះ និងប្រមាណនៃចំណែកដែលជាប្រហោងធ្លុះ លោកកំណត់ពោលទុកហើយ

---

១. វិមតិ. ទ្វេ ចីវរានិ បារុបន្តស្សាតិ គាមប្បវេសេ ទ្វិគុណំ កត្វា សង្ឃាដិយោ បារុបនំ សន្ធាយ វុត្តំ ។ សូម្បីសារត្ថទីបនី ៣/១៤៦ ក៏ពន្យល់ស្រដៀងគ្នា នេះ ។

គ្រប់អដ្ឋកថា ដូចគ្នា ។ ព្រោះដូច្នោះ វាទៈនោះឯងជាប្រមាណ ។ ព្រោះថា អដ្ឋកថាវាទៈនោះ លោកពោលបណ្តាយតាមព្រះបំណងរបស់ព្រះមានព្រះភាគ ពិតប្រាកដ ។ ចំណែកក្នុង៣ វាទៈក្រៅនេះ មិនមានកំណត់ឡើយ ។ ពាក្យមុខនឹងពាក្យក្រោយមិនសមគ្នា ដូច្នេះឯង ។

ក៏ភិក្ខុណា ផ្អបសំពត់ប៉ះភ្ជាប់ក្នុងទីទ្រុឌទ្រោមមុនសិនហើយ កាត់ទីដែលទ្រុឌទ្រោមចេញជាខាងក្រោយ, ការអធិដ្ឋានរបស់ភិក្ខុនោះមិនទាន់ដាច់ទៅ ។ សូម្បីក្នុងការផ្លាស់ប្តូរខ្នង (ចីវរ) ក៏មានន័យយ៉ាងនេះដូចគ្នា ។ សម្រាប់ចីវរ ២ ជាន់ កាលមួយជាន់មានប្រហោងធ្លុះ ឬរសាត់ (សាច់សំពត់) អធិដ្ឋាននៅមិនទាន់ដាច់ ។ ភិក្ខុធ្វើចីវរផ្ទាំងតូចឱ្យជាផ្ទាំងធំ ឬធ្វើផ្ទាំងធំឱ្យជាផ្ទាំងតូច, អធិដ្ឋាន មិនទាន់ដាច់ ។ កាលនឹងតរឹមពីរខាងចូលនៅត្រង់កណ្តាល បើថា កាត់ចេញមុនហើយដេរជាប់គ្នាជាខាងក្រោយ, អធិដ្ឋាន រមែងដាច់ ។ បើដេរតគ្នាហើយ ទើបកាត់ជាខាងក្រោយ, មិនទាន់ដាច់អធិដ្ឋាន ។ សូម្បីកាលប្រើពូកជាងជ្រលក់បោកគក់ឱ្យជាសំពត់ស អធិដ្ឋានក៏តាំងនៅជាអធិដ្ឋានដដែលនោះឯង ។

វិនិច្ឆ័យក្នុងការអធិដ្ឋាន ក្នុងពាក្យថា អន្តោឧសាហំ អធិដ្ឋេតិ វិកប្បេតិ នេះ ប៉ុណ្ណោះសិន ។

# អធិប្បាយការវិកប្បចីវរ

ចំណែកក្នុងការវិកប្បមានវិនិច្ឆ័យដូចតទៅនេះ ៖

វិកប្បមាន ២ យ៉ាង គឺ វិកប្បចំពោះមុខ១ វិកប្បកំបាំងមុខ១ ។

សួរថា តើវិកប្បចំពោះមុខ យ៉ាងណា ?

ឆ្លើយថា ភិក្ខុគប្បីជ្រាបថា ចីវរតែមួយផ្ទាំង ឬច្រើនផ្ទាំង និងថា ចីវរដាក់ទុកជិត ឬមិនបានដាក់ទុកជិត (នៅក្នុងហត្ថបាស ឬក្រៅហត្ថបាស) ហើយពោលថា "ឥមំ ចីវរំ : ចីវរផ្ទាំងនេះ"ខ្លះ ថា "ឥមានិ ចីវរានិ : ចីវរទាំងនេះ"ខ្លះ ថា "ឯតំ ចីវរំ : ចីវរនោះ"ខ្លះ ថា "ឯតានិ ចីវរានិ : ចីវរទាំងនោះ"ខ្លះ ហើយគប្បីពោលថា "តុយ្ហំ វិកប្បេមិ : ខ្ញុំព្រះករុណាវិកប្បដល់លោក" ដូច្នេះ ។ នេះ វិកប្បចំពោះមុខម្យ៉ាង ។ ដោយការវិកប្បត្រឹមតែប៉ុណ្ណេះ នឹងរក្សាទុកសមគួរ ។ នឹងប្រើប្រាស់ ឬនឹងលះបង់ ឬនឹងអធិដ្ឋាន មិនគួរ ។ តែកាលភិក្ខុនោះ (ភិក្ខុដែលទទួលវិកប្ប) ពោលពាក្យថា "មយ្ហំ សន្តកំ មយ្ហំ សន្តកានិ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ : ចីវរនេះ ឬចីវរទាំងនេះ ជារបស់ខ្ញុំព្រះករុណា លោកចូរប្រើប្រាស់ ចូរចំណាយ ចូរធ្វើតាមសមគួរដល់បច្ច័យចុះ" ដូច្នេះ ឈ្មោះថា បច្ចុទ្ធរណ៍ (ដកវិកប្ប), ចាប់ផ្ដើមតាំងពីនោះ សូម្បីការបរិភោគជាដើម

រមែងសមគួរ ។

ន័យមួយទៀត ភិក្ខុគប្បីដឹងថា ចីវរតែមួយផ្ទាំង ឬច្រើនផ្ទាំង និងថា ដាក់ទុកជិត ឬមិនបានដាក់ទុកជិតយ៉ាងនោះឯង ហើយពោលថា ឥមំ ចីវរំ ឬថា ឥមានិ ចីវរានិ ដូច្នេះ ថា ឯតំ ចីវរំ ឬថា ឯតានិ ចីវរានិ ដូច្នេះ ក្នុងសំណាក់របស់ភិក្ខុនោះឯង បញ្ជាក់ឈ្មោះសហធម្មិក ៥ រូបណាមួយ គឺអ្នកណាម្នាក់ ដែលខ្លួនពេញចិត្តហើយ គប្បីពោលថា "តិស្សស្ស ភិក្ខុនោ វិកប្បេមិ : ខ្ញុំព្រះករុណាវិកប្ប ... ដល់ភិក្ខុតិស្សៈ" ឬថា "តិស្សាយ ភិក្ខុនិយា, តិស្សាយ សិក្ខមានាយ, តិស្សស្ស សាមណេរស្ស, តិស្សាយ សាមណេរិយា វិកប្បេមិ : ខ្ញុំព្រះករុណាវិកប្ប ... ដល់តិស្សាភិក្ខុនី, ដល់តិស្សាសិក្ខមានា, ដល់តិស្សសាមណេរ, ដល់តិស្សាសាមណេរី" ដូច្នេះ ។ នេះជាវិកប្បចំពោះមុខ ម្យ៉ាងទៀត ។ ដោយការវិកប្បត្រឹមតែប៉ុណ្ណេះ និងរក្សាទុកសមគួរ ។ តែក្នុងការប្រើប្រាស់ជាដើម កិច្ចសូម្បីម្យ៉ាង រមែងមិនគួរ ។ តែកាលភិក្ខុនោះពោលពាក្យថា ចីវរនេះ របស់ភិក្ខុឈ្មោះតិស្សៈ ។ល ។ របស់សាមណេរីឈ្មោះតិស្សា លោកចូរបរិភោគក៏ដោយ ចូរចំណាយក៏ដោយ ចូរធ្វើតាមសមគួរដល់បច្ច័យក៏ដោយ ដូច្នេះ ឈ្មោះថា ជាការដក, ចាប់ផ្ដើមតាំងពីនោះ សូម្បីការប្រើប្រាស់ជាដើម ក៏សមគួរ ។

សួរថា ការវិកប្បកំបាំងមុខ តើធ្វើយ៉ាងណា ?

ឆ្លើយថា ភិក្ខុគប្បីជ្រាបថា ចីវរតែមួយផ្ទាំងឬច្រើនផ្ទាំង និងចីវរដាក់ទុកជិត ឬមិនបានដាក់ទុកជិត ដូចយ៉ាងនោះ ហើយពោលថា "ឥមំ ចីវរំ : នូវចីវរនេះ" ឬថា "ឥមានិ ចីវរានិ : នូវចីវរទាំងឡាយនេះ" ថា "ឯតំ ចីវរំ : នូវចីវរនោះ" ឬថា "ឯតានិ ចីវរានិ : នូវចីវរទាំងឡាយនោះ" ដូច្នេះ ហើយពោលថា "តុយ្ហំ វិកប្បេនត្ថាយ ទម្មិ : ខ្ញុំព្រះករុណាឱ្យដល់លោក ដើម្បីប្រយោជន៍ដល់ការវិកប្ប" ។ ភិក្ខុអ្នកវិកប្ប ដែលភិក្ខុទទួលវិកប្បនោះ គប្បីពោលថា "អ្នកណាជាមិត្ត ឬជាសម្លាញ់ធ្លាប់ឃើញ ឬជាមិត្តស្និទ្ធស្នាលរបស់លោក", លំដាប់នោះ ភិក្ខុដែលវិកប្បក្រៅនេះ គប្បីពោលថា "ភិក្ខុឈ្មោះតិស្ស:" ឬថា ។ល ។ "សាមណេរីឈ្មោះតិស្សា" ដោយន័យមុនទុំះឯង ។ ភិក្ខុនោះគប្បីពោលទៀតថា "អហំ តិស្សស្ស ភិក្ខុនោ ទម្មិ : ខ្ញុំព្រះករុណាឱ្យដល់ភិក្ខុឈ្មោះតិស្ស:" ។ល ។ ឬ "អហំ តិស្សាយ សាមណេរិយា ទម្មិ : ខ្ញុំព្រះករុណាឱ្យដល់សាមណេរីឈ្មោះតិស្សា" ដូច្នេះ ។ យ៉ាងនេះ ឈ្មោះថា វិកប្បកំបាំងមុខ ។ ដោយការវិកប្បត្រឹមតែប៉ុណ្ណេះ ការរក្សាទុកសមគួរ ។ ចំណែកក្នុងការប្រើប្រាស់ជាដើម កិច្ចសូម្បីតែម្យ៉ាង ក៏មិនសមគួរ ។ តែកាលភិក្ខុនោះពោលពាក្យថា "ឥត្ថន្នាមស្ស ភិក្ខុនោ សន្តកំ

បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ : (ចីវរ) របស់ភិក្ខុឈ្មោះនេះ លោកចូរប្រើប្រាស់ក៏បាន ចូរចំណាយក៏បាន ចូរធ្វើតាមសមគួរដល់បច្ច័យក៏បាន" ដោយន័យដូចពោលហើយក្នុងវិកប្ប ចំពោះមុខយ៉ាងទីពីរនុ៎ះឯង, ឈ្មោះថា ជាការដក ។ ចាប់ផ្ដើមតាំងពីដក ហើយនោះ សូម្បីកិច្ចទាំងឡាយមានការប្រើប្រាស់ជាដើម រមែងគួរ ។

សួរថា ការវិកប្បទាំង ២ យ៉ាង ផ្សេងគ្នាយ៉ាងណា ?

ឆ្លើយថា ក្នុងការវិកប្បចំពោះមុខ ភិក្ខុវិកប្បដោយខ្លួនឯង ហើយឱ្យអ្នកដទៃដកបាន, ក្នុងវិកប្បកំបាំងមុខ ភិក្ខុឱ្យអ្នកដទៃវិកប្បហើយ ឱ្យអ្នកដទៃនុ៎ះឯងដក, នេះជាសេចក្ដីផ្សេងគ្នា ក្នុងរឿងវិកប្បទាំង ២ នេះ ។ ក៏បើវិកប្បដល់អ្នកណា អ្នកនោះ មិនឆ្លាតក្នុងព្រះបញ្ញត្តិ មិនដឹងនឹងដក, គប្បីកាន់ចីវរនោះ ទៅកាន់សំណាក់សហធម្មិក ដទៃអ្នកឆ្លាតវិកប្បថ្មីហើយគប្បីឱ្យដក ។ នេះឈ្មោះថា ការវិកប្បបរិក្ខារដែលវិកប្បហើយគួរ ។

ក្នុងបទថា វិកប្បេតិ នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ក៏ពាក្យដែលព្រះមានព្រះភាគ ត្រាស់ទុកដោយមិនប្លែកគ្នាថា វិកប្បេតិ : បានវិកប្ប នេះ ហាក់ដូចជាខុសអំពីព្រះបាលីជាដើមថា អនុជានាមិ ភិក្ខវេ តិចីវរំ អធិដ្ឋាតុំ ន វិកប្បេតុំ : ម្នាលភិក្ខុទាំង

ឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុអធិដ្ឋានត្រៃចីវរ មិនឱ្យវិកប្បទេ” ដូច្នេះ, តែព្រះតថាគតទាំងឡាយ រមែងមិនត្រាស់ពាក្យដែលខុស ; ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបសេចក្ដីនៃពាក្យថា **អនុជានាមិ ភិក្ខវេ តិចីវរំ** ជាដើមនោះ ដោយន័យយ៉ាងនេះថា

តថាគតអនុញ្ញាតឱ្យអធិដ្ឋាន សម្រាប់ភិក្ខុដែលបរិហារត្រៃចីវរ ដោយសង្ខេបថា ត្រៃចីវរប៉ុណ្ណោះ មិនមែនឱ្យវិកប្ប ។ តែសំពត់ងូតទឹកភ្លៀង អនុញ្ញាតឱ្យវិកប្បតែម្យ៉ាង បន្ទាប់ពី៤ខែ(រដូវភ្លៀង) មិនត្រូវអធិដ្ឋាន, និងកាលមានអត្ថយ៉ាងនេះ ភិក្ខុរូបណាប្រាថ្នានឹងនៅប្រាសចាកត្រៃចីវរផ្ទាំងណាមួយ, ជាការទ្រង់ប្រទានឱកាសដល់ភិក្ខុនោះ ដើម្បីដកចីវរអធិដ្ឋានហើយវិកប្ប ដើម្បីងាយស្រួលក្នុងការនៅប្រាសចាក (ត្រៃចីវរ) មិនមានអាបត្តិក្នុងកាលកន្លង១០ថ្ងៃ ។ ដោយឧបាយនេះ បណ្ឌិតគប្បីជ្រាបការវិកប្បដែលមិនសម្រេចក្នុងចីវរជាដើមទាំងអស់ដូច្នេះឯង ។

បទថា **វិស្សជ្ជេតិ : ភិក្ខុបានលះ** មានវិនិច្ឆ័យថា ភិក្ខុឱ្យចីវរដល់អ្នកដទៃ, ក៏យ៉ាងណាជាការឱ្យហើយ និងយ៉ាងណា ជាការកាន់យកហើយ ? ភិក្ខុដែលលះបង់ឱ្យពោលថា “**ឥមំ តុយ្ហំ ទេមិ ទទាមិ ទជ្ជាមិ ឱណោជេមិ បរិច្ចជាមិ និស្សជ្ជាមិ វិស្សជ្ជាមិ : ខ្ញុំព្រះករុណាឱ្យ លើកឱ្យ ប្រគល់ឱ្យ បង្អោនឱ្យ លះបង់ឱ្យ ចំណាយចីវរ**

ផ្ទាំងនេះដល់លោក” ឬថា “ឥត្ថន្នាមស្ស ទេមិ ។បេ។ និស្សជ្ជាមិ : ខ្ញុំព្រះករុណាឱ្យ ។ល។ លះបង់ឱ្យដល់លោកអ្នកមានឈ្មោះនេះ” ដូច្នេះ ជាការឱ្យទាំងចំពោះមុខ ទាំងកំបាំងមុខហើយតែម្ដង ; កាលអ្នកលះបង់ឱ្យពោលថា “តុយ្ហំ គណ្ហាហិ : លោកចូរកាន់យករបស់លោក” ដូច្នេះ, ភិក្ខុដែលទទួលពោលថា “មយ្ហំ គណ្ហាមិ : ខ្ញុំព្រះករុណាកាន់យករបស់ខ្ញុំព្រះករុណា” ជាការឱ្យត្រូវនិងកាន់យកត្រូវ, កាលអ្នកលះបង់ឱ្យពោលថា “តវ សន្តកំ ករោហិ តវ សន្តកំ ហោតុ តវ សន្តកំ ករិស្សសិ : លោកចូរធ្វើឱ្យជារបស់លោកចូរជារបស់លោក លោកនឹងធ្វើឱ្យជារបស់លោក” ដូច្នេះ ។ ភិក្ខុដែលទទួលពោលថា “មម សន្តកំ ករោមិ : ខ្ញុំព្រះករុណា នឹងធ្វើឱ្យជារបស់ខ្ញុំព្រះករុណា, មម សន្តកំ ហោតុ ចូរជារបស់ខ្ញុំព្រះករុណា, មម សន្តកំ ករិស្សាមិ ខ្ញុំព្រះករុណា នឹងធ្វើឱ្យជារបស់ខ្ញុំព្រះករុណា” ដូច្នេះ, ជាការឱ្យមិនប្រពៃ និងជាការកាន់យកមិនប្រពៃ ។

ភិក្ខុអ្នកលះបង់ឱ្យ មិនដឹងដើម្បីឱ្យ ( មិនដឹងវិធីលះបង់ឱ្យ ) ឡើយ, ចំណែកអ្នកទទួលក៏មិនដឹងដើម្បីទទួល ( មិនដឹងវិធីទទួល ) ។ ក៏បើកាលភិក្ខុដែលលះបង់ចេញ ឱ្យពោលថា “សូមលោកធ្វើឱ្យជារបស់លោកចុះ” ភិក្ខុដែលទទួលពោលថា “ល្អណាស់ លោកម្ចាស់ ខ្ញុំព្រះករុណានឹង

ទទួលយក” ហើយកាន់យក, ជាការឱ្យមិនត្រឹមត្រូវ តែជាការទទួលយកត្រឹមត្រូវ ។ ក៏បើមួយរូបពោលថា “លោកនឹងកាន់យកចុះ” មួយរូបទៀត (គឺអ្នកទទួល) ពោលថា “ខ្ញុំព្រះករុណានឹងមិនកាន់យក” អ្នកលះបង់ឱ្យនោះពោលទៀតថា “លោកចូរកាន់យករបស់ដែលខ្ញុំព្រះករុណាឱ្យហើយដើម្បីលោក” ចំណែកភិក្ខុក្រៅនេះពោលថា “ខ្ញុំព្រះករុណា មិនត្រូវការវត្ថុនេះទេ” ក្រោយអំពីនោះ សូម្បីរូបមុនក៏ឱ្យកន្លង ១០ ថ្ងៃទៅដោយយល់ថា “យើងឱ្យហើយ” ចំណែករូបក្រោយក៏ឱ្យកន្លង ១០ ថ្ងៃទៅដោយយល់ថា “យើងបានបដិសេធទៅហើយ” ត្រូវអាបត្តិដល់ភិក្ខុណា មិនមានអាបត្តិដល់ភិក្ខុណា ? មិនមានអាបត្តិដល់ភិក្ខុណាទេ, ក៏ភិក្ខុរូបណាពេញចិត្ត, ភិក្ខុរូបនោះ គប្បីអធិដ្ឋានប្រើប្រាស់ចុះ ។

ចំណែកភិក្ខុដែលមានសេចក្តីសង្ស័យក្នុងការអធិដ្ឋាន នឹងធ្វើយ៉ាងណា ? គប្បីប្រាប់សេចក្តីជាអ្នកសង្ស័យហើយពោលថា “បើចីវរមិនបានអធិដ្ឋាន កាលជាយ៉ាងនោះ ចីវរជារបស់គួរដល់ខ្ញុំព្រះករុណា” ហើយគប្បីលះបង់ចេញ ដោយន័យដូចពោលហើយនុ៎ះឯង ។ ព្រោះថា កាលភិក្ខុឱ្យដឹងយ៉ាងនេះហើយធ្វើវិន័យកម្ម មិនជាមុសាវាទ ។ តែអាចារ្យពួកខ្លះពោលថា ចីវរនោះ ភិក្ខុមួយរូបកាន់យកជាវិសាសៈហើយសងវិញ ក៏គួរ ។ ពាក្យរបស់អាចារ្យពួកខ្លះនោះមិនប្រពៃ ។ ព្រោះនោះ មិនមែនវិន័យកម្មរបស់ភិក្ខុដែលមានសេចក្តីសង្ស័យនោះ ។ ទាំងសំពត់នោះ ក៏

មិនជាវត្ថុដទៃ ដោយហេតុត្រឹមតែថា កាន់យកហើយឱ្យវិញនេះ ។

ពាក្យថា ឆស្សតិ : ចីវរបាត់ ជាដើម មានអត្ថងាយយល់ហើយនោះឯង ។

[៩] ក្នុងពាក្យថា យោ ន ទទេយ្យ អាបត្តិ ទុក្កដស្ស : ភិក្ខុណាមិនឱ្យ ភិក្ខុនោះត្រូវអាបត្តិទុក្កដ នេះ មានវិនិច្ឆ័យដូច្នេះ ៖

ត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលមិនឱ្យ ដោយការសម្គាល់នេះថា ភិក្ខុនេះឱ្យហើយដល់យើង ។ តែភិក្ខុដែលដឹងថា ជារបស់ភិក្ខុនោះ ហើយដណ្តើមយកដោយលេស ព្រះវិន័យធរគប្បីឱ្យវាយតម្លៃវត្ថុពិន័យអាបត្តិ ដូច្នេះឯង ។

ក្នុងសមុដ្ឋានជាដើម សិក្ខាបទនេះ ឈ្មោះថា កឋិនសមុដ្ឋាន រមែងកើតមកកាយវាចា កាយវាចាចិត្ត ជាអកិរិយា ព្រោះត្រូវដោយការមិនអធិដ្ឋានទិនមិនវិកប្ប ជានោសញ្ញាវិមោក្ខ ព្រោះមិនផុតដោយសញ្ញាសូម្បីមិនដឹងក៏ត្រូវ ជាអចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ពណ៌នាបឋមកឋិនសិក្ខាបទ ចប់

## ២. ឧទោសិតសិក្ខាបទវណ្ណនា

[១០] ឧទ្ទោសិតសិក្ខាបទថា តេន សមយេន ពុទ្ធោ ភគវា : សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ វិនិច្ឆ័យក្នុងឧទ្ទោសិតសិក្ខាបទនោះ គប្បីជ្រាបតទៅនេះ ៖

### ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងភិក្ខុច្រើនរូប

បទថា សន្តរុត្តរេន : តែស្បង់និងចីវរ មានសេចក្តីថា អន្តរវាសក (សំពត់ស្លៀក) ត្រាស់ហៅថា អន្តរៈ ។ ឧត្តរាសង្គៈ (សំពត់ដណ្តប់) ត្រាស់ហៅថា ឧត្តរៈ ។ សំពត់ដណ្តប់ទឹងសំពត់ស្លៀកឈ្មោះថា សន្តរុត្តរៈ ។ មានតែសំពត់ដណ្តប់ទឹងសំពត់ស្លៀកនោះ ។ អធិប្បាយថា ព្រមដោយសំពត់ឧត្តរាសង្គៈ និងសំពត់អន្តរវាសកៈ ។

បទថា កណ្ណកិតានិ : ឆ្អកជាំអស់ បានដល់ កើតរុះអុជសខ្មៅ ៗ ក្នុងឱកាសដែលញើសត្រូវ ។

ពាក្យថា អទ្ទសា ខោ អាយស្មា អានន្ទោ សេនាសនចារិកំ អាហិណ្ឌន្តោ : ព្រះអានន្ទដ៏មានអាយុបានទិមន្តទៅកាន់សេនាសនចារិក មានសេចក្តីថា បានឮថា ព្រះថេរៈកាលព្រះមានព្រះភាគស្តេចចូលកាន់

ព្រះគន្ធកុដិ ដើម្បីព្រះប្រាថ្នានឹងសម្រាកក្នុងពេលថ្ងៃ បានឱកាសនោះហើយ រក្សាភណ្ឌៈឈើ និងភណ្ឌៈដី ដែលរក្សាទុកមិនល្អ បោសសំអាតស្ថានទីដែលមិនបានបោសផ្ញើបដិសណ្ឋារៈនឹងពួកភិក្ខុអាពាធ ទៅដល់សេនាសនស្ថាននៃភិក្ខុទាំងនោះ បានឃើញហើយ ។ ព្រោះហេតុនោះទើបព្រះធម្មសង្គាហកាចារ្យពោលថា "ព្រះអានន្ទដ៏មានអាយុបានទិមន្តទៅកាន់សេនាសនចារិក ត្រឡេកទៅឃើញភិក្ខុទាំងនោះ" ។

## អនុប្បញ្ញត្តិពន្យល់អត្ថក្នុងរឿងភិក្ខុអាពាធ

[១១] ពាក្យថា អវិប្បវាសសម្មតឹ ទាតុំ : ឱ្យនូវសម្មតិដើម្បីឱ្យនៅប្រាសចាក មានសេចក្ដីថា សម្មតិក្នុងការមិននៅប្រាសចាក (ត្រៃចីវរ) ឈ្មោះអវិប្បវាសសម្មតិ ។ មួយទៀត សម្មតិ ដើម្បីការមិននៅប្រាសចាក (ត្រៃចីវរ) ឈ្មោះថា អវិប្បវាសសម្មតិ ។ ក៏ក្នុងអវិប្បវាសសម្មតិនេះ មានអានិសង្សយ៉ាងណា ? ភិក្ខុនៅប្រាសចាកចីវរផ្ទាំងណា, ចីវរផ្ទាំងនោះ រមែងមិនជានិស្សគ្គិយ និងភិក្ខុដែលនៅប្រាសចាកមិនត្រូវអាបត្តិ ។ នៅប្រាសចាកបានអស់វេលាប៉ុន្មាន ?

ព្រះមហាសុមត្ថេរៈពោលទុកមុនថា រយៈកាលដែលរោគមិនទាន់បាត់, តែកាលរោគបាត់ហើយភិក្ខុគប្បីប្រញាប់ត្រឡប់មកកាន់ស្ថានទីរក្សា

ចីវរ ដូច្នេះ ។ ព្រះមហាបទុមត្ថេរៈពោលថា កាលភិក្ខុនោះប្រញាប់ប្រញាល់មក រោគគប្បីត្រឡប់កម្រើកឡើង; ព្រោះដូច្នោះ គួរនឹងមកជាសន្សឹម ៗ (កុំប្រញាប់ពេក), ក៏ភិក្ខុនៅស្វែងរកពួករទេះ ឬថា ធ្វើសេចក្ដីចងចិត្តថា យើងនឹងទៅ ចាប់ផ្ដើមតាំងពីកាលណា, នឹងនៅប្រាសចាកចាប់តាំងពីកាលនោះទៅ ក៏គួរ, តែកាលភិក្ខុធ្វើការដាក់ធុរៈយ៉ាងនេះថា យើងមិនទៅក្នុងវេលានេះទេ គប្បីដកចេញ, ត្រៃចីវរដែលដកហើយនឹងតាំងនៅក្នុងឋានៈជាអតិរេកចីវរ ដូច្នេះ ។

សួរថា បើថា រោគរបស់លោកត្រឡប់កម្រើកឡើង, លោកនឹងធ្វើយ៉ាងណា ?

ឆ្លើយថា ព្រះបុស្សទេវត្ថេរៈ ពោលទុកមុនថា បើរោគនោះឯងត្រឡប់កម្រើកឡើង អវិប្បវាសសម្មុតិនោះឯង តាំងនៅជាសម្មុតិដដែល, មិនមានកិច្ចដែលនឹងត្រូវឱ្យសម្មុតិថ្មី; បើរោគដទៃកម្រើក, គប្បីឱ្យសម្មុតិថ្មី ដូច្នេះ ។ ព្រះឧបតិស្សត្ថេរៈពោលថា រោគនោះ ឬរោគដទៃក៏ដោយ ចូរលើកទុក, មិនមានកិច្ចដែលនឹងត្រូវឱ្យសម្មុតិថ្មី ដូច្នេះ ។

[១២] ចំណែកក្នុងបទថា **និដ្ឋិតចីវរស្មឹ ភិក្ខុនា : កាលបើចីវររបស់ភិក្ខុសម្រេចហើយ** នេះ បណ្ឌិតកុំកាន់យកអត្ថដូចក្នុងសិក្ខាបទមុន គប្បីជ្រាបអត្ថនៃតតិយាវិភត្តិ ដោយអំណាចនៃឆដ្ឋីវិភត្តិយ៉ាងនេះថា

**និដ្ឋិតេ ចីវរស្មឹ ភិក្ខុនោ :** កាលចីវររបស់ភិក្ខុសម្រេចហើយ ដូច្នេះ ។ ព្រោះអត្ថដោយអំណាចនៃតតិយាវិភត្តិថា កិច្ចឈ្មោះនេះ ដែលភិក្ខុគប្បីធ្វើដូច្នេះ មិនមាន, ប៉ុន្តែថា អត្ថដោយអំណាចនៃឆដ្ឋីវិភត្តិយ៉ាងនេះថា កាលចីវររបស់ភិក្ខុសម្រេចហើយ និងកាលកឋិនដោះហើយ បើភិក្ខុមានបលិពោធដាច់ហើយយ៉ាងនេះ គប្បីនៅប្រាសចាកត្រៃចីវរស្មូម្បីអស់មួយរាត្រី ដូច្នេះ រមែងសមគួរ (ព្រោះហេតុណា ; ព្រោះហេតុនោះ គប្បីជ្រាបអត្ថនៃតតិយាវិភត្តិ ដោយអំណាចឆដ្ឋីវិភត្តិ) ។

បណ្តាបទទាំងនោះ បទថា **តិចីវរេន :** ត្រៃចីវរ បានដល់ អំពីបណ្តាត្រៃចីវរដែលអធិដ្ឋានហើយ ចីវរផ្ទាំងណាមួយ ។ ពិតមែន ភិក្ខុសូម្បីនៅប្រាសចាកចីវរតែមួយផ្ទាំង ក៏ចាត់ថា ជាអ្នកនៅប្រាសចាកត្រៃចីវរ ព្រោះជាអ្នកនៅប្រាសចាក (ចីវរមួយផ្ទាំង) ដែលរាប់បញ្ចូលក្នុងសេចក្តីសម្រេចជាត្រៃចីវរ ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទថា **តិចីវរេន** នោះ ព្រះអង្គទើបត្រាស់ពាក្យថា **សង្ឃាដិយា** ជាដើម ។

បទថា **វិប្បវសេយ្យ :** នៅប្រាសចាក គឺ គប្បីជាអ្នកនៅប្រាសចាក ។

# អធិប្បាយស្ថានទីរក្សាចីវរនិងវិធីបដិបត្តិ

[១៣] ពាក្យថា គាមោ ឯកូបចារោ : ស្រុកមានឧបចារតែមួយជាដើម ត្រាស់ទុកដើម្បីឱ្យកំណត់លក្ខណៈនៃការមិននៅប្រាសចាក (ត្រៃចីវរ) ។

[១៤] តពីពាក្យថា គាមោ ឯកូបចារោ ជាដើមនោះទៅ ព្រះមានព្រះភាគកាលទឹងទ្រង់ពង្រីកបទមាតិកា ១៥ បទទាំងនោះឯង ឱ្យពិស្តារតាមលំដាប់ ទើបត្រាស់ថា គាមោ ឯកូបចារោ ឆាម : ស្រុកដែលឈ្មោះថា មានឧបចារតែមួយ ជាដើម ។

ក្នុងពាក្យថា គាមោ ឯកូបចារោ : ស្រុកមានឧបចារតែមួយនោះ មានវិនិច្ឆ័យដូច្នេះ ៖

ព្រះរាជវាំងរបស់ព្រះរាជាមួយព្រះអង្គ ឬផ្ទះរបស់ម្ចាស់ផ្ទះម្នាក់ឈ្មោះថា ផ្ទះរបស់ត្រកូលមួយ ។ បទថា បរិក្ខិត្តោ : ដែលគេរាំងព័ទ្ធរបងជុំវិញ មានសេចក្តីថា លោមព័ទ្ធហើយដោយកំពែង ដោយរបង ឬដោយប្រឡាយ យ៉ាងណាមួយ ។

លោកសម្តែងសេចក្តីដែលស្រុករបស់ត្រកូលមួយ មានឧបចារតែមួយ ដោយពាក្យមានប្រមាណត្រឹមតែប៉ុណ្ណោះ ។

ពីរបទថា អន្តោគាមេ វត្ថព្វំ : ហើយនៅក្នុងខាងក្នុងស្រុក

មានសេចក្ដីថា ភិក្ខុនឹងរក្សាចីវរទុកក្នុងស្រុកដូច្នេះហើយ ឱ្យអរុណរះក្នុងទីដែលខ្លួនពេញចិត្តក្នុងចន្លោះស្រុក រមែងគួរ ។

ដោយបទថា **អបរិក្ខិត្តោ : ដែលគេមិនបានរាំងព័ទ្ធរបងជុំវិញ** នេះ លោកសម្ដែងសេចក្ដីដែលស្រុកនោះឯង មានឧបចារផ្សេងគ្នា ។

ពាក្យថា តស្មិំ ឃរេ វត្ថព្វំ **: ត្រូវនៅក្នុងផ្ទះនោះ** មានសេចក្ដីថា គប្បីនៅក្នុងផ្ទះដែលខ្លួនរក្សាចីវរទុកក្នុងស្រុកបែបនោះ ។

ច្រើនបទថា ហត្ថបាសា វា ន វិជហិតព្វំ **: ហើយមិនត្រូវលះហត្ថបាសឡើយ** មានសេចក្ដីថា ម្យ៉ាងទៀត មិនគប្បីលះផ្ទះនោះអំពីហត្ថបាសដោយជុំវិញ ។ មានពាក្យអធិប្បាយថា មិនគប្បីលះឱ្យឆ្ងាយពីប្រទេសប្រមាណ ២ ហត្ថ ១ ចំអាមទៅទេ ។ ក៏ការនៅខាងក្នុង ២ ហត្ថ ១ ចំអាម រមែងសមគួរ ។ កន្លងហួសប្រមាណនោះទៅ បើសូម្បីភិក្ខុដែលមានឫទ្ធិ ញ៉ាំងអរុណឱ្យតាំងឡើង ក្នុងអាកាស ក៏ជានិស្សគ្គិយដូចគ្នា ។

ក៏បណ្ឌិតគប្បីជ្រាបការកំណត់ផ្ទះក្នុងបទថា យស្មិំ ឃរេ **: ក្នុងផ្ទះនោះ** ក្នុងវិស័យថា ផ្ទះរបស់ត្រកូលមួយនេះ ដោយលក្ខណៈជាដើមថា ជាផ្ទះរបស់ត្រកូលតែមួយ ដូច្នេះ ។

ពាក្យថា នានាកុលស្ស គាមោ **: ស្រុករបស់ត្រកូលផ្សេងគ្នា**

បានដល់ ដំណាក់នៃព្រះរាជាអន្តផ្សេងគ្នា ឬស្រុករបស់ពួកនាយស្រុក ផ្សេង ៗ ដូចក្រុងវេសាលីនិងក្រុងកុសិនារាជាដើម ។

ដោយបទថា **បរិក្ខិត្តោ : ដែលគេរាំងព័ទ្ធរបងជុំវិញ** នេះ លោកសម្តែងសេចក្តីដែលស្រុករបស់ត្រកូលផ្សេងគ្នា មានឧបចារជាមួយគ្នា ។

លោកពោលសភា ដោយលិង្គផ្ទុយគ្នា ក្នុងពាក្យថា សភាយេ វា ទ្វារមូលេ វា **: ក្នុងរោងជាទីប្រជុំ ឬទៀបទ្វារ** នេះ ថា សភាយំ ។

បទថា ទ្វារមូលេ **: ទៀបទ្វារ** បានដល់ ទីជិតទ្វារក្រុង ។ មានពាក្យអធិប្បាយថា ឬគប្បីនៅក្នុងផ្ទះដែលខ្លួនរក្សាចីវរទុក ក្នុងស្រុកបែប នោះ ។ កាលភិក្ខុមិនអាចនឹងនៅក្នុងផ្ទះនោះ ព្រោះសំឡេងអឺកធឹក ឬ ព្រោះមនុស្សប្រសេចប្រសាច គប្បីនៅក្នុងសភា ឬទីជិតទ្វារក្រុង ។ កាលមិនអាចនៅសូម្បីក្នុងសភា ឬក្នុងទីជិតទ្វារក្រុងនោះ គប្បីនៅក្នុងទីសប្បាយកន្លែងណាមួយ ហើយមកខាងក្នុងអរុណ មិនគប្បីលះអំពីហត្ថបាសនៃសភានិងទីជិតទ្វារក្រុងនោះឡើយ ។ ចំណែកកិច្ចដែលភិក្ខុគប្បីនៅក្នុងហត្ថបាសនៃផ្ទះ ឬនៃចីវរ មិនមានឡើយ ។

ពាក្យថា **សភាយំ គច្ឆន្តេន ហត្ថបាសេ ចីវរំ និក្ខិបិត្វា : កាលបើភិក្ខុទៅក្នុងរោងជាទីប្រជុំ ត្រូវទុកចីវរក្នុងហត្ថបាស** មានសេចក្តី

ថា បើថា ភិក្ខុមិនរក្សាទុកក្នុងផ្ទះ ទៅកាន់សភាដោយធ្វើទុកក្នុងចិត្តថា យើងនឹងរក្សាទុកត្រង់សភា, កាលភិក្ខុនោះ ទៅកាន់សភា គប្បីលាតដៃចេញទៅក្នុងហត្ថបាស រក្សាចីវរទុកត្រង់រានផ្សារណាមួយ ដែលជាមកនៃការរក្សាទុក គឺ នៅក្នុងហត្ថបាសយ៉ាងនេះថា "ណ្ហើយចុះ យើងនឹងរក្សាចីវរនេះទុក" ហើយគប្បីនៅត្រង់សភា ឬទីជិតទ្វារ ឬមិនគប្បីលះ (ចីវរ) អំពីហត្ថបាស ដោយន័យមុននុ៎ះឯង ។

## មតិផ្សេងៗ ក្នុងស្ថានទីរក្សានិងការរក្សាចីវរ

ក្នុងវិស័យថា សភាយេ វា ទ្វារមូលេ វា : ក្នុងរោងជាទីប្រជុំ ឬទៀបទ្វារ នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ព្រះបុស្សទេវត្ថេរៈ ពោលទុកមុនថា មិនមានកិច្ចចាំបាច់ត្រូវនៅក្នុងហត្ថបាសនៃចីវរ, នឹងនៅក្នុងទីណាមួយ នឹងជាហត្ថបាសថ្នល់ក្តី ហត្ថបាសសភាក្តី ហត្ថបាសទ្វារក្តី រមែងសមគួរទាំងអស់ ដូច្នេះ ។

ចំណែកព្រះឧបតិស្សត្ថេរៈ ពោលថា ក្រុងមានទ្វារច្រើន ក៏មានមានសភាច្រើនក៏មាន ; ព្រោះដូច្នោះ នឹងនៅក្នុងទីទូទៅ មិនសមគួរ, តែមិនគប្បីលះអំពីហត្ថបាសនៃសភានិងទ្វារ ដែលមាននៅក្នុងទីត្រង់មុខនៃថ្នល់ដែលខ្ញុំនរក្សាចីវរទុក, ពិតមែន កាលជាយ៉ាងនេះ អាចនឹងជ្រាបការប្រព្រឹត្តទៅនៃចីវរបាន ដូច្នេះ ។

តែកាលភិក្ខុទៅកាន់សភា រក្សាចីវរទុកក្នុងដៃរបស់ម្ចាស់រានផ្សារណាម្នាក់, បើម្ចាស់រានផ្សារនោះ បែរជានាំចីវរនោះទៅរក្សាទុកឯផ្ទះ, ហត្ថបាសថ្នល់ការពារមិនបាន, ភិក្ខុគប្បីនៅក្នុងហត្ថបាសនៃផ្ទះប៉ុណ្ណោះ ។ បើផ្ទះធំតាំងប្រក់គ្របរីកសាយទៅ រហូតដល់អស់ថ្នល់ពីរ, ភិក្ខុគប្បីឱ្យអរុណតាំងឡើងក្នុងហត្ថបាសមកខាងមុខ ឬមកខាងក្រោយ (នៃផ្ទះនោះ) ។ តែភិក្ខុរក្សា (ចីវរ)ផ្ញើទុកក្នុងសភា គប្បីឱ្យអរុណរះឡើងក្នុងសភា ឬ ទីជិតទ្វារក្រុង ត្រង់មុខសភានោះ ឬថា ក្នុងហត្ថបាសនៃសភា ឬ ទីជិតទ្វារក្រុងនោះឯង ។

ដោយបទថា **អបរិក្ខិត្តោ** : ដែលគេមិនបានរាំងព័ទ្ធទេ នេះលោកសម្ដែងសេចក្ដីដែលស្រុកនោះឯង មានឧបចារផ្សេងគ្នា ។ គប្បីជ្រាបសេចក្ដីមានឧបចារជាមួយគ្នា និងមានឧបចារផ្សេងគ្នាក្នុងបទទាំងពួងដោយឧបាយយ៉ាងនេះដូចគ្នា ។ តែក្នុងព្រះបាលីព្រះមានព្រះភាគ ទ្រង់លើកបទមាតិកាឡើងត្រឹមតែមួយបទ ដែលមាននៅក្នុងពាក្យដើមយ៉ាងនេះថា “ស្រុកឈ្មោះថា មានឧបចារតែមួយ” និងដែលតាំងនៅក្នុងទីបំផុតយ៉ាងនេះថា “ទីវាល ឈ្មោះថា មានឧបចារតែមួយ” ហើយពង្រីកបទភាជនៈឱ្យពិស្តារ ។ ព្រោះដូច្នោះ គ្រប់បទទាំងអស់ គប្បីជ្រាបសេចក្ដីមានឧបចារជាមួយគ្នា ដោយអំណាចនៃទីមានរបងជាដើម និងសេចក្ដីមានឧបចារផ្សេងគ្នា ដោយអំណាចនៃទីដែលមិនមានរបងជាដើម

ដោយ ទំនងនៃបទនោះឯង ។

[១៥] ក្នុងនិវេសន៍ (ផ្ទះសម្រាក)ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

បទថា ឱវរកា : បន្ទប់ នេះ ជាពាក្យហៅបន្ទប់ទាំងឡាយនោះ ។

បទថា ហត្ថបាសា វា : ហត្ថបាស បានដល់ ចាកហត្ថបាសនៃបន្ទប់ ឬនៃផ្ទះ ។

បទថា ទ្វារមូលេ : ទៀបទ្វារ បានដល់ ក្នុងទីជិតទ្វារផ្ទះដែលសាធារណៈដល់ជនទាំងពួងក្តី ។

បទថា ហត្ថបាសា វា : ហត្ថបាស បានដល់ ចាកហត្ថបាសនៃបន្ទប់ ឬនៃផ្ទះ ឬទីជិតទ្វារផ្ទះ ។

[១៦] ដែលឈ្មោះថា ឃ្លាំងរក្សារបស់ នោះ បានដល់ រោងរក្សាវត្ថុមានយានជំនិះជាដើម ។ ចាប់ផ្តើមតាំងពីឃ្លាំងរក្សាវត្ថុនេះទៅគប្បីជ្រាបវិនិច្ឆ័យ ដោយន័យដូចពោលហើយក្នុងផ្ទះសម្រាក ។

[១៧] ដែលឈ្មោះថា បញ្ញា (បន្ទាយ)នោះ បានដល់ ទីអាស្រ័យពិសេស ដែលគេបូកដោយឥដ្ឋ ដើម្បីការពារព្រះរាជាជាសត្រូវជាដើម មានជញ្ជាំងក្រាស់ មានផែនដី ៤-៥ ជាន់ ។

[១៨] ប្រាសាទមានជ្រុង ៤ ដែលសង្គ្រោះចូលដោយដំបូលតែ

មួយ ឈ្មោះ ថា ផុះដំបូលមួយ ។

[១៩] ប្រាសាទវែង ឈ្មោះថា ប្រាសាទ ។

[២០] ប្រាសាទដែលមានដំបូលកាត់ (ប្រាសាទមានដំបូលត្រងិល) ឈ្មោះ ថា ហម្មិយ ។

[២១] អព្ភន្តរនោះ លោកពោលទុកក្នុងពាក្យថា ៧ អព្ភន្តរ[១] នេះ ។

[២២] បទថា សត្ថោ : ពួកឈ្មួញរទេះ មានសេចក្តីថា បើពួករទេះទៅឈប់សម្រាកពាសពេញភូមិឬទន្លេ ជាប់តគ្នានឹងពួករទេះ ដែលចូលទៅខាងក្នុងដេរដាស់ទៅរហូតដល់អស់ត្រើយអាយ និងត្រើយនាយ រមែងបានបរិហារថា ពួករទេះពិត ។ បើពួករទេះ នៅជាប់គ្នានៅត្រង់ស្រុក ឬថា ក្នុងទន្លេ, ពួករទេះដែលចូលទៅ ខាងក្នុងហើយ រមែងបានបរិហារថា ស្រុកនិងបរិហារថា ទន្លេ ។ បើពួករទេះឈប់សម្រាកហួសវិហារសីមាទៅ, ចីវរនៅខាងក្នុងសីមា គប្បីទៅកាន់វិហារហើយនៅខាងក្នុងសីមានោះ, បើចីវរនៅខាងក្រៅសីមា, គប្បីនៅក្នុងទីជិតពួករទេះនុ៎ះឯង ។ បើពួករទេះកំពុងធ្វើដំណើរកាលរទេះបាក់ ឬគោបាត់ រមែងដាច់គ្នាក្នុងចន្លោះ, ចីវរដែលរក្សាទុកក្នុងចំណែកណា គប្បីនៅក្នុងចំណែកនោះ ។

---

១. ជ.ណ. ១អព្ភន្តរ = ៧ព្យាម គឺ ២៨ហត្ថ, ៧អព្ភន្តរ = ៤៩ព្យាម គឺ ១៩៦ហត្ថ ។

[២៣] ហត្ថបាសនៃចីវរនុ៎ះឯង ឈ្មោះថា ហត្ថបាសក្នុងស្រែចំការរបស់ត្រកូលតែមួយ ៗ ហត្ថបាសនៃទ្វារស្រែចំការឈ្មោះថា ហត្ថបាសក្នុងស្រែចំការរបស់ត្រកូលផ្សេងគ្នា, ហត្ថបាសនៃចីវរប៉ុណ្ណោះ ឈ្មោះថា ហត្ថបាសក្នុងស្រែចំការដែលមិនបានហោមព័ទ្ធ ៗ

[២៤] លាន លោកហៅថា ធញ្ញករណ៍ (លានបែនស្រូវ) ៗ

[២៥] សួនផ្កាឈើឬសួនផ្លែឈើលោកហៅថា សួន ៗ ក្នុងលានបែនស្រូវ និងសួនទាំងពីរ មានវិនិច្ឆ័យដូចដែលពោលហើយក្នុងស្រែចំការនុ៎ះឯង ៗ

[២៦] ក្នុងបទថា វិហារេ : លំនៅ ក៏មានវិនិច្ឆ័យដូចគ្នានឹងផ្ទះសម្រាកនុ៎ះឯង ៗ

[២៧] ក្នុងរុក្ខមូល គប្បីជ្រាបវិនិច្ឆ័យ ដូច្នេះ ៖

បទថា អន្តោឆាយាយ គឺ ចំពោះខាងក្នុងឱកាសដែលម្លប់ជះទៅដល់ ៗ តែចីវរដែលភិក្ខុរក្សាទុកក្នុងឱកាសដែលកម្តៅថ្ងៃត្រូវ នៃដើមឈើមានមែកស្រឡះ ជានិស្សគ្គិយពិត ៗ ព្រោះដូច្នោះ ភិក្ខុគប្បីរក្សាចីវរទុកត្រង់ម្លប់នៃមែកឈើ ឬត្រង់ម្លប់នៃដើមរបស់ដើមឈើដូច្នោះ ៗ បើទឹងរក្សាទុកលើមែកឬលើបង្ខាប, គប្បីដាក់ទុកក្នុងឱកាសដែលម្លប់នៃមែកឈើដើមដទៃខាងលើជះទៅដល់ប៉ុណ្ណោះ ៗ ម្លប់របស់ដើមឈើតឿ

រមែងបែកមែករីករាលទៅឆ្ងាយ, គប្បីរក្សាទុកក្នុងឱកាសដែលម្លប់ជះទៅត្រូវ ។ គួរទីងរក្សាទុកក្នុងទីម្លប់ក្រាស់ប៉ុណ្ណោះ ។ ហត្ថបាស សូម្បីក្នុងអធិការនៃគល់ឈើនេះ ក៏គឺ ហត្ថបាសនៃចីវរនុ៎ះឯង ។

[២៨] ពាក្យថា អគាមកេ អរញ្ញេ : ទីក្នុងព្រៃដែលឥតមានស្រុក មានសេចក្ដីថា ព្រៃដែលឈ្មោះថា មិនមែនជាស្រុក រមែងបានក្នុងព្រៃភ្លើងមិនឆេះ (ព្រៃវិជ្ឈាដវី)ជាដើម ឬលើពួកកោះ ដែលមិនជាមកត្រាច់ទៅរបស់ពួកអ្នកប្រមង់ (នេសាទ) នៅកណ្ដាលសមុទ្រ ។

ពាក្យថា សមន្តា សត្តព្ភន្តរា : ចំនួន៧អព្ភន្តរដោយជុំវិញ មានសេចក្ដីថា ៧ អព្ភន្តរ ក្នុងទិសទាំងពួងនៃបុគ្គលអ្នកឈរត្រង់កណ្ដាល រួមជា ១៤ អព្ភន្តរ ដោយសងខាង ។ ភិក្ខុអង្គុយនៅកណ្ដាល រមែងរក្សាចីវរដែលរក្សាទុកក្នុងទីបំផុតជុំវិញនៃទិសខាងកើត ឬទិសខាងលិច ។ តែបើថា ភិក្ខុដើរទៅកាន់ទិសខាងកើត សូម្បីត្រឹមតែមួយសរសៃសក់ក្នុងវេលាអរុណរះឡើង ចីវរក្នុងទិសខាងលិចជានិស្សគ្គិយ ។ ក្នុងចីវរក្រៅពីនេះក៏ន័យនេះ ។ ក៏ឯក្នុងវេលាធ្វើឧបោសថ គប្បីជម្រះសត្តព្ភន្តរសីមាឱ្យហួតចត់តាំងពីភិក្ខុដែលអង្គុយក្នុងទីបំផុតនៃបរិស័ទ ។ ភិក្ខុសង្ឃពង្រីកទៅរហូតដល់អស់ទីប្រមាណប៉ុន្មាន, សូម្បីសីមាក៏ពង្រីកចេញទៅរហូតដល់អស់ទីប្រមាណប៉ុណ្ណោះ ។

[៣០] ក្នុងពាក្យថា អនិស្សជ្ជិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស : ភិក្ខុមិនបានលះ(ចីវរនិស្សគ្គិយ) ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ នេះ អាចារ្យពួកខ្លះពោលថា បើភិក្ខុដែលប្រកបសេចក្ដីព្យាយាម បំពេញព្យាយាមរហូតអស់ ១ យប់, ដល់ព្រឹកព្រលឹមដាក់ចិត្តថា "យើងនឹងស្រង់ទឹកក្នុងវេលាជិតភ្លឺ" ទើបចេញទៅ ដាក់ចីវរទាំង ៣ ផ្ទាំងទុកត្រង់ប្រាំងទន្លេ ហើយចុះកាន់ទន្លេ, ក៏កាលលោកកំពុងងូតទឹកនៅឯងអរុណរះឡើង, លោកគប្បីធ្វើយ៉ាងណា ? ឆ្លើយថា បើលោកឡើងមកហើយស្លៀកដណ្ដប់ចីវរ, រមែងត្រូវទុក្កដ ព្រោះមិនទាន់លះបង់ចីវរដែលជានិស្សគ្គិយ ហើយប្រើប្រាស់ជាបច្ច័យ, បើលោកអាក្រាតកាយទៅសូម្បីដោយការអាក្រាតកាយទៅយ៉ាងនោះ ក៏ត្រូវទុក្កដ ។

ឆ្លើយថា លោកមិនត្រូវ, ព្រោះថា លោកតាំងនៅក្នុងឋានៈ នៃភិក្ខុដែលមានចីវរបាត់ ព្រោះចីវរទាំងនោះ ជារបស់មិនគួរបរិភោគ ដរាបដែលនៅមិនទាន់ជួបភិក្ខុរូបដទៃហើយធ្វើវិន័យកម្ម, និងឈ្មោះថា វត្តដែលមិនសមគួរដល់ភិក្ខុដែលមានចីវរបាត់ មិនមាន ; ព្រោះដូច្នោះ លោកគប្បីស្លៀកមួយផ្ទាំង យកដៃកាន់ពីរផ្ទាំងទៅកាន់វិហារហើយធ្វើវិន័យកម្ម ។ បើថា វិហារនៅឆ្ងាយ, ក្នុងចន្លោះមកមានពួកអ្នកស្រុកសញ្ចរទៅមក, លោកជួបពួកអ្នកស្រុកទាំងនោះ គប្បីស្លៀកមួយផ្ទាំង

ដណ្តប់ផ្ទាំងមួយ ដាក់ផ្ទាំងមួយទុកលើនឹងចង្កួយស្មាហើយគប្បីដើរទៅ ។ ប្រសិនបើមិនជួបភិក្ខុដែលសភាគគ្នាក្នុងវិហារ, ភិក្ខុទាំងឡាយត្រាច់ទៅភិក្ខាចារ, លោកគប្បីដាក់សំពត់សង្ឃាដិទុកខាងក្រៅស្រុក ទៅកាន់រោងឆាន់ ដោយសំពត់ឧត្តរាសង្គជាមួយអន្តរវាសកហើយ ធ្វើវិន័យកម្ម ។ បើខាងក្រៅស្រុក មានចោរភ័យ គប្បីដណ្តប់សង្ឃាដិទៅផង, បើរោងឆាន់ចង្អៀតមានមនុស្សប្រសេចប្រសាច, លោកមិនអាចដោះចីវរចេញធ្វើវិន័យកម្មក្នុងផ្ទែកមួយបាន, គប្បីនាំភិក្ខុមួយរូបទៅក្រៅស្រុកធ្វើវិន័យកម្មហើយប្រើប្រាស់ចីវរទាំងឡាយចុះ ។

បើភិក្ខុទាំងឡាយ ឱ្យបាត្រនិងចីវរទុកក្នុងដៃនៃភិក្ខុកម្លោះទាំងឡាយកំពុងធ្វើដំណើរទៅ មានសេចក្តីប្រាថ្នានឹងដេកក្នុងបច្ឆិមយាម, គប្បីធ្វើចីវររបស់ខ្លួន ៗ ទុកក្នុងហត្ថបាសមុនហើយទើបដេក ។ បើកាលពួកភិក្ខុកម្លោះមកមិនទាន់ អរុណរះដល់ព្រះថេរៈទាំងឡាយអ្នកកំពុងដើរទៅនុ៎ះឯង, ចីវរទាំងឡាយ រមែងជានិស្សគ្គិយ ។ ចំណែកនិស្ស័យមិនរម្ងាប់ ។ កាលពួកភិក្ខុកម្លោះដើរខាងមុខទៅមុនក្តី ព្រះថេរៈទាំងឡាយដើរតាមមិនទាន់ក្តី មានន័យយ៉ាងនេះដូចគ្នា ។ សូម្បីកាលភិក្ខុទាំងឡាយបែកមកគ្នា មិនឃើញគ្នា ក្នុងព្រៃក៏មានន័យយ៉ាងនេះដូចគ្នា ។ ក៏បើពួកភិក្ខុកម្លោះឆ្លើយប្រាប់ថា លោកម្ចាស់ ពួកខ្ញុំព្រះករុណានឹង ដេក

សម្រាកតែមួយភ្លេតហើយ នឹងតាមទៅទាន់ពួកលោកក្នុងឱកាសឈ្មោះឯណោះ ដូច្នេះហើយ ដេកនៅដរាបអរុណរះ, ចីវរជានិស្សគ្គិយផង និស្ស័យក៏រម្ងាប់ផង ។ សូម្បីកាលព្រះថេរៈទាំងឡាយ បញ្ជូនពួកភិក្ខុកម្លោះទៅមុនហើយដេក ក៏មានន័យយ៉ាងនេះដូចគ្នា ។ ជួបមកបែកជាពីរ ព្រះថេរៈទាំងឡាយប្រាប់ថា មកនេះ, ពួកភិក្ខុកម្លោះឆ្លើយប្រាប់ថា មកនោះវិញ មិនជឿតាមពាក្យរបស់គ្នានិងគ្នា ចេញទៅ (បែកមកគ្នាទៅ), សូម្បីព្រមគ្នានឹងអរុណរះ ចីវរទាំងឡាយជានិស្សគ្គិយ និងនិស្ស័យរមែងរម្ងាប់ ។

បើពួកភិក្ខុកម្លោះចេញពីមកឆៀងចូលស្រុក ពោលថា "ពួកយើងនឹងត្រឡប់មកឱ្យទាន់ខាងក្នុងអរុណតែម្តង ហើយខ្ញុំព្រះករុណាទៅកាន់ស្រុកដើម្បីត្រូវការភេសជ្ជៈ" កំពុងដើរមក, វេលាដែលពួកលោកត្រឡប់មកមិនទាន់ដល់នុ៎ះឯង អរុណក៏រះឡើង ចីវរទាំងឡាយជានិស្សគ្គិយ, តែនិស្ស័យមិនរម្ងាប់ ។ ក៏បើថា ពួកលោកពោលថា "ពួកយើងឈរត្រឹមតែមួយភ្លេតហើយនឹងទៅ" ហើយឈរ ឬអង្គុយ ព្រោះខ្លាចមេគោ (មេគោកូនខ្ចី) ឬព្រោះខ្លាចសុនខហើយទើបដើរទៅ, កាលអរុណរះក្នុងចន្លោះមក ចីវរទាំងឡាយជានិស្សគ្គិយផង និស្ស័យក៏រម្ងាប់ផង ។ កាលភិក្ខុទាំងឡាយ (កាលអាចារ្យនិងអន្តេវាសិក) ចូលទៅកាន់ស្រុកខាងក្នុង

សីមាដោយគិតថា “យើងនឹងមកខាងក្នុងអរុណរះនោះឯង” អរុណរះក្នុងចន្លោះ, ចីវរទាំងឡាយមិនជានិស្សគ្គិយ និស្ស័យក៏មិនរម្ងាប់ ។ ក៏បើថាភិក្ខុទាំងឡាយអង្គុយដោយមិនគិតថា “រាត្រីចូរភ្លឺ ឬមិនភ្លឺក៏ដោយ” សូម្បីកាលអរុណរះហើយ ចីវរមិនជានិស្សគ្គិយ តែនិស្ស័យ រមែងរម្ងាប់ ។

ក៏ភិក្ខុពួកណាចូលទៅកាន់រោងខាងក្រៅឧបចារសីមា ទាំងដែលនៅមានឧស្សាហ៍ថា “យើងនឹងមកខាងក្នុងអរុណនុ៎ះឯង ដើម្បីប្រយោជន៍ដល់កម្ម មានឧបសម្បទាកម្មជាដើម” ពួកលោកនៅត្រង់រោងនោះឯងអរុណក៏តាំងឡើង ចីវរជានិស្សគ្គិយ តែនិស្ស័យមិនរម្ងាប់ ។ ភិក្ខុទាំងឡាយចូលទៅកាន់រោងនោះឯង ខាងក្នុងឧបចារសីមា, កាលអរុណតាំងឡើង ចីវរមិនជានិស្សគ្គិយ និស្ស័យក៏មិនរម្ងាប់ ។ តែភិក្ខុពួកណា នៅមានឧស្សាហ៍ទៅកាន់វិហារជិត ៗ ដើម្បីប្រាថ្នានឹងស្តាប់ធម៌តាំងចិត្តថានឹងមកឱ្យទាន់ខាងក្នុងអរុណ, តែអរុណរះទៅដល់ពួកលោកក្នុងចន្លោះមកនុ៎ះឯង ចីវរទាំងឡាយជានិស្សគ្គិយ តែនិស្ស័យមិនទាន់រម្ងាប់ ។ បើពួកលោកអង្គុយនៅដោយគោរពក្នុងធម៌ថា ពួកយើងស្តាប់ដរាបចប់ហើយទើបទៅ ព្រមគ្នានឹងអរុណរះឡើង សូម្បីចីវរទាំងឡាយក៏ជានិស្សគ្គិយ ទាំងនិស្ស័យក៏រម្ងាប់ ។

ព្រះថេរៈ កាលនឹងបញ្ជូនភិក្ខុកម្លោះទៅកាន់ចន្លោះស្រុក ដើម្បីត្រូវការបោកចីវរ គប្បីបច្ចុទ្ធរណ៍ចីវររបស់ខ្លួនសិនហើយ សឹមឱ្យ ។ សូម្បីចីវររបស់ភិក្ខុកម្លោះ ក៏គប្បីឱ្យបច្ចុទ្ធរណ៍ហើយរក្សាទុក ។ បើភិក្ខុកម្លោះទៅ សូម្បីដោយមិនមានសតិ, ព្រះថេរៈគប្បីដកចីវររបស់ខ្លួនហើយកាន់យកចីវររបស់ភិក្ខុកម្លោះដោយវិសាសៈ គប្បីរក្សាទុក ។ បើព្រះថេរៈរលឹកមិនបាន តែភិក្ខុកម្លោះរលឹកបាន ភិក្ខុកម្លោះគប្បីដកចីវររបស់ខ្លួន ហើយកាន់យកចីវររបស់ព្រះថេរៈដោយវិសាសៈ ហើយទៅឆ្លើយប្រាប់ថា "លោកម្ចាស់ សូមលោកម្ចាស់អធិដ្ឋានចីវររបស់លោកម្ចាស់ហើយនិមន្តប្រើប្រាស់ចុះ" ។ ចីវររបស់ខ្លួន លោកក៏គប្បីអធិដ្ឋាន ។ សូម្បីដោយសេចក្តីរលឹកបានរបស់ភិក្ខុមួយរូប យ៉ាងនេះ ក៏រមែងផុតអាបត្តិបាន ។ ពាក្យដ៏សេស មានអត្ថដែលងាយយល់ទាំងអស់ ។

បណ្ណាបកិណ្ណកៈ មានសមុដ្ឋានជាដើម ក្នុងបឋមកឋិនសិក្ខាបទជាអកិរិយាគឺ មិនអធិដ្ឋានទិនមិនវិកប្ប ក្នុងសិក្ខាបទនេះ ជាអកិរិយា គឺមិនបច្ចុទ្ធរណ៍ (មិនដក) យ៉ាងនេះប៉ុណ្ណោះជាសេចក្តីប្លែកគ្នា ។ ពាក្យដ៏សេស ក្នុងឋានៈទាំងអស់មានន័យដូចពោលហើយទាំងនោះឯង ។

ពណ៌នាឧទ្ទោសិតសិក្ខាបទ ចប់

# ៣. អកាលចីវរសិក្ខាបទវណ្ណនា

[៣២] តតិយកឋិនសិក្ខាបទថា តេន សមយេន : សម័យ នោះ ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ គប្បីជ្រាបវិនិច្ឆ័យតតិយក ឋិនសិក្ខាបទ ដូចតទៅនេះ ៖

## ពន្យល់អត្ថក្នុងរឿងភិក្ខុមួយរូប

ព្រេចីនបទថា ឧស្សាបេត្វា បុនប្បុនំ វិមជ្ជតិ : លើក(ចីវរ) ឡើង ហើយទាញឱ្យតឹង ធ្វើឱ្យយឺតសាចសំពត់នោះរឿយ ៗ មាន សេចក្តីថា ភិក្ខុនោះ សម្គាល់ថា កាលស្នាមរួញបាត់ហើយ ចីវរនេះ នឹង ធំឡើង ទើបយកទឹកស្រោចយកជើងជាន់ យកដៃទាញឡើងហើយរឹត ត្រង់ខ្នង ។ ចីវរនោះស្ងួតហើយដោយកម្តៅថ្ងៃ ក៏មានប្រមាណប៉ុនដើម វិញទុំះឯង ។ ភិក្ខុនោះក៏ធ្វើយ៉ាងនោះ ដដែលទៀត ។ ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យ ទើបពោលថា "លើកចីវរឡើងហើយ ទាញឱ្យ តឹង ធ្វើឱ្យយឺតសាច់សំពត់នោះរឿយ ៗ" ព្រះមានព្រះភាគគង់ប្រថាប់ក្នុង ព្រះគន្ធកុដិទុំះឯង ទតឃើញភិក្ខុនោះលំបាកយ៉ាងនោះ ទើបស្តេចចេញ ដូចស្តេចយាងទៅកាន់សេនាសនចារិក បានស្តេចទៅក្នុងទីនោះ ។ ព្រោះ ហេតុនោះ ព្រះធម្មសង្គាហកាចារ្យ ទើបពោលថា អទ្ទសា ខោ ភគវា : លុះទ្រង់ទតឃើញហើយ ជាដើម ។

[៣៤] បទថា ឯកាទសមាសេ : ក្នុងឱកាស ១១ ខែ បានដល់ រហូតដល់

អស់ ១១ ខែដែលសល់ វៀរខែកត្តិកចុងក្រោយមួយខែ[១] ។

បទថា សត្តមាសេ : ក្នុងឱកាស ៧ ខែ បានដល់ ៧ ខែដែលសល់ វៀរ ៥ ខែ គឺ ខែកត្តិកនោះផង ៤ ខែរដូវវស្សារផង ។

## ពន្យល់អត្ថក្នុងសិក្ខាបទវិភង្គសេចក្តីប្រាថ្នានឹងបានចីវរ

ច្រើនបទថា កាលេបិ អាទិស្ស ទិន្នំ : ជាកាលចីវរ ហើយឱ្យក៏ដោយ មានសេចក្តីថា ចីវរដែលទាយកប្រគេនឧទ្ទិសដល់សង្ឃថា "នេះជាអកាលចីវរ" ឬ ដែលទាយកប្រគេនដល់បុគ្គលមួយថា "ខ្ញុំព្រះករុណាថ្វាយចីវរនេះ ដល់លោក ម្ចាស់" ដូច្នេះ ។

បទថា សង្ឃតោ វា : អំពីសង្ឃក្តី មានសេចក្តីថា ចីវរកើតឡើងអំពីសង្ឃដោយអំណាចនៃចំណែកដែលត្រូវបានខ្លួនក្តី ។

បទថា គណតោ វា : អំពីគណៈក្តី មានសេចក្តីថា ពួកទាយករមែងប្រគេនដល់គណៈយ៉ាងនេះថា "ពួកខ្ញុំព្រះករុណាប្រគេនចីវរនេះ

---

១. គឺ ១ រោចខែអស្សុជ ដល់ ១៥ កើត ខែកត្តិក ។

ដល់គណៈនៃភិក្ខុដែលរៀនព្រះសូត្រ, ថ្វាយចីវរនេះដល់គណៈនៃភិក្ខុដែលរៀនព្រះអភិធម្ម” ចីវរគប្បីកើតឡើងអំពីគណៈនោះ ដោយអំណាចនៃចំណែកដែលត្រូវបានខ្លួនក្តី ។

[៣៦] ពាក្យថា **នោ ចស្ស ធារិបូរិ : បើចីវរនោះខ្វះធ្វើមិនគ្រាន់ទេ** គឺ បើសំពត់នោះ មិនទាន់ល្មម ។ អធិប្បាយថា ចីវរដែលគួរអធិដ្ឋានបាន ដែលភិក្ខុធ្វើដោយសំពត់ប្រមាណប៉ុន្មាន ទើបនឹងល្មម, បើចីវរនោះ ប្រមាណប៉ុណ្ណោះមិនទាន់មាន គឺ នៅខ្វះ ។

ក្នុងពាក្យថា **បច្ចាសា ហោតិ សង្ឃតោ វា : មានសេចក្តីសង្ឃឹមថា នឹងបានអំពីសង្ឃក្តី** ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

មានសេចក្តីប្រាថ្នាអំពីសង្ឃ ឬអំពីគណៈ យ៉ាងនេះថា ក្នុងថ្ងៃឈ្មោះឯណោះ សង្ឃនឹងបានចីវរ, គណៈនឹងបានចីវរ, ចីវរនឹងកើតឡើងដល់យើងអំពីសង្ឃ ឬអំពីគណៈនោះ ។ម្យ៉ាងទៀត សេចក្តីថា មានសេចក្តីប្រាថ្នាអំពីញាតិ ឬអំពីមិត្ត យ៉ាងនេះថា “សំពត់ពួកញាតិបញ្ជូនមកហើយ ពួកមិត្តបញ្ជូនមកហើយដល់យើងដើម្បីប្រយោជន៍ដល់ចីវរ, ជនទាំងនោះមកហើយ នឹងប្រគេនចីវរ” ។

ក៏[៨]ក្នុងបទថា **បំសុកូលតោ វា : អំពីបង្សុកូលក្តី** អ្នកសិក្សាគប្បីប្រកបពាក្យថា មានសេចក្តីប្រាថ្នានឹងបាន យ៉ាងនេះថា យើងនឹង

បានសំពត់បង្សុកូលក៏ដោយ ។

ពីរបទថា អត្តនោ វា ធនេន : អំពីទ្រព្យរបស់ខ្លួនក្តី សេចក្តីថា មានសេចក្តីប្រាថ្នាយ៉ាងនេះថា យើងនឹងបានក្នុងថ្ងៃឈ្មោះឯណោះ ដោយទ្រព្យមានកប្បាស និងអំបោះជាដើមរបស់ខ្លួនក៏ដោយ ។

[៣៧] ពាក្យថា តតោ ចេ ឧត្តរឹ និក្ខិបេយ្យ សតិយាបិ បច្ចាសាយ : លើសអំពីមួយខែនោះទៅ ទុកជាមានបំណងថា នឹងរកចីវរមកបំពេញទៀតក៏ដោយ មានសេចក្តីថា ប្រសិនបើភិក្ខុរក្សាទុកឱ្យយូរជាងមួយខែជាយ៉ាងក្រៃលែង, ជានិស្សគ្គិយបាចិត្តិយ ។

តែព្រះមានព្រះភាគមិនត្រាស់ទុកយ៉ាងនេះ ព្រោះកាលចីវរដែលប្រាថ្នានឹងបានមកកើតឡើងក្នុងចន្លោះ ចីវរដែលប្រាថ្នានឹងបានមក ដែលកើតឡើងតាំងពីថ្ងៃដែលចីវរដើមកើតឡើងទៅ ដរាបដល់ថ្ងៃទី ២០ រមែងធ្វើចីវរដើមឱ្យមានគតិនៃខ្លួន, តពីថ្ងៃទី ២០ នោះទៅ ចីវរដើមរមែងធ្វើចីវរដែលប្រាថ្នានឹងបានមក ឱ្យមានគតិនៃខ្លួន ; ក៏ព្រោះហេតុនោះ ដើម្បីទ្រង់សម្តែងសេចក្តីពិសេសនោះ ទើបត្រាស់បទភាជនៈដោយន័យមានជាដើមថា តទហុប្បន្នេ មូលចីវរេ : កាលបើមូលចីវរកើតឡើងក្នុងថ្ងៃនោះហើយ ដូច្នេះ ។ ពាក្យថា តទហុប្បន្នេ : កើតឡើងក្នុងថ្ងៃនោះហើយ ជាដើម មានអត្ថជាក់ច្បាស់ហើយតែម្តង ។

[៣៨] ពាក្យថា វិសភាគេ ឧប្បន្នេ មូលចីវរេ : កាលបើមូលចីវរមានចំណែកមិនស្មើគ្នាកើតឡើងហើយ មានសេចក្តីថា បើថាចីវរដើមសាច់ល្អិត ចីវរដែលប្រាថ្នានឹងបានមក សាច់គ្រោតគ្រាត មិនអាចដើម្បីប្រកបចូលគ្នាបាន រាត្រីក៏នៅមានសល់ និងខែមិនទាន់ពេញនៅឡើយ ។

បទថា ន អកាមា : បើភិក្ខុមិនចង់ធ្វើទេ ក៏មិន(ត្រូវធ្វើ) មានសេចក្តីថា ភិក្ខុកាលមិនប្រាថ្នា ក៏មិនគប្បីឱ្យធ្វើចីវរ ។ បានចីវរដែលប្រាថ្នានឹងបានមកដទៃហើយប៉ុណ្ណោះ គប្បីធ្វើខាងក្នុងកាល ។ សូម្បីចីវរដែលប្រាថ្នានឹងបានមក គប្បីអធិដ្ឋានជាបរិក្ខារចោឡៈ ។ បើចីវរពីដើមជាសំពត់សាច់គ្រោតគ្រាត, ចីវរដែលប្រាថ្នានឹងបានមកជាសំពត់សាច់ល្អិត, គប្បីអធិដ្ឋានចីវរដើមឱ្យជាបរិក្ខារចោឡៈ ហើយរក្សាចីវរដែលប្រាថ្នានឹងបានមកនុ៎ះឯង ឱ្យជាចីវរដើម ។ ចីវរនោះ រមែងបានបរិហារមួយខែទៀត ភិក្ខុរមែងគួរដើម្បីធ្វើការផ្លាស់ប្តូរគ្នានិងគ្នារក្សាទុកជាចីវរដើមដរាបប៉ុនដែលខ្លួនប្រាថ្នា ដោយឧបាយនេះនុ៎ះឯង ។ ពាក្យដ៏សេសមានអត្ថងាយយល់ទាំងអស់ ។ បកិណ្ណកៈ មានសមុដ្ឋានជាដើម ក៏ដូចគ្នានឹងបឋមកឋិនសិក្ខាបទនោះឯង ។

ពណ៌នាអកាលចីវរសិក្ខាបទទី ៣ ចប់

# ៤. បុរាណចីវរសិក្ខាបទវណ្ណនា

[៤២] បុរាណចីវរសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងបុរាណចីវរសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

## អធិប្បាយបុគ្គលដែលចាត់ជាញាតិនិងមិនមែនញាតិ

[៤៣] ពាក្យថា យាវ សត្តមា បិតាមហយុគា : ដរាបដល់គូនៃជីដូនជីតាជាគម្រប់៧ មានសេចក្តីថា បិតារបស់បិតាឈ្មោះថា បិតាមហៈ ។ យុគនៃបិតាមហៈ ឈ្មោះថា បិតាមហយុគ ។ ប្រមាណនៃអាយុលោកហៅថា យុគ ។ ក៏ស័ព្ទថា យុគ នេះ ត្រឹមតែជាវោហារនិយាយគ្នាប៉ុណ្ណោះ ។ តែដោយសេចក្តី បិតាមហៈនុ៎ះឯង ឈ្មោះថា បិតាមហយុគ ។ បព្វៈបុរស បន្ទាប់ឡើងទៅអំពីបិតាមហយុគនោះ សូម្បីទាំងអស់ ព្រះមានព្រះភាគ ទ្រង់កាន់យកដោយបិតាមហស័ព្ទនុ៎ះឯង ។ នាងភិក្ខុនី ដែលមិនជាប់ពាក់ព័ន្ធគ្នាមកដរាបដល់ ៧ ជួរបុរសយ៉ាងនេះ ត្រាស់ហៅថា ភិក្ខុនីដែលឥតមានជាប់ទាក់ទងដរាបដល់ ៧ តំណប្រមាណនៃអាយុរបស់បិតាមហ( បុព្វបុរស ) ។ បិតាមហ ស័ព្ទនេះ ជាមុខនៃទេសនាប៉ុណ្ណោះ ។ តែព្រោះព្រះបាលីថា មាតិតោ វា បីតិតោ វា : អំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដូច្នេះ បិតាម

ហយុគក្តី បិតាមហីយុគក្តី មាតាមហយុគក្តី មាតាមហីយុគក្តី ក៏ឈ្មោះថា បិតាមហយុគ, សូម្បីពួកញាតិ មានបងប្អូនប្រុស បងប្អូនស្រី ក្មួយ កូន និងចៅជាដើម របស់បិតាមហយុគជាដើម សូម្បីទាំងអស់នោះ គប្បីជ្រាបថា ទ្រង់សង្គ្រោះចូលក្នុងពាក្យថា **បិតាមហយុគ** នេះ ទាំងអស់ ។

ក្នុង៤ យុគ គឺ បិតាមហយុគ បិតាមហីយុគ មាតាមហយុគ និងមាតាមហីយុគនោះ មានន័យពិស្តារដូចតទៅនេះ ៖

ភិក្ខុនី ដែលឥតមានជាប់ទាក់ទងគ្នាដោយផ្នែកខាងមាតាក្តី និងខាងបិតាក្តី ដរាបដល់គូនៃជីដូនជីតាជាគម្រប់ ៧ ជួរយ៉ាងនេះ គឺ បិតា១, បិតារបស់បិតា(តា) ១, បិតារបស់តានោះ (តាទួត)១, បិតាសូម្បីរបស់បិតានោះ (តាលួត)១ ជាដើម ។

គូដរាបដល់ ៧ជួរ ទាំងខាងលើ និងខាងក្រោម; សូម្បីយ៉ាងនេះ គឺ បិតា១ មាតារបស់បិតា(យាយ)១ បិតានិងមាតារបស់មាតាសូម្បីនោះ (តាទួតយាយទួត)១ បងប្អូនប្រុស១ បងប្អូនស្រី១ បុត្រ១ ធីតា១ ។

គូដរាបដល់ ៧ ជួរ សូម្បីយ៉ាងនេះ គឺ បិតា, បងប្អូនប្រុសរបស់បិតា (អ៊ំពូ), បងប្អូនស្រីរបស់បិតា (អ៊ំមីង), កូនប្រុសរបស់បិតា (បងប្អូនប្រុស), កូនស្រីរបស់បិតា (បងប្អូនស្រី), សូម្បីពូជពង្សវង្សត្រកូលឡាយបុត្រធីតារបស់ជនទាំងនោះ ។

គូដរាបដល់ ៧ ជួរ យ៉ាងនេះ គឺ មាតា, មាតារបស់មាតា

( យាយ ), មាតារបស់យាយនោះ ( យាយទួត ) មាតារបស់យាយទួតនោះ ( យាយលួត )ជាដើម ។

គូដរាបដល់ ៧ជួរ ទាំងខាងលើនិងខាងក្រោម ស្តូម្បីយ៉ាងនេះ គឺ មាតា ១ បិតារបស់មាតា ( តា )១ បិតានិងមាតារបស់តានោះ ( តាទួតយាយទួត )១ បងប្អូនប្រុស១ បងប្អូនស្រី១ បុត្រ១ ធីតា១ ជាដើម ។

គូដរាបដល់ ៧ ជួរ ស្តូម្បីយ៉ាងនេះ គឺ មាតា, បងប្អូនប្រុសរបស់មាតា ( អ៊ំប្រុសមា ), បងប្អូនស្រីរបស់មាតា ( អ៊ំស្រីមីង ), កូនប្រុសរបស់មាតា, កូនស្រីរបស់មាតា, ពូជពង្សខ្សែស្រឡាយបុត្រធីតារបស់ជនស្តូម្បីទាំងនោះ, នេះឈ្មោះថា អ្នកមិនមែនញាតិ ។

## ចីវរចាស់និងការប្រើឱ្យបោក

បទថា ឧភតោ សង្ឃេ : ក្នុងសំណាក់សង្ឃទាំងពីរ មានសេចក្តីថា ភិក្ខុនីដែលឧបសម្បទា ដោយអដ្ឋវាចិកវិនយកម្ម គឺ ដោយញត្តិចតុត្ថកម្ម ក្នុងចំណែកភិក្ខុសង្ឃ ១ ដោយញត្តិចតុត្ថកម្ម ក្នុងចំណែកភិក្ខុនីសង្ឃ ១ ។

ពាក្យថា សកឹ និវត្ថំបិ សកឹ បារុតំបិ : សំពត់ដែលភិក្ខុស្លៀកម្តងក្តី ដណ្តប់ម្តងក្តី មានសេចក្តីថា ចីវរដែលជ្រលក់ហើយធ្វើកប្បៈសម្រេច ស្លៀកឬដណ្តប់ ស្តូម្បីត្រឹមតែម្តង ។ ដោយហោចទៅ

ពាក់ទុកលើស្មា ឬលើសីសៈ ដោយប្រាថ្នាការប្រើប្រាស់ជាធំ ធ្វើដំណើរទៅ ឬថា កើយសីសៈដេក, សួម្បីចីវរនោះ ក៏ឈ្មោះថា ចីវរចាស់ដូចគ្នា, ក្នុងកុរុន្ទីលោកពោលថា ក៏បើថា ភិក្ខុដេកយកចីវរទុកក្រោមកម្រាល ឬយកដៃទាំងពីរលើកឡើងធ្វើជាពិតាន លើអាកាស មិនឱ្យត្រូវសីសៈ ដើរទៅ ។ នេះ មិនទាន់ឈ្មោះថា ប្រើប្រាស់ ។

ក្នុងពាក្យថា ធោតំ និស្សគ្គិយំ ហោតិ : ចីវរដែលនាងភិក្ខុនីលាងហើយនោះ ជានិស្សគ្គិយ នេះ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុនីដែលត្រូវភិក្ខុប្រើយ៉ាងនេះ រមែងចាត់ចែងចង្ក្រាន ជញ្ជូនឧសមក បង្កាត់ភ្លើង ដងទឹកមក ដើម្បីប្រយោជន៍ដល់ការបោក, រមែងត្រូវអាបត្តិទុក្កដដល់ភិក្ខុ គ្រប់ប្រយោគរបស់នាងភិក្ខុនី រហូតដល់វេលាដែលនាងភិក្ខុនី លើកចីវរនោះឡើងបោក, ចីវរនោះល្មមបោករួចស្រេចហើយ លើកឡើង ក៏ជានិស្សគ្គិយ ។ បើនាងភិក្ខុនីសម្គាល់ថា ចីវរបោកមិនទាន់ស្អាត ទើបចាក់ទឹក ឬបោកថ្មី, ត្រូវអាបត្តិទុក្កដគ្រប់ប្រយោគរហូតដល់អស់វេលាដែលនៅមិនទាន់សម្រេច, សូម្បីក្នុងការជ្រលក់និងការដំ ក៏មានន័យយ៉ាងនេះ ។ ក៏ភិក្ខុនី ចាក់ទឹកជ្រលក់ ចុះក្នុងស្នុកសម្រាប់ជ្រលក់ ហើយជ្រលក់ត្រឹមតែម្តង, ធ្វើកិច្ច យ៉ាងណាមួយមុនការចាក់ទឹកជ្រលក់ជាដើមនោះ ដើម្បីប្រយោជន៍ ដល់ការជ្រលក់ ឬថា ខាងក្រោយ ត្រឡប់ជ្រលក់ថ្មី ត្រូវអាបត្តិទុក្កដដល់ភិក្ខុគ្រប់ប្រយោគ ក្នុង

ឋានៈទាំងពួង ។ សូម្បីក្នុងការជំគក់ ក៏គប្បីជ្រាបប្រយោគយ៉ាងនេះ ។

[៤៤] ពាក្យថា អញ្ញាតិកាយ អញ្ញាតិកាសញ្ញី បុរាណចីវរំ ធោវាបេតិ : នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនជាញាតិ ហើយប្រើឱ្យលាងនូវចីវរចាស់ មានសេចក្តីថា បើសូម្បីថា ភិក្ខុមិននិយាយថា "នាងចូរលាងចីវរនេះឱ្យយើង", តែធ្វើកាយវិការ ដើម្បីប្រយោជន៍ដល់ការបោក ឱ្យត្រង់ដៃដោយដៃ ឬតម្កល់ទុកជិតជើង ឬផ្ញើត ៗគ្នាទៅ គឺបញ្ជូនទៅក្នុងដៃរបស់នាងសិក្ខមានា សាមណេរ សាមណេរី ឧបាសិកា និងតិរិយជាដើម ឬថា បោះទៅក្នុងទីជិតនៃនាងភិក្ខុនី ដែលកំពុងបោកនៅត្រង់កំពង់, គឺ ក្នុងឱកាសខាងក្នុង១២ ហត្ថ ចីវរជាការភិក្ខុប្រើនាងភិក្ខុនីឱ្យបោកដូចគ្នា ។ ក៏បើថា ភិក្ខុលះឧបចារដាក់អំពីខាងអាយ នាងភិក្ខុនីនោះក៏បោក ហើយនាំមក, មិនមានអាបត្តិដល់ភិក្ខុ ។ ភិក្ខុឱ្យចីវរក្នុងដៃនៃនាងសិក្ខមានាក្តី សាមណេរក្តី ឧបាសិកាក្តី ដើម្បីប្រយោជន៍ដល់ការបោក, បើនាងសិក្ខមានានោះ ឧបសម្បទាហើយ ទើបបោក, ត្រូវអាបត្តិដូចគ្នា ។ ឱ្យទុកក្នុងដៃនៃឧបាសក, បើឧបាសកនោះ កាលភេទត្រឡប់ហើយ បព្វជ្ជាឧបសម្បទាក្នុងសំណាក់នាងភិក្ខុនីហើយ ទើបបោក, ត្រូវអាបត្តិដូចគ្នា ។ សូម្បីក្នុងចីវរដែលឱ្យក្នុងដៃរបស់សាមណេរ ឬរបស់ភិក្ខុក្នុងវេលាភេទត្រឡប់ ក៏មានន័យ យ៉ាងនេះដូចគ្នា ។

## អាបត្តិនិងអនាបត្តិក្នុងការប្រើឱ្យបោក

ក្នុងពាក្យថា ធោវាបេតិ រជាបេតិ : ហើយប្រើឱ្យលាង ឱ្យជ្រលក់ ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ចីវរជានិស្សគ្គិយដោយវត្ថុដំបូង ត្រូវអាបត្តិទុក្កដដល់ភិក្ខុដោយវត្ថុទី២, កាលភិក្ខុឱ្យធ្វើទាំង៣វត្ថុ ជានិស្សគ្គិយដោយវត្ថុដំបូង ត្រូវអាបត្តិទុក្កដ ២ ដោយវត្ថុដ៏សេស ។ តែព្រោះកាលភិក្ខុប្រើឱ្យធ្វើការបោកជាដើមនេះ តាមលំដាប់ ឬថា ខុសលំដាប់ ក៏មិនផុតពីអាបត្តិ; ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ចតុក្កៈ៣ពួក ទុកក្នុងព្រះបាលីនេះ ។ តែបើសូម្បីកាលភិក្ខុពោលថា "នាងចូរជ្រលក់ បោកចីវរនេះ ហើយនាំមកឱ្យយើង" ដូច្នេះ នាងភិក្ខុនីនោះ បោកមុនហើយ ទើបជ្រលក់ ខាងក្រោយ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយប៉ុណ្ណោះ ។ ក្នុងពាក្យដែលផ្ទុយគ្នាសូម្បីទាំងអស់ ក៏គប្បីជ្រាបន័យយ៉ាងនេះ ។ ក៏បើថា កាលភិក្ខុពោលថា "នាងបោកហើយចូរនាំមក" នាងភិក្ខុនីបោកគក់ផង ជ្រលក់ផង, ត្រូវអាបត្តិ ព្រោះការបោកជាបច្ច័យតែម្យ៉ាង, មិនមានអាបត្តិ ព្រោះការជ្រលក់ ។ គប្បីជ្រាបអនាបត្តិ ដោយលក្ខណៈនេះថា "ភិក្ខុមិនបានបង្គាប់ បោកដោយខ្លួនឯង" ព្រោះការធ្វើលើសជាងពាក្យដែលភិក្ខុបង្គាប់គ្រប់ ៗកន្លែង ដោយប្រការយ៉ាងនេះ ។ តែកាលភិក្ខុពោលថា "កិច្ចណា

ដែលគប្បីធ្វើក្នុងចីវរនេះ, កិច្ចនោះ ចូរជាភារៈរបស់នាងទាំងអស់” ដូច្នេះ រមែងត្រូវអាបត្តិច្រើន ព្រោះនិយាយពាក្យតែម្ដង ។ ក៏បទទាំងនេះថា អញ្ញាតិកាយ វេមតិកោ : នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុមានសេចក្ដីសង្ស័យ, អញ្ញាតិកាយ ញាតិកសញ្ញី : នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុជឹងច្បាស់ថា មិនមែនជាញាតិ គប្បីជ្រាបដោយពិស្តារ ដោយអំណាចនៃចតុក្កៈ ៣ ពួក ដោយន័យដូចពោលហើយនុ៎ះឯង ។

ពីរបទថា ឯកតោ ឧបសម្បន្នាយ : នាងភិក្ខុនីដែលជាឯកតោឧបសម្បន្នា មានសេចក្ដីថា ត្រូវអាបត្តិទុក្កដ ដល់ភិក្ខុដែលប្រើនាងភិក្ខុនីដែលឧបសម្បទា ក្នុងសំណាក់នៃភិក្ខុនីទាំងឡាយឱ្យបោក ។ តែកាលប្រើនាងភិក្ខុនី ដែលឧបសម្បទាក្នុងសំណាក់នៃភិក្ខុទាំងឡាយឱ្យបោកត្រូវអាបត្តិ តាមវត្ថុដូចគ្នា ។ នាងសាកិយានី ៥០០ ឈ្មោះថា អ្នកឧបសម្បទាក្នុងសំណាក់នៃភិក្ខុទាំងឡាយ ។

[៤៥] ពីរបទថា អវុត្តា ធោវតិ : ភិក្ខុនីយកមកលាងឱ្យ មិនចាំបាច់ប្រើ មានសេចក្ដីថា ភិក្ខុនីដែលមកដើម្បីឧទ្ទេស ឬថា ដើម្បីឱវាទ ឃើញចីវរស្មោគគ្រោក ជួយយកទៅពីទីដាក់ទុក ឬឱ្យនាំមកឱ្យដោយពោលថា “លោកម្ចាស់មេត្តាឱ្យចុះ ខ្ញុំម្ចាស់នឹងបោក” ហើយបោកក្ដី ជ្រលក់ក្ដី ជំក្ដី ភិក្ខុនីនេះ ឈ្មោះថា អ្នកដែលភិក្ខុមិនបាន បង្គាប់

បោកដោយខ្លួនឯង ។ សូម្បីភិក្ខុនីណាបានឮភិក្ខុបង្គាប់ភិក្ខុកម្លោះ ឬសាមណេរថា "លោកចូរបោកចីវរនេះ" ហើយពោលថា "លោកម្ចាស់ ចូរនាំមកចុះ ខ្ញុំម្ចាស់នឹងបោកដោយខ្លួនឯង" ហើយបោក ឬកាន់យកជារបស់ខ្លួនហើយ បោកជ្រលក់ឱ្យ សូម្បីភិក្ខុនីនេះ ក៏ឈ្មោះថា ជាអ្នកដែលភិក្ខុមិនបានបង្គាប់ បោកដោយខ្លួនឯង ។

ពីរបទថា អញ្ញំ បរិក្ខារំ : គ្រឿងបរិក្ខាឯទៀត មានសេចក្ដីថា ភិក្ខុប្រើភិក្ខុនីឱ្យបោកលាងបណ្ដាបរិក្ខារមានថង់ស្បែកជើង ស្លោកបាត្រ សំពត់ អង្សៈ វត្ថពន្ធចង្កេះ គ្រែ តាំង ពូក និងកន្ទេលទន់ជាដើមយ៉ាងណាមួយ មិនមានអាបត្តិ ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ មានអត្ថងាយយល់ទាំងអស់ ។

ក៏ក្នុងបណ្ដាបកិណ្ណកៈមានសមុដ្ឋានជាដើម សិក្ខាបទនេះ មានសមុដ្ឋាន៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្មវចីកម្ម មានចិត្ត៣ មានវេទនា៣ ដូច្នេះឯង ។

ពណ៌នាបុរាណចីវរធោវាបនសិក្ខាបទទី ៤ ចប់

# ៥. ចីវរបដិគ្គហណសិក្ខាបទវណ្ណនា

[៤៦] ចីវរបដិគ្គហណសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងចីវរបដិគ្គហណសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

## ពន្យល់អត្ថក្នុងសព្ទរឿងបឋមបញ្ញត្តិ

បទថា បិណ្ឌបាតបដិក្កន្តា : រួចត្រឡប់បិណ្ឌបាត គឺ បិណ្ឌបាតតោ បដិក្កន្តា : រួចត្រឡប់អំពីបិណ្ឌបាត ។

ពាក្យថា យេន អន្ធវនំ តេនុបសង្កមិ : ហើយចូលសំដៅទៅក្នុងអន្ធវន មានសេចក្តីថា កាលព្រះមានព្រះភាគ ទ្រង់មិនទាន់បានបញ្ញត្តិសិក្ខាបទ ភិក្ខុនីឧប្បលវណ្ណាដើរចូលទៅកាន់ព្រៃអន្ធវន ។

បទថា កតកម្មា : ធ្វើកម្ម បានដល់ អ្នកធ្វើចោរកម្ម ។ មានពាក្យអធិប្បាយថា ប្លន់ភណ្ឌៈរបស់អ្នកដទៃដោយកម្ម មានការកាត់ ឬចោះប្រហោងជាដើម ។

បទថា ចោរគាមណិកោ : មេចោរជាធំ បានដល់ ប្រធានចោរ ។ បានឮថា ប្រធានចោរនោះ ស្គាល់ព្រះថេរីមកអំពីកាលមុន ; ព្រោះដូច្នោះហើយ កាលទៅខាងមុខរបស់ពួកចោរឃើញព្រះថេរីនោះ

ទើបពោលថា ពួកលោកកុំទៅមកនោះ ចូរមកមកនេះទាំងអស់ដូច្នេះ ហើយបាននាំពួកចោរទាំងនោះទៅមកដទៃ ។

ពីរបទថា សមាធិម្हា វុដ្ឋហិត្វា : ចេញពីសមាធិហើយ មានសេចក្តីថា បានឮថា ព្រះថេរីចេញចាកសមាធិក្នុងវេលាដែលកំណត់ទុកនុ៎ះឯង ។ សូម្បីមេចោរនោះ បាននិយាយយ៉ាងនោះ ក្នុងខណៈនោះដូចគ្នា ; ព្រោះដូច្នោះ ព្រះថេរីនោះ ទើបបានឮ ។ ក៏ឯព្រះថេរីកាលបានឮសំឡេងនោះ ទើបគិតថា ឥឡូវនេះ ក្នុងទីនេះ មិនមានសមណៈ ឬព្រាហ្មណ៍ដទៃក្រៅពីយើង ទើបបានកាន់យកសាច់នោះ ។ ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ទើបបានពោលថា អថខោ ឧប្បលវណ្ណា ភិក្ខុនី : លំដាប់នោះ នាងឧប្បលវណ្ណាភិក្ខុនី ដូច្នេះជាដើម ។

## ឧទាយីភិក្ខុសូមអន្តរវាសកៈរបស់ព្រះថេរី

[៤៧] បទថា ឱហីយកោ : អ្នកនៅ បានដល់ គង់នៅ គឺនៅសល់, អធិប្បាយថា ដល់វារៈចាំវិហារ នៅក្នុងវិហារត្រឹមតែមួយរូប ។

សួរថា ព្រោះហេតុអ្វី ឧទាយីភិក្ខុទើបពោលថា "ប្រសិនបើនាងឱ្យស្បង់ដល់អាត្មា" ដូច្នេះ ។

ឆ្លើយថា ឧទាយីភិក្ខុឃើញស្បង់សាច់ល្អិតម៉ដ្ឋ និងរលោង ទើបពោលព្រោះសេចក្តីចង់បាន ។ ន័យមួយទៀតថា ការចង់បាននូវស្បង់របស់ឧទាយីភិក្ខុនោះ បន្តិចបន្តួច, តែកោដ្ឋាសសម្បត្តិរបស់ព្រះថេរីដល់កំពូលបំផុត ; ព្រោះហេតុនោះ ឧទាយីភិក្ខុទើបគិតថា យើងនឹងមើលភាពធាត់ទ្រលុកនៃសរីរៈ រាងរបស់ព្រះថេរីនោះ ហើយញ៉ាំងសេចក្តីចង់បានមិនស្មើ (ចង់ឃើញក្នុងទីដែលមិនគួរ) ឱ្យកើតឡើង ទើបបានពោលយ៉ាងនេះ ។

បទថា **អន្តិមំ : ជាទីបំផុត** បានដល់ ចីវរជាផ្ទាំងខាងចុងនៃចីវរ ៥ ផ្ទាំង ឈ្មោះថា ផ្ទាំងចុងបង្អស់ គឺ ផ្ទាំងចុងបំផុត ។ ចីវរផ្ទាំងដទៃដែលវិកប្ប ឬបច្ចុទ្ធរណ៍រក្សាទុកសូម្បីដោយលេស ក៏មិនមាន ; ព្រោះដូច្នោះ ព្រះថេរីពោលយ៉ាងនេះ ដោយអំណាចការទ្រទ្រង់ចីវរ ៥ ផ្ទាំង តាមដែលព្រះមានព្រះភាគទ្រង់អនុញ្ញាត មិនមែនដោយសេចក្តីលោភ ។ ពិតមែន សេចក្តីលោភរបស់ព្រះខីណាស្រពទាំងឡាយ រមែងមិនមាន ។

បទថា **និប្បីឡិយមានា : បេះតែទទូចសូម** មានសេចក្តីថា នាងត្រូវឧទាយីភិក្ខុសម្តែងឧបមាហើយបង្ខំខ្លាំងឡើង ៗ ។

ពាក្យថា **អន្តរវាសកំ ទត្វា ឧបស្សយំ អគមាសិ : ក៏ប្រគេនស្បង់ហើយត្រឡប់ទៅឯលំនៅរបស់ខ្លួនវិញ** មានសេចក្តីថា ព្រះ

ថេរីស្លៀកសំពត់រឹតដោះហើយបានសម្តែង (ចីវរ) លើបាត់ដៃប៉ុណ្ណោះ ប្រគេន ដោយអាការដែលមនោរថរបស់ឧទាយីភិក្ខុនឹងមិនអាចសម្រេចបានទៅហើយ ។

សួរថា ព្រោះហេតុអ្វី ទើបភិក្ខុនីទាំងឡាយ ពោលទោសពួកភិក្ខុដែលមិនទទួលចីវរដែលផ្លាស់ប្តូរ ។

ឆ្លើយថា ព្រោះជាអ្នកត្រូវសេចក្តីខ្វះខាតដៃ គឺ បច្ច័យបៀតបៀនយ៉ាងនេះថា បើលោកម្ចាស់ទាំងឡាយ មិនមានសេចក្តីជិតជិតក្នុងពួកយើង សូម្បីត្រឹមតែប៉ុណ្ណោះ, ពួកយើងនឹងញុំាងជីវិតិន្ទ្រិយឱ្យប្រព្រឹត្តទៅបានយ៉ាងណា ?

[៤៨] ពាក្យថា អនុជានាមិ ភិក្ខវេ ឥមេសំ បញ្ចន្នំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យអ្នកទាំងឡាយ(ទទួលយកចីវរដែលត្រូវការផ្លាស់ប្តូរគ្នា)របស់សហធម្មិកទាំង៥នេះ មានសេចក្តីថា តថាគតអនុញ្ញាតឱ្យទទួលចីវរផ្លាស់ប្តូរគ្នារបស់សហធម្មិកទាំង ៥ ពួកនេះ អ្នកមានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានទិដ្ឋិស្មើគ្នា ។

[៤៩] ពីរបទថា បយោគេ ទុក្កដំ : ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលទទួល មានសេចក្តីថា ជាអាបត្តិទុក្កដ ព្រោះអាការមានការលាតដៃចេញ ដើម្បីប្រាថ្នានឹងទទួលជាដើម ។

បទថា បដិលាភេន : ក្នុងខណៈដែលបានមក បានដល់ ព្រោះទទួល ។

ក៏គប្បីជ្រាបវិនិច្ឆ័យក្នុងការទទួលនោះដូច្នេះ ៖ ភិក្ខុនីចូរឱ្យត្រង់ដៃដោយដៃក៏ដោយ ដាក់ទុកត្រង់ជិតជើងក៏ដោយ បោះទៅក្នុងខាងលើក៏ដោយ, បើភិក្ខុត្រេកអរ, ចីវររមែងជាការភិក្ខុនោះទទួលហើយតែម្ដង ។ ក៏បើថា ភិក្ខុទទួល យកចីវរដែលភិក្ខុនីផ្ញើទៅក្នុងដៃរបស់សិក្ខមានា សាមណេរ សាមណេរី ឧបាសកនិងឧបាសិកាជាដើម, មិនមានអាបត្តិ ។ បរិស័ទទាំង ៤ នាំចីវរនិងសំពត់ពណ៌ផ្សេង ៗ មកដាក់ទុកជិតជើងនៃភិក្ខុដែលពោលធម្មកថា ឬឈរក្នុងឧបចារ ឬលះឧបចារ បោះឱ្យ ។ បណ្ដាសំពត់ទាំងនោះ ចីវរណាជារបស់នាងភិក្ខុនីទាំងឡាយ, ត្រូវអាបត្តិដល់ភិក្ខុដែលទទួលចីវរនោះដូចគ្នា វៀរលែងតែផ្លាស់ប្ដូរគ្នា ។

លោកពោលទុកក្នុងមហាបច្ចរី និងកុរុន្ទីថា ក៏បើថា ចីវរទាំងឡាយ ដែលបរិស័ទទាំង ៤ បោះទៅក្នុងវេលាយប់, ភិក្ខុមិនអាចដឹងបានថា នេះរបស់ភិក្ខុនី នេះរបស់អ្នកដទៃ, មិនមានកិច្ចដោយការផ្លាស់ប្ដូរ ។ ពាក្យដែលពោលទុកក្នុងមហាបច្ចរីនិងកុរុន្ទីនោះ មិនសមគ្នា ព្រោះសិក្ខាបទជាអចិត្តកៈ ។ បើភិក្ខុនីប្រគេនសំពត់ងូតទឹកភ្លៀង គប្បី

ធ្វើឱ្យជារបស់ផ្លាស់ប្តូរដូចគ្នា ។ ក៏បើភិក្ខុនីដាក់ទុកលើគំនរសម្រាមជាដើមដោយតាំងចិត្តថា "ភិក្ខុទាំងឡាយ ចូរកាន់យកជាសំពត់បង្សុកូល" ដូច្នេះ, ភិក្ខុនឹងអធិដ្ឋានជាសំពត់បង្សុកូលកាន់យក គួរ ។

[៥០] ពាក្យថា អញ្ញាតិកាយ អញ្ញាតិកសញ្ញី **:** នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនជាញាតិ គឺ ជាតិកបាចិត្តិយ ។

[៥១] ពីរបទថា ឯកតោ ឧបសម្បន្នាយ **:** នាងភិក្ខុនីដែលបានឧបសម្បទាអំពីសំណាក់ឯកតោសង្ឃ មានសេចក្តីថា ត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលទទួលពីដៃរបស់ភិក្ខុនី ដែលបានឧបសម្បទាក្នុងសំណាក់នាងភិក្ខុនីទាំងឡាយ (តែមួយផ្នែក) តែត្រូវអាបត្តិបាចិត្តិយ (ដល់ភិក្ខុដែលទទួលអំពីដៃ) របស់ភិក្ខុនី ដែលឧបសម្បទាក្នុងសំណាក់នៃភិក្ខុទាំងឡាយ ។

[៥២] ពីរបទថា បរិត្តេន វា វិបុលំ **:** ភិក្ខុទទួលយកចីវរមានតម្លៃច្រើន ដោយចីវរមានតម្លៃតិច មានសេចក្តីថា បើសូម្បីថា ភិក្ខុនឹងទទួលត្រៃចីវរមានតម្លៃច្រើន ដោយចីវរមានតម្លៃតិច ឬដោយបរិក្ខារដទៃមានថង់ស្បែកជើង ស្បោកបាត្រ សំពត់អង្សៈ និងវត្ថពន្ធចង្កេះជាដើម, មិនមានអាបត្តិ ។ តែក្នុងមហាបច្ចរីលោកពោលថា ដោយ

ហោចទៅសូម្បីដោយដុំសម៉ ។

ពីរបទថា **វិបុលេន វា បរិត្តំ** : **ភិក្ខុទទួលយកចីវរមានតម្លៃតិចដោយចីវរមានតម្លៃច្រើន** នេះ អ្នកសិក្សាគប្បីជ្រាប ដោយសេចក្តីវិបល្លាស(ផ្ទុយគ្នា) ពីដែលពោលហើយ ។

ពីរបទថា **អញ្ញំ បរិក្ខារំ** : **គ្រឿងបរិក្ខាឯទៀត** មានសេចក្តីថា បរិក្ខារប្រភេទណាមួយមានស្លាកបាត្រជាដើម ។ តែសូម្បីសំពត់តម្រងទឹក មានខ្នាតប៉ុនចីវរខ្នាតតូចដែលគួរវិកប្ប មិនគួរ ។ ចីវរណាមិនល្មមអធិដ្ឋាន មិនល្មមវិកប្ប, ចីវរនោះ គួរគ្រប់យ៉ាង ។ បើសូម្បីជាសំពត់ស្រោមពូកមានខ្នាតប៉ុនគ្រែ ក៏សមគួរដូចគ្នា ។ ក៏នឹងចាំបាច់ពោលទៅថ្វីក្នុងសំពត់ស្លាកបាត្រជាដើមនោះ ? បទដ៏សេសមានអត្ថងាយយល់ទាំងអស់នោះ ។

បណ្តាសមុដ្ឋានជាដើម សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយានិងអកិរិយា ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ពណ៌នាចីវរបដិគ្គហណសិក្ខាបទទី ៥ ចប់

# ៦. អញ្ញាតកវិញ្ញត្តិសិក្ខាបទវណ្ណនា

[៥៣] អញ្ញាតកវិញ្ញត្តិសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងអញ្ញាតិកវិញ្ញត្តិសក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

## ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងព្រះឧបនន្ទសក្យបុត្រ

ពីរបទថា ឧបនន្ទោ សក្យបុត្តោ : ភិក្ខុឈ្មោះឧបនន្ទជាសក្យបុត្ត បានដល់ បណ្ដាភិក្ខុដែលចេញពីសក្យត្រកូលប្រមាណ ៨ ម៉ឺនរូបហើយបួសព្រះឧបនន្ទ សក្យបុត្រជាភិក្ខុអាក្រក់លាមក មានជាតិឡេះឡោះ ។

បទថា បដ្ឋោ : ឈ្លាសវៃ បានដល់ ជាអ្នកឆ្លាត អាចហ៊ាន វាងវៃដល់ព្រមដោយសំឡេង គឺ ប្រកបដោយភាពជាអ្នកមានសំឡេងពីរោះ ។

បទថា កិស្មឹ វិយ : ហាក់ដូចជាមិនសមគួរ មានសេចក្ដីថា តើបីដូចជាអ្វី បីដូចជាអ្នកមានសេចក្ដីសៅហ្មង គឺ ដូចគ្នានឹងខ្លាចក្រែង ដូចនឹងតក់ស្លុតដោយអំណាចហិរិនិងឱតប្ប: ។

[៥៤] បទថា អទ្ធានមគ្គំ : មកឆ្ងាយ មានសេចក្ដីថា មកវែងពោលគឺ មកឆ្ងាយមិនមែនមកថ្នល់ក្នុងក្រុង ។

ពាក្យថា តេ ភិក្ខូ អច្ឆិន្ទឹសុ : ដណ្ដើម(យកបាត្រនិងចីវរ)

របស់ភិក្ខុទាំងនោះ មានសេចក្តីថា បានបូន់ គឺ បានប្រដេញដណ្តើមយក បាត្រ និងចីវររបស់ភិក្ខុទាំងនោះទៅ ។

បទថា អនុយុញ្ជាហិ : លោកចូរសង្កេតសួរ សេចក្តីថា លោក មេត្តាសាកសួរដើម្បីត្រូវការជ្រាបភាពជាភិក្ខុ ។

បទថា អនុយុញ្ជិយមានា : កាលសង្កេតសួរ សេចក្តីថា ភិក្ខុ ទាំងនោះ ត្រូវព្រះឧបាលីដេញដោលសួរដល់ការបព្វជ្ជា ឧបសម្បទា ការ អធិដ្ឋានបាត្រ និងចីវរជាដើមនោះ ។

ពាក្យថា ឯតមត្ថំ អារោចេសុម : ក៏បានប្រាប់ដំណើរនុ៎ះ មាន សេចក្តីថា ទូលឱ្យជ្រាបថា ជាភិក្ខុហើយ បានក្រាបទូលរឿងដែលភិក្ខុ ទាំងនោះពោល ដោយន័យជាដើមថា ជាអ្នកដើរមកឆ្ងាយ ចាកពីក្រុង សាកេត ទៅកាន់ក្រុងសាវត្ថី ។

## ហាមធ្វើដំណើរទាំងអាក្រាតកាយ

[៩៥] ក្នុងពាក្យថា អញ្ញាតកំ គហបតឹ វា : គហបតីក្តី ដែលមិនមែនជាញាតិជាដើម អ្នកសិក្សាគប្បីជ្រាបអនុបុព្វីកថា ចាប់តាំង ពីពាក្យដែលត្រាស់ទុកខាងមុខថា "បិទបាំងហើយដោយស្មៅ ឬដោយ ស្លឹកឈើជាដើម ដោយន័យដូចនឹងពោលតទៅយ៉ាងនេះ ៖

បើពួកភិក្ខុកម្លោះឃើញពួកចោរហើយ កាន់យកបាត្រ និងចីវរ

គេចបេញទៅ, ពួកចោរដណ្តើមយកត្រឹមតែសំពត់ស្លៀក និងសំពត់ដណ្តប់របស់ព្រះថេរៈទាំងឡាយប៉ុណ្ណោះទៅ, ព្រះថេរៈទាំងឡាយមិនទាន់គួរឱ្យសូមចីវរទេ, មិនទាន់គួរនឹងកាច់មែកឈើ និងក្តិចស្លឹកឈើ ។ បើពួកភិក្ខុកម្លោះចោលបង្វេចអ៊ីវ៉ាន់ទាំងអស់ចៀសចេញទៅ, ពួកចោរដណ្តើមយកសំពត់ស្លៀក និងសំពត់ដណ្តប់របស់ព្រះថេរៈនិងបង្វេចអ៊ីវ៉ាន់នោះទៅ, ពួកភិក្ខុកម្លោះ មកហើយ មិនទាន់គួរឱ្យសំពត់ស្លៀក និងសំពត់ដណ្តប់របស់ខ្លួន ដល់ព្រះថេរៈទាំងឡាយមុន ។ ព្រោះថា ពួកភិក្ខុដែលមិនបានត្រូវចោរដណ្តើមយកចីវរទៅ រមែងមិនបានដើម្បីកាច់មែកឈើ និងស្លឹកឈើដើម្បីប្រយោជន៍ដល់ខ្លួន, តែរមែងបាន (ដើម្បីកាច់មែកឈើ និងស្លឹកឈើ) ដើម្បីប្រយោជន៍ដល់ពួកភិក្ខុដែលត្រូវចោរដណ្តើមយកចីវរទៅ ។ ក៏ពួកភិក្ខុដែលត្រូវចោរដណ្តើមយកចីវរទៅ រមែងបាន (ដើម្បីកាច់មែកឈើនិងស្លឹកឈើ) ដើម្បីប្រយោជន៍ដល់ខ្លួនឯងផង ដល់អ្នកដទៃផង ។ ព្រោះដូច្នោះ ព្រះថេរៈទាំងឡាយ គប្បីកាច់មែកឈើ និងស្លឹកឈើ យកធ្មៃជាដើមដេរខ្ទាស់ហើយ គប្បីឱ្យដល់ពួកភិក្ខុកម្លោះ ឬពួកភិក្ខុកម្លោះកាច់ ដើម្បីប្រយោជន៍ដល់ព្រះថេរៈទាំងឡាយ ដេរខ្ទាស់ហើយឱ្យដល់ព្រះថេរៈទាំងនោះគ្រង់ដៃ ឬមិនឱ្យខ្លួនស្លៀកដោយខ្លួនឯងហើយឱ្យសំពត់ស្លៀក និងសំពត់ដណ្តប់របស់ខ្លួនដល់ ព្រះថេរៈទាំងឡាយ ។ មិនត្រូវអាបត្តិបាចិត្តិយ ព្រោះផ្តាច់ភូតគាមឡើយ ។ មិនត្រូវ

អាបត្តិទុក្កដ ព្រោះទ្រទ្រង់សំពត់ទង់ជ័យរបស់ពួកតិរិយនោះ ។

បើក្នុងចន្លោះមក មានលានរបស់ពួកជាងជ្រលក់ ឬប្រទះ ឃើញអ្នកស្រុកពួកដទៃ ដែលមានសភាពដូច្នោះដើរចូលមក, គប្បីឱ្យសូមចីវរ ។ ក៏ពួកអ្នកស្រុកដែលត្រូវសូមទាំងនោះ ឬ អ្នកស្រុកពួកដទៃ ឃើញពួកភិក្ខុស្លៀកមែកឈើ និងស្លឹកឈើហើយ កើតសេចក្ដីឧស្សាហ៍ប្រគេនសំពត់ពួកណាដល់ភិក្ខុទាំងអស់នោះ ។ សំពត់ទាំងនោះ ទឹងមានជាយឬមិនមានជាយក៏ដោយ មានពណ៌ផ្សេង ៗ ដូចពណ៌ខៀវជាដើមក៏ដោយ ជាកប្បិយខ្លះ ជាអកប្បិយខ្លះ, ទាំងអស់ ភិក្ខុទាំងនោះគួរស្លៀកនិងគួរដណ្ដប់បានទាំងនោះ ព្រោះពួកលោកតាំងនៅក្នុងឋាននៃអ្នកដែលត្រូវចោរដណ្ដើមចីវរ ។ ពិតមែន សូម្បីក្នុងគម្ពីរបរិវារ លោកក៏ពោលពាក្យនេះ ទុកថា ៖

"សំពត់ដែលភិក្ខុមិនបានធ្វើពិន្ទុកប្ប ទាំងមិនបានជ្រលក់ដោយគ្រឿងជ្រលក់ ភិក្ខុស្លៀកដណ្ដប់សំពត់នោះហើយដើរទៅបានតាមសេចក្ដីប្រាថ្នា ភិក្ខុនោះមិនត្រូវអាបត្តិ, ទាំងធម៌នោះសោត ក៏ព្រះសុគត ទ្រង់សម្ដែងហើយ, ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ"[១] ។

ពិតមែន ប្រស្នានេះ លោកពោលសំដៅដល់ភិក្ខុដែលត្រូវចោរ

១. វិន. បរិ. សេទមោចនគាថា. ១៣. ៤១៨/៤១៤ ។

ដណ្តើមចីវរ ។ ក៏បើថា ភិក្ខុទាំងឡាយសមាគមនឹងពួកតិត្ថិយ និងពួកតិត្ថិយនោះប្រគេនចីវរធ្វើពីស្បូវភ្លាំង ធ្វើពីសំបកឈើ និងធ្វើពីផ្លែឈើ, សូម្បីសំពត់ទាំងនោះ គួរដល់ភិក្ខុនឹងស្លៀកដណ្តប់បានមិនទទួលយកលទ្ធិ គឺ សូម្បីស្លៀកដណ្តប់ហើយ ក៏មិនគប្បីកាន់លទ្ធិ ( របស់គេ ) ។

ឥឡូវនេះ បណ្ឌិតគប្បីជ្រាបសន្និដ្ឋាន ក្នុងពាក្យថា ភិក្ខុដើរទៅដល់វត្តណាមុន, បើចីវរសម្រាប់វិហារ ឬរបស់សង្ឃក្នុងវត្តនោះ នៅមានជាដើមថា ដែលឈ្មោះថា ចីវរសម្រាប់វិហារ គឺ ចីវរដែលពួកអ្នកស្រុកឱ្យសាងវត្តហើយ ត្រៀមចីវរទុកដោយពោលថា បច្ច័យ ៤ ជាចំណែកផ្ទាល់របស់ពួកយើងប៉ុណ្ណោះ ចូរ ដល់ការប្រើប្រាស់ ហើយតាំងទុកក្នុងវត្តដែលខ្លួនឱ្យសាង ចីវរនេះ ឈ្មោះថា ចីវរសម្រាប់វិហារ ។

កម្រាលលើគ្រែ លោកហៅថា កម្រាលខាងលើ ។

កម្រាលដែលធ្វើដោយសំពត់សំណល់ ដើម្បីត្រូវការនឹងរក្សាផែនដីដែលធ្វើបរិកម្មលោកហៅថា សំពត់ក្រាលផែនដី ។ ភិក្ខុទាំងឡាយក្រាលកន្ទេលទន់លើកម្រាលនោះហើយ ដើរចង្ក្រម ។

សំបក ( ស្រោម ) ពូកទ្រាប់គ្រែ ឬពូកទ្រាប់តាំង ឈ្មោះថា សំបកពូក ។ បើសំបកពូកគេញាត់ទុកពេញ, សូម្បីខ្វេះចេញហើយកាន់យក ក៏គួរ ។ បណ្តាចីវរសម្រាប់វិហារជាដើមទាំងនេះ ដូចពោលមកយ៉ាងនេះ ចីវរដែលមាននៅក្នុងវត្តនោះ ពួកភិក្ខុដែលត្រូវចោរដណ្តើម

យកទៅ សូម្បីមិនសូមអនុញ្ញាតនឹងកាន់យកស្មៀក ឬដណ្តប់ក៏បាន ។ ក៏ឯការស្មៀក ឬការដណ្តប់នោះ រមែងបានដោយសេចក្តីប្រាថ្នាថា "យើងបាន (សំពត់ស្មៀក ឬ សំពត់ដណ្តប់ហើយ) ទឹងតាំងទុក គឺនឹងរក្សាទុកឱ្យដូចដើម" រមែងមិនបាន ដោយការដាច់មូលតម្លៃ (ការកាន់យកជាកម្មសិទ្ធិរបស់ខ្លួន) ។ ក៏ឯកាលបាន (សំពត់ស្មៀកឬសំពត់ដណ្តប់) អំពីញាតិ ឬអំពីឧបដ្ឋាក ឬសូម្បីអំពីទីកន្លែងណាមួយដទៃហើយ គប្បីធ្វើឱ្យត្រឡប់ ជាប្រក្រតីដូចដើមវិញ ។ ភិក្ខុទៅកាន់ទិសផ្សេងហើយ គប្បីរក្សាទុកក្នុងអាវាសរបស់សង្ឃមួយកន្លែង ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់ ដោយការប្រើប្រាស់ជារបស់សង្ឃ ។ បើចីវរសម្រាប់វិហារនោះ ទ្រុឌទ្រោម ឬបាត់ទៅ ដោយការប្រើប្រាស់របស់ភិក្ខុនោះ មិនជាសំណង ។ តែបើថា ភិក្ខុមិនបានសំពត់ណាមួយបណ្តាសំពត់ទាំងនេះ មានសំពត់របស់គ្រហស្ថជាដើម មានសំបកពូកជាទីបំផុត មានប្រការដូចពោលហើយ, លោកគប្បីយកស្មៅ ឬស្លឹកឈើបិទបាំងហើយមកចុះ ដូច្នេះឯង ។

សូម្បីចីវរ ដែលអាចារ្យនិងឧបជ្ឈាយ៍ អ្នកត្រូវចោរដណ្តើមចីវរទៅ សូមចំពោះពួកភិក្ខុដទៃថា "នាំចីវរមកចុះ អាវុសោ" ហើយកាន់យកទៅ ឬកាន់យកទៅដោយវិសាសៈ រមែងគួរដើម្បីពោលថា ដល់ការសង្គ្រោះចូលក្នុងពាក្យថា គោហិចិ វា អច្ឆិន្នំ : អ្នកណាមួយដណ្តើ

មួយកៅក្តី នេះ ។

មួយទៀត សូម្បីចីវរដែលពួកនិស្សិតបិទបាំងដោយស្មៅ និងស្លឹកឈើដោយខ្លួនឯង ហើយប្រគេនដល់ភិក្ខុមានអាចារ្យ និងឧបជ្ឈាយ៍ជាដើម អ្នកត្រូវចោរដណ្តើមចីវរ រមែងគួរដើម្បីពោលថា ដល់ការសង្គ្រោះចូល ក្នុងពាក្យថា បរិភោគជិណ្ណំ វា : ដែលចាស់ ព្រោះប្រើប្រាស់ក្តីនេះ ។ ពិតមែន កាលមានសេចក្តីដែលគួរពោលយ៉ាងនោះ ភិក្ខុទាំងនោះទឹងជាអ្នកតាំងនៅក្នុងឋាន ជាអ្នកត្រូវចោរដណ្តើមចីវរ និងក្នុងឋានជាអ្នកមានចីវរបាត់ពិត ៗ ព្រោះដូច្នោះ អនាបត្តិ ព្រោះវិញ្ញត្តិ និងព្រោះប្រើប្រាសអកប្បិយចីវរ ទឹងជារបស់សមគួរដល់ភិក្ខុទាំងនោះឯង ។

[៥៧] ក្នុងពាក្យថា ញាតកានំ បវារិតានំ : ក្នុងសំណាក់ជនទាំងឡាយ ដែលបវារណាហើយ នេះ បណ្ឌិតគប្បីឃើញសេចក្តីយ៉ាងនេះថា មិនមានអាបត្តិដល់ភិក្ខុដែលសូម គឺ អ្នកអង្វរសូមចំពោះញាតិនិងអ្នកបវារណាថា "ពួកលោកចូរប្រគេនរបស់ខ្លួនដល់ភិក្ខុទាំងនេះ", ពិតមែន មិនមានអាបត្តិ ឬអនាបត្តិដល់ភិក្ខុទាំងឡាយ ដែលពួកញាតិបវារណាហើយ[១] ។

សូម្បីក្នុងពាក្យថា អត្តនោ ធនេន : (ដូរ)ដោយទ្រព្យរបស់

១. ប្រែតាមអត្ថយោជនា. ញាតកានំ បវារិតានន្តិ ញាតកេហិ បវារិតានំ ភិក្ខូនំ ។

ខ្លួន នេះ បណ្ឌិតក៏គប្បីឃើញសេចក្តីយ៉ាងនេះថា មិនមានអាបត្តិដល់ភិក្ខុដែលសូម គឺ អ្នកបង្គាប់ឱ្យទិញ ឬបញ្ចូនឱ្យផ្លាស់ប្តូរដោយកប្បិយភណ្ឌរបស់ខ្លួន ដោយកប្បិយវោហារប៉ុណ្ណោះ ។

មួយទៀត ក្នុងពាក្យថា **បវារិតានំ : ដែលបវារណាហើយ** នេះ មាន វិនិច្ឆ័យដូច្នេះ ៖

ក្នុងបច្ច័យទាំងឡាយ ដែលគេបវារណាទុកដោយអំណាចនៃសង្ឃ គួរសូមតែល្មមប្រមាណប៉ុណ្ណោះ ។ ក្នុងការបវារណា ចំពោះបុគ្គល គួរសូមតែចំពោះវត្ថុដែលគេបវារណាដូចគ្នា ។ ពិតមែន អ្នកណាបវារណាដោយចតុប្បច្ច័យកំណត់ទុកដោយខ្លួនឯងតែម្តង ហើយប្រគេនវត្ថុដែលត្រូវការដោយអាការយ៉ាងនេះ គឺរមែងប្រគេនចីវរតាមសមគួរដល់កាល រមែងប្រគេនអាហារមានបបរ និងបាយជាដើមរាល់ថ្ងៃ, កិច្ចដែលនឹងសូមចំពោះអ្នកដូច្នោះ មិនមាន ។ ចំណែកបុគ្គលណាបវារណាហើយ រមែងមិនឱ្យព្រោះជាអ្នកល្ងង់ ឬព្រោះវង្វេងភ្លេចស្មារតី, បុគ្គលនោះ ដែលភិក្ខុគួរសូម ។ បុគ្គលពោលថា "ខ្ញុំព្រះករុណាបវារណាផ្ទះរបស់ខ្ញុំព្រះករុណា", ភិក្ខុគប្បីទៅកាន់ផ្ទះរបស់បុគ្គលនោះ ហើយគប្បីអង្គុយ គប្បីដេកតាមសប្បាយ មិនគប្បីទទួលយកវត្ថុអ្វីមួយ ។ ចំណែកបុគ្គលណា ពោលថា "ខ្ញុំព្រះករុណាសូមបវារណាវត្ថុ ដែលមាននៅក្នុងផ្ទះរបស់ខ្ញុំព្រះករុណា" ដូច្នេះ, គប្បីសូមវត្ថុជាកប្បិយដែលមាននៅក្នុងផ្ទះរបស់បុគ្គល

នោះ ។ ក្នុងក្បុរទីពោលថា តែភិក្ខុនឹងអង្គុយ ឬដេកក្នុងផ្ទះ មិនបាន ។

ក្នុងពាក្យថា អញ្ញស្សត្ថាយ : សូមឱ្យអ្នកដទៃ នេះ មានអត្ថតែម្យ៉ាង ដូច្នេះថា មិនមានអាបត្តិដល់ភិក្ខុដែលសូមចំពោះញាតិ និងអ្នកបវារណារបស់ខ្លួន ដើម្បីប្រយោជន៍ដល់ខ្លួនឯងតែម្យ៉ាង ក៏ទេ, តាមការពិត សូមដើម្បីប្រយោជន៍ដល់ភិក្ខុដទៃ ក៏មិនមានអាបត្តិ ។

ចំណែកអត្ថទីពីរក្នុងបទថា អញ្ញស្ស : អ្នកដទៃ នេះ ដូចតទៅនេះថា មិនមានអាបត្តិដល់ភិក្ខុដែលចេញមាត់សូមចំពោះញាតិ និងអ្នកបវារណារបស់ភិក្ខុដទៃ ដើម្បីប្រយោជន៍ដល់ភិក្ខុនោះឯង គឺ ព្រះពុទ្ធរក្ខិត ឬព្រះធម្មរក្ខិត ដែលបានវោហារថា អ្នកដទៃ[1] ។ ពាក្យដ៏សេសមានអត្ថងាយយល់ទាំងអស់ ។

បណ្ដាបកិណ្ណកៈមានសមុដ្ឋានជាដើម សិក្ខាបទស្សម្បីនេះ ក៏មានសមុដ្ឋាន ៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ពណ៌នាអញ្ញាតកវិញ្ញត្តិសិក្ខាបទទី ៦ ចប់

---

១. អត្ថយោជនា. កំណត់ឱ្យប្រែថា មិនជាអាបត្តិដល់ភិក្ខុដែលសូមបច្ច័យទាំងឡាយដែលពួក ញាតិរបស់ពួកភិក្ខុដទៃបវារណាទុក ដើម្បីប្រយោជន៍ដល់ពុទ្ធរក្ខិតភិក្ខុ ឬធម្មរក្ខិតភិក្ខុនោះឯង ដែលបានឈ្មោះថា អ្នកដទៃ ។

# ៧. តតុត្ថវិសិក្ខាបទវណ្ណនា

[៥៨] តតុត្ថវិសិក្ខាបទថា តេន សមយេន : សម័យនោះ ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងតតុត្ថវិសិក្ខាបទនោះ មានវិនិច្ឆ័យដូច្នេះ ៖

## ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងបវារណាដើម្បីនាំទៅ

សព្ទថា អភិ ក្នុងពាក្យថា អភិហដ្ឋុំ ជាឧបសគ្គ ។ មានអត្ថថា ដើម្បីនាំទៅ ។ មានពាក្យអធិប្បាយថា ដើម្បីកាន់យក ។

បទថា បវារេយ្យ : បវារណា មានសេចក្ដីថា គប្បីឱ្យប្រាថ្នា គឺ ឱ្យកើតសេចក្ដីប្រាថ្នា សេចក្ដីពេញចិត្ត, អធិប្បាយថា គប្បីប្រាប់ គឺ គប្បីនិមន្ត ។

[៥៩] ដើម្បីទ្រង់សម្ដែងអាការដែលអ្នកបវារណា ដើម្បីឱ្យនាំទៅនឹងពោល ទើបព្រះមានព្រះភាគត្រាស់បទភាជនៈនៃបទថា អភិហដ្ឋុំ : នាំមក ទុកយ៉ាងនេះថា "លោកម្ចាស់ត្រូវការចីវរប៉ុន្មាន ចូរទទួលយកប៉ុណ្ណោះចុះ" ។ ម្យ៉ាងទៀត ក្នុងបាទគាថានេះថា "នេក្ខម្មំ ទដ្ឋុ ខេមតោ

: បានឃើញថា បព្វជាជាការក្សេម"[១] មានអត្ថថា ធិស្វា (ឃើញហើយ) យ៉ាងណា, ពីរបទថា អភិហដ្ឋុំ បវារេយ្យ ស្មុមក្នុងសិក្ខាបទនេះ ក៏មានអត្ថថា គេនាំមកហើយបវារណា ដូច្នោះ ។

ការនាំមកក្នុងពាក្យថា អភិហរិត្វា : គេនាំមកហើយ នោះ មាន២យ៉ាង គឺការនាំមកដោយកាយ១ ការនាំមកដោយវាចា១ ។ គហបតីក្តី គហបតានីក្តី ដែលមិនមែនជាញាតិ នាំសំពត់ទាំង ឡាយមកដោយកាយហើយដាក់ទុកក្នុងទីជិតជើង គប្បីពោលបវារណាថា "លោកត្រូវការចីវរប៉ុន្មាន ក៏ចូរទទួលទៅប៉ុណ្ណោះចុះ" ។ មួយទៀត គប្បីពោលបវារណាដោយវាចាថា "ឃ្លាំងសំពត់របស់ពួកខ្ញុំព្រះករុណា ពេញបរិបូណ៌, លោកត្រូវការចីវរប៉ុន្មាន ក៏ចូរទទួលទៅប៉ុណ្ណោះចុះ" ។ ក៏ព្រោះរួមការនាំមកទាំងពីរនោះ ចូលគ្នាតែមួយ ត្រាស់ហៅថា បវារណាដើម្បីនាំទៅ ។

បទថា សន្តរុត្តរបរមំ : កំណត់ត្រឹមអន្តរវាសក និងឧត្តរាសង្គមានវិគ្រោះថា សំពត់ឧត្តរាសង្គៈ នឹងអន្តរវាសកៈ ជាយ៉ាងក្រៃលែងនៃចីវរនោះ ហេតុនោះ ចីវរនោះ ទើបឈ្មោះថា មានឧត្តរាសង្គៈនិងអន្ត

១. អង្គុ. បញ្ច. នីវរណវគ្គ. ៤៤. ៥៧/១៥៣; ខុទ្ទ. សុត្ត. បព្វជ្ជាសូត្រ. ៥៤. ៤១/១៣៤; ខុទ្ទ. ថេរ. សព្វកាមត្ថេរ. ៥៦. ២២៤/២៣៨; ខុទ្ទ. ថេរី. ឧប្បលវណ្ណាថេរី. ៥៧. ៣២៩/១៨៧; ខុទ្ទ. ចូឡ. ជតុកណ្ណីមាណវកបញ្ហានិទ្ទេស. ៦៧. ៣៩៥/៣១១ ។

វាសកៈជាយ៉ាងក្រៃលែង, មានពាក្យអធិប្បាយថា សំពត់ដណ្តប់និងសំពត់ស្បៀក ជាកំណត់យ៉ាងខ្ពស់នៃចីវរនោះ ។

ត្រើនបទថា តតោ ចីវរំ សាទិតព្វំ : **ភិក្ខុនោះគប្បីត្រេកអរចំពោះចីវរនោះ** មានសេចក្តីថា ភិក្ខុគប្បីកាន់យកចីវរមានប្រមាណប៉ុណ្ណោះ អំពីចីវរដែលគហបតី ឬគហបតានី ដែលមិនមែនជាញាតិនាំមកឱ្យនោះ, អធិប្បាយថា មិនគួរទទួលលើសជាងនេះ ។ ក៏ព្រោះថា ភិក្ខុដែលមានត្រឹមតែត្រៃចីវរប៉ុណ្ណោះ ត្រូវចោរដណ្តើមយកចីវរទៅអស់ គួរបដិបត្តិយ៉ាងនេះ, ភិក្ខុដទៃគួរបដិបត្តិសូម្បីយ៉ាងដទៃ; ដូច្នោះ ដើម្បីសម្តែងវិភាគនោះ ទើបព្រះមានព្រះភាគត្រាស់បទភាជនៈនៃបទថា តតោ ចីវរំ សាទិតព្វំ នោះ ដោយន័យថា សចេ តីណិ នដ្ឋានិ ហោន្តិ ជាដើម ។

វិនិច្ឆ័យក្នុងពាក្យថា សចេ តីណិ នដ្ឋានិ : **បើចីវរទាំងបីវិនាសទៅហើយ** ជាដើមនោះ ដូចតទៅនេះ ៖

បើភិក្ខុណាមានចីវរបាត់ ៣ផ្ទាំង, ភិក្ខុនោះ គប្បីត្រេកអរ ២ផ្ទាំង ។ គឺនឹងស្បៀកមួយផ្ទាំង ដណ្តប់មួយផ្ទាំង ហើយស្វែងរកមួយផ្ទាំងទៀតអំពីទីនៃភិក្ខុដែលជាសភាគគ្នា ។ ភិក្ខុណា មានចីវរបាត់ ២ ផ្ទាំង ភិក្ខុនោះគប្បីត្រេកអរតែមួយផ្ទាំង ។ បើភិក្ខុត្រាច់ទៅជាប្រក្រតីដោយឧត្តរាសង្គៈ និងអន្តរវាសកៈ គប្បីត្រេកអរ ២ ផ្ទាំង ។ កាលត្រេកអរដូច្នោះ ជាអ្នក

ស្មើនឹងភិក្ខុដែលត្រេកអរ តែមួយផ្ទាំងទុំះឯង ។ បាត់តែមួយផ្ទាំង មិនគប្បីត្រេកអរ ។ ភិក្ខុណាមានចីវរបាត់ទៅតែមួយផ្ទាំងក្នុងបណ្តាចីវរ ៣ ផ្ទាំង, ភិក្ខុនោះ មិនគួរត្រេកអរ ។ តែបណ្តាចីវរ ២ផ្ទាំងរបស់ភិក្ខុណាបាត់តែមួយផ្ទាំង, លោកគប្បីត្រេកអរតែមួយផ្ទាំង ។ តែចីវររបស់ភិក្ខុណា មានតែមួយផ្ទាំងប៉ុណ្ណោះ និងចីវរផ្ទាំងនោះបាត់, ភិក្ខុនោះ គប្បីត្រេកអរ ២ ផ្ទាំង ។ តែសម្រាប់ភិក្ខុនី កាលបាត់ទៅទាំង ៥ ផ្ទាំង គប្បីត្រេកអរ ២ ផ្ទាំង ។ កាលបាត់ ៤ ផ្ទាំង គប្បីត្រេកអរតែមួយផ្ទាំង ។ កាលបាត់ ៣ ផ្ទាំង មិនគប្បីត្រេកអរផ្ទាំងណាមួយឡើយ ។ ក៏ក្នុងចីវរដែលបាត់ទៅ ២ ផ្ទាំង ឬ ១ ផ្ទាំង នឹងចាំបាច់ពោលទៅថ្វីពិតមែន ភិក្ខុរូបណាមួយ គប្បីតាំងនៅក្នុងភាពជាអ្នកមានឧត្តរាសង្គៈ និងអន្តរវាសកៈ ជាយ៉ាងក្រៃលែង ។ ក្រៃលែងជាងនោះទៅ រមែងមិនបាន ។ ពាក្យដូចពោលមកនេះ ជាលក្ខណៈក្នុងប្រការនេះ ។

[៦១] ពីរបទថា សេសកំ អាហរិស្សាមិ : **អញនឹងនាំចីវរដែលសល់មក** មានសេចក្តីថា អាត្មាភាពនឹងធ្វើចីវរពីរផ្ទាំងហើយ នឹងនាំសំពត់ដ៏សេសមកសងវិញ ។

បទថា ន អច្ឆិន្នការណា : **ដោយឥតមានហេតុ គឺ ( ឥតមាន ) ចោរដណ្តើមយកចីវរ** មានសេចក្តីថា ពួកទាយកប្រគេនដោយអំណាចនៃ

គុណមានភាពជា ពហុស្សូតជាដើម ។

ក្នុងបទថា ញាតកានំ : របស់ញាតិទាំងឡាយ ជាដើម មានសេចក្តីថា មិនមានអាបត្តិដល់ភិក្ខុដែលត្រេកអរចីវររបស់ពួកញាតិប្រគេន អ្នកត្រេកអររបស់ពួកអ្នកបវារណាប្រគេន អ្នកត្រេកអរ ( ចីវរដែលទិញមក ) ដោយតម្លៃរបស់ខ្លួន ។

មួយទៀត ក្នុងអដ្ឋកថាទាំងឡាយ លោកពោលថា តាមប្រក្រតីទុះឯង នឹងសូមចីវរសូម្បីច្រើនក្នុងទីនៃញាតិនិងអ្នកបវារណា ក៏គួរ, ព្រោះហេតុដែលត្រូវចោរជាដើមដណ្តើមយកទៅ គួរនឹងសូមតែល្មមប្រមាណប៉ុណ្ណោះ ។ ពាក្យនោះមិនសមតាមព្រះបាលី ។ ក៏ព្រោះសិក្ខាបទនេះ ព្រះមានព្រះភាគទ្រង់បញ្ញត្តិ ព្រោះរឿងសូមឱ្យអ្នកដទៃប៉ុណ្ណោះ; ព្រោះដូច្នោះ ក្នុងសិក្ខាបទនេះ ព្រះអង្គទើបមិនត្រាស់ថា ដើម្បីឱ្យអ្នកដទៃ ។ ពាក្យដ៏សេសមានអត្ថងាយយល់ទាំងអស់ ។

បណ្តាបកិណ្ណកៈ មានសមុដ្ឋានជាដើម សិក្ខាបទសូម្បីនេះ ក៏មានសមុដ្ឋាន ៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ពណ៌នាតទុត្តរិសិក្ខាបទទី ៧ ចប់

# ៨. បឋមខុបក្ខជសិក្ខាបទវណ្ណនា

[៦២] ឧបក្ខដសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងឧបក្ខដសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

## ពន្យល់អត្ថក្នុងមូលហេតុបឋមបញ្ញត្តិ

ក្នុងពាក្យថា អត្ថាវុសោ មំ សោ ឧបដ្ឋាកោ : ម្នាលអាវុសោ បុរសនោះជាឧបដ្ឋាកខ្ញុំ នេះ មានសេចក្ដីយ៉ាងនេះថា លោកដ៏មានអាយុ បុរសដែលលោកនិយាយដល់សភាពនោះ គាត់ជាឧបដ្ឋាករបស់ខ្ញុំព្រះករុណា ។

ពាក្យថា អបិ មយ្យ[1] ឯវំ ហោតិ : មែនលោកម្ចាស់ ខ្ញុំគិតយ៉ាងនេះ មានសេចក្ដីថា បពិត្រលោកម្ចាស់ ពិតហើយ ខ្ញុំព្រះករុណាបានតាំងចិត្តទុកយ៉ាងនោះមែន ។ បាលីថា អបិ មយ្យា ឯវំ ហោតិ : បពិត្រលោកម្ចាស់ ចំពោះខ្ញុំព្រះករុណាក៏មានសេចក្ដីគិតយ៉ាងនេះ ដូច្នេះក៏មាន ។

---

១. ឱ.ម. មេយ្យ ។

បទថា ឧទ្ទិស្ស : ចំពោះ ដែលមាននៅក្នុងពាក្យថា ភិក្ខុំ បនេវ ឧទ្ទិស្ស នេះ មានអត្ថថា អាងដល់ គឺ ប្រារព្ធដល់ ។ ក៏ព្រោះតម្លៃសម្រាប់ចាត់ចែងចីវរដែលគហបតីក្ដី គហបតានីក្ដី ត្រៀមទុកចំពោះភិក្ខុណា ចាត់ថា ជាការគេត្រៀមហើយ ដើម្បីប្រយោជន៍ដល់ភិក្ខុនោះ ; ដូច្នោះ ក្នុងបទភាជនៈនៃបទថា ភិក្ខុំ បនេវ ឧទ្ទិស្ស : ចំពោះភិក្ខុនោះ ទើបព្រះឧបាលីពោលថា ភិក្ខុស្សត្ថាយ ដើម្បីប្រយោជន៍ដល់ភិក្ខុ ។

## ពន្យល់អត្ថក្នុងសិក្ខាបទវិភង្គតម្លៃសម្រាប់ទិញចីវរ

ពាក្យថា ភិក្ខុំ អារម្មណំ ករិត្វា : ធ្វើភិក្ខុឱ្យជាអារម្មណ៍ បានដល់ ធ្វើភិក្ខុឱ្យជាបច្ច័យ ។

ពិតមែន តម្លៃសម្រាប់ទិញចីវរដែលគហបតី ឬគហបតានីត្រៀមទុកចំពោះភិក្ខុណា រមែងឈ្មោះថា ជាការគេធ្វើភិក្ខុនោះឱ្យជាបច្ច័យត្រៀមទុកដោយពិតប្រាកដតែម្ដង ។ ព្រោះហេតុនោះ ទើបពោលថា ធ្វើភិក្ខុឱ្យជាអារម្មណ៍ ។ សេចក្ដីពិត សូម្បីបច្ច័យក៏មកហើយដោយឈ្មោះថា អារម្មណ៍ ក្នុងពាក្យថា "លភតិ មារោ អារម្មណំ : មាររមែង

បាននូវបច្ច័យ"[១] ដូច្នេះជាដើម ។

ឥឡូវនេះ ដើម្បីសម្ដែងអាការរបស់កត្តា ( អ្នកធ្វើ ) ក្នុងបទថា ឧទ្ទិស្ស នេះ ទើបព្រះមានព្រះភាគត្រាស់ថា ប្រាថ្នានឹងឱ្យភិក្ខុស្លៀកដណ្ដប់ ។ ពិតមែន គហបតីដែលប្រាថ្នានឹងឱ្យភិក្ខុស្លៀកដណ្ដប់នោះ ត្រៀមទុកចំពោះភិក្ខុនោះ, មិនមែន ( ត្រៀម ) ព្រោះហេតុដទៃ ។ ព្រោះហេតុនេះ គហបតីនោះ ទើបឈ្មោះថា ជាអ្នកប្រាថ្នានឹងឱ្យស្លៀកដណ្ដប់ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ពាក្យថា អ្នកប្រាថ្នានឹងឱ្យភិក្ខុស្លៀកដណ្ដប់ ។

ពីរបទថា អញ្ញាតកស្ស គហបតិស្ស វា : គហបតីក្ដី មិនមែនជាញាតិ មានអត្ថថា ដែលគហបតីមិនមែនជាញាតិក្ដី ។ ពិតមែន ពាក្យនេះ ជាឆដ្ឋីវិភត្តិចុះ ក្នុងអត្ថនៃតតិយាវិភត្តិ ។ តែក្នុងបទភាជនៈ ព្រះមានព្រះភាគ ដើម្បីមិនវិចារណាព្យញ្ជនៈសម្ដែងនូវអត្ថតែម្យ៉ាង ទើបត្រាស់ពាក្យមានជាដើមថា អញ្ញាតកោ នាម ។បេ ។ គហបតិ នាម : ហៅថា មិនមែនជាញាតិ ។ល ។ ហៅថា គហបតី ដូច្នេះ ។

---

១. សំយុ. សឡា. អាសីវិសវគ្គ. ៣៥. ៣២៧/៤១៨ ។

បទថា ចីវរចេតាបន្នំ : តម្លៃចីវរ គឺ មូលតម្លៃនៃចីវរ, ក៏ព្រោះមូលតម្លៃនៃចីវរនោះ រមែងជាវត្ថុណាមួយ ក្នុងបណ្ដាតម្លៃ មានប្រាក់ជាដើម; ដូច្នោះ ក្នុងបទភាជនៈ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា ហិរញ្ញំ វា : ប្រាក់ក្ដីជាដើម ។

ពីរបទថា ឧបក្ខដំ ហោតិ : ហើយតាំងទុក បានដល់ ជាតម្លៃដែលគេត្រៀមទុក គឺរៀបរៀមទុកហើយ ។ ក៏ព្រោះដោយពាក្យថា ហិរញ្ញំ វា : ប្រាក់ក្ដី ជាដើមនេះ រមែងជាការព្រះមានព្រះភាគទ្រង់សម្ដែងសេចក្ដីដែលមូលតម្លៃចីវរនោះ ជារបស់ដែលគហបតីនោះត្រៀមទុកហើយ ; ដូច្នោះ ព្រះមានព្រះភាគ ទើបទ្រង់មិនលើកបទថា "ឧបក្ខដំ ឆាម : ពាក្យថា ហើយតាំងទុក"ឡើងទេ, ហើយត្រាស់បទភាជនៈបែកទុកផ្សេងដទៃ ។ ព្រះមានព្រះភាគទ្រង់សំដៅដល់តម្លៃ ដែលគេត្រៀមទុក ទើបត្រាស់ថា ឥមិនា ជាដើម ។ ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទថា ឥមិនា នោះ ទើបត្រាស់ថា បច្ចុបដ្ឋិតេន : ដោយតម្លៃចីវរដែលតាំងឡើងចំពោះ ។ ពិតមែន មូលតម្លៃនៃចីវរដែលគហបតី ត្រៀមទុក គឺ រៀបរៀមទុកហើយ ឈ្មោះថា តម្លៃចីវរដែលតាំង

ឡើងចំពោះ ដូច្នេះឯង ។

ពាក្យថា អជ្ឈាចេស្សាមិ : អញនឹងឱ្យស្លៀកដណ្តប់ នេះ ជាពាក្យវោហារ ។ តែអត្ថន័យ ក្នុងពាក្យថា អជ្ឈាចេស្សាមិ នេះ ដូច្នេះថា ខ្ញុំព្រះករុណានឹងប្រគេនដល់ភិក្ខុឈ្មោះនេះ ។ ព្រោះហេតុនោះឯង សូម្បីក្នុងបទភាជនៈនៃបទថា អជ្ឈាចេស្សាមិ នោះ ព្រះអង្គទើបត្រាស់ថា ធស្សាមិ : អញនឹងប្រគេន ។

ក្នុងពាក្យថា តត្រ ចេ សោ ភិក្ខុ : បើភិក្ខុនោះ នេះ មានការភ្ជាប់បទយ៉ាងនេះថា យត្រ សោ គហបតិ វា គហបតានី វា តត្រ សោ ភិក្ខុ បុព្វេ អប្បវារិតោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជេយ្យ ចេ : បើភិក្ខុនោះ ដែលគេមិនបានបវារណាមុន ហើយចូលទៅក្នុងទីនោះ ហើយកំណត់ចីវរ ក្នុងសំណាក់របស់គហបតី ឬគហបតានីនោះ ។

បណ្តាបទទាំងនោះ កាលអត្ថនៃបទថា ឧបសង្កមិត្វា : ចូលទៅនេះ សម្រេចដោយបទថា គន្ត្វា : ទៅហើយ នេះឯង ទើបព្រះមានព្រះភាគត្រាស់ថា កាន់ផ្ទះ ដូច្នេះ ដោយអំណាចវោហារខាងច្រើន ។

សេចក្តីក្នុងបទថា គន្ត្វា : ទៅហើយ នេះ យ៉ាងនេះថា ក៏ទាយកនោះនៅក្នុងទីណា ទៅហើយ ក្នុងទីនោះ ។ ព្រោះដូច្នោះ ទើបត្រាស់ដដែលទៀតថា "ចូលទៅរកគេក្នុងទីណាមួយ" ។

ពីរបទថា វិកប្បំ អាបជ្ជេយ្យ : កំណត់ មានសេចក្តីថា គប្បីដល់សេចក្តីកំណត់ពិសេសក្រៃលែង គឺ ការចាត់ចែងយ៉ាងក្រៃលែង ។ តែក្នុងបទភាជនៈ ដើម្បីសម្តែងហេតុជាគ្រឿងឱ្យដល់សេចក្តីកំណត់ប៉ុណ្ណោះ ទើបត្រាស់ថា អាយតំ វា : វែងក្តីជាដើម ។

សព្ទថា សាធុ ជានិបាតចុះក្នុងសេចក្តីអង្វរ ។

សព្ទថា វត ជានិបាតប្រព្រឹត្តទៅក្នុងសេចក្តីរំពឹង ។

ភិក្ខុ រមែងអាងខ្លួនឯង ដោយបទថា មំ : ឱ្យអាត្មា ។

រមែងស្រែក គឺ រមែងហៅអ្នកដទៃថា អាយស្មា : អ្នកដ៏មានអាយុ ។

ក៏ពាក្យទាំងអស់នេះ ត្រឹមតែជាព្យញ្ជនៈ មានអត្ថងាយយល់ទាំងអស់ ; ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបមិនត្រាស់ អធិប្បាយទុកក្នុងបទភាជនៈនៃបទថា សាធុជាដើមនោះ ។

ពីរបទថា កល្យាណកម្យតំ ឧបាទាយ : ព្រោះអាស្រ័យ

សេចក្តីចង់បានចីវរល្អ មានសេចក្តីថា កាន់យក ព្រោះសេចក្តីប្រាថ្នាក្នុងចីវរដែលល្អ គឺ ជាអ្នកប្រាថ្នាចីវរដែលវិសេសក្រៃលែងដោយចិត្ត ។ បទថា ឧបាទាយ នោះ ភ្ជាប់សេចក្តីនឹងបទថា អាបជ្ជេយ្យ ចេ នេះ ។ មួយទៀត ព្រោះហេតុ ដែលភិក្ខុណា កាន់យកជាអ្នកប្រាថ្នាក្នុងចីវរល្អ រមែងដល់សេចក្តីកំណត់, ភិក្ខុនោះ រមែងជាអ្នកមានសេចក្តីត្រូវការចីវរល្អ គឺ មានសេចក្តីត្រូវការដោយចីវរដែលមានតម្លៃច្រើន; ដូច្នោះ ក្នុងបទភាជនៈនៃបទថា កល្យាណកម្យតំ ឧបាទាយ នោះ ទើបទ្រង់លះព្យញ្ជនៈចេញ ត្រាស់ពាក្យនោះប៉ុណ្ណោះ ដើម្បីសម្តែងចំពោះអត្ថដែលត្រូវការ ។ តែព្រោះអាបត្តិមិនទាន់ដល់ទីបំផុតដោយហេតុត្រឹមតែការដល់សេចក្តីកំណត់ចីវរនេះប៉ុណ្ណោះ ; ដូច្នោះ ទើបត្រាស់ពាក្យថា "តស្ស វចនេន : តាមសំដីភិក្ខុនោះ" ជាដើម ។

[៦៥] ក្នុងពាក្យថា អនាបត្តិ ញាតកានំ : អាបត្តិមិនមានដល់ភិក្ខុដែលកំណត់ចីវរ ក្នុងសំណាក់ជនជាញាតិ ជាដើម អ្នកសិក្សាគប្បីឃើញអត្ថយ៉ាងនេះថា មិនមានអាបត្តិដល់ភិក្ខុដែលដល់សេចក្តីកំណត់ក្នុងចីវររបស់ពួកញាតិ ។

ពាក្យថា មហគ្ឃំ ចេតាបេតុកាមស្ស អប្បគ្ឃំ ចេតាបេតិ :

ដល់ភិក្ខុដែលទាយកមានប្រាថ្នានឹងទិញចីវរមានតម្លៃច្រើនប្រគេន ឱ្យទិញចីវរមានតម្លៃតិចវិញ មានសេចក្ដីថា មិនមានអាបត្តិដល់ភិក្ខុដែលពោលដល់គហបតី អ្នកប្រាថ្នានឹងឱ្យទិញចីវរមានតម្លៃ ២០ បាទថា កុំឡើយ ដោយចីវរមានតម្លៃ ២០ បាទ នេះ ដល់អាត្មា, ចូរប្រគេនចីវរមានតម្លៃ ១០ បាទ ឬ ៨ បាទចុះ ។

ពាក្យថា **អប្បគ្ឃំ : ចីវរមានតម្លៃតិច** នេះ ត្រាស់ទុក ដើម្បីការពារតម្លៃដែលច្រើនពេកទៅនុ៎ះឯង ។ តែសូម្បីក្នុងចីវរដែលស្មើគ្នា (មានតម្លៃប៉ុនគ្នា) ក៏មិនមានអាបត្តិ ។ ក៏ឯចីវរនោះស្មើគ្នា (ប៉ុនគ្នា) ដោយអំណាចនៃតម្លៃប៉ុណ្ណោះ មិនមែនដោយអំណាចប្រមាណ (ខ្នាត) ។ ពិតមែន សិក្ខាបទនេះ មានការឱ្យបន្ថែមតម្លៃ; ព្រោះដូច្នោះ សូម្បីនិយាយចំពោះគហបតី អ្នកប្រាថ្នានឹងឱ្យទិញអន្តរវាសកៈមានតម្លៃ ២០ បាទ ថា ចូរប្រគេនចីវរមានតម្លៃត្រឹមតែប៉ុណ្ណោះឯង ដូច្នេះ ក៏គួរ ។ ពាក្យដ៏សេសមានអត្ថងាយយល់ទាំងអស់ ។ សូម្បីសមុដ្ឋានជាដើម ក៏ដូចគ្នានឹងតទុត្តិសិក្ខាបទនុ៎ះឯង ។

ពណ៌នាបឋមឧបក្ខដសិក្ខាបទទី ៨ ចប់

# ៩. ទុតិយឧបក្ខដសិក្ខាបទវណ្ណនា

[៦៦] បណ្ឌិតគប្បីជ្រាបសេចក្ដីក្នុងទុតិយឧបក្ខដសិក្ខាបទដោយន័យនេះឯង ។ ព្រោះថា សិក្ខាបទដំបូងនោះ ដូចគ្នានឹងអនុប្បញ្ញត្តិនៃសិក្ខាបទទីពីរនេះ ។ ក្នុងសិក្ខាបទមុន ភិក្ខុត្រឹមតែធ្វើសេចក្ដីបៀតបៀនដល់មនុស្សតែមួយនាក់ប៉ុណ្ណោះ ក្នុងសិក្ខាបទទី ២ ធ្វើដល់មនុស្ស ២ នាក់ ។ នេះជាសេចក្ដីប្លែកគ្នាក្នុងសិក្ខាបទនេះ ។ ពាក្យដ៏សេសទាំងអស់ដូចគ្នានឹងសិក្ខាបទមុនទាំងអស់នោះ ។ អ្នកសិក្សាគប្បីជ្រាបថា ត្រូវអាបត្តិ សូម្បីដល់ភិក្ខុធ្វើសេចក្ដីបៀតបៀនដល់មនុស្សច្រើននាក់កាន់យក ដូចធ្វើដល់មនុស្ស ២ នាក់ កាន់យកដូច្នោះ ។

ពណ៌នាទុតិយឧបក្ខដសិក្ខាបទទី ៩ ចប់

# ១០. រាជសិក្ខាបទវណ្ណនា

[៧០៧១] រាជសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងរាជសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

## ពន្យល់អត្ថក្នុងមូលហេតុបឋមបញ្ញត្តិ

ពីរបទថា ឧបាសកំ សញ្ញាបេត្វា : ក៏ពន្យល់ឧបាសក បានដល់ ឱ្យឧបាសកយល់ហើយ ។ អធិប្បាយថា ពោលហើយយ៉ាងនេះថា លោកចូរទិញចីវរដោយមូលតម្លៃនេះហើយ ប្រគេនព្រះថេរៈ ។

បទថា បញ្ញាសម្ពន្ធោ : ត្រូវលក់អ្នកនោះ ហាសិបកហាបណៈ មានពាក្យអធិប្បាយថា ត្រូវពិន័យ ៥០ កហាបណៈ ។ បាលីថា បញ្ញាសំ ពន្ធោ : ត្រូវទារយកហាសិបកហាបណៈ ក៏មាន អធិប្បាយថា ឈ្នះ ៥០ កហាបណៈ គប្បីឱ្យគេបង់ ៥០ កហាបណៈ ។

ច្រើនបទថា អជ្ជុណ្ហោ ភន្តេ អាគមេហិ : បពិត្រលោកដ៏ចម្រើន លោកម្ចាស់សូមបង្អង់ថ្ងៃនេះមួយថ្ងៃសិន មានសេចក្តីថា លោកម្ចាស់ ថ្ងៃនេះ មេត្តាឈប់ គឺ ផ្អាកឱ្យខ្ញុំព្រះករុណា មួយថ្ងៃសិន ។

បទថា បរាមសិ : ក៏លូកចាប់ បានដល់ ចាប់ទាញ ។

បទថា ឯិនោសិ : យើងឈ្នះអ្នក មានសេចក្ដីថា អ្នកត្រូវពួកយើងឈ្នះ គឺ ឈ្នះលោក ៥០ កហាបណៈ អធិប្បាយថា អ្នកនឹងត្រូវឱ្យ៥០ កហាបណៈ ។

បទថា រាជភោគ្គោ : រាជអាមាត្យ មានវិគ្រោះថា ឈ្មោះថារាជអាមាត្យ ព្រោះមានប្រាក់ចិញ្ចឹម និងបរិភោគ ឬគប្បីប្រើប្រាស់អំពីព្រះរាជា ។ បាលីថា រាជភោគោ ក៏មាន ។ សេចក្ដីថា អ្នកមានភោគៈ (ភាពជាធំ) អំពីព្រះរាជា ។

បទថា បហិណេយ្យ : បញ្ជូន បានដល់ គប្បីបញ្ជូនទៅ ។ តែព្រោះមានអត្ថងាយយល់ ទើបព្រះមានព្រះភាគមិនបានត្រាស់បទភាជនៈនៃបទថា បហិណេយ្យ នោះទុកទេ ។ ក៏បទថា បហិណេយ្យ នេះព្រះមានព្រះភាគមិនបានត្រាស់បទភាជនៈទុកយ៉ាងណា, សូម្បីបទថា ចីវរំ : នូវចីវរ, ឥត្ថន្នាមំ ភិក្ខុំ : ភិក្ខុឈ្មោះនេះ ជាដើម ក៏យ៉ាងនោះបណ្ឌិតគប្បីជ្រាបថា មិនបានត្រាស់បទភាជនៈទុក ព្រោះមានអត្ថងាយយល់ទាំងអស់ ។

បទថា អាភតំ : នាំមក បានដល់ នាំមកហើយ ។

ពីរបទថា កាលេន កប្បិយំ : សមគួរដោយកាលដ៏គួរ គឺដោយកាលដែលសមគួរ ។

សេចក្តីថា ពួកយើងនឹងទទួលចីវរដែលគួរក្នុងវេលាពួក យើងមានសេចក្តីត្រូវការ ។

បទថា វេយ្យាវច្ចករោ : ជាវេយ្យាវច្ចករ បានដល់ អ្នកធ្វើកិច្ច, សេចក្តីថា កប្បិយការកៈ( អ្នកធ្វើរបស់ឱ្យសមគួរ ) ។

ពាក្យថា សញ្ញត្តោ សោ មយា : វេយ្យាវច្ចករនោះ ខ្ញុំព្រះករុណាបានពន្យល់ហើយ មានសេចក្តីថា អ្នកដែលលោកសម្តែងជាវេយ្យាវច្ចករនោះ ខ្ញុំព្រះករុណាបង្គាប់ឱ្យយល់ហើយ គឺ បង្គាប់ដោយប្រការដែលលោកមានសេចក្តីត្រូវការដោយចីវរ គេនឹងប្រគេនចីវរដល់លោក ។

ពាក្យថា អត្ថោ មេ អាវុសោ ចីវរេន : ម្នាលអាវុសោ អាត្មាត្រូវការចីវរ នេះ ជាពាក្យសម្តែងលក្ខណៈនៃការទាមទារ (ដោយវាចា) ។ ពិតមែន ពាក្យវោហារនេះ គួរពោល, ម្យ៉ាងទៀត អត្ថនៃពាក្យថា អាវុសោ អាត្មាមានសេចក្តីត្រូវការដោយចីវរនោះ គួរពោលដោយភាសាណាមួយ ។ លក្ខណៈនេះ ឈ្មោះថា លក្ខណៈនៃការទាមទារ ។ ចំណែកពាក្យថា ចូរឱ្យចីវរដល់អាត្មាជាដើម ត្រាស់ទុកដើម្បី

សម្តែងអាការដែលមិនគួរពោល ។ ពិតមែន ពាក្យទាំងនេះ ឬ សេចក្តីរបស់ពាក្យទាំងនេះ មិនគួរពោលដោយភាសាណាភាសាមួយ ។

ពាក្យថា ទុតិយម្បិ វត្តព្វោ តតិយម្បិ វត្តព្វោ : គប្បីនិយាយនឹងវេយ្យាវច្ចករនោះ អស់វារៈពីរដងផង គប្បីនិយាយអស់វារៈបីដងផង មានសេចក្តីថា វេយ្យាវច្ចករនោះ ដែលភិក្ខុគប្បីពោលពាក្យនេះឯងដល់ ៣ ដងថា អាវុសោ អាត្មាមានសេចក្តីត្រូវការចីវរ ។

លុះព្រះមានព្រះភាគទ្រង់សម្តែងកំណត់ការទាមទារ ដែលលើកឡើងសម្តែងក្នុងពាក្យថា គប្បីទាមទារ គប្បីដាស់តឿនពីរបីដង យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងសេចក្តី ដោយសង្ខេបនៃបទទាំងនេះថា ទ្វិត្តិក្ខត្តុំ ចោទយមានោ សារយមានោ តំ ចីវរំ អភិនិប្ផាទេយ្យ ឥច្ចេតំ កុសលំ : កាលបើភិក្ខុទៅតឹងទារទៅដាស់តឿនអស់ពីរបីលើក ក៏ញ៉ាំងចីវរនោះឱ្យសម្រេចបាន ការនេះជាការល្អ ទើបត្រាស់ថា សចេ អភិនិប្ផាទេតិ, ឥច្ចេតំ កុសលំ : បើភិក្ខុញ៉ាំងចីវរនោះឱ្យសម្រេចបាន ការនេះជាការល្អ ។ កាលទាមទារដល់ ៣ ដងយ៉ាងនេះ បើញ៉ាំងចីវរនោះឱ្យសម្រេចបាន គឺ រមែងអាចឱ្យសម្រេចដោយអំណាច ( ធ្វើ )ឱ្យខ្លួនបានមក, ការញ៉ាំងការឱ្យសម្រេចបានយ៉ាងនេះជាការល្អ គឺឱ្យសម្រេចប្រយោជន៍ ល្អជាទីគាប់ចិត្ត ។

ពាក្យថា ចតុក្ខត្តុំ បញ្ចក្ខត្តុំ ឆក្ខត្តុបរមំ តុណ្ហីភូតេន ឧទ្ទិស្ស ឋាតព្វំ : គប្បីទៅឈរស្ងៀមចំពោះមុខបួនលើក ប្រាំលើក ប្រាំមួយលើកយ៉ាងច្រើន នេះ ជាការសម្ដែងលក្ខណៈនៃការឈរ ។ ក៏ពាក្យថា ឆក្ខត្តុបរមំ នេះប្រាប់ភាវៈ នបុំសកលិង្គ ។ ពិតមែន ភិក្ខុនេះ គប្បីឈរស្ងៀមចំពោះចីវរ ៦ ដង យ៉ាងច្រើន ។ មិនគប្បីធ្វើកិច្ចអ្វី ៗ ដទៃ ។ នេះជាលក្ខណៈនៃការឈរ ។ ដើម្បីទ្រង់សម្ដែងជាអ្នកស្ងៀម (ដែលត្រាស់) ទុកក្នុងបទថា តុណ្ហីភូតេន នោះដែលជាសាធារណៈដល់ការឈរគ្រប់ ៗ គ្រាមុន ទើបព្រះមានព្រះភាគត្រាស់ពាក្យថា តត្ថ គន្ត្វា តុណ្ហីភូតេន : ភិក្ខុគប្បីទៅក្នុងទីនោះ (ហើយឈរ)នៅស្ងៀម ជាដើម ក្នុងបទភាជនៈ ។

## អធិប្បាយការទាមទារនិងការឈរ

បណ្ដាបទទាំងនោះ ពីរបទថា ន អាសនេ និសីទិតព្វំ : មិនគប្បីអង្គុយលើអាសនៈ មានសេចក្ដីថា ភិក្ខុសូម្បីដែលវេយ្យាវច្ចករពោលថា “មេត្តាអង្គុយទីនេះចុះ លោកម្ចាស់” ក៏មិនគួរអង្គុយ ។

ពីរបទថា ន អាមិសំ បដិគ្គហេតព្វំ : មិនគប្បីទទួលអាមិស មានសេចក្ដីថា សូម្បីដែលគេអង្វរថា មេត្តាទទួលអាមិសដែលមានយាគូ

និងរបស់ទំពាជាដើម ត្រឹមតែបន្តិចចុះ លោកម្ចាស់” ក៏មិនគួរទទួល ។

ពីរបទថា **ន ធម្មោ ភាសិតព្វោ : មិនគប្បីនិយាយធម៌** មានសេចក្ដីថា សូម្បីត្រូវគេអង្វរថា “មេត្តាពោលមង្គល ឬអនុមោទនាចុះ” ក៏មិនគួរពោលអ្វីឡើយ ។ កាលត្រូវគេសួរតែម្យ៉ាងថា “លោកមកព្រោះហេតុអ្វី ?” ភិក្ខុគប្បីនិយាយប្រាប់គេថា “ម្នាលអ្នកដ៏មានអាយុ អ្នកចូរដឹងចុះ” ពិតមែន ពាក្យថា **បុច្ឆិយមានោ** នេះ ជាបឋមាវិភត្តិចុះក្នុងអត្ថនៃតតិយាវិភត្តិ ។ ម្យ៉ាងទៀត អ្នកសិក្សាគប្បីឃើញសេចក្ដីក្នុងបទថា **បុច្ឆិយមានោ : កាលត្រូវគេសួរតែម្យ៉ាង** នេះ សូម្បីយ៉ាងនេះថា ត្រូវគេតាំងបញ្ហាសួរ ។ ពិតមែន បុគ្គលណា រមែងតាំងបញ្ហាសួរ, ភិក្ខុគួរតបបុគ្គលនោះប៉ុណ្ណោះឯង ។

ពីរបទថា **ឋានំ ភញ្ជតិ : ឈ្មោះថា កាច់កិរិយាឈរ** គឺ រមែងកាច់នូវហេតុនៃការមក ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការបន្ថែម និងការបន្ថយក្នុងការទាមទារ ៣ ដង និងការឈរ ៦ ដង ដែលព្រះអង្គត្រាស់ទុកហើយ ទើប ត្រាស់ពាក្យជាដើមថា **ចតុក្ខត្តុំ ចោទេត្វា : គប្បីទារបួនដង** ជាដើម ។ មួយទៀត ក្នុងព្រះបាលីនេះ ត្រាស់ឱ្យបន្ថយការឈរ ២ ដង ដោយបន្ថែមការទាមទារម្ដង ; ព្រោះដូច្នោះ ទើបជាការ

ទ្រង់សម្តែងលក្ខណៈថា ការទាមទារម្តងប៉ុននឹងការឈរពីរដង ។ មានពាក្យអធិប្បាយថា ដោយលក្ខណៈដូចពោលមកនេះ ភិក្ខុទាមទារ ៣ ដង គប្បីឈរបាន ៦ ដង, ទាមទារ ២ ដង គប្បីឈរបាន ៨ ដង, ទាមទារម្តង គប្បីឈរបាន ១០ ដង, ដូចដែលលោកពោលទុកថា ទាមទារ ៦ ដងហើយ មិនគប្បីឈរយ៉ាងណា ឈរ ១២ ដងហើយ ក៏មិនគប្បី ទាមទារ ដូច្នោះ យ៉ាងនេះក៏មានន័យដូចគ្នា ។

ព្រោះដូច្នោះ បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យក្នុងការទាមទារ និងការឈរទាំងពីរនោះយ៉ាងនេះថា បើភិក្ខុទាមទារតែម្យ៉ាង មិនឈរ រមែងបានការទាមទារ ៦ ដង ។ បើឈរតែម្យ៉ាង មិនទាមទារ រមែងបានការឈរ ១២ ដង ។ បើទាមទារខ្លះ ឈរខ្លះគប្បីបន្ថយការឈរ ២ ដង ចំពោះការទាមទារ ១ ដង, បណ្តាការទាមទារនិងការឈរនោះភិក្ខុណា ទៅទាមទាររឿយ ៗ មួយថ្ងៃប៉ុណ្ណោះដល់ទៅ ៦ ដង, ឬថា ទៅត្រឹមតែម្តង តែនិយាយ ៦ ដងថា អ្នកមានអាយុ អាត្មា ត្រូវការចីវរ, មួយទៀត ទៅឈររឿយ ៗ មួយថ្ងៃប៉ុណ្ណោះដល់ ១២ ដង, ឬថា ទៅត្រឹមតែម្តងតែឈរក្នុងទីនោះ ៗ ១២ ដង, ភិក្ខុសូម្បីនោះ រមែងកាច់ការទាមទារទាំងអស់ និងការឈរទាំងអស់ ក៏នឹងចាំបាច់ពោលទៅថ្វី ក្នុងរឿងកាច់ការទាមទារនិងការឈររបស់ភិក្ខុដែលធ្វើយ៉ាងនេះ ក្នុងថ្ងៃផ្សេងគ្នានោះ ?

ពាក្យថា យតស្ស ចីវរចេតាបន្នំ អាភតំ : **តម្លៃចីវរដែលគេនាំមក ដើម្បីភិក្ខុនោះអំពីសំណាក់បុគ្គលណា** មានសេចក្ដីថា តម្លៃសម្រាប់ទិញចីវរដែលគេនាំមកដើម្បីភិក្ខុនោះ អំពីព្រះរាជា ឬអំពីរាជអាមាត្យណា ។ បាលីថា យត្រាស្ស ក៏មានសេចក្ដីយ៉ាងនេះដូចគ្នា ។ អាចារ្យពួកខ្លះសូធ្យថា យត្ថស្ស ក៏មាន ទិងពោលអត្ថថា តម្លៃសម្រាប់ទិញចីវរដែលគេបញ្ជូនមកដើម្បីភិក្ខុនោះ ក្នុងទីណា, ប៉ុន្តែថា ព្យញ្ជនៈមិនសមគ្នា ។

បទថា តត្ថ : **ក្នុងសំណាក់បុគ្គលនោះ** មានសេចក្ដីថា ក្នុងសំណាក់នៃព្រះរាជា ឬថា រាជអាមាត្យនោះ ។ ពិតមែន ពាក្យថា តត្ថ នេះ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា ជិត ។

ពាក្យថា ន តំ តស្ស ភិក្ខុនោ កិញ្ចិ អត្ថំ អនុភោតិ : **តម្លៃចីវរនោះមិនសម្រេចប្រយោជន៍បន្តិចបន្តួចដល់ភិក្ខុនោះទេ** មានសេចក្ដីថា តម្លៃសម្រាប់ទិញចីវរនោះ មិនឱ្យសម្រេចកម្មតិចតួចសោះ គឺសូម្បីមានប្រមាណបន្តិចបន្តួចដល់ភិក្ខុនោះ ។

ពាក្យថា យុញ្ជន្តាយស្មន្តោ សកំ : **អ្នកដ៏មានអាយុទាំងឡាយចូរតឿនទារយករបស់ខ្លួនចុះ** មានសេចក្ដីថា លោកទាំងឡាយចូរទាមទារយកទ្រព្យរបស់ខ្លួន គឺ ចូរតាមយកទ្រព្យនោះត្រឡប់ទៅវិញ ។

ពាក្យថា មា វោ សកំ វិនស្ស : ទ្រព្យរបស់អ្នកទាំងឡាយ ចូរកុំឱ្យវិនាស មានសេចក្តីថា ទ្រព្យរបស់លោកចូរកុំបាត់បង់ទៅឡើយ, មួយទៀត ភិក្ខុណា រមែងមិនទៅដោយខ្លួនឯង ទាំងមិនបញ្ជូនទូតទៅ, ភិក្ខុនោះ រមែងត្រូវអាបត្តិទុក្កដ ព្រោះលះវត្តចោល ។

## កប្បិយការកនិងវេយ្យាវច្ចករ

សួរថា ក៏ក្នុងកប្បិយការកទាំងពួង ទឹងបដិបត្តិយ៉ាងនេះឬ ?

ឆ្លើយថា មិនត្រូវបដិបត្តិ ( យ៉ាងនេះទាំងអស់ទេ ) ។

ពិតមែន ឈ្មោះថា កប្បិយការកនេះ ដោយសង្ខេបមាន ២ យ៉ាង គឺ អ្នកដែលត្រូវសម្តែង ១ អ្នកដែលមិនបានត្រូវសម្តែង ១, ក្នុង២ ពួកនោះ កប្បិយការកអ្នកដែលត្រូវសម្តែង មាន ២ គឺ អ្នកដែលភិក្ខុសម្តែងមួយយ៉ាង អ្នកដែលទូតសម្តែងមួយយ៉ាង ។ សូម្បីកប្បិយការកដែលមិនត្រូវសម្តែងក៏មាន ២ យ៉ាង គឺ កប្បិយការកៈដែលសូមធ្វើជាកប្បិយការកដោយខ្លួនឯងចំពោះមុខ ១ កប្បិយការកៈដែលសូមដោយកំបាំងមុខ ១ ។ បណ្តាកប្បិយការក ដែលភិក្ខុសម្តែងជាដើមនោះ កប្បិយការកៈដែលភិក្ខុសម្តែង មាន ៤ យ៉ាង ដោយអំណាចចំពោះមុខនិងកំបាំងមុខ ។ កប្បិយការកដែលទូតសម្តែងក៏ដូចគ្នា ។

តើយ៉ាងណា ? គឺ បុគ្គលខ្លះក្នុងលោកនេះ រមែងបញ្ជូនអកប្បិយវត្ថុទៅដោយទូត ដើម្បីប្រយោជន៍ដល់ចីវរសម្រាប់ភិក្ខុ ។ ទូតចូលទៅរកភិក្ខុរូបនោះ ពោលថា "លោកម្ចាស់ ជនឈ្មោះនេះ បញ្ជូនអកប្បិយវត្ថុនេះ មកដើម្បីប្រយោជន៍ដល់ចីវរសម្រាប់លោកម្ចាស់, សូមលោកម្ចាស់ទទួលអប្បិយវត្ថុនោះ" ។ ភិក្ខុហាមថា "អកប្បិយវត្ថុនេះមិនសមគួរ" ។ ទូតសួរថា "លោកម្ចាស់ចុះវេយ្យាវច្ចកររបស់លោកមានដែរឬ" និងវេយ្យាវច្ចករទាំងឡាយ ដែលពួកឧបាសកជាអ្នកត្រូវការបុណ្យបង្គាប់ទុកថា "ពួកលោកចូរធ្វើការបម្រើដល់ភិក្ខុទាំងឡាយ ឬវេយ្យាវច្ចករពួកខ្លះជាសម្លាញ់ធ្លាប់ឃើញធ្លាប់សេពគប់គ្នាមក របស់ភិក្ខុទាំងឡាយមាន" ។ បណ្ដាវេយ្យាវច្ចករទាំងនោះ អ្នកណាម្នាក់អង្គុយនៅ ក្នុងសំណាក់របស់ភិក្ខុ ក្នុងខណៈនោះ, ភិក្ខុសម្ដែងអ្នកនោះថា "អ្នកនេះជា វេយ្យាវច្ចៈរបស់ភិក្ខុទាំងឡាយ" ដូច្នេះ ។ ទូតប្រគល់អកប្បិយវត្ថុទុកក្នុងដៃ របស់វេយ្យាវច្ចករនោះ បង្គាប់ថា លោកចូរទិញចីវរប្រគេនព្រះថេរៈ ដូច្នេះហើយទៅ ។ នេះឈ្មោះថា វេយ្យាវច្ចករដែលភិក្ខុសម្ដែងចំពោះមុខ ។

បើវេយ្យាវច្ចករ មិនបានអង្គុយនៅក្នុងសំណាក់របស់ភិក្ខុ, មួយនាក់ទៀតនោះឯង ភិក្ខុរមែងសម្ដែងឡើងថា អ្នកឈ្មោះនេះ ក្នុងស្រុកឈ្មោះឯណោះ ជាវេយ្យាវច្ចកររបស់ភិក្ខុទាំងឡាយ ។ ទូតនោះទៅប្រគល់អកប្បិយវត្ថុ ទុកក្នុងដៃរបស់វេយ្យាវច្ចករនោះ បង្គាប់ថា "លោក

គប្បីទិញចីវរប្រគេនព្រះថេរៈ” មកប្រាប់ដល់ភិក្ខុ ហើយទើបទៅ ។ វេយ្យាវច្ចករនេះ ឈ្មោះថា អ្នកដែលភិក្ខុសម្តែងមិនចំពោះមុខ ប្រភេទទីមួយ ។

ក៏ឯទូតនោះ មិនបានមកប្រាប់ដោយខ្លួនឯងឡើយ តែត្រឡប់ពឹងពាក់អ្នកដទៃទៅប្រាប់ថា “លោកម្ចាស់ តម្លៃសម្រាប់ទិញចីវរ ខ្ញុំព្រះករុណាបានប្រគល់ទុកក្នុងដៃអ្នកនោះ, សូមលោកម្ចាស់ទទួលយកចីវរចុះ” ។ វេយ្យាវច្ចករនេះ ឈ្មោះថា អ្នកដែលភិក្ខុសម្តែងមិនចំពោះមុខ ប្រភេទទីពីរ ។

ទូតនោះ មិនបានពឹងពាក់អ្នកដទៃទៅឡើយ, តែទៅប្រាប់ភិក្ខុដោយខ្លួនឯងថា “ខ្ញុំព្រះករុណានឹងប្រគល់តម្លៃសម្រាប់ទិញចីវរទុកក្នុងដៃនៃអ្នកនោះ, សូមលោកម្ចាស់ទទួលយកចីវរចុះ” ។ អ្នកនេះឈ្មោះថា វេយ្យាវច្ចករដែលភិក្ខុសម្តែងមិនចំពោះមុខ ប្រភេទទីបី ។ ដោយប្រការដូចពោលមកនេះ វេយ្យាវច្ចករ ៤ ពួកទាំងនេះ គឺ អ្នកដែលភិក្ខុសម្តែងចំពោះមុខមួយពួក អ្នកដែលភិក្ខុសម្តែង មិនចំពោះមុខបីពួក ឈ្មោះថា វេយ្យាវច្ចករដែលភិក្ខុសម្តែង ។ ក្នុងវេយ្យាវច្ចករ ៤ ពួកនេះ ភិក្ខុគប្បីបដិបត្តិដោយន័យដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងរាជសិក្ខាបទនេះឯង ។

ភិក្ខុមួយរូបទៀត ត្រូវទូតសួរហើយ ដោយន័យមុនន៎ុះឯង ព្រោះ

វេយ្យាវច្ចករមិនមាន ឬព្រោះមិនចង់នឹងចាត់ការ ទើបពោលថា ពួកយើងមិនមានកប្បិយការក និងក្នុងខណៈនោះមានអ្នកណាមួយដើរចូលមក, ទូតទើបប្រាប់អកប្បិយវត្ថុទុកក្នុងដៃរបស់គេ ហើយពោលថា "លោកគប្បីទទួលយកចីវរពីដៃរបស់អ្នកនេះចុះ" ហើយចេញទៅ, វេយ្យាវច្ចករនេះ ឈ្មោះថា អ្នកដែលទូតសម្តែងចំពោះមុខ ។

នៅមានទូតដទៃទៀត ចូលទៅកាន់ស្រុកហើយ ប្រគល់អកប្បិយវត្ថុទុកក្នុងដៃរបស់អ្នកណាម្នាក់ ដែលខ្លួនគាប់ចិត្តហើយមកប្រាប់ ឬពឹងពាក់អ្នកដទៃទៅប្រាប់ដោយន័យមុនទុំះឯង ឬពោលថា "ខ្ញុំព្រះករុណានឹងឱ្យតម្លៃសម្រាប់ទិញចីវរទុកក្នុងដៃរបស់អ្នកឈ្មោះឯណោះ, លោកម្ចាស់គប្បីទទួលយកចីវរចុះ" ដូច្នេះ ហើយចេញទៅ ។ វេយ្យាវច្ចករទី ៣ នេះឈ្មោះថា អ្នកដែលទូតសម្តែងមិនចំពោះមុខ ដោយប្រការដូចពោលមកនេះវេយ្យាវច្ចករ ៤ ពួកទាំងនេះ គឺ វេយ្យាវច្ចករដែលទូតសម្តែងចំពោះមុខមួយពួក វេយ្យាវច្ចករដែលទូតសម្តែងមិនចំពោះមុខ ៣ ពួក ឈ្មោះថា វេយ្យាវច្ចករដែលទូតសម្តែង ។ ក្នុងវេយ្យាវច្ចករទាំង ៤ ពួកនេះ ភិក្ខុគប្បីបដិបត្តិដោយន័យដូចដែលព្រះមានព្រះភាគត្រាស់ទុកក្នុងមេណ្ឌកសិក្ខាបទទុំះឯង ។

សមដូចពាក្យដែលព្រះមានព្រះភាគ ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងឡាយមានសទ្ធាជ្រះថ្លា, មនុស្សទាំងនោះ ទុកដាក់

មាសនិងប្រាក់ក្នុងដៃកប្បិយការកៈទាំងឡាយ ដោយពាក្យថា របស់ណាគួរដល់លោកម្ចាស់ ចូរអ្នកទាំងឡាយ ប្រគេនរបស់នោះ ដោយមាសនិងប្រាក់នេះចុះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុត្រេកអរចំពោះវត្ថុជាកប្បិយៈ (ដែលកើត)អំពីមាសនិងប្រាក់នោះបាន, ម្នាលភិក្ខុទាំងឡាយ តែតថាគតមិនពោលថា ត្រូវអ្នកត្រេកអរ ត្រូវស្វែងរកមាសនិងប្រាក់ ដូច្នេះ ដោយបរិយាយណាទីមួយឡើយ"[១] ។

ក្នុងអធិការនៃវេយ្យាវច្ចករ ៤ ពួកដែលទូតសម្តែងនេះ មិនមានកំណត់ការទាមទារ ។ ការដែលភិក្ខុមិនត្រេកអរមូលតម្លៃត្រេកអរតែកប្បិយភណ្ឌៈដោយការទាមទារឬការឈរ សូម្បីទាំងពាន់ដង ក៏គួរ ។ បើវេយ្យាវច្ចករនោះមិនឱ្យ, សូម្បីនឹងតាំងកប្បិយការកដទៃ ឱ្យនាំមកក៏បាន ។ បើភិក្ខុប្រាថ្នា គប្បីប្រាប់សូម្បីដល់ម្ចាស់របស់ពីដើម ។ បើមិនប្រាថ្នា, ក៏មិនត្រូវប្រាប់ ។

ភិក្ខុមួយរូបទៀត ត្រូវទូតសួរដោយន័យមុនដូចគ្នា ពោលថា "ពួកយើងមិនមានកប្បិយការកៈ" ។ អ្នកដទៃក្រៅពីទូតនោះ ឈរជិត ៗ បានឮទើបពោលថា "លោកដ៏ចម្រើន មេត្តានាំមកចុះ, ខ្ញុំព្រះករុណានឹងទិញចីវរប្រគេនដល់លោកម្ចាស់" ដូច្នេះ ។ ទូតពោលថា "អញ្ជើញចុះ

១. វិន. មហា. ភេសជ្ជក្ខន្ធកៈ. ៧. ១៣៣/៣៥៩ ។

លោកដ៏ចម្រើន លោកគប្បីប្រគេន” ហើយប្រគល់ទុកក្នុងដៃរបស់អ្នកនោះ មិនប្រាប់ដល់ភិក្ខុឡើយ ចេញទៅ ។ នេះឈ្មោះថា កប្បិយការកអ្នកចេញមាត់ជាកប្បិយការក ដោយខ្លួនឯងចំពោះមុខ ។

ទូតម្នាក់ទៀត ប្រគល់អកប្បិយវត្ថុទុកក្នុងដៃឧបដ្ឋាករបស់ភិក្ខុ ឬអ្នកដទៃហើយបង្គាប់ថា លោកគប្បីប្រគេនចីវរដល់ព្រះថេរៈ ហើយចៀសទៅអំពីទីនោះតែម្តង ។ នេះឈ្មោះថា កប្បិយការកកំបាំងមុខ; ដូច្នោះ កប្បិយការកទាំងពីរនេះ ទើបឈ្មោះថា កប្បិយការកដែលទូតមិនបានសម្តែង ។ ក្នុងកប្បិយការកទាំង ២ នេះ គប្បីបដិបត្តិដូចក្នុងអញ្ញាតកសិក្ខាបទ និងអប្បវារិតសិក្ខាបទ ដូច្នោះ ។ បើកប្បិយការកៈដែលទូតមិនបានសម្តែងទាំងឡាយ បើនាំចីវរមកប្រគេន ដោយខ្លួនឯង, ភិក្ខុគប្បីទទួល, បើមិនបាននាំមកប្រគេន, កុំគប្បីនិយាយពាក្យណាមួយឡើយ ។

ក៏ពាក្យថា **ទូតេន ចីវរចេតាបន្នំ បហិណេយ្យ : បញ្ជូនតម្លៃចីវរទៅដោយបម្រើ** នេះ ត្រឹមតែជាទេសនាប៉ុណ្ណោះ ។ ទោះជាក្នុងពួកកប្បិយការក សូម្បីអ្នកនាំអកប្បិយវត្ថុមកប្រគេន ដើម្បីប្រយោជន៍ដល់បិណ្ឌបាតជាដើមដោយខ្លួនឯង ក៏មានន័យយ៉ាងនេះដូចគ្នា ។

## វិធីបដិបត្តិក្នុងរឿងប្រាក់និងមាសដែលមានអ្នកប្រគេន

ភិក្ខុមិនមែនទទួលដើម្បីប្រយោជន៍ដល់ខ្លួនឯងតែម្យ៉ាងប៉ុណ្ណោះទេ ដែលមិនសមគួរ, សូម្បីអ្នកណាមួយ នាំយកមាសនិងប្រាក់មកពោលថា "ខ្ញុំព្រះករុណាប្រគេនមាសនិងប្រាក់នេះដល់សង្ឃ, លោកទាំងឡាយចូរសាងអារាម វិហារ ចេតិយ ឬរោងឆាន់ជាដើមយ៉ាងណាមួយ ក៏ដោយ" នឹងទទួលមាសនិងប្រាក់សូម្បីនេះ មិនគួរ ។ ក្នុងមហាបច្ចរីលោកពោលទុកថា ពិតមែន ត្រូវអាបត្តិទុក្កដដល់ភិក្ខុរូបណាមួយ ដែលទទួលដើម្បីប្រយោជន៍ដល់អ្នកដទៃ ។ ក៏បើកាលភិក្ខុបដិសេធថា "ភិក្ខុទាំងឡាយនឹងទទួលមាសនិងប្រាក់នេះ មិនសមគួរ" ។ គេពោលថា "មាសនិងប្រាក់នឹងនៅក្នុងដៃរបស់ពួកជាងឈើ ឬពួកកម្មករ, លោកទាំងឡាយចូរទទួលជ្រាបការងារដែលគេធ្វើល្អ និងមិនល្អតែម្យ៉ាង" ដូច្នេះហើយប្រគល់ទុកក្នុងដៃពួកជាងឈើ ឬពួកកម្មករទាំងនោះទើបចៀសចេញទៅ, នឹងទទួល ក៏គួរ, បើសូម្បីគេពោលថា មាសនិងប្រាក់នឹងនៅក្នុងដៃរបស់ពួកមនុស្សរបស់ខ្ញុំព្រះករុណានេះឯង, ឬថា នឹងនៅក្នុងដៃរបស់ខ្ញុំព្រះករុណានេះឯង, លោកគប្បីបញ្ជូនដំណឹងទៅដើម្បីប្រយោជន៍ ដល់បុគ្គលអ្នកដែលយើងនឹងត្រូវឱ្យមាស និងប្រាក់គេតែម្យ៉ាង, សូម្បីយ៉ាងនេះក៏គួរ ។

ក៏បើថា ពួកគេមិនបញ្ចេញឈ្មោះសង្ឃ គណៈ ឬបុគ្គលពោលថា ខ្ញុំព្រះករុណាទាំងឡាយប្រគេនប្រាក់ និងមាសនេះដល់ចេតិយ, ប្រគេនដល់វិហារ, ប្រគេនដើម្បីនវកម្មដូច្នេះ នឹងបដិសេធមិនសមគួរ ។ គប្បីប្រាប់ដល់ពួកកប្បិយការកថា ជនទាំងនេះពោលពាក្យនេះ ។ តែកាលគេពោលថា លោកទាំងឡាយចូរទទួលរក្សា ទុកដើម្បីប្រយោជន៍ដល់ចេតិយជាដើមចុះ គប្បីបដិសេធថា "ការដែលពួកយើងទទួលទុកមិនសមគួរ" ។

តែបើអ្នកខ្លះនាំយកប្រាក់ និងមាសមកច្រើនពោលថា "ខ្ញុំព្រះករុណាសូមប្រគេនប្រាក់ និងមាសនេះដល់សង្ឃ, លោកទាំងឡាយ ចូរបរិភោគបច្ច័យ ៤ ចុះ" បើសង្ឃទទួលប្រាក់និងមាសនោះ ត្រូវអាបត្តិទាំងដោយការទទួលទាំងដោយការបរិភោគ ។ បើបណ្ដាភិក្ខុទាំងនោះភិក្ខុមួយរូបបដិសេធថា វត្ថុនេះមិនគួរ ។ និងឧបាសកពោលថា "បើមិនគួរទើងជារបស់ខ្ញុំព្រះករុណាដោយខ្លួនឯង" ដូច្នេះ ហើយទៅ, ភិក្ខុនោះដែលភិក្ខុរូបខ្លះមិនគប្បីពោលនូវពាក្យណាមួយថា "លោកធ្វើអន្តរាយលាភរបស់សង្ឃ, ព្រោះភិក្ខុណាចោទលោក" ភិក្ខុនោះឯងជាអ្នកមានអាបត្តិជាប់ខ្លួន ។ តែលោកមួយ រូបធ្វើភិក្ខុ ជាច្រើនមិនឱ្យត្រូវអាបត្តិ ។ ក៏បើថា កាលភិក្ខុទាំងឡាយបដិសេធថា "មិនគួរ" គេពោលថា "នឹងនៅក្នុងដៃរបស់ពួកកប្បិយការក ឬនឹងនៅក្នុងដៃរបស់ពួកបុរសរបស់ខ្ញុំព្រះ

ករុណា ឬ ក្នុងដៃរបស់ខ្ញុំព្រះករុណា, លោកទាំងឡាយ ចូរបរិភោគបច្ច័យ តែម៉្យាងប៉ុណ្ណោះ" ដូច្នេះ, សមគួរ ។

មួយទៀត គេប្រគេនដើម្បីប្រយោជន៍ដល់ចតុប្បច្ច័យ គប្បីបង្អោនទៅដើម្បីបច្ច័យដែលត្រូវការ ។ គេប្រគេនដើម្បីប្រយោជន៍ដល់ចីវរ គប្បីបង្អោនទៅក្នុងចីវរប៉ុណ្ណោះ ។ បើថា មិនមានសេចក្តីត្រូវការចីវរនោះ, សង្ឃលំបាកដោយបច្ច័យមានបិណ្ឌបាតជាដើម គប្បីអបលោកដើម្បីសេចក្តីល្អនៃសង្ឃហើយ បង្អោនទៅ ដើម្បីប្រយោជន៍ដល់បិណ្ឌបាតជាដើម ។ សូម្បីក្នុងអកប្បិយវត្ថុដែលគេប្រគេន ដើម្បីប្រយោជន៍ដល់បិណ្ឌបាត និងគិលានបច្ច័យ ក៏ន័យនេះ ។

មួយទៀត អកប្បិយវត្ថុដែលគេប្រគេនដើម្បីប្រយោជន៍ ដល់សេនាសនៈ គប្បីបង្អោនទៅក្នុងសេនាសនៈប៉ុណ្ណោះ ព្រោះសេនាសនៈ ជាគរុភណ្ឌ ។ ក៏បើថា កាលពួកភិក្ខុលះបោលសេនាសនៈទៅ សេនាសនៈនឹងវិនាសអស់, ក្នុងកាលដូច្នេះ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឱ្យភិក្ខុទាំងឡាយ ចំណាយសូម្បីសេនាសនៈហើយ បរិភោគ( បច្ច័យ ) បាន ។

ព្រោះដូច្នោះ ដើម្បីរក្សាសេនាសនៈទុក ភិក្ខុកុំធ្វើឱ្យជាច់មូលតម្លៃ គប្បីបរិភោគល្មមញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ ។ និងមិនមែនប្រាក់មាសតែម៉្យាងប៉ុណ្ណោះ, សូម្បីអកប្បិយវត្ថុដទៃមានស្រែ និងទីដីជាដើមដែលភិក្ខុមិនគួរទទួល ។

## វិធីបដិបត្តិក្នុងបឹងនិងស្រះទឹកជាដើមដែលមានអ្នកប្រគេន

បើអ្នកណាមួយពោលថា បឹងធំឱ្យសម្រេចសន្ទូង ៣ ដងរបស់ខ្ញុំព្រះករុណាមាន, ខ្ញុំព្រះករុណាសូមប្រគេនបឹងធំនោះដល់សង្ឃ, បើសង្ឃទទួលបឹងធំនោះ ត្រូវអាបត្តិទាំងក្នុងការទទួលទាំង ក្នុងការបរិភោគដូចគ្នា ។ តែភិក្ខុណាបដិសេធបឹងធំនោះ, ភិក្ខុនោះដែលភិក្ខុណាមួយមិនគួរពោលបន្ទោសដោយពាក្យណាមួយ ដោយន័យមុន ដូចគ្នា ។ ព្រោះថាភិក្ខុណាចោទលោក, ភិក្ខុនុ៎ះឯងមានអាបត្តិជាប់ខ្លួន ។ តែលោកមួយរូបបានធ្វើឱ្យភិក្ខុច្រើនរូបមិនត្រូវអាបត្តិ ។

មួយទៀត អ្នកណាសូម្បីពោលថា ខ្ញុំព្រះករុណាប្រគេនបឹងធំដូច្នោះដូចគ្នា ត្រូវពួកភិក្ខុបដិសេធថា មិនគួរ, បើនៅតែពោលថា បឹងឯណោះនិងបឹងឯណោះរបស់សង្ឃមាន, បឹងនោះ រមែងគួរបានយ៉ាងណា ? គប្បីប្រាប់គេថា គេនឹងធ្វើឱ្យជាកប្បិយ ហើយប្រគេនទេដឹង ? គេសួរថា ប្រគេនយ៉ាងណា ទើបនឹងជាកប្បិយ ? គប្បីពោលថា គេពោលប្រគេនថា "លោកទាំងឡាយ ចូរបរិភោគបច្ច័យ ៤ ចុះ" ដូច្នេះ ។ បើគេពោលថា "ល្អណាស់ លោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយបរិភោគបច្ច័យ ៤ ចុះ" ដូច្នេះ, គួរ ។

បើសូម្បីគេពោលថា "សូមលោកម្ចាស់ទាំងឡាយទទួលបឹងចុះ"

ត្រូវពួកភិក្ខុទាំងឡាយហាមថា "មិនគួរ" ហើយសួរថា "កប្បិយការកមានដែរឬ ?" កាលភិក្ខុឆ្លើយថា "មិនមាន" ទើបពោលថា អ្នកឈ្មោះឯណោះនឹងចាត់ការនូវ បឹងនេះ, ឬថា នឹងនៅក្នុងសេចក្ដីថែរក្សារបស់អ្នកឯណោះ ឬក្នុងសេចក្ដីថែរក្សារបស់ខ្ញុំព្រះករុណា, សូមសង្ឃបរិភោគកប្បិយភណ្ឌៈចុះ ដូច្នេះ, នឹងទទួល គួរ ។ បើសូម្បីថា ទាយកនោះត្រូវភិក្ខុបដិសេធថា មិនគួរ ហើយពោលថា អ្នកទាំងឡាយនឹងបរិភោគទឹកនឹងបោកលាងវត្ថុ, ពួកម្រឹគនិងបក្សីនឹងផឹកស៊ី, សូម្បីការពោលយ៉ាងនេះក៏សមគួរ ។

បើសូម្បីថា ទាយកត្រូវភិក្ខុបដិសេធថា "មិនគួរ" ហើយនៅតែពោលថា "សូមលោកទាំងឡាយទទួលដោយរបស់សមគួរជាធំចុះ", ភិក្ខុនឹងពោលថា "ល្អណាស់ឧបាសក សង្ឃនឹងផឹកទឹក នឹងបោកលាងវត្ថុពួកម្រឹគនិងបក្សីនឹងផឹក" ដូច្នេះ ហើយបរិភោគ គួរ ។ សូម្បីបើថា កាលទាយកពោលថា "ខ្ញុំព្រះករុណាប្រគេនបឹងឬស្រះបោក្ខរណីដល់សង្ឃ" ភិក្ខុនឹងពោលពាក្យជាដើមថា "ល្អណាស់ ឧបាសក សង្ឃនឹងផឹកទឹក" ហើយបរិភោគប្រើប្រាស់ សមគួរដូចគ្នា ។

ក៏បើពួកភិក្ខុសូមហត្ថកម្ម និងជីកកប្បិយបឋវីដោយដៃរបស់ខ្លួនឯង ឱ្យសាងស្រះទឹកដើម្បីត្រូវការទឹកប្រើប្រាស់, បើពួកអ្នកស្រុកអាស្រ័យស្រះនោះ ធ្វើស្រូវឱ្យសម្រេចហើយប្រគេនកប្បិយ ភណ្ឌៈក្នុង

វិហារ គួរ ។ សូម្បីបើថា ពួកអ្នកស្រុកទុំះឯង ជីកជីរបស់សង្ឃដើម្បីត្រូវការឧបការៈដល់សង្ឃ ហើយប្រគេនកប្បិយ ភណ្ឌៈអំពីស្រូវដែលអាស្រ័យស្រះទឹកនោះសម្រេចហើយ ។ កប្បិយភណ្ឌៈសូម្បីនេះ ក៏សមគួរ ។ ក៏កាលគេពោលថា "លោកទាំងឡាយ ចូរតាំងកប្បិយការកឱ្យពួកខ្ញុំព្រះករុណាម្នាក់" សូម្បីភិក្ខុនឹងតាំងក៏បាន ។

មួយទៀត បើពួកអ្នកស្រុកនោះ ត្រូវរាជពលីរុកកួនទាំគ្នាគេចចេញទៅ, អ្នកស្រុកដទៃទើងធ្វើ, និងមិនប្រគេនអ្វី ៗ ដល់ភិក្ខុទាំងឡាយ, ពួកភិក្ខុហួងហែងទឹក ក៏បាន ។ ក៏ឯការហួងហែងទឹកនោះ រមែងបានក្នុងវេជ្ជវធ្វើស្រែប៉ុណ្ណោះ មិនមែនក្នុងវេជ្ជវសទ្ទូង ( សម្រេចហើយ ) ។ បើពួកអ្នកស្រុកពោលថា លោកម្ចាស់ សូម្បីកាលមុន ពួកអ្នកស្រុកបានអាស្រ័យទឹកនេះធ្វើសន្ទូង មិនមែនឬ ? កាលនោះគប្បីប្រាប់ពួកគេថា "ពួកនោះគេបានធ្វើឧបការៈយ៉ាងនេះ និងយ៉ាងនេះដល់សង្ឃ, និងបានប្រគេនសូម្បីកប្បិយភណ្ឌៈ នេះផង នេះផង" ។ បើថា ពួកគេពោលថា "សូម្បីពួកខ្ញុំព្រះករុណា ក៏នឹងប្រគេន" ដូច្នេះ, យ៉ាងនេះក៏គួរ ។

ក៏បើថា ភិក្ខុរូបខ្លះមិនយល់ ទទួលស្រះឬឱ្យសាងស្រះដោយអកប្បិយវោហារ, ស្រះនោះពួកភិក្ខុមិនគួរបរិភោគប្រើប្រាស់ ។ សូម្បីកប្បិយភណ្ឌៈ ដែលអាស្រ័យស្រះនោះបានមក ក៏ជាអកប្បិយដែរ ។ បើម្ចាស់របស់ ( ស្រះ ) បុត្រ និងធីតារបស់គេ ឬ អ្នកណា ៗ ដទៃ

ដែលកើតក្នុងវង្សរបស់គេជ្រាបថា "ភិក្ខុទាំងឡាយលះបង់ហើយ" ទើបប្រគេនដោយកប្បិយវោហារថ្មី, ស្រះនោះ គួរ ។ កាលវង្សត្រកូលរបស់គេដាច់សូន្យ អ្នកណាជាម្ចាស់របស់ជនបទនោះ, អ្នកនោះរឹបយកហើយប្រគេនត្រឡប់មកវិញ ដូចរាជមហេសីនាមថា អនុឡាទេវី ទ្រង់រឹបយកនូវទំនប់ទឹករបស់ភិក្ខុដែលនៅក្នុងចិត្តលតាបព្វតនាំមកហើយ ប្រគេនត្រឡប់មកវិញ ដូច្នោះ, សូម្បីយ៉ាងនេះក៏គួរ ។

នឹងធ្វើការកើបដីឡើង និងទប់ទំនប់ថ្មី ក្នុងស្រះដែលទទួលទុកដោយអំណាចនៃទឹក សូម្បីជាកប្បិយវោហារ រមែងគួរដល់ភិក្ខុដែលមានចិត្តបរិសុទ្ធ ។ តែការដែលភិក្ខុឃើញពួកអ្នកស្រុកអាស្រ័យស្រះនោះ ធ្វើសន្ទូង នឹងតាំងកប្បិយការក មិនគួរ ។ បើពួកគេប្រគេនកប្បិយភណ្ឌៈដោយខ្លួនឯង, គួរទទួល, បើពួកគេមិនប្រគេន, មិនគួរទាមទារមិនគួរដាស់តឿន ។ ការដែលនឹងតាំងកប្បិយការកក្នុងស្រះដែលទទួលទុកដោយអំណាចនៃបច្ច័យ គួរ ។ តែនឹងធ្វើការកើបដីឡើងនិងការពារទំនប់ស្រះជាដើម មិនគួរ, បើពួកកប្បិយការក ធ្វើដោយខ្លួនឯងប៉ុណ្ណោះ, ទើបគួរ ។ កាលលជ្ជីភិក្ខុដែលមិនឆ្លាតប្រើពួកកប្បិយការកឱ្យកើបដីឡើងជាដើម ស្រះទឹកនឹងជាកប្បិយ ព្រោះការទទួល ក៏ពិតមែនហើយ តែថា ជាការបរិភោគមិនល្អ ដូចបិណ្ឌបាតដែលលាយថ្នាំពិស និងដូចភោជនដែលលាយអកប្បិយមំសៈ ដូច្នោះ ព្រោះកប្បិយភណ្ឌៈដែលលាយដោយវត្ថុដែល

កើតអំពីប្រយោគរបស់ភិក្ខុជាបច្ច័យ ជាអកប្បិយដល់ពួកភិក្ខុទូទៅដូចគ្នា ។

តែបើនៅមានឱកាសដើម្បីទឹក, ភិក្ខុនឹងចាត់ការចំពោះទឹកប៉ុណ្ណោះ យ៉ាងនេះថា លោកចូរធ្វើទំនប់របស់ស្រះឱ្យមាំទាំ ទប់ទឹកបានច្រើន គឺចូរធ្វើឱ្យទឹកជន់ ឡើងព្រៀបប្រាំង ដូច្នេះ គួរ ។

## វិធីបដិបត្តិក្នុងផលដែលបានព្រោះស្រះទឹកវត្តជាដើម

ជនទាំងឡាយកំពុងពន្លត់ភ្លើងក្នុងចង្ក្រាន ទឹងពោលថា "ពួកលោកចូរបានឧទកកម្មមុនចុះ ឧបាសក" ដូច្នេះ ក៏គួរ ។ តែទឹងពោលថា "លោកនឹងធ្វើសន្ទូងហើយនាំមក មិនគួរ" ។ ក៏បើថា ភិក្ខុឃើញទឹកក្នុងស្រះច្រើនពេកទៅ ឱ្យនាំទឹកចេញតាមប្រឡាយ អំពីផ្នែកខាង ឬផ្នែកក្រោយ ឱ្យកាប់ឆ្ការព្រៃ ឱ្យធ្វើភ្លឺស្រែទាំងឡាយ មិនកាន់យកចំណែកប្រក្រតីក្នុងភ្លឺស្រែពីដើម កាន់យកចំណែកដែលលើស, ប៉ាន់ស្មានបង្ខិតបង្ខំយកកហាបណៈថា "លោកទាំងឡាយ ចូរឱ្យកហាបណៈប្រមាណប៉ុណ្ណោះ" ក្នុងសន្ទូងក្រៅរដូវកាល ឬក្នុងសន្ទូងថ្មីដែលមិនបានកំណត់ទុក, ជាអកប្បិយដល់ភិក្ខុគ្រប់រូប ។

មួយទៀត ភិក្ខុណា មិនបានពោលថា "ពួកលោកចូរភ្ជួរ ចូរសាបព្រោះ" ប៉ាន់ផ្ទៃដីយ៉ាងនេះថា "សម្រាប់ផ្ទៃដីប៉ុណ្ណោះ មានចំណែកឈ្មោះប្រមាណប៉ុណ្ណោះ"គឺ កាលពួកអ្នកស្រែពោលថា "ពួកខ្ញុំព្រះករុណាធ្វើសន្ទូ

ងក្នុងចំណែកផ្ទៃដី ប៉ុណ្ណេះ, លោកម្ចាស់ទាំងឡាយ ចូរកាន់យកនូវចំណែកឈ្មោះប្រមាណប៉ុណ្ណេះ" យកខ្សែ ឬឈើច្រត់វាស់ដើម្បីកំណត់ប្រមាណផ្ទៃដីក្តី ឈររក្សា នៅត្រង់លានក្តី ឱ្យជញ្ជូនចេញចាកលានទៅក្តី ឱ្យរក្សាទុកក្នុងជង្រុកក្តី ផលដែលកើតឡើងអំពីទីដីនោះ ជាអកប្បិយដល់ភិក្ខុរូបនោះប៉ុណ្ណោះ ។

បើអ្នកស្រែទាំងឡាយនាំកហាបណៈមក ហើយពោលថា "កហាបណៈទាំងនេះ ពួកខ្ញុំព្រះករុណានាំមកដើម្បីសង្ឃ" និងភិក្ខុរូបណាមួយ ពោលថា "លោកចូរនាំសំពត់មកដោយកហាបណៈប៉ុណ្ណេះ, ចូរចាត់ចែងបាយយាគូជាដើម ដោយកហាបណៈប្រមាណប៉ុណ្ណេះ" ដោយការសម្គាល់ថា "សង្ឃមិនទំពានូវកហាបណៈទេ" វត្ថុដែលពួកគេនាំមកជាអកប្បិយដល់ពួកភិក្ខុទូទៅ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភិក្ខុចាត់ចែងកហាបណៈ ។

បើពួកអ្នកស្រែនាំស្រូវមកពោលថា "ស្រូវនេះ ពួកខ្ញុំព្រះករុណានាំមកដើម្បីសង្ឃ" និងភិក្ខុរូបណាមួយពោលថា ពួកលោកចូរនាំយកវត្ថុនេះ និងវត្ថុនេះមកដោយស្រូវប្រមាណប៉ុណ្ណេះ" ដោយន័យមុននុ៎ះឯង វត្ថុដែលពួកគេនាំមក ជាអកប្បិយ ចំពោះភិក្ខុនោះប៉ុណ្ណោះ ។ ព្រោះហេតុអ្វី ? ព្រោះភិក្ខុចាត់ចែងធញ្ញជាតិ ។

បើពួកគេនាំយកស្រូវ ឬអបរណ្ណជាតិមកពោលថា "ពួកខ្ញុំព្រះ

ករុណានាំវត្ថុនេះមកដើម្បីសង្ឃ” ។ ភិក្ខុរូបណាមួយពោលថា “ពួកលោកចូរនាំយកវត្ថុនេះ និងវត្ថុនេះមកដោយស្រូវមានប្រមាណប៉ុណ្ណេះ” ដោយន័យមុនទុំះឯង, វត្ថុដែលពួកគេនាំមក ជាកប្បិយដល់ភិក្ខុទាំងអស់ ។ ព្រោះហេតុអ្វី ? ព្រោះភិក្ខុចាត់ចែងស្រូវជាដើមដែលជាកប្បិយ ។ មិនមានអាបត្តិសូម្បីព្រោះទិញ ព្រោះប្រាប់កប្បិយការក ។

តែក្នុងកាលមុន ភិក្ខុមួយរូបនៅឯចិត្តលតាបព្វត បានធ្វើមណ្ឌល (រូបព្រះចន្ទ) ទុកលើផែនដី ជិតទ្វារសាលា ៤ មុខ ដើម្បីឱ្យកើតសេចក្តីយល់ដល់ពួកអារាមិកជនដោយរំពឹងថា “ឱហ្ន៎ ពួកអារាមិកជនគប្បីដាក់នំប្រមាណប៉ុណ្ណេះ ដើម្បីសង្ឃក្នុងថ្ងៃស្អែកនេះ” ។ អារាមិកជនអ្នកឆ្លាត ឃើញមណ្ឌលនោះ (រូបព្រះចន្ទ)ហើយ បានធ្វើយ៉ាងនោះក្នុងថ្ងៃទីពីរ កាលពួកគេវាយស្គរ ប្រជុំសង្ឃហើយ ទើបកាន់យកនំទៅប្រាប់ព្រះសង្ឃត្ថេរៈថា “លោកម្ចាស់ ក្នុងកាលពីមុននេះ ពួកខ្ញុំព្រះករុណាមិនធ្លាប់បានឮបិតាមាតា មិនធ្លាប់បានស្តាប់តាយាយ(ប្រាប់ហេតុការណ៍) យ៉ាងនេះឡើយ, ព្រះគុណម្ចាស់មួយរូបបានធ្វើគ្រឿងសម្គាល់ជិតទ្វារសាលា ៤ មុខ ដើម្បីប្រយោជន៍ដល់នំ, ឥឡូវនេះ ចាប់ផ្តើមតាំងពីនេះទៅ ព្រះគុណម្ចាស់ទាំងឡាយ ចូរប្រាប់តាមសេចក្តីពេញចិត្តរបស់ខ្លួន ៗ ចុះ, សូម្បីពួកខ្ញុំព្រះករុណា ក៏នឹងនៅជាសុខសប្បាយ” ។ ព្រះមហាថេរៈត្រឡប់ពីទីនោះភ្លាម ។ សូម្បីភិក្ខុមួយរូបក៏មិនទទួលនំឡើយ ។

ក្នុងកាលមុនភិក្ខុទាំងឡាយ រមែងមិនឆាន់ សូម្បីនំដែលកើតឡើងក្នុងអារាមនោះ យ៉ាងនេះ ; ព្រោះដូច្នោះ

សល្លេខំ អច្ចជន្តេន អប្បមត្តេន ភិក្ខុនា
កប្បិយេបិ ន កាតព្វា អាមិសត្ថាយ លោលតា ។

ភិក្ខុអ្នកមិនប្រមាទ មិនលះការបដិបត្តិជុសខាត់ មិនគប្បីធ្វើសេចក្ដីល្មោភ ដើម្បីប្រយោជន៍ដល់អាមិស សូម្បីក្នុងវត្ថុដែលជាកប្បិយ ដូច្នេះឯង ។

មួយទៀត សូម្បីក្នុងស្រះបោក្ខរណី ទំនប់ទឹកនិងប្រឡាយជាដើម ក៏មានន័យដូចដែលពោលទុកហើយ ក្នុងស្រះនេះដែរ ។ សូម្បីកាលទាយកពោលថា "ខ្ញុំព្រះករុណាប្រគេនស្រែ" ឬថា ទីដីយ៉ាងណាមួយដែលជាស្ថានទីបណ្ដុះបុព្វណ្ណជាតិ អបរណ្ណជាតិ អំពៅនិងដូងជាដើម ភិក្ខុគប្បីបដិសេធថា "មិនគួរ" ហើយបដិបត្តិ ដោយន័យដូចដែលពោលហើយក្នុងស្រះនុ៎ះឯង ។ ក្នុងវេលាគេពោលដោយកប្បិយវោហារថា "ខ្ញុំព្រះករុណាប្រគេនដើម្បីប្រយោជន៍ដល់ការបរិភោគបច្ច័យ ៤" ភិក្ខុគួរទទួល, ក៏កាលគេពោលថា "ខ្ញុំព្រះករុណាប្រគេនសួន, ប្រគេនព្រៃ" គួរនឹងទទួលទុក ។

បើពួកអ្នកស្រុកមិនបានត្រូវភិក្ខុបង្គាប់ឡើយ កាត់ដើមឈើ ក្នុង

ព្រៃនោះ ញ៉ាំងអបរណ្ណជាតិជាដើម ឱ្យដល់ព្រមហើយ ប្រគេនចំណែក ដល់ភិក្ខុទាំងឡាយ, ទឹងទទួលក៏គួរ ។ ពួកគេមិនប្រគេន, មិនគួរទាម ទារ មិនគួរដាស់តឿន ។

បើកាលពួកគេនាំគ្នាភៀសខ្លួនទៅ ព្រោះអន្តរាយយ៉ាងណាមួយ, ពួក មនុស្សដទៃធ្វើ និងមិនប្រគេនអ្វីតិចតួចដល់ភិក្ខុទាំងឡាយឡើយ, គប្បី ហាមពួកជននោះ ។ បើពួកគេពោលថា សូម្បីកាលមុន ពួកអ្នកស្រុក បានធ្វើសន្ទូងក្នុងទីនេះមិនមែនឬ លោកម្ចាស់, លំដាប់នោះ គប្បីប្រាប់ គេថា ពួកនោះគេបានឱ្យកប្បិយភណ្ឌៈ យ៉ាងនេះ ៗ ដល់សង្ឃ ។ បើ ពួកគេពោលថា "សូម្បីពួកខ្ញុំព្រះករុណាក៏នឹងប្រគេន" យ៉ាងនេះ គួរ ។

ពួកគេពោលសំដៅដល់ភូមិប្រទេស ដែលជាកន្លែងសូងសន្ទូ ងណាមួយថា ខ្ញុំព្រះករុណានឹងប្រគេនព្រំប្រទល់ គួរ ។ តែភិក្ខុទាំង ឡាយ មិនគួរបោះសសរ ឬដាក់ថ្ម ដើម្បីកំណត់ព្រំប្រទល់ខ្លួនឯង ។ ព្រោះហេតុអ្វី ? ព្រោះធម្មតាថា ផែនដីមានតម្លៃរាប់មិនបាន, ភិក្ខុនឹងត្រូវ អាបត្តិបារាជិក សូម្បីដោយហេតុបន្តិចបន្តួច ។ តែគប្បីប្រាប់ពួកអារាមិ កជនថា ខេត្តរបស់ពួកយើងទៅដល់ទីនេះ ។ ក៏បើសូម្បីថា ពួកគេកាន់ យកច្រើនទៅមិនមានអាបត្តិ ព្រោះពោលដោយបរិយាយ ។ ក៏បើថា ព្រះរាជានិងរាជអាមាត្យជាដើម ឱ្យបោះសសរដោយខ្លួនឯងហើយប្រគេន ថា "សូមលោកម្ចាស់ទាំងឡាយបរិភោគបច្ច័យ ៤ ចុះ" ការប្រគេននោះ

គួរដូចគ្នា ។

បើអ្នកណាមួយ ជីកស្រះខាងក្នុងព្រំប្រទល់សីមា ឬជីកប្រឡាយទៅកាត់ពាក់កណ្តាលវត្ត វមែងទម្លាយលានចេតិយ និងលានពោធិព្រឹក្សជាដើម, គប្បីហាម ។ បើសង្ឃបានអ្វី ៗ យ៉ាងណាមួយហើយ មិនហាមព្រោះជួន់ក្នុងអាមិស, ភិក្ខុមួយរូបហាម, ភិក្ខុរូបនោះប៉ុណ្ណោះ ជាធំ ។ បើភិក្ខុមួយរូបមិនហាមថា ពួកលោកចូរចេញទៅ ភិក្ខុនោះ ជាបក្ខពួករបស់អ្នកស្រុកទាំងនោះឯង, សង្ឃហាម, សង្ឃប៉ុណ្ណោះ ជាធំ ។ ពិតមែន ក្នុងកម្មដែលជារបស់សង្ឃ ភិក្ខុរូបណាធ្វើកម្មប្រកបដោយធម៌ ។ ភិក្ខុរូបនោះ ជាធំ ។ បើសូម្បីបុគ្គលដែលត្រូវភិក្ខុហាមហើយ នៅតែប្រឹងធ្វើ, គប្បីលុបអាចម៍ដីដែលគេកកាយទុកខាងក្រោមបំពេញខាងក្រោម លុបអាចម៍ដីដែលគេកកាយទុកខាងលើ បំពេញខាងលើឱ្យពេញ ។

ព្រះមហាសុមត្ថេរៈពោលថា បើអ្នកណាមួយ ប្រាថ្នានឹងប្រគេនអំពៅ ឬអបរណ្ណជាតិ ឬផ្លែឈើវល្លិ មានឃ្លោកនិងត្រឡាចជាដើម តាមដែលកើតហើយនុ៎ះឯង ពោលថា ខ្ញុំព្រះករុណា នឹងប្រគេនចំការអំពៅ ចំការអបរណ្ណជាតិ រណ្តៅ (បណ្តុះ) ផ្លែឈើ វល្លិទាំងអស់នេះ ដូច្នេះ, មិនគួរ ព្រោះគេបញ្ចូលព្រមទាំងវត្ថុ (ចំការ) ។ ចំណែកព្រះមហាបទុមត្ថេរៈពោលថា នោះត្រឹមតែជាវោហារ, ព្រោះទីដីនោះ នៅជារបស់ពួកម្ចាស់ដីដដែលនុ៎ះឯង ; ព្រោះហេតុនោះ ទើបគួរ ។

# វិធីបដិបត្តិក្នុងទាស អារាមិកជន និងបសុសត្វ

ទាយកពោលថា “ខ្ញុំព្រះករុណាប្រគេនទាសៈ” ការប្រគេននោះមិនគួរ ។ កាលគេពោលថា “ខ្ញុំព្រះករុណាប្រគេនអារាមិកជន, ប្រគេនវេយ្យាវច្ចករ ប្រគេនកប្បិយការកៈ” ដូច្នេះ ទើបគួរ ។ បើអារាមិកជននោះ ធ្វើការងាររបស់សង្ឃប៉ុណ្ណោះទាំងមុនភត្ត និងខាងក្រោយភត្ត, ភិក្ខុគប្បីធ្វើសូម្បីការព្យាបាលដោយថ្នាំគ្រប់យ៉ាងដល់គេដូចសាមណេរ, បើគេធ្វើការងាររបស់សង្ឃមុនភត្ត តែមួយវេលា, ខាងក្រោយភត្តទៅធ្វើការងាររបស់ខ្លួន មិនគប្បីឱ្យអាហារក្នុងវេលាល្ងាច ។ សូម្បីជនពួកណាធ្វើការងាររបស់សង្ឃតាមវារៈ ៥ ថ្ងៃ ឬតាមវារៈបក្ខ ក្នុងវេលាដ៏សេសធ្វើការងាររបស់ខ្លួន គប្បីឱ្យភត្តនិងអាហារសូម្បីដល់បុគ្គលទាំងនោះ ក្នុងវេលាធ្វើប៉ុណ្ណោះ ។ បើការងាររបស់សង្ឃមិនមាន, ពួកគេធ្វើការងាររបស់ខ្លួនឯងចិញ្ចឹមជីវិត, បើពួកគេនាំយកមូលតម្លៃហត្ថកម្មមកប្រគេនគប្បីទទួល ។ បើពួកគេមិនប្រគេន ក៏កុំនិយាយពាក្យណាមួយឡើយ ។ ការទទួលទាស អ្នកជ្រលក់សំពត់ក្តី ទាសជាងតម្បាញក្តី យ៉ាងណាមួយដោយឈ្មោះថា អារាមិកជន គួរ ។

បើពួកទាយកពោលថា “ពួកខ្ញុំព្រះករុណាប្រគេនគោទាំងឡាយ” ដូច្នេះ, ភិក្ខុគប្បីហាមពួកគេថា “មិនសមគួរ” កាលមានពួកអ្នកស្រុកសួរថា “គោទាំងនេះ លោកបានមកពីណា ?” គប្បីប្រាប់គេថា “ពួកបណ្ឌិត

ប្រគេនទុក ដើម្បីប្រយោជន៍ដល់ការបរិភោគបញ្ចគោរស" ។ កាលពួកគេពោលថា "សូមពួកខ្ញុំព្រះករុណា ក៏ប្រគេន ដើម្បីប្រយោជន៍បរិភោគបញ្ចគោរស" ដូច្នេះ គួរ ។ សូម្បីក្នុងបសុសត្វមានមេពពែជាដើម ក៏ន័យនេះឯង ។

ពួកអ្នកស្រុកពោលថា "ពួកខ្ញុំព្រះករុណាសូមប្រគេនដំរី, ប្រគេនសេះ, ក្របី, មាន់, ជ្រូក" ដូច្នេះ, នឹងទទួលមិនគួរ ។ បើពួកអ្នកស្រុកខ្លះពោលថា "លោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយជាអ្នកខ្វល់ខ្វាយតិចចុះ, ពួកខ្ញុំព្រះករុណានឹងទទួលសត្វទាំងនេះ ហើយប្រគេនកប្បិយភណ្ឌៈដល់លោកម្ចាស់ទាំងឡាយ" ហើយទទួលទៅ, រមែងគួរ ។ នឹងលែងចោលក្នុងព្រៃដោយពោលថា "មាន់និងជ្រូកទាំងនេះ ចូរនៅតាមសប្បាយចុះ" ដូច្នេះ ក៏គួរ ។ កាលគេពោលថា "ពួកខ្ញុំព្រះករុណាប្រគេនស្រះនេះ ស្រែនេះ ចំការនេះដល់វិហារ" ភិក្ខុនឹងបដិសេធមិនបានដូច្នេះឯង ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ មានអត្ថងាយយល់ទាំងអស់ដូច្នេះឯង ។

បណ្តាសមុដ្ឋានជាដើម សិក្ខាបទសូម្បីនេះ ក៏មាន សមុដ្ឋាន ៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ពណិនាភាជសិក្ខាបទ ចប់

# ចំនួនសិក្ខាបទក្នុងចីវរវគ្គទី ១ នោះ គឺ

| | |
|---|---|
| ១, កឋិនសិក្ខាបទ | ការអស់អំណាចកឋិន ទុកអតិរេកចីវរហួស ១០ ថ្ងៃ |
| ២, ឧទ្ទោសិតសិក្ខាបទ | ការនៅប្រាសចាកចីវរ កន្លងមួយរាត្រី |
| ៣, អកាលចីវរសិក្ខាបទ | ការទុកអកាលចីវរហួសមួយខែ |
| ៤, បុរាណចីវរសិក្ខាបទ | ការប្រើភិក្ខុនីមិនមែនញាតិឱ្យលាងចីវរចាស់ |
| ៥, ចីវរបដិគ្គហណសិក្ខាបទ | ការទទួលចីវរពីដៃភិក្ខុនីមិនមែនជាញាតិ |
| ៦, អញ្ញាតកវិញ្ញត្តិសិក្ខាបទ | ការសូមចីវរពីគ្រហស្ថមិនមែនជាញាតិ |
| ៧, តតុត្តរិសិក្ខាបទ | ការសូមចីវរហួសពីអន្តរវាសកៈ និងឧត្តរាសង្គៈ |
| ៨, បឋមឧបក្ខដសិក្ខាបទ | ការទៅនិយាយនឹងគ្រហស្ថមិនមែនជាញាតិ ឱ្យគេប្រគេនចីវរល្អ |
| ៩, ទុតិយឧបក្ខដសិក្ខាបទ | ការឱ្យគេរួបរួមថ្លៃគ្នា ដើម្បីទិញចីវរឱ្យល្អ |
| ១០, រាជសិក្ខាបទ | ការតឹងទារចីវរហួសបីដង នឹងឈរហួសប្រាំមួយដង |

## ចប់ កឋិនវគ្គ ទី ១

# កោសិយវគ្គ

## ១. កោសិយសិក្ខាបទវណ្ណនា

[៧៤] កោសិយសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងកោសិយសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៧៥] ប្រើនបទថា សន្ថរិត្វា កតំ ហោតិ : គ្រឿងកម្រាលដែល (មិនបានត្បាញ) គេស្ទាច់សម្រេចតែម្តង មានសេចក្តីថាសន្ថត់ដែលលាតសរសៃសូត្រត្រួត ៗ គ្នា លើផ្ទៃដីស្មើ ហើយយកទឹកបាយជាដើមចាក់ស្រោចចុះទៅហើយស្ទាច់ (បិទសំពត់ភ្ជាប់គ្នាប្រើនស្រទាប់ដោយវត្ថុស្អិត) ។

ក្នុងពាក្យថា ឯកេនបិ កោសិយំសុនា មិស្សិត្វា : ភិក្ខុលាយដោយសរសៃសូត្រ សូម្បីមួយសរសៃ នេះ អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យថា សន្ថត់ដែលលាយ (សូត្រ) ដោយអំណាចនៃសេចក្តីពេញចិត្តរបស់ខ្លួនឯងចូរលើកទុក, បើសូម្បីថា ខ្យល់បក់យកសូត្រតែមួយសរសៃ ទៅទម្លាក់ចុះក្នុងទីស្ទាច់សន្ថត់នោះ សូម្បីយ៉ាងនេះ ក៏ឈ្មោះថាស្ទាច់សន្ថត់លាយ (ដោយសូត្រ) ដូចគ្នា ។ ពាក្យដ៏សេសគ្រប់ ៗ កន្លែងមានអត្ថងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត៣ វេទនា៣ ដូច្នេះឯង ។

ពណ៌នាកោសិយសិក្ខាបទទី ១ ចប់

## ២. សុទ្ធកាឡកសិក្ខាបទវណ្ណនា

[៧៨] សុទ្ធកាឡកសិក្ខាបទថា តេន សមយេន : សម័យនោះ ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ៖

ក្នុងសុទ្ធកាឡកសិក្ខាបទនោះ បទថា សុទ្ធកាឡកានំ : ខ្មៅសុទ្ធ សេចក្តីថា ខ្មៅសុទ្ធ គឺ ខ្មៅមិនលាយដោយរោមចៀមយ៉ាងដទៃ ។ ពាក្យដ៏សេសមានអត្ថងាយយល់ទាំងអស់ ។

សូម្បីសមុដ្ឋានជាដើម ក៏ដូចគ្នា នឹងកោសិយសិក្ខាបទនុ៎ះឯង ។

ពណ៌នាសុទ្ធកាឡកសិក្ខាបទទី ២ ចប់

# ៣. ទ្វេភាគសិក្ខាបទវណ្ណនា

[៨២] ទ្វេភាគសិក្ខាបទថា តេន សមយេន : សម័យនោះជា ដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងទ្វេភាគសិក្ខាបទនោះ មាន វិនិច្ឆ័យដូច្នេះ ៖

ពីរបទថា អន្តេ អាទិយិត្វា : លាយបន្តិចត្រង់ជាយ មាន សេចក្តីថា ឱ្យភ្ជាប់រោម ចៀមសទុកត្រង់ជាយនៃសន្ថតដូចអនុវាទត្រង់ជា យសំពត់ដូច្នោះ ។

[៨៣] ពីរបទថា ទ្វេ ភាគា : ពីរភាគ គឺ ២ ចំណែក ។

បទថា អាទាតព្វា : ហើយសឹមកាន់យក គឺ គប្បីកាន់យក ។

បទថា គោចរិយានំ : រោមចៀមក្រហម ប្រែថា មានពណ៌ ក្រហម ។

ពាក្យថា ទ្វេ តុលា អាទាតព្វា : ភិក្ខុថ្លឹងពីរជញ្ជីង ហើយ សឹមកាន់យក លោកពោលសំដៅយក ភិក្ខុដែលប្រាថ្នានឹងឱ្យធ្វើដោយ រោមចៀម ៤ចំណែក ។ បណ្ឌិតគប្បីជ្រាបសន្និដ្ឋានថា ក៏ដោយសេចក្តី ជាការទ្រង់សម្តែងពាក្យនេះតែម្តងថា ភិក្ខុមានសេចក្តីប្រាថ្នានឹងធ្វើដោយ រោមចៀម មានប្រមាណប៉ុន្មាន, ក្នុងរោមចៀមមានប្រមាណប៉ុណ្ណោះ រោមចៀមខ្មៅ ២ចំណែករោមចៀមស១ ចំណែក រោមចៀមក្រហម

១ចំណែក ។ ពាក្យដ៏សេសមានអត្ថងាយយល់ទាំងអស់ ។

សមុដ្ឋានជាដើម ក៏ដូចកោសិយសិក្ខាបទទុំះឯង ។ សិក្ខាបទនេះ អ្នកសិក្សាគប្បីជ្រាបថា ជាកិរិយានិងអកិរិយាតែម្យ៉ាង ព្រោះកាន់យកនិងមិនកាន់យកធ្វើ ដូច្នេះឯង ។

ពណ៌នាវិភាគសិក្ខាបទទី ៣ ចប់

# ៤. ឆព្វស្សសិក្ខាបទវណ្ណនា

[៨៦] ឆព្វស្សសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ៖

ពីរបទថា ឧហទន្តិបិ ឧម្មិហន្តិបិ : ជុះដាក់ខ្លះ នោមដាក់ខ្លះ មានរូបសេចក្ដីដែលលោកពោលទុកថា ពួកក្មេង ៗ បន្ទោបង់ឧច្ចារៈស្រោចខ្លះ បន្ទោបង់បស្សាវៈស្រោចខ្លះ ខាងលើសន្ថត់ទាំងឡាយ ។

ព្រះបុស្សទេវត្ថេរៈពោលថា ភិក្ខុដែលបានទទួលសន្មតយ៉ាងនេះថា សន្ថតសម្មតិសង្ឃឱ្យហើយដល់ភិក្ខុឈ្មោះនេះ រមែងបានដើម្បីធ្វើសន្ថតក្នុងទីដែលខ្លួនទៅដល់រហូតដល់អស់វេលា ដែលរោគមិនទាន់សះស្បើយ ។ បើលោកសះស្បើយរោគហើយ ត្រឡប់អាពាធទៀតដោយ

ព្យាធិពីដើមនុ៎ះឯង, បរិហារ (ការឃុំគ្រង) នោះឯងតាំងនៅ, មិនមានកិច្ចដែលនឹងត្រូវសន្មតទៀត ។

ចំណែកព្រះឧបតិស្សថេរៈពោលថា អាពាធនោះកម្រើកឡើងឬ អាពាធដទៃក៏ដោយ, លោកបានឈ្មោះថា ជាអ្នកអាពាធ ក៏ជាការបានហើយនោះឯង, មិនមានកិច្ចដែលនឹងត្រូវសន្មតថ្មី ។

ពាក្យថា ឱរេន ចេ ឆន្នំ វស្សានំ : បើប្រើមិនទាន់គ្រប់ប្រាំមួយឆ្នាំទេ បានដល់ ចំណែករួមក្នុងគឺ ខាងក្នុង៦ ឆ្នាំ ។ តែក្នុងបទភាជនៈ ដើម្បីសម្តែងត្រឹមតែសង្ខតា ទើបត្រាស់ថា នៅខ្វះ៦ ឆ្នាំ ។

[៩០] ពាក្យថា អនាបត្តិ ឆព្វស្សានិ ករោតិ : អាបត្តិមិនមានដល់ភិក្ខុប្រើប្រាស់សន្ថតចាស់ដល់ ៦ ឆ្នាំ ហើយធ្វើសន្ថតថ្មីទៀត មានសេចក្តីថា រមែងធ្វើសន្ថតក្នុងវេលាគ្រប់ ៦ឆ្នាំបរិបូណ៌ ។ សូម្បីក្នុងបទទី ២ គប្បីឃើញសេចក្តីយ៉ាងនេះថា ធ្វើក្នុងវេលាលើស៦ វស្សាទៅ ។ សេចក្តីពិត ភិក្ខុនោះនឹងធ្វើរហូតដល់អស់ ៦ឆ្នាំ ក៏ទេ ។ ពាក្យដ៏សេសមានអត្ថងាយយល់ទាំងអស់ ។ សមុដ្ឋានជាដើម ក៏ដូចកោសិយសិក្ខាបទនុ៎ះឯង, តែសិក្ខាបទនេះជាកិរិយានិងអកិរិយា ដូច្នេះឯង ។

ពណ៌នាឆព្វស្សសិក្ខាបទទី ៤ ចប់

# ៥. និសីទនសន្ថតសិក្ខាបទវណ្ណនា

[៩១] និសីទនសន្ថតសិក្ខាបទថា តេន សមយេន : សម័យនោះ ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងនិសីទនសន្ថតសិក្ខាបទនោះ មានវិនិច្ឆ័យដូច តទៅនេះ ៖

ពីរបទថា ឥច្ឆាមហំ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា សេចក្តីថា បានឮថា ព្រះមានព្រះភាគ ទតមិនឃើញសត្វដែលគួរឱ្យត្រាស់ដឹងណាមួយឡើយ រហូតអស់ខាងក្នុងត្រៃមាសនោះ ; ព្រោះហេតុនោះ ទើបត្រាស់យ៉ាងនេះ ។ សួម្បីកាលជាយ៉ាងនោះ ព្រះអង្គក៏នឹងត្រូវទ្រង់ធ្វើព្រះធម្មទេសនា ដោយអំណាចនៃតន្តិប្រពៃណី ។

មួយទៀត ព្រោះព្រះអង្គបានទ្រង់មានព្រះតម្រិះយ៉ាងនេះថា កាលតថាគតឱ្យធ្វើឱកាសពួនសម្ងំនោះ ភិក្ខុទាំងឡាយនឹងធ្វើកតិកាវត្តដែលមិនប្រកបដោយធម៌, ឧបសេនៈនឹងទម្លាយកតិកាវត្តដែលមិនប្រកបដោយធម៌នោះ, តថាគតនឹងជ្រះថ្លា ( ពេញចិត្ត ) លោក ហើយអនុញ្ញាតឱ្យភិក្ខុទាំងឡាយចូលគាល់, បន្ទាប់ពីនោះ ពួកភិក្ខុដែលប្រាថ្នានឹងមកសួរសុខទុក្ខតថាគតជាច្រើន នឹងសមាទានធុតង្គទាំងឡាយ ហើយតថាគតនឹងបញ្ញត្តិសិក្ខាបទ ព្រោះសន្ថតដែលភិក្ខុទាំងនោះលះចោលជាបច្ច័យ ។ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនោះ ។ ក៏ក្នុងការពួនសម្ងំនេះ មាន

អានិសង្សច្រើនយ៉ាងនេះឯង ។

[៩២] ពាក្យថា សបរិសោ យេន ភគវា តេនុបសង្កមិ : ព្រមដោយបរិស័ទ បានចូលទៅគាល់សម្តេចព្រះមានព្រះភាគត្រង់ទីដែលព្រះអង្គគង់នៅ មានសេចក្តីថា បានឮថា ព្រះថេរៈបានទទួលការតិះដៀលក្នុងខន្ធកសិក្ខាបទនេះថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានវស្សាថយអំពី ១០ ចុះមក មិនត្រូវឱ្យឧបសម្បទាដល់កុលបុត្រឡើយ, ភិក្ខុណាឱ្យឧបសម្បទា, ត្រូវអាបត្តិទុក្កដ"[១] ដោយន័យមានជាដើមយ៉ាងនេះថា "នែមោឃបុរស អ្នកគួរតែឱ្យភិក្ខុដទៃទូន្មានប្រៀនប្រដៅ ដូចម្តេចឡើយ ក៏តាំងចិត្តទូន្មានប្រៀនប្រដៅភិក្ខុដទៃវិញ"[២] ទើបគិតថា ព្រះសាស្តាទ្រង់អាស្រ័យបរិស័ទរបស់យើងបានទ្រង់ប្រទានការតិះដៀលដល់យើង, ឥឡូវនេះ យើងនោះនឹងញ៉ាំងព្រះមានព្រះភាគ ឱ្យថ្លែងព្រះសូរសៀងដូចព្រហ្ម ដោយព្រះភក្ត្រដ៏បរិបូណ៌ដោយអាការគ្រប់យ៉ាង មានសិរីដូចព្រះចន្ទពេញបូរមីនោះឯង ហើយនឹងឱ្យប្រទានសាធុការ ព្រោះអាស្រ័យបរិស័ទនុ៎ះឯង ជាកុលបុត្រ ដែលមានហទយៈល្អ ធ្វើដំណើរកន្លងទៅបានជាង ១០០ យោជន៍ បានណែនាំបរិស័ទ ជាអ្នកដែលភិក្ខុ

---

១.២. វិន. មហា. មហាខន្ធក. ៦. ៩០/១៧៩ ។

ប្រមាណ ៥០០ រូប ហែហមហើយ ទើបចូលទៅគាល់ព្រះមានព្រះភាគទៀត ។ ព្រោះហេតុនោះ ព្រះធម្មសង្គីតិកាចារ្យ ទើបពោលថា សបរិសោ យេន ភគវា តេនូបសង្កមិ ជាដើម ។ ពិតមែន អ្នកណា ៗ មិនអាចនឹងឱ្យព្រះពុទ្ធទាំងឡាយ ប្រោសប្រាណបានដោយប្រការដទៃក្រៅអំពីវត្តសម្បត្តិ ។

ពាក្យថា ភគវតោ អវិទូរេ និសិន្នោ : អង្គុយជិតព្រះដ៏មានព្រះភាគ មានសេចក្ដីថា ភិក្ខុនោះជាអ្នកអស់សេចក្ដីរង្កៀស ព្រោះជាអ្នកបរិសុទ្ធិដោយវត្ត សម្បត្តិ ទើបអង្គុយក្នុងទីមិនឆ្ងាយព្រះមានព្រះភាគដូចសីហៈ អង្គុយនៅជិតល្អាងនៃភ្នំមាសដូច្នោះ ។

បទថា ឯតទវោច : ត្រាស់សួរយ៉ាងនេះ គឺ ព្រះមានព្រះភាគបានត្រាស់ពាក្យនេះ ដើម្បីលើករឿងរ៉ាវឡើង ។

ពាក្យថា មនាបានិ តេ ភិក្ខុ បំសុកូលានិ : ម្នាលភិក្ខុ បង្សុកូលទាំងឡាយ ជាទីគាប់ចិត្តរបស់អ្នកដែរឬ សេចក្ដីថា ម្នាលភិក្ខុ សំពត់បង្សុកូលទាំងនេះ ជាទីពេញចិត្តរបស់អ្នកឬ ? គឺ អ្នកកាន់តាមសេចក្ដីពេញចិត្ត តាមសេចក្ដីគាប់ចិត្តរបស់ខ្លួនឬ ?

ដោយពាក្យថា ន ខោ មេ ភន្តេ មនាបានិ : បពិត្រព្រះអង្គ

ដ៏ចម្រើន មិនជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គទេ នេះ ភិក្ខុនោះ រមែងសម្ដែងថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានកាន់តាមសេចក្ដីពេញចិត្ត តាមសេចក្ដីគាប់ចិត្តរបស់ខ្លួន គឺ ខ្ញុំព្រះអង្គ ជាអ្នកត្រូវឧបជ្ឈាយ៍ឱ្យកាន់ដូចបុគ្គលត្រូវបង្គាប់ឱ្យ កាន់ដោយការបង្ខិតបង្ខំ និងដោយការវាយត្រង់ក្បាលដូច្នោះ ។

បទថា បញ្ញាយិស្សតិ : បានបញ្ញត្ត មានសេចក្ដីថា នឹងជាអ្នកប្រាកដ គឺ ជាអ្នកមានកេរ្តិ៍ឈ្មោះ ។ មានពាក្យអធិប្បាយថា នឹងប្រាកដក្នុងកតិកានោះ ។

ពាក្យថា ន មយំ អប្បញ្ញត្តំ បញ្ញាបេស្សាម : ខ្ញុំព្រះអង្គទាំងឡាយ នឹងមិនបញ្ញត្តនូវហេតុដែលព្រះអង្គមិនទាន់បានបញ្ញត្តទុកហើយទេ មានសេចក្ដីថា យើងទាំងឡាយ ឈ្មោះថា ជាសាវក នឹងមិនបញ្ញត្តិសិក្ខាបទ ដែលព្រះមានព្រះភាគមិនបានទ្រង់បញ្ញត្តិទុក ។ ពិតមែនវិស័យ គឺ ការបញ្ញត្តិសិក្ខាបទដែលមិនបានទ្រង់បញ្ញត្តិ ឬការដកសិក្ខាបទដែលទ្រង់បញ្ញត្តិទុកហើយ ដោយន័យថា បាចិត្តិយ ទុក្កដជាដើមនេះ ជាពុទ្ធវិស័យ ។

ដោយបទថា សមាទាយ : កាន់យកតាម នេះ ព្រះឧបសេនៈសម្ដែងថា "យើងទាំងឡាយ នឹងសមាទានសិក្ខាបទនោះ ៗ" ហើយ

ទទួលថា "ល្អណាស់ ដោយល្អ" ដូច្នេះ ហើយនឹងសិក្សាក្នុងសិក្ខាបទទាំងពួង តាមដែលព្រះពុទ្ធអង្គទ្រង់បញ្ញត្តិទុក ។ ព្រះមានព្រះភាគទ្រង់មានព្រះហឫទ័យត្រេកត្រអាលហើយ បានទ្រង់ធ្វើសាធុការសួម្បីទៀតដល់ព្រះឧបសេនៈនោះថា "ល្អណាស់ ល្អណាស់" ។

បទសន្ធិថា អនុញ្ញាតាវុសោ កាត់បទថា អនុញ្ញាតំ អាវុសោ : ម្នាលអាវុសោ ព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ។

[៩៣] បទថា បិហាលុ : កាលប្រាថ្នា គឺ សង្ឃឹមក្នុងចិត្ត ។

ពីរបទថា សន្ថតានិ ឧជ្ឈិត្វា : ទើបលះបង់ចោលនូវសន្ថតទាំងឡាយ មានសេចក្តីថា លះចោលសន្ថតទាំងពួងហើយ ព្រោះជាអ្នកមានការសម្គាល់ក្នុងសន្ថតថា ជាចីវរផ្ចុំនទី ៤ ។

ពាក្យថា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ : ទើបទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយ មានសេចក្តីថា ព្រះមានព្រះភាគ ទតឃើញសន្ថតទាំងឡាយរាត់រាយពាសពេញ ហើយទ្រង់ត្រិះរិះថា "មិនមានហេតុក្នុងការដែលនឹងញ៉ាំងសទ្ធាទេយ្យឱ្យធ្លាក់ទៅ, តថាគតនឹងសម្តែងឧបាយក្នុងការប្រើប្រាស់ ដល់ភិក្ខុទាំងនោះ" ហើយទ្រង់ធ្វើធម្មីកថាត្រាស់ជាស់តឿនភិក្ខុទាំងឡាយ ។

[៩៤] ពាក្យថា សកឹ និវត្ថំបិ សកឹ បារុតំបិ : សូម្បីស្លៀកម្តង សូម្បីដណ្តប់ម្តង បានដល់ អង្គុយនិងដេកហើយអស់វារៈម្តង ៗ

បទថា សាមន្តា : ដោយជុំវិញ មានសេចក្តីថា គប្បីកាន់យកដោយប្រការដែលខ្លួនកាត់យកជារង្វង់មូល ឬជាបួនជ្រុង( ចតុរស្ស )អំពីជាយម្ខាង មានប្រមាណមួយចំអាម ៗ តែភិក្ខុកាលនឹងក្រាល គប្បីពាក់ចុះក្នុងឯកទេស ឬ ត្រដោះ( រុះ )ចេញហើយក្រាលឱ្យផ្សំគ្នា ដោយន័យដូចពោលក្នុងបាលីនោះឯង ។ សន្ថ័តដែលភិក្ខុ ស្អាច់ហើយយ៉ាងនេះ នឹងជារបស់មាំទាំក្រៃលែងឡើង ។ ពាក្យដ៏សេសមានអត្ថងាយយល់ទាំងអស់នោះឯង ។ សមុដ្ឋានជាដើម នៃសិក្ខាបទនេះ ដូចគ្នានឹងទ្វេភាគសិក្ខាបទ ព្រោះជាកិរិយានិងអកិរិយា ដូច្នេះឯង ។

និសីទនសន្ថតសិក្ខាបទទី ៥ ចប់

ក៏ក្នុងសន្ថ័តទាំង ៥ ប្រភេទនេះ, សន្ថ័ត ៣ ប្រភេទខាងដើម អ្នកសិក្សាគប្បីជ្រាបថា ធ្វើវិន័យកម្មហើយបានមក មិនគួរ ប្រើប្រាស់, ២ ប្រភេទខាងក្រោយធ្វើវិន័យកម្មហើយបានមក នឹងប្រើប្រាស់ គួរ ៗ

# ៦. ឯឡកលោមសិក្ខាបទវណ្ណនា

[៩៧] ឯឡកលោមសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងឯឡកលោមសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា ឧប្បណ្ឌេសុំ : នាំគ្នានិយាយចំអក មានសេចក្ដីថា ពួកអ្នកស្រុកពោលពាក្យចំអកលេងជាដើមថា "លោកម្ចាស់ (រោមចៀមនេះ) លោកម្ចាស់ទិញមកថ្លៃប៉ុន្មាន ?"

ពីរបទថា ឋិតកោវ អាសុម្ភិ : អ្នកឈរទម្លាក់ចោល មានសេចក្ដីថា ពួកអ្នកស្រុកជញ្ជូនបាច់ឧសអម្រែកធំមកពីព្រៃនឿយហត់ហើយបោះចុះទៅ ទាំងនៅឈរយ៉ាងណា ភិក្ខុនេះបានបោះ (រោមចៀម) ឱ្យធ្លាក់ចុះទៅយ៉ាងនោះ ។

[៩៨] បទថា សហត្ថា : ដៃខ្លួនឯង គឺ ដោយដៃខ្លួនឯង ។ មានពាក្យអធិប្បាយថា នាំទៅដោយខ្លួនឯង

ពីរបទថា ពហិតិយោជនំ បាតេតិ : តែចោលរោមចៀមឱ្យធ្លាក់ចុះខាងក្រៅបីយោជន៍ មានសេចក្ដីថា បោះចេញទៅខាងក្រៅ ៣ យោជន៍ ។ កាលរោមចៀមនឹងធ្លាក់ទៅ ដោយមិនមានអន្តរាយ ល្មមផុតពីដៃ ជានិស្សគ្គិយបាចិត្តិយច្រើន តាមចំនួនសរសៃរោម ។ បើរោម

ចៀមដែលបោះទៅនោះប៉ះខ្ទប់ដើមឈើ ឬសសរខាងក្រៅ ៣ យោជន៍ ហើយធ្លាក់ចុះខាងក្នុង(៣ យោជន៍)ទៀត មិនទាន់ត្រូវអាបត្តិ ។ បើបង្វេចរោមចៀម ធ្លាក់ចុះដល់ផែនដីឈប់ហើយប្រមៀលទៅ ត្រឡប់ចូលមកខាងក្នុង(៣ យោជន៍) ទៀត ត្រូវអាបត្តិពិត ។

ភិក្ខុឈរខាងក្នុងយកដៃ ឬជើង ឬឈើប្រត់ប្រមៀលទៅ, បង្វេចរោមចៀមនឹងឈប់ ឬមិនឈប់ក៏ដោយ ប្រមៀលចេញទៅ, ត្រូវអាបត្តិដូចគ្នា ។ ភិក្ខុដាក់ទុកដោយតាំងចិត្តថា អ្នកដទៃនឹងនាំទៅ, សូម្បីកាលអ្នកនោះនាំរោមចៀមទៅត្រូវអាបត្តិដូចគ្នា ។ រោមចៀមដែលភិក្ខុដាក់ទុកដោយចិត្តបរិសុទ្ធ ខ្យល់បក់ទៅឬអ្នកដទៃធ្វើឱ្យធ្លាក់ទៅ ខាងក្រៅដោយធម្មតារបស់ខ្លួន ត្រូវអាបត្តិដូចគ្នា ។ ព្រោះភិក្ខុមានឧស្សាហ៍ និងព្រោះសិក្ខាបទជាអចិត្តកៈ ។ តែក្នុងកុរុន្ទីជាដើមលោកពោលអនាបត្តិទុកព្រោះរោមចៀមដែលត្រូវខ្យល់បក់ទៅ ឬបុគ្គលដទៃឱ្យធ្លាក់ទៅខាងក្រៅនេះ ។ អនាបត្តិដែលលោកពោលទុកនោះ មិនសមតាមបាលីនៃអនាបត្តិវារ ។

ភិក្ខុធ្វើបង្វេចទាំងពីរខាងឱ្យជាប់គ្នា កាលដាក់ទុកឱ្យបង្វេចមួយនៅខាងក្នុងព្រំប្រទល់ មួយបង្វេចទៀតឱ្យនៅខាងក្នុងខេត្តក្រៅព្រំប្រទល់, នៅរក្សានៅឡើយ ។ សូម្បីក្នុងអម្រែកដែលជាប់គ្នា ក៏មានន័យដូចគ្នានេះ ។ តែបើថា រោមចៀមត្រឹមតែ ភិក្ខុដាក់ទុកត្រង់ចុងអម្រែកមិនបាន

ចងឡើយ, រមែងការពារអាបត្តិមិនបាន ។ កាលភិក្ខុផ្លាស់ប្ដូរសូម្បីរោមចៀមដែលជាប់តគ្នាទៅ ដាក់ទុកជំនួស ក៏ត្រូវអាបត្តិដូចគ្នា ។

ក្នុងពាក្យថា អញ្ញស្ស យានេ វា : ភិក្ខុដាក់រោមចៀមក្នុងយានក្ដីនៃអ្នកដទៃ នេះ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុដាក់ទុកលើយាន ឬលើខ្នងដំរីជាដើម ដែលកំពុងទៅ ដោយតាំងចិត្តថា កាលម្ចាស់របស់គេមិនដឹងនោះ វានឹងនាំទៅឯង, កាលយាននោះ កន្លងហួស ៣ យោជន៍ ទៅត្រូវអាបត្តិ ។ សូម្បីក្នុងយានដែលចតនៅ ក៏មានន័យយ៉ាងនេះដូចគ្នា ។ ក៏បើថា ភិក្ខុដាក់រោមចៀមទុកលើយាន ឬលើខ្នងដំរីជាដើមដែលមិនទៅ ហើយឡើងជិះបរទៅ ឬទៅដេញខាងក្រោម ឬហៅឱ្យទៅតាម, មិនមានអាបត្តិ ព្រោះព្រះបាលីថា **អញ្ញំ ហរាបេតិ** : ភិក្ខុឱ្យអ្នកដទៃនាំយកទៅ ។ តែក្នុងកុរុន្ទីជាដើមលោកពោលថា ត្រូវអាបត្តិ ។ ពាក្យនោះមិនសមតាមពាក្យនេះថា ភិក្ខុឱ្យអ្នកដទៃជួយនាំទៅ ។ ក៏ក្នុងអទិន្នាទានត្រូវអាបត្តិ ព្រោះសុង្កឃាដ (បំបាត់ភាសី) ។ ពិតមែន អាបត្តិណា ក្នុងអទិន្នាទាននោះ, អាបត្តិនោះ ជាអនាបត្តិក្នុងសិក្ខាបទនេះ, អាបត្តិណាក្នុងសិក្ខាបទនេះ, អាបត្តិនោះ ជាអនាបត្តិក្នុងអទិន្នាទាននោះ ។

ភិក្ខុទៅដល់ស្ថានទីនោះបញ្ជូនចិត្តទៅដទៃ ឬត្រូវពួកចោរជាដើម

រកកួនហួសទៅក្តី, ត្រូវអាបត្តិដូចគ្នា ។ គប្បីជ្រាបចំនួនអាបត្តិ តាមចំនួនសរសៃរោមក្នុងឋានៈទាំងពួង ។

[១០០] ត្រើនបទថា តិរោជនំ វាសាធិប្បាយោ គន្ត្វា តតោ បរំ ហរតិ : ដល់ភិក្ខុប្រាថ្នាដើម្បីនឹងនៅ តែត្រូវទៅកាន់ទីមានចម្ងាយមកបីយោជន៍ ហើយនាំយករោមចៀមទៅកាន់ទីដទៃចាកទីនោះ មានសេចក្តីថា មិនមានអាបត្តិដល់ភិក្ខុដែលនាំទៅ សូម្បីទាំងវយោជន៍យ៉ាងនេះ គឺ ព្រោះមិនបានឧទ្ទេស និងបរិបុច្ឆាជាដើម ឬបច្ច័យជាដើមក្នុងទីដែលខ្លួនទៅហើយ ភិក្ខុទើបទៅក្នុងទីដទៃអំពីទីនោះ, ទៅក្នុងទីដទៃសូម្បីចាកទីនោះ ។

ពីរបទថា អច្ឆិន្នំ បដិលភិត្វា : ត្រឡប់បានរោមចៀមដែលចោរលួចយកទៅហើយនាំយកទៅ មានសេចក្តីថា ពួកចោរដណ្តើមយករោមចៀមនោះទៅ ដឹងថា មិនមានប្រយោជន៍ ហើយយកមកឱ្យវិញ, មិនមានអាបត្តិដល់ភិក្ខុដែលនាំរោមចៀមនោះទៅ ។

ពីរបទថា និស្សដ្ឋំ បដិលភិត្វា : ត្រឡប់បានរោមចៀមដែលលះបង់ដោយវិនយកម្មហើយនាំយកទៅ មានសេចក្តីថា បានរោមចៀមដែលធ្វើវិន័យកម្មហើយបានមកវិញ ។

បទថា កតភណ្ឌំ : របស់ដែលធ្វើហើយ មានសេចក្តីថា រោម

ចៀមដែលគេធ្វើជាវត្ថុ មានសំពត់កម្ពល ព្រំ និងសន្ថតជាដើម យ៉ាងណាមួយ ដោយហោចទៅសូម្បីត្រឹមតែចងដោយសរសៃអំបោះ ។ មួយទៀត ភិក្ខុណា ស៊ិករោមចៀមចុះក្នុងចន្លោះស្លោកបាត្រខ្លះ ៗក្តី ក្នុងសំពត់រឹតជើង(ជង្គង់) សំពត់អង្សៈ និង វត្ថុពន្ធចង្កេះជាដើមក្តី ក្នុងស្រោមកាំបិត ដើម្បីការពារស្នឹមកន្ត្រៃជាដើមក្តី ដោយហោចទៅ សូម្បីអាពាធកើតអំពីខ្យល់ សៀតរោមចៀមទុកសូម្បីក្នុងរន្ធត្រចៀកហើយដើរទៅត្រូវអាបត្តិដល់ភិក្ខុនោះដូចគ្នា, តែរោមចៀមដែលចងដោយអំបោះដាក់ទុក (ក្នុងចន្លោះស្បែកជើង និងស្លោកបាត្រជាដើម) រមែងតាំងនៅក្នុងឋានៈនៃរោមចៀមដែលធ្វើជាវត្ថុ ។ ភិក្ខុធ្វើឱ្យជាផ្នួងសក់ហើយនាំទៅ, នេះឈ្មោះថា គេចវាងយក, ត្រូវអាបត្តិ ដូចគ្នា ។ ពាក្យដ៏សេសមានអត្ថងាយយល់ទាំងអស់ ។

បណ្តាសមុដ្ឋានជាដើម ឯឡូកលោមសិក្ខាបទនេះ ឈ្មោះថា ឯឡូកលោមសមុដ្ឋាន (មានរោមចៀមជាសមុដ្ឋាន) រមែងកើតអំពីកាយ ១ កាយចិត្ត ១ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ឯឡូកលោមសិក្ខាបទទី ៦ ចប់

# ៧. ឯឡកលោមធោវាបនសិក្ខាបទវណ្ណនា

[១០១] ឯឡកលោមធោវាបនសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ៖

បណ្ដាបទទាំងនោះ បទថា វិញ្ចន្តិ : លះបោល បានដល់ បោះបង់ចោល គឺ រមែងលះបង់ចេញ ។ មានពាក្យអធិប្បាយថា រមែងមិនអាចដើម្បីប្រកបរឿយ ៗ ។

ពាក្យដ៏សេសក្នុងឯឡកលោមធោវាបនសិក្ខាបទនេះ ព្រមទាំងសមុដ្ឋានជាដើម មានន័យដូចពោលហើយ ក្នុងបុរាណចីវរសិក្ខាបទនោះឯង ។

ឯឡកលោមធោវាបនសិក្ខាបទទី ៧ ចប់

# ៨. រូបិយសិក្ខាបទវណ្ណនា

[១០៥] រូបិយសិក្ខាបទថា យោ បន ភិក្ខុ ជាតរូបរជតំ : ឧគ្គណ្ហេយ្យ វា... 

ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងរូបិយសិក្ខាបទនោះ មាន វិនិច្ឆ័យដូចតទៅនេះ ៖

បទថា បដិវិសោ : ចំណែក ប្រែថា ចំណែក ។

ក្នុងបទថា ជាតរូបរជតំ : នូវមាសប្រាក់ នេះ ពាក្យថា ជាតរូប ជាឈ្មោះនៃមាស ។ ក៏ព្រោះមាសនោះដូចគ្នានឹងព្រះឆវិវណ្ណនៃ ព្រះតថាគត ; ព្រោះដូច្នោះ លោកទើបពោលទុកក្នុងបទភាជនៈថា បីដូច ជាពណ៌នៃព្រះសាស្ដា ។

សេចក្ដីនៃបទភាជនៈនោះថា លោហៈពិសេសមានពណ៌លឿង ដូចជាព្រះឆវិវណ្ណរបស់ព្រះសាស្ដា នេះឈ្មោះថា ជាតរូប[1] ។ ចំណែក ប្រាក់លោកហៅថា រូបិយៈ[2] ក្នុងពាក្យទាំងឡាយថា ស័ង្ខ សិលា ប្រវាឡ ប្រាក់ មាសជាដើម ។ តែក្នុងសិក្ខាបទនេះ លោកប្រាថ្នាយក កហាបណៈជាដើមយ៉ាងណាមួយ ដែលដល់វោហារគេចាយវាយបាន ។ ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទថា រជតំ នោះ លោកទើប ពោលពាក្យថា កហាបណៈ លោហមាសក ដូច្នេះជាដើម ។

---

១. រូបធម្មជាតិគឺមាស ។ ២. រូបិយៈ គឺពណ៌ដែលមានលំអរ សស្អាត ។

## អធិប្បាយវត្ថុនៃនិស្សគ្គិយនិងទុក្កដ

[១០៦] បណ្តាបទថា កហាបណៈជាដើមនោះ កហាបណៈដែលគេធ្វើដោយមាសក្តី ធ្វើដោយប្រាក់ក្តី កហាបណៈធម្មតាក្តី ឈ្មោះថា កហាបណៈ ។

មាសក ដែលធ្វើដោយរ៉ែទង់ដែងជាដើម ឈ្មោះថា លោហមាសក ។

មាសកដែលធ្វើដោយឈើខ្លឹមក្តី ដោយឫស្សីក្តី ដោយហោចទៅ សូម្បីមាសកដែលគេធ្វើដោយស្លឹកត្នោត ឆ្លាក់ជារូប ក៏ឈ្មោះថា មាសកឈើ ។

មាសកដែលគេធ្វើដោយអាចម៍ល័ក្ខក្តី ដោយជ័រក្តី សូនឱ្យកើតរូបឡើង ឈ្មោះថា មាសកជ័រ ។

ក៏ដោយបទថា **យេ វោហារំ គច្ឆន្តិ : រមែងដល់នូវវោហារ**នេះ លោកសង្គ្រោះយកមាសកទាំងអស់ ដែលប្រើជាកំណត់មាត្រាតម្លៃទិញដូរក្នុងជនបទ ក្នុងវេលាទិញដូរគ្នា ដោយហោចទៅធ្វើដោយឆ្អឹងខ្លះ ធ្វើដោយស្បែកខ្លះ ធ្វើដោយគ្រាប់ផ្លែឈើខ្លះ សូនឱ្យជារូបខ្លះ មិនបានសូនឱ្យជារូបខ្លះ ។ វត្ថុទាំង ៤ យ៉ាង គឺ ប្រាក់ មាស ទាំងអស់នេះ

យ៉ាងនេះ(និង) មាសកមាស មាសកប្រាក់ មានប្រភេទ ដូចពោល ហើយសូម្បីទាំងអស់ ចាត់ជាវត្ថុនៃនិស្សគ្គិយ, វត្ថុនេះ គឺ កែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រវាឡ ត្បូងទទឹម ពេជ្រភ្នែកឆ្មា ធញ្ញជាតិ ៧ ប្រភេទ ទាសា ទាសី ស្រែ ចំការ សួនផ្កាឈើ សួនផ្លែឈើជាដើម ចាត់ជាវត្ថុនៃទុក្កដ ។ វត្ថុនេះ គឺអំបោះ ផាលនង្គ័ល ផ្ទាំងសំពត់ កប្បាស អបរណ្ណជាតិមានច្រើនប្រការ និងភេសជ្ជៈ មានទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅជាដើម ចាត់ជាកប្បិយវត្ថុ ។

បណ្តានិស្សគ្គិយវត្ថុ និងទុក្កដវត្ថុនោះ ភិក្ខុទីងទទួលនិស្សគ្គិយវត្ថុ ដើម្បីប្រយោជន៍ខ្លួនឯង ឬដើម្បីប្រយោជន៍ដល់សង្ឃ គណៈ បុគ្គល និងចេតិយជាដើម រមែងមិនគួរ ។ ជានិស្សគ្គិយបាចិត្តិយ ដល់ភិក្ខុដែលទទួលដើម្បីប្រយោជន៍ដល់ខ្លួនឯង ។ ជាអាបត្តិទុក្កដ ដល់ភិក្ខុដែលទទួលដើម្បីប្រយោជន៍ដល់អ្នកដទៃជាដើមដ៏សេស ។ ត្រូវអាបត្តិទុក្កដតែម្យ៉ាង ដល់ភិក្ខុដែលទទួលទុក្កដវត្ថុ ដើម្បីប្រយោជន៍គ្រប់យ៉ាង, មិនមានអាបត្តិក្នុងកប្បិយវត្ថុ ។ ជាអាបត្តិបាចិត្តិយ ដោយអំណាចដែលមកក្នុងរតនសិក្ខាបទខាងមុខ ដល់ភិក្ខុដែលទទួលវត្ថុមានប្រាក់ជាដើម សូម្បីទាំងអស់ ដោយនាទីនៃភណ្ឌាគារិកដើម្បីត្រូវការនឹងរក្សាទុក ។

## ការទទួល ការប្រើឱ្យទទួល និងវិធីបដិបត្តិក្នុងរូបិយៈ

បទថា ឧគ្គណ្ហេយ្យ : ទទួលដោយខ្លួនឯង គឺ គប្បីកាន់យក ។ ក៏ព្រោះកាលភិក្ខុទទួលយកទើបត្រូវអាបត្តិ ; ដូច្នោះ ក្នុងបទភាជនៈនៃបទថា ឧគ្គណ្ហេយ្យ នោះ លោកទើបពោលថា ភិក្ខុទទួលដោយខ្លួនឯង ជានិស្សគ្គិយបាចិត្តិយ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យយ៉ាងនេះ ។

ក្នុងការទទួលដោយខ្លួនឯង និងប្រើឱ្យទទួលនោះ មានវិនិច្ឆ័យដូច្នេះ ៖

ជាអាបត្តិតែមួយដល់ភិក្ខុដែលទទួលដោយខ្លួនឯង ឬប្រើឱ្យគេទទួលវត្ថុតែមួយ ក្នុងបណ្តាកណ្ឋៈ គឺ មាស ប្រាក់ ទាំងកហាបណៈ និងមាសក ។ បើសូម្បីថា ភិក្ខុទទួលដោយខ្លួនឯង ឬប្រើឱ្យទទួលទាំងពាន់រួមគ្នា, ត្រូវអាបត្តិច្រើនតាមចំនួនវត្ថុ ។ តែក្នុងមហាបច្ចរីនិងកុរុន្ទីពោលរួមគ្នាថា ត្រូវអាបត្តិ ដោយរាប់រូបក្នុងថង់ដែលចងទុកជួរ ៗ ឬក្នុងភាជនៈដែលបញ្ចុះទុករល្វេង ៗ ។ ចំណែកក្នុងថង់ដែលចងទុកណែន ឬក្នុងភាជនៈដែលដាក់ណែន ត្រូវអាបត្តិតែមួយប៉ុណ្ណោះ ។

ចំណែកក្នុងការត្រេកអរប្រាក់មាសដែលគេរក្សាទុក មានវិនិច្ឆ័យដូច្នេះ ៖

កាលគេពោលថា "នេះជារបស់លោកម្ចាស់" បើសូម្បីភិក្ខុ

ត្រេកអរដោយចិត្ត ជាអ្នកប្រាថ្នាដើម្បីទទួលយក, តែបដិសេធដោយកាយ ឬវាចាថា "នេះមិនគួរ" មិនមានអាបត្តិ ។ សូម្បីមិនហាមដោយកាយនិងវាចា ជាអ្នកមានចិត្តបរិសុទ្ធិ មិនត្រេកអរដោយគិតថា "នេះមិនគួរដល់យើង" មិនមានអាបត្តិដូចគ្នា ។ ពិតមែន បណ្ដាទ្វារដែលភិក្ខុហាមហើយដោយទ្វារណាមួយ ក៏ជាការហាមហើយពិត ។ តែបើមិនហាមដោយកាយនិងវាចា ទទួលដោយចិត្ត រមែងត្រូវអាបត្តិ ក្នុងកាយទ្វារនិងវចីទ្វារ មានការមិនធ្វើជាសមុដ្ឋាន ព្រោះមិនធ្វើការហាមដែលខ្លួនគប្បីធ្វើដោយកាយនិងវាចា ។ តែឈ្មោះថា អាបត្តិតាមមនោទ្វារមិនមាន ។

បុគ្គលម្នាក់ដាក់មាសប្រាក់ ទាំងរយទាំងពាន់ទុកជិតជើងដោយពោលថា "មាសប្រាក់នេះ ចូរជារបស់លោក" ។ ភិក្ខុហាមថា "មាសប្រាក់នេះ ជារបស់មិនគួរ" ។ ឧបាសកនិយាយថា "ខ្ញុំព្រះករុណាលះបង់ប្រគេន លោកម្ចាស់ហើយ" ក៏ទៅ ។ មានអ្នកដទៃមកទីនោះ សួរថា "នេះអ្វី លោកម្ចាស់" ភិក្ខុគប្បីប្រាប់ពាក្យដែលឧបាសកនោះ និងខ្លួននិយាយគ្នា ។ បើគេនិយាយថា "ខ្ញុំព្រះករុណានឹងរក្សាឱ្យលោកម្ចាស់ លោកចូរសម្ដែងទីរក្សា ។ ភិក្ខុគប្បីឡើងទៅកាន់ប្រាសាទដល់ជាន់ទី ៧ ហើយគប្បីប្រាប់ថា នេះទីរក្សា ។ តែកុំប្រាប់ថា ចូររក្សាទុកក្នុងទីនេះ ។ អកប្បិយវត្ថុ (មានមាស និងប្រាក់ជាដើម) រមែងជាការអាស្រ័យវត្ថុ

ដែលជាកប្បិយ និងអកប្បិយ តាំងនៅដោយពាក្យប្រាប់មានប្រមាណប៉ុណ្ណេះ, គប្បីបិទទ្វារហើយនៅរក្សា ។

បើថា ឧបាសកកាន់យកបាត្រ និងចីវរដែលជារបស់សម្រាប់លក់យ៉ាងណាមួយមក, កាលគេពោលថា "លោកម្ចាស់ នឹងទទួលវត្ថុនេះទេ" គប្បីពោលថា "ឧបាសកពួកយើងមានសេចក្ដីត្រូវការរបស់នេះ ទាំងវត្ថុឈ្មោះបែបនេះ ក៏មាន, តែមិនមានកប្បិយការក" ។ បើគេនិយាយថា "ខ្ញុំព្រះករុណានឹងជាកប្បិយការក, សូមលោកមេត្តាបើកទ្វារឱ្យចុះ" គប្បីបើកទ្វារ ហើយពោលថា "តាំងនៅក្នុងឱកាសនេះ" ។ និងកុំពោលថា "លោកចូរកាន់យកវត្ថុនេះ" ។ សូម្បីយ៉ាងនេះ អកប្បិយវត្ថុ ក៏ជាការអាស្រ័យវត្ថុដែលជាកប្បិយ និងអកប្បិយតាំងនៅដូចគ្នា ។ បើគេកាន់យកកហាបណៈនោះហើយ ប្រគេនកប្បិយភណ្ឌៈដល់លោក, គួរ ។ បើគេកាន់យកច្រើនពេក គប្បីប្រាប់គេថា "**ន មយំ តវ ភណ្ឌំ គណ្ហាម និក្ខមាហិ** : ពួកយើងនឹងមិនយកភណ្ឌៈរបស់អ្នក, ចូរអ្នកទៅចុះ" ។

ក្នុងពាក្យថា **សង្ឃមជ្ឈេ និស្សជ្ជិតព្វំ** : (មាសប្រាក់នោះ)ភិក្ខុគប្បីលះក្នុងកណ្ដាលនៃសង្ឃ នេះ ព្រះមានព្រះភាគមិនត្រាស់ថា គប្បីលះបង់ដល់សង្ឃ ឬដល់គណៈ ឬដល់បុគ្គល ក៏ព្រោះធម្មតាថា រូបិយៈជាអកប្បិយ (ជារបស់មិនសមគួរ) ។

មួយទៀត ព្រោះរូបិយៈនោះ ត្រឹមតែភិក្ខុទទួលទុកប៉ុណ្ណោះ លោកមិនបានទិញរកកប្បិយភណ្ឌៈអ្វីដោយរូបិយៈនោះ ; ដូច្នោះ ដើម្បីទ្រង់សម្តែងការប្រើប្រាស់ដោយឧបាយ ទើបត្រាស់ថា គប្បីលះបង់នៅកណ្តាលនៃសង្ឃ ។

ពាក្យថា កប្បិយំ អាចិក្ខិតព្វំ សប្បិ វា : ភិក្ខុគប្បីប្រាប់វត្ថុដែលគួរ គឺ សប្បិ ឬ...... មានសេចក្តីថា គប្បីប្រាប់យ៉ាងនេះថា ឧបាសក ទឹកដោះថ្លា ឬប្រេង រមែងគួរ ដល់បព្វជិតទាំងឡាយ ។

## បច្ច័យដែលបានពីរូបិយៈដែលភិក្ខុទទួល មិនគួរដល់លោកអ្នកទទួល

ពាក្យថា រូបិយប្បដិគ្គាហកំ ឋបេត្វា សព្វេហេវ បរិភុញ្ជិតព្វំ : ភិក្ខុទាំងពួងគប្បីបរិភោគបានទាំងអស់ លើកលែងតែភិក្ខុអ្នកទទួលរូបិយមួយចេញ មានសេចក្តីថា ភិក្ខុទាំងអស់គប្បីចែកគ្នាបរិភោគ ។ ភិក្ខុដែលទទួលរូបិយៈមិនគប្បីទទួលចំណែកបែងចែក ។ សូម្បីបានចំណែកដែលត្រូវបានដល់ពួកភិក្ខុដទៃ ឬអារាមិកជនហើយ ទឹងបរិភោគក៏មិនគួរ ។ ដោយហោចទៅ ទឹកដោះថ្លា ឬប្រេងនោះដែលសត្វតិរច្ឆាន មានស្វាជាដើមលួចយកទៅអំពីចំណែកបែងចែកនោះ ដាក់ទុកក្នុងព្រៃ ឬដែលជ្រុះអំពីដៃរបស់សត្វទាំងនោះ នៅជារបស់ដែលសត្វតិរច្ឆានហួងហែងក្តី ជារបស់បង្សុកូលក្តី មិនសមគួរទាំងអស់ ។ សូម្បីនឹងអប់

សេនាសនៈ ដោយទឹកអំពៅដែលនាំមកពីចំណែកបែងចែកនោះ ក៏មិនគួរ ។ នឹងអុជប្រទីបដោយទឹកដោះថ្លា ឬប្រេងហើយដេកក្តី ធ្វើកសិណបរិកម្មក្តី អានសៀវភៅក្តី ដោយពន្លឺនៃប្រទីប មិនគួរ ។ មួយទៀត នឹងលាបដំបៅក្នុងរាងកាយដោយប្រេង ទឹកឃ្មុំនិងទឹកអំពៅជាដើម អំពីចំណែកបែងចែកនោះ ក៏មិនគួរដូចគ្នា ។

មនុស្សទាំងឡាយ យកវត្ថុនោះ ទិញគ្រែនិងតាំងជាដើមក្តី សាងឧបោសថាគារក្តី សាងរោងឆាន់ក្តី នឹងបរិភោគ ប្រើប្រាស់ ក៏មិនគួរ ។ សូម្បីមួប(នៃរោងឆាន់ជាដើម) ដែលជះទៅនៅតាមខេត្តរបស់ផ្ទះ ក៏មិនគួរ ។ មួបដែលហួសខេត្តទៅ គួរ ព្រោះជារបស់ជ្រែមក ។ នឹងដើរទៅតាមមកក្តី ស្ពានក្តី ទូកក្តី ក្បូនក្តី ដែលគេចំណាយវត្ថុនោះសាងទុក មិនគួរ ។ នឹងផឹក ឬប្រើប្រាស់ទឹកដែលជន់ឡើងពេញមាត់ស្រះបោក្ខរណី ដែលគេឱ្យជីកដោយវត្ថុនោះក៏មិនគួរ ។ ប៉ុន្តែថា កាលទឹកខាងក្នុង(ស្រះ) មិនមាន ទឹកដែលហូរមកថ្មី ឬទឹកភ្លៀងហូរចូលទៅសមគួរ ។ សូម្បីទឹកដែលមកថ្មី ដែលទិញមកព្រមនឹងស្រះបោក្ខរណីដែលទិញមក (ដោយវត្ថុនោះ) ក៏មិនគួរ ។

សង្ឃតាំងវត្ថុនោះជារបស់ផ្ញើ(រក្សាផ្កាផ្លែ) បរិភោគបច្ច័យ, សូម្បីបច្ច័យទាំងនោះ ក៏មិនគួរដល់លោក ។ សូម្បីអារាមដែលជាទីដែលសង្ឃទទួលទុក (ដោយវត្ថុនោះ) ក៏មិនគួរដើម្បីបរិភោគប្រើ

ប្រាស់ ។ បើផែនដីក្តី ពូជក្តី ជាអកប្បិយ, នឹងប្រើប្រាស់ផែនដី នឹងបរិភោគផ្លែឈើមិនគួរទាំងអស់នោះ ។ បើភិក្ខុទិញដីតែម៉្យាង បណ្តុះពូជដទៃ, នឹងបរិភោគផ្លែ គួរ ។ បើភិក្ខុទិញពូជមកដាំចុះក្នុងដីដែលជាកប្បិយ នឹងបរិភោគផ្លែ មិនគួរ ។ នឹងអង្គុយឬដេកលើផែនដី គួរ ។

ពាក្យថា សចេ សោ ឆឌ្ឌេតិ : បើគេចោលរូបិយនោះទៅ មានសេចក្តីថា គេបោះចោល ទៅក្នុងទីកន្លែងណាមួយ ។ បើសូម្បីគេមិនចោល ឬកាន់យក ទៅដោយខ្លួនឯង, មិនគប្បីហាមគេ ។

ពាក្យថា នោ ចេ ឆឌ្ឌេតិ : បើគេមិនចោលទេ មានសេចក្តីថា បើគេមិនកាន់យកទៅ និងមិនយកទៅចោល ចៀសទៅតាមសេចក្តីប្រាថ្នា ដោយដាក់ចិត្តថា “មានប្រយោជន៍អ្វីដល់យើងដោយការខ្វល់ខ្វាយនេះ”, លំដាប់នោះ សង្ឃគប្បីសន្មតភិក្ខុដែលមានលក្ខណៈ តាមដែលព្រះមានព្រះភាគត្រាស់ហើយ ឱ្យជាអ្នកចោលរូបិយៈ ។

## អង្គនៃភិក្ខុដែលចោលរូបិយៈ

ក្នុងពាក្យថា យោ ន ឆន្ទាគតឹ : ភិក្ខុដែលមិនដល់នូវឆន្ទាគតិ ១ ជាដើម មានវិនិច្ឆ័យ ដូច្នេះ ៖

ភិក្ខុដែលធ្វើវត្តនោះដើម្បីខ្លួន ឬលើកខ្លួនឡើងអាង ដោយ

អំណាចនៃសេចក្តីលោភ ឈ្មោះថា រមែងដល់សេចក្តីលំអៀង ព្រោះស្រឡាញ់ ។ កាលរកពានអ្នកដទៃដោយអំណាចនៃទោសៈថា "ភិក្ខុនេះមិនដឹងបទមាតិកាឡើយ មិនដឹងវិន័យ" ឈ្មោះថា រមែងដល់សេចក្តីលំអៀងព្រោះទោសៈ ។ កាលដល់ភាពជាអ្នកភាន់ភាំងនិងវង្វេងភ្លេចសតិដោយអំណាចមោហៈ ឈ្មោះថា រមែងដល់សេចក្តីលំអៀងព្រោះវង្វេង ។ កាលមិនអាចនឹងចោលព្រោះខ្លាចភិក្ខុដែលទទួលរូបិយៈ ឈ្មោះថា រមែងដល់សេចក្តីលំអៀងព្រោះខ្លាច ។ ភិក្ខុដែលមិនធ្វើយ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា រមែងមិនដល់សេចក្តីលំអៀងព្រោះស្រឡាញ់ ។ល។ រមែងមិនដល់សេចក្តីលំអៀងព្រោះខ្លាច ។

ពីរបទថា **អនិមិត្តំ កត្វា : មិនត្រូវកំណត់ទី** បានដល់ មិនធ្វើឱ្យមានទីសម្គាល់ ។ អធិប្បាយថា ភិក្ខុដែលចោលរូបិយៈនោះ បិទភ្នែកហើយ មិនក្រឡេកមើលក្រោយ គឺ មិនកំណត់ចំណាំទីធ្លាក់ គប្បីចោលឱ្យធ្លាក់ទៅក្នុងទន្លេ ក្នុងជ្រោះ ឬក្នុងគុម្ពឈើ ។ ក្នុងរូបិយៈដែលភិក្ខុគប្បីវៀរស យ៉ាងនេះ ទើបព្រះមានព្រះភាគត្រាស់ប្រាប់ការបរិភោគប្រើប្រាស់ ដល់ភិក្ខុទាំងឡាយដោយបរិយាយ ។ ក៏ការបរិភោគបច្ច័យដែលកើតឡើងអំពីរូបិយៈនោះ រមែងមិនសមគួរដល់ភិក្ខុដែលទទួលរូបិយៈដោយបរិយាយណាមួយឡើយ ក៏ការបរិភោគបច្ច័យដែលកើតឡើងនេះ

មិនគួរដល់ភិក្ខុដែលទទួលរូបិយៈនោះ យ៉ាងណា, បច្ច័យដែលកើតឡើង ព្រោះការពោលអួតឧត្តរិមនុស្សធម្មដែលមិនមានពិតក្តី ព្រោះកុលទូសកកម្មក្តី ព្រោះការបញ្ឆោតលួងលោមជាដើមក្តី រមែងមិនគួរដល់ភិក្ខុនោះ និងដល់ភិក្ខុដទៃ ដូច្នោះ ។ សូម្បីបច្ច័យដែលកើតឡើងដោយធម៌ ដោយសម្មាអាជីវៈ មិនទាន់បានពិចារណា ទើងបរិភោគ ក៏មិនគួរ ។

## អធិប្បាយកាបរិភោគបច្ច័យមាន ៤ យ៉ាង

ពិតមែន ការបរិភោគ មាន ៤ យ៉ាង គឺ **ថេយ្យបរិភោគ** (បរិភោគដូចចោរ) ១ **ឥណបរិភោគ** (បរិភោគដូចអ្នកជាប់បំណុល) ១ **ទាយជ្ជបរិភោគ** (បរិភោគដូចជាអ្នកទទួលមត៌ក) ១ **សាមីបរិភោគ** (បរិភោគដូចជាម្ចាស់របស់) ១ ។ បណ្តាការបរិភោគ ៤ យ៉ាងនោះ ការបរិភោគរបស់ភិក្ខុដែលទ្រុស្តសីលដែលអង្គុយបរិភោគ សូម្បីនៅកណ្តាលជំនុំសង្ឃ ឈ្មោះថា ថេយ្យបរិភោគ ។ ការបរិភោគមិនពិចារណារបស់ភិក្ខុដែលមានសីល ឈ្មោះថា ឥណបរិភោគ ។ ព្រោះដូច្នោះ ភិក្ខុដែលមានសីលគប្បីពិចារណាចីវរគ្រប់ខណៈដែលបរិភោគប្រើប្រាស់ ។ បិណ្ឌបាតគប្បីពិចារណាគ្រប់ ៗ ពំនូតដែលលេបចូល ។ កាលមិនអាចយ៉ាងនោះ គប្បីពិចារណាក្នុងកាលមុនឆាន់ ក្រោយឆាន់ យាមដើម យាមកណ្តាល និងយាមចុងបន្លស់ ។ បើកាលលោកមិនទាន់

ពិចារណាអរុណរះឡើង, រមែងតាំងនៅក្នុងឋានៈបរិភោគជាប់បំណុល ។ សូម្បីសេនាសនៈ ក៏គប្បីពិចារណាគ្រប់ ៗ ខណៈដែលប្រើប្រាស់ ។ ការមានសតិជាបច្ច័យទាំងក្នុងខណៈទទួល ទាំងក្នុងខណៈបរិភោគភេសជ្ជៈ រមែងគួរ ។ សូម្បីកាលជាយ៉ាងនោះ ក៏ត្រូវអាបត្តិដល់ភិក្ខុដែលធ្វើសតិក្នុងការទទួល មិនធ្វើក្នុងការបរិភោគតែម្យ៉ាង ។ តែមិនមានអាបត្តិដល់ភិក្ខុដែលមិនធ្វើសតិក្នុងការទទួល ធ្វើតែក្នុងវេលាបរិភោគ ។

ក៏សុទ្ធិមាន ៤ យ៉ាង គឺ **ទេសនាសុទ្ធិ** (បរិសុទ្ធដោយការសម្តែង) ១ **សំវរសុទ្ធិ** (បរិសុទ្ធដោយសំវរៈ) ១ **បរិយិដ្ឋិសុទ្ធិ**[1] (បរិសុទ្ធដោយការស្វែងរក)១ **បច្ចវេក្ខណសុទ្ធិ** (បរិសុទ្ធដោយការពិចារណា) ១ ។ បណ្តាសុទ្ធិ ៤ យ៉ាង នោះ បាតិមោក្ខសំវរសីល ឈ្មោះថា ទេសនាសុទ្ធិ ។ ក៏បាតិមោក្ខសំវរសីលនោះ លោកហៅថា ទេសនាសុទ្ធិ ព្រោះបរិសុទ្ធិដោយការសម្តែង ។ ឥន្ទ្រិយសំវរសីល ឈ្មោះថា សំវរសុទ្ធិ ។ ក៏ឥន្ទ្រិយសំវរសីលនោះ លោកហៅថា សំវរសុទ្ធិ ព្រោះបរិសុទ្ធិដោយសំវរៈ គឺ ការតាំងចិត្តអធិដ្ឋានថា យើងនឹងមិនធ្វើយ៉ាងនេះទៀតទេ ។ អាជីវបារិសុទ្ធិសីល ឈ្មោះថា បរិយិដ្ឋិសុទ្ធិ[1] ។ ក៏អាជីវបារិសុទ្ធិសីលនោះលោកហៅថា បរិយិដ្ឋិសុទ្ធិ ព្រោះជាសេចក្តីបរិសុទ្ធិដោយការស្វែងរករបស់ភិក្ខុដែលលះអនេសនា

១. ក្នុងទីដទៃ ៗ ជាបរិយេដ្ឋិសុទ្ធិ ។

ហើយញ៉ាំងបច្ច័យទាំងឡាយឱ្យកើតឡើងដោយធម៌ ដោយសម្មាអាជីវៈ ។ បច្ចយបរិភោគសន្និស្សិតសីល ឈ្មោះថា បច្ចវេក្ខណសុទ្ធិ ។ ពិតមែន បច្ចយបរិភោគសន្និស្សិតសីលនោះ លោកហៅថា បច្ចវេក្ខណសុទ្ធិ ព្រោះបរិសុទ្ធិដោយការពិចារណាដែលព្រះមានព្រះភាគត្រាស់ទុកដោយន័យមានជាដើមថា ភិក្ខុរមែងពិចារណាដោយឧបាយនៃប្រាជ្ញាហើយសេពចីវរ ដូច្នេះ ។ ព្រោះហេតុនោះ ទើបខ្ញុំព្រះករុណាពោលថា តែមិនជាអាបត្តិដល់ភិក្ខុដែលមិនធ្វើសតិក្នុងការទទួល ធ្វើតែក្នុងការបរិភោគ ។ ការបរិភោគបច្ច័យរបស់ព្រះសេក្ខៈ ៧ ពួក ឈ្មោះថា ទាយជ្ជបរិភោគ ។ ពិតមែន ព្រះសេក្ខៈទាំង ៧ នោះ ជាព្រះឱរសរបស់ព្រះមានព្រះភាគ ; ព្រោះដូច្នោះ ទើបជាទាយាទនៃបច្ច័យដែលជារបស់ព្រះពុទ្ធបិតា បរិភោគនូវបច្ច័យទាំងអស់នោះ ។

សួរថា ក៏ព្រះសេក្ខៈទាំងនោះ បរិភោគបច្ច័យរបស់ព្រះមានព្រះភាគ ឬ បរិភោគបច្ច័យរបស់ពួកគ្រហស្ថ ?

ឆ្លើយថា បច្ច័យទាំងនោះ សូម្បីដែលពួកគ្រហស្ថប្រគេន ក៏ពិតហើយ តែឈ្មោះថា ជារបស់ព្រះមានព្រះភាគ ព្រោះព្រះមានព្រះភាគទ្រង់អនុញ្ញាតទុក ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា ព្រះសេក្ខៈទាំងនោះ

បរិភោគបច្ច័យរបស់ព្រះមានព្រះភាគ ។ ក៏ធម្មទាយាទសូត្រ ជាគ្រឿងសាធកក្នុងការបរិភោគបច្ច័យរបស់ព្រះមានព្រះភាគនេះ ។

ការបរិភោគ របស់ព្រះខីណាស្រពទាំងឡាយ ឈ្មោះថា សាមីបរិភោគ ។ ពិតមែន ព្រះខីណាស្រពទាំងឡាយនោះ ឈ្មោះថា ជាម្ចាស់របស់បរិភោគ ព្រោះ កន្លងភាពជាទាសនៃតណ្ហាបានហើយ ។ បណ្ដាការបរិភោគទាំង ៤ នេះ សាមីបរិភោគ និងទាយជ្ជបរិភោគ រមែងគួរសម្រាប់ដល់ភិក្ខុទាំងពួង ។ ឥណបរិភោគមិនសមគួរឡើយ ។ ក្នុងថេយ្យបរិភោគ មិនមានពាក្យដែលត្រូវនិយាយ(ថា សមគួរក្នុងការបរិភោគ)ឡើយ ។

## អធិប្បាយ ការបរិភោគ ៤ យ៉ាងទៀត

ការបរិភោគសម្បូរដទៃទៀត ៤ គឺ លជ្ជីបរិភោគ អលជ្ជីបរិភោគ ធម្មិយបរិភោគ អធម្មិយបរិភោគ ។ បណ្ដាការបរិភោគ ៤ យ៉ាងនោះ ការបរិភោគរបស់អលជ្ជីភិក្ខុរមទនឹងលជ្ជីភិក្ខុ សមគួរ ។ មិនគប្បីពិន័យអាបត្តិចំពោះលោក ។ ការបរិភោគរបស់លជ្ជីភិក្ខុរមទនឹងអលជ្ជីភិក្ខុ រមែងគួរក្នុងវេលាដែលលោកមិនទាន់ដឹង ។ ព្រោះថា ធម្មតាភិក្ខុដែលជាអលជ្ជីមកពីដំបូងមិនមាន ។ ព្រោះដូច្នោះ លោកដឹងនូវភាវៈនៃភិក្ខុនោះ

ជាអលជ្ជីក្នុងកាលណា គប្បីពោលក្នុងកាលនោះថា “លោកប្រព្រឹត្តល្មើសក្នុងកាយទ្វារ និងវចីទ្វារ, ការធ្វើនោះ មិនសមគួរ, លោកកុំធ្វើយ៉ាងនេះឡើយ” ។ បើលោកមិនអើពើនៅចចេសធ្វើដដែលទៀត, បើនៅតែធ្វើការបរិភោគរួមនឹងអលជ្ជីនោះ, សូម្បីលោកក៏ជាអលជ្ជីដែរ ។ ចំណែកភិក្ខុណា ធ្វើការបរិភោគរួមនឹងអលជ្ជី អ្នកដែលជាភារៈរបស់ខ្លួន, សូម្បីភិក្ខុនោះ ដែលភិក្ខុដទៃឃើញ គប្បីហាម, បើលោកមិនព្រមវៀរចាក, ភិក្ខុសូម្បីរូបនេះ ក៏ជាអលជ្ជីដូចគ្នា ។ អលជ្ជីភិក្ខុសូម្បីតែមួយរូប រមែងធ្វើឱ្យភិក្ខុជាអលជ្ជីបានសូម្បីទាំងរយរូបយ៉ាងនេះ ។ ឈ្មោះថាអាបត្តិក្នុងការបរិភោគរួមគ្នារវាងអលជ្ជីនឹងអលជ្ជី រមែងមិនមាន ។ ការបរិភោគរួមរវាងលជ្ជីនឹងលជ្ជី ដូចគ្នានឹងខត្តិយកុមារពីរព្រះអង្គសោយរួមគ្នាក្នុងសុវណ្ណភាជន៍ ។ ការបរិភោគប្រកបដោយធម៌ និងមិនប្រកបដោយធម៌ អ្នកសិក្សាគប្បីជ្រាបដោយអំណាចនៃបច្ច័យនុ៎ះឯង ។

ក្នុងការបរិភោគប្រកបដោយធម៌ និងមិនប្រកបដោយធម៌នោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

បើសូម្បីបុគ្គលក៏ជាអលជ្ជី សូម្បីបិណ្ឌបាតក៏មិនប្រកបដោយធម៌, គួររង្កៀសទាំង ២ ចំណែក ។ បុគ្គលជាអលជ្ជី តែបិណ្ឌបាតប្រកបដោយធម៌, ភិក្ខុទាំងឡាយរង្កៀសបុគ្គលហើយ មិនគប្បីទទួលបិណ្ឌ

បាត ។ តែក្នុងមហាបច្ចរី លោកពោលទុកថា អ្នកទ្រុស្តសីល បាន ឧទ្ទេសភត្តជាដើមអំពីសង្ឃហើយ ប្រគេនដល់សង្ឃនុ៎ះឯង, ឧទ្ទេសភត្តជាដើមនេះ រមែងគួរ ព្រោះប្រព្រឹត្តទៅតាមដែលគេប្រគេននុ៎ះឯង ។ បុគ្គលជាលជ្ជី បិណ្ឌបាតមិនប្រកបដោយធម៌, បិណ្ឌបាតគួរវៀរ មិនគួរទទួលយក ។ បុគ្គលជាលជ្ជី សូម្បីបិណ្ឌបាតក៏ប្រកបដោយធម៌ រមែងសមគួរ ។

## អធិប្បាយការលើកតម្កើងនិងការបរិភោគយ៉ាងៗ ២ ទៀត

នៅមានការលើកតម្កើង ២ យ៉ាង និងការបរិភោគ ២ យ៉ាងទៀត គឺ ការលើកតម្កើងលជ្ជី ១ ការលើកតម្កើងអលជ្ជី ១ ធម្មបរិភោគ ១ អាមិសបរិភោគ ១, ក្នុងការលើកតម្កើង និងការបរិភោគនោះ ការលើកតម្កើងលជ្ជីរបស់អលជ្ជី សមគួរ ។ លោកមិនគួរពិន័យអាបត្តិ ។ ក៏បើថា លជ្ជីលើកតម្កើងអលជ្ជី រមែងនិមន្តដោយអនុមោទនា និមន្តដោយធម្មកថា ឧបត្ថម្ភក្នុងត្រកូលទាំងឡាយ, សូម្បីអលជ្ជីក្រៅនេះ ក៏ពោលសរសើរលោកក្នុងបរិស័ទថា អាចារ្យរបស់ពួកយើង រមែងជាអ្នកដូច្នេះ និងដូច្នេះ, ភិក្ខុនេះ បណ្ឌិតគប្បីជ្រាបថា រមែងធ្វើព្រះសាសនា ឱ្យសាបសូន្យចុះ គឺ ឱ្យអន្តរធានទៅ ។

ក៏បណ្តាធម្មបរិភោគនិងអាមិសបរិភោគ អាមិសបរិភោគ ក្នុងបុគ្គលណា សមគួរ, សូម្បីធម្មបរិភោគ ក្នុងបុគ្គលនោះ ក៏សមគួរ ។ លោកពោលទុក (ក្នុងអដ្ឋកថាទាំងឡាយ) ថា ក៏គម្ពីរណា តាំងនៅក្នុងចុងបន្ទស់ នឹងវិនាសទៅ ដោយកាលកន្លងទៅនៃបុគ្គលនោះ នឹងរៀនយកគម្ពីរនោះ ដើម្បីអនុគ្រោះធម៌ គួរ ។ ក្នុងការអនុគ្រោះធម៌នោះ មានរឿងតទៅនេះ ៖

## រឿងរៀនគណ្ឋៈពីមនុស្សអាក្រក់ដើម្បីអនុគ្រោះធម៌

បានឮថា ក្នុងយុគមហាភ័យ មានភិក្ខុដែលជំនាញមហានិទ្ទេស ត្រឹមតែមួយរូបប៉ុណ្ណោះ ។ គ្រានោះ ព្រះឧបជ្ឈាយ៍របស់ព្រះតិស្សថេរៈ អ្នកទ្រទ្រង់និកាយ ៤ ឈ្មោះថា មហាតិបិដកថេរៈ ពោលនឹងព្រះមហារក្ខិតថេរៈថា "អាវុសោ មហារក្ខិត លោកចូររៀនយកមហានិទ្ទេសក្នុងសំណាក់នៃភិក្ខុនោះចុះ" ។ លោកឆ្លើយប្រាប់ថា "បានឮថា លោករូបនេះអាក្រក់ថោកទាបលោកម្ចាស់ ខ្ញុំព្រះករុណានឹងមិនរៀនយក" ។

ឧបជ្ឈាយ៍. "រៀនទុកចុះ ខ្ញុំព្រះករុណានឹងអង្គុយជិត ៗ លោក" ។

ព្រះថេរៈ. "ល្អណាស់ លោកម្ចាស់ កាលលោកអង្គុយនៅជាមួយខ្ញុំព្រះករុណានឹងរៀនយក" ហើយចាប់ផ្តើមរៀនជាប់តគ្នាទាំងថ្ងៃ ទាំង

យប់ ថ្ងៃចុងក្រោយឃើញស្ត្រីនៅខាងក្រោមគ្រែហើយ ទូលប្រាប់ថា "លោកម្ចាស់ ខ្ញុំព្រះករុណាបានស្តាប់មកមុនហើយតែម្តង, បើថា ខ្ញុំព្រះករុណាគប្បីដឹងយ៉ាងនេះ នឹងមិនគប្បីរៀនធម៌ក្នុងសំណាក់មនុស្សបែបនេះឡើយ ។ ក៏ព្រះមហាថេរៈជាច្រើន បានរៀនយកក្នុងសំណាក់របស់ព្រះថេរៈនោះហើយ បានប្រតិស្ឋានមហានិទ្ទេសទុកបន្តមក ។

[១០៧] ក៏មាសនិងប្រាក់សូម្បីទាំងអស់ អ្នកសិក្សាគប្បីជ្រាបថា ដល់ការសង្គ្រោះថា រូបិយៈទាំងនោះ ក្នុងពាក្យថា រូបិយេ រូបិយសញ្ញី : រូបិយ ភិក្ខុសម្គាល់ថា រូបិយមែន នេះ ។

ពីរបទថា រូបិយេ វេមតិកោ : រូបិយ ភិក្ខុសង្ស័យ មានសេចក្តីថា កើតមានសេចក្តីសង្ស័យ ដោយន័យជាដើមថា ជាមាស ឬស្ពាន់[១]ហ្ន៎ ។

ពីរបទថា រូបិយេ អរូបិយសញ្ញី : រូបិយ ភិក្ខុសម្គាល់ថា មិនមែនរូបិយ មានសេចក្តីថា មានការសម្គាល់ក្នុងមាសថា ជាស្ពាន់ជាដើម ។

ម្យ៉ាងទៀត បុគ្គលអ្នកប្រាថ្នាក្នុងបុណ្យទាំងឡាយ មាននាងស្នំរបស់ព្រះរាជាជាដើម ប្រគេនប្រាក់និងមាសដាក់ទុកក្នុងភត្ត របស់គួរទំពារ របស់ក្រអូប និងកំញានជាដើម, ប្រគេនផ្ទាំងសំពត់តូច ៗ រួមជា

(១) វិមតិ ខរបត្តន្តិ ខរសង្ខាតំ សុវណ្ណបដិរូបកំ វត្ថុ ប្រែថា ដែលឈ្មោះថា

ខរបត្តៈ បានដល់ វត្ថុដែលរាប់ថា រីង មាសក្រឡៃ. អ្នកជម្រះ ។ មួយកហាបណៈដែលវេចទុកត្រង់ជាយសំពត់ជាដើមនុ៎ះឯង ដល់ភិក្ខុទាំងឡាយដែលត្រាច់រកសំពត់, ភិក្ខុទាំងឡាយទទួលយកដោយសម្គាល់ថា ភត្តាហារជាដើម ឬសម្គាល់ថា សំពត់, ភិក្ខុនេះ គប្បីជ្រាបថា អ្នកមានការសម្គាល់ក្នុងរូបិយៈ ថា មិនមែនរូបិយៈ ទទួលយករូបិយៈដោយអាការយ៉ាងនេះ ។

តែភិក្ខុដែលទទួល គប្បីកំណត់ឱ្យល្អថា វត្ថុនេះយើងបានក្នុងផ្ទះនេះ ព្រោះថា អ្នកដែលប្រគេនរបស់ដោយមិនមានសតិ បានសតិហើយនឹងត្រឡប់មក (សាកសួរ), លំដាប់នោះ ភិក្ខុគប្បីប្រាប់គេថា លោកចូរត្រួតមើលបង្វេចសំពត់របស់លោក ដូច្នេះ ។ បទដ៏សេសក្នុងសិក្ខាបទនេះ មានអត្ថងាយយល់ទាំងអស់ ។

បណ្ដាសមុដ្ឋានជាដើម សិក្ខាបទនេះ មានសមុដ្ឋាន ៦ ពេលខ្លះជាកិរិយា ព្រោះត្រូវដោយការទទួល ពេលខ្លះជាអកិរិយា ព្រោះមិនធ្វើការហាម, ពិតមែន រូបិយសិក្ខាបទ អញ្ញវាទកសិក្ខាបទ និងឧបស្សុតិសិក្ខាបទ ទាំង ៣ មានកំណត់ តែម្យ៉ាងដូចគ្នា ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

រូបិយសិក្ខាបទទី ៨ ចប់

# ៩. រូបិយសំវោហារសិក្ខាបទវណ្ណនា

[១០៩] រូបយិសំវោហារសិក្ខាបទថា តេន សមយេន : សម័យនោះ ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងរូបិយសំវោហារសិក្ខាបទនោះ មាន វិនិច្ឆ័យដូចតទៅនេះ ៖

បទថា នានប្បការកំ : មានប្រការផ្សេង ៗ បានដល់ មានប្រការមិនមែនតិច ដោយអំណាចរូបិយៈដែលធ្វើ (ជារូបភ័ណ្ឌ) និងមិនបានធ្វើ(ជារូបភ័ណ្ឌ) ជាដើម ។

បទថា រូបិយសំវោហារំ : ទិញដូរដោយរូបិយ បានដល់ ការផ្លាស់ប្ដូរដោយមាសនិងប្រាក់ ។

បទថា សមាបជ្ជន្តិ : ប្រព្រឹត្ត មានសេចក្ដីថា ពួកភិក្ខុឆព្វគ្គិយមើលមិនឃើញទោសក្នុងការផ្លាស់ប្ដូរដោយមាស និងប្រាក់ដែលខ្លួនទទួលទុកហើយ ព្រោះព្រះមានព្រះភាគទ្រង់ហាមការទទួលតែម្យ៉ាងទើបប្រព្រឹត្ត(ទិញដូរដោយរូបិយ) ។

[១១០] ក្នុងពាក្យថា សីសូបគំ : រូបិយដែលធ្វើសម្រាប់ពាក់លើក្បាល ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

មាសប្រាក់រូបភ័ណ្ឌ ដែលឈ្មោះថា សីសូបគៈ ព្រោះអត្ថថា ប្រជាប់សីសៈ ។ ក៏ក្នុងគម្ពីរទាំងឡាយសរសេរទុកថា សីសូបគំ ក៏

មាន ។ ពាក្យថា **សីសូបកំ** នេះ ជាឈ្មោះរបស់គ្រឿងប្រដាប់សិរ្សៈប្រភេទណាមួយ ។ ក្នុងបទទាំងពួងក៏ន័យនេះ ។

ក្នុងបទថា **កតេន កតំ : នូវរូបិយដែលធ្វើសម្រេចហើយដោយរូបិយដែលធ្វើសម្រេចហើយ** ជាដើមនេះ បណ្ឌិតគប្បីជ្រាបការទិញដូរដោយរូបិយៈសុទ្ធ ៗ ប៉ុណ្ណោះ ។

[១១១] ខ្ញុំព្រះករុណា នឹងពោលវិនិច្ឆ័យក្នុងបទថា **រូបិយេ រូបិយសញ្ញី : រូបិយ ភិក្ខុសម្គាល់ថា រូបិយមែន** ជាដើមតទៅ ៖

បណ្ដាវត្ថុដែលពោលហើយក្នុងសិក្ខាបទមុន កាលភិក្ខុទិញដូរនិស្សគ្គិយវត្ថុដោយនិស្សគ្គិយវត្ថុ ។ ការទទួលមូលតម្លៃ ជានិស្សគ្គិយបាចិត្តិយដោយសិក្ខាបទមុន, ការទិញដូររបស់ដទៃ ៗ ជានិស្សគ្គិយបាចិត្តិយដោយសិក្ខាបទនេះឯង ។ សូម្បីកាលទិញដូរទុក្កដវត្ថុ ឬកប្បិយវត្ថុដោយនិស្សគ្គិយវត្ថុ ក៏មានន័យយ៉ាងនេះដូចគ្នា ។

## ការទិញដូររូបិយៈដោយរូបិយៈជាដើម

ពិតមែន អ្នកសិក្សាគប្បីជ្រាបតិកៈថា ភិក្ខុមានការសម្គាល់ក្នុងរូបិយៈថា ជារូបិយៈ ទិញដូរវត្ថុដែលមិនមែនរូបិយៈជាដើម នេះជាតិកៈមួយទៀត សូម្បីមិនបានត្រាស់ទុក ព្រោះអនុលោមដល់តិកៈទីពីរដែល

ត្រាស់ទុកថា ភិក្ខុមានការសម្គាល់ក្នុងវត្ថុដែលមិនមែនរូបិយៈថា ជារូបិយៈ ទិញដូររូបិយៈជាដើមនេះ ។ ពិតមែន ភិក្ខុទិញដូររូបិយៈរបស់អ្នកដទៃ ដោយវត្ថុមិនមែនរូបិយៈរបស់ខ្លួនក្តី ទិញដូរវត្ថុដែលមិនមែនរូបិយៈរបស់អ្នកដទៃដោយរូបិយៈរបស់ខ្លួនក្តី សូម្បីដោយការទិញដូរទាំងពីរប្រការ ក៏ចាត់ថាធ្វើការទិញដូរដោយរូបិយៈដូចគ្នា ។ ព្រោះដូច្នោះ ក្នុងបាលីទើបត្រាស់តិកៈតែមួយប៉ុណ្ណោះ ក្នុងចំណែករូបិយៈតែម្ខាងដូច្នេះឯង ។

ក៏កាលភិក្ខុទិញដូរវត្ថុនៃនិស្សគ្គិយ ដោយវត្ថុនៃទុក្កដ ជាអាបត្តិទុក្កដដោយសិក្ខាបទមុន ក្នុងការទទួលមូលតម្លៃ ។ ជានិស្សគ្គិយបាចិត្តិយដោយសិក្ខាបទនេះ ក្នុងការផ្លាស់ប្តូរខាងក្រោយ ព្រោះទិញដូររបស់ធ្ងន់ ។ កាលទិញដូរទុក្កដវត្ថុនុ៎ះឯង ឬកប្បិយវត្ថុ ដោយវត្ថុនៃទុក្កដ ជាអាបត្តិទុក្កដដោយសិក្ខាបទមុន ក្នុងការទទួលមូលតម្លៃ, ជាអាបត្តិទុក្កដដូចគ្នាដោយសិក្ខាបទនេះ សូម្បីក្នុងការប្តូរផ្លាស់ខាងក្រោយ ។ ព្រោះហេតុអ្វី ? ព្រោះទិញដូរដោយអកប្បិយវត្ថុ ។

ចំណែកក្នុងអដ្ឋកថាអន្ធកៈ លោកពោលថា បើភិក្ខុដល់ការទិញដូរជានិស្សគ្គិយបាចិត្តិយ ពាក្យនោះ លោកពោលទុកមិនប្រពៃ ។ ព្រោះហេតុអ្វី ? ព្រោះឈ្មោះថា ការទិញដូរ ក្រៅអំពីការឱ្យនិងការទទួល មិនមាន ។ និងកយវិក្កយសិក្ខាបទ ព្រះមានព្រះភាគត្រាស់សំដៅយកការ

ផ្លាស់ប្តូរកប្បិយវត្ថុដោយកប្បិយវត្ថុប៉ុណ្ណោះ ។ ក៏ឯការផ្លាស់ប្តូរនោះក្រៅអំពីពួកសហធម្មិក ។

សិក្ខាបទនេះ ព្រះមានព្រះភាគត្រាស់សំដៅយកការទិញ ដូររូបិយៈនិងវត្ថុមិនមែនរូបិយៈដោយរូបិយៈ និងការទិញដូរ រូបិយៈដោយវត្ថុមិនមែនរូបិយៈ, ចំណែកការទិញដូរវត្ថុនៃទុក្កដ ដោយវត្ថុនៃទុក្កដ មិនបានត្រាស់ទុកក្នុងបាលីនៃសិក្ខាបទនេះ (និង)មិនបានត្រាស់ទុក ក្នុងបាលីនៃកយវិក្កយសិក្ខាបទនោះឡើយ ។ ក៏ក្នុងការទិញដូរវត្ថុនៃទុក្កដ ដោយវត្ថុនៃទុក្កដនេះ មិនគួរនឹងពោលថា "ជាអនាបត្តិ"ទេ ។ ព្រោះដូច្នោះ ពួកអាចារ្យអ្នកដឹងព្រះបំណងនៃព្រះមានព្រះភាគ ទើបបានពោលពាក្យថា ក្នុងការទទួលវត្ថុនៃទុក្កដ ត្រូវអាបត្តិទុក្កដ យ៉ាងណា, សូម្បីក្នុងការទិញដូរវត្ថុនៃទុក្កដនោះ ដោយវត្ថុនៃទុក្កដនោះឯង ត្រូវអាបត្តិទុក្កដ ក៏ប្រពៃហើយ យ៉ាងនោះដែរ ។

មួយទៀត កាលភិក្ខុទិញដូរវត្ថុនិស្សគ្គិយ ដោយកប្បិយវត្ថុ ជាអនាបត្តិដោយសិក្ខាបទមុន ក្នុងការទទួលមូលតម្លៃ, ជានិស្សគ្គិយបាចិត្តិយ ដោយសិក្ខាបទនេះ ក្នុងការប្តូរផ្លាស់ខាងក្រោយ ។ សមពិតដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា មិនមែនរូបិយៈ ភិក្ខុសម្គាល់ថា មិនមែនរូបិយៈ ហើយទិញដូរនូវរូបិយៈ ជានិស្សគ្គិយ ភិក្ខុនោះត្រូវ

អាបត្តិបាចិត្តិយ ។ កាលភិក្ខុទិញជូរវត្ថុ នៃទុក្កដដោយកប្បិយវត្ថុនោះឯង មិនជាអាបត្តិ ដូចយ៉ាង(បាចិត្តិយ)នោះ ក្នុងការទទួលមូលតម្លៃ, ត្រូវអាបត្តិទុក្កដ ដោយសិក្ខាបទនេះ ក្នុងការផ្លាស់ប្តូរខាងក្រោយ ។ ព្រោះហេតុ អ្វី ? ព្រោះទិញជូរវត្ថុជាអកប្បិយ ។

មួយទៀត កាលភិក្ខុផ្លាស់ប្តូរកប្បិយវត្ថុ ដោយកប្បិយវត្ថុ ក្រៅអំពីពួកសហធម្មិក មិនមានអាបត្តិ ដោយសិក្ខាបទមុន ក្នុងការទទួលមូលតម្លៃ ។ ជានិស្សគ្គិយបាចិត្តិយដោយកយវិក្កយសិក្ខាបទខាងមុខ ក្នុងការផ្លាស់ប្តូរខាងក្រោយ ។ កាលភិក្ខុកាន់យកផុតការទិញជូរទៅ មិនមានអាបត្តិ សូម្បីដោយសិក្ខាបទខាងមុខ ។ (តែ) ត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលប្រកបការរកផលកម្រៃ ។

## អធិប្បាយបត្តចតុក្កៈ ជាឧទាហរណ៍

មួយទៀត អ្នកសិក្សាគប្បីជ្រាបបត្តចតុក្កៈនេះ ដែលសម្តែងដល់សេចក្តីដែលរូបិយសំវោហារសិក្ខាបទនេះ ធ្ងន់ ។ សេចក្តីពិស្តារថា ភិក្ខុណា ទទួលយករូបិយៈ ហើយជួលឱ្យជីករ៉ែដែកឡើងដោយរូបិយៈនោះ, ឱ្យជាងដែករំលាយរ៉ែដែកនោះ ហើយឱ្យធ្វើបាត្រដោយលោហៈនោះ ។ បាត្រនេះ ឈ្មោះថា ជាមហាអកប្បិយ ភិក្ខុនោះ មិនអាចធ្វើឱ្យជាកប្បិយបានដោយឧបាយណាមួយឡើយ ។ ក៏បើថា ទម្លាយបាត្រនោះហើយឱ្យ

ជាងធ្វើភាជន៍ ។ សូម្បីភាជន៍នោះ ក៏ជាអកប្បិយ ។ ឱ្យធ្វើកាំបិត សូម្បីឈើស្ទន់ដែលកាត់ដោយកាំបិតនោះ ក៏ជាអកប្បិយ ។ ឱ្យធ្វើសន្ទូច សូម្បីត្រីដែលគេឱ្យស្លាប់ដោយសន្ទូចនោះ ក៏ជាអកប្បិយ ។ ភិក្ខុឱ្យជាងដុតកាំបិតឱ្យក្តៅហើយ ត្រាំទឹក ឬទឹកដោះស្រស់ឱ្យក្តៅ ។ សូម្បីទឹកនិងទឹកដោះស្រស់នោះ ក៏ជាអកប្បិយដូចគ្នា ។

ក្នុងមហាបច្ចរី លោកពោលថា ក៏ភិក្ខុណា ទទួលរូបិយៈ ហើយទិញបាត្រដោយរូបិយៈនោះ, សូម្បីបាត្រនេះរបស់ភិក្ខុនោះ ក៏ជាអកប្បិយ មិនសមគួរសូម្បីដល់សហធម្មិកទាំង ៥ ។ តែភិក្ខុនោះ អាចធ្វើបាត្រនោះ ឱ្យជាកប្បិយបាន ។ ពិតមែន បាត្រនោះ នឹងជាកប្បិយបាន ចំពោះកាលឱ្យមូលតម្លៃដល់ម្ចាស់របស់មូលតម្លៃ និងកាលឱ្យបាត្រដល់ម្ចាស់របស់បាត្រ ។ ភិក្ខុនឹងឱ្យកប្បិយភណ្ឌៈហើយទទួលយកទៅប្រើប្រាស់សមគួរ ។

ចំណែកភិក្ខុណា ឱ្យទទួលយករូបិយៈទុកហើយទៅកាន់ត្រកូលជាងដែកជាមួយនឹងកប្បិយការក ឃើញបាត្រហើយនិយាយថា "បាត្រនេះ អាត្មាពេញចិត្ត" ។ កប្បិយការកឱ្យរូបិយៈនោះ ហើយឱ្យជាងដែកយល់ព្រម ។ សូម្បីបាត្រនេះ ដែលភិក្ខុនោះ កាន់យកដោយកប្បិយវោហារ ដូចគ្នានឹងបាត្រទី ២ ទុះឯង ចាត់ជាអកប្បិយដូចគ្នា

ព្រោះភិក្ខុទទួលមូលតម្លៃ ។

សួរថា ព្រោះហេតុអ្វី ទើបមិនគួរដល់សហធម្មិកដ៏សេស ?

ឆ្លើយថា ព្រោះមិនលះបង់មូលតម្លៃចេញ ។

មួយទៀត ភិក្ខុណា មិនទទួលរូបិយៈទៅកាន់ត្រកូលជាងដែក ព្រមទាំងកប្បិយការកដែលទាយកបញ្ជូនមកថា លោកចូរទិញបាត្រប្រគេនព្រះថេរៈ ឃើញបាត្រហើយ ឱ្យកប្បិយការកទិញដោយកហាបណៈថា លោកចូរទទួលយកកហាបណៈទាំងនេះហើយ ឱ្យបាត្រនេះហើយបានកាន់យកទៅ ។ បាត្រនេះ មិនគួរដល់ភិក្ខុរូបនេះប៉ុណ្ណោះ ព្រោះចាត់ការមិនប្រពៃ, តែគួរដល់ពួកភិក្ខុដទៃ ព្រោះមិនបានទទួលមូលតម្លៃ ។

បានឮថា ឧបជ្ឈាយ៍របស់ព្រះមហាសុមត្ថេរៈ មានឈ្មោះថា អនុរុទ្ធត្ថេរៈ ។ លោកបំពេញបាត្របែបនេះរបស់ខ្លួន ឱ្យពេញដោយទឹកដោះថ្លាហើយ លះបង់ដល់សង្ឃ ។ ពួកសទ្ធិវិហារិក សុម្បីរបស់ព្រះចុល្លនាគត្ថេរៈ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ក៏មានបាត្រដូច្នោះដែរ ។ ព្រះថេរៈបង្គាប់ឱ្យបំពេញបាត្រនោះឱ្យពេញ ដោយទឹកដោះថ្លាហើយឱ្យលះបង់ដល់សង្ឃ ដូច្នេះឯង ។ នេះឈ្មោះថា អកប្បិយបត្តចតុក្កៈ ។ ក៏បើថា ភិក្ខុមិនទទួលរូបិយៈទៅកាន់ត្រកូលនៃជាងដែក ព្រមដោយកប្បិយការកដែលទាយកបញ្ជូនមកថា លោកចូរទិញបាត្តប្រគេនព្រះថេរៈ ឃើញ

បាត្រហើយ ពោលថា "បាត្រនេះអាត្មាពេញចិត្ត" ឬថា "អាត្មានឹងយកបាត្រនេះ", ក៏កប្បិយការកឱ្យរូបិយៈនោះ ហើយឱ្យជាងដែកយល់ព្រម ។ បាត្រនេះសមគួរគ្រប់យ៉ាង គួរដល់ការបរិភោគសូម្បីនៃព្រះពុទ្ធទាំងឡាយ ។

ពីរបទថា អរូបិយេ រូបិយសញ្ញី : មិនមែនរូបិយ ភិក្ខុសម្គាល់ថា រូបិយ បានដល់ មានការសម្គាល់ក្នុងស្មាន់ថា ជាមាសជាដើម ។

ពីរបទថា អាបត្តិ ទុក្កដស្ស : ត្រូវអាបត្តិទុក្កដ មានសេចក្ដីថា បើភិក្ខុទិញដូរវត្ថុដែលមិនមែនរូបិយៈ ដោយវត្ថុដែលមិនមែនរូបិយៈដែលមានការសម្គាល់ថា ជារូបិយៈនោះ ត្រូវអាបត្តិទុក្កដ ។ ក្នុងភិក្ខុដែលមានសេចក្ដីសង្ស័យ ក៏មានន័យយ៉ាងនេះ ។ តែមិនមានអាបត្តិដល់ភិក្ខុមានការសម្គាល់ថា មិនមែនរូបិយៈ សូម្បីធ្វើការទិញដូរ ជាមួយសហធម្មិក ៥ ថា លោកចូរកាន់យកវត្ថុនេះហើយឱ្យវត្ថុនេះ ។ ពាក្យដ៏សេសមានអត្ថងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា នោសញ្ញាវិមោក្ខ ជាអចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

រូបិយសំវោហារ សិក្ខាបទទី ៩ ចប់

# ១០. កយវិក្កយសិក្ខាបទវណ្ណនា

[១១៣] កយវិក្កយសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងកយវិក្កយសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ពាក្យថា កតិ ហិបិ ត្យាយំ : របស់អ្នកនេះនឹងធន់បានប៉ុន្មានថ្ងៃ គឺ សង្ឃាដិនេះ របស់លោកនឹងនៅបានប៉ុន្មានថ្ងៃ ។ ក៏ក្នុងបទថា កតិហិបិ នេះ ហិ សព្ទ ជាបទបូរណៈ បិ សព្ទប្រព្រឹត្តទៅក្នុងសេចក្តីតិះដៀល ។ អធិប្បាយថា សង្ឃាដិរបស់លោកផ្ទាំងនេះទ្រុឌទ្រោម នឹងនៅបានត្រឹមប៉ុន្មានថ្ងៃ, មួយយ៉ាងទៀត បាលីថា កតិហំបិ ត្យាយំ ក៏មាន ។ បណ្តាបទទាំងនោះ បទថា កតិហំ គឺ អស់ថ្ងៃប៉ុន្មាន ។ មានពាក្យអធិប្បាយថា រហូតដល់អស់ត្រឹមប៉ុន្មានថ្ងៃ ។ បទដ៏សេសមានន័យដូចពោលហើយដូចគ្នា ។ ពាក្យថា កតីហិបិ ម្យាយំ នេះ ក៏គប្បីជ្រាបដោយន័យនេះដូចគ្នា ។

ក្នុងពាក្យថា គិហីបិ ណំ គិហិស្ស : សូម្បីគ្រហស្ថ(ក៏រមែងឱ្យ)នូវវត្ថុនោះ ដល់គ្រហស្ថ នេះ សព្ទថា ណំ ជានិបាត ចុះក្នុងអត្ថនៃនាមសព្ទ ។ មានពាក្យអធិប្បាយថា ធម្មតាថា សូម្បីគ្រហស្ថ ក៏នៅសងឱ្យដល់គ្រហស្ថ ។

[១១៨] បទថា នានប្បការកំ : មានប្រការផ្សេង ៗ គឺ មានប្រការមិនតែមួយ (ច្រើន) ដោយអំណាចនៃកប្បិយភណ្ឌៈ មានចីវរជាដើម ៗ ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទថា នានប្បការំ នោះ លោកទើបសម្តែងចំពោះកប្បិយភណ្ឌៈ ចាប់ផ្តើមតាំងពីចីវរ មានអំបោះវេងជើងជាទីបំផុត ៗ ពិតមែន ការផ្លាស់ប្តូរដោយអកប្បិយភណ្ឌៈ រមែងមិនដល់ការសង្គ្រោះចូលក្នុងការទិញដូរ ៗ

## អធិប្បាយការទិញនិងលក់ដែលធ្វើឱ្យត្រូវអាបត្តិ

បទថា កយវិក្កយំ : ទិញដូររបស់ បានដល់ ការទិញនិងការលក់ ៗ ភិក្ខុកាលកាន់យកកប្បិយភណ្ឌៈរបស់អ្នកដទៃ ដោយន័យជាដើមថា លោកចូរឱ្យវត្ថុនេះដោយវត្ថុនេះ ឈ្មោះថា រមែងដល់ការទិញ, កាលឱ្យកប្បិយភណ្ឌៈរបស់ខ្លួន ឈ្មោះថា រមែងដល់ការលក់ ៗ

បទថា អជ្ឈាចរតិ : ភិក្ខុពោលពាក្យមិនសមគួរ គឺ រមែងប្រព្រឹត្តគ្របសង្កត់ ៗ អធិប្បាយថា រមែងពោលវាចាកន្លងហួស ៗ

ពាក្យថា យតោ កយិតញ្ច ហោតិ វិក្កីតញ្ច[១] : កាលណា ... ហៅថា ទិញ ហៅថា លក់ មានសេចក្តីថា ក្នុងវេលាធ្វើភណ្ឌៈរបស់

---

១. ឆដ្ឋ. វិក្កយិតញ្ច ឱ.ម. វិក្កយិតញ្ច ៗ

អ្នកដទៃឱ្យនៅក្នុងដៃរបស់ខ្លួន ឈ្មោះថា ទិញ និងក្នុងវេលាធ្វើភណ្ឌៈរបស់ខ្លួនឱ្យនៅក្នុងដៃរបស់អ្នកដទៃ ឈ្មោះថា លក់ ។ តែដោយបទនេះក្នុងបាលីសម្ដែងតែភណ្ឌៈរបស់ខ្លួនមុន ដោយសមគួរដល់ពាក្យ មានពាក្យថា ឥមំ ជាដើម ។

បទថា និស្សជ្ជិតព្វំ : ភិក្ខុគប្បីលះ មានសេចក្ដីថា គប្បីលះបង់កប្បិយភណ្ឌៈ ដែលទទួលយកអំពីដៃរបស់អ្នកដទៃ ដោយអំណាចនៃការទិញដូរយ៉ាងនេះ ។ ក៏ការទិញដូរយ៉ាងនេះជាមួយនឹងពួកគ្រហស្ថ និងអ្នកបួសដ៏សេស វៀរសហធម្មិកទាំង ៥ ដោយហោចទៅសូម្បីនឹងមាតាបិតា ក៏មិនគួរ ។

វិនិច្ឆ័យក្នុងការទិញដូរនោះ ដូចតទៅនេះ ៖

សំពត់នឹងសំពត់ក៏ដោយ អាហារនឹងអាហារក៏ដោយ ចូរលើកទុក, ភិក្ខុ ពោលដល់កប្បិយភណ្ឌៈយ៉ាងណាមួយថា លោកចូរឱ្យវត្ថុនេះដោយវត្ថុនេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពោលយ៉ាងនោះហើយឱ្យភណ្ឌៈរបស់ខ្លួនសូម្បីដល់មាតា ក៏ត្រូវអាបត្តិទុក្កដ ។ ភិក្ខុដែលមាតាពោលថា លោកចូរឱ្យវត្ថុនេះដោយវត្ថុនេះ ឬពោលថា លោកចូរឱ្យវត្ថុនេះ ខ្ញុំព្រះករុណានឹងឱ្យវត្ថុនេះដល់លោក ហើយកាន់យកភណ្ឌៈសូម្បីរបស់មាតាដើម្បីខ្លួន ក៏ត្រូវអាបត្តិទុក្កដ ។ កាលភណ្ឌៈរបស់ខ្លួនដល់ដៃរបស់អ្នក

ដទៃ និងកាលកណ្ឌៈរបស់អ្នកដទៃដល់ដៃរបស់ខ្លួន ជានិស្សគ្គិយ ។ តែកាលភិក្ខុពោលនឹងមាតា ឬបិតាថា លោកចូរឱ្យវត្ថុនេះ មិនជាការបេញមាត់សូម ។ កាលភិក្ខុពោលថា លោកចូរកាន់យកវត្ថុនេះ មិនជាការញ៉ាំងសទ្ធាទេយ្យឱ្យធ្លាក់ចុះ ។ កាលភិក្ខុនិយាយចំពោះអ្នកមិនមែនញាតិថា លោកចូរឱ្យវត្ថុនេះ ជាការបេញមាត់សូម, កាលនិយាយថា លោកចូរកាន់យកវត្ថុនេះ ជាការញ៉ាំងសទ្ធាទេយ្យឱ្យធ្លាក់ចុះ ។ កាលភិក្ខុដល់ការទិញដូរថា លោកចូរឱ្យវត្ថុនេះ ដោយវត្ថុនេះ ជានិស្សគ្គិយ ។ ព្រោះដូច្នោះ កាលភិក្ខុមានបំណងនឹងផ្លាស់ប្តូរកប្បិយភណ្ឌៈ គប្បីផ្លាស់ប្តូរនឹងមាតាបិតាឱ្យផុតការទិញដូរ នឹងពួកជនមិនមែនញាតិ ឱ្យផុតអាបត្តិ ៣ ។

## អធិប្បាយវិធីផ្លាស់ប្តូរកប្បិយភណ្ឌៈ

ក្នុងកប្បិយភណ្ឌៈនោះ មានវិធីផ្លាស់ប្តូរដូចតទៅនេះ ៖

ភិក្ខុមានអង្ករជាស្បៀងតាមមក ។ លោកឃើញបុរសកាន់បាយក្នុងចន្លោះមកហើយនិយាយថា "អាត្មាមានអង្ករ, ហើយអាត្មាមិនមានសេចក្តីត្រូវការដោយអង្ករនេះ, តែត្រូវការបាយ" ដូច្នេះ ។ បុរសទទួលយកអង្ករហើយប្រគេនបាយ គួរ ។ មិនមានអាបត្តិទាំង ៣ ។ ដោយហោចទៅសូម្បីត្រឹមតែនិមិត្តកម្ម ក៏មិនមាន ។ ព្រោះហេតុអ្វី ? ព្រោះ

មានមូលហេតុ ។ និងព្រះមានព្រះភាគបានត្រាស់ពាក្យនេះ ទុកខាងមុខនុ៎ះឯងថា "ភិក្ខុនិយាយថា ទ្រព្យនេះរបស់យើងមាន យើងត្រូវការទ្រព្យនេះផង នេះផង ដូច្នេះ" ។

មួយទៀត ភិក្ខុណា មិនធ្វើយ៉ាងនេះ ផ្លាស់ប្តូរថា លោកចូរឱ្យវត្ថុនេះដោយវត្ថុនេះ ត្រូវអាបត្តិតាមវត្ថុពិត ។ ភិក្ខុឃើញអ្នកស៊ីដែលពោលថា "លោកចូរស៊ីបាយនេះ ហើយនាំទឹកជ្រលក់ ឬឱសមកឱ្យ" ហើយឱ្យ (បាយ) ។ ជានិស្សគ្គិយច្រើនតាមចំនួន បំណែកទឹកជ្រលក់និងចំនួនឱស ។ ភិក្ខុពោលថា "ពួកលោកបរិភោគ បាយនេះហើយ ចូរធ្វើកិច្ចឈ្មោះនេះ" ហើយប្រើពួកជាងសិប្បៈមានជាងឆ្លាក់ភ្លុកជាដើម ឱ្យធ្វើបរិក្ខារនោះ ៗ បណ្តាបរិក្ខារមានធម្មក្រកជាដើម ឬប្រើពួកជាងជ្រលក់ឱ្យបោកសំពត់, ត្រូវអាបត្តិតាមវត្ថុតែម្តង ។ ភិក្ខុប្រើពួកជាងកោរឱ្យកោរសក់ឱ្យពួកកម្មករធ្វើនវកម្ម, ត្រូវអាបត្តិតាមវត្ថុដូចគ្នា ។ ក៏បើភិក្ខុមិនពោល ពួកលោកបរិភោគអាហារនេះហើយ ចូរធ្វើកិច្ចនេះពោលថា "លោកចូរបរិភោគអាហារនេះ, លោកបរិភោគហើយ, (ឬ) នឹងបរិភោគ, ចូរជួយធ្វើកិច្ចឈ្មោះនេះ" រមែងសមគួរ ។ ក៏ក្នុងការឱ្យធ្វើបរិក្ខារជាដើមនេះ ភណ្ឌៈរបស់អ្នកដទៃ ដែលដល់ដៃរបស់ខ្លួន ឈ្មោះថាដែលភិក្ខុគប្បីលះបង់ រមែងមិនមានក្នុងការបោកសំពត់ ឬក្នុងការកោរ

សក់ ឬក្នុងនវកម្មមានការជម្រុះផ្ទៃដីជាដើម ក៏ពិតមែនហើយ តែថា ព្រោះលោកពោលទុកធ្ងន់សួម្បីក្នុងមហាអដ្ឋកថា អ្នកណា ៗ មិនអាចជំទាស់ពាក្យនោះបាន; ព្រោះដូច្នោះ ភិក្ខុគប្បីសម្ដែងបាចិត្តិយ ព្រោះការជួលបោកសំពត់ជាដើមសូម្បីនេះ ដូចសម្ដែងបាចិត្តិយ ព្រោះនិស្សគ្គិយវត្ថុ ដែលខ្លួនប្រើប្រាស់ហើយ ឬវិនាសអស់ហើយ ដូច្នោះ ។

[១១៥] ក្នុងពាក្យថា **កយវិក្កយេ កយវិក្កយសញ្ញី :** ទ្រព្យដែលទិញដូរ ភិក្ខុសំគាល់ថា ទិញដូរ ជាដើម អ្នកសិក្សាគប្បីជ្រាបសេចក្ដីយ៉ាងនេះថា ភិក្ខុណា ដល់ការទិញដូរ, ភិក្ខុនោះ ចូរជាអ្នកមានការសម្គាល់ក្នុងការទិញដូរ នោះថា ជាការទិញដូរ ឬមានសេចក្ដីសង្ស័យ ឬមានការសម្គាល់ថា មិនមែនការទិញដូរក៏ដោយ ជានិស្សគ្គិយបាចិត្តិយទាំងអស់ ។ ក្នុងចូឡតិកៈជាអាបត្តិទុក្កដដូចគ្នាទាំង ២ បទ ។

## អធិប្បាយអនាបត្តិវារ

[១១៦] ពីរបទថា **អគ្ឃំ បុច្ឆតិ :** ដល់ភិក្ខុដែលគ្រាន់តែសួរតម្លៃ មានសេចក្ដីថា ភិក្ខុសួរថា "បាត្ររបស់អ្នកនេះតម្លៃប៉ុន្មាន ?" តែកាលម្ចាស់របស់បាត្រពោលថា "តម្លៃប៉ុណ្ណេះ" បើកប្បិយភណ្ឌៈរបស់ភិក្ខុនោះ មានតម្លៃច្រើន, ចំណែកភិក្ខុពោលតបទៅនឹងឧបាសកនោះយ៉ាង

នេះថា "ឧបាសក វត្ថុរបស់យើងនេះមានតម្លៃច្រើន, លោកចូរឱ្យបាត្ររបស់លោកដល់អ្នកដទៃចុះ" ។ ចំណែកឧបាសកបានឮពាក្យនោះពោលថា "ខ្ញុំព្រះករុណានឹងថែមភាជន៍ដទៃឱ្យទៀត" នឹងទទួលយកទុកក៏គួរ ។ របស់នោះធ្លាក់ទៅក្នុងលក្ខណៈដែលត្រាស់ទុកថា យើងមានវត្ថុនេះជាដើម ។ បើបាត្រនោះមានតម្លៃថ្លៃ, វត្ថុរបស់ភិក្ខុមានតម្លៃថោក, និងម្ចាស់របស់បាត្រមិនដឹងថា របស់នោះតម្លៃថោក, ភិក្ខុកុំគប្បីទទួលយកបាត្រ ។ គប្បីប្រាប់ថា វត្ថុរបស់យើងមានតម្លៃថោក ។ ពិតមែនកាលភិក្ខុដឹងថា បាត្រមានតម្លៃច្រើនហើយបញ្ឆោតកាន់យក(បាត្រ)ទៅរមែងដល់ភាពជាអ្នកដែលព្រះវិន័យធរ គប្បីឱ្យវាយតម្លៃវត្ថុដែលលោកកាន់យកហើយពិន័យអាបត្តិ ។ បើម្ចាស់របស់បាត្រពោលថា "ណ្ហើយចុះលោកម្ចាស់ ចំណែកដែលលើស នឹងជាបុណ្យដល់ខ្ញុំព្រះករុណា" ហើយប្រគេន គួរ ។

ពីរបទថា **គប្បិយការកស្ស អាចិក្ខតិ : ដល់ភិក្ខុប្រាប់ដល់កប្បិយការក** មានសេចក្តីថា ភិក្ខុកាន់យកភណ្ឌអំពីដៃរបស់អ្នកណា, ធ្វើអ្នកដទៃឱ្យជាកប្បិយការក វៀរលែងតែអ្នកដែលខ្លួនទទួលភណ្ឌៈអំពីដៃដោយហោចទៅសូម្បីជាបុត្រ ឬបងប្អូនប្រុសរបស់គេ ហើយប្រាប់ថា "លោកចូរយកវត្ថុនេះផង វត្ថុនេះឱ្យផង" ។ បើបុត្រ ឬបងប្អូនប្រុស

នោះ ជាអ្នកឆ្លាតនាំចេញហើយជជែកជជែល ៗ ហើយ ទើបទទួលយក, ភិក្ខុគប្បីឈរនៅស្ងៀម ។ បើគេជាអ្នកមិនឆ្លាត មិនស្គាល់ដើម្បីកាន់យក ឈ្មួញលួងលោមគេ, ភិក្ខុគប្បីប្រាប់គេថា "លោកកុំយក" ដូច្នេះ ។

ក្នុងពាក្យថា "អាត្មាមានវត្ថុនេះ"ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុពោលថា "ប្រេង ឬទឹកដោះថ្លាដែលទទួលប្រគេនហើយនេះរបស់អាត្មាមាន, តែអាត្មាត្រូវការរបស់ដទៃដែលមិនទាន់បានប្រគេន" បើគេទទួលយកប្រេង ឬទឹកដោះថ្លានោះ ឱ្យប្រេង ឬទឹកដោះថ្លាដទៃ ៗ កុំគប្បីឱ្យវាល់ប្រេងរបស់ខ្លួនមុន ៗ ព្រោះហេតុអ្វី ? ព្រោះមានប្រេងសល់នៅក្នុងនាឡិប្រេង ៗ ប្រេងនៅសល់នោះ នឹងធ្វើប្រេងដែលនៅមិនបានទទួលប្រគេន របស់ភិក្ខុដែលវាល់ខាងក្រោយឱ្យវិនាសទៅ ដូច្នេះឯង ៗ ពាក្យដ៏សេសមានអត្ថងាយយល់ទាំងអស់ ៗ

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ៗ

ពណ៌នាកយវិក្កយសិក្ខាបទទី ១០ ចប់

## ចំនួនសិក្ខាបទក្នុងកោសិយវគ្គទី២ នោះ គឺ

១, កោសិយសិក្ខាបទ ការធ្វើសន្ថតដោយរោមចៀមលាយសូត្រ
២, សុទ្ធកាឡកសិក្ខាបទ ការធ្វើសន្ថតដោយរោមចៀមខ្មៅសុទ្ធ
៣, ទ្វេភាគសិក្ខាបទ ការធ្វើសន្ថតយករោមចៀមខ្មៅពីរភាគមកលាយ
៤, ឆព្វស្សសិក្ខាបទ ការធ្វើសន្ថតថ្មីហើយត្រូវប្រើប្រាស់ឱ្យបាន ៦ ឆ្នាំ
៥, និសីទនសន្ថតសិក្ខាបទ ការធ្វើនិសីទនៈ ត្រូវកាត់យកសន្ថតចាស់មកលាយ
៦, ឯឡកលោមសិក្ខាបទ ការកាន់យករោមចៀមដើរបានត្រឹម ៣ យោជន៍
៧, ឯឡកលោមធោវាបនសិក្ខាបទ ការប្រើភិក្ខុនីឱ្យលាងជ្រលក់គក់រោមចៀម
៨, រូបិយសិក្ខាបទ ការទទួលរូបិយ
៩, រូបិយសំវោហារសិក្ខាបទ ការលក់ទិញដោយរូបិយ
១០, កយវិក្កយសិក្ខាបទ ការទិញផ្លាស់ប្តូរដោយអប្បិយវត្ថុ

**ចប់ កោសិយវគ្គ ទី ២**

# បត្តវគ្គ

## ១. បត្តសិក្ខាបទវណ្ណនា

[១១៧] បត្តសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងបត្តសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា បត្តវាណិជ្ជំ : នូវជំនួញបាត្រ មានសេចក្តីថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រនឹងត្រាច់ធ្វើការលក់បាត្រ ក្នុងទីទាំងឡាយមានស្រុក និងនិគមជាដើម ។ ភាជនៈ លោកហៅថា អាមត្តៈ (ក្នុងពាក្យថា អាមត្តិកាបណំ) ។ ភាជនៈទាំងនោះ ជាទំនិញ របស់ជនពួកណា ជនពួកនោះ ឈ្មោះថា អាមត្តិកា (អ្នកមានភាជនៈជាទំនិញ) ។ រានផ្សាររបស់អ្នកមានភាជនៈជាទំនិញទាំងនោះ ឈ្មោះថា អាមត្តិកាបណៈ : រានផ្សារលក់ភាជន៍ដី ។ អធិប្បាយថា រានលក់ទំនិញរបស់ពួកស្មូនឆ្នាំង ។

### អធិប្បាយខ្នាតបាត្រ ៣-៩ ខ្នាត

[១១៩] ច្រើនបទថា តយោ បត្តស្ស វណ្ណា : ខ្នាតនៃបាត្រមាន ៣ យ៉ាង បានដល់ ខ្នាតនៃបាត្រ ៣ ប្រភេទ ។

ពីរបទថា **អឌ្ឍាឡ្ហកោទនំ គណ្ហាតិ : ចំណុះបាយនៃអង្ករកន្លះអាឡ្ហក** មានសេចក្តីថា រមែងចុះបាយនៃអង្ករ ២ នាឡិ ដោយនាឡិមគធ ។ ក្នុងអន្ធកដ្ឋកថា លោកពោលថា ដែលឈ្មោះថា នាឡិមគធ មាន ១២ បលៈកន្លះ ។ ក្នុងមហាអដ្ឋកថា លោកពោលថា ក្នុងកោះសីហឡ នាឡិតាមប្រក្រតីធំ នាឡិរបស់អ្នកស្រុកទមិឡតូច, នាឡិមគធបានខ្នាត ។ កន្លះនាឡិមគធនោះ ស្មើមួយនាឡិសីហឡ ។

បទថា **ចតុព្ភាគំ ខាទនីយំ : ចំណុះខាទនីយស្មើចំណែកបាយជាគម្រប់ ៤** មានសេចក្តីថា ខាទនីយប្រមាណប៉ុនចំណែកទី ៤ នៃបាយ ។ ខាទនិយៈនោះ គប្បីជ្រាបដោយអំណាចនៃសម្បូរ សណ្តែកបាយល្មមចាប់ដោយដៃបាន ។

ពីរបទថា **តទុបិយំ ព្យញ្ជនំ : ចំណុះម្ហូបល្មមសមគួរនឹងបាយនោះ** មានសេចក្តីថា ម្ហូបមានត្រីសាច់បន្លែផ្លែឈើនិងទំពាំងជាដើម ដែលសមគួរដល់បាយនោះ ។

ក្នុងបាត្រនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

គប្បីយកអង្ករនៃស្រូវសាលីចាស់ (ដែលរក្សាទុកដើមឆ្នាំ) ដែលមិនបាក់ ដែលស្រិតបរិសុទ្ធល្អហើយ ២ នាឡិមគធ ដាំឱ្យជាបាយដោយអង្ករទាំងនោះ មិនជាត់ទឹក មិនជាបាយពងបង្កួយ (នៅឆៅ) មិន

ជ្រាយ មិនជាដុំ ទន់ល្អ ដូចគំនរផ្កាម្លិះកំពុងក្នុងឆ្នាំង ហើយដាក់ចូលក្នុងបាត្រមិនឱ្យនៅសល់ បន្ថែមសម្លរសំណែកដែលផ្សំគ្រឿងគ្រប់យ៉ាង មិនខាប់ពេកមិនរាវពេក ល្មមដៃកាន់បាន ដាក់ចូលទៅប្រមាណប៉ុនចំណែកទី ៤ នៃបាយនោះ ។ បន្ទាប់ពីនោះ ទើបបន្ថែមម្ហូបមានត្រី សាច់ជាដើមចូលទៅ សមគួរដល់ពំនូត បាយជាពំនូត ៗ ដរាបល្មមនឹងពំនូតបាយជាយ៉ាងក្រៃលែង ។ ចំណែកទឹកដោះថ្លា ប្រេង រសប្រេងទឹកដោះនិងទឹកបាយជាដើម មិនគួររាប់ ។ ព្រោះរបស់ទាំងនោះ មានគតិដូចបាយនោះឯង មិនអាចថយចុះនិងមិនអាចបន្ថែមឡើងបាន ។ អាហារដែលដាក់ចូលយ៉ាងនេះ សូម្បីទាំងអស់នោះ បើតាំងនៅ ស្មើខាងក្រោមនៃវណ្ណកណ្ដាប់មាត់បាត្រ, កាលយកសរសៃអំបោះ ឬ ចំរៀកឈើ (ចំរៀកត្នោត)ច្រៀកទៅ (របស់ក្នុងបាត្រនេះ) ពាល់ត្រូវទីបំផុតខាងក្រោមសរសៃអំបោះ ឬចំរៀកឈើនោះ (គឺ របស់ក្នុងបាត្រមានបាយកន្លះនាឡិជាដើមនេះ ពាល់ត្រូវទីបំផុតខាងក្រោមនៃអំបោះ ឬ ចំរៀកត្នោត របស់បុគ្គលអ្នកកាត់ដោយអំបោះ ឬចំរៀកត្នោត, បាត្រនេះឈ្មោះថា បាត្រខ្នាតធំ (យ៉ាងកណ្ដាល) ។ បើរបស់ក្នុងបាត្រនោះ ពូនជាកំពូលកំពុងហួសវណ្ណ (កណ្ដាប់មាត់បាត្រ) នោះឡើងមក, បាត្រនេះ ឈ្មោះថា បាត្រខ្នាតធំយ៉ាងតូច ។ បើរបស់ក្នុងបាត្រនោះ មិនដល់វណ្ណកណ្ដាប់ (មាត់បាត្រ) ចន្លោះនៅខាងក្នុងប៉ុណ្ណោះ, បាត្រនេះ ឈ្មោះថា បាត្រខ្នាត

ធំយ៉ាងធំ ។

បទថា ឆាឡង្គុលកោដធំ : ចំណុះបាយនៃអង្ករ ១ នាឡិ បានដល់ បាយនៃអង្ករ ១ នាឡិ ដោយនាឡិមគធ ។

បទថា បត្ថោធំ : ចំណុះបាយនៃអង្ករ១បត្ថ បានដល់ បាយកន្លះនាឡិដោយនាឡិមគធ ។ បទដ៏សេស គប្បីជ្រាបដោយន័យដូចពោលហើយនុ៎ះឯង ។ តែមានសេចក្តីប្លែកគ្នាក្នុងហេតុត្រឹមតែឈ្មោះ ដូចតទៅនេះ ៖

បើរបស់មានបាយ ១ នាឡិជាដើមស្ងួបទាំងអស់ដែលដាក់អស់ហើយ នៅស្មើវណ្ណកណ្តាប់ក្រោម ដោយន័យដូចពោលហើយនុ៎ះឯង ។ បាត្រនេះ ឈ្មោះថា បាត្រខ្នាតកណ្តាល ។ បើរបស់កពូនជាកំពូលហួសវណ្ណកណ្តាប់នោះឡើង មក, បាត្រនេះ ឈ្មោះថា បាត្រខ្នាតកណ្តាលយ៉ាងតូច ។ បើមិនដល់វណ្ណកណ្តាប់នោះ, ចន្លោះនៅត្រឹមតែខាងក្នុងប៉ុណ្ណោះ, បាត្រនេះ ឈ្មោះថា បាត្រខ្នាតកណ្តាលយ៉ាងធំ ។ បើរបស់ទាំងអស់មានបាយប្រមាណកន្លះនាឡិជាដើម ដែលសម្រេចចុះហើយនៅស្មើវណ្ណក្រោម (នៃកណ្តាប់មាត់បាត្រ), បាត្រនេះ ឈ្មោះថា បាត្រខ្នាតតូច(យ៉ាងកណ្តាល) ។ បើរបស់ពូនកំពុងឡើងជាកំពូលហួសវណ្ណកណ្តាប់នោះឡើងមក, បាត្រនេះ ឈ្មោះថា បាត្រខ្នាតតូចយ៉ាងតូច ។

បើរបស់មិនដល់វេណ្ឌកណ្ដាប់នោះ ខ្ទះចន្លោះនៅខាងក្នុងប៉ុណ្ណោះ, បាត្រនេះ ឈ្មោះថា បាត្រខ្នាតតូចយ៉ាងធំ ។ អ្នកសិក្សាគប្បីជ្រាបបាត្រ ៩ ប្រភេទទាំងនេះ ដោយប្រការដូចពោលមកដូច្នេះឯង ។

បណ្ដាបាត្រ ៩ ប្រភេទនោះ បាត្រ ២ ប្រភេទ គឺ បាត្រខ្នាតធំយ៉ាងធំ ១ បាត្រតូចយ៉ាងតូច ១ មិនចាត់ជាបាត្រ (ជាបាត្រប្រើមិនបាន) ។ ពិតមែន ពាក្យថា ធំជាងនោះ មិនមែនបាត្រតូចជាងនោះ មិនមែនបាត្រ, នេះត្រាស់សំដៅយកបាត្រ ២ ប្រភេទនោះ ។ ពិតមែន បណ្ដាបាត្រ ២ ប្រភេទនេះ បាត្រខ្នាតធំយ៉ាងធំ គឺ ធំជាងនោះ ត្រាស់ថា មិនមែនបាត្រ ព្រោះធំជាងខ្នាតធំ ។ និងបាត្រខ្នាតតូចយ៉ាងតូច គឺ តូចជាងនោះ ត្រាស់ថា មិនមែនបាត្រ ព្រោះតូចជាងខ្នាតតូច ។ ព្រោះដូច្នោះ បាត្រទាំងនេះ គួរប្រើប្រាស់ដូចជាការប្រើប្រាស់ភាជនៈ មិនគួរអធិដ្ឋាន មិនគួរវិកប្ប ។ ចំណែកបាត្រ ៧ ប្រភេទក្រៅនេះ គប្បីអធិដ្ឋាន ឬ វិកប្បទុកប្រើចុះ ។

[១២០] កាលភិក្ខុមិនធ្វើយ៉ាងនេះ ឱ្យបាត្រនោះកន្លង ១០ ថ្ងៃទៅ ជា និស្សគ្គិយបាចិត្តិយ គឺ កាលភិក្ខុឱ្យបាត្រសូម្បីទាំង ៧ ប្រភេទនោះ ហួសវេលា ១០ ថ្ងៃទៅ ជានិស្សគ្គិយបាចិត្តិយ ដូច្នេះឯង ។

[១២៥] ពាក្យថា និស្សគ្គិយំ បត្តំ អនិស្សជ្ជិត្វា បរិភុញ្ជតិ

**:** ភិក្ខុមិនលះបង់បាត្រដែលជានិស្សគ្គិយ ហើយប្រើប្រាស់ គប្បីជ្រាបសេចក្តីថា ត្រូវអាបត្តិទុក្កដ គ្រប់ប្រយោគយ៉ាងនេះ គឺ កាលភិក្ខុផឹកយាគូ ហើយលាងបាត្រ ត្រូវអាបត្តិទុក្កដ, កាលឆាន់បង្អែម ឆាន់ភត្តាហារហើយ លាងបាត្រត្រូវអាបត្តិទុក្កដ ។

## អធិប្បាយបាត្រដែលគួរអធិដ្ឋាននិងវិកប្ប

[១២៦] ក៏ក្នុងពាក្យថា អនាបត្តិ អន្តោទសាហំ អធិដ្ឋេតិ វិកប្បេតិ **:** អាបត្តិមិនមានដល់ភិក្ខុដែលបានអធិដ្ឋាន បានវិកប្ប ក្នុងរវាង ១០ ថ្ងៃ នេះ អ្នកសិក្សាគប្បីជ្រាបសូម្បីបាត្រដែលបានប្រមាណជាបាត្រគួរអធិដ្ឋាននិងវិកប្ប ដោយន័យដូចពោលយ៉ាងនេះ ៖

បាត្រដែក ដុតហើយដោយការដុត ៥ ភ្លើង បាត្រដីដុតហើយដោយការដុត ២ ភ្លើង ទើបគួរអធិដ្ឋាន ។ បាត្រទាំង ២ ប្រភេទ កាលឱ្យមូលតម្លៃដែលគួរឱ្យហើយនុ៎ះឯង បើដុតនៅខ្វះ សូម្បីត្រឹមតែមួយភ្លើង ឬមិនទាន់បានឱ្យមូលតម្លៃសូម្បីត្រឹមតែមួយកាកណិក មិនគួរអធិដ្ឋាន ។ បើម្ចាស់របស់បាត្រពោលថា លោកចូរឱ្យក្នុងវេលាលោកមានមូលតម្លៃ, លោកចូរអធិដ្ឋានប្រើប្រាស់ចុះ ដូច្នេះ ក៏មិនទាន់គួរអធិដ្ឋានពិត ។ ព្រោះថា មិនទាន់ដល់ការរាប់ថា ជាបាត្រ ព្រោះការដុតនៅខ្វះ, មិនទាន់ដល់ភាពជាបាត្ររបស់ខ្លួន ។ នៅជារបស់អ្នកដទៃនៅ

ឡើយ ព្រោះមូលតម្លៃទាំងអស់ ឬចំណែកមួយមិនទាន់បានឱ្យ ; ព្រោះដូច្នោះកាលដុត និងកាលឱ្យមូលតម្លៃរួចហើយទុ៎ះឯង ទើបជាបាត្រគួរអធិដ្ឋាន, បាត្រដែលគួរអធិដ្ឋានប៉ុណ្ណោះ ទើបគួរវិកប្ប ។ បាត្រនោះនឹងមកដល់ដៃហើយក៏ដោយ មិនទាន់មកដល់ក៏ដោយ គួរអធិដ្ឋាន ឬគួរវិកប្បទុក ។

ក៏បើថា ជាងបាត្របានមូលតម្លៃហើយ ឬជាអ្នកប្រាថ្នានឹងប្រគេនដោយខ្លួនឯង ពោលថា "លោកម្ចាស់ ខ្ញុំព្រះករុណានឹងធ្វើបាត្រប្រគេនលោកម្ចាស់ ដុតហើយក្នុងថ្ងៃឈ្មោះឯណោះ នឹងរក្សាទុក" និងភិក្ខុឱ្យកន្លង ១០ ថ្ងៃទៅ អំពីថ្ងៃដែលជាងបាត្រនោះកំណត់ទុកជានិស្សគ្គិយបាចិត្តិយ ។ ក៏បើថា ជាងបាត្រពោលថា "ខ្ញុំព្រះករុណា នឹងធ្វើបាត្រប្រគេនលោកម្ចាស់" ដុតហើយនឹងបញ្ជូនដំណឹងមកឱ្យជ្រាប ហើយធ្វើដោយប្រការដូច្នោះ, ចំណែកភិក្ខុដែលជាងបាត្រនោះ ពឹងពាក់ទៅមិនប្រាប់ដល់ភិក្ខុនោះ, ភិក្ខុដទៃឃើញ ឬបានឮទើបប្រាប់ថា "លោកម្ចាស់ បាត្ររបស់លោកសម្រេចហើយ" ការប្រាប់របស់ភិក្ខុនោះមិនជាប្រមាណ ។ តែក្នុងវេលាដែលភិក្ខុដែលជាងបាត្រនោះពឹងពាក់ទុ៎ះឯងប្រាប់, កាលភិក្ខុឱ្យកន្លង ១០ ថ្ងៃទៅ ចាប់តាំងពីថ្ងៃដែលបានឮពាក្យពោលប្រាប់របស់ភិក្ខុនោះ ជានិស្សគ្គិយបាចិត្តិយ ។ បើជាងបាត្រពោលថា "ខ្ញុំព្រះករុណានឹងធ្វើបាត្រ ប្រគេនលោកម្ចាស់" ដុតហើយនឹងបញ្ជូនទៅក្នុងដៃរបស់ភិក្ខុរូបខ្លះ ហើយធ្វើតាម

ពាក្យនិយាយនោះ, តែភិក្ខុដែលទទួលបាត្រមករក្សាទុក ក្នុងបរិវេណរបស់ខ្លួន ហើយមិនប្រាប់ដល់លោក, ភិក្ខុណាមួយដទៃ ពោលថា "លោកម្ចាស់ បាត្រដែលបានមកថ្មីស្អាតល្អដែរទេ ?" លោកពោលថា "អ្នកមានអាយុ បាត្រនៅឯណា ?" ភិក្ខុរូបខ្លះនោះ ពោលថា ជាងបាត្របញ្ជូនមកក្នុងដៃរបស់ភិក្ខុឈ្មោះនេះ ។ ពាក្យរបស់ភិក្ខុសូម្បីនេះក៏មិនជាប្រមាណ ។ តែក្នុងវេលាដែលភិក្ខុនោះឱ្យបាត្រ, កាលលោកឱ្យកន្លង ១០ ថ្ងៃទៅ រាប់តាំងពីថ្ងៃដែលបានបាត្រមក ជានិស្សគ្គិយបាចិត្តិយ ។ ព្រោះដូច្នោះ កុំឱ្យកន្លង ១០ ថ្ងៃ គប្បីអធិដ្ឋានឬគប្បីវិកប្បទុក ។

## អធិប្បាយការអធិដ្ឋានបាត្រ

បណ្តាការអធិដ្ឋាននិងវិកប្បនោះ អធិដ្ឋានបាត្រមាន ២ យ៉ាង គឺ អធិដ្ឋានដោយកាយ ១ អធិដ្ឋានដោយវាចា ១ ។ ភិក្ខុកាលនឹងអធិដ្ឋានដោយអំណាចនៃការអធិដ្ឋាន ២ យ៉ាងនោះ គប្បីបច្ចុទ្ធរណ៍បាត្រចាស់ដែលតាំងនៅចំពោះមុខ ឬក្នុងទីកំបាំងមុខ យ៉ាងនេះថា "**ឥមំ បត្តំ បច្ចុទ្ធរាមិ** : ខ្ញុំដកនូវបាត្រនេះ" ឬថា "**ឯតំ បត្តំ បច្ចុទ្ធរាមិ** : ខ្ញុំដកនូវបាត្រនោះ" ឬឱ្យដល់ភិក្ខុដទៃហើយ យកដៃស្ទាបអង្អែលបាត្រថ្មីដែលតាំងនៅក្នុងទីកន្លែងណាមួយ ហើយធ្វើអាភោគចិត្តហើយធ្វើកាយ

វិការអធិដ្ឋានដោយកាយ ឬបញ្ចេញវាចា ហើយអធិដ្ឋានដោយវាចាថា "ឥមំ បត្តំ អធិដ្ឋាមិ : ខ្ញុំអធិដ្ឋាននូវបាត្រនេះ" ។

ក្នុងអធិដ្ឋានវិស័យនោះ អធិដ្ឋានមាន ២ យ៉ាង ។ បើបាត្រនៅក្នុងហត្ថបាស គប្បីបញ្ចេញវាចាថា "ឥមំ បត្តំ អធិដ្ឋាមិ : ខ្ញុំអធិដ្ឋាននូវបាត្រនេះ" ។ បើបាត្រនោះ នៅខាងក្នុងបន្ទប់ក្តី ក្នុងប្រាសាទជាន់លើក្តី ក្នុងវិហារជិត ៗក្តី, ភិក្ខុគប្បីកំណត់ស្ថានទីដែលបាត្រតាំងនៅ ហើយគប្បីបញ្ចេញវាចាថា "ឯតំ បត្តំ អធិដ្ឋាមិ : ខ្ញុំអធិដ្ឋាននូវបាត្រនោះ" ។ ក៏ភិក្ខុដែលអធិដ្ឋាន សូម្បីអធិដ្ឋានតែម្នាក់ ឯងក៏គួរ ។ សូម្បីនឹងអធិដ្ឋានក្នុងសំណាក់របស់ភិក្ខុដទៃ ក៏គួរ ។

ការអធិដ្ឋានក្នុងសំណាក់របស់ភិក្ខុដទៃមានអានិសង្សដូចតទៅនេះ ៖

បើលោកកើតសេចក្តីសង្ស័យថា "បាត្រយើងអធិដ្ឋានហើយ ឬមិនទាន់អធិដ្ឋានហ្ន៎" ដូច្នេះ, មួយរូបទៀត នឹងជាស់តឿនឱ្យនឹកបាន កាត់សេចក្តីសង្ស័យចេញ ។ បើភិក្ខុរូបណាមួយ បានបាត្រមក ១០ ខ្ទង់ ឯងប្រាថ្នានឹងប្រើប្រាស់ទាំងអស់តែម្តង, កុំគប្បីអធិដ្ឋានទាំងអស់ ។ អធិដ្ឋានបាត្រមួយហើយថ្ងៃស្អែកដកបាត្រនោះ ហើយគប្បីអធិដ្ឋានបាត្រថ្មី ។ ដោយឧបាយនេះ អាចនឹងបានរក្សាទាំង ១០០ ឆ្នាំ ។

## ការដាច់អធិដ្ឋានរបស់បាត្រ

សួរថា ការដាច់អធិដ្ឋាន គប្បីមានដល់ភិក្ខុដែលមិនប្រមាទ យ៉ាងនេះបានឬ ?

ឆ្លើយថា គប្បីមានបាន ។

បើថា ភិក្ខុនេះ ឱ្យបាត្រដល់ភិក្ខុដទៃក្តី សឹកទៅកាន់ហីនភេទក្តី ពោលលាសិក្ខាក្តី ធ្វើមរណកាលក្តី ក្លាយភេទក្តី បច្ចុទ្ធរណ៍ចេញក្តី បាត្រមានប្រហោងធ្លុះក្តី បាត្ររមែងដាច់អធិដ្ឋាន ។ ក៏ពាក្យនេះសូម្បីអាចារ្យទាំងឡាយក៏បានពោលទុកថា

ទិន្នវិព្ភន្តបច្ចក្ខា កាលំកិរិយកតេន ច
លិង្គបច្ចុទ្ធរា ចេវ ឆិទ្ទេន ភវតិ សត្តមំ ។

ការដាច់អធិដ្ឋាន រមែងមានដោយការឱ្យ ១ សឹកទៅ ១ លាសិក្ខា ១ ធ្វើកាលកិរិយា ១ ក្លាយភេទ ១ បច្ចុទ្ធរណ៍ (ដក) ១ ជាគម្រប់ ៧ នឹងប្រហោងធ្លុះ ដូច្នេះ ។

សូម្បីព្រោះចោរលួច និងការកាន់យកដោយវិសាសៈ បាត្រក៏ដាច់អធិដ្ឋានដូចគ្នា ។ បាត្រនឹងដាច់អធិដ្ឋានដោយប្រហោងធ្លុះប្រមាណប៉ុនណា ? នឹងដាច់អធិដ្ឋានដោយប្រហោងធ្លុះល្មម គ្រាប់ថ្លៅចេញបាន និងចូលបាន ។

ពិតមែន បណ្តាធញ្ញជាតិ ៧ ប្រភេទ គ្រាប់ថ្ពៅនេះ ជាគ្រាប់ធញ្ញជាតិយ៉ាងតូច ។ កាលប្រហោងនោះចុកឱ្យជិតជាប្រក្រតីដោយយកម្ទេចដែក ឬដោយយកន្ទាស់ហើយគប្បីអធិដ្ឋានបាត្រនោះថ្មីខាងក្នុង១០ ថ្ងៃ ។

ក្នុងការអធិដ្ឋានដែលត្រាស់ទុកក្នុងពាក្យថា អន្តោទសាហំ អធិដ្ឋេតិ វិកប្បេតិ : ភិក្ខុដែលអធិដ្ឋាន ... ក្នុងរវាង ១០ ថ្ងៃ នេះ មានវិនិច្ឆ័យត្រឹមតែប៉ុណ្ណោះសិន ។

## ការវិកប្បបាត្រ

ក៏ក្នុងការវិកប្ប មានវិនិច្ឆ័យដូចតទៅនេះ ៖

វិកប្បមាន ២ យ៉ាង គឺ វិកប្បចំពោះមុខម្យ៉ាង វិកប្បកំបាំងមុខម្យ៉ាង ។ វិកប្បចំពោះមុខជាយ៉ាងណា ? គឺ ភិក្ខុគប្បីដឹងថា បាត្រមានតែមួយ ឬច្រើន និងដាក់ទុកជិត ឬ មិនបានដាក់ទុកជិត ហើយពោលថា "ឥមំ បត្តំ : នូវបាត្រនេះ" ឬថា "ឥមេ បត្តេ : នូវបាត្រទាំងនេះ" ក្តី, ថា "ឯតំ បត្តំ : នូវបាត្រនោះ" ឬថា "ឯតេ បត្តេ : នូវបាត្រទាំងនោះ" ក្តី, ហើយពោលថា "តុយ្ហំ វិកប្បេមិ : ខ្ញុំព្រះករុណាវិកប្បដល់លោក" នេះឈ្មោះថា វិកប្បចំពោះមុខម្យ៉ាង ។ ដោយវិធីវិកប្បត្រឹមតែប៉ុណ្ណោះនឹងរក្សាទុក គួរ ។ តែនឹងប្រើប្រាស់ នឹងលះ

បង់ ឬនឹងអធិដ្ឋានមិនសមគួរ ។ តែកាលភិក្ខុដែលទទួលវិកប្បពោល យ៉ាងនេះថា "មយ្ហំ សន្តកំ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ : បាត្រនេះរបស់ខ្ញុំព្រះករុណា លោកចូរប្រើប្រាស់ ចូរលះបង់ ឬចូរ ធ្វើតាមបច្ច័យក៏ដោយ" ដូច្នេះ ឈ្មោះថា ដក ។ ចាប់ផ្តើមតាំងពីនោះ សូម្បីការ ប្រើប្រាស់ជាដើមគួរ ។

ន័យមួយទៀត ភិក្ខុជ្រាបថា បាត្រមានតែមួយឬច្រើន និងដាក់ទុកជិតឬមិនបានដាក់ទុកជិតយ៉ាងនោះដូចគ្នា ហើយពោល "ឥមំ បត្តំ : នូវបាត្រនេះ" ឬថា "ឥមេ បត្តេ : នូវបាត្រទាំងឡាយនេះ" ក្តី, ថា "ឯតំ បត្តំ : នូវបាត្រនោះ" ឬថា "ឯតេ បត្តេ : នូវបាត្រទាំងឡាយនោះ" ក្តី, ក្នុងសំណាក់របស់ភិក្ខុនោះឯង ហើយបញ្ញាក់ឈ្មោះនៃបណ្តាសហធម្មិកទាំង ៥ រូបណាមួយ គឺ លោកនាមួយ ដែលខ្លួនពេញចិត្ត ហើយគប្បីពោលថា "តិស្សស្ស ភិក្ខុនោ វិកប្បេមិ : ខ្ញុំព្រះករុណាវិកប្បដល់ភិក្ខុឈ្មោះថា តិស្សៈ" ដូច្នេះក្តី ថា "តិស្សាយ ភិក្ខុនិយា ... តិស្សាយ សិក្ខមានាយ ... តិស្សស្ស សាមណេរស្ស ... តិស្សាយ សាមណេរិយា វិកប្បេមិ : ខ្ញុំព្រះករុណាវិកប្បដល់ភិក្ខុនីឈ្មោះតិស្សា ... ដល់សិក្ខមានា ឈ្មោះតិស្សា ... ។ ដល់សាមណេរឈ្មោះតិស្សៈ ... ។ ដល់សាមណេរីឈ្មោះតិស្សា" ដូច្នេះក្តី នេះឈ្មោះ

ថា វិកប្បចំពោះមុខ សូម្បីដទៃទៀត ។ ដោយពាក្យត្រឹមតែប៉ុណ្ណេះ នឹងរក្សាទុកសមគួរ, តែបណ្ដាកិច្ចមានការប្រើប្រាស់ជាដើម សូម្បីកិច្ចយ៉ាងណាមួយក៏មិនគួរ ។ តែកាលភិក្ខុដែលទទួលវិកប្បនោះ ពោលថា "តិស្សស្ស ភិក្ខុនោ សន្តកំ ។បេ ។ តិស្សាយ សាមណេរិយា សន្តកំ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ : បាត្រនេះ របស់ភិក្ខុឈ្មោះតិស្សៈ ។ល ។ របស់សាមណេរីឈ្មោះតិស្សា លោកចូរប្រើប្រាស់ក៏ដោយ ចូរចំណាយក៏ដោយ ចូរធ្វើតាមបច្ច័យក៏ដោយ" ដូច្នេះហើយ ឈ្មោះថា ដក ។ ចាប់ផ្ដើមតាំងពីនោះ សូម្បីការបរិភោគជាដើមក៏សមគួរ ។

វិកប្បកំបាំងមុខ តើយ៉ាងណា ? គឺ ភិក្ខុជ្រាបថា បាត្រមានតែមួយឬច្រើន ដាក់ទុកជិត ឬមិនបានដាក់ទុកជិតយ៉ាងនោះឯង ហើយពោលថា "ឥមំ បត្តំ : នូវបាត្រនេះ" ឬថា "ឥមេ បត្តេ : នូវបាត្រទាំងនេះ" ក្ដី, ថា "ឯតំ បត្តំ : នូវបាត្រនោះ" ឬថា "ឯតេ បត្តេ : នូវបាត្រទាំងនោះ" ក្ដី, ហើយពោលថា "តុយ្ហំ វិកប្បនត្ថាយ ទម្មិ : ខ្ញុំព្រះករុណាឱ្យដល់លោកដើម្បីត្រូវការវិកប្ប" ដូច្នេះ ។

ភិក្ខុដែលទទួលវិកប្បនោះ គប្បីសួរលោកថា "អ្នកណាជាមិត្ត ឬជាសម្លាញ់ធ្លាប់ឃើញគ្នារបស់លោក" ។ លំដាប់នោះ ភិក្ខុដែលវិកប្ប

ក្រៅនេះ គប្បីពោលថា "តិស្សោ ភិក្ខុ : ភិក្ខុឈ្មោះថា តិស្សៈ" ។ល។ ឬថា "តិស្សា សាមណេរី សាមណេរីឈ្មោះថា តិស្សា" ដោយន័យមុនទុំះឯង ។ ភិក្ខុអ្នកវិកប្បនោះ គប្បីពោលទៀតថា "អហំ តិស្សស្ស ភិក្ខុនោ ធម្មិ : ខ្ញុំព្រះករុណាឱ្យដល់ភិក្ខុឈ្មោះតិស្សៈ" ។បេ។ ឬថា "តិស្សាយ សាមណេរិយា ធម្មិ : ខ្ញុំព្រះករុណាឱ្យដល់សាមណេរីឈ្មោះតិស្សា" ។ នេះឈ្មោះថា វិកប្បកំបាំងមុខ ។ ដោយការវិកប្បត្រឹមតែប៉ុណ្ណេះនឹងរក្សាទុក គួរ, តែបណ្ដាកិច្ចមានការប្រើប្រាស់ជាដើម សូម្បីតែម្យ៉ាង ក៏មិនគួរ ។ កាលភិក្ខុនោះពោលថា "ឥត្ថន្នាមស្ស សន្តកំ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ : បាត្រនេះ របស់ភិក្ខុឈ្មោះនេះ លោកចូរប្រើប្រាស់ក៏ដោយ ចូរចំណាយក៏ដោយ ចូរធ្វើតាមបច្ច័យក៏ដោយ" ដោយន័យដូចពោលហើយ ក្នុងវិកប្បចំពោះមុខដូចទីពីរនុ៎ះឯង រមែងឈ្មោះថា ដក ។ ចាប់តាំងពីពេលនោះមក សូម្បីការនឹងប្រើប្រាស់ជាដើម ក៏គួរ ។ តែសេចក្ដីផ្សេងគ្នា នៃវិកប្បទាំងពីរយ៉ាងនេះ និងលំដាប់នៃវណ្ណនាដ៏សេសទាំងអស់ អ្នកសិក្សាគប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងវណ្ណនានៃបឋមកឋិនសិក្ខាបទនុ៎ះឯង ព្រមទាំងសមុដ្ឋានជាដើម ដូច្នេះឯង ។

បត្តសិក្ខាបទទី ១ ចប់

## ២. ឩនបញ្ចពន្ធនសិក្ខាបទវណ្ណនា

[១២៨] ឩនបញ្ចពន្ធនសិក្ខាបទថា តេន សមយេន : សម័យនោះ ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងឩនបញ្ចពន្ធនសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា ន យាបេតិ : នឹងរកចិញ្ចឹម( ខ្លួន )ក៏មិនបាន មានសេចក្ដីថា បានឮថា ស្ត្រូនឆ្នាំងនោះត្រូវភិក្ខុឆព្វគ្គិយទាំងនោះរុកកួនយ៉ាងនេះ បើនឹងមិនបានជាព្រះអរិយសាវកហើយ គង់នឹងដល់សេចក្ដីខូចចិត្តសូម្បីយ៉ាងដទៃទៅ ។ តែព្រោះគាត់ជាសោតាបន្ន ខ្លួនឯងតែម្យ៉ាងប៉ុណ្ណោះ មិនល្មមចិញ្ចឹមជីវិត ។ ព្រោះហេតុនោះ ព្រះធម្មសង្គីតិកាចារ្យទើបពោលថា "សូម្បីនឹងរកចិញ្ចឹមជីវិតខ្លួនឯង ក៏មិនបាន កូននិងប្រពន្ធទាំងឡាយ របស់ស្ត្រូនឆ្នាំងនោះសោត ក៏ព្រួយលំបាក" ។

### អធិប្បាយបាត្រមានចំណងមិនទាន់គ្រប់ ៥ ជាដើម

[១៣០] ក្នុងបទថា ឩនបញ្ចពន្ធនេន : មិនទាន់មានចំណង ៥ អន្លើ នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

បាត្រដែលឈ្មោះថា មិនទាន់មានចំណង ៥ អន្លើ ព្រោះមានចំណងខ្វះ( តិចជាង ) ៥ អន្លើ ។ អធិប្បាយថា បាត្រនោះមានប្រហោង

ផ្ទះមិនទាន់គ្រប់ ៥ អន្លើ ។ មានបាត្រ មានចំណងខ្វះ ៥ នោះ ។ (បទនេះថា) តតិយាវិភត្តិ ចុះក្នុងលក្ខណៈនៃឥត្ថម្ភូត, ក្នុងបាត្រមានមិនទាន់មានចំណងនោះ សូម្បីបាត្រមិនទាន់មានចំណង នឹងមានចំណងមិនទាន់គ្រប់ ៥ អន្លើ ព្រោះមិនទាន់មានដោយប្រការទាំងពួង ; ដូច្នោះ ក្នុងបទភាជនៈ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា អពន្ធនោ វា : ដែលគ្មានចំណងក្តី ជាដើម និងព្រោះត្រាស់ពាក្យថា ឩនបញ្ចពន្ធនេន : មិនទាន់មានចំណង ៥ អន្លើ ដូច្នេះ បាត្រភិក្ខុណាមានចំណងគ្រប់ ៥ អន្លើ, បាត្រនោះ របស់ភិក្ខុនោះ មិនចាត់ជាបាត្រ; ព្រោះដូច្នោះ ទើបគួរសូមបាត្រថ្មីបាន ។ ក៏ព្រោះដែលឈ្មោះថា ចំណងនេះ កាលមានឱកាសនៃចំណង ទើបមានបាន កាលមិនមានឱកាសនៃចំណង ក៏មិនមាន ; ដូច្នោះ ដើម្បីទ្រង់សម្តែងលក្ខណៈនៃប្រហោងផ្ទះនោះ ទើបត្រាស់ពាក្យថា អពន្ធនោកាសោ ឆាម : ហៅថា បាត្រមិនទាន់មានឱកាសនៃចំណង ជាដើម ។

ពាក្យថា ទ្វង្គុលា រាជិ ន ហោតិ : ដែលមានស្នាមប្រេះបែកមិនទាន់ដល់ពីរធ្នាប់ បានដល់ មិនមានស្នាមប្រេះសូម្បីតែមួយ ប្រវែងប្រមាណពីរធ្នាប់ ខាងក្រោមកណ្តាប់មាត់ ។

ពាក្យថា យស្ស ទ្វង្គុលា រាជិ ហោតិ : ដែលមានស្នាមប្រេះបែកប្រមាណដល់ពីរធ្នាប់ មានសេចក្តីថា បាត្រដែលមានស្នាមប្រេះតែមួយដូច្នេះ គប្បីយកដែកសម្រាប់ចោះបាត្រ ចោះទីបំផុតមាត់ក្រោមរបស់ស្នាមប្រេះនោះ ដុតហើយចងរឹតដោយខ្សែអំបោះ និងខ្សែធ្មៃជាដើម ឬដោយលួស ៗ គប្បីចុកប្រហោងធ្លុះនោះដោយបន្ទះសំណ ឬដោយជ័រសម្រាប់ភ្ជាប់យ៉ាងណាមួយ ដើម្បីមិនឱ្យអាមិសជាប់ ៗ ក៏បាត្រនោះគប្បីអធិដ្ឋានទុកប្រើចុះ ៗ មួយទៀត គប្បីចងធ្វើប្រហោងឱ្យតូច ៗ តែនឹងបិទដោយក្រមួនឃ្មុំ អាចម៍ល័ក្ខ និងជ័រស្រស់ជាដើមសុទ្ធ ៗ មិនគួរ ៗ នឹងស្ងោរទឹកអំពៅហើយបិទដោយកំទេចថ្ម គួរ ៗ តែបាត្រដែលភិក្ខុយកដែកចោះ ចោះក្នុងទីជិតកណ្តាប់មាត់នឹងបែក ព្រោះបន្ទះដែកគ្រាស់ ; ព្រោះដូច្នោះ ទើបគួរចោះខាងក្រោម ៗ តែសម្រាប់បាត្រដែលមានស្នាមប្រេះ ២ អន្ទើ, ឬត្រឹមមួយកន្លែង តែប្រេះដល់ ៤ ធ្នាប់ គួរឱ្យគ្រឿងចង ២ ៗ គប្បីឱ្យគ្រឿងចង ៣ ដល់បាត្រដែលមានស្នាមប្រេះ ៣ អន្ទើ ឬមានត្រឹមមួយកន្លែងតែប្រេះដល់ ៦ ធ្នាប់ ៗ គប្បីឱ្យគ្រឿងចង ៤ អន្ទើ ដល់បាត្រដែលមានស្នាមប្រេះ ៤ អន្ទើ ឬមានត្រឹមមួយកន្លែងតែប្រេះដល់ ៨ ធ្នាប់, បាត្រដែលមានស្នាមប្រេះ ៥ អន្ទើ ឬមានត្រឹមមួយកន្លែងតែប្រេះដល់ ១០ ធ្នាប់ នឹងចងក៏ដោយ មិនចងក៏

ដោយ មិនចាត់ជាបាត្រឡើយ, គួរសូមបាត្រថ្មី ។ នេះជាវិនិច្ឆ័យក្នុងបាត្រដីមុន ។

ចំណែកវិនិច្ឆ័យក្នុងបាត្រដែក គប្បីជ្រាបដូចតទៅនេះ ៖

បើសូម្បីមានប្រហោងធ្លុះ ៥ អន្លើ ឬលើសជាង, និងប្រហោងធ្លុះទាំងនោះចុកដោយកម្ទេចដែក ដោយកន្លាស់ ឬដោយដុំដែកមូល ៗ ជារបស់រលីង, គួរប្រើប្រាស់បាត្រនោះឯង, មិនគួរសូមបាត្រថ្មី ។ តែបើមានប្រហោងធ្លុះសូម្បីប្រហោងតែមួយ តែជាប្រហោងធំ ។ សូម្បីចុកដោយដុំដែកមូល ៗ ក៏មិនរលីង, អាមិសជាប់ក្នុងបាត្របាន ជាអកប្បិយ, បាត្រនេះ មិនមែនបាត្រ គួរសូមបាត្រថ្មីបាន ។

[១៣២] ពីរបទថា ថេរោ វត្តព្វោ : ភិក្ខុនោះត្រូវប្រាប់ព្រះថេរៈ មានសេចក្តីថា ភិក្ខុសម្តែងអានិសង្សក្នុងបាត្រហើយ គប្បីទូលព្រះថេរៈថា "លោកម្ចាស់ បាត្រនេះមានខ្នាតត្រឹមត្រូវ ស្អាតល្អ សមគួរដល់ព្រះថេរៈ, សូមលោកមេត្តាទទួលបាត្រនោះទុកចុះ" ។

ពីរបទថា យោ ន គណ្ហេយ្យ : ភិក្ខុណាមួយមិនទទួល មានសេចក្តីថា កាលព្រះថេរៈមិនទទួលទុកដើម្បីអនុគ្រោះ ត្រូវអាបត្តិទុក្កដ ។ តែព្រោះសេចក្តីសន្តោសមិនមានអាបត្តិដល់ភិក្ខុដែលមិនទទួលដោយគិតថា "នឹងមានប្រយោជន៍អ្វីដល់យើងដោយបាត្រដទៃ" ។

បទថា បត្តបរិយន្តោ : បាត្រណាមួយដែលជាទីបំផុត បាន ដល់ បាត្រដែលផ្លាស់ប្តូរគ្នាយ៉ាងនេះតាំងនៅចុងបំផុត ។

បទថា អទេសេ : ក្នុងទីមិនគួរ មានសេចក្តីថា ភិក្ខុនោះ មិនគប្បីរក្សា បាត្រនោះទុកក្នុងទីមិនគួរ មានគ្រែ តាំង ឆត្រ និងធ្មេញនាគជាដើម ។ គប្បីរក្សាទុកក្នុងទីដែលខ្លួនរក្សាបាត្រល្អទុកពីមុនន៎ុះឯង ។ សេចក្តីពិត ទីរក្សាបាត្រ ព្រះមានព្រះភាគត្រាស់ទុកហើយ ក្នុងខន្ធកៈន៎ុះឯង ដោយន័យជាដើមថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រឿងរង( ជើង )ដំកល់បាត្រ"[១] ដូច្នេះ ។

បទថា ន អភោគេន : មិន( ត្រូវប្រើប្រាស់ )ដោយការប្រើមិនសមគួរ គឺ មិនគប្បីប្រើបាត្រដោយការប្រើមិនសមគួរ មានការដាំបបរនិងដាំទឹកជ្រលក់ជាដើម ។ តែកាលកើតអាពាធក្នុងចន្លោះមក កាលភាជនៈដទៃមិនមាន នឹងយកដីស្អិតបំពោកហើយដាំបបរ ឬដាំទឹកក្តៅគួរ ។

បទថា ន វិស្សជ្ជេតព្វោ : មិនត្រូវបោលបាត្រនោះឡើយ មានសេចក្តីថា មិនគួរឱ្យដល់អ្នកដទៃ ។ តែបើថា សទ្ធិវិហារិកឬអន្តេវាសិកដាក់បាត្រដែលល្អ ដទៃទុកជំនួសកាន់យកទៅដោយគិតថា "បាត្រនេះ

១. វិន. ចុល្ល. ខុទ្ទកវត្ថុក្ខន្ធក. ១០. ១៥១/១៥១ ។

គួរដល់យើង, បាត្រនេះគួរដល់ព្រះថេរៈ” ដូច្នេះ គួរ ។ ឬភិក្ខុដទៃកាន់យកបាត្រនោះ ហើយប្រគេនបាត្ររបស់ខ្លួន ក៏គួរ ។ មិនមានកិច្ចដែលត្រូវពោលថា “លោកចូរយកបាត្ររបស់យើងមក” ។

[១៣៧] ក៏ក្នុងបទថា **បវារិតានំ : អំពីសំណាក់ជនដែលបវារណា** នេះ មានអធិប្បាយថា ក្នុងកុរុន្ទីលោកពោលថា ភិក្ខុមានបាត្រមានស្នាមប្រេះត្រឹមតែ ៥ អន្លើ ទឹងសូមបាត្រថ្មីក្នុងទីដែលគេបវារណាទុកដោយអំណាចនៃសង្ឃ គួរ, សូម្បីមានបាត្រមានស្នាមប្រេះ ១ៈ ៥ អន្លើ ទឹងសូមក្នុងទីដែលគេ បវារណាទុកដោយអំណាចនៃបុគ្គល ក៏គួរ ដូច្នេះ ។ ពាក្យដែលនៅសល់ក្នុងសិក្ខាបទនេះ មានអត្ថងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ឩនបញ្ចពន្ធនសិក្ខាបទ ចប់

# ៣. ភេសជ្ជសិក្ខាបទវណ្ណនា

[១៣៨] ភេសជ្ជសិក្ខាបទថា តេន សមយេន : សម័យនោះ ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងភេសជ្ជសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

## ពន្យល់អត្ថក្នុងបឋមបញ្ញត្តិរឿងព្រះបិលិន្ទវច្ឆៈ

ព្រះរាជាទតឃើញភិក្ខុទាំងឡាយ ខ្វល់ខ្វាយជម្រះញកភ្នំ ដើម្បីប្រយោជន៍ ជាទីពួនសម្ងំរបស់ព្រះថេរៈ មានព្រះរាជប្រាថ្នា នឹងប្រគេនអ្នកធ្វើការវត្ត ទើបបានត្រាស់សួរថា អត្ថោ ភន្តេ អយ្យស្ស អារាមិកេន : បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ត្រូវការមនុស្សថែទាំរក្សាអារាមឬទេ ។

បទថា បាដិយេក្កោ : មួយផ្សេងដោយឡែក គឺ ជាស្រុកមួយផ្សេងដទៃ ។

[១៣៩] បទថា មាលាកិតេ : ដោយផ្កាកម្រង បានដល់ អ្នកធ្វើកម្រងផ្កាឈើ គឺ ទ្រទ្រង់ទុកនូវកម្រងផ្កាឈើ, អធិប្បាយថា ប្រដាប់ដោយកម្រងផ្កាឈើ ។

បទថា តិណណ្ឌុបកំ : វង្វេលស្មៅ បានដល់ មកុដស្មៅ ។

បទថា បដិមុញ្ចិ : បំពាក់ គឺ ពាក់ទុក ( លើក្បាល ) ។

ពាក្យថា សា អហោសិ សុវណ្ណមាលា : វង្វេលស្មៅនោះ ក៏ក្លាយជាកម្រងមាស មានសេចក្ដីថា វង្វេលស្មៅនោះ លុះពាក់លើក្បាលរបស់ក្មេងស្រីប៉ុណ្ណោះ បានក្លាយជាកម្រងផ្កាមាសដោយអំណាចនៃការអធិដ្ឋានរបស់ព្រះថេរៈ ។ ពិតមែន ព្រះថេរៈអធិដ្ឋានវង្វេលស្មៅនោះដែលលុះដាក់លើសីរសៈនុ៎ះឯងថា "ចូរក្លាយជាកម្រងផ្កាមាស" ។

ពាក្យថា ទុតិយម្បិ ខោ ។បេ ។ ឧបសង្កមិ : ជាគម្រប់ពីរដង ។ល ។ ទើបចូលទៅ បានដល់ ព្រះថេរៈបានទៅរកក្នុងថ្ងៃស្អែកនុ៎ះឯង ។

ពីរបទថា សុវណ្ណន្តិ អធិមុច្ចិ : ក៏អធិដ្ឋានឱ្យក្លាយជាមាសទៅ បានដល់ ព្រះថេរៈបានអធិដ្ឋានថា "ចូរសម្រេចជាមាស" ។

[១៤០] ពីរបទថា បញ្ចន្នំ ភេសជ្ជានំ : ភេសជ្ជៈ ៥ បានដល់ ភេសជ្ជៈមានទឹកដោះថ្លាជាដើម ។

បទថា ពាហុល្លិកា : ច្រើនរឿយ ៗ បានដល់ អ្នកបដិបត្តិដើម្បីជាអ្នកប្រាថ្នាច្រើនដោយបច្ច័យ ។

ក្នុងពាក្យថា គោលម្ពេបិ[១] ឃដេបិ : ក្នុងថ្លាងផង ក្នុងក្អមផង នេះ ភាជន៍មាត់ធំ ហៅថា គោលម្ពៈ ។

បទថា ឱលីនវិលីនានិ : លេចហៀរចេញមកពាសពេញ បាន ដល់ ជ្រាបស្រក់ចុះខាងក្រោម និងជាយខាងទាំងពីរ ។

បទថា ឱកិណ្ណវិកិណ្ណា : ក៏ដេរដាសពាសពេញ មានសេចក្ដីថា ពួកកណ្ដុរកកាយដីរាយប៉ាយនិងកកេកាត់ជញ្ជាំង រត់ប្រសេចប្រសាចទៅមកខាងលើ ដេរដាស់ ព្រោះក្លិននៃភេសជ្ជៈ ៥ មានទឹកដោះថ្លាជាដើម ។

បទថា អន្តោកោដ្ឋាគារិកា : មានកណ្ដូតម្កល់ទុកក្នុងឃ្លាំង បាន ដល់ មានឃ្លាំងចាត់ចែងទុក នៅខាងក្នុង ។

បទថា បដិសាយនីយានិ : គប្បីឆាន់បាន បានដល់ ដែលគួរភ្លក់រស ។ អធិប្បាយថា គួរបរិភោគ ។

បទថា ភេសជ្ជានិ : ភេសជ្ជៈទាំងឡាយ មានសេចក្ដីថា ភេសជ្ជៈទាំងឡាយ នឹងធ្វើកិច្ចនៃភេសជ្ជៈឬមិនធ្វើក៏ដោយ ក៏បានវោហារ (ថា ភេសជ្ជៈ) យ៉ាងនេះ ។

១. ថៃ. គោលុម្ពេបិ ។

ដោយបទថា គោសប្បិ : សប្បិរបស់គោ ជាដើម ព្រះមានព្រះភាគទ្រង់សម្តែងទឹកដោះថ្លាដែលប្រាកដក្នុងលោក ហើយទ្រង់សម្តែងសង្គ្រោះយកទឹកដោះថ្លាសូម្បីនៃសត្វពួកដទៃមានម្រឹគ រមាំង និងទន្សាយជាដើម ចូលជាមួយនឹងពាក្យថា យេសំ មំសំ កប្បតិ : សាច់របស់សត្វទាំងឡាយណា ដែលសមគួរដល់ពុទ្ធានុញ្ញាត នេះ ៗ ពិតមែនសត្វពួកណាមានទឹកដោះ, សត្វទាំងនោះ ក៏មានទឹកដោះថ្លាផង ៗ តែទឹកដោះថ្លារបស់សត្វទាំងនោះ ទឹងរកបានងាយ ឬរកបានលំបាកក៏ដោយ ក៏ត្រាស់ទុក ដើម្បីការមិនច្រឡំ ៗ សូម្បីទឹកដោះខាប់ ក៏យ៉ាងនោះ ៗ

## អធិប្បាយវិធីបដិបត្តិក្នុងការទទួលប្រគេនភេសជ្ជៈផ្សេងៗ

ពីរបទថា សន្និធិការកំ បរិភុញ្ជិតព្វានិ : គួរទុកឆាន់បាន មានសេចក្តីថា គប្បីធ្វើការសន្សំ គឺ រក្សាទុកបរិភោគ ៗ យ៉ាងណា ? គឺ បណ្តាភេសជ្ជៈមានទឹកដោះថ្លាជាដើម ដែលមកក្នុងព្រះបាលី នឹងពោលដល់ទឹកដោះថ្លាមុន ដែលភិក្ខុទទួលប្រគេនមុនឆាន់ គួរនឹងឆាន់លាយអាមិសក៏បាន ប្រាសចាកអាមិសក៏បាន ក្នុងវេលាមុនភត្តក្នុងថ្ងៃនោះ ៗ តាំងពីខាងក្រោយភត្តទៅ គប្បីឆាន់ប្រាសចាកអាមិសបានរហូត

ដល់អស់ ៧ ថ្ងៃ ។ សូម្បីព្រោះកន្លង ៧ ថ្ងៃទៅ បើភិក្ខុរក្សាទុកក្នុងភាជនៈតែមួយ ជានិស្សគ្គិយតែមួយ ។ បើរក្សាទុកក្នុងភាជនៈច្រើន ជានិស្សគ្គិយច្រើន តាមចំនួនវត្ថុ ។

ទឹកដោះថ្លាដែលភិក្ខុទទួលប្រគេនខាងក្រោយភត្ត គួរឆាន់ បានមិនលាយអាមិសឡើយរហូតដល់អស់ ៧ ថ្ងៃ ។ ភិក្ខុនឹងផឹកទឹកដោះថ្លាដែលខ្លួនធ្វើឱ្យជាឧគ្គហិតក៏ រក្សាទុកក្នុងវេលាមុនភត្ត ឬក្រោយភត្តរមែងមិនគួរ ។ គប្បីបង្អោនទៅប្រើក្នុងកិច្ចដទៃ មានការប្រើលាបជាដើម ។ សូម្បីព្រោះកន្លង ៧ ថ្ងៃទៅ ក៏មិនមានអាបត្តិ ព្រោះដល់ភាពជារបស់មិនគួរផឹក ។ សមពិត ដូចដែលត្រាស់ទុកថា "ជារបស់គប្បីឆាន់បាន" ។

បើអនុបសម្បន្នធ្វើទឹកដោះថ្លាដោយទឹកដោះខាប់ដែលទទួលប្រគេនទុកក្នុងវេលាមុនភត្តប្រគេន, នឹងឆាន់ជាមួយនឹងអាមិសក្នុងវេលាមុនភត្ត គួរ ។ បើភិក្ខុធ្វើដោយខ្លួនឯង, ឆាន់មិនលាយអាមិសឡើយរមែងគួរសូម្បីរហូតដល់អស់ ៧ ថ្ងៃ ។ តែទឹកដោះថ្លាដែលបុគ្គលណាម្នាក់ ធ្វើដោយទឹកដោះខាប់ដែលទទួលប្រគេនក្នុងវេលាក្រោយភត្ត គួរឆាន់បានមិនលាយអាមិសរហូតដល់អស់ ៧ ថ្ងៃ ដូចគ្នា ។

# អធិប្បាយវិធីបដិបត្តិក្នុងទឹកដោះថ្លានិងទឹកដោះខាប់

[១៤១] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងទឹកដោះថ្លា ដែលធ្វើដោយទឹកដោះខាប់ (ដែលភិក្ខុធ្វើឱ្យ)ជាឧគ្គហិតក៍ ដោយន័យនៃទឹកដោះថ្លាសុទ្ធ ៗ ដូចដែលពោលហើយមុននោះឯង ។ ទឹកដោះថ្លាធ្វើដោយទឹកដោះស្រស់ ដែលភិក្ខុទទួលប្រគេនទុកមុនឆាន់ក្ដី ដោយទឹកដោះជូរក្ដី ដែលអនុបសម្បន្នធ្វើ គួរឆាន់បាន សូម្បីលាយអាមិស ក្នុងវេលាមុនភត្តក្នុងថ្ងៃនោះ ។ ភិក្ខុធ្វើខ្លួនឯង គួរឆាន់ប្រាសចាកអាមិសតែម្យ៉ាង, ខាងក្រោយភត្ត មិនគួរ ។

ពិតមែន កាលភិក្ខុចម្អិនទឹកដោះខាប់ មិនចាត់ជាសាមបក្កៈ ។ តែឆាន់អាមិសលាយដោយទឹកដោះខាប់នោះ ដែលជាសាមបក្កៈ រមែងមិនគួរ ។ តាំងពីខាងក្រោយភត្តទៅ ក៏មិនគួរដូចគ្នា ។ មិនត្រូវអាបត្តិសូម្បីព្រោះកន្លង ៧ ថ្ងៃទៅ ព្រោះទទួលប្រគេនទាំងវត្ថុ ។ សមពិត ដូចទ្រង់ត្រាស់ទុកថា "ទទួលប្រគេនភេសជ្ជៈទាំងនោះ ហើយជាដើម", តែទឹកដោះថ្លាដែលធ្វើដោយទឹកដោះស្រស់ និងទឹកដោះជូរដែលភិក្ខុទទួលប្រគេនក្នុងពេលក្រោយភត្ត គួរបង្អោនទៅប្រើក្នុងកិច្ចមានការលាបខ្លួនជាដើម ។ ទឹកដោះថ្លាដែលធ្វើដោយទឹកដោះស្រស់ ទឹកដោះជូរដែលជាឧគ្គហិតសូម្បីក្នុងវេលាមុនភត្ត (ក៏គួរបង្អោនចូលទៅប្រើក្នុងកិច្ច មានការលាប

ខ្លួនជាដើម ) ។ មិនមានអាបត្តិសូម្បីព្រោះទឹកដោះថ្លាទាំងពីរយ៉ាងកន្លង ៧ ថ្ងៃទៅ ។ ក្នុងទឹកដោះថ្លារបស់ពួកសត្វ ដែលមានសាច់ ជាអកប្បិយ ក៏មានន័យយ៉ាងនេះដែរ ។ តែមានសេចក្តីប្លែកគ្នា ដូចតទៅនេះ ៖

ជានិស្សគ្គិយ ដោយទឹកដោះខាប់ និងទឹកដោះថ្លាដែលមកហើយក្នុងព្រះបាលីណា, ក្នុងព្រះបាលីនោះ ត្រូវអាបត្តិទុក្កដដោយទឹកដោះថ្លារបស់ពួកសត្វដែលមានសាច់ជាអកប្បិយនេះ ។ ក្នុងអដ្ឋកថាអន្ធកៈលោកជំទាស់ទឹកដោះថ្លា និងទឹកដោះខាប់របស់មនុស្សទុកធ្វើឱ្យសមគួរដល់ហេតុ ។ ទឹកដោះថ្លា និងទឹកដោះខាប់របស់មនុស្សនោះ លោកជំទាស់ទុកមិនប្រពៃ ព្រោះអាចារ្យទាំងឡាយអនុញ្ញាតទុកក្នុងអដ្ឋកថាទាំងពួង ។ និងសូម្បីការវិនិច្ឆ័យទឹកដោះថ្លា និងទឹកដោះខាប់របស់មនុស្សនោះ នឹងមកខាងមុខ ។ សូម្បីទឹកដោះ ខាប់ដែលមកហើយក្នុងព្រះបាលី ភិក្ខុទទួលប្រគេន ក្នុងវេលាមុនឆាន់ សូម្បីឆាន់លាយ អាមិសក្នុងវេលាមុនឆាន់ក្នុងថ្ងៃនោះ គួរ, តាំងពីខាងក្រោយភត្តទៅ មិនលាយអាមិស ទើបគួរ ។ ព្រោះកន្លង ៧ ថ្ងៃទៅ ក្នុងទឹកដោះខាប់ ដែលរក្សាទុក ក្នុងភាជនៈផ្សេងគ្នា ជានិស្សគ្គិយ តាមចំនួនភាជនៈ, ក្នុងទឹកដោះខាប់ដែលរក្សាទុកជាដុំ ៗ មិនលាយគ្នា សូម្បីក្នុងភាជនៈ តែមួយ ក៏ជានិស្សគ្គិយតាមចំនួនដុំ ។ ទឹកដោះខាប់ដែលភិក្ខុទទួលប្រគេនទុក ក្នុងវេលាខាងក្រោយឆាន់ អ្នកសិក្សាគប្បីជ្រាបដោយន័យនៃទឹកដោះថ្លាដូចគ្នា ។

ចំណែកសេចក្ដីប្លែកគ្នាក្នុងទឹកដោះខាប់នេះ មានដូច្នេះ ៖

ដុំទឹកដោះជូរខ្លះ តំណក់ប្រេងទឹកដោះខ្លះ មាន, ព្រោះដូច្នោះ ពួកព្រះថេរៈចំនួនពាក់កណ្ដាល ទើបបានពោលថា "ដែលសំអាតហើយទើងគួរ" ។ ចំណែកព្រះមហាសីវត្ថេរៈពោលថា តាំងពីវេលាដែលព្រះមានព្រះភាគ ទ្រង់អនុញ្ញាតហើយ ទឹកដោះខាប់ ល្មមលើកឡើងអំពីកាកប្រេងទឹកដោះប៉ុណ្ណោះ ភិក្ខុទាំងឡាយឆាន់បាន ។ ព្រោះហេតុនោះ ភិក្ខុនឹងឆាន់ទឹកដោះខាប់ គប្បីជម្រះ គឺ ជួសយកទឹកដោះជូរ កាកប្រេងទឹកដោះ រុយ និងស្រមោចក្រហមជាដើមចេញហើយ ឆាន់ចុះ ។ ភិក្ខុប្រាថ្នានឹងចម្រាញ់ឱ្យជាទឹកដោះថ្លាឆាន់ នឹងចម្រាញ់ សូម្បីទឹកដោះខាប់ដែលនៅមិនសំអាត ក៏គួរ ។ ទឹកដោះខាប់នោះ វត្ថុណាដែលជាទឹកដោះជូរក្ដី ដែលជាកាកប្រេងទឹកដោះក្ដី វត្ថុនោះនឹងដល់ការអស់ទៅ ។ ក៏ដោយហេតុត្រឹមតែប៉ុណ្ណោះ មិនឈ្មោះថា ទទួលប្រគេនព្រមទាំងវត្ថុ អធិប្បាយដូចពោលមកនេះ ជាអធិប្បាយក្នុងពាក្យរបស់ព្រះមហាសីវត្ថេរនេះ ។ តែភិក្ខុទាំងឡាយអ្នកច្រើនវង្វៀស រមែងវង្វៀសសូម្បីក្នុងទឹកដោះខាប់ដែលចម្រាញ់នោះ ព្រោះការចម្រាញ់ព្រមទាំងអាមិស ។

ឥឡូវនេះ អ្នកសិក្សាគប្បីកាន់យកន័យនៃអាបត្តិ អនាបត្តិ ការបរិភោគ និងមិនបរិភោគ ក្នុងទឹកដោះខាប់ដែលពាល់ត្រូវហើយរក្សាទុកក្នុងទឹកដោះខាប់ដែលភិក្ខុទទួលប្រគេនទឹកដោះស្រស់ និងទឹកដោះជូរមុន

ឆាន់ ហើយធ្វើ ក្នុងទឹកដោះខាប់ដែលភិក្ខុទទួលប្រគេនទឹកដោះស្រស់ ទឹកដោះជូរនោះខាងក្រោយឆាន់ ហើយធ្វើក្នុងទឹកដោះខាប់ដែលធ្វើដោយ ទឹកដោះស្រស់ និងទឹកដោះជូរដែលជាឧគ្គហិត និងក្នុងទឹកដោះខាប់របស់ ពួកសត្វ ដែលមានសាច់ជាអកប្បិយទាំងអស់ ដោយលំដាប់ដូចពោល ហើយក្នុងទឹកដោះថ្លានុ៎ះឯង ។ ពួកអ្នកស្រុក រមែងចាក់នូវទឹកដោះថ្លាខ្លះ ទឹកដោះខាប់ខ្លះ ប្រេងដែលចម្រាញ់ហើយខ្លះ ប្រេងដែលនៅមិនបាន ចម្រាញ់ខ្លះ ចុះក្នុងទឹកដោះថ្លានោះនុ៎ះឯង របស់ភិក្ខុទាំងឡាយដែលចូល ទៅដើម្បីសូមប្រេង ។ តំណក់ប្រេងទឹកដោះខាញ់ និងទឹកដោះជូរខ្លះ គ្រាប់បាយខ្លះ កន្ទក់ខ្លះ ពួករុយជាដើមខ្លះ មាននៅក្នុងទឹកដោះថ្លានោះ ។ ទឹកដោះថ្លានោះ ភិក្ខុធ្វើឱ្យឆ្អិន ដោយកម្តៅថ្ងៃហើយត្រងយកទុក ចាត់ជា សត្តាហកាលិក ។

ក៏កាលភិក្ខុនឹងរម្ងាស់ជាមួយភេសជ្ជៈ ដែលទទួលប្រគេនទុក ហើយ ធ្វើការនត្ថុបានៈ(ចូលតាមច្រមុះ) គួរ ។ បើក្នុងសម័យ រាំងភ្លៀង សាមណេរលជ្ជី កាលដោះការចម្អិនអាមិសឱ្យរួចផុតទៅ ដូច ពួកភិក្ខុមិនចម្អិនអង្ករ និងកន្ទក់ជាដើម ដែលធ្លាក់ចុះទៅក្នុងទឹកដោះថ្លា នោះ ធ្វើឱ្យរលាយលើភ្លើង ហើយត្រងទុក ចម្រាញ់ប្រគេនថ្មី រមែងគួរ រហូតដល់អស់ ៧ ថ្ងៃ ដោយន័យមុនដូចគ្នា ។

# អធិប្បាយវិធីបដិបត្តិក្នុងភេសជ្ជៈ គឺប្រេង

បណ្តាប្រេងទាំងឡាយ នឹងពោលដល់ប្រេងល្ងមុន ដែលទទួលប្រគេនមុនភត្ត សូម្បីលាយអាមិស រមែងគួរ ក្នុងវេលាមុនភត្ត ។ តាំងពីខាងក្រោយឆាន់ទៅ ប្រាសចាកអាមិសប៉ុណ្ណោះទើបគួរ ។ អ្នកសិក្សាគប្បីជ្រាបសេចក្តី ដែលប្រេងល្ងនោះ ជានិស្សគ្គិយដោយចំនួនភាជនៈព្រោះកន្លង ៧ ថ្ងៃទៅ ។ ប្រេងល្ងដែលទទួលប្រគេនខាងក្រោយភត្តប្រាសចាកអាមិសប៉ុណ្ណោះ ទើបគួរ រហូតដល់អស់ ៧ ថ្ងៃ ។ នឹងឆាន់ប្រេងល្ងដែលធ្វើឱ្យជាឧគ្គហិត រក្សាទុក មិនគួរផឹក ។ គួរបង្អោនចូលទៅក្នុងកិច្ចមានការលាបសីសៈជាដើម ។ សូម្បីព្រោះកន្លង ៧ ថ្ងៃទៅក៏មិនមានអាបត្តិ ។ ប្រេងដែលភិក្ខុទទួលប្រគេនគ្រាប់ល្ង ក្នុងបុរេភត្តធ្វើលាយអាមិស រមែងគួរក្នុងបុរេភត្ត ។ តាំងពីបច្ឆាភត្តទៅជារបស់មិនគួរឆាន់ ។ គប្បីបង្អោនទៅក្នុងកិច្ចមានការលាបសីសៈជាដើម ។ សូម្បីក្នុងកាលកន្លង ៧ ថ្ងៃទៅ ក៏មិនមានអាបត្តិ ។ ប្រេងដែលភិក្ខុទទួលប្រគេនគ្រាប់ល្ង ក្នុងបច្ឆាភត្តហើយធ្វើជារបស់មិនគួរឆាន់ដូចគ្នា ព្រោះទទួលប្រគេនទាំងវត្ថុ ។ សូម្បីក្នុងកាលកន្លង ៧ ថ្ងៃទៅ ក៏មិនមានអាបត្តិ ។ គប្បីបង្អោនចូលទៅក្នុងកិច្ច មានការលាបសីសៈជាដើម ។ សូម្បីប្រេងដែលធ្វើដោយគ្រាប់ល្ង ដែលភិក្ខុពាល់ត្រូវក្នុងបុរេភត្ត ឬ ក្នុងបច្ឆាភត្តក៏មានន័យយ៉ាងនេះដូចគ្នា ។

ប្រេងដែលលីងគ្រាប់ល្ង ដែលភិក្ខុទទួលប្រគេនក្នុងបុរេភត្តហើយ ចំហុយមេ្សៅល្ងឬឱ្យជោគដោយទឹកក្តៅធ្វើ, បើអនុបសម្បន្នធ្វើសូម្បីលាយអាមិស រមែងគួរក្នុងបុរេភត្ត ។ ដែលធ្វើខ្លួនឯង ព្រោះបន្ទេចវត្ថុចេញហើយមិនមានអាមិស ទើបគួរក្នុងបុរេភត្ត ។ ព្រោះជាប្រេងដែលចម្រាញ់ខ្លួនឯង លាយអាមិសទើបមិនគួរ ។ ក៏ព្រោះជារបស់ដែលទទួលប្រគេនព្រមទាំងវត្ថុ សូម្បីទាំងពីរយ៉ាង ទើបមិនគួរឆាន់ ចាប់ផ្តើមតាំងពីបច្ឆាភត្តទៅ គប្បីបង្អោនចូលទៅក្នុងការលាបសីសៈជាដើម ។ សូម្បីក្នុងកាលកន្លង ៧ ថ្ងៃទៅ ក៏មិនមានអាបត្តិ, តែបើថា ទឹកក្តៅមានតិច, ទឹកនោះត្រឹមតែប្រោសព្រំប៉ុណ្ណោះ ជាអព្វោហារិក រមែងមិនដល់ការរាប់ថាជាសាមបក្កៈ ។ សូម្បីក្នុងប្រេងគ្រាប់ស្ពៃជាដើម ដែលភិក្ខុទទួលប្រគេនព្រមទាំងវត្ថុ ក៏មានវិនិច្ឆ័យដូចដែលពោលហើយក្នុងប្រេងល្ងដែលមិនមានវត្ថុនុ៎ះឯង ។

ក៏បើថា ភិក្ខុអាចដើម្បីធ្វើប្រេងអំពីលំអិតនៃគ្រាប់ស្ពៃជាដើមដែលទទួលប្រគេនទុកក្នុងបុរេភត្ត ចម្រាញ់ដោយកម្តៅថ្ងៃ, ប្រេងនោះសូម្បីលាយដោយអាមិស រមែងគួរក្នុងបុរេភត្ត ។ តាំងពីបច្ឆាភត្តទៅមិនលាយអាមិស ទើបគួរ ។ ក្នុងកាលកន្លង ៧ ថ្ងៃទៅ ជានិស្សគ្គិយ ។ មួយទៀត ព្រោះភិក្ខុទាំងឡាយ ចំហុយលំអិតគ្រាប់ស្ពៃ និងស្រគំជាដើម និងលីងគ្រាប់ល្ហុងហើយធ្វើប្រេងយ៉ាង នេះ; ដូច្នោះ ប្រេងរបស់ភិក្ខុទាំង

ឡាយនោះ ដែលពួកអនុបសម្បន្នធ្វើ សូម្បីលាយអាមិស ក៏គួរក្នុងវេលាមុនភត្ត ។ ក៏ព្រោះវត្ថុជាយាវជីវិក ទើបមិនមានទោស ។ ក្នុងការទទួលប្រគេន ព្រមទាំងវត្ថុដូច្នេះឯង ។ ប្រេងគ្រាប់ស្ពៃជាដើម ដែលធ្វើខ្លួនឯងគប្បីបរិភោគដោយការបរិភោគប្រាសចាកអាមិសតែម្យ៉ាង រហូតដល់អស់ ៧ ថ្ងៃ ។ ប្រេងដែលធ្វើដោយគ្រាប់ស្ពៃជាដើម ដែលជាឧគ្គហិត មិនគួរឆាន់ គួរក្នុងការប្រើប្រាស់ខាងក្រៅ ។ សូម្បីកាលកន្លង ៧ ថ្ងៃទៅ ក៏មិនមានអាបត្តិ ។

ប្រេងដែលភិក្ខុទទួលប្រគេនគ្រាប់ស្ពៃ ស្រគំ និងគ្រាប់ល្ហុងដើម្បីត្រូវការទឹងធ្វើប្រេង ហើយធ្វើក្នុងថ្ងៃនោះឯង ជាសត្តាហកាលិក, ធ្វើក្នុងថ្ងៃទី ២ គួរបរិភោគ បាន ៦ ថ្ងៃ ។ ធ្វើក្នុងថ្ងៃទី ៣ គួរបរិភោគ បាន ៥ ថ្ងៃ ។ តែប្រេងដែលធ្វើក្នុងថ្ងៃទី ៤ គួរ ៤ ថ្ងៃ ... ក្នុងថ្ងៃទី ៥ គួរ ៣ ថ្ងៃ ... ក្នុងថ្ងៃទី ៦ គួរ ២ ថ្ងៃ ... ក្នុងថ្ងៃទី ៧ គួរក្នុងថ្ងៃនោះប៉ុណ្ណោះ ។ បើនៅមានដរាបដល់អរុណរះឡើង ជានិស្សគ្គិយ ។ ដែលធ្វើក្នុងថ្ងៃទី ៨ មិនគួរឆាន់ឡើយ, តែគួរក្នុងការប្រើប្រាស់ខាងក្រៅ ព្រោះជារបស់មិនទាន់លះបង់ចេញ ។ សូម្បីបើថា មិនធ្វើ, ក្នុងកាលគ្រាប់ស្ពៃដែលខ្លួនទទួលទុក ដើម្បីប្រយោជន៍ដល់ប្រេងជាដើម កន្លង ៧ ថ្ងៃទៅ ក៏ត្រូវអាបត្តិទុក្កដតែម្យ៉ាង ។

មួយទៀត ប្រេងរបស់ផ្លែឈើ មានដូង គ្រាប់ស្មៅ ពង្រ

ក្រញាំខ្វែង និងសំរោងជាដើម សូម្បីពួកដទៃដែលមិនបានមកក្នុងព្រះបាលី ក៏នៅមាន ។ កាលភិក្ខុទទួលប្រគេនប្រេងទាំងនោះ ហើយឱ្យកន្លង ៧ ថ្ងៃទៅត្រូវអាបត្តិទុក្កដ ។

ក្នុងប្រេងជូងជាដើមទាំងនេះ មានសេចក្ដីប្លែកគ្នា ដូច្នេះ ៖

គប្បីកំណត់វត្ថុនៃយាវកាលិក និងវត្ថុនៃយាវជីវិកដ៏សេស ហើយជ្រាបវិធីការនៃសាមបក្កៈ (ឱ្យឆ្អិនខ្លួនឯង) សវត្ថុក (របស់ដែលទទួលទាំងវត្ថុ) របស់ដែលទទួលប្រគេនក្នុងបុរេភត្ត ទទួលប្រគេនក្នុងបច្ឆាភត្ត និងឧគ្គហិតវត្ថុ (វត្ថុដែលនៅមិនបានទទួលប្រគេនភិក្ខុពាល់ត្រូវ) ទាំងអស់ តាមន័យដូចពោលហើយនុ៎ះឯង ។

## អធិប្បាយប្រេងធ្វើអំពីខ្លាញ់សត្វផ្សេងៗ

បទថា វសាតេលំ : ប្រេងធ្វើពីខ្លាញ់ បានដល់ ប្រេងនៃខ្លាញ់សត្វដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកយ៉ាងនេះថា "អនុជានាមិ ភិក្ខវេ វសានិ ភេសជ្ជានិ អច្ឆវសំ មច្ឆវសំ សុសុការវសំ សូករវសំ គទ្រភវស : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្លាញ់ជាភេសជ្ជៈ គឺ ខ្លាញ់ខ្លាឃ្មុំ ខ្លាញ់ត្រី ខ្លាញ់ក្រពើ ខ្លាញ់ជ្រូក ខ្លាញ់លា"[១] ក៏បណ្ដាខ្លាញ់ ៥

១. វិន. មហា. ភេសជ្ជក្ខន្ធកៈ. ៧. ៧៥/២២៥ ។

ប្រភេទនេះ ដោយពាក្យថា ខាញ់ខ្លាឃ្មុំ ព្រះមានព្រះភាគទ្រង់អនុញ្ញាតខាញ់នៃសត្វ ដែលមានសាច់ជាអកប្បិយទាំងអស់ វៀរខាញ់នៃមនុស្សចេញ ។ មួយទៀត សូម្បីត្រីឆ្លាម ក៏ព្រះអង្គទ្រង់កាន់យកហើយ ដោយស័ព្ទថា ត្រី ។ តែព្រោះត្រីឆ្លាមជាត្រីកាច ព្រះអង្គទើបត្រាស់លើកទុកផ្សេង ។ ក្នុងបាលីនេះ ព្រះអង្គទ្រង់អនុញ្ញាតខាញ់នៃពួកសត្វ មានសាច់ជាកប្បិយ សូម្បីគ្រប់ប្រភេទ ដោយស័ព្ទថា ត្រីជាដើម ។

ពិតមែន ក្នុងបណ្ដាសាច់ទាំងឡាយ សាច់របស់មនុស្ស, ដំរី, សេះ, សុនខ, ពស់, សីហៈ, ខ្លាធំ, ខ្លាដំបង, ខ្លាឃ្មុំ, ខ្លារខិន; ១០ ប្រភេទ ជាអកប្បិយ ។ បណ្ដាខាញ់ទាំងឡាយ ខាញ់របស់មនុស្សតែម្យ៉ាង ជាអកប្បិយ ។ បណ្ដាអវយវៈយ៉ាងដទៃ មានទឹកដោះជាដើម ឈ្មោះថា ជាអកប្បិយមិនមាន ។ ប្រេង ខាញ់ ដែលពួកអនុបសម្បន្នធ្វើនិងត្រងហើយ ភិក្ខុទទួលប្រគេនមុនភត្ត សូម្បីលាយអាមិស ក៏គួរមុនភត្ត ។ តាំងពីក្រោយភត្តទៅ មិនលាយអាមិស ទើបគួររហូតដល់អស់ ៧ ថ្ងៃ ។ វត្ថុណាដែលប្រាកដដូចធូលីល្អិត ជាសាច់ក្ដី សសៃក្ដី ឆ្អឹងក្ដី ឈាមក្ដី លាយក្នុងខាញ់ ដូច្នោះ វត្ថុនោះចាត់ជាអព្វោហារិក ។

ក៏បើថា ភិក្ខុទទួលប្រគេនខាញ់ធ្វើប្រេងខ្លួនឯង ទទួលប្រគេនហើយចម្រាញ់ ត្រងស្រេចក្នុងបុរេភត្ត គប្បីបរិភោគ ដោយប្រាសចាកអាមិសរហូត ៧ ថ្ងៃ ។ ពិតមែន ព្រះមានព្រះភាគ ទ្រង់សំដៅដល់ការ

បរិភោគប្រាសចាកអាមិស ទើបត្រាស់ពាក្យនេះថា “ដែលភិក្ខុទទួលក្នុងកាលគួរ ចម្អិនក្នុងកាលគួរ លាយគ្នាក្នុងកាលគួរ សម្រាប់ឱ្យភិក្ខុប្រើប្រាស់ដោយវិធីប្រើប្រាស់ដូចប្រេង (ជាសត្តាហកាលិក) បាន”[១] ។ សាច់ដែលល្អិតជាដើមស្ងួន្យក្នុងប្រេង ដែលទទួលប្រគេនខាញ់ហើយចម្អិនលាយនោះ ក៏ជាអញ្ញោហារិកដូចគ្នា ។ តែនឹងទទួលប្រគេន ឬចម្អិនក្នុងបច្ឆាភត្ត មិនគួរឡើយ ។

សមពិត ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ បើខាញ់ដែលភិក្ខុបានទទួលក្នុងកាលមិនគួរ ចម្អិនក្នុងកាលមិនគួរ លាយគ្នាក្នុងកាលមិនគួរ បើភិក្ខុបរិភោគខាញ់នោះ ត្រូវអាបត្តិទុក្កដបី ។ ម្នាលភិក្ខុទាំងឡាយ បើខាញ់ដែលភិក្ខុទទួលក្នុងកាលគួរ តែចម្អិនក្នុងកាលមិនគួរ លាយគ្នាក្នុងកាលមិនគួរ បើភិក្ខុបរិភោគខាញ់នោះ ត្រូវអាបត្តិទុក្កដពីរ ។ ម្នាលភិក្ខុទាំងឡាយ បើខាញ់ដែលភិក្ខុទទួលក្នុងកាលគួរ ចម្អិនក្នុងកាលគួរ តែលាយគ្នាក្នុងកាលមិនគួរ បើភិក្ខុបរិភោគខាញ់នោះ ត្រូវអាបត្តិទុក្កដមួយ ។ ម្នាលភិក្ខុទាំងឡាយ បើខាញ់ដែលភិក្ខុទទួលក្នុងកាលគួរ ចម្អិនក្នុងកាលគួរ លាយគ្នាក្នុងកាលគួរ បើភិក្ខុបរិភោគខាញ់នោះ មិនត្រូវអាបត្តិឡើយ”[២] ដូច្នេះ ។

---

១.២. វិន. មហា. ភេសជ្ជក្ខន្ធកៈ. ៧. ៧៥/២២៦ ។

តែពួកអន្តេវាសិក សួរព្រះឧបតិស្សត្ថេរថា “លោកម្ចាស់ ទឹកដោះថ្លា ទឹកដោះខាប់ និងខ្លាញ់ ដែលភិក្ខុចម្រាញ់រួមគ្នា ហើយស្រង់កាកចេញ គួរឬមិនគួរ” ។

ព្រះថេរៈឆ្លើយថា “មិនគួរ អាវុសោ” បានពួថា ព្រះថេរៈវង្វៀសក្នុងទឹកដោះថ្លា ទឹកដោះខាប់ ខ្លាញ់ ដែលភិក្ខុចម្រាញ់រួមគ្នាហើយ ស្រង់ចេញនេះ ដូចក្នុងកាកប្រេងល្ង ដែលចម្រាញ់ហើយ ។

ខាងក្រោយពួកអន្តេវាសិក សួរលោកធ្ងន់ឡើងថា “លោកម្ចាស់ ដុំទឹកដោះជូរក្តី កាកក្តី មាននៅក្នុងទឹកដោះខាប់, ទឹកដោះខាប់នោះ គួរទេ ?”

ព្រះថេរៈឆ្លើយថា “អ្នកមានអាយុ សូម្បីទឹកដោះខាប់នោះ ក៏មិនគួរ” ។ លំដាប់នោះ ពួកអន្តេវាសិកទើបសួរលោកថា “លោកម្ចាស់ ប្រេងដែលចម្រាញ់រួមគ្នាត្រង់ហើយ មានការក្តៅខ្លាំង រមែងបំបាត់រោគបាន ។ ព្រះថេរៈព្រមទទួលថា “ល្អណាស់ អាវុសោ” ដូច្នេះ ។

តែព្រះមហាសុមត្ថេរៈពោលទុកថា ខ្លាញ់របស់សត្វដែលមានសាច់ជាកប្បិយ រមែងគួរក្នុងការបរិភោគលាយអាមិស, ខ្លាញ់របស់ពួកសត្វដែលមានសាច់ជាអកប្បិយក្រៅនេះ គួរក្នុងការបរិភោគប្រាសចាកអាមិស ។

ចំណែកព្រះមហាបទុមត្ថេរៈបដិសេធថា នេះអ្វី ? ហើយពោលថា

ពួកភិក្ខុអាពាធដោយរោគខ្យល់ ថែមខាញ់ខាឃ្មុំ និងជ្រុកជាដើមចុះ ក្នុងយាគូដែលដាំដោយទឹកចត់ឫសឈើ ៥ ប្រភេទ ហើយឆាន់បបរយាគូ, យាគូនោះបំបាត់រោគបាន ព្រោះមានការក្តៅខ្លាំង” ដូច្នេះ ទើបពោលថា សមគួរ ។

## អធិប្បាយភេសជ្ជៈទឹកឃ្មុំ

ពីរបទថា មធុ នាម មក្ខិកាមធុ : **ទឹកផ្អែមកើតពីមេឃ្មុំជាដើម ឈ្មោះថា ទឹកឃ្មុំ** បានដល់ ទឹកផ្អែមដែលពួកមេឃ្មុំធំ ឃ្មុំតូច និងពួកមេពង្រួត ដែលមានឈ្មោះថា សត្តុល្លិតធ្វើទឹកផ្អែម ( ទឹកឃ្មុំ ) ធ្វើហើយ ។ ទឹកឃ្មុំនោះ ភិក្ខុទទួលប្រគេនមុនឆាន់ សូម្បីទីងបរិភោគលាយអាមិសក្នុងបុរេភត្ត ក៏គួរ ។ តាំងពីបច្ឆាភត្តទៅ គួរបរិភោគប្រាសចាកអាមិសតែម្យ៉ាង រហូតដល់អស់ ៧ ថ្ងៃ ក្នុងកាលកន្លង ៧ ថ្ងៃទៅ បើទឹកឃ្មុំច្រើនដូចជាជ័រ ( រម្ញាស់ឱ្យខាប់ ) ធ្វើជាកំណាត់តូច កំណាត់ធំរក្សាទុក ឬទឹកឃ្មុំប្រភេទខ្លះ ក្រៅនេះរក្សាទុកក្នុងភាជនៈផ្សេង ៗគ្នា ជានិស្សគ្គិយច្រើនតាមចំនួនវត្ថុ ។ បើមានត្រឹមតែមួយដុំប៉ុណ្ណោះ ឬទឹកឃ្មុំខ្លះក្រៅនេះ ក៏រក្សារួមទុកក្នុងភាជនៈ តែមួយ ជានិស្សគ្គិយត្រឹមតែមួយ ។ ទឹកឃ្មុំដែលជាឧគ្គហិត គប្បីជ្រាបតាមន័យដែលពោលហើយនុ៎ះឯង ។ គប្បីបង្អោនចូលទៅ ក្នុងកិច្ចដទៃមានលាបដំបៅជាដើម ។

ផិតឃ្មុំ ឬក្រមួនឃ្មុំ បើទឹកឃ្មុំមិនជាប់ បរិសុទ្ធិ ជាយាវជីវិក ។ តែដែលមានទឹកឃ្មុំនៅជាប់ មានគតិដូចទឹកឃ្មុំដូចគ្នា ។ មេឃ្មុំខ្នងវែងមានស្លាប ឈ្មោះថា ចិរិកា, ពង្រួតធំ ខ្នងខ្មៅ មានស្លាបវែង មានឈ្មោះថា តុម្ពលះ ។ ក្នុងសំបុករបស់មេឃ្មុំទាំងនោះ មានទឹកឃ្មុំដូចជ័រ ។ ទឹកឃ្មុំនោះ ជាយាវជីវិក ។

## អធិប្បាយភេសជ្ជៈទឹកអំពៅ

ពាក្យថា ផាណិតំ ណាម ឧច្ឆុម្ហា ណិព្វត្តំ : ទឹកផ្អែមកើតពីអំពៅ ឈ្មោះថា ទឹកអំពៅ មានសេចក្តីថា ស្ករអំពៅដែលនៅមិនបានរម្ងាស់ ឬដែលរម្ងាស់ហើយ មិនមានកាក ឬដែលមិនមានកាកសូម្បីទាំងអស់ រហូតទាំងទឹកអំពៅស្រស់ គប្បីជ្រាបថា ស្ករអំពៅ ។ ស្ករអំពៅនោះដែលភិក្ខុទទួលប្រគេនមុនឆាន់ សូម្បីលាយអាមិស ក៏គួរ ក្នុងបុរេភត្ត ។ តាំងពីបច្ឆាភត្តទៅ មិនលាយអាមិស ទើបគួររហូតដល់អស់ ៧ ថ្ងៃ ។ ក្នុងកាលកន្លង ៧ ថ្ងៃទៅ ជានិស្សគ្គិយតាមចំនួនវត្ថុ ។ ដុំស្ករអំពៅសូម្បីច្រើន ភិក្ខុធ្វើឱ្យតូចហើយ ដាក់ទុកក្នុងភាជនៈជាមួយគ្នា រមែងស្អិតជាប់គ្នាណែន ជានិស្សគ្គិយត្រឹមតែមួយ ។ ស្ករអំពៅដែលជាឧគ្គហិត គប្បីជ្រាបតាមន័យដែលពោលហើយនោះឯង ។ គប្បីបង្អោនចូលទៅក្នុងកិច្ចដទៃមានការអប់ផ្ទះជាដើម ។

ស្ករអំពៅ ដែលគេធ្វើដោយទឹកអំពៅស្រស់ដែលនៅមិនទាន់បានត្រង ដែលភិក្ខុទទួលប្រគេនទុកក្នុងវេលាមុនឆាន់ បើអនុបសម្បន្នធ្វើសូម្បីលាយអាមិស ក៏គួរ ។ បើភិក្ខុធ្វើខ្លួនឯង មិនលាយអាមិស ទើបគួរ ។ ក៏ចាប់ផ្តើមតាំងអំពីបច្ឆាភត្តទៅ មិនគួរឆាន់ ព្រោះជារបស់ទទួលប្រគេនទាំងវត្ថុ ។ សូម្បីក្នុងកាលកន្លង ៧ ថ្ងៃទៅ ក៏មិនមានអាបត្តិ ។ សូម្បីគេធ្វើដោយទឹកអំពៅស្រស់ ដែលភិក្ខុទទួលប្រគេន ទាំងមិនទាន់បានត្រងក្នុងបច្ឆាភត្ត ក៏មិនគួរឆាន់ដូចគ្នា ។ សូម្បីក្នុងកាលកន្លង ៧ ថ្ងៃទៅ ក៏មិនមានអាបត្តិ សូម្បីក្នុងស្ករអំពៅដែលភិក្ខុទទួលប្រគេនដើមអំពៅធ្វើ ក៏មានន័យយ៉ាងនេះ ។

ក៏ស្ករអំពៅដែលធ្វើដោយទឹកអំពៅស្រស់ ដែលត្រង និងទទួលប្រគេនទុកក្នុងកាលមុនឆាន់ បើអនុបសម្បន្នធ្វើ សូម្បីលាយអាមិស ក៏គួរក្នុងបុរេភត្ត ។ តាំងពីបច្ឆាភត្តទៅ មិនលាយអាមិស ទើបគួរហូតដល់អស់ ៧ ថ្ងៃ ។ ដែលធ្វើខ្លួនឯង មិនលាយអាមិស រមែងគួរសូម្បីក្នុងបុរេភត្ត, ចាប់តាំងពីបច្ឆាភត្តទៅមិនលាយអាមិសដូចគ្នា គួរ ហូតដល់អស់ ៧ ថ្ងៃ ។ តែស្ករអំពៅធ្វើដោយទឹកអំពៅស្រស់ ដែលត្រងនិងទទួលប្រគេនហើយក្នុងបច្ឆាភត្ត ប្រាសចាកអាមិសប៉ុណ្ណោះ ទើបគួរហូតដល់អស់ ៧ ថ្ងៃ ។ ស្ករអំពៅដែលជាឧគ្គហិត មានន័យដូចពោលហើយដូចគ្នា ។

ក្នុងមហាអដ្ឋកថាលោកពោលថា ស្ករអំពៅដែលធ្វើដោយទឹកអំពៅដុតក្តី ស្ករអំពៅដែលធ្វើដោយទឹកអំពៅគាបក្តី គួរតែក្នុងបុរេភត្តប៉ុណ្ណោះ ។ ចំណែកក្នុងមហាបច្ចរី លោកតាំងពាក្យ សួរថា ស្ករអំពៅដែលម្ចាស់ទាំងវត្ថុ(កាក) នេះ គួរឬមិនគួរ ? ដូច្នេះ ហើយពោលថា ស្ករអំពៅដែលធ្វើដោយទឹកអំពៅស្រស់ ឈ្មោះថា មិនគួរក្នុងបច្ឆាភត្តរមែងមិនមាន ។ ពាក្យនោះ ត្រូវហើយ ។

ស្ករអំពៅផ្កាស្រគំដែលគេធ្វើដោយទឹកត្រជាក់ សូម្បីលាយអាមិស ក៏គួរក្នុងបុរេភត្ត ។ ចាប់ផ្តើមតាំងពីបច្ឆាភត្តទៅ មិនលាយអាមិសទើបគួរហូតដល់អស់ ៧ ថ្ងៃ ។ ក្នុងកាលកន្លង ៧ ថ្ងៃទៅ ត្រូវអាបត្តិទុក្កដតាមចំនួនវត្ថុ ។ ចំណែកស្ករអំពៅ ស្រគំដែលគេថែមទឹកដោះស្រស់ធ្វើ ជាយាវកាលិក ។ តែជនទាំងឡាយ ដូសពពុះទឹកដោះស្រស់ចេញហើយ ជម្រះខណ្ឌសក្ករគឺដុំស្ករឱ្យស្អាត; ព្រោះដូច្នោះ ខណ្ឌសក្ករនោះ ក៏គួរ ។

ចំណែកផ្កាស្រគំស្រស់ រមែងគួរសូម្បីក្នុងបុរេភត្ត លីងហើយក៏គួរ, លីងហើយបុកផ្សំដោយរបស់ដទៃ មានគ្រាប់ល្ងជាដើម ឬមិនផ្សំក៏គួរ ។

តែបើថា ជនទាំងឡាយកាន់យកស្រគំនោះ លាយចូលគ្នា (ផ្សំ)

ដើម្បីត្រូវការ មេរ័យ, ផ្កាស្រគំដែលផ្សំហើយនោះ រមែងមិនគួរតាំងពីពូជ ។ ស្ករអំពៅនៃផ្លែឈើដែលជាយាវកាលិកទាំងអស់ មានបេក ផ្លែខជ្ជូរី ស្វាយ ខ្នុរ សម្ពរ ខ្នុរណាំង និងអំពិលជាដើម ជាយាវកាលិកដូចគ្នា ។ ជនទាំងឡាយធ្វើស្ករអំពៅដោយម្ទេសទុំ, ស្ករអំពៅនោះ ជាយាវជីវិក ។

ពីរបទថា តានិ បដិគ្គហេត្វា : ភិក្ខុទទួលភេសជ្ជៈនោះ មានសេចក្តីថា បើភិក្ខុទទួលប្រគេនភេសជ្ជៈ ៥ យ៉ាង មានទឹកដោះថ្លាជាដើម សូម្បីទាំងអស់ រក្សាទុកមិនញែកគ្នាក្នុងឆ្នាំងតែមួយ កាលកន្លង ៧ ថ្ងៃទៅហើយ ជានិស្សគ្គិយត្រឹមតែមួយ, កាលរក្សាផ្សេងគ្នា ជានិស្សគ្គិយ ៥ ។ ភេសជ្ជៈ ៥ នេះ នៅមិនទាន់កន្លង ៧ ថ្ងៃ ភិក្ខុដែលអាពាធក្តី មិនអាពាធក្តី គួរបរិភោគ តាមសប្បាយដោយន័យដូចពោលហើយ ។

## អធិប្បាយខដែលទ្រង់អនុញ្ញាតទុកចំពោះ ៧ យ៉ាង

ក៏ខដែលឈ្មោះថា ទ្រង់អនុញ្ញាតចំពោះ មាន ៧ យ៉ាង គឺ អនុញ្ញាតចំពោះអាពាធ ១ ចំពោះបុគ្គល ១ ចំពោះកាល ១ ចំពោះសម័យ ១ ចំពោះប្រទេស ១ ចំពោះខ្លាញ់ ១ ចំពោះភេសជ្ជៈ ១ ។

បណ្តាអនុញ្ញាតចំពោះ ៧ យ៉ាងនោះ ដែលឈ្មោះថា ទ្រង់អនុញ្ញាតចំពោះអាពាធ បានដល់ ខដែលទ្រង់អនុញ្ញាតចំពោះអាពាធយ៉ាង

នេះថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសាច់ឆៅ ឈាមស្រស់ដល់ភិក្ខុដែលមានអាពាធកើតអំពីអមនុស្ស”[១] ។ សាច់ឆៅនិងឈាមស្រស់នោះ គួរដល់ភិក្ខុដែលអាពាធដោយអាពាធនោះតែម្យ៉ាង មិនគួរដល់ភិក្ខុដទៃ ។ ក៏ឯសាច់ស្រស់និងឈាមស្រស់នោះជាកប្បិយក្តី ជាអកប្បិយក្តី រមែងគួរទាំងអស់ ទាំងក្នុងកាលទាំងក្នុងវិកាល ។

ដែលឈ្មោះថា ទ្រង់អនុញ្ញាតចំពោះបុគ្គល បានដល់ សេចក្តីដែលទ្រង់អនុញ្ញាតចំពោះបុគ្គលយ៉ាងនេះថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការ ទំពារអៀងដល់ភិក្ខុអ្នកទំពារអៀងជាប្រក្រតី, ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែភិក្ខុកុំខ្ទាក់អាហារចេញមកខាងក្រៅទ្វារមាត់ ហើយលេបចូលទៅវិញ”[២] ។ ការទំពារអៀងនោះ គួរដល់ភិក្ខុដែលច្រើនទំពារអៀងនោះប៉ុណ្ណោះ មិនគួរដល់ភិក្ខុដទៃ ។

ដែលឈ្មោះថា ទ្រង់អនុញ្ញាតចំពោះកាល បានដល់ សេចក្តីដែលទ្រង់អនុញ្ញាតចំពោះកាលដែលភិក្ខុត្រូវពស់ចិកយ៉ាងនេះថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុឱ្យថ្នាំមហាវិកដ ៤ យ៉ាង គឺគូថ ( អាចម៍ ) ១ ទឹកមូត្រ ( ទឹកនោម )១ ផេះ១ ដី ១”[៣] ។ ថ្នាំមហាវិកដនោះ ចំពោះ

---

១. វិន. មហា. ភេសជ្ជក្ខន្ធកៈ ៧. ៨៤/២៣២ ។ ២. វិន. ចុល្ល. ខុទ្ទកវត្ថុក្ខន្ធក. ១០. ២៥៤/២១២ ។ ៣. វិន. មហា. ភេសជ្ជក្ខន្ធកៈ. ៧. ៩១/២៤៣ ។

ក្នុងកាលនោះ សូម្បីមិនទទួលប្រគេន ក៏គួរ, ក្នុងកាលដទៃមិនគួរទេ ។

ដែលឈ្មោះថា ទ្រង់អនុញ្ញាតចំពោះសម័យ បានដល់ អនាបត្តិទាំងឡាយ ដែលទ្រង់អនុញ្ញាតទុកចំពោះសម័យនោះ ៗ ដោយន័យជាដើមថា "ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរលែងតែមានសម័យ"[១] ដូច្នេះជាដើម ។ អនាបត្តិទាំងនោះ ជាអនាបត្តិចំពោះក្នុងសម័យនោះ ៗ ប៉ុណ្ណោះ, មិនមែនក្នុងសម័យដទៃទេ ។

ដែលឈ្មោះថា អនុញ្ញាតចំពោះប្រទេស បានដល់ សង្ឃកម្មមានឧបសម្បទាជាដើម ដែលទ្រង់អនុញ្ញាតចំពោះក្នុងបច្ចន្តប្រទេសយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តិជនបទទាំងឡាយបែបនេះ តថាគតអនុញ្ញាតនូវឧបសម្បទា ដោយគណៈ សង្ឃមានវិន័យធរជាគម្រប់ ៥ បាន"[២] ។ សង្ឃកម្ម មានឧបសម្បទាជាដើមនោះ[៣] រមែងគួរចំពោះក្នុងបច្ចន្តិជនបទនោះប៉ុណ្ណោះ, ក្នុងមជ្ឈិមប្រទេស មិនគួរទេ ។

---

១. វិន. និស្ស. ចីវរវគ្គ. ៣. ៥៤/៥៤ ; វិន. បាចិ. ៤. : ៤៨/៤៧ ; ៧០/៦៥ ; ១០០/៩៧ ; ១០៧/១០៦; ១៦៩/១៧៩; ២៣៣/២៣៤ ។ ២. វិន. មហា. ចម្មក្ខន្ធកៈ. ៧. ៧១/២១៥ ។ ៣. ពាក្យថា ជាដើមនោះ គឺ ឧបសម្បទាដោយគណៈសង្ឃមានវិន័យធរជាគម្រប់ ៥, ស្បែក ជើង ៤ ជាន់ឡើងទៅ, ងូតទឹកបានជានិច្ច, កម្រាលស្បែកទាំងឡាយ គឺ ស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ ។

ដែលឈ្មោះថា ទ្រង់អនុញ្ញាតចំពោះខ្លាញ់ បានដល់ សេចក្ដីដែលទ្រង់អនុញ្ញាតភេសជ្ជៈដោយឈ្មោះនៃខ្លាញ់យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្លាញ់ជាភេសជ្ជៈ"[១] ។ ខ្លាញ់ជាភេសជ្ជៈនោះរបស់ពួកសត្វមានខ្លាញ់ជាកប្បិយ និងអកប្បិយទាំងអស់ វៀរខ្លាញ់របស់មនុស្សចេញ រមែងគួរ ដើម្បីបរិភោគដូចការបរិភោគប្រេង ដល់ពួកភិក្ខុដែលមានសេចក្ដីត្រូវការដោយប្រេងនោះ ។

ដែលឈ្មោះថា ទ្រង់អនុញ្ញាតចំពោះភេសជ្ជៈ បានដល់ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ និងស្ករអំពៅ ដែលអាចផ្សាយទៅដើម្បីសម្រេចអាហារកិច្ច ដែលទ្រង់អនុញ្ញាតទុក ដោយឈ្មោះនៃភេសជ្ជៈយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតភេសជ្ជៈ ៥"[២] ។ ភេសជ្ជៈ ៥ ទាំងនោះ ភិក្ខុទទួលប្រគេនហើយ គប្បីបរិភោគបានតាមសប្បាយក្នុងបុរេភត្តក្នុងថ្ងៃនោះ, តាំងពីបច្ឆាភត្តទៅ កាលមានហេតុ គប្បីបរិភោគ បានរហូតដល់អស់ ៧ ថ្ងៃ ដោយន័យដូចពោលហើយ ។

---

១. វិន. មហា. ភេសជ្ជក្ខន្ធកៈ. ៧. ៧៥/២២៥ ។ ២. វិន. មហា. ភេសជ្ជក្ខន្ធកៈ. ៧ ៧៣/២២៤ ។

# អធិប្បាយបទភាជនីនិងអនាបត្តិវារ

[១៤២] ពាក្យថា សត្តាហាតិក្កន្តេ អតិក្កន្តសញ្ញី និស្សគ្គិយំ បាចិត្តិយំ : កាលភេសជ្ជៈកន្លងហួស ៧ ថ្ងៃទៅហើយ ភិក្ខុសំគាល់ថាកន្លងហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ មានសេចក្ដីថា សូម្បីបើថាភេសជ្ជៈនោះមានប្រមាណប៉ុនគ្រាប់ស្ពៃ ល្មមនឹងយកម្រាមកេះហើយភ្លក់រសដោយអណ្ដាតម្ដង ដែលភិក្ខុចាំបាច់ត្រូវលះបង់ចេញពិត និងគប្បីសម្ដែងអាបត្តិ បាចិត្តិយចេញ ។

[១៤៣] ពាក្យថា ន កាយិកេន បរិភោគេន បរិភុញ្ជិតព្វំ : មិនត្រូវយកមកបរិភោគប្រើប្រាស់ដោយកាយ មានសេចក្ដីថា ភិក្ខុកុំគប្បីយកលាបរាងកាយ ឬលាបដំបៅត្រង់រាងកាយ ។ សូម្បីបរិក្ខារមានសំពត់កាសាវៈ ឈើប្រត់ ស្បែកជើង ទ្រនាប់ជូតជើង គ្រែ និងតាំងជាដើម ត្រូវភេសជ្ជៈដែលជា និស្សគ្គិយវត្ថុទាំងនោះប្រលាក់ហើយ ជារបស់មិនគួរបរិភោគ ។ ក្នុងមហាបច្ចរី ពោលថា ទីសម្រាប់ដៃចាប់សូម្បីក្នុងសន្លឹកទ្វារ និងបង្អួចក៏មិនគួរលោប ។ ក្នុងមហាអដ្ឋកថា លោកពោលថា តែបើផ្សំបុះក្នុងទឹកអម្ចត់ហើយគួរលោបសន្លឹកទ្វារនិងបង្អួចបាន ។

[១៤៤] ពាក្យថា អនាបត្តិ អន្តោសត្តាហំ អធិដ្ឋេតិ : អាបត្តិមិនមានដល់ភិក្ខុដែលតាំងចិត្តទុក ក្នុងរវាង ៧ ថ្ងៃ មានសេចក្ដីថា

ខាងក្នុង៧ ថ្ងៃ ភិក្ខុអធិដ្ឋានទឹកដោះថ្លា ប្រេង និង ខ្លាញ់ ទុកជាប្រេងលាបសីសៈ ឬជាប្រេងសម្រាប់បន្តក់, អធិដ្ឋានទឹកឃ្មុំទុកជាថ្នាំលាបដំបៅ ទឹកអំពៅជាគ្រឿងអប់ផ្ទះ មិនមានអាបត្តិ ។ បើភិក្ខុប្រាថ្នានឹងសំរិតប្រេងដែលអធិដ្ឋានយកទុកហើយ ចុះក្នុងភាជនៈដាក់ប្រេងដែលនៅមិនបានអធិដ្ឋាន, បើក្នុងភាជនៈ មានប្រហោងតូចចង្អៀត ប្រេងដែលហូរសន្សឹម ៗ ចូលទៅត្រូវប្រេងចាស់ហៀរឡើងមកលិច, គប្បីអធិដ្ឋានថ្មី ។ បើភាជន៍មាត់ធំ ប្រេងច្រើនហូរចូលទៅយ៉ាងរហ័ស ដរាបដល់លិចប្រេងចាស់ មិនមានកិច្ចដែលនឹងត្រូវអធិដ្ឋានថ្មី ។ ពិតមែន ប្រេងនោះ មានគតិដូចប្រេងដែលអធិដ្ឋានហើយ ។ អ្នកសិក្សាគប្បីជ្រាបសូម្បីការបង្ហូរប្រេងដែលមិនបានអធិដ្ឋានចុះក្នុងភាជនៈដាក់ប្រេងដែលអធិដ្ឋានហើយដោយន័យនេះ ។

ក្នុងបទថា វិស្សជ្ជេតិ : លះបង់ចោល នេះមានវិនិច្ឆ័យដូច្នេះ ៖

បើភេសជ្ជៈនោះជារបស់មានម្ចាស់ពីរ ភិក្ខុមួយរូបទទួលប្រគេនទុក មិនទាន់បានបែងចែកគ្នា, ក្នុងកាលកន្លង៧ ថ្ងៃទៅមិនមានអាបត្តិសូម្បីទាំង ២ រូប, តែមិនគួរបរិភោគ ។ បើរូបណា ទទួលប្រគេនទុក រូបនោះពោលនឹងមួយរូបទៀតថា "លោកដ៏មានអាយុ ប្រេងនេះដល់ ៧ ថ្ងៃហើយ, លោកចូរបរិភោគប្រេងនោះចុះ" ដូច្នេះ លោកក៏មិនធ្វើការ

បរិភោគ នឹងត្រូវអាបត្តិដល់អ្នកណា ? មិនមានអាបត្តិសូម្បីដល់អ្នកណាមួយទាំងអស់នោះ ។ ព្រោះហេតុអ្វី ? ព្រោះភិក្ខុដែលទទួលប្រគេនក៏លះបង់ហើយ និងព្រោះភិក្ខុមួយរូបទៀត ក៏មិនបានទទួលប្រគេន ។

បទថា វិនស្សេតិ : វិនាសទៅ បានដល់ ជារបស់បរិភោគមិនបាន ។

ក្នុងពាក្យថា ចត្តេន : ដែលបរិច្ចាគ ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ភេសជ្ជៈដែលភិក្ខុលះបង់ហើយ ចោលហើយ លះផុតហើយដោយចិត្តណា, ចិត្តនោះ ព្រះមានព្រះភាគត្រាស់ហៅថា លះបង់ហើយ ចោលហើយ លះផុតហើយ ។ ត្រាស់ហៅបុគ្គលអ្នកមិនមានសេចក្ដីហួងហែងដោយចិត្តនោះ ។ អធិប្បាយថា អ្នកមិនមានសេចក្ដីហួងហែងយ៉ាងនោះឱ្យហើយដល់សាមណេរ ។ ពាក្យនេះ ត្រាស់ទុកព្រោះហេតុអ្វី ? ព្រះមហាសុមត្ថេរៈពោលថា ត្រាស់ទុក ដើម្បីសម្ដែងថា មិនមានអាបត្តិដល់ភិក្ខុឱ្យហើយខាងក្នុង៧ ថ្ងៃយ៉ាងនោះ ខាងក្រោយបានត្រឡប់មកវិញហើយឆាន់ ។

ចំណែកព្រះមហាបទុមត្ថេរៈពោលថា ប្រេងនេះ ភិក្ខុមិនគួរសូម, ព្រោះថា ក្នុងការបរិភោគថ្មីនូវប្រេងដែលឱ្យទៅហើយខាងក្នុង៧ ថ្ងៃ មិន

មានអាបត្តិឡើយ, តែត្រាស់ពាក្យនេះទុក ក៏ដើម្បីសម្ដែងថា មិនមានអាបត្តិ ព្រោះបរិភោគប្រេងដែលកន្លង ៧ ថ្ងៃទៅ ។ ព្រោះហេតុនោះ ភេសជ្ជៈដែលគេប្រគេន ហើយយ៉ាងនេះបើសាមណេរផ្សំហើយ ឬមិនបានផ្សំប្រគេនដល់ភិក្ខុនោះដើម្បីធ្វើការនត្ថុ (បន្តក់តាមច្រមុះ) ភិក្ខុទទួលហើយ គប្បីធ្វើនត្ថុកម្មចុះ ។ បើសាមណេរជាមនុស្សល្ងង់ មិនចេះប្រគេន, ភិក្ខុដទៃគប្បីប្រាប់លោកថា "នែសាមណេរ លោកមានប្រេងឬ ?" លោកទទួលថា "ព្រះករុណា លោកម្ចាស់ មាន" ភិក្ខុនោះគប្បីប្រាប់លោកថា "នាំមកចុះ, យើងនឹងធ្វើថ្នាំប្រគេនព្រះថេរៈ" ។ ប្រេង រមែងគួរ សូម្បីដោយការកាន់យកយ៉ាងនេះ ។ ពាក្យដ៏សេសមានអត្ថងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋានដូចកឋិនសិក្ខាបទ ជាអកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

ភេសជ្ជសិក្ខាបទ ចប់

# ៤. វស្សិកសាដិកសិក្ខាបទវណ្ណនា

[១៨៥] វស្សិកសាដិកសិក្ខាបទថា តេន សមយេន : សម័យនោះ ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងវស្សិកសាដិកសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ពីរបទថា វស្សិកសាដិកា អនុញ្ញាតា : ទ្រង់អនុញ្ញាតវស្សិកសាដកហើយ មានសេចក្ដីថា សំពត់ងូតទឹកភ្លៀងព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកហើយក្នុងរឿងនាងវិសាខាក្នុងចីវរក្ខន្ធកៈ[១] ។

បទថា បដិកច្ចេវ : មុនគេ បានដល់ មុននោះឯង ។

[១៨៦] ច្រើនបទថា មាសោ សេសោ គិម្ហានំ : ភិក្ខុកំណត់ដឹងថា ខែមួយខាងចុងនៃគិម្ហរដូវ មានសេចក្ដីថា រដូវក្ដៅ ៤ ខែ នៅសល់ខែខាងចុងបង្អស់ ១ខែ ទៀត ។

បទថា កត្វា : គប្បីធ្វើ មានសេចក្ដីថា ឱ្យសម្រេចអស់ដោយការដេរ ជ្រលក់និងកប្បៈជាទីបំផុត ។ ក៏ភិក្ខុកាលនឹងធ្វើ គប្បីធ្វើតែមួយផ្ទាំងប៉ុណ្ណោះ ហើយអធិដ្ឋានក្នុងសម័យ នឹងអធិដ្ឋាន២ផ្ទាំង មិនគួរ ។

ពាក្យថា អតិរេកមាសេ សេសេ គិម្ហានេ : ថ្ងៃមុនពីមួយខែជា

---

១. វិន. មហា. ចីវរក្ខន្ធកៈ. ៨. ៥៩/១៣៥ : ម្ចាស់វិសាខា តថាគតអនុញ្ញាតពរ ៨ ប្រការដល់នាង ។

ខាងចុងគិម្ហរដូវ បានដល់ កាលខែដែលមានឈ្មោះថា រដូវក្តៅ នៅសល់ជាង១ខែ ៗ តែអ្នកសិក្សាតាំងនៅក្នុងពាក្យថា អតិរេកឌ្ឍមាសេ សេសេ គិម្ហានេ កត្វា និវាសេតិ : ធ្វើស្រេចហើយប្រើប្រាស់ក្នុងកាលមុនកន្លះខែជាខាងចុង គិម្ហរដូវ នេះហើយ គប្បីជ្រាបខេត្រនៃសំពត់ងូតទឹកភ្លៀង ៤ ខេត្ត គឺ ខេត្រនៃការស្វែងរក ១ ខេត្រនៃការធ្វើ ១ ខេត្រនៃការស្លៀកដណ្តប់ ១ ខេត្រនៃការអធិដ្ឋាន ១ និងខេត្រនៃសម័យពីរយ៉ាង គឺ កុច្ឆិសម័យ ១ បិដ្ឋិសម័យ ១, និង ចតុក្កៈ ២ គឺ បិដ្ឋិសម័យចតុក្កៈ ១ កុច្ឆិសម័យចតុក្កៈ ១ ៗ

បណ្តាខេត្ត សម័យ និងចតុក្កៈទាំងនោះ កន្លះខែមួយ តាំងពីថ្ងៃ ១រោច ក្រោយថ្ងៃពេញបូណ៌មីខែ ៧ ទៅដរាបដល់ថ្ងៃឧបោសថក្នុងកាឡបក្ខនេះជាខេត្រនៃការស្វែងរក និងខេត្រនៃការធ្វើ ៗ ពិតមែន ក្នុងចន្លោះនេះ ភិក្ខុនឹងស្វែងរកសំពត់ងូតទឹកភ្លៀងដែលមិនទាន់បានផង នឹងធ្វើសំពត់ងូតទឹកភ្លៀងដែលបានហើយផង គួរ ៗ ស្លៀកដណ្តប់និងអធិដ្ឋាន មិនគួរ ៗ កន្លះខែមួយ តាំងពីថ្ងៃ ១ កើត ក្រោយថ្ងៃឧបោសថក្នុងកាឡបក្ខទៅដរាបដល់ថ្ងៃពេញបូណ៌មីខែ ៨ នេះជាខេត្រនៃការស្វែងរក ការធ្វើនិងការស្លៀកដណ្តប់ សូម្បីទាំង ៣ ៗ ពិតមែន ក្នុងចន្លោះនេះ នឹងស្វែងរកសំពត់ងូតទឹកភ្លៀងដែលមិនទាន់បានផង នឹង

ធ្វើសំពត់ដែលបានហើយផង នឹងស្លៀកដណ្ដប់ផង គួរ ។ នឹងអធិដ្ឋានតែម្យ៉ាង មិនគួរ ។ តាំងពីថ្ងៃ ១ រោច ក្រោយថ្ងៃពេញបូណ៌មីខែ ៨ ទៅ ដរាបដល់ថ្ងៃពេញបូណ៌មីខែកត្តិក (ខែ ១២) ៤ ខែនេះជាខែត្រដែននៃការស្វែងរកការធ្វើ ការស្លៀកដណ្ដប់ និងអធិដ្ឋាន សូម្បីទាំង ៤ ។ ពិតមែន ក្នុងចន្លោះនេះ នឹងស្វែងរកសំពត់ងូតទឹកភ្លៀងដែលមិនទាន់បានផង នឹងធ្វើសំពត់ដែលបានហើយផង នឹងស្លៀកដណ្ដប់ផង និងនឹងអធិដ្ឋានផង គួរ ។ គប្បីជ្រាបខែត្ត ៤ យ៉ាងនេះមុន ។

មួយទៀត តាំងពីថ្ងៃ១រោច ក្រោយថ្ងៃពេញបូណ៌មីខែ ១២ ទៅ ដរាបដល់ថ្ងៃពេញបូណ៌មីនៃខែ ៧, ៧ ខែនេះ ឈ្មោះថា បិដ្ឋិសម័យ (ក្រោយសម័យ) ។ ពិតមែន ក្នុងចន្លោះនេះ កាលភិក្ខុធ្វើការជាស់តឿនសតិ ដោយន័យជាដើមថា កាលនៃសំពត់ងូតទឹកភ្លៀង ហើយឱ្យចីវរ គឺ សំពត់ងូតទឹកភ្លៀងសម្រេចបាកទីរបស់ជនមិនមែនញាតិ និងមិនបានបវារណា ជានិស្សគ្គិយបាចិត្តិយ ដោយសិក្ខាបទនេះ, កាលធ្វើវិញ្ញត្តិដោយន័យជាដើមថា "អ្នកទាំងឡាយចូរឱ្យចីវរគឺ សំពត់ងូតទឹកភ្លៀងដល់អាត្មា" ហើយឱ្យសម្រេច ជានិស្សគ្គិយបាចិត្តិយ ដោយអញ្ញាតកវិញ្ញត្តិសិក្ខាបទ ។ កាលធ្វើការជាស់តឿនសតិ ដោយន័យដូចពោលហើយនុ៎ះឯង ឱ្យសម្រេចបាកទីនៃញាតិនិងអ្នកបវារណា ជានិស្សគ្គិយបាចិត្តិយ ដោយសិក្ខាបទនេះឯង, កាលធ្វើវិញ្ញត្តិឱ្យសម្រេចមិនមាន

អាបត្តិ ដោយអញ្ញាតកវិញ្ញត្តិសិក្ខាបទ ។ សមពិតដូចព្រះតម្រាស់ដែលត្រាស់ទុកក្នុងគម្ពីរបរិវារៈថា ៖

"សូមចីវរនឹងមាតា តែមិនមែនជាចីវរ ដែលមាតាបង្អោនទៅដើម្បីសង្ឃ ភិក្ខុនោះត្រូវអាបត្តិ ព្រោះហេតុអ្វី មួយទៀត ភិក្ខុមិនត្រូវអាបត្តិ ព្រោះសូមចីវរនឹងពួកញាតិ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ"[១] ។

ក៏បញ្ហានេះ លោកពោលសំដៅដល់សេចក្តីនេះឯង ។ គប្បីជ្រាបបិដ្ឋិសម័យចតុក្កៈយ៉ាងនេះ ។

មួយទៀត តាំងពីថ្ងៃ១រោច ក្រោយថ្ងៃពេញបូណ៌មីនៃខែ ៧ ទៅដរាបដល់ថ្ងៃពេញបូណ៌មីខែកត្តិក ៥ ខែនេះ ឈ្មោះថា កុច្ឆិសម័យ ( សម័យ ) ។ ពិតមែន ក្នុងចន្លោះនេះ កាលភិក្ខុធ្វើការជាស់តៀនសតិដោយន័យដូចពោលហើយនុ៎ះឯង ឱ្យចីវរ គឺ សំពត់ងូតទឹកភ្លៀងសម្រេចបាកទីនៃជនមិនមែនញាតិ និងមិនបានបវារណាត្រូវអាបត្តិទុក្កដព្រោះវត្ថុភេទ ។ តែពួកអ្នកស្រុក ដែលធ្លាប់ប្រគេនចីវរគឺ សំពត់ងូតទឹកភ្លៀងសូម្បីក្នុងកាលមុន បើទោះជាថា នឹងជាអ្នកមិនមែនញាតិ និងមិនមែនអ្នកបវារណារបស់ខ្លួន ក៏មិនមានការជាវត្ថុភេទ ព្រោះធ្វើការជាស់

១. វិន. បរិ. សេទមោចនគាថា. ១៣. ៤១៣/៤១២ ។

តឿនសតិ ក្នុងជនទាំងនោះ ទ្រង់អនុញ្ញាតទុក ។ កាលភិក្ខុធ្វើវិញ្ញត្តិឱ្យសម្រេចជានិស្សគ្គិយបាចិត្តិយ ដោយអញ្ញាតកវិញ្ញត្តិសិក្ខាបទ ។ ព្រោះហេតុអ្វី ? ព្រោះត្រាស់ទុកថា ភិក្ខុចូលទៅរកពួកអ្នកស្រុកដែលធ្លាប់ប្រគេនចីវរ គឺ សំពត់ងូតទឹកភ្លៀងមុន ហើយគប្បីពោលយ៉ាងនេះដូច្នេះជាដើម ។

ក៏ចីវរ គឺ សំពត់ងូតទឹកភ្លៀងនេះ តាមប្រក្រតី រមែងមានសូម្បីក្នុងពួកទាយកដែលប្រគេនសំពត់ងូតទឹកភ្លៀងនុ៎ះឯង ។ កាលភិក្ខុជាស់តឿនឱ្យកើតសតិ ដោយន័យដូចពោលហើយនុ៎ះឯង ហើយឱ្យសម្រេចបាកទីនៃជនជាញាតិនិងអ្នកបវារណា មិនមានអាបត្តិដោយសិក្ខាបទនេះ, កាលធ្វើវិញ្ញត្តិឱ្យសម្រេចមក មិនមានអាបត្តិដោយអញ្ញាតកវិញ្ញត្តិសិក្ខាបទ ។ ពិតមែន ពាក្យថា "ពួកភិក្ខុមិនត្រូវនិយាយថា អ្នកទាំងឡាយចូរឱ្យដល់អាត្មា" នេះត្រាស់សំដៅដល់ជនមិនមែនញាតិនិងមិនមែនអ្នកបវារណានុ៎ះឯង ។ គប្បីជ្រាបកុច្ចិសម័យចតុក្កៈ ( ពួក ៤ ក្នុងសម័យ ) យ៉ាងនេះ ។

[១៤៧] ក្នុងពាក្យថា ឆន្នោ កាយំ ឱវស្សាបេតិ អាបត្តិ ទុក្កដស្ស : តែភិក្ខុស្រាតងូតទឹកភ្លៀង ត្រូវអាបត្តិទុក្កដ នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ភិក្ខុអាក្រាតកាយងូតទឹកភ្លៀងនោះ ព្រះវិន័យធរកុំពិន័យ តាមចំនួនគ្រាប់ទឹកភ្លៀង គប្បីពិន័យដោយទុក្កដ គ្រប់ ៗប្រយោគ ដោយអំណាចសម្រេចការងូតទឹក ។ ក៏ឯភិក្ខុនោះងូតទឹកដែលធ្លាក់ចុះមកពីអាកាស នៅក្នុងលានដែលបើកចំហ ( ក្នុងទីវាល ) ប៉ុណ្ណោះ ( ទើបត្រូវទុក្កដ ) ។ កាលងូតនៅក្នុងបន្ទប់ទឹក និងក្នុងបឹងជាដើម ឬដោយទឹកដែលប្រើផ្ទាំងជូសស្រោច ( ជងងូត ) មិនមានអាបត្តិ ។

[១៤៨] ក្នុងពាក្យថា វស្សំ ឧក្កឌ្ឍិយតិ : **គេលើកខែមួយជាខាងដើមនៃវស្សានរដូវ** នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

បើកាលសំពត់ងូតទឹកភ្លៀងធ្វើសម្រេចហើយ ពួកភិក្ខុឱ្យខែចុងរដូវក្តៅអស់ទៅហើយបន្ថិតខែដើមរដូវភ្លៀងនុំះឯង ឡើងមកជាខែចុងរដូវក្តៅទៀត, គប្បីបោកសំពត់ងូតទឹកភ្លៀងរក្សាទុក ។ មិនត្រូវអធិដ្ឋាន មិនត្រូវវិកប្ប បានបរិហាររហូតដល់អស់ ២ ខែ ។ គប្បីអធិដ្ឋានក្នុងថ្ងៃវស្សូបនាយិកា ( ថ្ងៃចូលវស្សា ) ។ បើថា សំពត់ងូតទឹកភ្លៀងភិក្ខុមិនបានធ្វើ ព្រោះភ្លេចសតិ ឬព្រោះសំពត់ មិនគ្រប់គ្រាន់ក្តី រមែងបានបរិហាររហូតដល់អស់ ៦ ខែ គឺ ២ ខែនោះផង ៤ ខែរដូវភ្លៀងផង ។ តែបើភិក្ខុក្រាលកឋិនក្នុងខែ កត្តិក រមែងបានបរិហារ ៤ ខែទៀត ។ រួមជា ១០ ខែដោយប្រការយ៉ាងនេះ ។ សូម្បីតពី ១០ ខែនោះទៅ កាលមានសេចក្តីប្រាថ្នា ( នឹងបានសំពត់ងូតទឹកភ្លៀង ) របស់ភិក្ខុដែល

ធ្វើឱ្យជាចីវរដើមរក្សាទុក បានបរិហារមួយខែទៀត ដូច្នោះ ទើបបាន បរិហាររហូតដល់អស់ ១១ ខែ ដោយប្រការយ៉ាងនេះ ។

សួរថា ក៏បើថា សំពត់ងូតទឹកភ្លៀងដែលបានហើយនិងសម្រេចហើយ ក្នុងកាលថ្ងៃចូលវស្សាមិនទាន់មកដល់ ដោយអំណាចមួយថ្ងៃនិងពីរថ្ងៃជាដើម ដរាបដល់១០ថ្ងៃ ឬខាងក្នុងវស្សា នឹងអធិដ្ឋានកាលណា ?

ឆ្លើយថា ពាក្យនេះ លោកមិនបានពិចារណាទុកក្នុងអដ្ឋកថាទាំងឡាយ ។ ពួកយើងមានអត្តនោមតិយ៉ាងនេះថា ក៏ឯសំពត់ងូតទឹកភ្លៀងដែលសម្រេចហើយ ខាងក្នុង១០ ថ្ងៃ តាំងពីថ្ងៃដែលបានមក គប្បីអធិដ្ឋានខាងក្នុង១០ ថ្ងៃនោះឯង ។ ដែលសម្រេចក្នុងកាលកន្លង ១០ ថ្ងៃទៅ គប្បីអធិដ្ឋានក្នុងថ្ងៃនោះ, កាលមិនទាន់គ្រប់ ១០ ថ្ងៃ មិនគប្បីឱ្យហួសចីវរកាលទៅ ។ ព្រោះហេតុអ្វី ? ព្រោះព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុអធិដ្ឋានត្រៃចីវរ មិនឱ្យវិកប្បទេ, ឱ្យអធិដ្ឋានសំពត់សម្រាប់ងូតទឹកភ្លៀងអស់ ៤ ខែនៃរដូវភ្លៀង តអំពីកាល ៤ ខែនោះទៅត្រូវវិកប្បទុក"[១] ព្រោះដូច្នោះ ទើបមិនមានអាបត្តិ សូម្បីព្រោះការកន្លង ១០ ថ្ងៃទៅ មុនថ្ងៃចូលវស្សា ។ សមពិតដូចដែលទ្រង់ត្រាស់ថា "ភិក្ខុត្រូវទុកអតិរេកចីវរបានតែត្រឹមដប់ថ្ងៃ"[២] ។

---

១. វិន. មហា. ចីវរក្ខន្ធកៈ. ៨. ៦៦/១៤៣ ។ ២. វិន. និស្ស. ចីវរវគ្គ. ៣. ២/៤ ។

ព្រោះដូច្នោះ សំពត់ងូតទឹកភ្លៀងដែលបានមក និងសម្រេចហើយក្នុងកាលថ្ងៃចូលវស្សា នៅ មិនទាន់មកដល់ដោយអំណាចនៃមួយថ្ងៃ និងពីរថ្ងៃជាដើម ដរាបដល់ ១០ ថ្ងៃ ឬខាងក្នុងវស្សា គប្បីអធិដ្ឋានខាងក្នុង ១០ ថ្ងៃ ឬក្នុងថ្ងៃនោះ ដោយន័យដូចពោលហើយនុ៎ះឯង, កាលមិនទាន់គ្រប់ ១០ ថ្ងៃ ក៏មិនគប្បីឱ្យកន្លងហួសចីវរកាលទៅ ។

ក្នុងអធិការនៃសំពត់ងូតទឹកភ្លៀងនោះ នឹងមានការតវ៉ាថា ព្រោះព្រះបាលីថា "តថាគតអនុញ្ញាតឱ្យអធិដ្ឋានរហូតដល់អស់ ៤ ខែរដូវភ្លៀង" ខាងក្នុង៤ ខែនឹងអធិដ្ឋានក្នុងពេលណាមួយ ក៏គួរនឹងប្រើបាន ។ បើកាលមានពាក្យយ៉ាងនេះ, ពាក្យដែលត្រាស់ទុកថា "តថាគតអនុញ្ញាត ឱ្យអធិដ្ឋានសំពត់សម្រាប់គ្របកម កំណត់ត្រឹមមានអាពាធ" និងសូម្បីសំពត់សម្រាប់គ្របកមនោះ ក៏មិនគួរឱ្យកន្លង ១០ ថ្ងៃ, និងកាលមានការកន្លង ១០ ថ្ងៃទៅយ៉ាងនោះ ពាក្យថា ត្រូវទុកអតិរេកចីវរបានតែត្រឹមដប់ថ្ងៃ នេះ ក៏នឹងខុសទៅ ។ ព្រោះដូច្នោះបណ្ឌិត ទើបគួរជឿពាក្យតាមដែលពោលនុ៎ះឯង ។ ឬថា បានហេតុដែលមិនធូរស្រាល យ៉ាងដទៃហើយ ក៏គួរបោះបង់ចោល ។

មួយទៀត សូម្បីក្នុងកុរុន្ទី ក៏ពោលទុកក្នុងទីបំផុតនៃនិស្សគ្គិយថា សំពត់ងូតទឹកភ្លៀងគួរអធិដ្ឋានកាលណា ? ក៏ឯសំពត់ងូតទឹកភ្លៀងដែល

សម្រេចហើយខាងក្នុង១០ ថ្ងៃ តាំងពីថ្ងៃដែលបានមក គួរអធិដ្ឋានខាងក្នុង១០ ថ្ងៃនោះឯង ។ បើសំពត់មិនគ្រប់គ្រាន់ រមែងបានបរិហារទៅដរាបដល់ថ្ងៃពេញបូរមីខែ ១២ ។

ពាក្យថា អច្ឆិន្នចីវរស្ស : ដល់ភិក្ខុមានចីវរដែលចោរដណ្តើមយកទៅ នេះ ព្រះមានព្រះភាគត្រាស់សំដៅយកចំពោះសំពត់ងូតទឹកភ្លៀងប៉ុណ្ណោះ ។ ពិតមែន មិនមានអាបត្តិដល់ភិក្ខុទាំងនោះ ដែលអាក្រាតកាយ ព្រោះញ៉ាំងទឹកភ្លៀងឱ្យស្រោចរាងកាយ ។

ក៏ក្នុងបទថា អាបទាសុ : ដល់ភិក្ខុដែលមានសេចក្តីអន្តរាយនេះ ឧបទ្រវៈគឺ ចោរ ឈ្មោះថា អន្តរាយនៃភិក្ខុដែលស្លៀកងូតទឹកភ្លៀងមានតម្លៃថ្លៃ នៅងូតទឹក ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ មានអត្ថងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

វស្សិកសាដិកសិក្ខាបទ ចប់

# ៥. ចីវរអច្ឆិន្ទនសិក្ខាបទវណ្ណនា

[១៨៩] ចីវរអច្ឆិន្ទនសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងចីវរអច្ឆិន្ទនសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ក្រើនបទថា យំបិ ត្យាហំ កាត់បទជា យម្បិ តេ អហំ : ខ្ញុំបានឱ្យចីវរណាដល់លោក ។ បានឮថា ព្រះឧបនន្ទនោះ គិតថា "ភិក្ខុនេះនឹងនាំបាត្រ ចីវរ ស្បែកជើង និងសំពត់ក្រាលដេកជាដើមរបស់យើង ទៅកាន់ទីចារិកជាមួយនឹងយើង ទើបបានឱ្យហើយ ; ព្រោះហេតុនោះឯង លោកទើបបានពោលយ៉ាងនោះ ។

## ការដណ្ដើមយកមកវិញ របស់ភិក្ខុដែលឱ្យចីវរ

[១៩០] បទថា អច្ឆិន្ទិ : ដណ្ដើម បានដល់ បានកាន់យកហើយដោយកម្លាំង ។ តែព្រោះកាន់យកដោយសម្គាល់ថា "របស់ខ្លួន" ទើបមិនត្រូវអាបត្តិបារាជិកដល់លោក ។ ព្រោះលោកធ្វើឱ្យលំបាកហើយកាន់យកចីវរ ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តិអាបត្តិទុក ។

ពាក្យថា សយំ អច្ឆិន្ទតិ និស្សគ្គិយំ ធាចិត្តិយំ[១] : ដណ្ដើម

១. ក្នុងបិដកខ្មែរ មិនមានពាក្យថា ធាចិត្តិយំ នេះ តែទីទាំងពួងមាន ។

យកមកដោយខ្លួនឯងវិញ ចីវរនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ មានសេចក្តីថា សម្រាប់ភិក្ខុដែលដណ្តើមយកចីវរតែមួយផ្ទាំងនិងច្រើនផ្ទាំង ដែលជាប់គ្នា ត្រូវអាបត្តិតែមួយ ។ កាលភិក្ខុដណ្តើមយកចីវរច្រើនផ្ទាំង ដែលមិនជាប់គ្នា និងតាំងនៅបែកគ្នា និងកាលប្រើឱ្យអ្នកដទៃនាំមកឱ្យ ដោយបង្គាប់យ៉ាងនេះថា "លោកចូរនាំសង្ឃាដិមក, ចូរនាំសំពត់ឧត្តរាសង្គមក ត្រូវអាបត្តិច្រើនតាមចំនួនវត្ថុ ។ សូម្បីកាលពោលថា "លោកចូរនាំចីវរទាំងអស់ដែលយើងឱ្យហើយ ត្រឡប់មកវិញ" ក៏ត្រូវអាបត្តិចំនួនច្រើន ព្រោះពាក្យនិយាយតែមួយម៉ាត់នុ៎ះឯង ។

ពាក្យថា អញ្ញំ អាណាបេតិ អាបត្តិ ទុក្កដស្ស : ភិក្ខុបង្គាប់អ្នកដទៃ ត្រូវអាបត្តិទុក្កដ មានសេចក្តីថា បង្គាប់ថា "លោកចូរកាន់យកចីវរ" ត្រូវអាបត្តិទុក្កដតែមួយ ។ ភិក្ខុដែលទទួលបង្គាប់កាន់ចីវរច្រើន, ក៏ត្រូវអាបត្តិបាចិត្តិយតែមួយ កាលភិក្ខុពោលថា "លោកចូរយកសង្ឃាដិមក, ចូរយកឧត្តរាសង្គមក" ត្រូវអាបត្តិទុក្កដ គ្រប់ពាក្យនិយាយ ។ កាលពោលថា "លោកចូរយកចីវរដែលយើងឱ្យទាំងអស់ត្រឡប់មកវិញ" ត្រូវអាបត្តិចំនួនច្រើន ព្រោះពាក្យនិយាយតែមួយម៉ាត់ ។

[១៥១] ពីរបទថា អញ្ញំ បរិក្ខារំ : បរិក្ខារដទៃ មានសេចក្តី

ថា បរិក្ខារយ៉ាងណាមួយ វៀរចីវរយ៉ាងតូចដែលគួរនឹងវិកប្បបាន ដោយហោចទៅសូម្បីតែម្ជុល ។ សូម្បីក្នុងពួកម្ជុលដែលខ្ចប់រក្សាទុក ក៏ជាអាបត្តិទុក្កដច្រើនតាមចំនួនវត្ថុ ។ ក្នុងម្ជុលដែលខ្ចប់ទុកជួរ ៗ (ក៏ត្រូវអាបត្តិទុក្កដច្រើនតាមចំនួនវត្ថុ) យ៉ាងនោះដូចគ្នា ។ ក្នុងមហាបច្ចរីលោកពោលថា ក៏ក្នុងម្ជុលទាំងឡាយដែលគេចងទុកណែន ជាអាបត្តិទុក្កដតែមួយប៉ុណ្ណោះ ។

សូម្បីក្នុងម្ជុលដែលគេដាក់ទុកក្នុងបំពង់ម្ជុល ក៏មានន័យយ៉ាងនេះដូចគ្នា ។ សូម្បីក្នុងភេសជ្ជៈមានគ្រឿងហឹរ ៣ ប្រភេទ ដែលគេដាក់ទុកក្នុងថង់យាមចងទុកជួរ និងចងទុកណែន ក៏មានន័យយ៉ាងនេះដូចគ្នា ។

## ការសងដល់ម្ចាស់ដើមនៃភិក្ខុដែលទទួលទៅ

[១៥២] ពីរបទថា សោ វា ទេតិ **: ដល់ភិក្ខុដែលភិក្ខុអ្នកទទួលចីវរនោះ គេឱ្យត្រឡប់មកវិញក្តី** មានសេចក្តីថា ភិក្ខុនោះ ឱ្យយ៉ាងនេះថា "លោកម្ចាស់ ចីវរនេះសមគួរដល់លោកម្ចាស់ប៉ុណ្ណោះ" ដូច្នេះក្តី ។ ម្យ៉ាងទៀត ក៏ភិក្ខុកម្លោះនោះត្រូវព្រះថេរៈនោះ ពោលពាក្យមានជាដើមយ៉ាងនេះថា "អ្នកមានអាយុ យើងបានឱ្យចីវរដល់លោកដោយប្រាថ្នាថា នឹងធ្វើវត្តបដិបត្តិ នឹងកាន់ឧបជ្ឈាយ៍ នឹងរៀនធម៌ក្នុងសំណាក់

របស់យើង មកឥឡូវនេះ លោកនោះមិនធ្វើវត្ត មិនកាន់ឧបជ្ឈាយ៍ មិនរៀនធម៌" ដូច្នេះ ទើបឱ្យវិញថា "លោកម្ចាស់ មើលទៅលោក ហាក់ដូចជានិយាយដើម្បីត្រូវការចីវរវិញ, នេះចីវររបស់លោកយកទៅវិញចុះ" ។ ភិក្ខុដែលទទួលទៅនោះ ឱ្យវិញសូម្បីដោយអាការយ៉ាងនេះ ក្តី ។ ឬក៏ថាព្រះថេរៈពោលដល់ភិក្ខុកម្លោះ ដែលចៀសទៅកាន់ទិសថា "ពួកលោកចូរឱ្យលោកត្រឡប់"; លោកមិនត្រឡប់ ។ ព្រះថេរៈបន្ទាប់ថា "ពួកលោកចូរនាំគ្នាចាប់ចីវរទុក បើយ៉ាងនេះ លោកត្រឡប់ជាការល្អ" ។ បើលោកពោលថា "ពួកលោកមើលទៅហាក់ដូចជានិយាយ ដើម្បីត្រូវការបាត្រនិងចីវរ, ពួកលោកចូរទទួលយកវាទៅវិញចុះ" ហើយឱ្យមកវិញ ។ សូម្បីយ៉ាងនេះ ក៏ឈ្មោះថា ភិក្ខុដែលទទួលទៅនោះឱ្យមកវិញដោយខ្លួនឯងក្តី ។

មួយទៀត ព្រះថេរៈឃើញលោកសឹកហើយ ពោលថា "យើងបានឱ្យបាត្រនិងចីវរដល់លោកដោយប្រាថ្នាថា នឹងធ្វើវត្ត ឥឡូវនេះលោកនោះក៏សឹកទៅហើយ" ។ ចំណែកភិក្ខុកម្លោះ ដែលសឹកទៅនិយាយថា "សូមលោកមេត្តាទទួលយកបាត្រនិងចីវររបស់លោកទៅចុះ" ហើយឱ្យមកវិញ ។ សូម្បីយ៉ាងនេះ ក៏ឈ្មោះថា ភិក្ខុដែលទទួលទៅនោះ

ឯង ឱ្យមកវិញដោយខ្លួនឯងក្ដី ។ តែនឹងឱ្យដោយពោលយ៉ាងនេះថា "យើងឱ្យដល់លោកអ្នកកាន់ឧបជ្ឈាយ៍ក្នុងសំណាក់របស់យើងប៉ុណ្ណោះ យើងមិនឱ្យដល់អ្នកកាន់ឧបជ្ឈាយ៍ក្នុងទីដទៃ, យើងឱ្យចំពោះដល់អ្នកធ្វើវត្ត, មិនឱ្យដល់អ្នកមិនធ្វើវត្ត យើងឱ្យដល់អ្នករៀនធម៌ប៉ុណ្ណោះ មិនឱ្យដល់អ្នកមិនរៀន យើងឱ្យដល់អ្នកមិនសឹកប៉ុណ្ណោះ មិនឱ្យដល់អ្នកសឹក" ដូច្នេះ មិនគួរ ។ ត្រូវអាបត្តិទុក្កដដល់អ្នកឱ្យ ។ តែនឹងប្រើឱ្យនាំត្រឡប់មកវិញគួរ ។ ភិក្ខុដែលដណ្ដើមយកចីវរដែលខ្លួនលះបង់ឱ្យហើយត្រឡប់មកវិញ ព្រះវិន័យធរគប្បីពិន័យតាមតម្លៃវត្ថុ ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ រមែងកើតអំពីកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

ចីវរអច្ឆិន្ទនសិក្ខាបទ ចប់

# ៦. សុត្តវិញ្ញត្តិសិក្ខាបទវណ្ណនា

[១៩៣] *សុត្តវិញ្ញត្តិសិក្ខាបទថា* តេន សមយេន **:** *សម័យនោះ ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងសុត្តវិញ្ញត្តិសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖*

## កំណើតអំបោះ ៦ ប្រភេទ

[១៩៤] *បទថា* ខោមំ **:** *អំបោះសម្បកឈើ បានដល់ អំបោះដែលធ្វើដោយសំបកឈើ ។*

*បទថា* កប្បាសិកំ **:** *អំបោះកប្បាស បានដល់ អំបោះដែលកើតអំពីកប្បាស ។*

*បទថា* កោសេយ្យំ **:** *សូត្រ បានដល់ អំបោះដែលរវៃធ្វើដោយសរសៃសូត្រ ។*

*បទថា* កម្ពលំ **:** *អំបោះរោមសត្វ បានដល់ អំបោះធ្វើដោយរោមចៀម ។*

*បទថា* សាណំ **:** *អំបោះធ្មៃ បានដល់ អំបោះដែលធ្វើដោយសំបកឈើសាណៈ ( ធ្មៃ ) ។*

*បទថា* ភង្គំ **:** *អំបោះផ្សំគ្នា អាចារ្យមួយពួកពោលថា បានដល់*

អំបោះដែលធ្វើដោយធ្មៃមួយប្រភេទផ្សេងដទៃ ។ តែអំបោះដែលគេធ្វើផ្សំគ្នាដោយសម្ភារៈទាំង ៥ យ៉ាងនោះ អ្នកសិក្សាគប្បីជ្រាបថា ភង្គៈ ។

ច្រើនបទថា **វាយាបេតិ បយោគេ ទុក្កដំ** : **ប្រើពួកជាងតម្បាញ ត្រូវអាបត្តិទុក្កដតាមប្រយោគ** មានសេចក្ដីថា បើជាងតម្បាញមិនមានត្រល់ឬកីជាដើម, គេគិតថា "យើងនឹងនាំរបស់ទាំងនោះមកពីព្រៃ" ទើបសំលៀងកាំបិតឬពូថៅ, តាំងពីនោះទៅគេធ្វើប្រយោគណា ៗ ដើម្បីត្រូវការគ្រឿងឧបករណ៍ក្ដី ដើម្បីត្រូវការទឹងត្បាញចីវរក្ដី ត្រូវអាបត្តិទុក្កដដល់ភិក្ខុគ្រប់ប្រយោគរបស់ជាងតម្បាញនោះ ក្នុងកិច្ចទាំងពួង ។ កាលជាងតម្បាញត្បាញសំពត់បានបណ្ដោយប្រវែង ១ ចំអាមនិងទទឹងប្រវែង ១ ហត្ថ ជានិស្សគ្គិយបាចិត្តិយ ។ តែក្នុងមហាបច្ចរីលោកពោលថា ជានិស្សគ្គិយបាចិត្តិយ គ្រប់ ៗ ផ្ទាំងក្ដារកី[1] ដល់ភិក្ខុដែលឱ្យជាងតម្បាញត្បាញរហូតដល់ទីបំផុត សូម្បីពាក្យនោះ ក៏គប្បីជ្រាបថា លោកពោលសំដៅយកប្រមាណនេះឯង ។ ពិតមែន ប្រមាណសំពត់យ៉ាងទាបគួរវិកប្បបាន ទើបដល់ការរាប់ថា ចីវរនោះឯង ។

---

(១) ប្រដាប់សម្រាប់ស្ទាល់ឬបន្ដឹងសំពត់ដែលត្បាញឱ្យតឹង កុំឱ្យរួញសាច់ សំពត់, ចុងទាំងពីរ មានម្ជុល សម្រាប់ស៊ិកចូលត្រង់ជាយសំពត់ ។

## ការប្រើឱ្យត្បាញដោយអំបោះកប្បិយជាដើម

មួយទៀត បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា វាយាបេតិ បយោគេ ទុក្កដំ : ប្រើពួកជាងតម្បាញឱ្យត្បាញ ត្រូវអាបត្តិទុក្កដតាមប្រយោគ នេះ យ៉ាងនេះ ៖

នឹងពោលដល់អំបោះមុន ដែលភិក្ខុសូមដោយខ្លួនឯង ជាអកប្បិយ ។ អំបោះដ៏សេសដែលកើតឡើងដោយអំណាចនៃញាតិជាដើម ជាកប្បិយ ។ សូម្បីជាងតម្បាញក៏មិនមែនញាតិ និងមិនមែនអ្នកបវារណា ភិក្ខុបានមកដោយការសូម ជាអកប្បិយ ។ ជាងតម្បាញដ៏សេសជាកប្បិយ ។ បណ្ដាអំបោះនិងជាងតម្បាញ ទាំងនោះ អំបោះដែលជាអកប្បិយៈ ជានិស្សគ្គិយដល់ភិក្ខុដែលឱ្យជាងតម្បាញដែលជាអកប្បិយត្បាញ ដោយន័យដូចពោលហើយក្នុងកាលមុន ។

មួយទៀត កាលភិក្ខុឱ្យជាងតម្បាញជាអកប្បិយនោះឯង ត្បាញអំបោះដែលជាកប្បិយត្រូវអាបត្តិទុក្កដ ដូចជានិស្សគ្គិយក្នុងខាងដើមនុ៎ះឯង ។ កាលភិក្ខុឱ្យជាងតម្បាញអកប្បិយនោះឯង ត្បាញអំបោះកប្បិយនិងអកប្បិយ បើចីវរដូចជាខ្នង់ស្រែជាប់គ្នាប៉ុនប្រមាណនៃចីវរខ្នាតតូចយ៉ាងនេះ គឺ ផ្នែកមួយសម្រេចដោយអំបោះកប្បិយសុទ្ធ ៗ ផ្នែកមួយសម្រេចដោយអំបោះអកប្បិយ ។ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ ផ្នែក

ដែលសម្រេចដោយអំបោះអកប្បិយ ។ ត្រូវអាបត្តិទុក្កដក្នុងផ្ទៃកដែលសម្រេចដោយអំបោះ ជាកប្បិយ ក្រៅនេះ យ៉ាងនោះដូចគ្នា ។ បើមានច្រើនផ្ទៃកតូចជាងខ្នាតចីវរដែលគួរវិកប្បជាយ៉ាងទាបនោះ ដោយហោចទៅសូម្បីខ្នាតប៉ុនអណ្តាតភ្លើងក៏ត្រូវអាបត្តិទុក្កដ តាមចំនួនផ្ទៃកគ្រប់ ៗ ផ្ទៃក ។ បើចីវរត្បាញដោយអំបោះដែលឆ្លាស់គ្នាម្តងមួយសរសៃក្តី ត្បាញឱ្យអំបោះកប្បិយនៅមកខាងបណ្តោយ (ផ្ទៃកឈរ) ឱ្យអំបោះអកប្បិយនៅមកខាងទទឹង(ផ្ទៃកផ្តេក)ក្តី, ត្រូវអាបត្តិទុក្កដគ្រប់ផ្ទាំងក្តារកី ។

ពិតមែន កាលភិក្ខុប្រើជាងតម្បាញកប្បិយ ឱ្យត្បាញអំបោះដែលជាអកប្បិយ ត្រូវអាបត្តិទុក្កដ ដូចជានិស្សគ្គិយខាងដើម ។ កាលភិក្ខុឱ្យជាងតម្បាញកប្បិយនោះនុ៎ះឯង ត្បាញអំបោះដែលជាកប្បិយនិងអកប្បិយ បើថា មានផ្ទៃកនៃអំបោះអកប្បិយច្រើនផ្ទៃកខ្នាតប៉ុនចីវរយ៉ាងតូច ឬខ្វះជាង, ក្នុងផ្ទៃកអំបោះអកប្បិយទាំងនោះ ត្រូវអាបត្តិទុក្កដដោយចំនួនផ្ទៃក ។ ក្នុងផ្ទៃកអំបោះដែលជាកប្បិយទាំងឡាយ មិនមានអាបត្តិ ។ បើចីវរត្បាញដោយអំបោះយាំងលំដាប់(ឆ្លាស់)គ្នាម្តងមួយសរសៃ ៗក្តី ត្បាញឱ្យអំបោះកប្បិយនៅមកផ្ទៃកវែង(ផ្ទៃកឈរ) ឱ្យអំបោះអកប្បិយនៅផ្ទៃកទទឹង (ផ្ទៃកផ្តេក)ក្តី, ត្រូវអាបត្តិទុក្កដក្នុងគ្រប់ ៗ ប្រឡោះក្តារកី ។

# ជាងតម្បាញ ២ នាក់ផ្លាស់ប្តូរគ្នាត្បាញ

ក៏បើមានជាងតម្បាញ២នាក់ ម្នាក់ជាកប្បិយ ម្នាក់ជាអកប្បិយ និងអំបោះក៏ជាអកប្បិយ, បើជាងតម្បាញ២នាក់នោះ ផ្លាស់គ្នាត្បាញ, ត្រូវអាបត្តិបាចិត្តិយក្នុងគ្រប់ ៗបន្ទះក្តារកី ដែលជាងតម្បាញអកប្បិយត្បាញ ត្រូវអាបត្តិទុក្កដ ក្នុងចីវរដែលខ្វះចុះមក ។ ត្រូវអាបត្តិទុក្កដ ក្នុងផ្ទែកទាំងពីរដែលជាងតម្បាញកប្បិយក្រៅនេះត្បាញ ។ បើជាងតម្បាញទាំង ២ អ្នកចាប់កីត្បាញជាមួយគ្នា, ត្រូវអាបត្តិទុក្កដក្នុងគ្រប់ ៗបន្ទះក្តារកី ។ បើអំបោះជាកប្បិយ និងចីវរមានផ្ទែកដោយការបាំងដូចខ្នង់ស្រែជាដើម, ត្រូវអាបត្តិទុក្កដគ្រប់ផ្ទែកដែលជាងតម្បាញអកប្បិយ ត្បាញ ។ ក្នុងផ្ទែកដែលជាងតម្បាញកប្បិយក្រៅនេះត្បាញ មិនមានអាបត្តិ ។ បើជាងតម្បាញទាំង ២ នាក់ ចាប់កីត្បាញជាមួយគ្នា ត្រូវអាបត្តិទុក្កដ តាមចំនួនបន្ទះក្តារកី ។ បើសូម្បីអំបោះទាំងកប្បិយទាំងអកប្បិយ, បើជាងតម្បាញទាំងពីរអ្នកនោះផ្លាស់គ្នាត្បាញ, ក្នុងផ្ទែកដែលសម្រេចដោយអំបោះអកប្បិយ មានប្រមាណប៉ុនចីវរខ្នាតតូច ដែលជាងតម្បាញអកប្បិយត្បាញ ត្រូវអាបត្តិបាចិត្តិយ តាមចំនួនផ្ទែក ។ ត្រូវអាបត្តិទុក្កដក្នុងផ្ទែកទាំងឡាយដែលខ្វះពីនោះចុះមក និងដែលសម្រេចដោយអំបោះកប្បិយ ។ ត្រូវអាបត្តិទុក្កដដូចគ្នាក្នុងផ្ទែកដែលសម្រេចដោយអំបោះអកប្បិយ ដែល

បានខ្នាតឬខ្វះចុះមក ដែលជាងតម្បាញកប្បិយត្បាញ ។ ក្នុងផ្នែកដែល សម្រេចដោយអំបោះកប្បិយ មិនមានអាបត្តិ ។

បើជាងតម្បាញទាំង ២ អ្នកត្បាញដោយអំបោះដែលឆ្លាស់គ្នាម្តង មួយសរសៃក្តី ត្បាញឱ្យអំបោះអកប្បិយនៅមកផ្នែកវែង (ផ្នែកឈរ) ឱ្យអំបោះកប្បិយនៅមកផ្នែកទទឹង (ផ្នែកផ្តេក) ក្តី សូម្បីទាំងពីរនាក់ ចាប់កីត្បាញជាមួយគ្នាក្តី, ត្រូវអាបត្តិទុក្កដគ្រប់ ៗ បទុះក្តារកី ក្នុងចីវរ ដែលមិនមានផ្នែក ។ ចំណែកសេចក្តីថា ក្នុងចីវរ ដែលមានផ្នែកត្រូវ អាបត្តិទុក្កដច្រើនដោយអំណាចនៃផ្នែក, នេះមិនប្រាកដក្នុងមហាអដ្ឋកថា ប្រាកដតែក្នុងមហាបច្ចរីជាដើម, ក្នុងអដ្ឋកថា នេះប្រាកដដោយអាការទាំង ពួង មែនពិត ។

បើទាំងអំបោះក៏ជាកប្បិយ ទាំងជាងតម្បាញក៏ជាកប្បិយ គឺ ជា ញាតិ និងជាអ្នកបវារណា ឬភិក្ខុជួលមកដោយមូលតម្លៃ មិនមានអាបត្តិ ព្រោះការប្រើឱ្យត្បាញជាបច្ច័យ ។ តែភិក្ខុកាល នឹងការពារអាបត្តិ ព្រោះ ការកន្លង ១០ ថ្ងៃ ជាបច្ច័យ គប្បីអធិដ្ឋានចីវរដែលត្បាញហើយនុ៎ះឯង ក្នុងកាលដែលជាងតម្បាញត្បាញ បានខ្នាតប៉ុនចីវរដែលគួរវិកប្ប ។ ព្រោះថា ចីវរដែលជាងតម្បាញត្បាញឱ្យសម្រេចចុះដោយកន្លង ១០ ថ្ងៃ ទៅ នឹងជានិស្សគ្គិយ ដូច្នេះឯង ។

សូម្បីក្នុងចីវរដែលពួកញាតិជាដើម លើកតម្បាញឡើង ហើយ

ប្រគល់ប្រគេនថា “លោកដ៏ចម្រើន លោកគប្បីទទួលយកចីវរនេះ ដើម្បីលោក” ក៏មានន័យយ៉ាងនេះដូចគ្នា ។ បើជាងតម្បាញ ដែលភិក្ខុជួលមកយ៉ាងនេះ ឬជាអ្នកប្រាថ្នានឹងប្រគេនដោយខ្លួនឯង ទើបពោលថា “លោកម្ចាស់ ខ្ញុំព្រះករុណានឹងត្បាញចីវរថ្វាយលោក ក្នុងថ្ងៃឈ្មោះឯណោះហើយនឹងរក្សាទុក” ចំណែកភិក្ខុឱ្យកន្លង ១០ ថ្ងៃទៅអំពីថ្ងៃដែលជាងតម្បាញនោះកំណត់ទុក ជានិស្សគ្គិយបាចិត្តិយ ។ តែបើជាងតម្បាញពោលថា “ខ្ញុំព្រះករុណា នឹងត្បាញចីវរប្រគេនលោក” ហើយនឹងបញ្ជូនដំណឹងទៅឱ្យជ្រាប ហើយធ្វើដូចដែលបាននិយាយទុក, តែភិក្ខុដែលគេពឹងពាក់ទៅ មិនប្រាប់ដល់ភិក្ខុនោះ, ភិក្ខុរូបដទៃឃើញ ឬបានឮហើយប្រាប់ថា “លោកម្ចាស់ ចីវររបស់លោកសម្រេចហើយ” ការប្រាប់របស់ភិក្ខុនេះ មិនជាប្រមាណ ។ តែក្នុងវេលាកាលលោកឱ្យកន្លង ១០ ថ្ងៃទៅ ចាប់ផ្តើមតាំងពីថ្ងៃ ដែលលោកបានឮពាក្យរបស់ភិក្ខុ ដែលជាងតម្បាញនោះពឹងពាក់ទៅនុ៎ះឯងប្រាប់ ទើបជានិស្សគ្គិយបាចិត្តិយ ។

បើជាងតម្បាញពោលថា “ខ្ញុំព្រះករុណាត្បាញចីវរ ដើម្បីលោកហើយ នឹងបញ្ជូនទៅប្រគេនក្នុងដៃរបស់ភិក្ខុរូបណាមួយ” ហើយធ្វើតាមដែលនិយាយនោះ, តែភិក្ខុដែលទទួលចីវរទៅរក្សា ទុកត្រង់បរិវេណរបស់ខ្លួន មិនប្រាប់ដល់លោក ភិក្ខុដទៃរូបខ្លះពោលថា “លោកម្ចាស់ ចីវរដែលមកថ្មីស្អាតល្អដែរឬ ?”, លោកពោលថា “ចីវរឯណា

អ្នកមានអាយុ ?” ភិក្ខុនោះទើបឆ្លើយថា ដែលគេបញ្ជូនមកក្នុងដៃនៃភិក្ខុឈ្មោះនេះ, ពាក្យនិយាយស្ដីរបស់ភិក្ខុនេះ ក៏មិនជាប្រមាណ ។ តែកាលណាភិក្ខុនោះប្រគេនចីវរ, កាលលោកឱ្យកន្លង ១០ ថ្ងៃទៅរាប់ពីថ្ងៃដែលខ្លួនបានចីវរ មកនោះ ជានិស្សគ្គិយបាចិត្តិយ ។ តែបើតម្លៃឈ្នួលត្បាញភិក្ខុមិនទាន់បានបង់ឱ្យ, នៅរក្សាដរាបប៉ុនដែលតម្លៃឈ្នួលធ្វើនៅសល់ សូម្បីត្រឹមតែមួយកាកណិក ។

[១៥៦] ពាក្យថា **អនាបត្តិ ចីវរំ សិព្វេតុំ : អាបត្តិមិនមានដល់ភិក្ខុដែលសូមអម្បោះមកដើម្បីដេរចីវរ** មានសេចក្ដីថា មិនមានអាបត្តិដល់ភិក្ខុដែលសូមអំបោះដើម្បីត្រូវការដេរចីវរ ។

ក្នុងចីវរទាំងឡាយមានជាដើមថា សំពត់រឹតជើងជាដើម មានអធិប្បាយថា ពាក្យថា **អាយោគេ : ដើម្បីធ្វើសំពត់អាយោគ** ជាដើម ជាសត្តមីវិភត្តិចុះ ក្នុងអត្ថនៃនិមិត្ត ។ មិនមានអាបត្តិដល់ភិក្ខុដែលសូមអំបោះ មានសំពត់រឹតជើងជាដើមជានិមិត្ត ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ មានអត្ថងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋាន៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សុត្តវិញ្ញត្តិសិក្ខាបទ ចប់

# ៧. មហាបេសការសិក្ខាបទវណ្ណនា

[១៥៧-៨] មហាបេសការសិក្ខាបទថា តេន សមយេន : សម័យនោះ ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងមហាបេសការសិក្ខាបទនោះមានវិនិច្ឆ័យដូចតទៅនេះ ៖

ពីរបទថា សុត្តំ ធារយិត្វា : ចូរនាងថ្លឹងអំបោះ បានដល់ ថ្លឹងអំបោះឱ្យបានកំណត់មួយបល្ល: ។

បទថា អប្បិតំ : ឱ្យសាច់ញឹក គឺ ឱ្យណែន ។

បទថា សុវិតំ : ធ្វើឱ្យស្មើល្អ បានដល់ ឱ្យជារបស់ដែលត្បាញល្អ គឺ ឱ្យជារបស់ដែលត្បាញស្មើក្នុងទីគ្រប់កន្លែង ។

បទថា សុប្បវាយិតំ : រឹតឱ្យតឹងល្អ បានដល់ រឹតឱ្យល្អ គឺ រឹតតម្បាញឱ្យតឹងស្មើគ្រប់ទីកន្លែង ។

បទថា សុវិលេខិតំ : ត្រដោះកូតឱ្យល្អ បានដល់ ឱ្យជារបស់សសោះល្អដោយគ្រឿងសសោះ ។

បទថា សុវិតច្ឆិតំ : សិតឱ្យល្អ ប្រែថា ឱ្យជារបស់សិតដោយស្និត (ដោយប្រាស) ។ អធិប្បាយថា ឱ្យជារបស់ជម្រះរៀបរយ ។

បទថា បដិពទ្ធំ : ចងចំពោះ គឺ សេចក្តីខ្វះខាត ។

បទថា តន្តេ : ស្រីនោះ មានសេចក្តីថា នាំចូលទៅក្នុងតម្បាញ

ដែលសន្ទឹងទៅមកផ្នែកវែង (ខាងបណ្ដោយ)នុ៎ះឯង ។

ប្រែបទថា តត្រ ចេ សោ ភិក្ខុ : បើភិក្ខុនោះ ... ក្នុងរឿងចីវរនោះ សេចក្ដីថា ក្នុងស្រុក ឬនិគមដែលពួកជាងតម្បាញទាំងនោះ ។

ពីរបទថា វិកប្បំ អាបជ្ជេយ្យ : ហើយដល់នូវកិរិយាកំណត់ មានសេចក្ដីថា ដល់សេចក្ដីកំណត់ពិសេស គឺ ចាត់ចែងយកយ៉ាងក្រៃលែង ។ តែក្នុងបាលី ដើម្បីទ្រង់សម្ដែងអាការដែលជាហេតុឱ្យភិក្ខុដល់សេចក្ដីកំណត់យក ទើបព្រះមានព្រះភាគត្រាស់ថា ឥទំ ខោ អាវុសោ : នៃអ្នកមានអាយុ (ចីវរ)នេះ ជាដើម ។

ពីរបទថា ធម្មំបិ ភណតិ : ភិក្ខុសម្ដែងធម៌ឱ្យស្ដាប់ក្ដី បានដល់ ពោលធម្មកថា ។ ព្រះមានព្រះភាគទ្រង់សម្ដែងអាការ គឺ ការបន្ថែមអំបោះប៉ុណ្ណោះ ដោយពាក្យថា គេធ្វើឱ្យវែងក្ដី ឱ្យធំក្ដី ឱ្យណែនក្ដី តាមពាក្យរបស់ភិក្ខុនោះ ។

ពីរបទថា បុព្វេ អប្បវារិតោ : គេមិនបានបវារណាមកពីមុន បានដល់ ជាអ្នកដែលម្ចាស់នៃចីវរទាំងឡាយមិនបានបវារណាទុកមុន ។ ពាក្យដែល នៅសល់មានអត្ថងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះ មានសមុដ្ឋាន៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

មហាបេសការសិក្ខាបទ ចប់

# ៨. អច្ចេកចីវរសិក្ខាបទវណ្ណនា

[១៦០] អច្ចេកចីវរសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងអច្ចេកចីវរសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា ទសាហានាគតំ : ខ្វះ ១០ ថ្ងៃទៀត មានសេចក្តីថា ថ្ងៃទាំងឡាយ ១០ ឈ្មោះថា ទសាហៈ ។ (ថ្ងៃបុណ្ណមីដែលគ្រប់ ៣ ខែ នៃខែកត្តិក) ១០ថ្ងៃ នោះ នៅមិនទាន់មកដល់ ឈ្មោះថា ទសាហានាគតៈ ។ អធិប្បាយថា មិនទាន់មកដល់ ១០ ថ្ងៃ ។ ក្នុងថ្ងៃបុណ្ណមីដែលមិនទាន់មកដល់ ១០ ថ្ងៃនោះទៀត ។ ទុតិយាវិភត្តិចុះក្នុងអត្ថនៃសត្តមីវិភត្តិ ដោយអំណាចនៃអច្ចន្តសំយោគ ។ ព្រោះហេតុនោះឯង ក្នុងបទភាជនៈនៃបទថា ទសាហានាគតំ នោះ ទើបត្រាស់ថា "ទសាហានាគតាយ : នៅខ្វះ ១០ ថ្ងៃទៀត" ។

[១៦២] ក៏ពាក្យថា បវារណាយ : ទឹងដល់ថ្ងៃបវារណា នេះជាពាក្យប្រកបតាមក្រោយ ដើម្បីសេចក្តីមិនសង្ស័យ ដើម្បីសម្តែងបវារណា ដែលត្រាស់ទុកថា ទសាហានាគតា ដោយសរុប ។

# អធិប្បាយការកើតនៃអច្ចេកចីវរ

បទថា កត្តិកតេមាសិកបុណ្ណមំ : ថ្ងៃពេញបូណ៌មីនៃខែកត្តិក ដែលជាខែទី៣ នៃវស្សានរដូវ បានដល់ ថ្ងៃបុណ្ណមីដែលគ្រប់ ៣ ខែ នៃខែកត្តិកដើម (គឺខែអស្សុជ) ។ សូម្បីក្នុងបទថា កត្តិកតេមាសិកបុណ្ណមំ នេះ ក៏ជាទុតិយាវិភត្តិចុះ ក្នុងអត្ថនៃសត្តមីវិភត្តិដោយន័យមុនដូចគ្នា ព្រោះប្រកបតាមក្រោយបទដើម ។ មានពាក្យអធិប្បាយថា ថ្ងៃមហាបវារណាដំបូង ត្រាស់ហៅថា **ទសាហានាគតា** តាំងពីកាលណាទៅ, បើសូម្បីថា អច្ចេកចីវរ គប្បីកើតឡើងដល់ភិក្ខុពិតប្រាកដរហូតដល់អស់ថ្ងៃទាំងនោះតែម្តង (ក្នុង១០ ថ្ងៃនោះ ថ្ងៃណាមួយ) ។ ភិក្ខុដឹងថា នេះជាអច្ចេកចីវរ (ចីវរប្រញាប់ប្រញាល់) គប្បីទទួលទុកបានសូម្បីទាំងអស់ ។

ដោយពាក្យថា ទសាហានាគតំ កត្តិកតេមាសិកបុណ្ណមំ នោះ ជាការព្រះអង្គទ្រង់សម្តែងកាលជាទីរក្សាចីវរដែលកើតឡើង ពីដើមដំបូង តាំងពីថ្ងៃទី ៥ នៃជុណ្ហបក្ខរបស់ខែបវារណា ។ ក៏កាលជាទីរក្សាចីវរនោះសម្រេចដោយពាក្យថា គប្បីទ្រទ្រង់អតិរេក ចីវរបាន ១០ ថ្ងៃ ជាយ៉ាងក្រៃលែងនេះ ក៏ពិតហើយ តែទ្រង់សម្តែងរឿងដូចមិនធ្លាប់មាន

ដោយអំណាចនៃរឿងដែលកើតឡើង ហើយទ្រង់តាំងសិក្ខាបទទុក ។

ចីវរប្រញាប់ប្រញាល់ ត្រាស់ហៅថា "**អច្ចេកចីវរ : ចីវរដែលបុគ្គលធ្វើដោយរួសរាន់**" ។ ក៏ដើម្បីសម្ដែងចីវរនោះ ជាសំពត់ប្រញាប់ប្រញាល់ ទើបត្រាស់ពាក្យថា បុគ្គលប្រាថ្នានឹងទៅក្នុងកងទ័ពក្ដីជាដើម ។

បណ្ដាបទទាំងនោះ ដោយបទថា សទ្ធា នេះ ទ្រង់សម្ដែងហេតុត្រឹមតែសទ្ធាធម្មតាប៉ុណ្ណោះ ។

ដោយបទថា **បសាទោ : សេចក្ដីជ្រះថ្លា** នេះ ទ្រង់សម្ដែងសទ្ធាយ៉ាងខ្លាំងក្លា មានសេចក្ដីថ្លាផូរផង់ល្អ ។

ចីវរដែលទាយកមានសេចក្ដីប្រាថ្នានឹងប្រគេន ដោយហេតុទាំងនេះ ទើបបញ្ជូនទូតមក ឬមកប្រាប់ខ្លួនឯងយ៉ាងនេះថា ខ្ញុំព្រះករុណាប្រគេនសំពត់ចាំណាំវស្សា បានឈ្មោះថា អច្ចេកចីវរ ក្នុងពាក្យថា **ឯតំ អច្ចេកចីវរំ ឆាម : ចីវរនេះ ឈ្មោះថា ចីវរដែលបុគ្គលធ្វើដោយរួសរាន់** នេះឯង ។ តែចំពោះចីវរដែលភិក្ខុបច្ចុទ្ធរណ៍ (ដក) សូម្បីនូវចីវរដែលមិនមែនជាអច្ចេកចីវរ ដែលកើតឡើងតាំងពីថ្ងៃ ៦ ហើយរក្សាទុកក៏បានបរិហារនេះដូចគ្នា ។

ច្រើនបទថា **សញ្ញាណំ កត្វា និក្ខិបិតព្វំ :** **ភិក្ខុត្រូវធ្វើសេចក្តីសំគាល់ ហើយទុកដាក់ចុះ** បានដល់ គប្បីធ្វើគ្រឿងចំណាំយ៉ាងណាមួយហើយ រក្សាទុក ។ ពាក្យថា គប្បីធ្វើគ្រឿងចំណាំហើយរក្សាទុកនេះ ព្រះមានព្រះភាគត្រាស់ ទុកដូចម្តេច ? ព្រោះថា បើភិក្ខុទាំងឡាយចែកអច្ចេកចីវរនោះមុនថ្ងៃបវារណា, ភិក្ខុដែលបានសំពត់អច្ចេកចីវរនោះទៅ ត្រូវមិនជាអ្នកដាច់វស្សា ។ តែបើជាអ្នកដាច់វស្សា ចីវរនឹងក្លាយជារបស់សង្ឃមែនពិត ; ព្រោះដូច្នោះ នឹងត្រូវកំណត់ចែកឱ្យល្អ ; ( ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះទុក ) ។

[១៦៣] ពាក្យយ៉ាងនេះថា **អច្ចេកចីវរំ អច្ចេកចីវរសញ្ញី :** **អចេកចីវរពិតមែន ភិក្ខុក៏សំគាល់ថា ជាអចេកចីវរ** ជាដើម ព្រះមានព្រះភាគត្រាស់សំដៅយកតែចីវរដែលចែកគ្នាទៅ ហើយកាន់យក ។ តែបើមិនទាន់បានចែកគ្នា ឬជាចីវរដែលរក្សាទុកក្នុងឃ្លាំងរបស់សង្ឃ, សូម្បីព្រោះកន្លងសម័យទៅ ក៏មិនមានអាបត្តិ ។ អតិរេកចីវរបានបរិហារ ១០ ថ្ងៃ ដោយប្រការដូច្នេះ ត្រៃចីវរមិន មានបរិហារឡើយ សូម្បីមួយថ្ងៃ ។

អ្នកសិក្សាគប្បីជ្រាបថា ចីវរ គឺ សំពត់ងូតទឹកភ្លៀងដែលមិនទាន់បានធ្វើ កាលមិនបានក្រាលកឋិន បានបរិហារ ៥ ខែ, កាលបន្ថែម

រដូវភ្លៀង (បន្ថែមអធិកមាស)បានបរិហារ ៦ ខែ, កាលបានក្រាលកឋិនបានបរិហារ ៤ ខែទៀត, បានបរិហារមួយខែទៀត ដោយអំណាចការអធិដ្ឋានឱ្យជាចីវរដើម កាលមានសេចក្ដីប្រាថ្នានឹងបាន (សំពត់) ក្នុងថ្ងៃចុងបង្អស់នៃហេមន្តរដូវ រួមជាបរិហារ ១១ ខែយ៉ាងនេះ ។ អច្ចេកចីវរ កាលមិនបានក្រាលកឋិន បានបរិហារ ១ ខែនិង ១១ ថ្ងៃ, កាលបានក្រាលកឋិន បានបរិហារ ៥ ខែនិង ១១ ថ្ងៃ, តពីនោះទៅមិនបានបរិហារ សូម្បីមួយថ្ងៃ ។

បទថា អនច្ចេកចីវរេ : **មិនមែនជាអចេកចីវរ** បានដល់ ក្នុងចីវរដទៃដែលដូចនឹងអច្ចេកចីវរ ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះ ជាកឋិនសមុដ្ឋាន ជាអកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

អច្ចេកចីវរសិក្ខាបទ ចប់

# ៩. សាសង្កសិក្ខាបទវណ្ណនា

[១៦៥] សាសង្កសិក្ខាបទថា តេន សមយេន : សម័យនោះ ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងសាសង្កសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ពីរបទថា វុដ្ឋវស្សា អារញ្ញកេសុ : នៅចាំវស្សាហើយ ក្នុងព្រៃ មានសេចក្តីថា ភិក្ខុទាំងឡាយនោះ សូម្បីក្នុងកាលមុន ក៏នៅក្នុងព្រៃដូចគ្នា ។ តែភិក្ខុទាំងនោះ នៅចាំវស្សាក្នុងសេនាសនៈជិតស្រុក ដោយអំណាចនៃបច្ច័យ ព្រោះជាអ្នកមានចីវរគ្រាំគ្រា ជាអ្នកមានចីវរសម្រេចហើយ ប្រឹក្សាគ្នាថា ឥឡូវនេះ ពួកយើងអស់កង្វល់ហើយ នឹងធ្វើសមណធម៌ ទើបនាំគ្នានៅក្នុងសេនាសនៈព្រៃ ។

បទថា កត្តិកចោរកា : ពួកចោរខែកត្តិក បានដល់ ពួកអ្នកដែលធ្វើចោរកម្មក្នុងខែ ១២ ។

បទថា បរិបាតេន្តិ : ហើយក៏នាំគ្នាបៀតបៀន មានសេចក្តីថា រមែងរុកកួន គឺ រត់ខ្វាត់ខ្វែងទៅមកក្នុងទីនោះ ហើយធ្វើឱ្យកត់ស្លុត ឱ្យគេចទៅ ។

បទថា អន្តរឃរេ និក្ខិបិតុំ : ឱ្យទុកក្នុងចន្លោះផ្ទះបាន បានដល់ ដើម្បីរក្សាទុកនៅខាងក្នុងស្រុក ។ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឱ្យរក្សាទុកក្នុងចន្លោះស្រុក ដើម្បីថែទាំចីវរទុក ព្រោះធម្មតាថា បច្ច័យ

ទាំងឡាយ ជារបស់រកបានលំបាកប្រកបដោយធម៌, ពិតមែន ភិក្ខុដែលមានសេចក្ដីជុសខាត់ មិនអាចសូមចីវរ សូម្បីចំពោះមាតា ។ តែព្រះអង្គទ្រង់មិនហាមការនៅព្រៃ ព្រោះជាការសមគួរដល់ភិក្ខុទាំងឡាយ ។

ក្នុងពាក្យថា ឧបវស្សំ ខោ បន : **កាលបើភិក្ខុទាំងឡាយ ចាំវស្សារួចហើយ** នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា ឧបវស្សំ : **ចាំវស្សារួចហើយ** គឺ ចូលទៅនៅហើយ ។ មានពាក្យអធិប្បាយថា ចូលទៅនៅចាំវស្សាហើយ ។ ពិតមែន បណ្ឌិតគប្បីឃើញនិគ្គហិតក្នុងពាក្យថា ឧបវស្សំ នេះ ដូចក្នុងពាក្យមានពាក្យថា ឧបសម្បជ្ជំ ជាដើម ។ សេចក្ដីថា ចូលដល់រដូវភ្លៀងនិងនៅហើយ (ចូលចាំវស្សានិងបវារណាហើយ) ។ និងបទថា ឧបវស្សំ នេះ សម្ពន្ធដោយពាក្យនេះថា តថារូបេសុ ភិក្ខុ សេនាសនេសុ វិហរន្តោ : **កាលភិក្ខុនៅក្នុងសេនាសនៈទាំងឡាយ មានសភាពដូច្នោះ** ។ លោកពោលអធិប្បាយទុកយ៉ាងណា ?

លោកពោលទុកថា ភិក្ខុចូលដល់រដូវភ្លៀងនិងនៅហើយ (ចូលចាំវស្សា និងបវារណាហើយ) ទឹងនៅក្នុងសេនាសនៈព្រៃដែលដឹងថា "ជាទីរង្កៀស មានភ័យចំពោះមុខបែបនោះ រហូតដល់អស់កាលជាទីបំផុត នៃថ្ងៃពេញបូណ៌មី ខែកត្តិកក្រោយ តពីនោះមក កាលប្រាថ្នាគប្បី

រក្សាចីវរ ៣ ផ្ទាំងណាមួយទុកក្នុងចន្លោះស្រុកបាន” ។

មួយទៀត ព្រោះថា ភិក្ខុណា ចូលចាំវស្សាហើយ នៅមកដរាបដល់ថ្ងៃពេញបូណ៌មី ខែកត្តិកដើម, ភិក្ខុរូបនោះ ជាអ្នកនៅខាងក្នុងនៃពួកភិក្ខុដែលនៅចាំវស្សាហើយ ; ដូច្នោះ ព្រះមានព្រះភាគកាលទ្រង់មិនធ្វើការវិចារណាព្យញ្ជនៈដែលសាំញ៉ាំក្រៃលែងនេះ សម្ដែងបុគ្គលដែលគួរដល់ការរក្សាចីវរតែម្យ៉ាងក្នុងបទភាជនៈ ទើបត្រាស់ពាក្យថា វុដ្ឋវស្សានំ ដូច្នេះ ។ ចំពោះបទថា វុដ្ឋវស្សានំ នោះ ក៏សម្ព័ន្ធនឹងពាក្យនេះថា ភិក្ខុកាលនៅក្នុងសេនាសនៈ ។ ពិតមែន ក្នុងពាក្យថា វុដ្ឋវស្សានំ នេះ មានសេចក្ដីដូច្នេះថា នៅក្នុងសេនាសនៈទាំងឡាយ របស់ពួកភិក្ខុដែលនៅចាំវស្សាហើយ ។ មានពាក្យអធិប្បាយថា ភិក្ខុរូបណា មួយនៅខាងក្នុងនៃភិក្ខុទាំងឡាយ មានសភាពបែបនេះ ។ លក្ខណៈនៃព្រៃ ខ្ញុំព្រះករុណាបានពោលហើយក្នុងវណ្ណនានៃអទិន្នាទាន ។

ចំណែកសេចក្ដីប្លែកគ្នាដូចតទៅនេះ ៖

បើថា វត្តមានរបង គប្បីវាស់តាំងពីសរសេរខឿននៃស្រុកដែលមានរបង និងអំពីស្ថានទីគួរលោមព័ទ្ធនៃស្រុកដែលមិនបានធ្វើរបងទៅ ដរាបដល់របងវត្ត ។ បើជាវត្តដែលមិនបាន ធ្វើរបង, ជាស្ថានទីណាដែលនៅខាងដើមគេ ទោះជាសេនាសនៈក្ដី រោងអាហារក្ដី ស្ថានទីប្រជុំជាប្រចាំក្ដី ដើមពោធិព្រឹក្សក្ដី ចេតិយក្ដី, បើសូម្បីមាននៅឆ្ងាយពីសេនាសនៈ, គប្បី

វាស់យកទីនោះឱ្យជាខេត្តកំណត់ ។

បើសូម្បីថា មានភូមិនៅជិត, ពួកភិក្ខុនៅក្នុងវត្ត រមែងបានឮសំឡេងរបស់ពួកអ្នកស្រុក, តែមិនអាចនឹងទៅមកត្រង់បាន ព្រោះមានភ្នំនិងទន្លេជាដើមនៅឃាំង ។ និងមកណាជាមកតាមប្រក្រតីរបស់ស្រុកនោះ បើសូម្បីនឹងត្រូវទៅដោយទូក, ក៏គប្បីកំណត់យកប្រាំរយធ្នូ អំពីស្រុកដោយមកនោះ ។ តែភិក្ខុណា បិទមកក្នុងទីនោះ ៗ ដើម្បីញ៉ាំងស្រុកជិតឱ្យដល់ព្រមដោយអង្គ ភិក្ខុនេះគប្បីជ្រាបថា ធុតង្គចោរ ។

បទថា សាសង្កសម្មតានិ : ដែលគេសន្មតថា ជាទីមានសេចក្តីរង្កៀស បានដល់ សន្មតឱ្យដឹងគ្រប់គ្នាថា ជាទីមានរង្កៀស ។ អធិប្បាយថា គេដឹងហើយយ៉ាងនោះ ។ តែក្នុងបទភាជនៈ ដើម្បីទ្រង់សម្តែងហេតុឱ្យសេនាសនៈទាំងនោះ ជាទីដឹងគ្រប់គ្នាថា ជាទីមានរង្កៀស ទើបត្រាស់ពាក្យមានជាដើមថា អារាមេ អារាមូបចារេ : ក្នុងអារាម ឬ ក្នុងឧបចារអារាម ជាដើម ។ សេនាសនៈដែលប្រព្រឹត្តទៅនឹងដោយភ័យចំពោះមុខ ឈ្មោះថា សប្បដិភយៈ (មានភ័យចំពោះមុខ) ។ អធិប្បាយថា មានភ័យកាចសាហាវខ្លាំងក្លា ។ តែក្នុងបទភាជនៈ ដើម្បីទ្រង់សម្តែងហេតុឱ្យសេនាសនៈទាំងនោះ ជាទីមានភ័យចំពោះមុខ ទើបត្រាស់ពាក្យថា អារាមេ អារាមូបចារេ ជាដើម ។

[១៦៦] ពាក្យថា សមន្តា គោចរគាមេ និក្ខិបេយ្យ : គប្បី

ទុកក្នុងស្រុកជាទីគោចរដោយជុំវិញបាន មានសេចក្ដីថា កាលមានអង្គគ្រប់គប្បីរក្សាទុក ក្នុងគោចរគ្រាមដែលខ្លួនពេញចិត្ត ក្នុងទិសាភាគដោយជុំវិញនៃសេនាសនៈព្រៃ ។

ក្នុងសេនាសនៈព្រៃនោះ មានអង្គសម្បត្តិដូចតទៅនេះ ៖

ភិក្ខុចូលវស្សា ក្នុងថ្ងៃចូលវស្សាដំបូង បវារណាក្នុងថ្ងៃមហាបវារណា, នេះជាអង្គមួយ ។ បើភិក្ខុចូលវស្សាក្នុងថ្ងៃចូលវស្សាក្រោយក្ដី មានវស្សាដាច់ក្ដី រមែងមិនបានដើម្បីរក្សាទុក ។ ជាខែ១២ ប៉ុណ្ណោះ, នេះជាអង្គទី ២ ។ ក្រៅអំពីខែ១២ ទៅ រមែងមិនបានដើម្បីរក្សា ។ ជាសេនាសនៈដែលប្រកបដោយប្រមាណយ៉ាងទាប ៥០០ ធ្នូប៉ុណ្ណោះ, នេះជាអង្គទី៣ ។ ក្នុងសេនាសនៈដែលមានចម្ងាយខ្វះ ឬមានចម្ងាយលើសមួយគាវុតទៅ រមែងមិនបាន (ដើម្បីរក្សាទុក) ។ ពិតមែន ភិក្ខុត្រាច់បិណ្ឌបាត ហើយអាចត្រឡប់មកកាន់វត្តទាន់វេលាឆាន់ ក្នុងសេនាសនៈណា, សេនាសនៈនោះ ទ្រង់ប្រាថ្នាយកក្នុងសិក្ខាបទនេះ ។ តែភិក្ខុដែលទទួលនិមន្តទុកទៅអស់មកកន្លះយោជន៍ខ្វះ មួយយោជន៍ខ្វះ ហើយត្រឡប់មកដើម្បីនៅ ។ ទីនេះមិនជាប្រមាណ ។ ជាសេនាសនៈមានសេចក្ដីរង្កៀស និងមានភ័យចំពោះមុខប៉ុណ្ណោះ, នេះជាអង្គទី ៤ ពិតមែន ភិក្ខុដែលនៅក្នុងសេនាសនៈ មិនមានសេចក្ដីរង្កៀស មិនមានភ័យចំពោះមុខសូម្បីប្រកបដោយអង្គ ក៏មិនបាន ដើម្បីរក្សាទុក ដូច្នេះឯង ។

ពីរបទថា អញ្ញត្រ ភិក្ខុសម្មតិយា : វៀរលែងតែភិក្ខុដែលបានសេចក្ដីសន្មតអំពីសង្ឃ មានសេចក្ដីថា វៀរទុកតែកោសម្ពិកសម្មតិដែលទ្រង់អនុញ្ញាតទុកក្នុងឧទ្ទោសិតសិក្ខាបទ ។ ក៏បើថា មានភិក្ខុបានសន្មតនោះសោត, នឹងនៅ ប្រាសចាកលើស ៦ រាត្រីទៅក៏បាន ។

[១៦៨] ពាក្យថា បុន គាមសីមំ ឱក្កមិត្វា : ហើយត្រឡប់មកកាន់ដែននៃស្រុកនោះវិញ មានសេចក្ដីថា បើមានសេនាសនៈនៅមកទិសខាងកើតអំពីគោចរគ្រាម និងភិក្ខុនេះ នឹងទៅកាន់ទិសខាងលិច, លោកមិនអាចនឹងមកកាន់សេនាសនៈឱ្យទាន់អរុណទី ៧ រះឡើង ឆៀងចុះកាន់សូម្បីគាមសីមាសម្រាកក្នុងសភាឬក្នុងទីកន្លែងណាមួយ ជ្រាបដំណឹងនៃចីវរហើយ ទើបចៀសចេញទៅគួរ ។

ភិក្ខុដែលមិនអាចយ៉ាងនោះ គប្បីឈរក្នុងទីដែលខនទៅ ហើយនោះឯង បច្ចុទ្ធរណ៍ (ដក) ចេញ ។ ចីវរនឹងតាំងនៅ ក្នុងឋាននៃអតិរេកចីវរ ដូច្នេះឯង ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះ ងាយយល់ទាំងអស់នោះឯង ។

សិក្ខាបទនេះ ជាកឋិនសមុដ្ឋាន កើតអំពីកាយវាចា ១ កាយវាចាចិត្ត ១ ជាអកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្មវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

សាសង្កសិក្ខាបទ ចប់

# ១០. បរិណតសិក្ខាបទវណ្ណនា

[១៦៩] បរិណតសិក្ខាបទថា តេន សមយេន : សម័យនោះជាដើម ខ្ញុំព្រះករុណានឹងពោលតទៅ ។ ក្នុងបរិណតសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា បូគស្ស : ប្រជុំជន គឺ ពួកជន ។ សេចក្ដីថា ក្រុមអ្នកបំពេញធម៌ ។

បទថា បដិយត្តំ : តាក់តែង គឺ តាក់តែងហើយ ។

ដោយពាក្យថា ពហូ សង្ឃស្ស ភត្តា : ចង្ហាន់របស់សង្ឃក៏មានច្រើន នេះ ពួកភិក្ខុឆព្វគ្គិយ រមែងសម្ដែងអត្ថន័យថា សង្ឃមានភត្តច្រើនណាស់ គឺមានមកកើតលាភមិនមែនតិច សង្ឃមិនខ្វះខាតដោយអ្វី ៗ ។

បទថា ឱណោជេថ : ពួកលោកចូរប្រគេន គឺ ចូរឱ្យ ។

សួរថា ក៏ការដែលភិក្ខុពោលយ៉ាងនេះ គួរឬ ?

ឆ្លើយថា មានរឿងអ្វី ថា មិនគួរ ? ព្រោះថា ភិក្ខាដែលគេនាំមកចំពោះនេះ ជារបស់ដែលគេនាំមកតាក់តែងទុក ដើម្បីប្រយោជន៍ដល់សង្ឃក្នុងមួយគ្រា ។ ធម្មតាបយុត្តវាចា (ការបេញមាត់សូម) រមែងមិនមានក្នុងបច្ច័យមានចីវរជាដើម ដែលគេនាំមកត្រៀមទុក និងក្នុងចំណែកដែលគេតាំងចំពោះទុក ។

# អធិប្បាយលាភសង្ឃនិងការបង្អោនលាភសង្ឃ

បទថា **សង្ឃិកំ : របស់សង្ឃ** បានដល់ របស់មាននៅនៃសង្ឃ ។ ពិតមែន លាភនោះសូម្បីមិនទាន់ដល់ដៃ ក៏ចាត់ថា ជារបស់សង្ឃដោយបរិយាយមួយ ព្រោះគេបង្អោនទៅដើម្បីសង្ឃហើយ, តែក្នុងបទភាជនៈ ព្រះឧបាលីសម្តែងលាភរបស់សង្ឃដោយត្រង់តែម្តង ដោយអំណាចនៃការពង្រីកសេចក្តី យ៉ាងនេះថា ដែលឈ្មោះថា របស់សង្ឃ បានដល់ របស់ដែលគេប្រគេនហើយ បរិច្ចាគហើយដល់សង្ឃ ។

ព្រះមានព្រះភាគត្រាស់វត្ថុដែលសង្ឃគួរបាន ដោយបទថា លាភំ ។ ព្រោះហេតុនោះឯង ក្នុងនិទ្ទេសនៃបទថា លាភំ នោះ ទើបត្រាស់ពាក្យថា **ចីវរំបិ** ជាដើម ។

បទថា **បរិណតំ : ដែលគេនឹងបង្អោនទៅ** បានដល់ ដែលគេប្រគេនសង្ឃ គឺ ដែលគេតម្កល់ទុកជារបស់បង្អោនទៅដើម្បីសង្ឃប្រគល់ទៅដើម្បីសង្ឃ ។ ក៏ដើម្បីទ្រង់សម្តែងហេតុដែលគេបង្អោនលាភនោះទៅ ទើបព្រះមានព្រះភាគត្រាស់បទភាជនៈថា “**ទស្សាម ករិស្សាមាតិ វាចា ភិន្នា ហោតិ : គឺ ម្ចាស់ទានបញ្ចេញវាចាថា ពួកយើងនឹងឱ្យ ពួកយើងនឹងធ្វើ**” ដូច្នេះ ។

[១៧០] ពីរបទថា បយោគេ ទុក្កដំ : ត្រូវអាបត្តិទុក្កដ តាមប្រយោគ មានសេចក្តីថា ត្រូវអាបត្តិទុក្កដ គ្រប់ប្រយោគដែលបង្អោនលាភ ដែលគេបង្អោនទៅ (ដើម្បីសង្ឃ) មកដើម្បីខ្លួន ៗ ជានិស្សគ្គិយព្រោះបានមកគឺ ព្រោះលាភនោះដល់ដៃ ។ តែបើថា របស់នោះ ជារបស់ដែលគេប្រគេនសង្ឃហើយ ។ ទឹងទទួលយករបស់ដែលគេប្រគេនសង្ឃ ហើយនោះមក មិនគួរ, គប្បីប្រគេនដល់សង្ឃនោះឯង ។ ក៏ភិក្ខុណា ចូលដៃជើងជាមួយនឹងពួកអារាមិកជនទំពាស៊ីក្នុងទីជាមួយគ្នា, សង្ឃគប្បីឱ្យវាយតម្លៃភណ្ឌៈនោះ ពិន័យអាបត្តិដល់ភិក្ខុនោះ ។ តែជានិស្សគ្គិយ បាចិត្តិយដល់ភិក្ខុដែលដឹងថា លាភគេបង្អោនទៅដើម្បីសង្ឃហើយ បង្អោនលាភដែលគេបង្អោនទៅហើយ របស់ពួកសហធម្មិកក្តី របស់ពួកគ្រហស្ថក្តី ដោយហោចទៅ សូម្បីរបស់មាតាមកដើម្បីខ្លួនថា លោកចូរឱ្យវត្ថុនេះដល់យើងហើយកាន់យក ។ ត្រូវអាបត្តិបាចិត្តិយសុទ្ធ ៗ ដល់ភិក្ខុដែលបង្អោនទៅដើម្បីអ្នកដទៃយ៉ាងនេះថា លោកចូរឱ្យដល់ភិក្ខុនេះ ។ ភិក្ខុបង្អោនបាត្រមួយ ឬចីវរមួយផាំងដើម្បីខ្លួន, បង្អោនបាត្រមួយ ឬចីវរមួយផាំង ដើម្បីអ្នកដទៃ, ជានិស្សគ្គិយបាចិត្តិយផង ជាសុទ្ធិកបាចិត្តិយផង ។ ក្នុងបាត្រ និងចីវរច្រើន ក៏មានន័យយ៉ាងនេះដូច

គ្នា ។ សេចក្តីនេះសមដូចពាក្យដែលព្រះឧបាលិថេរៈពោលទុកថា ៖

"ភិក្ខុត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ និងសុទ្ធកបាចិត្តិយ ក្នុងខណៈជាមួយគ្នា ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ"[១] ។

ក៏បញ្ហានេះ លោកពោលសំដៅយកការៈបង្អោន (លាភ) ។ ចំណែកភិក្ខុណាជ្រាបថា សំពត់ងូតទឹកភ្លៀង គេបង្អោនទៅដើម្បីសង្ឃ សូម្បីក្នុងផ្ទះរបស់មាតា ក្នុងសម័យនៃសំពត់ងូតទឹកភ្លៀង ហើយបង្អោនយកទៅដើម្បីខ្លួន, ជានិស្សគ្គិយដល់ភិក្ខុនោះ បង្អោនទៅដើម្បីអ្នកដទៃ ត្រូវអាបត្តិបាចិត្តិយសុទ្ធ ។ ពួកអ្នកស្រុកប្រឹក្សាគ្នាថា ពួកយើងនឹងធ្វើសង្ឃភត្ត ទើបនាំទឹកដោះថ្លា និងប្រេងជាដើមមក ។ បើសូម្បីភិក្ខុអាពាធ ដឹងថា គេបង្អោនទៅដើម្បីប្រគេនសង្ឃហើយ នៅតែសូម វត្ថុណាមួយ ជានិស្សគ្គិយបាចិត្តិយដូចគ្នា ។ ក៏បើភិក្ខុអាពាធនោះសួរថា "ទឹកដោះថ្លា ជាដើមរបស់ពួកលោកដែលនាំមក មានដែរឬ ?" កាលពួកគេឆ្លើយថា "មានលោកម្ចាស់" ហើយពោលថា "ពួកលោកចូរឱ្យដល់យើងខ្លះ" ដូច្នេះ សមគួរ ។ បើសូម្បីពួកឧបាសក វង្វៀសភិក្ខុអាពាធនោះ និយាយថា

១. វិន. បរិ. សេទមោចនគាថា. ១៣. ៣៩៥/៤០៦ ។

"សូម្បីសង្ឃ រមែងបានទឹកដោះថ្លាជាដើមដែលពួកយើងប្រគេននេះឯង ។ និមន្តលោកទទួលចុះ លោកម្ចាស់" សូម្បីយ៉ាងនេះ ក៏គួរ ។

ពាក្យថា សង្ឃស្ស បរិណតំ អញ្ញសង្ឃស្ស : លាភដែលទាយកបង្អោនទៅដើម្បីសង្ឃហើយ (ភិក្ខុបង្អោនទៅ) ដើម្បីសង្ឃដទៃ មានសេចក្ដីថា បង្អោនលាភដែលគេបង្អោនទៅដើម្បីប្រគេនសង្ឃក្នុងវត្តមួយ ឬដែលគេបង្អោនទៅចំពោះវត្តដទៃដោយនិយាយថា "ពួកលោកចូរប្រគេនដល់សង្ឃក្នុងវត្តឈ្មោះឯណោះ" ។

បទថា ចេតិយស្ស វា : ដើម្បីចេតិយក្ដី មានសេចក្ដីថា បង្អោនទៅដើម្បីចេតិយ យ៉ាងនេះថា "ប្រគេនសង្ឃមានប្រយោជន៍អ្វី ពួកលោកចូរធ្វើការបូជាដល់ចេតិយ" ដូច្នេះក្ដី ។

ក្នុងពាក្យថា ចេតិយស្ស បរិណតំ : លាភដែលទាយកបង្អោនទៅដើម្បីចេតិយហើយ នេះ មានវិនិច្ឆ័យដូច្នេះ ៖

សូម្បីនឹងបូជាផ្កាឈើដល់ចេតិយដទៃ អំពីដើមផ្កាឈើ ដែលគេដាំទុក ដើម្បីប្រយោជន៍ដល់ចេតិយដទៃ ក៏មិនគួរ ។ តែឃើញឆត្រ ឬទង់ផ្ទាំងសំពត់ដែលគេបូជាទុកដល់ចេតិយមួយ ហើយឱ្យប្រគេនរបស់ដ៏សេសដល់ចេតិយដទៃ សមគួរ ។

ពីរបទថា **បុគ្គលស្ស បរិណាតំ : លាភដែលទាយកបង្អោនទៅដើម្បីបុគ្គល** មានសេចក្ដីថា ដោយហោចទៅ សូម្បីអាហារដែលគេបង្អោនទៅដើម្បីសុនខ ភិក្ខុបង្អោនទៅដើម្បីបុគ្គលដទៃយ៉ាងនេះថា "លោកកុំឱ្យដល់សុនខនេះ ចូរឱ្យសុនខនោះ" ដូច្នេះ ក៏ជាអាបត្តិទុក្កដ ។ តែបើពួកទាយកពោលថា "ពួកយើងប្រាថ្នានឹងប្រគេនភត្តដល់សង្ឃ, ចង់ធ្វើការបូជាព្រះចេតិយ, ប្រាថ្នានឹងប្រគេនបរិក្ខារដល់ភិក្ខុមួយរូប, នឹងប្រគេនតាមសេចក្ដីពេញចិត្តរបស់ពួកលោកម្ចាស់, សូមលោកម្ចាស់មេត្តាប្រាប់, ពួកយើងនឹងប្រគេនក្នុងទីណា ?" កាលពួកទាយកពោលយ៉ាងនេះហើយ ភិក្ខុនោះ គប្បីប្រាប់ពួកគេថា "ពួកអ្នកចូរប្រគេនក្នុងទីដែលពួកអ្នកប្រាថ្នា" ។ តែបើពួកទាយកសួរថា "ពួកខ្ញុំព្រះករុណា នឹងប្រគេនក្នុងទីណា" ដូច្នេះប៉ុណ្ណោះ ភិក្ខុគប្បីពោលតាមន័យដែលមកហើយ ក្នុងបាលីនុ៎ះឯង ។ ពាក្យដ៏សេសក្នុងសិក្ខាបទនេះងាយយល់ទាំងអស់ ។

សិក្ខាបទនេះ មានសមុដ្ឋាន ៣ កើតឡើងមកកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា ៣ ដូច្នេះឯង ។

ពណ៌នាបរិណតសិក្ខាបទ ចប់

## ចំនួនសិក្ខាបទក្នុងបត្តវគ្គទី៣នោះ គឺ

១, បត្តសិក្ខាបទ — ការទុកអតិរេកបាត្រ

២, ឩនបញ្ចពន្ធនសិក្ខាបទ — ការមានបាត្រដែលមិនទាន់មានចំណងគ្រប់ ៥ អន្លើ

៣, ភេសជ្ជសិក្ខាបទ — ការទុកភេសជ្ជៈបានប្រាំពីរថ្ងៃ

៤, វស្សិកសាដិកសិក្ខាបទ — ការស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង

៥, ចីវរអច្ឆិន្ទនសិក្ខាបទ — ការឱ្យចីវរហើយដណ្តើមយកមកវិញ

៦, សុត្តវិញ្ញត្តិសិក្ខាបទ — ការសូមនូវអំបោះឱ្យជាងត្បាញចីវរ

៧, មហាបេសការសិក្ខាបទ — ការប្រើឱ្យគេត្បាញចីវរ

៨, អច្ចេកចីវរសិក្ខាបទ — ការទទួលអច្ចេកចីវរទុក

៩, សាសង្កសិក្ខាបទ — ការនៅក្នុងព្រៃដែលគេសន្មតថាជាទីមានសេចក្តីរង្កៀស

១០, បរិណតសិក្ខាបទ — ការបង្អោនលាភរបស់សង្ឃ

## ចប់ បត្តវគ្គទី ៣

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## និស្សគ្គិយ៣០

## តតិយភាគ ៣

## ចប់

# សមន្តបាសាទិកា

## អដ្ឋកថា  វិនយបិដក

## មហាវិភង្គ

## សង្ឃាទិសេស១៣  អនិយត២

## និស្សគ្គិយ៣០

## ភាគ  ២_៣

ចប់  ដោយបរិបូណ៌



